មគ្គុទេសន៍ចំពោះការបំរើជាអ្នកផ្សព្វផ្សាយសាសនា

# ប្រកាសដំណឹងល្អរបស់យើង

(សូមមើល គ និង ស 50:14)



“ចូរប្រែចិត្តចុះ ឱអ្នករាល់គ្នានៅចុងផែនដីអើយ ហើយចូរមករកយើង
ហើយទទួលបុណ្យជ្រមុជទឹក ដោយនូវឈ្មោះរបស់យើងចុះ ប្រយោជន៍ឱ្យអ្នករាល់គ្នា
អាចបានញែកចេញបរិសុទ្ធ ដោយការទទួលនូវព្រះវិញ្ញាណបរិសុទ្ធ” (នីហ្វៃទី3 27:20)។

នាម៖

បេសកកម្ម និងកាលបរិច្ឆេទនៃការបំរើ៖

សរសេរអំពីតំបន់៖

ដៃគូ៖

នាម និងអាស័យដ្ឋានរបស់អ្នកដែលបានទទួលបុណ្យជ្រមុជទឹក និងទទួលពិធីបញ្ជាក់៖

# ប្រកាសដំណឹងល្អរបស់យើង (សូមមើល គ និងស 50:14)

បោះពុម្ពដោយ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ
ទីក្រុងសលត៍ លេក រដ្ឋយូថាហ៍

គំរបះ *យ៉ូហាន បាទីស្ទ កំពុងធ្វើបុណ្យជ្រមុជទឹកឱ្យព្រះយេស៊ូវ* © 1988 ដោយ Greg K. Olsen
ចេញពី Mill Pond Press និង Dr. Gerry Hooper ។ ហាមថតចម្លង។

© 2004 ដោយ Intellectual Reserve, Inc.
រក្សាសិទ្ធិគ្រប់យ៉ាង

បោះពុម្ពនៅសហរដ្ឋអាមេរិក
អនុញ្ញាតជាភាសាអង់គ្លេសៈ 1/05
អនុញ្ញាតឱ្យបកប្រែៈ 1/05
ការបកប្រែនៃ *Preach My Gospel*
Cambodian
36617 258

# ប្រកាសដំណឹងល្អរបស់យើង (សូមមើល គ និងស 50:14)


សារលិខិតរបស់គណៈប្រធានទីមួយ . . . . . . . . . . v

បុព្វកថា ៖ តើខ្ញុំអាចប្រើ “*ប្រកាសដំណឹងល្អរបស់យើង*” បានល្អបំផុតដោយរបៀបណា? . . . . . . . . . . vii

1 តើគោលបំណងរបស់ខ្ញុំ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ ជាអ្វី? . . . . . . . . . . 1

2 តើខ្ញុំអាចសិក្សា និងរៀបចំការបង្រៀន ដែលប្រកបដោយប្រសិទ្ធភាពបានយ៉ាងដូចម្ដេច? . . . . . . . . . . 17

3 តើអ្វីដែលខ្ញុំត្រូវសិក្សា និងត្រូវបង្រៀន? . . . . . . . . . . 29

- មេរៀនទី 1៖ សារដំណឹងនៃការស្ដារឡើងវិញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ . . . . . . . . . . 31
- មេរៀនទី2 ៖ ផែនការនៃសេចក្ដីសង្គ្រោះ . . . . . . . . . . 47
- មេរៀនទី 3 ៖ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ . . . . . . . . . . 61
- មេរៀនទី4៖ បទបញ្ញត្តិ . . . . . . . . . . 72
- មេរៀនទី5 ៖ ច្បាប់ និងពិធីការទាំងឡាយ . . . . . . . . . . 83

4 តើខ្ញុំអាចស្គាល់ ហើយយល់អំពីព្រះវិញ្ញាណយ៉ាងដូចម្ដេច? . . . . . . . . . . 91

5 តើតួនាទីរបស់ព្រះគម្ពីរមរមនគឺជាអ្វី? . . . . . . . . . . 105

6 តើខ្ញុំអាចអភិវឌ្ឍន៍លក្ខណៈឱ្យដូចជាព្រះគ្រីស្ទ យ៉ាងដូចម្ដេច? . . . . . . . . . . 117

7 តើខ្ញុំអាចរៀនភាសាក្នុងបេសកកម្មរបស់ខ្ញុំ ឱ្យបានល្អដោយរបៀបណា? . . . . . . . . . . 129

8 តើខ្ញុំត្រូវប្រើពេលវេលា ដោយឆ្លាតវៃដោយរបៀបណា? . . . . . . . . . . 139

9 តើខ្ញុំអាចស្វែងរកមនុស្ស ដើម្បីបង្រៀនដោយរបៀបណា? . . . . . . . . . . 159

10 តើខ្ញុំអាចពង្រីកជំនាញនៃការបង្រៀនរបស់ខ្ញុំបានដោយរបៀបណា? . . . . . . . . . . 179

11 តើខ្ញុំជួយឱ្យមនុស្សធ្វើ និងរក្សាការតាំងចិត្ត យ៉ាងដូចម្ដេច? . . . . . . . . . . 199

12 តើខ្ញុំត្រូវរៀបចំមនុស្ស សំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ដោយរបៀបណា? . . . . . . . . . . 207

13 តើខ្ញុំអាចធ្វើការជាមួយនឹងអ្នកដឹកនាំក្នុងស្ដេក និងវួដបានដោយរបៀបណា? . . . . . . . . . . 217

លិបិក្រម . . . . . . . . . . 229

# សារលិខិតរបស់គណៈប្រធានទីមួយ

*អ្នកផ្សព្វផ្សាយសាសនាជាទីស្រឡាញ់៖*

*យើងសូមសរសើរ ដល់អ្នកទាំងអស់គ្នា នៅក្នុងឱកាសដ៏អស្ចារ្យ ដែលអ្នកបានក្លាយជាអ្នកផ្សព្វផ្សាយសាសនាម្នាក់។ គ្មានកិច្ចការណាមួយ ដែលតម្រូវឱ្យធ្វើ ច្រើនជាងកិច្ចការនេះទេ ហើយក៏គ្មានកិច្ចការណា ដែលអាចនាំមកនូវ សេចក្តីសោមនស្ស ជាងកិច្ចការនេះដែរ។*

*ប្រកាសដំណឹងល្អរបស់យើង មានបំណងជួយអ្នកឱ្យត្រៀមខ្លួនកាន់តែប្រសើរ ក្លាយទៅជាអ្នកផ្សព្វផ្សាយសាសនាដែលកាន់ មានភាពចាស់ទុំខាងផ្នែកវិញ្ញាណ ព្រមទាំងក្លាយជាគ្រូបង្រៀនដ៏ពូកែ។ យើងជំរុញអ្នកឱ្យប្រើសៀវភៅនេះ រាល់ថ្ងៃនៅក្នុង ការរៀបចំផ្ទាល់ខ្លួន និងជាមួយដៃគូ នៅក្នុងការប្រជុំក្នុងមណ្ឌល និងសន្និសីទក្នុងហ្សូន។ ចូរសិក្សាអំពីព្រះគម្ពីរយ៉ាង ហើយរៀនអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ។*

*យើងជំរុញឱ្យអ្នកបង្កើនការតាំងចិត្តរបស់អ្នក ដើម្បីជួយដល់ព្រះវរបិតានៅស្ថានសួគ៌ នៅក្នុងកិច្ចការដ៏រុងរឿងរបស់ទ្រង់។ អ្នកផ្សព្វផ្សាយសាសនាគ្រប់រូប មានតួនាទីសំខាន់មួយដើម្បីជួយនាំមកនូវជីវិតអមតៈ និងជីវិតអស់កល្បរបស់មនុស្ស (សូមមើល ម៉ូសេ 1:39)។*

*ព្រះអម្ចាស់នឹងប្រទានរង្វាន់ និងពរជ័យដ៏មហិមាដល់អ្នក នៅពេលអ្នកបំរើទ្រង់ដោយរាបសារ និងដោយការអធិស្ឋាន។ សុភមង្គលយ៉ាងច្រើនថែមទៀតរង់ចាំអ្នក នៅពេលអ្នកធ្វើការងារក្នុងចំណោមកូនចៅរបស់ទ្រង់។*

*គណៈប្រធានទីមួយ*

កត់ចំណាំ

# បុព្វកថា ៖ តើខ្ញុំអាចប្រើ *ប្រកាសដំណឹងល្អរបស់យើង* បានល្អបំផុតដោយរបៀបណា?

## *ប្រកាសដំណឹងល្អរបស់យើង*




ចូរប្រើ *ប្រកាសដំណឹងល្អរបស់យើង* ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នក ដែលជាអ្នកផ្សព្វផ្សាយសាសនា។ អ្នកអាចចំណាយ ពេលសិក្សាវគ្គទាំងមូល លើកថាកំណ្ឌមួយចំនួន ឬពេញមួយជំពូក។ អ្នកអាចសិក្សាជំពូកទាំងឡាយ តាមលំដាប់លំដោយ ឬធ្វើផែន ការមួយទៀត ដើម្បីបំពេញតាមតំរូវការរបស់អ្នកឱ្យកាន់តែប្រសើរឡើង។ ការបត់បែននេះ អនុញ្ញាតឱ្យអ្នកសិក្សាអំពីអ្វីដែលអ្នក ត្រូវការ និងតាមការដឹកនាំពីប្រធានបេសកកម្ម។

គ្រប់ជំពូកទៅក្នុង *ប្រកាសដំណឹងល្អរបស់យើង* នឹងជួយរៀបចំឱ្យអ្នកសំរេចតាមគោលបំណងរបស់អ្នក នៅក្នុងនាមជាអ្នក ផ្សព្វផ្សាយសាសនាម្នាក់។ ទោះជាយ៉ាងណាក៏ដោយ នៅពេលអ្នកចាប់ផ្តើមសិក្សានៅជំពូកទី3 អ្នកអាចដឹងអំពីវិធីប្លែកៗគ្នា។ ជំពូកភាគច្រើន គឺសំរាប់អ្នក។ ជាទូទៅ ជំពូកទី3 គឺសំរាប់អ្នករៀន។ អ្នកនឹងរៀនគោលលទ្ធិទាំងឡាយ នៅក្នុងជំពូកទី3 (ក) ដើម្បីពង្រឹងចំណេះដឹងខាងដំណឹងល្អ និងទីបន្ទាល់ផ្ទាល់ខ្លួន ហើយ (ខ) ដើម្បីបង្រៀនអ្នកដទៃ និងរៀបចំពួកគេឱ្យធ្វើ និង គោរពតាមការតាំងចិត្ត និងសេចក្តីសញ្ញាទាំងឡាយ។

គោលលទ្ធិនៅក្នុងជំពូកមួយចំនួនទៀត នឹងអាចជួយអ្នក ដើម្បីបង្រៀនសាសនទាគន់ការី និងសមាជិកថ្មីផងដែរ។ ឧទាហរណ៍ ជំពូកទី 4 “តើខ្ញុំអាចដឹង និងយល់ព្រះវិញ្ញាណបានយ៉ាងដូចម្តេច?” អាចជួយអ្នកបង្រៀនដល់សាសនទាគន់ការីមួយចំនួន អំពីរបៀប ដើម្បីទទួលបានទីបន្ទាល់ ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។ ជំពូកទី 5 “តើតួនាទីនៃព្រះគម្ពីរមរមន គឺជាអ្វី?” អាចជួយអ្នក ឱ្យដោះស្រាយកង្វល់របស់សាសនទាគន់ការី អំពីការអានព្រះគម្ពីរមរមន។ គំនិតមកពីជំពូកទី2 “តើខ្ញុំសិក្សា និងរៀបចំដើម្បីបង្រៀនដោយមានប្រសិទ្ធភាពបានយ៉ាងដូចម្តេច?” អាចជួយអ្នកផ្លាស់គំនិតថ្មី ឱ្យទទួលបានការយល់ដឹងច្រើនមកពីការសិក្សាព្រះគម្ពីរមរមនរបស់ពួកគេ។

*ប្រកាសដំណឹងល្អរបស់យើង* ផ្តោតទៅលើគ្រឹះនៃកិច្ចការអ្នកផ្សព្វផ្សាយសាសនា។ ប្រកាសដំណឹងល្អរបស់យើង មិនបានឆ្លើយរាល់សំនួរ ឬស្ថានភាពដែលអ្នកនឹងជួបប្រទះទេ។ នឹងមានប្រសិទ្ធភាពខ្លាំងបំផុត នៅពេលអ្នកធ្វើតាមព្រះវិញ្ញាណ ស្ម័គ្របទគម្ពីរ រក្សាបទបញ្ញត្តិទាំងឡាយ និងអនុវត្តអ្វីៗ ដែលអ្នករៀនមកនោះ។

ចូរសិក្សាជំពូកទាំងឡាយ នៅពេញមួយបេសកកម្មរបស់អ្នក។ អនុវត្តនូវអ្វីដែលអ្នករៀន។ វាយតំលៃកិច្ចការរបស់អ្នក។ អ្នកផ្សព្វផ្សាយសាសនាទាំងឡាយណា ដែលព្យាយាមរៀបចំខ្លួនពួកគេជាប្រចាំ ព្រមទាំងស្វែងរកការរីកចំរើនជាទៀងទាត់ នោះនឹងទទួលបានការដឹកនាំមកពីព្រះវិញ្ញាណបរិសុទ្ធ ហើយមើលឃើញពរជ័យទាំងឡាយនៅក្នុងជីវិតរបស់ពួកគេ។

## មេរៀនអ្នកផ្សព្វផ្សាយសាសនា

អ្នកអាចមានភាពបត់បែន ក្នុងការបង្រៀនមេរៀន តាមរបៀបណាក៏ដោយដែលជួយដល់មនុស្ស ដែលអ្នកបង្រៀនច្រើនបំផុត ដើម្បីរៀបចំពួកគេសំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីការបញ្ជាក់។ គោលបំណងរបស់អ្នក គឺមិនមែនបង្រៀនតាមតែឯកសារប៉ុណ្ណោះទេ គឺដើម្បីជួយដល់អ្នកដទៃឱ្យមកឯព្រះគ្រីស្ទ តាមរយៈជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ការប្រែចិត្ត ពិធីបុណ្យជ្រមុជទឹក ទទួលអំណោយទានព្រះវិញ្ញាណបរិសុទ្ធ និងកាន់ខ្ជាប់ដល់ចុងបំផុត។ មិនជាញឹកញាប់ទេ ដែលមេរៀនមួយ បង្រៀនលើសពី 45 នាទី។ អ្នកអាចនឹងឃើញថា ពេលវេលាដែលហុចឱ្យដើម្បីទៅជួបបង្រៀននឹងមានរយៈពេលមួយខ្លី។ នៅក្នុងករណីនេះ អ្នកអាចចាំបាច់ទៅជួបបង្រៀនឱ្យបានញឹកញាប់ ហើយបង្រៀនខ្លីៗ និយាយអំពីផ្នែកតូចៗនៃឯកសារ។

អ្នកអាចបង្រៀនមេរៀនបានច្រើនរបៀប។ តើអ្នកបង្រៀនមេរៀនណា នៅពេលណាអ្នកបង្រៀន ហើយអ្នកត្រូវចំណាយរយៈពេលប៉ុន្មាន ដើម្បីកំណត់តាមតំរូវការរបស់សាសនទាគន់ការីបានល្អបំផុត ព្រមទាំងមានការដឹកនាំដោយព្រះវិញ្ញាណ។ សូមកុំទន្ទេញចាំមេរៀនទាំងមូលឡើយ។

កត់ចំណាំ

## ការសិក្សាផ្ទាល់ខ្លួន ការសិក្សាជាមួយដៃគូ ការប្រជុំក្នុងមណ្ឌល និងសន្និសីទហ្សូន

ការសិក្សាដែលមានប្រសិទ្ធភាព អំឡុងពេលនៃបេសកកម្មរបស់អ្នក នឹងជួយអ្នកសំរេចគោលបំណងរបស់អ្នកជាអ្នកផ្សព្វផ្សាយសាសនា ហើយពង្រឹងទីបន្ទាល់របស់អ្នកអំពីដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ។ ឱកាសសិក្សាបួន សំខាន់បំផុតរបស់អ្នក គឺការសិក្សាផ្ទាល់ខ្លួន ការសិក្សាជាមួយដៃគូ ការប្រជុំក្នុងមណ្ឌល និងសន្និសីទហ្សូន។ កាលវិភាគប្រចាំថ្ងៃរបស់អ្នក រួមមានទាំងម៉ោងសិក្សាផ្ទាល់ខ្លួន និងសិក្សាជាមួយដៃគូរៀងរាល់ថ្ងៃ។

កាលវិភាគជាប្រចាំរបស់អ្នកផ្សព្វផ្សាយសាសនា *

| | |
|---|---|
| 6:30 ព្រឹក | ក្រោកឡើង អធិស្ឋាន ហាត់ប្រាណ (30 នាទី) ហើយរៀបចំសំរាប់ថ្ងៃនេះ។ |
| 7:30 ព្រឹក | អាហារពេលព្រឹក។ |
| 8:00 ព្រឹក | សិក្សាផ្ទាល់ខ្លួនៈ ព្រះគម្ពីរមរមន បទគម្ពីរផ្សេងៗ គោលលទ្ធិនៃមេរៀនអ្នកផ្សព្វផ្សាយសាសនា និងជំពូកផ្សេងៗ ដែលយកមកពី *ប្រកាសដំណឹងល្អរបស់យើង សៀវភៅក្បួនច្បាប់អ្នកផ្សព្វផ្សាយសាសនា និងមគ្គុទេសន៍សុខភាព អ្នកផ្សព្វផ្សាយសាសនា។* |
| 9:00 ព្រឹក | សិក្សាជាមួយដៃគូៈ ចែកចាយពីអ្វី ដែលអ្នកបានរៀនពេលសិក្សាផ្ទាល់ខ្លួន រៀបចំដើម្បីបង្រៀន អនុវត្តការបង្រៀន សិក្សាជំពូកទាំងឡាយចេញពី *ប្រកាសដំណឹងល្អរបស់យើង* ពិនិត្យមើលផែនការសំរាប់ថ្ងៃនេះ។ |
| 10:00 ព្រឹក | ចាប់ផ្តើមចេញផ្សព្វផ្សាយ។ អ្នកផ្សព្វផ្សាយសាសនាទាំងឡាយ ដែលរៀនភាសា ចូរសិក្សាភាសា នោះ សំរាប់រយៈពេល 30 ទៅ 60 នាទីបន្ថែម បញ្ចូលទាំងផែនការសកម្មភាពរៀនភាសា ដើម្បីប្រើនៅអំឡុងពេលនៃថ្ងៃនេះ។<br><br>អ្នកផ្សព្វផ្សាយសាសនាទាំងឡាយ អាចចំណាយពេលមួយម៉ោងសំរាប់អាហារថ្ងៃត្រង់ និងសិក្សាបន្ថែម ហើយមួយម៉ោងសំរាប់អាហារពេលល្ងាចក្នុងមួយថ្ងៃ ដែលសមរម្យនឹងបំផុតជាមួយម៉ោងផ្សព្វផ្សាយរបស់ពួកគេ។ ជាធម្មតាអាហារពេលល្ងាច មិនឱ្យលើសពីម៉ោង 6:00 ល្ងាចនោះទេ។ |
| 9:00 ល្ងាច | ត្រឡប់មកកន្លែងស្នាក់នៅវិញ (លុះត្រាតែមានការបង្រៀន នោះទើបត្រឡប់មកវិញនៅម៉ោង 9:30 ល្ងាច) ហើយធ្វើផែនការសំរាប់សកម្មភាពនៅថ្ងៃបន្ទាប់ (30 នាទី)។ ចូរសរសេរនៅក្នុងសៀវភៅកំណត់ហេតុ រៀបចំចូលគេង អធិស្ឋាន។ |
| 10:30 ល្ងាច | ចូលគេង។ |

** នៅក្នុងការពិគ្រោះជាមួយនឹងគណៈប្រធាន នៃក្រុមចិតសិបនាក់ ឬគណៈប្រធានតំបន់ ប្រធានបេសកកម្មរបស់អ្នកអាច ផ្លាស់ប្តូរកាលវិភាគនេះ ដើម្បីឱ្យត្រូវគ្នានឹងស្ថានភាពនៅក្នុងតំបន់។*

អ្វីដែលអ្នករៀននៅក្នុងការសិក្សាផ្ទាល់ខ្លួន នឹងជួយអ្នកនៅក្នុងការសិក្សាជាមួយដៃគូ ការប្រជុំក្នុងមណ្ឌល និងការប្រជុំក្នុងហ្សូន នៅកន្លែងដែលអ្នកបង្រៀនដល់គ្នាទៅវិញទៅមកនូវគោលលទ្ធិ នៃនគរ (សូមមើល គ និងស 88:77)។ អ្វី ដែលអ្នកទទួល បានពីវគ្គសិក្សាក្នុងការប្រជុំរបស់អ្នក និងការប្រជុំក្នុងមណ្ឌល នឹងជួយអ្នកបង្រៀនដោយអំណាចខាងវិញ្ញាណ។




### ការសិក្សាផ្ទាល់ខ្លួន

គោលបំណងនៃការសិក្សាផ្ទាល់ខ្លួន គឺដើម្បីពង្រឹង ចំណេះដឹងរបស់អ្នក និងទីបន្ទាល់នៃដំណឹងល្អដែលបានស្តារឡើងវិញ ហើយជួយអ្នកឱ្យរៀបចំ ដើម្បីបំពេញតំរូវការរបស់អ្នកទាំងឡាយ ដែលអ្នកបង្រៀន។ នៅក្នុងការសិក្សាផ្ទាល់ខ្លួន របស់អ្នក ចូរផ្តោតទៅលើព្រះគម្ពីរ និងបណ្ណាល័យអ្នកផ្សព្វផ្សាយសាសនាដែលបានអនុញ្ញាត។

- *Jesus the Christ (ព្រះយេស៊ូវជាព្រះគ្រីស្ទ)*
- *Our Heritage (កេរ្តិ៍មរតករបស់យើង)*
- *Our Search for Happiness (ស្វែងរកសុភមង្គលរបស់យើង)*
- *True to the Faith (នៅពិតចំពោះសេចក្តីជំនឿ)*

កត់ចំណាំ

អ្នកអាចធ្វើឱ្យការសិក្សាផ្ទាល់ខ្លួនមានប្រសិទ្ធភាព នៅពេលអ្នកៈ

- អានព្រះគម្ពីរមរមន និងបទគម្ពីរផ្សេងទៀត។
- សិក្សាគោលលទ្ធិទាំងឡាយ នៃមេរៀនអ្នកផ្សព្វផ្សាយសាសនា។
- សិក្សាជំពូកផ្សេងៗមកពី *ប្រកាសដំណឹងល្អរបស់យើង*។

### ការសិក្សាជាមួយដៃគូ

គោលបំណង នៃការសិក្សាជាមួយដៃគូ គឺ (1) ដើម្បីសាងឱ្យមានការឯកភាព ក្នុងភាពជាដៃគូរបស់អ្នក ដើម្បីបង្រៀនដោយព្រះវិញ្ញាណ និង (2) ផ្ដោតទៅលើការរីកចំរើន នៃអ្នកទាំងឡាយ ដែលអ្នកបង្រៀន។ អ្នកអាចធ្វើឱ្យការសិក្សាជាមួយដៃគូមានប្រសិទ្ធភាព នៅពេលអ្នកៈ

- ចែកចាយការយល់ដឹងជាមួយគ្នាទៅវិញទៅមក មកពីការសិក្សាផ្ទាល់ខ្លួន។
- រៀបចំសំរាប់ការណាត់ជួបបង្រៀនឱ្យជាក់លាក់ សួរសុខទុក្ខសមាជិក ឱកាសស្វែងរកអ្នករៀន និងសកម្មភាពដទៃទៀត ។ សម្ភារៈសិក្សា ដែលជួយអ្នកបង្រៀន ស្វែងរក និងធ្វើការឱ្យកាន់តែមានប្រសិទ្ធភាព។ ចូរពិភាក្សាជាមួយមនុស្សដែលអ្នកកំពុងធ្វើការជាមួយ។ ធ្វើផែនការ ដើម្បីអនុវត្តនូវអ្វី ដែលអ្នកកំពុងរៀន។
- នៅពេញមួយថ្ងៃ ចូរបន្តពិភាក្សាអំពីគោលការណ៍ គោលដៅ ជំនាញ និងផែនការទាំងឡាយ ដែលបានមកពីការសិក្សាជាមួយដៃគូ។

### ការប្រជុំក្នុងមណ្ឌល

គោលបំណងនៃការប្រជុំក្នុងមណ្ឌល គឺដើម្បីបង្រៀនគ្នាទៅវិញទៅមកនូវគោលលទ្ធិនៃនគរ (សូមមើល គ និងស 88ៈ77)។

- ការប្រជុំក្នុងមណ្ឌល ត្រូវធ្វើឡើងរយៈពេល 60 ទៅ 90 នាទីក្នុងសប្ដាហ៍នីមួយៗ។
- អ្នកដឹកនាំមណ្ឌល ធ្វើផែនការ និងដឹកនាំការប្រជុំក្នុងមណ្ឌល ហើយអាចអញ្ជើញអ្នកផ្សព្វផ្សាយសាសនាផ្សេងទៀត ឱ្យជួយបង្រៀន។
- ការប្រជុំក្នុងមណ្ឌលអាចរួមមានដូចខាងក្រោមៈ
  - ការចែកចាយការយល់ដឹងមកពីការសិក្សាផ្ទាល់ខ្លួន និងការសិក្សាជាមួយដៃគូ។
  - ការអនុវត្តមេរៀន នៅក្នុងស្ថានភាពផ្សេងៗដែលអាចកើតឡើង។
  - ការពន្យល់ ការស្រាយបំភ្លឺ និងការអនុវត្តគោលការណ៍ និងជំនាញទាំងឡាយ ត្រូវបានពិពណ៌នាទៅក្នុង *ប្រកាសដំណឹងល្អរបស់យើង*។
  - ការពិភាក្សាអំពីការរីកចំរើន និងតំរូវការទាំងឡាយរបស់សាសនាគន់ការី។
  - ការពិភាក្សា និងការប្រាប់អំពីឧបសគ្គ ទាំងឡាយ នៅក្នុងមណ្ឌល។
  - ការចែកចាយបទពិសោធន៍ និងទីបន្ទាល់ នៃកិច្ចការផ្សព្វផ្សាយសាសនា។
- អ្នកដឹកនាំមណ្ឌល អាចប្រើការប្រជុំក្នុងមណ្ឌល ដើម្បីទទួលរបាយការណ៍ អំពីការខិតខំរបស់អ្នកផ្សព្វផ្សាយសាសនា នៅក្នុងមណ្ឌល។ ពួកគេមិនគួរដាក់គោលដៅ ឬចែកចាយដល់អ្នកផ្សព្វផ្សាយសាសនាដទៃទៀតទេ។

### សន្និសីទហ្សូន

សន្និសីទហ្សូន គឺធ្វើឡើងក្រោមការដឹកនាំរបស់ប្រធានបេសកកម្ម។

## លក្ខណៈនៃ *ប្រកាសដំណឹងល្អរបស់យើង*

ជំពូកនីមួយៗនៅក្នុង *ប្រកាសដំណឹងល្អរបស់យើង* មានលក្ខណៈពិសេសមួយចំនួន។ លក្ខណៈទាំងនេះ គួរតែជួយដល់អ្នកឱ្យទទួលបានច្រើនទៀត ចេញពីការសិក្សាផ្ទាល់ខ្លួន—មិនបង្ខំអ្នកឱ្យរៀនតាមរបៀបមួយជាក់លាក់ទេ។ ចូរប្រើលក្ខណៈទាំងនេះនៅក្នុងរបៀបមួយដែលអាចបត់បែនបាន អាស្រ័យទៅលើតំរូវការរបស់អ្នក។

កត់ចំណាំ

### ការសិក្សាផ្ទាល់ខ្លួន

*ប្រកាសដំណឹងល្អរបស់យើង* ជារឿយៗសួរថា តើអ្នកប្រើសៀវភៅកំណត់ហេតុក្នុងការសិក្សា ដើម្បីជួយអ្នកឱ្យយល់ បញ្ជាក់ និងចងចាំនូវអ្វី ដែលអ្នកកំពុងរៀនដែរឬទេ។ អែលឌើរ រីឆាត ជី. ស្កត បានបង្រៀនថា “ចេះដឹង ត្រូវបានកត់ត្រាប្រុងប្រយ័ត ទុកជាចំណេះដឹង ដែលអាចរកបាននៅពេលត្រូវការ។ ពត៌មានដែលដឹងដោយខាងវិញ្ញាណ គួរតែរក្សាទុកនៅក្នុងកន្លែងពិសិដ្ឋមួយ ដែលអាចទាក់ទងនឹងព្រះអម្ចាស់ ពីរបៀបដែលអ្នករក្សាវាទុក។ ការអនុវត្តនេះ ពង្រីកភាពដែលសមគួរ នៃការទទួល ពន្លឺបន្ថែមទៀតរបស់អ្នក” (“Acquiring Spiritual Knowledge,” *Ensign*, ខែវិច្ឆិកា ឆ្នាំ 1993, 86)។ ចូររំលឹកអំពីសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក ដើម្បីចាំបទពិសោធន៍ខាងព្រះវិញ្ញាណ មើលឃើញការយល់ដឹងថ្មី និងនឹកឃើញពីការរីកចំរើនរបស់អ្នក។

សៀវភៅកំណត់ហេតុក្នុងការសិក្សារបស់អ្នក អាចចងក្រងជាសៀវភៅកំណត់ហេតុ សៀវភៅកត់ចំណាំ ឬសៀវភៅចងក្រងមួយ។ ចូរកត់ត្រា និងសំគាល់អំពីគំនិតរបស់អ្នក និងអារម្មណ៍នៅក្នុងរបៀបមួយ ដែលសមគ្នានឹងរបៀបដែលអ្នករៀន។ ពង្រីករបៀបផ្ទាល់ខ្លួនរបស់អ្នក ដើម្បីងាយស្រួលរកពត៌មានគន្លឹះ នៅពេលអនាគត។ ប្រើសៀវភៅនេះឱ្យបានញឹកញាប់ ដើម្បីរំលឹក រកមើល និងអនុវត្តអ្វី ដែលអ្នកបានរៀន។ ប្រើសៀវភៅកំណត់ហេតុក្នុងការសិក្សា របស់អ្នក ដើម្បីកត់ចំណាំ និងកត់ត្រានូវអារម្មណ៍ អំឡុងពេលការសិក្សាផ្ទាស់ខ្លួន និងការសិក្សាជាមួយដៃគូរបស់អ្នក ការប្រជុំក្នុងមណ្ឌល សន្និសីទក្នុងហ្សូន និងការសម្ភាសន៍ជាមួយប្រធានបេសកកម្ម។

### ប្រអប់ពត៌មាន

ប្រអប់នៅក្នុង *ប្រកាសដំណឹងល្អរបស់យើង* នឹងជួយអ្នកឱ្យរៀន។ ប្រអប់ខ្លះៗ បង្ហាញជាមុន ឬសង្ខេបចំណុចសំខាន់ៗ។ ប្រអប់ដទៃទៀតជួយអ្នកឱ្យផ្តោតលើការសិក្សារបស់អ្នក រៀនពីបទគម្ពីរ អនុវត្តអំពីដែលអ្នករៀន ពង្រីកសមត្ថភាពរបស់អ្នក និងបំពេញសេចក្តីត្រូវការរបស់អ្នកទាំងឡាយ ដែលអ្នកបង្រៀន។ នៅក្នុងករណីភាគច្រើន ប្រអប់ទាំងនេះ គឺដោយសាមញ្ញជាចំណុចចាប់ផ្តើមមួយ។ អធិស្ឋាន ដើម្បីសាងនៅលើសកម្មភាពនៅក្នុងប្រអប់ ដោយការអភិវឌ្ឍន៍សកម្មភាពសិក្សាថ្មី និងការស្រាវជ្រាវបទគម្ពីរបន្ថែម។

---

**ចូរពិចារណាចំណុចនេះ**

- តើពាក្យ “ស្វែងរកពួកគេដែ
- តើខ្ញុំអាចពង្រីកសេចក្តីជំនឿ
- តើហេតុអ្វីខ្ញុំត្រូវទំនាក់ទំនង

**“ចូរពិចារណាអំពីការណ៍នេះ។”** ក្នុងជំពូកភាគច្រើន ចាប់ផ្តើមជាមួយនឹងសំនួរ នៅក្នុងប្រអប់ “ចូរពិចារណាអំពីការណ៍នេះ”។ សំនួរ ទាំងឡាយ គឺផ្តោតទៅលើចំណុចគន្លឹះ នៃជំពូក ហើយផ្តល់ជាយោបល់គោល សំរាប់ការសិក្សារបស់អ្នក។ ចូរប្រើសំនួរទាំងនេះ ដើម្បីរៀបចំយល់ដឹង ពិចារណា និងអនុវត្តអ្វី ដែលអ្នករៀន។

---

**ចូរចងចាំចំណុចនេះ**

- ស្តាបនាសាសនាចក្រឡើង
- ស្វែងរក និងធ្វើតាមព្រះវិញ
- មនុស្សនៅក្នុងតំបន់របស់អ្ន

**“ចូរចងចាំការណ៍នេះ។”** ក្នុងជំពូកភាគច្រើនបញ្ចប់ជាមួយនឹងប្រអប់ “ចូរចងចាំការណ៍នេះ”—ជាការសង្ខេបនៃចំណុចសំខាន់ៗ បំផុតមួយមកពីជំពូក។ នៅពេលអ្នកបញ្ចប់ការសិក្សាជំពូកមួយ ចូររំលឹកប្រសាសន៍ទាំងនេះ ដើម្បីឱ្យប្រាកដថា អ្នកយល់គោលការណ៍សំខាន់ៗទាំងនេះ។ ចូរធ្វើការវាយតំលៃ ថាតើអ្នកបានអនុវត្តចំណុចទាំងនេះ ហើយធ្វើផែនការ ដើម្បីអនុវត្តនូវអ្វី ដែលអ្នកបានរៀនបានល្អយ៉ាងណា។

---

**ការសិក្សាព្រះគម្ពីរ**

**តើខគម្ពីរទាំងនេះ ប្រាប់អ្វីខ្លះអំ**

នីហ្វៃទី 3 12៖48

នីហ្វៃទី 3 27៖21, 27

**“ការសិក្សាព្រះគម្ពីរ។”** ប្រអប់ទាំងនេះ ណែនាំអ្នកអំពីសេចក្តីយោង ដែលអាចស្ថាបនាការយល់ដឹង និងទីបន្ទាល់របស់អ្នក។ ស្ថាបនានៅលើសេចក្តីយោងទាំងនេះ ដោយការស្ទង់បទគម្ពីរបន្ថែម។ ចូរសួរខ្លួនឯងនូវសំនួរទាក់ទងបន្ថែម ដែលនឹងជួយអ្នកឱ្យ ទទួលបានការយល់ដឹង ហើយអនុវត្តនូវអ្វីដែលអ្នករៀន។




**"សកម្មភាព"** ក្នុងជំពូកភាគច្រើន មានសកម្មភាពសំរាប់ការសិក្សាផ្ទាល់ខ្លួន និងជាមួយដៃគូ ដើម្បីពង្រីកការរៀន និងការអនុវត្តរបស់អ្នក។ ចូរធ្វើសកម្មភាពទាំងនេះដដែលៗ នៅពេញមួយបេសកកម្មរបស់អ្នក។ អ្នកនឹងទទួលបានការយល់ដឹងថ្មី រាល់ពេលដែលអ្នកធ្វើ ពីព្រោះជាសេចក្ដីត្រូវការរបស់អ្នក—និងជាសេចក្ដីត្រូវការ នៃអ្នកទាំងឡាយ ដែលអ្នកកំពុងបង្រៀន—នឹងមានការផ្លាស់ប្ដូរ។




**ប្រអប់ក្រហម។** ប្រអប់ទាំងនេះមានពត៌មាន និងយោបល់សំខាន់ សំរាប់ការបង្រៀន និងស្ថានភាពនៃការផ្សព្វផ្សាយជាច្រើន។

## រឿង

គ្រប់រឿងនៅក្នុង *ប្រកាសដំណឹងល្អរបស់យើង* គឺជាការពិត ទោះបីជាឈ្មោះរបស់មនុស្សទាំងនោះភាគច្រើនត្រូវបានផ្លាស់ប្ដូរក៏ដោយ។ រឿងនីមួយៗបង្ហាញអំពីគោលការណ៍ច្រើន ដែលទាក់ទងជាមួយនឹងកិច្ចការផ្សព្វផ្សាយសាសនា។ នៅពេលអ្នកអានរឿងទាំងនេះ ចូររកមើលគោលការណ៍ទាំងឡាយ ដែលពួកគេបង្ហាញ។

### គំនិតសំរាប់ការសិក្សា និងការអនុវត្ត

ជំពូកនីមួយៗបញ្ចប់ជាមួយនឹងគំនិតបន្ថែម សំរាប់ការសិក្សាផ្ទាល់ខ្លួន ការសិក្សាជាដៃគូ ការប្រជុំក្នុងមណ្ឌល និងសន្និសីទក្នុងហ្សូន។ ប្រភពនៃសកម្មភាពការរៀនសូត្រដ៏សំបូរណ៍នេះ ត្រូវបានផ្ដល់ឧទាហរណ៍នៃមធ្យោបាយដែលមាន ប្រសិទ្ធភាព ដើម្បីរៀនមេរៀន។ ចូរមានការឆ្នៃប្រឌិត ហើយស្វែងរកការបំផុសគំនិត ដើម្បីបង្កើតសកម្មភាពមេរៀនបន្ថែម នៅរាល់ពេលដែលអ្នកសិក្សា ឬបង្រៀនវគ្គមួយ នៃវគ្គទាំងនេះ។ ចូរបំពេញសកម្មភាពទាំងនេះឱ្យបានច្រើនផង អំឡុងពេល បេសកកម្មរបស់អ្នក។




## អ្នកផ្សព្វផ្សាយសាសនាកំពុងបំរើនៅក្នុងសាខា និងមណ្ឌល

អ្នកផ្សព្វផ្សាយសាសនាជាច្រើន បំរើនៅក្នុងសាខា និងមណ្ឌល។ ទោះបីជាសៀវភៅសិក្សានេះ សំដៅទៅលើ*វួដ* និង *ស្តេក* នូវគោលការណ៍ និងការជួបបង្រៀន ដែលអនុវត្តចំពោះ*សាខា* និង*មណ្ឌល*។ ប្រធានបេសកកម្មនឹងណែនាំអ្នកអំពីការកែប្រែអ្វីមួយ ដើម្បីធ្វើ នៅពេលធ្វើការជាមួយនឹងអ្នកដឹកនាំក្នុងសាខា ឬមណ្ឌល។

## ការប្រើដោយអ្នកផ្សព្វផ្សាយសាសនានៅវួដ និងអ្នកដឹកនាំ

*ប្រកាសដំណឹងល្អរបស់យើង* គឺសំរាប់អ្នកផ្សព្វផ្សាយសាសនាពេញម៉ោង នៃសាសនាចក្រ។ ទោះជាយ៉ាងណាក៏ដោយ គោលការណ៍ និងគោលលទ្ធិ ដែលបានបង្រៀននៅក្នុងនេះ គឺអាចអនុញ្ញាតបានចំពោះអ្នកផ្សព្វផ្សាយសាសនានៅក្នុងវួដ និងអ្នកដឹកនាំផងដែរ នៅពេលពួកគេស្វែងរក ដើម្បីស្ថាបនានគរព្រះអម្ចាស់។ ការសិក្សាជាញឹកញាប់នៅក្នុងសៀវភៅសិក្សានេះ នឹងអាចធ្វើឱ្យពួក គេបំពេញតាមកាតព្វកិច្ចរបស់ពួកគេ ក្នុងនាមជាសមាជិកអ្នកផ្សព្វផ្សាយសាសនា ហើយនឹងផ្ដល់ការសហការគ្នាជាមួយអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង។

កត់ចំណាំ

កត់ចំណាំ



*ដាន ជូនស៍ ជាអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យម្នាក់ ក្នុងចំណោមអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យ នៅក្នុងសម័យកាន់កាប់គ្រួត គ្រានេះ ផ្សព្វផ្សាយសាសនានៅវែល។*

# តើអ្វីទៅដែលជាគោលបំណងរបស់ខ្ញុំ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាមួយរូប?

កំណត់ចំណាំ

## គោលបំណងរបស់អ្នក

អញ្ជើញមនុស្សដទៃ មកកាន់ព្រះគ្រីស្ទដោយការជួយពួកគេ ឱ្យទទួលដំណឹងល្អដែលបានស្តារឡើងវិញ តាមរយៈសេចក្តីជំនឿ នៅលើ ព្រះគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ការកែប្រែចិត្ត ពិធីបុណ្យជ្រមុជទឹក ការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ និងកាន់ភ្ជាប់ដរាបដល់ចុងបំផុត។

## ចូរពិចារណាការណ៍នេះ

- តើអ្វីទៅដែលជាគោលបំណងរបស់ខ្ញុំ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាមួយរូប?
- តើដំណឹងល្អជាអ្វី?
- តើហេតុអ្វីបានជាយើងត្រូវប្រកាសដំណឹងល្អ?
- តើហេតុអ្វីបានជាខ្ញុំត្រូវតែបង្រៀនដោយអំណាច និងដោយសិទ្ធិអំណាច?
- តើសារដំណឹងនៃការស្តារឡើងវិញនោះជាអ្វី? តើហេតុអ្វីបានជាវាមានសារៈសំខាន់?
- តើអ្វីទៅដែលជាការទទួលខុសត្រូវរបស់ខ្ញុំ នៅក្នុងការជួយអ្នកដទៃឱ្យផ្លាស់ប្តូរសាសនា?
- តើខ្ញុំដឹងដោយរបៀបណាថា ខ្ញុំជាអ្នកផ្សព្វផ្សាយសាសនាដែលប្រកបដោយជោគជ័យ?

## បេសកកម្មរបស់អ្នក បង្រៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដែលបានស្តារឡើងវិញ

អ្នកត្រូវបានពទ្ធ័ជុំវិញ ដោយមនុស្ស។ អ្នកធ្វើដំណើរឆ្លងកាត់ពួកគេនៅលើផ្លូវ សួរសុខទុក្ខពួកគេនៅក្នុងផ្ទះពួកគេ ហើយធ្វើដំណើរនៅក្នុងចំណោមពួកគេ។ ពួកគេទាំងអស់គ្នាជាកូនរបស់ព្រះ ជាបងប្អូនប្រុស និងបងប្អូនស្រីរបស់អ្នក។ ព្រះស្រឡាញ់ ពួកគេ ដូចជាទ្រង់ស្រឡាញ់អ្នកផងដែរ។ មនុស្សជាច្រើននៃមនុស្សទាំងនេះ កំពុងតែស្រាវជ្រាវរកពីគោលបំណងក្នុងជីវិត។ ពួកគេបារម្ភចំពោះ ក្រុមគ្រួសារពួកគេ។ ពួកគេត្រូវការញាណនៃកម្មសិទ្ធិ ដែលមកពីចំណេះដឹងមួយដែលថា ពួកគេជាកូន របស់ព្រះ ជាសមាជិកនៃ គ្រួសារដ៏អស់កល្បជានិច្ចរបស់ទ្រង់។ ពួកគេចង់មានអារម្មណ៍សុវត្ថិភាពនៅក្នុង លោកីយ៍ដែលតែងតែមានការផ្លាស់ប្តូរជានិច្ច។ ពួកគេចង់បាន "សេចក្តីសុខសាន្ត នៅនាលោកីយ៍នេះ និងជីវិតដ៏នៅអស់កល្បជានិច្ច នៅបរលោកនាយ" (គ និង ស 59៖23) ប៉ុន្តែពួកគេ "លាក់ពីសេចក្តីពិត ពីព្រោះពួកគេមិនដឹងទៅរកសេចក្តីពិតឯណាទេ" (គ និង ស 123៖12)។

© 1993 Clark Kelley Price ។ ហាមថតចំលង

កំណត់ចំណាំ

ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ដោយសារការស្ដារឡើងវិញតាមរយៈ យ៉ូសែប ស្ម៊ីធ នោះនឹងប្រទានពរជ័យដល់ក្រុមគ្រួសារ បំពេញសេចក្ដីត្រូវការខាងវិញ្ញាណ ហើយជួយពួកគេឱ្យបំពេញតាមបំណងប្រាថ្នាដ៏ជ្រៅបំផុតរបស់ពួកគេ។ សូម្បីតែពួកគេ ប្រហែលជាមិនដឹងថា មកពីមូលហេតុអ្វី ប៉ុន្តែពួកគេត្រូវការ ការស្រាកស្រាន្តចេញពីអារម្មណ៍ថាមានកំហុស ដែលមកពីការធ្វើខុស និងអំពើបាប។ ពួកគេត្រូវការមានបទពិសោធន៍ អំពីសេចក្ដីអំណរនៃសេចក្ដីប្រោសលោះ ដោយទទួលនូវការអភ័យបាប ពីអំពើ បាបរបស់ពួកគេ ហើយសប្បាយរីករាយនឹងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។



ដោយមានសិទ្ធិអំណាច ធ្វើជាអ្នកតំណាងព្រះយេស៊ូវគ្រីស្ទ អ្នកអាចបង្រៀនមនុស្សដោយអំណាច និងសិទ្ធិអំណាចដែល “សេចក្ដីប្រោសលោះនឹងមកដោយ និងតាមរយៈព្រះមែស៊ីដ៏បរិសុទ្ធ” ហើយគ្មានរូបកាយណា“អាចរស់នៅក្នុងវត្តមាននៃព្រះបានឡើយ លើកលែងតែដោយបុណ្យគុណ និងសេចក្ដីមេត្តាករុណា និងព្រះគុណនៃព្រះមែស៊ីដ៏បរិសុទ្ធ” (នីហ្វៃទី2 2:6,8)។ នៅពេលដែលមនុស្សមកដើម្បីទទួលយក ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ហើយទទួលពិធីការនៃពិធីបុណ្យ ជ្រមុជទឹក និងពិធីបញ្ជាក់ដោយសិទ្ធិអំណាចបព្វជិតភាព ពួកគេនឹងបានប្រាកដថាពួកគេ “គេនឹងមិនត្រូវបោះបង់ចោលរហូត ឡើយ” (ព្រះគម្ពីរមរមន ទំព័រចំណងជើង)។

នៅពេលដែលការយល់ដឹងរបស់អ្នកអំពី ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទរីកចំរើននោះ បំណងប្រាថ្នារបស់អ្នកដើម្បីចែកចាយដំណឹងល្អ នឹងរីកចំរើនដែរ។ អ្នកនឹងមានអារម្មណ៍ ដូចជាលីហៃបានមាន ដែលថា “ជាការសំខាន់បំផុត ដើម្បីធ្វើឱ្យប្រជាជនទាំងឡាយនៅលើផែនដីបានដឹង” (នីហ្វៃទី2 2:8)។

ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសិន បានបង្រៀនថាៈ “យើងត្រូវបានបញ្ជាដោយព្រះ ដើម្បីនាំយកដំណឹងល្អនេះ ទៅកាន់ពិភពលោកទាំងមូល។ នេះហើយជាមូលហេតុដែលយើងត្រូវតែរួមសាមគ្គីគ្នា នាពេលបច្ចុប្បន្ននេះ។ មានតែដំណឹងល្អទេ ដែលអាចសង្គ្រោះពិភពលោកពីទុក្ខលំបាកនៃការបំផ្លិចបំផ្លាញបាន។ មានតែដំណឹងល្អទេ ដែលនឹងបង្រួបបង្រួម មនុស្សគ្រប់ជាតិ សាសន៍ទាំងអស់ ឱ្យមានសន្តិភាព។ មានតែដំណឹងល្អទេ ដែលនឹងនាំយកមកនូវ សេចក្ដីអំណរ សុភមង្គល និងសេចក្ដីសង្គ្រោះ ដល់គ្រួសារមនុស្សជាតិ។ *(The Teaching of Ezra Taft Benson* [1988], 167)។

អ្នកត្រូវបានហៅ ដើម្បីធ្វើជាតំណាងព្រះយេស៊ូវគ្រីស្ទ នៅក្នុងការជួយមនុស្សឱ្យបានជ្រះស្អាតពី អំពើបាបរបស់ពួកគេ។ អ្នកធ្វើ ដូច្នេះ ដោយការអញ្ជើញពួកគេឱ្យមកឯព្រះគ្រីស្ទ ហើយផ្លាស់គំនិតមករកដំណឹងល្អរបស់ទ្រង់ដែលបានស្ដារឡើងវិញ។ ដើម្បីមក ឯព្រះអង្គសង្គ្រោះ ពួកគេត្រូវតែមានសេចក្ដីជំនឿ ការប្រែចិត្ត— ធ្វើការផ្លាស់ប្ដូរដែលចាំបាច់ ដើម្បីនាំជីវិតពួកគេ បានស្រប ជាមួយនឹង ការបង្រៀនរបស់ទ្រង់។ អ្នកអាចជួយមនុស្សអភិវឌ្ឍន៍ សេចក្ដីជំនឿដូចនោះ ដោយការបង្រៀនពួកគេ អំពីការស្ដារ ឡើងវិញនៃដំណឹងល្អ តាមរយៈព្រះវិញ្ញាណ ហើយអញ្ជើញពួកគេឱ្យតាំងចិត្តរស់នៅតាមការបង្រៀននោះ។ ការរក្សាការតាំងចិត្ត នេះ រៀបចំពួកគេសំរាប់សេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ហើយនឹងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដ៏វិសេសវិសាល។ ការណ៍ទាំងអស់នោះ គឺដើម្បីប្រែចេញពី ភាពជា “សាច់ឈាម” ហើយក្លាយទៅជាពួកបរិសុទ្ធ“ ដោយសារ ដង្វាយធួនរបស់ព្រះគ្រីស្ទ ដ៏ជាព្រះ” (ម៉ូសាយ 3:19)។

## សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន ឬការសិក្សាជាមួយដៃគូ

ចូរធ្វើការពិនិត្យពិច័យ អំពីរូបភាពដើមឈើជីវិត ដែលមាននៅលើទំព័រនេះ នៅពេលដែលអ្នកសិក្សាអំពី ការនិមិត្ត នៃដើមឈើជីវិត ដែលមាននៅក្នុង នីហ្វៃទី1 8 និង 11។ នៅក្នុងការនិមិត្តនេះ ដើមឈើជីវិតតំណាងឱ្យ សេចក្ដីស្រឡាញ់របស់ព្រះ (សូមមើល នីហ្វៃទី1 11:21–22)។

- តើលីហៃមានបំណងអ្វី បន្ទាប់ពីគាត់បានបរិភោគផ្លែឈើនោះហើយ? (សូមមើល នីហ្វៃទី1 8:10–18)។
- នៅក្នុងការនិមិត្តនោះ តើប្រជាជនត្រូវការធ្វើអ្វី ដើម្បីពួកគេអាចបរិភោគផ្លែឈើនោះបាន? តើយើងត្រូវធ្វើអ្វី ដើម្បីទទួលបានពរជ័យនៃដង្វាយធួនទាំងអស់នោះ? តើការតាំងចិត្ត និងសេចក្ដីសញ្ញា ជួយយើងឱ្យទទួលបានពរជ័យទាំងនេះ តាមរបៀបណា?
- ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ តើអ្វីទៅដែលជាករណីយកិច្ចរបស់អ្នក ក្នុងការជួយអ្នកដទៃ ស្វែងរកនិងទទួលទានផ្លែឈើនៃដំណឹងល្អបាន?

កំណត់ចំណាំ

## ដំណឹងល្អប្រទានពរដល់ក្រុមគ្រួសារ

សារដំណឹងអំពី ការស្ដារឡើងវិញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ប្រទានពរដល់ក្រុមគ្រួសារ។ ពីព្រោះតែការស្ដារឡើងវិញ ធ្វើឱ្យយើងយល់អំពីគោលបំណងព្រះ សំរាប់ក្រុមគ្រួសារៈ “ផែនការនៃសុភមង្គលរបស់ព្រះ ធ្វើឱ្យទំនាក់ទំនងជាគ្រួសារចេះតែ បន្តរហូតហួសពីសេចក្ដីស្លាប់។ ពិធីបរិសុទ្ធ និងសេចក្ដីសញ្ញាដ៏ពិសិដ្ឋទាំងប៉ុន្មាន ដែលមាននៅក្នុងព្រះវិហារបរិសុទ្ធ ធ្វើឱ្យបុគ្គល នីមួយៗ អាចវិលត្រឡប់មកវត្តមាននៃព្រះវិញ ហើយធ្វើឱ្យគ្រួសារបានរួបរួមជួបជុំគ្នា នៅអស់កល្បជានិច្ច។ (ក្រុមគ្រួសារៈ ការប្រកាសដល់ពិភពលោក” *Ensign*, ខែវិច្ឆិកា ឆ្នាំ1995, 102)។

> *“កិច្ចការព្រះអម្ចាស់ដ៏សំខាន់ជាងគេបំផុត ដែលអ្នកនឹងធ្វើ នោះនឹងនៅក្នុងជញ្ជាំង នៃគេហដ្ឋានផ្ទាល់របស់អ្នក។”*
>
> —ប្រធាន ហារ៉ូល ប៊ី. លី
> *THE TEACHING OF HAROLD B. LEE*
> ជ្រើសរើសដោយ CLYDE J. WILLIAM (1996), 280

នៅលើផែនដី ទំនាក់ទំនងក្នុងគ្រួសារអាចជា ប្រភពខ្លះនៃភាពសប្បាយរីករាយដ៏អស្ចារ្យ។ សាតាំងកំពុងតែវាយប្រហារ ចំពោះ ក្រុមគ្រួសារ ដោយគ្រប់វិធី ហើយមានក្រុមគ្រួសារជាច្រើន កំពុងតែមានការបែកបាក់គ្នា ដោយសារតែការខិតខំប្រឹងប្រែង របស់វានោះ។ សារដំណឹង អំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ នឹងផ្ដល់អត្ថិភាព ឱ្យក្រុមគ្រួសារ ដើម្បីពួកគេ អាចបានរួបរួមគ្នាសំរាប់ពេលនេះ និងអស់កល្បជានិច្ច។ ដោយការរស់នៅតាមគោលការណ៍នៃដំណឹងល្អ ក្រុមគ្រួសារនឹងជួបនូវ សន្តិភាព សេចក្ដីអំណរ និងញាណដែលទាក់ទង ហើយមានគោលដៅនៅក្នុងជីវិតនេះ។ តាមរយៈពន្លឺនៃដំណឹងល្អ ក្រុមគ្រួសារ អាចរកដំណោះស្រាយ អំពីការភាន់ច្រឡំ ការឈ្លោះទាស់ទែង និងឧបសគ្គនានា។ គ្រួសារដែលបាក់បែកមកពីការខ្វែងគំនិតគ្នា អាចនឹងផ្សះផ្សាបាន តាមរយៈការប្រែចិត្ត ការអភ័យទោស និងសេចក្ដីជំនឿនៅក្នុងអំណាចនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ។ “សុភមង្គលនៅក្នុង ជីវិតនៃគ្រួសារ អាចសំរេចបានបំផុត នៅពេលធ្វើតាមការបង្រៀននៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ គ្រួសារ និង អាពាហ៍ពិពាហ៍ដែលមានជោគជ័យ សុភមង្គល គឺបានស្ថាបនា និងរក្សាដោយគោលការណ៍ នៃសេចក្ដីជំនឿ ការអធិស្ឋាន ការប្រែចិត្ត ការអភ័យទោស ការគោរព សេចក្ដីស្រលាញ់គ្នា សេចក្ដីមេត្តាករុណា ការងារ និងកម្មវិធីកំសាន្តល្អៗទាំងឡាយ។” (*Ensign*, ខែវិច្ឆិកា ឆ្នាំ 1995, 102)។

ចូរព្យាយាមស្វែងរក និងបង្រៀនក្រុមគ្រួសារ— ឪពុក ម្ដាយនិងកូនៗ— ដែលពួកគេអាចជួយគ្នាទៅវិញទៅមក នៅក្នុងការ រស់នៅតាមដំណឹងល្អ ហើយនៅទីបំផុតពួកគេត្រូវបានផ្សាភ្ជាប់ជាក្រុមគ្រួសារ ដោយសារសិទ្ធិអំណាចបព្វជិតភាពដែលបានស្ដារ ឡើងវិញ។

## ការបង្រៀនដោយព្រះវិញ្ញាណ

ពីព្រោះតែដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ “ព្រះចេស្ដានៃព្រះ នឹងជួយសង្គ្រោះ ដល់អ្នកណាដែលជឿ” (រ៉ូម 1:16) សារដំណឹងស្ដីអំពីការស្ដារឡើងវិញនៃដំណឹងល្អ ត្រូវតែបង្រៀនដោយព្រះចេស្ដាដ៏ទេវភាព—ព្រះដេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ដែលជាអង្គទីបីនៃក្រុមព្រះ។ ជាញឹកញាប់ទ្រង់តែងតែត្រូវបានហៅថា ជាព្រះវិញ្ញាណ ហើយកិច្ចការ មួយក្នុងចំណោមកិច្ចការរបស់ទ្រង់នោះគឺដើម្បីបង្រៀន និងថ្លែងអំពីសេចក្ដីពិត។ នៅពេលដែលអ្នកបង្រៀន ដោយព្រះចេស្ដាព្រះវិញ្ញាណបរិសុទ្ធនឹងៈ

- បង្រៀនអ្នកអំពីការពិតថ្មី និងរំឮកពីគ្រប់ទាំងសេចក្ដីដែលអ្នកបានរៀន (សូមមើល យ៉ូហាន 14:26)។
- សេចក្ដីដែលត្រូវនិយាយ នឹងបានប្រទានដល់អ្នករាល់គ្នានៅចំម៉ោងនោះឯង (សូមមើល គ និង ស 84:85)។
- នាំយកសារដំណឹងចូលទៅក្នុងចិត្ត នៃកូនចៅមនុស្ស ដែលអ្នកបង្រៀន (សូមមើល នីហ្វៃ 33:1)។
- ថ្លែងទីបន្ទាល់នៃការពិតអំពីសារដំណឹងរបស់អ្នក ហើយនឹងជាសាក្សីដល់ពាក្យសំដីរបស់អ្នក (សូមមើល គ និង ស 100:5–8)។
- ជួយអ្នកដឹងអំពីសេចក្ដីត្រូវការរបស់មនុស្ស ដែលអ្នកកំពុងបង្រៀន (សូមមើល អាលម៉ា 12:7)។

ព្រះវិញ្ញាណ មានសារៈសំខាន់ណាស់នៅក្នុងការបង្រៀន សេចក្ដីពិតនៃដំណឹងល្អ នៅក្នុងវិធីមួយដែលនឹងស្ថាបនាសេចក្ដីជំនឿរបស់អ្នកដទៃ។ នៅពេលដែលអ្នកខិតខំប្រឹងប្រែង អភិវឌ្ឍន៍សេចក្ដីជំនឿ ដើម្បីពឹងផ្អែកទៅលើព្រះវិញ្ញាណ អ្នកគួរតែៈ

- អធិស្ឋានដើម្បីមានព្រះវិញ្ញាណ (សូមមើល គ និង ស 42:14)។
- ជំរះចិត្តអ្នកឱ្យបានបរិសុទ្ធ (សូមមើល គ និង ស 112:28)។
- រក្សាបទបញ្ញត្តិទាំងឡាយ (សូមមើល គ និង ស 20:77, 79)។
- ចូរខិតខំព្យាយាម ដើម្បីឱ្យបានព្រះបន្ទូលព្រះ (សូមមើល គ និង ស 11:21, 84:85)។

កំណត់ចំណាំ

- បង្រៀន ដើម្បីឱ្យអ្នកដទៃបានយល់ដឹងអំពីសារដំណឹងរបស់អ្នក ហើយនឹងត្រូវបានស្អាងឡើង (សូមមើល គ និង ស 50:13–22)។
- អនុវត្តសេចក្ដីជំនឿ (សូមមើល ម៉ូរ៉ូណៃ 10:7)។

អ្នកត្រូវបានតែងតាំងសំរាប់ការហៅបំរើដ៏ពិសិដ្ឋរបស់អ្នក ជាមួយនឹងសេចក្ដីសន្យាថា ព្រះវិញ្ញាណនឹងត្រូវប្រទានដល់អ្នក នៅពេលជួប នឹងសេចក្ដីត្រូវការ ដែលបានរៀបចំពីព្រះអម្ចាស់។ ចូរទាញយកអត្ថប្រយោជន៍ពីអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដែលនោះគួរតែជា បំណងប្រាថ្នាដ៏ពិតប្រាកដរបស់អ្នក។

## អំណាច និងសិទ្ធិអំណាចនៃការហៅឱ្យបំរើរបស់អ្នក

អ្នកផ្សព្វផ្សាយសាសនាត្រូវទៅ "ដោយអំណាចនៃការតែងតាំងដែល [គាត់ ]ត្រូវបានតែងតាំងនោះ ដោយការប្រកាសប្រាប់ពីដំណឹងដ៏រីករាយនៃសេចក្ដីអំណរដ៏ធំ គឺជាដំណឹងល្អដ៏អស់កល្បអស់កល្បជានិច្ច" (គ និង ស 79:1)។ អ្នកមានសិទ្ធិអំណាច ដើម្បីប្រកាសដំណឹងល្អ។ បើសិនជាអ្នកកាន់បព្វជិតភាព អ្នកមានសិទ្ធិអំណាចដើម្បី បំរើពិធីការផ្សេងៗ។ កាលដែលអ្នក ពោរពេញដោយការអធិស្ឋាន និងការអនុវត្តប្រកបដោយភាពសក្ដិសមនោះ អ្នកនឹងទទួលអំណាចខាងវិញ្ញាណ ដែលជាភស្ដុតាងនៃការហៅបំរើ របស់អ្នក។ ចូរកុំខ្លាច ឬខ្មាស់អៀនអំពីការបំពេញបេសកកម្មនេះឡើយ។ ប្រៀបបាននឹង កូនប្រុសទាំងឡាយរបស់ ម៉ូសាយ អ្នកត្រូវបង្រៀន ដោយព្រះដេស្ដា និងសិទ្ធិអំណាចនៃព្រះ (សូមមើល អាលម៉ា 17:2–3)។

កាលដែលបានត្រូវញែកចេញដោយអំណាចបព្វជិតភាព អ្នកបានទទួលសិទ្ធិ និងឯកសិទ្ធិដើម្បី ធ្វើជាតំណាងព្រះអម្ចាស់។ អ្នកបានទទួលសេចក្ដីបញ្ជាក់ជាផ្លូវការ ដែលថា ត្រូវនាំសិទ្ធិអំណាចទៅកាន់ពិភពលោក។ ប្រធាន ស្ពែនសឺ ដបុលយូ.ឃិមបឹល បានមានប្រសាសន៍ថាៈ "ពិធីញែកចេញជាការបញ្ជាក់ពីសេចក្ដីពិត វាជាការញែកចេញពីអំពើបាប ញែកចេញខាងរាងកាយ ញែកចេញពីអ្វីៗដែលជាភាពចង្អៀត ភាពទាប ភាពសាហាវ ភាពថោកទាប ឬក៏ញែកចេញ ពីភាពបាតផ្សា *ញែកចេញ* ពីពិភពលោក ដើម្បីទៅរកការគិត និងសកម្មភាព ដែលមានកំរិតប្រសើរជាង។ ពរជ័យគឺពឹងផ្អែកទៅលើការប្រតិបត្តិដែលពោរពេញដោយសេចក្ដីជំនឿ" (*The Teaching of Spencer W. Kimball*, ពិនិត្យផ្ទៀងផ្ទាត់ដោយ Edward L. Kimball [1982], 478)។

ជាមួយគ្នានឹងសិទ្ធិអំណាចរបស់អ្នក មកនូវការទទួលខុសត្រូវដើម្បីរស់នៅ ដោយភាពសក្ដិសមនៃការហៅបំរើរបស់អ្នក។ ក្នុងនាមជាអ្នកតំណាងរបស់ព្រះអម្ចាស់ អ្នកត្រូវ "ធ្វើជាគំរូដល់ពួកអ្នកជឿ" (ធីម៉ូថេ ទី1 4:12)។ ចូរខិតខំរស់នៅតាមបទបញ្ញត្តិរបស់ ព្រះ ហើយរក្សាសេចក្ដីសញ្ញា ដែលអ្នកបានធ្វើនៅក្នុងព្រះវិហារបរិសុទ្ធ យល់ដឹងព្រះគម្ពីរ សុភាពរាបសារ មកទាន់ម៉ោង និងពឹង ផ្អែកបានធ្វើតាមការណែនាំនៃបទដ្ឋានរបស់អ្នកផ្សព្វផ្សាយសាសនា ទាំងសំលៀកបំពាក់ ការកាត់សក់ ស្រឡាញ់មនុស្ស ដែលអ្នក បំរើ និងអ្នកធ្វើការជាមួយគ្នា។ គោរពព្រះនាមព្រះអម្ចាស់តាមរយៈសកម្មភាពរបស់អ្នក។

បន្ថែមពីលើសិទ្ធិអំណាច អ្នកត្រូវតែអនុវត្តអំណាច នៅក្នុងកិច្ចការរបស់អ្នក។ សិទ្ធិអំណាចដែលអ្នកបានទទួល អាចនាំឱ្យអ្នកមានអំណាច។ តាមការពិតទៅ អំណាចខាងវិញ្ញាណ ជាភស្ដុតាងមួយដែលបញ្ជាក់ថាសិទ្ធិអំណាច របស់អ្នកគឺពិត។ អំណាចខាងវិញ្ញាណ ជាអំណោយដែលអាចធ្វើឱ្យអ្នក ប្រតិបត្តិកិច្ចការរបស់អ្នក ប្រកបដោយប្រសិទ្ធភាព។

អំណាច និងសិទ្ធិអំណាចរបស់អ្នក គួរតែត្រូវបានបញ្ជាក់ឱ្យឃើញ នៅពេលអ្នកធ្វើកិច្ចការ និងបង្រៀន។ អំណាចអាចត្រូវបានស្ដែងឱ្យឃើញ នៅក្នុងកិច្ចការដែលអ្នកធ្វើ ដូចជាៈ

- ត្រូវបានដឹកនាំដោយព្រះវិញ្ញាណ ដើម្បីឱ្យនិយាយអ្វីដែលព្រះអម្ចាស់ចង់ឱ្យអ្នកនិយាយ នៅចំពេលនោះឯង (សូមមើល គ និង ស 84:85)។
- ទទួលការណែនាំអំពីទីកន្លែង ដែលត្រូវទៅ ឬពីអ្វីដែលត្រូវធ្វើ (សូមមើល គ និង ស 28:15, 31:11, 75:26-27)។
- ដោយមានបញ្ជាក់ពីទីបន្ទាល់របស់អ្នក ដែលមានព្រះវិញ្ញាណជាសាក្សី (សូមមើល នីហ្វៃ ទី2 33:1, គ និង ស 100:5–8)។
- ចូលរួមនៅក្នុងពិធីការនានានៃសេចក្ដីសង្គ្រោះ (សូមមើល គ និងស 84:19–20)។
- ផ្ដល់ការប្រសិទ្ធិពរ បើសិនជាអ្នកជាអែលឌើរ (សូមមើល យ៉ាកុប 5:14–15)។
- ការអធិស្ឋានជាមួយ និងសំរាប់មនុស្សដែលអ្នកធ្វើការជាមួយ (សូមមើល អាលម៉ា 6:6, 8:18–22, 10:7–11 , 31:26–35, គ និង ស 75:19)។
- បង្ហាញក្ដីស្រឡាញ់ចំពោះព្រះអម្ចាស់ គ្រួសាររបស់អ្នក ធ្វើជាមិត្តចំពោះអ្នកផ្សព្វផ្សាយសាសនា និងចំពោះមនុស្សដែល អ្នកបំរើ។

កំណត់ចំណាំ

## ការសិក្សាព្រះគម្ពីរ

**តើអ្នកទទួលអំណាចដោយវិធីណា?**

| | | |
|---|---|---|
| អាលម៉ា 17:2–3 | គ និង ស 53:3 | កូរិនថូសទី1 2:4 |

## សកម្មភាពៈ ការសិក្សាដោយផ្ទាល់ខ្លួន និងការសិក្សាជាមួយដៃគូ

ចូរសំលឹងទៅលើ រូបគំនូររបស់ព្រះអម្ចាស់ ដែលកំពុងតែតែងតាំងសាវក ហើយបន្ទាប់មកសូមអាន យ៉ូហាន 15:1–16។

តើនៅក្នុងវិធីអ្វីដែលព្រះយេស៊ូវជាដើមទំពាំងបាយជូ? តើអ្នកអាចជាមែកដើមទំពាំងបាយជូនោះ ដោយរបៀបណា? តើពិធីញែកចេញរបស់អ្នក ទាក់ទងនឹងទំនាក់ទំនងនេះ យ៉ាងដូចម្ដេច?

---

ចូរអាន សេចក្ដីបញ្ជាក់ម្ដងទៀត។ ចូរសរសេរពីអារម្មណ៍ និងគំនិតរបស់អ្នកពីអ្វីដែលអ្នកបានអាន។ រាល់ពេល ដែលអ្នក សិក្សាពីជំពូកនេះ សូមធ្វើការណ៍នេះម្ដងទៀត។ ចូរធ្វើកំណត់ចំណាំ ពីការផ្លាស់ប្ដូរនៃអារម្មណ៍របស់អ្នករាល់ពេល។

---

ចូរសិក្សា គោលលទ្ធិ និងសេចក្ដីសញ្ញា 109:13–15, 21–30, 38–39, 55–57 បានដកស្រង់មកពី ពិធីឧទ្ទិសបួងសួង ដែលមានការបំផុសគំនិត របស់ព្យាការី យ៉ូសែប ស្ម៊ីធ សំរាប់ព្រះវិហារបរិសុទ្ធ នៅខឺតឡេន។ តើមានពរជ័យអ្វីខ្លះដែល យ៉ូសែប ស្ម៊ីធ បានទូលសុំសំរាប់សេចក្ដីស្មោះត្រង់?



## ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ

ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ឱ្យន័យយ៉ាងច្បាស់ ទាំងសារដំណឹង និងគោលបំណងរបស់អ្នក ដែលថា ដំណឹងល្អពន្យល់ទាំង "អ្វី" និង"មូលហេតុ" នៃកិច្ចការរបស់អ្នកផ្សព្វផ្សាយសាសនា។ ព្រះអង្គសង្គ្រោះបានឱ្យអត្ថន័យពី ដំណឹងល្អរបស់ទ្រង់ ដើម្បីរួមបញ្ចូល គោលលទ្ធិដ៏សំខាន់មួយចំនួន។ ទ្រង់យាងមកពិភពលោកដើម្បី ធ្វើតាមឆន្ទៈព្រះវរបិតាទ្រង់ ហើយព្រះវរបិតាទ្រង់បញ្ជូន ទ្រង់មកពិភពលោក ដើម្បីត្រូវឆ្កាងនៅលើឈើឆ្កាង។ ដោយសារដង្វាយធួន និងការរស់ឡើងវិញរបស់ទ្រង់ មនុស្សរាល់រូប នឹងត្រូវបានលើបឡើង ឈរនៅខាងមុខព្រះគ្រីស្ទ ដើម្បីធ្វើការជំនុំជំរះអំពីកិច្ចការ របស់ពួកគេ ទោះបីជាកិច្ចការល្អ ឬក៏ជាកិច្ចការ អាក្រក់ក្ដី។ ចំពោះជនទាំងឡាយណាដែលបាន អនុវត្តសេចក្ដីជំនឿនៅក្នុងព្រះគ្រីស្ទ ប្រែចិត្តពីអំពើបាប ហើយធ្វើ ពិធីបុណ្យ ជ្រមុជទឹក នៅក្នុងព្រះនាមព្រះគ្រីស្ទ នោះពួកគេអាច នឹងញែកចេញជាបរិសុទ្ធដោយ ព្រះវិញ្ញាណបរិសុទ្ធ។ បើសិនជាពួកគេ ស៊ូទ្រាំដល់ទីបំផុត នោះពួកគេនឹងឈរដោយគ្មានស្នាមប្រឡាក់ នៅខាងមុខព្រះគ្រីស្ទ នាថ្ងៃចុងក្រោយ ហើយនឹង ចូលនៅ ទីសំរាកនៃព្រះអម្ចាស់។ ព្រះគ្រីស្ទនឹងកាន់ពួកគេ ដោយគ្មានទោសកំហុស នៅពីមុខព្រះវរបិតា។ ទ្រង់នឹង ជាព្រះសង្គ្របសង្គ្រម និងជាព្រះអង្គគាំទ្ររបស់ពួកគេ។ ចំពោះជនទាំងឡាយណា ដែលមិនស៊ូទ្រាំ ដោយស្មោះត្រង់ដល់ទីបំផុតទេនោះ ពួកគេនឹង " បោះចោលទៅក្នុងភ្លើង . . . ពីព្រោះតែសេចក្ដីយុត្តិធម៌នៃព្រះវរបិតា។" (សូមមើល នីហ្វៃ ទី3 27:13–22, ប្រៀបធៀបនឹង នីហ្វៃ ទី2 3:11–21, នីហ្វៃ ទី3 11:31–41, គ និង ស 76:40–42, 50-53។)

កំណត់ចំណាំ

គោលបំណងនៃដំណឹងល្អ គឺដើម្បីលាងជំរះមនុស្សលោកពីអំពើបាបរបស់ពួកគេ ដើម្បីពួកគេអាចទទួលសេចក្ដីមេត្តាករុណានៃព្រះ អង្គសង្គ្រោះ នៅថ្ងៃកាត់សេចក្ដី។ ហេតុដូច្នេះ ចំណុចផ្ដោតអារម្មណ៍នៃសៀវភៅនេះ ដែលវាមានសារៈសំខាន់ជាងគេនោះ គឺជាកិច្ចការអ្នកធ្វើ ជារៀងរាល់ថ្ងៃ ដើម្បីអញ្ជើញមនុស្សដទៃឱ្យមកឯព្រះគ្រីស្ទ ដោយការជួយពួកគេឱ្យទទួល ដំណឹងល្អដែលបានការស្ដារឡើងវិញ តាមរយៈជំនឿនៅលើព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ការប្រែចិត្ត ការទទួលបុណ្យជ្រមុជទឹក ការទទួលអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ និងការស៊ូទ្រាំដល់ទីបំផុត។

បុគ្គលម្នាក់ៗ និងក្រុមគ្រួសារនីមួយៗ នឹងចាប់ផ្ដើមធ្វើតាមគំរូព្រះយេស៊ូវគ្រីស្ទ នៅពេលដែលពួកគេអនុវត្តសេចក្ដីជំនឿលើទ្រង់ ហើយប្រែចិត្តពីអំពើបាបរបស់ពួកគេ។ ពួកគេទទួលការរំដោះបាបតាមរយៈ ពិធីបុណ្យជ្រមុជទឹក និងដោយការទទួល អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ពីមនុស្សម្នាក់ដែលមានសិទ្ធិអំណាចមកពីព្រះដើម្បីធ្វើពិធីការទាំងនេះ។ បន្ទាប់ មកពួកគេស៊ូទ្រាំដល់ទីបំផុត ឬអាចនិយាយបានថា ពួកគេត្រូវបន្តរហូតអស់មួយជីវិត នៅក្នុងការអនុវត្ត សេចក្ដីជំនឿលើ ព្រះគ្រីស្ទ ដោយការប្រែចិត្ត និងការរំឭកកិច្ចសញ្ញាដែលពួកគេបានធ្វើ។ ទាំងអស់នេះមិនមែនជាជំហានដែល ពួកគេគ្រាន់តែធ្វើតែម្ដង ក្នុងមួយជីវិតនោះទេ ប៉ុន្តែនៅពេលដែលពួកគេធ្វើម្ដងហើយម្ដងទៀត គោលការណ៍ទាំងនេះនឹងក្លាយទៅជា គំរូនៃ រង្វាន់សំរាប់ជីវិតកាន់តែប្រសើរឡើង។ ជាការពិត នេះគឺជាវិធីតែមួយគត់នៃការរស់នៅ ដែលនឹងនាំមក នូវភាពសុខសាន្តនៃមនុស្សការ ហើយអាចធ្វើឱ្យកូនចៅ ព្រះវរបិតាសួគ៌ អាចត្រឡប់ទៅរស់នៅក្នុងទីវត្តមានរបស់ទ្រង់។

> “បង្រៀនគោលការណ៍ទីមួយនៃដំណឹងល្អ—បង្រៀនគោលការណ៍ទាំងនោះម្ដងទៀតៈ អ្នកនឹងឃើញថាពីមួយថ្ងៃទៅមួយថ្ងៃ គំនិតថ្មីបន្ថែមទៀត នឹងបង្ហាញដល់អ្នក ដើម្បីបំភ្លឺអំពីគោលការណ៍ទាំងនោះទៅដល់ពួកគេ។ អ្នកអាចបង្កើន ការយល់ដឹងនៃគោលការណ៍ទាំងនោះបាន ហើយវានឹងធ្វើឱ្យអ្នកមានការយល់ដឹងកាន់តែច្បាស់ឡើង។ បន្ទាប់មកអ្នកនឹង មានសមត្ថភាព ដើម្បីធ្វើឱ្យ[មនុស្ស]ដែលអ្នក បង្រៀនមានការយល់ដឹងអំពីគោលការណ៍នេះ កាន់តែច្បាស់ឡើងថែមទៀត។”
>
> —ហៃរុម ស្ម៊ីធ
> *HISTORY OF THE CHURCH,* ៦:៣២៣

ការគោរពប្រតិបត្តិដល់ព្រះយេស៊ូវគ្រីស្ទ គឺជាការតាំងចិត្តអស់មួយជីវិត។ តាមរយៈការអនុវត្តសេចក្ដីជំនឿ ការប្រែចិត្ត ការទទួលបុណ្យជ្រមុជទឹក ហើយប្ដេជ្ញាចិត្តបំរើព្រះគ្រីស្ទ ហើយបន្ទាប់មកទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ យើងអាចមាន បទពិសោធន៍ការព្យាបាលខាងវិញ្ញាណ ការអភ័យទោសពីអំពើបាប និងការផ្លាស់សាសនាដោយពេញលេញ ទៅឯព្រះអង្គសង្គ្រោះ និងដំណឹងល្អរបស់ទ្រង់។

ជួយមនុស្សបង្កើននូវសេចក្ដីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ហើយនាំមករកការប្រែចិត្ត ដោយការបង្រៀន និងការថ្លែងទីបន្ទាល់ថាភាពដ៏ពេញលេញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ និងសិទ្ធិអំណាចនៃបព្វជិតភាព ត្រូវបានស្ដារឡើងវិញ និងដោយការអញ្ជើញពួកគេឱ្យរស់នៅតាមការបង្រៀនរបស់ទ្រង់។

**ការសិក្សាព្រះគម្ពីរ**

**តើអ្វីទៅដែលជាដំណឹងល្អ ឬជាគោលលទ្ធិរបស់ព្រះគ្រីស្ទ?**

នីហ្វៃទី2 31:10–21 | នីហ្វៃទី3 11:31–41 | នីហ្វៃទី3 27:13–22

## សារដំណឹងនៃការស្ដារឡើងវិញៈ មូលដ្ឋានគ្រឹះនៃជំនឿ

មិនថាជានៅទីកន្លែងណា ដែលអ្នកបំរើ ឬជាមនុស្សណាដែលអ្នកបង្រៀននោះទេ ចូរផ្ដោតការបង្រៀនរបស់អ្នកទៅលើ ការស្ដារឡើងវិញ នៃដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ។ “ព្រះអម្ចាស់នឹងប្រទានពរដល់អ្នក នៅពេលដែលអ្នកបង្រៀន សារដំណឹងនៃ ការស្ដារឡើងវិញ ទៅកាន់ពិភពលោកថា ភាពអស់សង្ឃឹម ត្រូវការដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ” (“Statement on Missionary Work,” សារលិខិត របស់គណៈប្រធានទីមួយ ថ្ងៃទី 11 ខែធ្នូ ឆ្នាំ 2002)។ កាលដែលអ្នកសិក្សាអំពី គោលលទ្ធិ ទាំងឡាយនៅក្នុងមេរៀនសំរាប់អ្នកផ្សព្វផ្សាយសាសនា អ្នកនឹងឃើញថា យើងមានសារដំណឹងមួយ។ តាមរយៈ ព្យាការីសម័យថ្មី ព្រះបានស្ដាបនាចំណេះដឹងឡើងវិញ អំពីផែនការនៃសេចក្ដីសង្គ្រោះ ដែលផ្ដោតទៅលើ ដង្វាយធួនរបស់ព្រះគ្រីស្ទ ហើយនឹងត្រូវបានបំពេញដោយការរស់នៅតាម គោលការណ៍ និងពិធីការណ៍ទីមួយនៃដំណឹងល្អ។

កំណត់ចំណាំ

ត្រូវប្រាកដថា មនុស្សម្នាក់ៗ ដែលអ្នកបង្រៀន មានការយល់ដឹងយ៉ាងច្បាស់អំពីកិច្ចការដូចតទៅនេះ

- ព្រះជា ព្រះវរបិតាពិតរបស់យើងនៅឯស្ថានសួគ៌។ ទ្រង់ស្រឡាញ់យើង។ មនុស្សគ្រប់រូបនៅលើ ផែនដីនេះជាកូនរបស់ ព្រះ ហើយជាសមាជិកនៃគ្រួសាររបស់ព្រះ។ ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ហើយជាព្រះអង្គសង្គ្រោះ និងជាអង្គ ប្រោសលោះយើង។
- ព្រះវរបិតា បានឈោងដល់កូនៗរបស់ទ្រង់ តាំងពីជំនាន់ នៃព្រះគម្ពីរបរិសុទ្ធ ដោយការបង្ហាញដំណឹងល្អ របស់ទ្រង់ទៅព្យាការី។ ជាអកុសល មានមនុស្សជាច្រើនបានបដិសេធដំណឹងល្អនោះ សូម្បីតែមនុស្សខ្លះ ដែលបាន ទទួលយកដំណឹងល្អ ក៏ធ្វើការផ្លាស់ប្ដូរគោលលទ្ធិ និងពិធីការនានានៃដំណឹងល្អ ហើយក៏ធ្លាក់ទៅ ក្នុងការគ្មានសេចក្ដីជំនឿ និងមានការក្បត់សាសនា។
- ព្រះវរបិតាយើងដែលគង់នៅឯស្ថានសួគ៌ បានបញ្ជូនបុត្រាសំណប់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ មកកាន់ផែនដី។ ទ្រង់បានបង្កើត ឱ្យមានអព្ភូតហេតុ ហើយទ្រង់បង្រៀនដំណឹងល្អរបស់ទ្រង់។ ទ្រង់ធ្វើឱ្យដង្វាយធួនបានសំរេច ហើយបានរស់ឡើងវិញ។
- ចាប់ផ្ដើមដោយការនិមិត្តលើកទីមួយ ជាថ្មីម្ដងទៀតព្រះទ្រង់ឈោងដល់កូនៗទ្រង់ ដោយសេចក្ដីស្រឡាញ់។ ទ្រង់បានស្ដារ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និងសិទ្ធិអំណាចបព្វជិតភាព ហើយទ្រង់បានរៀបចំសាសនាចក្ររបស់ទ្រង់ នៅលើផែនដី ឡើងវិញ តាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ។ ព្រះគម្ពីរមរមន នេះជាភស្ដុតាងដ៏ជាក់ច្បាស់ នៃការស្ដារឡើងវិញនេះ។



នៅពេលអ្នកជួយ សាសនាគន់ការី ឱ្យឃើញពីទំរង់នៃការក្បត់សាសនា និងការស្ដារឡើងវិញ ពួកគេនឹងរៀបចំខ្លួន ដើម្បីយល់ អំពីសេចក្ដីត្រូវការដ៏មហិមា ដើម្បីឱ្យមានការស្ដារឡើងវិញនាថ្ងៃចុងក្រោយ។ ពួកគេនឹងឃើញ អំពីសេចក្ដីត្រូវការ ដើម្បីទទួល យកដំណឹងល្អដែលបានស្ដារឡើងវិញ ទទួលយកពិធីការនៃសេចក្ដីសង្គ្រោះ ដោយសិទ្ធិអំណាចនៃបព្វជិតភាព ដែលបាន ស្ដារឡើង វិញ ហើយដើរតាមផ្លូវទៅកាន់ជីវិតអស់កល្បជានិច្ច។ ចូរជួយមនុស្សឱ្យដឹងថា សាសនាចក្រនេះ មិនមែនជាសាសនាចក្រផ្សេង ថ្មីមួយទៀតទេ ហើយក៏មិនមែនជាសាសនារបស់ជនជាតិអាមេរិកកាំងនោះដែរ។ ប៉ុន្តែវាជាការស្ដារឡើង វិញនៃ "ភាពពេញលេញ[នៃ] ដំណឹងល្អ" (គ និង ស 1:23) ដែលដូចគ្នានឹងការបើកសំដែង និងការបង្រៀនតាំងពី គ្រាតំបូងមកម្លេះ។

ព្រះគម្ពីរមរមនៈ សក្ខីបទមួយទៀត អំពីព្រះយេស៊ូវគ្រីស្ទ គឺជាភស្ដុតាងយ៉ាងជាក់ច្បាស់ថា យ៉ូសែប ស្ម៊ីធ ជាព្យាការី ហើយថា ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានស្ដារឡើងវិញហើយ។ វាជាមូលដ្ឋាននៃសាសនារបស់យើង ជាប្រភពដែលប្រកបដោយ អំណាចយ៉ាងខ្លាំងសំរាប់បង្រៀនសារដំណឹងនេះ។ សេចក្ដីពិតដ៏សំខាន់ៗមួយចំនួន ត្រូវបានស្ដារឡើងវិញតាមរយៈ យ៉ូសែប ស្ម៊ីធ ដោយរួមបញ្ចូលទាំងចំណេះដឹងដែលថា ព្រះជាព្រះវរបិតារបស់យើង ហើយថាយើងជាកូនទ្រង់ខាងវិញ្ញាណ ថាយើងបាន រស់នៅជាមួយទ្រង់ពីមុនចាប់កំណើត ហើយថាក្រុមគ្រួសារ អាចរស់នៅជាមួយគ្នាជារៀងរហូតនៅឯទីវត្តមានរបស់ព្រះ តាមរយៈដង្វាយធួនព្រះគ្រីស្ទ ដោយការគោរពតាមក្រិត្យវិន័យ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អ។

ព្រះគម្ពីរមរមន នេះជាភស្ដុតាងអំពីសេចក្ដីស្រឡាញ់របស់ព្រះ ចំពោះកូនៗទ្រង់។ វាបង្ហាញថា ព្រះមានព្រះបន្ទូលមកកាន់កូនៗទ្រង់។ នៅពេលដែលអ្នកបង្រៀន និងថ្លែងទីបន្ទាល់ ចូរអញ្ជើញមនុស្សម្នាក់ អានព្រះគម្ពីរមរមន និងអធិស្ឋានអំពីសារដំណឹងនេះ។ មនុស្សម្នាក់ៗដែលអ្នកបង្រៀន ត្រូវតែសំរេចចិត្ត បើសិនជាពួកគេទទួលយកព្រះគម្ពីរមរមនថា ជាវិវរណៈមកពីព្រះ ឬក៏ទេ។

ចូរទុកចិត្តទៅលើការសន្យាដ៏អស្ចារ្យ នៅក្នុង ម៉ូរ៉ូណៃ 10:3–5។ ចូរធ្វើអ្វីៗគ្រប់យ៉ាង ឱ្យអស់ពីសមត្ថភាព ដើម្បីឱ្យ មនុស្សគ្រប់គ្នាអាន ស្វែងយល់ពីព្រះគម្ពីរ ហើយទូលសុំព្រះដោយចិត្តស្មោះត្រង់ ថាតើព្រះគម្ពីរនេះជាព្រះគម្ពីរពិតឬក៏អត់។ សាក្សីដែលជាព្រះវិញ្ញាណបរិសុទ្ធ នឹងក្លាយទៅជាមូលដ្ឋាននៃសេចក្ដីជំនឿរបស់ពួកគេ ដែលថា ព្រះគ្រីស្ទបានស្ដារឡើងវិញ សាសនាចក្រទ្រង់។ សូមជួយ អ្នកទាំងឡាយណាដែលអ្នកបង្រៀន ដើម្បីមានការបញ្ជាក់ខាងព្រះវិញ្ញាណ។

កំណត់ចំណាំ

### ការសិក្សាព្រះគម្ពីរ

**តើអ្នកគួរប្រើព្រះគម្ពីរមរមន នៅក្នុងកិច្ចការផ្សព្វផ្សាយសាសនារបស់អ្នកដោយរបៀបណា?**

| | | |
|---|---|---|
| នីហ្វៃទី1 13:39 | ម៉ូរ៉ូណៃ 10:3–5 | គ និង ស 42:12–14 |
| នីហ្វៃទី2 29:8–10 | គ និង ស 20:5–16 | |

### សកម្មភាព៖ ការសិក្សាផ្ទាល់ខ្លួន

ចូរនឹកគិតថា អ្នកនឹងសរសេរអត្ថបទមួយអំពីសារដំណឹងនៃការស្តារឡើងវិញ សំរាប់សារព័ត៌មានក្នុងស្រុកមួយ។ នៅក្នុងសៀវភៅ កត់ត្រា ចូរសរសេរចំណងជើងមួយ ដែលពិពណ៌នាអំពីចំណុចរួមនៃសារដំណឹង។ បន្ទាប់មកចូរកត់អំពី គំនិតនិងអារម្មណ៍ របស់អ្នក អំពីសារដំណឹងនេះ ដោយមានរួមបញ្ចូលទាំង របៀបនៃការផ្លាស់ប្តូរនៃវិថីនៃជីវិត និងរបៀបដែលអ្នកសំលឹងទៅ ពិភពលោក នៅជុំវិញអ្នកថានឹងទៅជាយ៉ាងណា បើសិនជាអ្នកយល់អំពីព្រះគម្ពីរប្រសើរជាងនេះ។

## ជួយអ្នកដទៃ ឱ្យធ្វើការតាំងចិត្ត៖ ច្រកនាំទៅកាន់ជំនឿ និងការប្រែចិត្ត

ជួយមនុស្សឱ្យមានគុណសម្បត្តិសំរាប់ ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ដោយការបង្រៀនពួកគេ អំពីគោលលទ្ធិពិត និងការអញ្ជើញពួកគេ ឱ្យប្រែចិត្ត និងផ្លាស់ប្តូរជីវិត តាមរយៈការធ្វើ និងការរក្សាការតាំងចិត្ត ដែលបានសាងសេចក្តីជំនឿពួកគេ នៅក្នុងព្រះគ្រីស្ទ។ ការតាំងចិត្តទាំងអស់នេះរៀបចំមនុស្សដើម្បីធ្វើ និងរក្សាសេចក្តីសញ្ញាពិសិដ្ឋ។

អែលឌើរ ដេល្លិន អេ. អូក ក្រៅ... អែលឌើរ ជេហ្វ្រី អរ. ហូឡេន បានបង្រៀនថា “ រឿងដំបូងដែលអ្នកនឹងធ្វើត្រូវនៅពេលដែល សាសនាទាគន់ការី ប្រាប់អ្នកថាពួកគេ មិនបានអាន ឬអធិស្ឋាន អំពីព្រះគម្ពីរមរមនទេ អ្នកត្រូវបង្ហាញការខកចិត្ត . . . ។ មានពេលជាច្រើន យើងមិនសូវខ្វល់ អំពីរឿងទាំងនេះទេ។ នេះជាជីវិតដ៏នៅអស់កល្បជានិច្ច។ នេះគឺជាសេចក្តីសង្គ្រោះដល់កូនរបស់ព្រះ។ ភាពដ៏អស់កល្បជានិច្ច របស់ សាសនាទាគន់ការី អាស្រ័យទៅលើអ្វីដែលអ្នកជ្រើសដើម្បីធ្វើ . . . ។ នេះជាវិធីដ៏សំខាន់បំផុត ដែលសាសនាទាគន់ការី នឹងដើរលើ។ ប៉ុន្តែបើសិនជា ពួកគេ មិនដឹងអំពីការជ្រើសរើសទេនោះ យ៉ាងហោចណាស់ ក៏មានអ្នកដែរ ដែលដឹងអំពីវា! . . . ។ ដូច្នេះត្រូវ ទប់ស្កាត់នូវស្ថានភាពបែបនេះ។ ចូរបង្រៀនដោយអំណាច និងដោយសិទ្ធិអំណាច ព្រោះបន្ទាប់មក នឹងត្រូវបរាជ័យ បើសិន ជាជំហានទីមួយ ដែលជាជំហាននាំទៅ កាន់ការរក្សាបទបញ្ញត្តិ និងការរក្សាសេចក្តីសញ្ញា មិនបាន ចាប់ផ្តើមដោយ ជោគជ័យទេនោះ៖” (Making and Keeping Convenants,” ការចាក់ផ្សាយតាមផ្កាយ រណបអំពីអ្នក ផ្សព្វផ្សាយសាសនា ខែ មេសា 1997)។

នៅពេលដែលអ្នកបង្រៀនមនុស្ស ឱ្យយល់អំពីភាពពេញលេញនៃដំណឹងល្អ ដែលបានស្តារឡើងវិញ គឺអ្នកត្រូវ “ផ្សាយប្រាប់ពីការប្រែចិត្ត” (គ និង ស 15:6)។ ការប្រែចិត្តមានទំនាក់ទំនងនឹងការផ្លាស់ប្តូរនៃដួងចិត្ត និងបំណងប្រាថ្នា ដើម្បីលះបង់អំពើបាប និងបំរើព្រះ។ វាមានទំនាក់ទំនងនឹងការបន្ទាបខ្លួនដ៏ទន់ភ្លន់ចំពោះព្រះវិញ្ញាណ និងការចុះចូលតាមឆន្ទៈរបស់ព្រះ។ វាតម្រូវឱ្យមនុស្សបង្កើនការតាំងចិត្តរបស់ពួកគេ ដើម្បីរស់នៅក្នុងសេចក្តីព្រមព្រៀងជាមួយនឹងឆន្ទៈរបស់ព្រះ។ ការប្រែចិត្ត តម្រូវឱ្យមានការផ្លាស់ប្តូរដោយស្មោះសរ និងជារៀងរហូតនៃគំនិត បំណងប្រាថ្នា ទំលាប់ និងសកម្មភាពផ្សេងៗ។ ការប្រែចិត្តជាបទពិសោធន៍ វិជ្ជមាន ដែលនឹងនាំមកភាពរីករាយ និងសេចក្តីសុខសាន្ត។ ចូរក្លាហាន និងមានសេចក្តីស្រឡាញ់ ក្នុងការជួយមនុស្សឱ្យយល់ ពីអ្វីដែលពួកគេត្រូវធ្វើដើម្បីការប្រែចិត្ត។ ដោយការអញ្ជើញមនុស្ស ឱ្យធ្វើការតាំងចិត្ត នោះអ្នកអាចដាស់តឿនពួកគេ និងផ្តល់សេចក្តីសង្ឃឹម ដល់ពួកគេប្រកបដោយប្រសិទ្ធភាពផងដែរ។

### ការសិក្សាព្រះគម្ពីរ

**តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះ អំពីការផ្សាយប្រាប់នៃការប្រែចិត្ត?**

| | | |
|---|---|---|
| អាលម៉ា 29:1–4 | អាលម៉ា 62:45 | គ និង ស 15:6, 16:6 |
| អាលម៉ា 42:31 | គ និង ស 14:8 | |

## ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់

ការធ្វើបុណ្យជ្រមុជទឹក និងការធ្វើពិធីបញ្ជាក់ សំរាប់មនុស្សដែលអ្នកបង្រៀន គឺជាចំណុចកណ្តាលនៃគោលបំណងរបស់អ្នក។ ពិធីបុណ្យជ្រមុជទឹក គឺសំរាប់ការរំដោះបាប ហើយអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ នឹងនាំមកនូវពរជ័យជាច្រើន ដល់អ្នកទាំង

កំណត់ចំណាំ

ឡាយណា ដែលមានភាពសក្តិសម។ តាមរយៈពិធីការទាំងនេះ មនុស្សអាចចូលមកតាមទ្វារ ហើយបន្តទៅលើផ្លូវដែលនាំទៅកាន់ជីវិតដ៏អស់កល្បជានិច្ច។ អែលឌើរ ដាល់លិន អេចអូកស៍ បានមានប្រសាសន៍ថា៖ "យើងមិនផ្សាយ និងបង្រៀន ដើម្បី 'នាំមនុស្សមកកាន់សាសនាចក្រ' ឬដើម្បីបង្កើនសមាជិកភាពនៃសាសនាចក្រនោះទេ។ យើងមិនផ្សាយ និងបង្រៀនគ្រាន់តែ បញ្ចុះបញ្ចូលមនុស្សឱ្យមានជីវិតរស់នៅប្រសើរជាងនោះទេ . . . ។ ប៉ុន្តែយើងអញ្ជើញមនុស្សទាំងអស់ ឱ្យមកឯព្រះគ្រីស្ទ ដោយការប្រែចិត្ត និងទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ដើម្បីបើកទ្វារនៃនគរសេឡេស្ទាល សំរាប់បុត្រា និងបុត្រីនៃព្រះ។ គ្មាននរណាផ្សេងអាចធ្វើកិច្ចការនេះបានទេ" ("The Purpose of Missionary Work," ការចាក់ផ្សាយតាមផ្កាយរណបអំពីអ្នក ផ្សព្វផ្សាយសាសនា ខែមេសា 1995)។

ពេលដែលអ្នកបង្រៀនអំពីការស្តារឡើងវិញនៃដំណឹងល្អ ចូរជួយពួកគេឱ្យយល់អំពីលក្ខណៈដ៏ពិសិដ្ឋ នៃពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។ ចូរជួយពួកគេឱ្យយល់ថា ការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ជាពរជ័យដ៏ធំជាងគេ នៅក្នុងជីវិតនេះ ហើយជាកូនសោនៃសេចក្តីសង្គ្រោះ។ ព្រះវិញ្ញាណបរិសុទ្ធនឹង "បង្រៀន [ពួកគេ] នូវគ្រប់សេចក្តីទាំងអស់" (យ៉ូហាន 14៖26)។ ប្រធាន ប៊យ ខេ. ផាកកឺ បានបង្រៀនថា៖ "ពេលដែលអ្នកកំពុងតែបង្រៀនសាសនាគន់ការីពីសាសនាចក្រ និងកំពុងតែ រៀបចំពួកគេសំរាប់ពិធីបុណ្យជ្រមុជដោយទឹក នោះអ្នកត្រូវតែគិតផងដែរអំពីអំណោយនៃព្រះវិញ្ញាណបរិសុទ្ធ—បុណ្យជ្រមុជ ទឹកដោយភ្លើង។ ចូរចាត់ទុកថា ឃ្លានេះមានតែមួយប្រយោគ។ ជាដំបូងគឺជាបុណ្យជ្រមុជដោយទឹក ហើយបន្ទាប់មកបុណ្យជ្រមុជ ដោយភ្លើង" ("The Gift of the Holy Ghost: ជាអ្វីដែលអ្នកផ្សព្វផ្សាយសាសនាគ្រប់គ្នាគួរតែដឹង—ព្រមទាំង សមាជិកគ្រប់គ្នាផងដែរ" សិក្ខាសាលាសំរាប់ប្រធានបេសកកម្មថ្មី ខែមិថុនា ឆ្នាំ 2003)។ ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនថា៖ "ពិធីបុណ្យជ្រមុជដោយទឹក ជាពិធីបុណ្យជ្រមុជតែពាក់កណ្តាលទេ ហើយវាមិនល្អទេ បើគ្មានពិធីបុណ្យមួយទៀត–ដែលវាជាពិធីបុណ្យជ្រមុជ ដោយព្រះវិញ្ញាណបរិសុទ្ធ" (*History of the Church,* 5៖499)។

ជួយអ្នកទាំងឡាយណាដែលអ្នកបង្រៀន ឱ្យយល់ថា ដើម្បីមានគុណសម្បត្តិគ្រប់គ្រាន់សំរាប់ទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ពួកគេត្រូវតែមានលក្ខខ័ណ្ឌ ដែលបានផ្តល់ឱ្យនៅក្នុង គោលលទ្ធិ និងសេចក្តីសញ្ញា 20៖37។

### គ និង ស 20៖37 គុណសម្បត្តិសំរាប់ពិធីបុណ្យជ្រមុជទឹក

- បន្ទាបខ្លួនពួកគេ នៅចំពោះព្រះ។
- មានបំណងប្រាថ្នាទទួលបុណ្យជ្រមុជទឹក។
- មកដោយមានចិត្តសង្រេង និងវិញ្ញាណទន់ទាប។
- ប្រែចិត្តចេញពីអំពើបាបទាំងអស់។
- មានឆន្ទះដើម្បីលើកដាក់ខ្លួនពួកគេនូវព្រះនាមព្រះគ្រីស្ទ។
- ប្ដេជ្ញាចិត្ត ដើម្បីបំរើព្រះគ្រីស្ទរហូតដល់ទីបំផុត។
- បង្ហាញតាមរយៈកិច្ចការរបស់ពួកគេថា ពួកគេបានទទួលព្រះវិញ្ញាណនៃព្រះគ្រីស្ទ ដែលនាំឱ្យមានការរំដោះបាបរបស់ ពួកគេ។

បន្ទាប់ពីអ្នកផ្លាស់គំនិតដែលមានភាពសក្តិសមបានទទួលបុណ្យជ្រមុជទឹក ពួកគេត្រូវបានទទួលពិធីបញ្ជាក់ថា ជាសមាជិកសាសនាចក្រ ហើយអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ នឹងត្រូវបានប្រគល់ឱ្យពួកគេ។ ពិធីបញ្ជាក់នេះ នឹងកើតឡើង នៅក្រោមការណែនាំរបស់ប៊ីស្សព ឬប្រធានសាខា នៅក្នុងការប្រជុំសាក្រាម៉ង់ បន្ទាប់ពីទទួលបុណ្យជ្រមុជទឹកហើយភ្លាម។ នៅពេលដែល ពិធីការពីរដាច់ពីគ្នាក្នុងរយៈពេលខ្លី នោះពិធីបញ្ជាក់បានបញ្ចូលបង្គ្រប់ បំពេញកិច្ចនៃពិធីបុណ្យជ្រមុជទឹក។

### ការសិក្សាព្រះគម្ពីរ

**តើក្នុងវិធីអ្វី ដែលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ជាអំណោយទានមួយក្នុងចំណោមអំណោយទានដ៏អស្ចារ្យជាច្រើន ដែលយើង អាចទទួល?**

| | | |
|---|---|---|
| នីហ្វៃទី3 19៖1–13 | យ៉ូហាន 3៖5 | កាឡាទី 5៖22–25 |
| គ និង ស 45៖56–57 | យ៉ូហាន 14៖26 | Guide to the Scriptures, "Holy Ghost" |

កំណត់ចំណាំ

**តើហេតុអ្វី បានជាអ្នកផ្លាស់គំនិត គួរតែមានបំណងចង់បានអំណោយទាន នៃព្រះវិញ្ញាណបរិសុទ្ធ?**

| | | |
|---|---|---|
| នីហ្វៃទី2 31:12–17 | កិច្ចការពួកសាវក 8:14–17 | កិច្ចការពួកសាវក 19:1–6 |
| នីហ្វៃទី2 32:1–5 | | |

### សកម្មភាពៈ ការសិក្សាជាមួយដៃគូ

ចូរស្រាវជ្រាវរកខគម្ពីរដូចខាងក្រោមនេះ ហើយនិងធ្វើបញ្ជីនៃគុណសម្បត្តិ និងសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក។ ចូរពិភាក្សាជាមួយនឹងដៃគូអ្នក អំពីរបៀបដែលត្រូវបង្រៀនអំពី តម្រូវការទាំងនោះទៅអ្នកដទៃ។

| | | |
|---|---|---|
| នីហ្វៃទី2 31:13 | អាលម៉ា 7:14–16 | មរ៉ូណៃ 6:1–4 |
| ម៉ូសាយ 18:8–10 | នីហ្វៃទី3 11:21–41 | គ និង ស 20:37 |

## ការស្ថាបនាសាសនាចក្រ

នៅពេលដែលមនុស្សម្នាក់ បានទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ឱ្យក្លាយជាសមាជិកនៃសាសនាចក្រ ចូរអ្នកបន្ដធ្វើការជាមួយនឹង អ្នកដឹកនាំនៅក្នុងវួដ និងសមាជិក ដើម្បីជួយអ្នកដែលទើបផ្លាស់គំនិតថ្មី ឱ្យសំរបនឹងជីវិតថ្មីរបស់ពួកគេ ហើយបន្តការរីកចំរើនខាងវិញ្ញាណរបស់ពួកគេ។ សាសនាចក្រ គឺត្រូវបានកសាងឡើង នៅពេលដែលមនុស្សដែលមានសក្ខីភាព បានទទួលបុណ្យ ជ្រមុជទឹក និងពិធីបញ្ជាក់ រក្សាសេចក្ដីសញ្ញារបស់ពួកគេ រៀបចំដើម្បីទៅព្រះវិហារបរិសុទ្ធ និងជួយពង្រឹងវួដ ឬសាខា។

អ្នកផ្លាស់គំនិតដែលមានមិត្តភ័ក្ដជាសមាជិក ដែលត្រូវបានផ្ដល់ឱ្យមានការទទួលខុសត្រូវ និងដែលត្រូវបានបីបាច់ដោយព្រះបន្ទូលរបស់ព្រះ នឹងរីកចំរើនខាងសក្ខីភាព និងខាងសេចក្ដីជំនឿ។ អ្នកផ្សព្វផ្សាយសាសនា ថ្នាក់ដឹកនាំក្នុងវួដ និងសមាជិកសាសនាចក្រ មិនគួរបដិសេធការទទួលខុសត្រូវរបស់ពួកគេ ដើម្បីបីបាច់ និងពង្រឹងសមាជិកថ្មីទេ។

## អ្នកផ្សព្វផ្សាយសាសនាប្រកបដោយជោគជ័យ

ជោគជ័យរបស់អ្នក ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ គឺត្រូវបានស្ទង់តាំងពីដំបូង តាមរយៈការតាំងចិត្ត ដើម្បីស្វែងរកបង្រៀន ធ្វើបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ដល់មនុស្ស និងដើម្បីជួយពួកគេក្លាយជាសមាជិកស្មោះត្រង់នៃសាសនាចក្រ ដែលរីករាយនឹងវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធ។

ចូរជៀសវាងការប្រៀបធៀបខ្លួនអ្នក ទៅនឹងអ្នកផ្សព្វផ្សាយសាសនាដទៃទៀត និងវាស់លទ្ធផលខាងក្រៅ នៃការខិតខំប្រឹងប្រែងរបស់អ្នក ទៅនឹងការខិតខំប្រឹងប្រែងរបស់ពួកគេ។ ចូរចងចាំថា មនុស្សមានសិទ្ធិសេរីភាព ដើម្បីធ្វើការជ្រើសរើសព្រមទទួល ឬមិនទទួលសារដំណឹង។ ការទទួលខុសត្រូវរបស់អ្នក គឺដើម្បីបង្រៀនដោយច្បាស់លាស់ និងដោយព្រះចេស្ដា ដើម្បីពួកគេអាចធ្វើការជ្រើសរើសត្រឹមត្រូវ។ មនុស្សខ្លះ អាចមិនទទួលយកសារដំណឹងរបស់អ្នក សូម្បីតែពួកគេបានទទួលសាក្សីខាងវិញ្ញាណថា ជាការពិតក៏ដោយ។ អ្នកប្រហែល នឹងមិនសប្បាយចិត្ត ពីព្រោះអ្នកស្រឡាញ់ពួកគេ ហើយចង់ឱ្យពួកគេបានសេចក្ដីសង្គ្រោះ។ ទោះជាយ៉ាងណាក៏ដោយ អ្នកមិនត្រូវបាក់ទឹកចិត្តទេ ព្រោះការបាក់ទឹកចិត្តនឹងធ្វើឱ្យជំនឿអ្នកចុះខ្សោយ។ បើអ្នកបន្ថយការរំពឹងគិតរបស់អ្នក នោះប្រសិទ្ធភាពរបស់អ្នកនឹងចុះអន់ខ្សោយ បំណងប្រាថ្នារបស់អ្នកនឹងចុះខ្សោយ ហើយអ្នកនឹងមានការលំបាកកាន់តែខ្លាំងឡើង ដើម្បីធ្វើតាមព្រះវិញ្ញាណ។

អ្នកអាចដឹងថា អ្នកជាអ្នកផ្សព្វផ្សាយសាសនា ដែលទទួលបានជោគជ័យ នៅពេលអ្នកៈ

- ទទួលអារម្មណ៍ថា ព្រះវិញ្ញាណបរិសុទ្ធថ្លែងទីបន្ទាល់ទៅកាន់មនុស្សដទៃ តាមរយៈអ្នក។
- ស្រឡាញ់មនុស្ស និងចង់ឱ្យពួកគេបានសេចក្ដីសង្គ្រោះ។
- គោរពប្រតិបត្តិតាមដោយត្រឹមត្រូវ។
- រស់នៅតាមរបៀបដែល អ្នកអាចទទួល និងដឹងពីរបៀបដើម្បីធ្វើតាមព្រះវិញ្ញាណ ដែលនឹងបង្ហាញអ្នកពីទីកន្លែងដែលត្រូវទៅ អ្វីដែលត្រូវធ្វើ និងអ្វីដែលត្រូវនិយាយ។
- អភិវឌ្ឍន៍លក្ខណៈដូចព្រះគ្រីស្ទ។

កំណត់ចំណាំ

- ធ្វើការដោយមានប្រសិទ្ធភាពជារៀងរាល់ថ្ងៃ ធ្វើដោយអស់ពីសមត្ថភាព ដើម្បីនាំវិញ្ញាណមកឯព្រះគ្រីស្ទ ហើយស្វែងរកឱកាសដោយស្មោះអស់ពីចិត្តដើម្បីរៀន និងអភិវឌ្ឍន៍។
- ជួយកសាងសាសនាចក្រ (វួដ) ទោះជានៅទីកន្លែងណាក៏ដោយ ដែលអ្នកត្រូវបានចាត់តាំងឱ្យធ្វើការ។
- ព្រមានមនុស្សអំពីផលវិបាកនៃអំពើបាប។ អញ្ជើញពួកគេឱ្យធ្វើ និងរក្សាការតាំងចិត្ត។
- បង្រៀន និងបំរើអ្នកផ្សព្វផ្សាយសាសនាដទៃទៀត។
- ធ្វើការល្អ និងបំរើមនុស្សនូវគ្រប់ឱកាសទាំងអស់ ទោះជាពួកគេទទួល ឬបដិសេធសារដំណឹងរបស់អ្នក។

នៅពេលអ្នកធ្វើអស់ពីសមត្ថភាពរបស់អ្នក នោះអ្នកប្រហែលនៅតែជួបនឹងបទពិសោធន៍ខកបំណង ប៉ុន្តែអ្នកមិនត្រូវខកបំណងលើខ្លួនរបស់អ្នកទេ។ អ្នកអាចដឹងដោយច្បាស់ថា ព្រះអម្ចាស់សព្វព្រះហរទ័យ នៅពេលដែលអ្នកទទួលអារម្មណ៍ថា ព្រះវិញ្ញាណបរិសុទ្ធធ្វើកិច្ចការទ្រង់តាមរយៈអ្នក

## ការសិក្សាព្រះគម្ពីរ

**តើអ្នកបំរើរបស់ព្រះអម្ចាស់ មានអារម្មណ៍ដូចម្តេច ចំពោះកិច្ចការបំរើ? តើអ្នកបំរើរបស់ព្រះអម្ចាស់ នឹងមានឥទ្ធិពលចំពោះមនុស្សដែលពួកគេបំរើ យ៉ាងដូចម្តេច?**

| | | |
|---|---|---|
| ម៉ូសាយ 28:3 | នីហ្វៃទី3 28:4–10 | គ និង ស 68:2–6 |
| អាលម៉ា 8:14–15 | អេធើរ 12:13–15 | |
| ហេលេមិន 10:3–5 | គ និង ស 15:4–6, 16:4–6 | |

## សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

- អាន ហេលេមិន 10:1–5 និង នីហ្វៃទី3 7:17–18។ តើព្រះអម្ចាស់ មានអារម្មណ៍យ៉ាងដូចម្តេច ចំពោះអ្នកផ្សព្វផ្សាយសាសនាទាំងនេះ និងការបំរើរបស់ពួកគេ?
- ចូរគិតអំពីការខិតខំប្រឹងប្រែងនៃអ្នកផ្សព្វផ្សាយសាសនា អ័ប៊ីណាដៃ និងអាំម៉ូន (សូមមើល ម៉ូសាយ 11–18, អាលម៉ា 17–20, 23–24)។ តើហេតុអ្វី បានជាអ្នកផ្សព្វផ្សាយសាសនាទាំងពីរនោះ ទទួលបានជោគជ័យសូម្បីតែលទ្ធផលនៃការខិតខំរបស់ពួកគេ ខុសពីគ្នា?
- ចូរសរសេរក្នុងសៀវភៅសិក្សារបស់អ្នក ពីអ្វីដែលអ្នកបានរៀន។

## ចូរចងចាំចំណុចនេះ

- គោលបំណងរបស់អ្នក គឺដើម្បីអញ្ជើញមនុស្សដទៃ មកឯព្រះគ្រីស្ទដោយការជួយពួកគេ ឱ្យទទួលដំណឹងល្អដែល បានស្តារឡើងវិញ តាមរយៈសេចក្តីជំនឿ នៅលើ ព្រះគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ការកែប្រែចិត្ត ពិធីបុណ្យជ្រមុជទឹក ការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ និងកាន់ខ្ជាប់ដរាបដល់ចុងបំផុត។
- ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ ជាផ្លូវតែមួយគត់ដែលយើងអាច ស្វែងរកសុភមង្គលដ៏អស់កល្បជានិច្ច។
- ការហៅបំរើរបស់អ្នក ផ្តល់ដល់អ្នកនូវសិទ្ធិអំណាច ការរក្សាសេចក្តីសញ្ញារបស់អ្នក ផ្តល់ដល់អ្នកនូវអំណាច។
- ភាពពេញលេញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ត្រូវបានស្តារឡើងវិញ តាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ។ ព្រះគម្ពីរមរមន ជាភស្តុតាងបញ្ជាក់ថា យ៉ូសែប ស្ម៊ីធ ជាព្យាការី។
- អ្នកជួយមនុស្សឱ្យរស់នៅតាមដំណឹងល្អ ដោយការអញ្ជើញពួកគេឱ្យធ្វើ និងរក្សាការតាំងចិត្ត។
- អ្នកបង្ហាញក្តីស្រឡាញ់របស់អ្នកចំពោះព្រះអម្ចាស់ និងបង្ហាញការដឹងគុណសំរាប់ដង្វាយធួន ដោយការនាំព្រលឹងទាំងឡាយមករកទ្រង់។
- អ្នកមានជោគជ័យ ពេលដែលអ្នកគោរពប្រតិបត្តិ រស់នៅសុចរិត និងធ្វើឱ្យអស់ពីសមត្ថភាពរបស់អ្នក ក្នុងការជួយអ្នកដទៃ ឱ្យរស់តាមដំណឹងល្អ។

កំណត់ចំណាំ

## កិច្ចការអ្នកផ្សព្វផ្សាយសាសនា

ខាងក្រោមនេះ ជាសេចក្ដីថ្លែងដែលបានថ្លែងដោយ ប្រធាននៃសាសនាចក្រ នៅក្នុងសម័យកាន់កាប់ត្រួតត្រានេះ។

### ប្រធានយ៉ូសែប ស្ម៊ីធ (1830–1844)

"បន្ទាប់ពីកិច្ចការទាំងអស់បាននិយាយចប់ហើយ ករណីយកិច្ចដ៏ធំជាងគេ និងសំខាន់ជាងគេ គឺផ្សាយដំណឹងល្អ" (*Teachings of the Prophet Joseph Smith*, ត្រូវបានជ្រើសរើសដោយ Joseph Fielding Smith [1976], 113)។

"សូមឱ្យពួកបរិសុទ្ធចងចាំថា កិច្ចការដ៏អស្ចារ្យ គឺពឹងផ្អែកទៅលើការខំប្រឹងប្រែងដោយផ្ទាល់របស់ពួកគេ ហើយថា ពួកគេបានហៅឱ្យបំរើជាមួយពួកយើង និងព្រះវិញ្ញាណបរិសុទ្ធ ក្នុងការបំពេញកិច្ចការដ៏អស្ចារ្យ នៃថ្ងៃចុងក្រោយបង្អស់" (*Teachings of the Prophet Joseph Smith*, 178–790 ។

### ប្រធាន ព្រិកហាំ យ៉ង់ (1847–1877)

"គ្មានបុរស ឬស្ត្រីណាម្នាក់ នៅក្នុងសាសនាចក្រនេះ ដែលគ្មានការបំពេញបេសកកម្មនោះទេ។ បេសកកម្មនោះ នឹងបន្តរហូតបើពួកគេនៅមានជីវិតរស់នៅ ហើយបេសកកម្មនេះគឺ ដើម្បីធ្វើល្អ បង្ហាញសេចក្ដីសុចរិត ដើម្បីបង្រៀនគោលការណ៍នៃសេចក្ដីពិត និងដើម្បីយកជ័យជំនះលើខ្លួនគេ និងមនុស្សគ្រប់រូបជុំវិញពួកគេ ឱ្យរស់នៅតាមគោលការណ៍ទាំងនោះ ដែលពួកគេអាចបានទទួលជីវិតអស់កល្បជានិច្ច" (*Discourses of Brigham Young*, ត្រូវបានជ្រើសរើសដោយ John A. Widtsoe [1954], 322)។

### ប្រធាន យ៉ូហាន ថេល័រ (1880–1887)

"ករណីយកិច្ចរបស់យើង គឺការផ្សព្វផ្សាយដំណឹងល្អដល់មនុស្សគ្រប់រូប . . . ។ នេះជាអ្វី ដែលព្រះរំពឹងចង់បានពីយើង" ( *The Gospel Kingdom*, ត្រូវបានជ្រើសរើសដោយ G. Homer Durham [1943], 234–35)។

### ប្រធាន វិលហ្វដ វូឌរើប (1889–1898)

"យើងមកលើផែនដីនេះ ដោយមានបេសកកម្មមួយ . . . ដែលយើងអាចមានអំណាចដើម្បីដើរឆ្ពោះទៅមុខ និងព្រមានដល់ជាតិសាសន៍ នៃផែនដី . . . ។ ក្នុងនាមជាអែលឌើរនៃអ៊ីស្រាអែល ពួកយើងមានតែមួយចំនួនតូចប៉ុណ្ណោះ ដែលយល់ច្បាស់ពី មុខដំណែងការហៅបំរើ ទំនាក់ទំនងរបស់យើងចំពោះព្រះ ការទទួលខុសត្រូវរបស់យើង ឬកិច្ចការដែលព្រះអម្ចាស់តម្រូវនៅលើ ដៃរបស់យើង" (*The Discourses of Wilford Woodruff*, ជ្រើសរើស G. Homer Durham [1946], 124)។

### ប្រធាន ឡូរែនសូ ស្នូ (1898–1901)

"គ្មានបុរសខាងសាច់ឈាមណាម្នាក់ ដែលចាប់អារម្មណ៍ខ្លាំងទៅលើជោគជ័យរបស់អែលឌើរម្នាក់ឡើយ នៅពេលដែលគាត់ផ្សព្វផ្សាយដំណឹងល្អ នៅពេលដែលព្រះអម្ចាស់បានបញ្ជូនគាត់ ឱ្យទៅផ្សាយដល់មនុស្សដែលជាកូនចៅរបស់ព្រះអម្ចាស់" (*The Teachings of Lorenzo Snow*, ចងក្រងដោយ Clyde J. William [1984], 70)។

### ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ (1901– 1918)

"យើងមានបេសកកម្មនៅក្នុងពិភពលោកៈ បុរស ស្ត្រី កុមារគ្រប់រូបដែលមានការរីកចំរើនឡើងខាងការយល់ដឹង ឬ នៅអាយុនៃការទទួលខុសត្រូវ ត្រូវតែ . . . មានភាពសក្ដិសមដើម្បីផ្សព្វផ្សាយសេចក្ដីពិត ថ្លែងទីបន្ទាល់នៃសេចក្ដីពិត" (*Gospel Doctrine*, 13th បោះពុម្ព [1968, 252–52) ។

### ប្រធាន ហ៊ី បើ ចេ. គ្រាន្ត (1918–1945)

"យើងជាមនុស្សមានកិច្ចការដ៏សំខាន់មួយត្រូវធ្វើ ហើយនោះគឺជាការប្រកាសដល់ពិភពលោកឱ្យប្រែចិត្តពីអំពើបាប ដើម្បីមកឯព្រះ។ ហើយវាជាករណីយកិច្ចរបស់យើង លើករណីយកិច្ចណាៗ ទាំងអស់ ដើម្បីឆ្ពោះទៅមុខ និងប្រកាសដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដែលស្តារឡើងវិញម្ដងទៀតអំពីផែនការនៃជីវិត និងសេចក្ដីសង្គ្រោះ . . . ។ យើងមានកែវមុក្តាដ៏មានតំលៃក្រៃ។ យើងមានវាដែលមានតំលៃលើសទ្រព្យទាំងឡាយ និងដំណឹងវិទ្យាសាស្ត្រដែលពិភពលោកត្រូវការទៅទៀត។ យើងមានផែនការនៃជីវិត និងសេចក្ដីសង្គ្រោះ . . . ។ វិធីល្អជាងគេបំផុតនៅក្នុងពិភពលោក ដើម្បីបង្ហាញសេចក្ដីស្រឡាញ់របស់យើង ចំពោះអ្នកជិតខាងយើង គឺការឆ្ពោះ

កំណត់ចំណាំ

ទោមុខ និងប្រកាសពីដំណឹងល្អនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានផ្តល់ឱ្យយើងនូវចំណេះដឹងយ៉ាងច្បាស់ ពីទេវភាពនៃផែនការ។ (ក្នុង Conference Report, ខែមេសា ឆ្នាំ1927, 175–76)។

### ប្រធាន ជត អាលប៊ើត ស៊្មីធ (1945–1951)

"នោះជាបេសកកម្មរបស់អ្នក បងប្អូនប្រុសស្រីនៃសាសនាចក្រអើយ នោះជាការទទួលខុសត្រូវរបស់បងប្អូន។ បងប្អូនបានទទួល ដោយមិនបានបង់ថ្លៃ ហើយព្រះវរបិតាសួគ៌របស់យើង នឹងសង្ឃឹមថា បងប្អូននឹងចែកចាយទៅបុត្រាបុត្រីដទៃទៀតរបស់ទ្រង់ នូវសេចក្តីពិតដ៏រុងរឿងទាំងនេះ" (*Sharing the Gospel with Others*, ជ្រើសរើសដោយ Preston Nibley [1948], 213)។

"យើងអាចសម្រេចដល់ការលើកតំកើងរបស់យើង នៅក្នុងនគរសេឡេស្ទាលបាន មានតែតាមលក្ខខ័ណ្ឌដែលយើងចែកចាយជាមួយ កូនចៅដទៃទៀតរបស់ព្រះវរបិតារបស់យើង នូវពរជ័យនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និងរក្សាព្រះបញ្ញត្តិ ដែលនឹងធ្វើឱ្យជីវិតយើងបរិបូរណ៍នៅទីនេះ និងក្រោយមកប៉ុណ្ណោះ" (*Sharing the Gospel with Others*, 190)។

### ប្រធាន ដាវីឌ អូ មិកឃេ (1951–1970)

"រាល់សមាជិក . . . ជាអ្នកផ្សព្វផ្សាយសាសនា!" (ក្នុង Conference Report ខែមេសា ឆ្នាំ1959, 122)។

"គ្រីស្ទានពិតប្រាកដ បង្ហាញសេចក្តីស្រឡាញ់តាមរយៈសកម្មភាព។ គ្មានវិធីណាដែលប្រសើរជាងនេះ ដើម្បីបង្ហាញសេចក្តីស្រឡាញ់ ដល់ព្រះ ជាងការបង្ហាញសេចក្តីស្រឡាញ់ដោយគ្មានចិត្តកំណាញ់ ដល់មនុស្សនៅជុំវិញយើងខ្លួនយើងឡើយ។ នេះជាវិញ្ញាណនៃកិច្ចការអ្នក ផ្សព្វផ្សាយសាសនា" (*Gospel Ideals* [1954], 129) ។

### ប្រធាន យ៉ូសែប ហ្វីលឌីង ស៊្មីធ (1907–1972)

"យើងបានធ្លាប់ឮហើយថា យើងទាំងអស់គ្នាជាអ្នកផ្សព្វផ្សាយសាសនា។ រាល់សមាជិក . . . គឺជា ឬគួរតែជាអ្នកផ្សព្វផ្សាយសាសនា . . . ដោយជាសមាជិកនៃសាសនាចក្រ យើងបានធ្វើកិច្ចសន្យាចំពោះខ្លួនឯងថា នឹងធ្វើឱ្យដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទរីកចំរើនឡើង យើងក្លាយជាអ្នកផ្សព្វផ្សាយសាសនា។ នោះជាផ្នែកមួយនៃការទទួលខុសត្រូវ នៃសមាជិកគ្រប់រូបនៃសាសនាចក្រ" (*Take Heed to Yourselves* [1971], 27–28)។

### ប្រធាន ហារ៉ូល ប៊ី លី (1972–1973)

"កិច្ចការអ្នកផ្សព្វផ្សាយសាសនា ជាការបង្រៀនតាមផ្ទះចំពោះអ្នកទាំងឡាយណាដែលមិនមែនជាសមាជិកនៃសាសនាចក្រ ហើយការបង្រៀនតាមផ្ទះ គឺគ្មានអ្វីតិចជាង ឬច្រើនជាងកិច្ចការផ្សព្វផ្សាយសាសនាចំពោះសមាជិក នៃសាសនាចក្រនោះទេ" (*Improvement Era*, ខែធ្នូ 1964, 1078)។

### ប្រធាន ស្ពែនស៊ើ ដបិលយូ ឃីមបល (1973–1985)

"ឥឡូវនេះជាពេលនៅក្នុងតារាងពេលវេលារបស់ព្រះអម្ចាស់ ដើម្បីនាំយកដំណឹងល្អទៅឱ្យកាន់តែឆ្ងាយជាង ធ្លាប់មានពីមុនមក . . .។ មានមនុស្សជាច្រើនក្នុងពិភពលោកនេះ កំពុងតែស្រែកយំទោះជាស្គាល់ និងមិនស្គាល់ 'ចូរមក . . . ហើយជួយយើង'។ គាត់ប្រហែលជាអ្នកជិតខាងរបស់អ្នក។ នាងប្រហែលជាមិត្តរបស់អ្នក។ គាត់ប្រហែលជាសាច់ញាតិរបស់អ្នក។ នាងប្រហែលជាមនុស្សម្នាក់ដែលអ្នកទើបតែជួប កាលពីម្សិលមិញ។ ប៉ុន្តែយើងមានអ្វីដែលពួកគេត្រូវការ។ ចូរយើងមានសេចក្តីក្លាហានជាថ្មី ដែលចេញមកពីការ សិក្សា និងការអធិស្ឋាន របស់អ្នកដូចពេត្រុសបានធ្វើ 'ឥឡូវនេះ ឱព្រះអម្ចាស់អើយ . . . សូមប្រទានឱ្យអ្នកបំរើទ្រង់ បានផ្សាយព្រះ បន្ទូលដោយសេចក្តីក្លាហានដោយពេញលេញ' (កិច្ចការពួកសាវក 4:29)" (*Teachings of Spencer W. Kimball* [1982], 546) ។

### ប្រធាន អែសរ៉ា ថេហ្វ បែនសឹន (1985–1994)

"យើងត្រូវចែកចាយដំណឹងល្អជាមួយអ្នកដទៃ។ នោះជាការទទួលខុសត្រូវរបស់យើង—រាល់សមាជិកគ្រប់រូបជាអ្នកផ្សព្វផ្សាយសាសនា។ ដែលវាជាការហៅបំរើពីព្យាការីនៃព្រះ . . . ។

" . . . សមាជិកធ្វើកិច្ចការអ្នកផ្សព្វផ្សាយសាសនា នេះជាគន្លឹះដ៏អស្ចារ្យមួយក្នុងចំណោមគន្លឹះដ៏អស្ចារ្យជាច្រើន ចំពោះការរីកចំរើននៃ បុគ្គលម្នាក់ៗ នៃសមាជិករបស់យើង។ វាជាការជឿជាក់របស់ខ្ញុំថា សមាជិកធ្វើកិច្ចការអ្នកផ្សព្វផ្សាយសាសនា នឹងធ្វើឱ្យជីវភាព ខាងវិញ្ញាណរីកចំរើនឡើងនៅក្នុងវួដជាច្រើន នៅទីណាដែលកិច្ចការនេះអាចអនុវត្តបាន" (*Teachings of Ezra Taft Benson*, 208–9) ។

កំណត់ចំណាំ

### ប្រធាន ហោវើដ ដបិលយូ ហាន់ធើរ (1994–1995)

"ប្រាកដណាស់ ការនាំយកដំណឹងល្អទៅគ្រប់ទាំងសាសន៍ គ្រប់ពូជអំបូរ គ្រប់ភាសា គឺជាការទទួលខុសត្រូវតែមួយដ៏សំខាន់បំផុតដែលយើងមាននៅក្នុងជីវិតរមែងស្លាប់នេះ . . . ។ យើងបានមានឯកសិទ្ធិដ៏ពិសេសដើម្បីចាប់កំណើតនៅថ្ងៃចុងក្រោយនេះ ដើម្បីប្រឆាំងនឹងសម័យកាន់កាប់ត្រួតត្រាមុន ដើម្បីជួយនាំយកដំណឹងល្អទៅកាន់ទូទាំងផែនដី" ("Walls of the Mind," *Ensign*, ខែកញ្ញា ឆ្នាំ 1990, 10) ។

"តើដង្វាយធួនមានទំនាក់ទំនងអ្វី នឹងកិច្ចការអ្នកផ្សព្វផ្សាយសាសនា? រាល់ពេលដែលយើងមានបទពិសោធន៍ទទួលពរជ័យដែលបានមកពីដង្វាយធួន នៅក្នុងជីវិតយើង នោះយើងមិនអាចជួយបានទេ តែយើងមានក្តីព្រួយបារម្ភចំពោះសុខុមាលភាពអ្នកដទៃ ប៉ុន្តែយើងមិនអាចជួយបាន . . . ។ ការចង្អុលបង្ហាញដ៏អស្ចារ្យមួយនៃការផ្លាស់គំនិតរបស់មនុស្សម្នាក់ គឺបំណងប្រាថ្នាដើម្បីចែកចាយដំណឹងល្អជាមួយនឹងអ្នកដទៃ។ ("The Atonement and Missionary Work," seminar for new mission presidents, ខែមិថុនា ឆ្នាំ 1994) ។

### ប្រធាន គរដិន ប៊ី ហ៊ិងឃ្លី (1995–)

"យើងមកទីនេះ ដើម្បីជួយព្រះវរបិតារបស់យើងនៅក្នុងកិច្ចការ និងភាពរុងរឿងរបស់ទ្រង់ ដើម្បីឱ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស (សូមមើល ម៉ូសេ 1:39 )។ កាតព្វកិច្ចរបស់អ្នក គឺសំខាន់ស្មើនឹងការទទួលខុសត្រូវរបស់អ្នក ដូចជាកាតព្វកិច្ចរបស់ខ្ញុំក្នុងការទទួលខុសត្រូវរបស់ខ្ញុំផងដែរ" (នៅក្នុង Conference Report, ខែមេសា ឆ្នាំ1995, 94 ឬ *Ensign*, ខែឧសភា ឆ្នាំ 1995, 71)។

"សូមឱ្យមានការលើកទឹកចិត្ត ផ្ទែកសម្បជញ្ញៈក្នុងបេះដូងសមាជិកម្នាក់ៗ អំពីសក្តានុពលរបស់ពួកគេផ្ទាល់ ដើម្បីនាំអ្នកដទៃមកកាន់ចំណេះដឹងនៃសេចក្តីពិត។ សូមឱ្យពួកគេប្រឹងប្រែងលើកិច្ចការនោះ ។ សូមឱ្យពួកគេអធិស្ឋានដោយអស់ពីដួងចិត្តអំពីកិច្ចការនេះ" ("Find the Lambs, Feed the Sheep," *Ensign*, ខែមេសា ឆ្នាំ1999, 106)។

# គំនិតសំរាប់ការសិក្សា និងការអនុវត្ត

កំណត់ចំណាំ

## ការសិក្សាផ្ទាល់ខ្លួន

- ចូររៀបចំការនិយាយ រយះពេលពីរនាទីអំពីសំនួរមួយនៃសំនួរ នៅពេលចាប់ផ្តើមនៃជំពូកនេះ។ ចូរត្រៀមខ្លួន ដើម្បីចែកចាយការនិយាយរបស់អ្នក ជាមួយនឹងដៃគូអ្នក ឬអ្នកផ្សព្វផ្សាយសាសនាដទៃទៀត នៅក្នុងការប្រជុំមណ្ឌល។

- ចូរសួរដល់អ្នកផ្លាស់គំនិតថ្មី ឱ្យប្រាប់ពីរឿងផ្លាស់គំនិតរបស់ពួកគេ។ តើអ្វីបានជួយពួកគេឱ្យមាន "សេចក្តីជំនឿ ចំពោះការកែប្រែចិត្ត" (អាលម៉ា 34:17)? តើហេតុអ្វីបានជាពួកគេសំរេចចិត្តទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់? តើពួកគេ មានអារម្មណ៍បែបណា ក្នុងការក្លាយជាសមាជិកថ្មី នៅក្នុងសាសនាចក្រ? តើអ្នកផ្សព្វផ្សាយសាសនាអាចបំរើពួកគេឱ្យកាន់តែប្រសើរជាងនោះ ដោយរបៀបណា?

- ចូរពិចារណាពីអត្ថន័យ ដើម្បីផ្សាយប្រាប់ពីការប្រែចិត្ត (សូមមើល យ៉ាកុប 3:12, គ និង ស 1:4, 38:41, 63:57–58, 88:81, 112:5, អេសេគាល 3:17–21, 33:1–12)។ ចូរសរសេរជាពាក្យផ្ទាល់ខ្លួនរបស់អ្នកថា តើវាមានន័យយ៉ាងណា និងតើអ្នកអាចធ្វើវាដោយរបៀបណា។

- ចូរអាន មរមន 8 និងម៉ូរ៉ូណៃ 1 និង 10។ កាលអ្នកអានវា សូមសួរទៅខ្លួនឯងថាះ "តើអ្វីទៅដែលជាក្តីសង្ឃឹមរបស់ ម៉ូរ៉ូណៃ ចំពោះជំនាន់របស់យើង? តើគាត់ចង់ឱ្យយើងធ្វើអ្វីជាមួយនឹង ព្រះគម្ពីរមរមន? តើខ្ញុំអាចនិយាយអ្វីទៅម៉ូរ៉ូណៃ បើសិនជាខ្ញុំមានឱកាសនិយាយជាមួយគាត់? សូមកត់នូវរាល់គំនិតរបស់អ្នក នៅក្នុងសៀវភៅសិក្សារបស់អ្នក។

- ចូរគិតពិចារណាអំពីព្រឹត្តិការណ៍នៅក្នុងជីវិតរបស់អ្នក ដែលបានពង្រឹងសក្ខីយភាពរបស់អ្នក អំពីយ៉ូសែប ស៊្មីធ និងការស្តារឡើងវិញ។ បន្ទាប់មកចូរឆ្លើយនឹងសំនួរនេះះ តើអ្វីបានជួយអ្នកឱ្យដឹងថា ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ បានយាងមកជួបយ៉ូសែប ស៊្មីធ?

## ការសិក្សាជាមួយដៃគូ

- ចូរប្រាប់គ្នា ទៅវិញទៅមក អំពីចំលើយនៃ សំនួរនៅក្នុងជំពូក "ចូរពិចារណាការណ៍នេះ" នៅខាងដើមជំពូក។

- ចែកចាយជាមួយគ្នា ទៅវិញទៅមក អំពីអ្វីដែលជាសេចក្តីសង្ឃឹម និងបំណងប្រាថ្នារបស់អ្នក ចំពោះបេសកកម្មរបស់អ្នក នៅពេលដែលអ្នកទទួលបានការហៅបំរើបេសកកម្មរបស់អ្នក។ តើដោយសារវិធីអ្វីដែលបទពិសោធន៍របស់អ្នក បានរីកលូតលាស់ ដល់ចំណុច ដែលអ្នកបានរំពឹងទុក? តើអ្នកអាចបំពេញនូវក្តីរំពឹងនេះដោយរបៀបណា?

- ចូរអាន និងពិភាក្សា "ការបំរើ" នៅក្នុង Guide to the Scriptures ។

- ចូរជ្រើសរើសអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យមួយក្នុង ចំណោមអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យដូចខាងក្រោមនេះ ហើយចូរអានសេចក្តីយោងដូចបានសរសេរ។ ពេលដែលអ្នកអាន ចូរពិភាក្សាពីរបៀបអ្នកផ្សព្វផ្សាយសាសនាម្នាក់នេះ (1)បាន យល់នឹងបានតាំងចិត្ត ចំពោះការហៅបំរើបេសកកម្មរបស់គាត់ (2) ការបង្ហាញអត្តចរិត និងបំណងប្រាថ្នារបស់គាត់ចំពោះកិច្ចការ និង (3)ជួយអ្នកដទៃឱ្យទទួលយកដំណឹងល្អ។

| | | |
|---|---|---|
| អាលម៉ា (ម៉ូសាយ 18) | នីហ្វៃ និងលីហៃ (ហេលេមិន 5) | ប៉ុល (កិច្ចការពួកសាវក 16) |
| អើរ៉ុន (អាលម៉ា 22, 23:1–6) | ពេត្រុស (កិច្ចការពួកសាវក 2) | |

- ចូរជ្រើសរើសទំនុកតំកើងព្រះមួយអំពីការស្តារឡើងវិញ ដូចជា "ព្រះវិញ្ញាណនៃព្រះ" "យើងសូមអរគុណព្រះអង្គចំពោះ ព្យាការី" ឬ "ការអធិស្ឋានដំបូងរបស់ យ៉ូសែប ស៊្មីធ"។ ចូរអាន ឬច្រៀងទំនុកដំកើងព្រះ។ ពិភាក្សាពីអត្ថន័យនៃពាក្យពេជន៍ ទាំងនោះ។

- ចូរអានជាមួយគ្នានូវពាក្យ "សេចក្តីជំនឿ" "ការប្រែចិត្ត" ពិធីបុណ្យជ្រមុជទឹក, ទទួលបុណ្យជ្រមុជទឹក" និង "ព្រះវិញ្ញាណបរិសុទ្ធ" នៅក្នុង Guide to the Scriptures។ ចូរអាននិងពិភាក្សា នូវរាល់សេចក្តីយោងនៃខព្រះគម្ពីរទាំងអស់ នៅក្នុងការ ផ្តើមទីមួយៗ។

- ចូរអានជាមួយគ្នា "សម័យកាន់កាប់ត្រួតត្រា" នៅក្នុង Guide to the Scriptures។ ហើយចូរអាន និងពិភាក្សា ផងដែរ អំពីគោលលទ្ធិ និងសេចក្តីសញ្ញា 136:37។

កំណត់ចំណាំ

## ការប្រជុំមណ្ឌល និងសន្និសីទហ្សូន

- ចូរអញ្ជើញសមាជិកដែលទើបផ្លាស់គំនិតថ្មីៗ ពីរទៅបីនាក់ ដើម្បីចែកចាយបទពិសោធន៍នៃការផ្លាស់គំនិតរបស់ពួកគេ។ តើពួកគេមានអារម្មណ៍យ៉ាងណាចំពោះអ្នកផ្សព្វផ្សាយសាសនា? អំពីអ្វីដែលអ្នកផ្សព្វផ្សាយសាសនាបានបង្រៀន? អំពីការតាំងចិត្ត ? តើអ្វីទៅដែលបានមានឥទ្ធិពលខ្លាំងបំផុតចំពោះ ការផ្លាស់គំនិតរបស់ពួកគេ?

- ចូរអញ្ជើញអ្នកដឹកនាំបព្វជិតភាពម្នាក់ ឱ្យនិយាយទៅអ្នកផ្សព្វផ្សាយសាសនា អំពីឱកាស និងការលំបាកនៃការកសាងសាសនាចក្រនៅក្នុងតំបន់របស់អ្នក។

- ចូរអាន អាលម៉ា 18 ហើយពិភាក្សាសំណួរទាំងនេះ៖ តើឡាម៉ូណៃមានអារម្មណ៍យ៉ាងណា នៅពេលចាប់ផ្តើមរឿង? តើពួកគេបានផ្លាស់ប្តូរដោយរបៀបណា? តើមនុស្សម្នាក់ត្រូវមានអារម្មណ៍បែបណា ដើម្បីទទួលបានពរជ័យនៃដំណឹងល្អ? ចូរអាន អាលម៉ា 34:15–16 ហើយចូរប្រៀបធៀបវា ជាមួយនឹងរឿងរបស់ឡាម៉ូណៃ។ តើដង្វាយធួនរបស់ព្រះគ្រីស្ទអាចជួយយើងឱ្យមានសេចក្តីមេត្តាករុណាដោយរបៀបណា?

- ចូរពិភាក្សា ពីអត្ថន័យ នៃអ្នកផ្សព្វផ្សាយសាសនាដែលប្រកបដោយជោគជ័យ។ ចូរអញ្ជើញ អ្នកផ្សព្វផ្សាយសាសនាឱ្យផ្តល់នូវគំរូនៃការទទួលជោគជ័យជាក់លាក់មួយ។

- ចូរបែងចែកអ្នកផ្សព្វផ្សាយសាសនា ចេញជាបីក្រុម។ ចាត់ឱ្យក្រុមមួយអាន កិច្ចការពួកសាវក 2:36–38 (ពេត្រុស), ក្រុមមួយទៀតអាន កិច្ចការពួកសាវក 1:25–33 (ប៉ុល) ហើយក្រុមចុងក្រោយឱ្យអាន ម៉ូសាយ 18:8–11 (អាលម៉ា)។ សួរទៅក្រុមនីមួយៗ ឱ្យឆ្លើយនឹងសំនួរ ”តើអ្នកផ្សព្វផ្សាយនេះ បានធ្វើអ្វីដើម្បី ជួយអ្នកដទៃឱ្យបង្កើន សេចក្តីជំនឿនៅក្នុងព្រះគ្រីស្ទ ប្រែចិត្ត និងទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់?” ចូរពិភាក្សាពីអ្វីដែលអ្នកផ្សព្វផ្សាយសាសនាបានរៀនពីរឿងទាំងនេះ ដែលអាច ជួយពួកគេឱ្យអនុវត្តសេចក្តីជំនឿ នៅពេលដែលអញ្ជើញមនុស្សឱ្យប្រែចិត្ត និងទទួលបុណ្យជ្រមុជទឹក និងទទួលអំណោយ ទាននៃព្រះវិញ្ញាណ បរិសុទ្ធ?

- បីបួនថ្ងៃពីមុនការប្រជុំ ចូរចាត់តាំងឱ្យអ្នកផ្សព្វផ្សាយសាសនាមួយចំនួន ឱ្យគិតនិងពិចារណា សំណួរមួយចំនួនដែល ជ្រើសរើសចេញពី “ចូរពិចារណាការណ៍នេះ” នៅដើមជំពូក។ ចូរសួរអ្នកផ្សព្វផ្សាយសាសនានីមួយៗ ឱ្យរៀបចំការនិយាយរយៈ ពេលពីរទៅបីនាទី ចំពោះសំណួរដែលបានចាត់តាំងដល់ពួកគេ។ កំឡុងពេលការប្រជុំមណ្ឌល ឬសន្និសីទហ្សូន អនុញ្ញាតឱ្យអ្នកផ្សព្វផ្សាយសាសនាឱ្យឡើងនិយាយ។ បន្ទាប់ពីការនិយាយ ចូរពិភាក្សាពីអ្វីដែលពួកគេបានរៀន និងអំពីរបៀបដែល ពួកគេអាចប្រើវានៅក្នុងកិច្ចការអ្នកផ្សព្វផ្សាយសាសនារបស់ពួកគេ។

- ចូរបែងចែកអ្នកផ្សព្វផ្សាយសាសនាចេញជាបួនក្រុម។ ចូរសួរក្រុមនីមួយៗ ឱ្យសរសេរអំពីការពិត សេចក្តីសញ្ញា និង ពិធីការផ្សេងៗ ដែលពួកគេអាចធ្វើ ដែលបានស្តារឡើងវិញ និងបានបើកសម្តែងតាមរយៈព្យាការីយ៉ូសែប ស៊្មីធ។ ចូរឱ្យក្រុមនីមួយៗចែកចាយពីលទ្ធផលរបស់ពួកគ។ ចូរអញ្ជើញអ្នកផ្សព្វផ្សាយសាសនាឱ្យចែកចាយ ពីសេចក្តីពិតដែលបានបើកសម្តែងតាមរយៈការ ស្តារឡើងវិញ ដែលមានឥទ្ធិពលចំពោះជីវិតរបស់ពួកគេ។

## ប្រធានបេសកកម្ម

- អំឡុងពេលកិច្ចសម្ភាសន៍ សួរឱ្យអ្នកផ្សព្វផ្សាយសាសនា ចែកចាយជាមួយអ្នកៈ
  - ទីបន្ទាល់របស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ទ។
  - ទីបន្ទាល់របស់ពួកគេអំពីដំណឹងល្អ ដែលបានស្តារឡើងវិញ និងអំពីបេសកកម្មរបស់យ៉ូសែប ស៊្មីធ។
  - ទីបន្ទាល់អំពីព្រះគម្ពីរមរមន។
  - គំនិតរបស់ពួកគេអំពី គោលបំណងរបស់ពួកគេក្នុងនាមជា អ្នកផ្សព្វផ្សាយសាសនាមួយរូប។

- អញ្ជើញអ្នកផ្សព្វផ្សាយសាសានា ឱ្យសរសេរនៅក្នុងសៀវភៅសិក្សារបស់ពួកគេ ពីអ្វីដែលពួកគេមានអារម្មណ៍នោះគឺជាគោលបំណងនៃបេសកកម្មរបស់ពួកគេ។ នៅក្នុងកិច្ចសម្ភាសន៍ ចូរសួរឱ្យពួកគេ ចែកចាយអ្វីដែលពួកគេបានសរសេរ។

- ផ្ញើលិខិតអបអរសាទរមួយច្បាប់ទៅសមាជិកថ្មីម្នាក់។



# តើខ្ញុំអាចសិក្សា និងរៀបចំការបង្រៀន ដែលប្រកប ដោយប្រសិទ្ធភាពបានយ៉ាងដូចម្ដេច?

កំណត់ចំណាំ

### ចូរពិចារណាចំណុចនេះ

- តើហេតុអ្វីសំខាន់ដើម្បីសិក្សាដំណឹងល្អ?
- តើការសិក្សារបស់ខ្ញុំនឹងមានឥទ្ធិពលទៅលើអ្នកទាំងឡាយណា ដែលខ្ញុំបង្រៀនបានយ៉ាងដូចម្ដេច?
- ហេតុអ្វីខ្ញុំត្រូវបន្តរក្សាទុកក្នុងគំនិត នូវគោលលទ្ធិនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដូច្នេះ?
- តើខ្ញុំអាចរៀនដោយមានប្រសិទ្ធភាព អំពីគោលលទ្ធិ នៃការសាងឡើងវិញនូវដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និងរៀបចំ ដើម្បីបង្រៀនអ្នកដទៃយ៉ាងដូចម្ដេច?
- តើខ្ញុំអាចធ្វើឱ្យការសិក្សាផ្ទាល់ខ្លួន និងជាដៃគូបានរីកចំរើនដោយរបៀបណា?

ព្រះអម្ចាស់មានព្រះបន្ទូលថា មុនពេលយើងប្រកាសព្រះបន្ទូលរបស់ទ្រង់ យើងគួរខំព្យាយាម ដើម្បីឱ្យបានព្រះបន្ទូល របស់ទ្រង់ជាមុនសិន ហើយខណៈនោះ អណ្ដាតរបស់យើងនឹងបានស្រាយ ពេលនោះបើសិនជាយើងមានប្រាថ្នា នោះយើង នឹងបានព្រះវិញ្ញាណរបស់ទ្រង់ និងព្រះបន្ទូលរបស់ទ្រង់ ព្រះចេស្ដានៃព្រះ ដើម្បីបញ្ចុះបញ្ចូលមនុស្សលោក (សូមមើលគ និងស 11:21)។ ដើម្បីអោយការបង្រៀនប្រកបដោយប្រសិទ្ធភាព អ្នកត្រូវការមានចំណេះដឹងខាងវិញ្ញាណ។ ចំពោះអ្នក ដើម្បីឱ្យបានរីក ចំរើននៅក្នុងដំណឹងល្អ ហើយស្ថិតនៅលើផ្លូវ ដែលនាំទៅរកជីវិតអស់កល្បជានិច្ច អ្នកត្រូវការពង្រីកទំលាប់សិក្សាដំណឹងល្អ (សូមមើល គ និង ស 131:6)។ ទំលាប់ការសិក្សាទាំងឡាយ ដែលអ្នកបានពង្រីក ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ ហើយនឹងប្រទានពរដល់អ្នក និងជួយអ្នកទាំងឡាយណា ដែលអ្នកបង្រៀនឱ្យបង្កើនសេចក្ដីជំនឿនៅក្នុងព្រះអង្គសង្គ្រោះ។

ការសិក្សាដែលប្រកបដោយប្រសិទ្ធភាពជាប្រចាំ ត្រូវតែចាប់ផ្ដើមដោយការអធិស្ឋានជានិច្ច។ ការសិក្សាគឺជាទង្វើ នៃជំនឿ ដែលតំរូវឱ្យប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួន។ អ្នកផ្សព្វផ្សាយសាសនាជាច្រើន ជួបនឹងការពិបាក ថាតើត្រូវធ្វើយ៉ាងណាដើម្បីឱ្យ ការសិក្សាមានប្រសិទ្ធភាព។ អ្នកខ្លះពឹងផ្អែកយ៉ាងខ្លាំងទៅលើអ្នកដទៃ និងកម្មវិធីដែលបានណែនាំ ដើម្បីប្រាប់ពួកគេថាត្រូវសិក្សា អ្វីខ្លះ និងដោយរបៀបណា។ ការរៀនសូត្រមកពីគ្រូបង្រៀនល្អម្នាក់ គឺជាការសំខាន់ណាស់ ប៉ុន្តែវានឹងជាការសំខាន់ជាងសំរាប់អ្នក ក្នុងការយល់អំពីបទពិសោធន៍នៃការរៀនសូត្រ ដោយខ្លួនអ្នកផ្ទាល់។ ការទទួលបានលទ្ធផលល្អមកពីការសិក្សា នោះអាស្រ័យទៅលើការមានបំណងយ៉ាងខ្លាំងក្លា ទៅលើការរៀន ការសិក្សាដោយ“ចិត្តស្មោះស” (ម៉ូរ៉ូណៃ 10:4) “កំពុងស្រេកឃ្លាន សេចក្ដីសុចរិត” (ម៉ាថាយ 5:6) និងការស្រាវជ្រាវរកចំលើយ សំរាប់សំនួរ និងកង្វល់របស់សាសនាគន់ការីរបស់អ្នក។

កំណត់ចំណាំ

### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

ចូរមើលរូបភាពនៃយ៉ូសែប ស្ម៊ីធនៅលើទំព័រខាងមុខ។ សូមអានប្រវត្តិ—យ៉ូសែប ស្ម៊ីធ1ៈ11–13។ សូមអានសំនួរដូចខាងក្រោម នៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក។

- តើការអាន និងការពិចារណារបស់យ៉ូសែប ស្ម៊ីធ អំពី យ៉ាកុប 1ៈ5 បានទាំឱ្យលោកទទួលវិវរណៈដោយរបៀបណា?
- តើការសិក្សារបស់លោកបានជះឥទ្ធិពលអ្វីខ្លះ ដល់មនុស្សនៅជំនាន់ក្រោយ?
- តើការសំរេចចិត្តរបស់លោកដើម្បីសិក្សា និងស្រាវជ្រាវមានឥទ្ធិពលអ្វីខ្លះ នៅក្នុងជីវិតរបស់អ្នក?
- តើការសិក្សាដំណឹងល្អរបស់អ្នកមានឥទ្ធិពលយ៉ាងណា នៅក្នុងជីវិតរបស់អ្នក?

### ការសិក្សាព្រះគម្ពីរ

**តើព្រះអម្ចាស់ចង់ឱ្យយើងចាប់ផ្ដើមការសិក្សាដំណឹងល្អដោយរបៀបណា?**

នីហ្វៃទី2 4ៈ15–16
គ និងស 58ៈ26–28
គ និងស 88ៈ118
នីហ្វៃទី2 32ៈ3

## រៀនដោយព្រះវិញ្ញាណបរិសុទ្ធ



ការសិក្សាដំណឹងល្អរបស់អ្នក នឹងមានឥទ្ធិពលបំផុត នៅពេលអ្នកត្រូវបានបង្រៀនដោយព្រះវិញ្ញាណបរិសុទ្ធ។ ចូរចាប់ផ្ដើមការសិក្សាដំណឹងល្អ ដោយការអធិស្ឋាន ដើម្បីឱ្យមានព្រះវិញ្ញាណបរិសុទ្ធជានិច្ច ដើម្បីជួយអ្នកអោយចេះ។ ទ្រង់នឹងនាំមកនូវចំណេះដឹង និងការផ្លាស់គំនិត ដែលនឹងប្រទានពរដល់ជីវិតអ្នក ហើយអនុញ្ញាតឱ្យអ្នកប្រទានពរ ដល់ជីវិតរបស់អ្នកដទៃ។ ជំនឿរបស់អ្នក នៅក្នុងព្រះយេស៊ូវគ្រីស្ទ នឹងរីកចំរើន។ ចំណង់របស់អ្នក ដើម្បីប្រែចិត្ត និងភាពរីកចំរើននឹងបានរីកធំធាត់ឡើង។

ការសិក្សារបៀបនេះ រៀបចំអ្នកសំរាប់ការបំរើ ផ្ដល់ការកំសាន្ដចិត្ត ដោះស្រាយបញ្ហា ហើយផ្ដល់ឱ្យអ្នកនូវកម្លាំង ដើម្បី កាន់ខ្ជាប់ដល់ចុងបំផុត។ ការសិក្សាដំណឹងល្អដែលប្រកបដោយជោគជ័យតំរូវឱ្យមានចំណង់ និងសកម្មភាព។ “ត្បិតអ្នកណា ដែលព្យាយាមរកនឹងឃើញ ហើយការអាថ៌កំបាំងទាំងឡាយនៃព្រះនឹងបានបង្ហាញដល់គេ គឺដោយព្រះចេស្ដា នៃព្រះវិញ្ញាណបរិសុទ្ធ ទោះនៅជំនាន់នេះក៏ដូចជានៅជំនាន់ដើម” (នីហ្វៃទី1 10ៈ19)។ ដូចជាលោកអេណុស នៅពេលអ្នកស្រេកឃ្លាន ដើម្បីដឹងព្រះបន្ទូលនៃជីវិតដ៏អស់កល្បជានិច្ច និងនៅពេលអ្នកអនុញ្ញាតឱ្យពាក្យទាំងនេះ “ឱ្យជ្រួតជ្រាប នៅក្នុងដួងចិត្តឱ្យរបស់អ្នក ”(អេណុស1ៈ3) ព្រះវិញ្ញាណបរិសុទ្ធ នឹងបើកគំនិត និងចិត្តរបស់អ្នកទៅរកពន្លឺដ៏ចិញ្ចាចចិញ្ចែង និងការយល់ដឹង។

ការរៀនដំណឹងល្អ គឺជារបៀបនៃការទទួលវិវរណៈ (សូមមើល យ៉ាកុប 4ៈ8)។ ចំពោះអរលិវើរ ខោឌើរី ព្រះអម្ចាស់មានព្រះបន្ទូលថាៈ អរលិវើរពុំយល់ឡើយ អ្នកបានសន្និដ្ឋានថា យើងនឹងប្រទានឯកសិទ្ធិនេះដល់អ្នក កាលណាអ្នក ពុំបានយកគតិមកគិតសោះ ក្រៅពីសូមដល់យើង។ ប៉ុន្តែមើលចុះយើងប្រាប់អ្នកថា អ្នកត្រូវសិក្សាក្នុងគំនិតរបស់អ្នក រួចហើយត្រូវសូមដល់យើង បើសិនការណ៍នេះត្រឹមត្រូវ ហើយបើសិនជាត្រឹមត្រូវ នោះយើងនឹងបណ្ដាលអោយទ្រូង អ្នកខ្វល់ខ្វាញ់ខាងក្នុង ហេតុដូច្នេះហើយ អ្នកនឹងមានអារម្មណ៍ថា ការណ៍នោះត្រឹមត្រូវ”(គ និងស 9ៈ7–8)។ នៅពេលអ្នកសិក្សា ចូរយកចិត្តទុកដាក់ចំពោះគំនិត ដែលមកនៅក្នុងគំនិតរបស់អ្នក និងអារម្មណ៍ ដែលមានមកនៅក្នុងចិត្តរបស់អ្នក ជាពិសេសអំពីមនុស្សដែលអ្នកកំពុងបង្រៀន។

កំណត់ចំណាំ

**ការសិក្សាព្រះគម្ពីរ**

**តើតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងការជួយយើងរៀនអំពីដំណឹងល្អគឺជាអ្វី?**

| | | |
|---|---|---|
| នីហ្វៃទី2 32:5 | គ និងស 11:12–14 | យ៉ូហាន 16:13 |
| អាលម៉ា 5:45–46 | គ និងស 39:5–6 | កូរិនថូសទី1 2:9–14 |
| មរ៉ូណៃ 10:5 | យ៉ូហាន 14:26 | |

## ធ្វើតាមអ្វី ដែលអ្នករៀន

នៅពេលអ្នកមានអារម្មណ៍នៃសេចក្ដីអំណរ ដែលមកពីការយល់ដឹងអំពីដំណឹងល្អ អ្នកនឹងចង់អនុវត្តអ្វីដែលអ្នករៀន។ ចូរព្យាយាម រស់ នៅឱ្យសមទៅតាមការយល់ដឹងរបស់អ្នក។ ការធ្វើដូច្នោះនឹងពង្រឹងជំនឿ ចំណេះដឹង និងទីបន្ទាល់របស់អ្នក។ ការធ្វើសកម្មភាពទៅ លើអ្វីដែលអ្នកបានរៀន នឹងនាំមកនូវចំណេះដឹងបន្ថែម និងការកាន់ខ្ជាប់ការយល់ដឹង (សូមមើលយ៉ូហាន 7:17)។

នៅពេលអ្នករក្សាទុកក្នុងគំនិតនូវពាក្យនៃបទគម្ពីរ និងព្យាការីថ្ងៃចុងក្រោយដោយការសិក្សា និងជំនឿ ចំណង់របស់អ្នក ដើម្បីចែកចាយដំណឹងល្អ នឹងកើនឡើង។ អ្នកត្រូវបានសន្យាថា ព្រះវិញ្ញាណនឹងជួយអ្នកឱ្យដឹងនូវអ្វីដែលត្រូវនិយាយ នៅពេលអ្នកបង្រៀន។ ព្រះអម្ចាស់មានព្រះបន្ទូលថា ហើយចូរអ្នករាល់គ្នាកុំថប់ព្រួយទុកជាមុនពីអ្វី ដែលអ្នករាល់គ្នាត្រូវថានោះ ឡើយ ប៉ុន្ដែចូរក្សាទុកក្នុងគំនិតអ្នករាល់គ្នា អោយបន្តនូវព្រះបន្ទូលទាំងឡាយខាងជីវិតវិញ ហើយសេចក្ដីដែលត្រូវនិយាយ នឹងបានប្រទានដល់អ្នករាល់គ្នានៅចំម៉ោងនោះឯងនូវចំណែក ដែលនឹងបានវាល់ដល់មនុស្សគ្រប់រូប (គ និងស84:85)។

> *"ការយល់ដឹង គោលលទ្ធិពិត នឹងផ្លាស់ប្តូរអាកប្បកិរិយា និងឥរិយាបទ។ ការសិក្សាគោលលទ្ធិ នៃដំណឹងល្អ ទាំងឡាយនឹង អភិវឌ្ឍន៍ឥរិយាបទឱ្យបាន ប្រសើរឡើងឆាប់រហ័សជាងការសិក្សា អំពីឥរិយាបទ ដើម្បីអភិវឌ្ឍន៍ឥរិយាបទ។"*
>
> ប្រធាន ប៊ិយ ខេ ផាកកឺ
> "LITTLE CHILDREN," *ENSIGN*, ខែកញ្ញា ឆ្នាំ1986, 17។

**ការសិក្សាព្រះគម្ពីរ**

**តើបទគម្ពីរ បង្រៀនអ្វីខ្លះ អំពីការរៀនដំណឹងល្អ?**

| | | |
|---|---|---|
| នីហ្វៃទី1 10:17–19 | គ និងស 50: 19–22 | គ និងស 88:118 |
| គ និងស 11:21–22 | | |

## ការសិក្សា និងការរៀបចំ ដើម្បីបង្រៀនមេរៀន

មេរៀន (នៅក្នុងជំពូកទី3 ) មានផ្ទុកនូវសំនួរសំរាប់ធ្វើការសម្ភាសន៍បុណ្យជ្រមុជទឹក ការតាំងចិត្ត និងគោលលទ្ធិទាំងឡាយដែលអ្នកត្រូវបង្រៀន។ នៅក្នុងមេរៀន អ្នកនឹងរកបានយោបល់ដែលមានប្រយោជន៍ សំរាប់ការបង្រៀន។ ទោះយ៉ាងណាក៏ដោយ មេរៀនមិនបានប្រាប់អ្វីៗទាំងអស់ដែលអ្នកនឹងនិយាយ—ឬរបៀប ដើម្បីនិយាយនោះទេ។ ប៉ុន្តែអ្នកមានការទទួលខុសត្រូវដើម្បីយល់ដឹងអំពីមេរៀនអោយបានច្បាស់លាស់ និងបង្រៀនដោយព្រះវិញ្ញាណ តាមពាក្យសំដីរបស់អ្នកផ្ទាល់។ បង្រៀនដោយរបៀបនេះនឹងធ្វើឱ្យអ្នកដទៃពង្រឹង ជំនឿរបស់ពួកគេទៅក្នុងព្រះយេស៊ូវគ្រីស្ទ មានបំណងប្រែចិត្ត ហើយចូលទៅក្នុងសេចក្ដីសញ្ញាជាមួយព្រះ។

គ្រូបង្រៀនដែលមានប្រសិទ្ធភាព តែងតែរៀនពង្រីកចំណេះដឹង និងសមត្ថភាពរបស់ពួកគេជានិច្ច។ ថ្វីត្បិតតែ អ្នកនឹងមិនបង្រៀនទូវអ្វីៗដែលអ្នកដឹងអំពីគោលលទ្ធិ ការរីកចំរើនចំណេះដឹងរបស់អ្នក នឹងសាងទីបន្ទាល់ និងសមត្ថភាព របស់អ្នក ដើម្បីបង្រៀនដោយអំណាចខាងវិញ្ញាណ។ អ្នកនឹងដឹងថា អ្នកនឹងប្រើមេរៀន ដូចបានប៉ងទុក នៅពេលអ្នកៈ

- ស្វែងរក និងធ្វើតាមព្រះវិញ្ញាណ នៅពេលអ្នករៀបចំ និងបង្រៀនមេរៀន។
- ព្យាយាមសិក្សាជានិច្ច រក្សាទុក និងអនុវត្តគោលលទ្ធិនៅក្នុងជីវិតរបស់អ្នក។
- ធ្វើការជាមួយនឹងដៃគូរបស់អ្នក ដើម្បីធ្វើផែនការជាក់លាក់មួយ សំរាប់មនុស្សម្នាក់ៗ ដែលអ្នកបង្រៀន។
- ផ្ដោតទៅលើសារលិខិត និងគោលលទ្ធិសំខាន់ៗ ពេលអ្នកបង្រៀន។

កំណត់ចំណាំ

- កែប្រែលំដាប់លំដោយ រយៈពេល និងជំហាននៃមេរៀន ដើម្បីបំពេញសេចក្ដីត្រូវការនៃអ្នកទាំងឡាយណា ដែលអ្នកបង្រៀន។
- បង្រៀនជារឿយៗមកពីបទគម្ពីរមានការច្បាស់លាស់ និងមានការផ្លាស់ប្រែគំនិត។
- ចែកចាយទីបន្ទាល់អោយបានញឹកញាប់។
- ជួយអ្នកដទៃធ្វើ និងរក្សាការតាំងចិត្ត ដែលនឹងនាំទៅរកពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។

ការធ្វើនូវរឿងទាំងនេះនឹងធ្វើឱ្យអ្នកអាចជួយដល់អ្នកដទៃឱ្យទទួលបានទីបន្ទាល់នៃដំណឹងល្អ របស់ព្រះយេស៊ូវគ្រីស្ទ ដែលបានសាងឡើងវិញ។

នៅពេលអ្នកចាប់ផ្ដើមបេសកកម្មរបស់អ្នក អ្នកនឹងត្រូវរៀនអំពីការរៀបចំសារលិខិត និងត្រូវខិតខំរៀនជំនាញក្នុងការបង្រៀន ដែលចាំបាច់។ នៅពេលអ្នកទទួលបានបទពិសោធន៍ អ្នកនឹងចង់ អោយចំណេះដឹងរបស់អ្នកកាន់តែបានជ្រៅជ្រះ និងចង់ពង្រីក សមត្ថភាព ការបង្រៀនរបស់អ្នកថែមទៀត។ នៅពេលអ្នករៀបចំការណាត់ជួបបង្រៀន អ្នកនឹងចង់មានផែនការមេរៀនមួយ ដែលធ្វើឱ្យអ្នកបង្រៀន ដោយព្រះវិញ្ញាណ និងជួយអ្នកដទៃធ្វើ និងរក្សាការតាំងចិត្ត។ ការណែនាំនៅខាងក្រោម ត្រូវបានឱ្យជា យោបល់ថា អ្នកអាចអនុវត្តនៅក្នុងបេសកកម្មរបស់អ្នក។ ទោះជាយ៉ាងណាក៏ដោយ មិនត្រូវមានអារម្មណ៍ថា អ្នកត្រូវតែប្រើការណែនាំទាំងអស់នៅគ្រប់ស្ថានភាព។ ជំនួសពីលើនោះ អនុវត្តការណែនាំទាំងនេះឱ្យត្រូវនឹងសេចក្ដីត្រូវ ការរបស់អ្នក និងនៅពេល អ្នកត្រូវបាន ដឹកនាំដោយព្រះវិញ្ញាណ។ បើអ្នកកំពុងរៀនមេរៀនភាសាថ្មី ចូរអនុវត្តការណែនាំទាំងនេះ ជាភាសាជាតិរបស់អ្នក ដំបូងគេ ហើយ បន្ទាប់មកជាភាសានៅបេសកកម្មរបស់អ្នក។

- **ការផ្ដោតទៅលើការតាំងចិត្ត និងសំនួរសម្ភាសន៍ធ្វើពិធីបុណ្យជ្រមុជទឹក។** ចូរបង្រៀន ដើម្បីឱ្យមនុស្សនឹងធ្វើ ការតាំងចិត្ត និងរៀបចំសំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។ ចូរយល់អំពីសំនួរសម្ភាសន៍ធ្វើពិធីបុណ្យជ្រមុជទឹក និងការតាំងចិត្តសំរាប់ អ្នករៀនទីមួយៗ។ ចូរសិក្សាអំពីអ្វី ដែលនរណាម្នាក់គួរតែដឹង មានអារម្មណ៍ ហើយគួរតែធ្វើ ពីព្រោះតែ ការបង្រៀនរបស់អ្នក។ ចូរធ្វើការជាមួយនឹងដៃគូរបស់អ្នក ដើម្បីពន្យល់គោលការណ៍ទាំងនេះជាសំដីរបស់អ្នកផ្ទាល់ដោយភាព ច្បាស់លាស់ និងអំណាច។

- **រៀន និងអនុវត្តគោលលទ្ធិ។** គោលលទ្ធិគឺជាគ្រឹះ នៃមេរៀន។ ចូរសិក្សាដោយការអធិស្ឋានអំពី បទគម្ពីរ មេរៀន កូនសៀវភៅ “គំនិតសំរាប់បង្រៀន” និងសៀវភៅសំរាប់អ្នកផ្សព្វផ្សាយសាសនា ដើម្បីទទួលការយល់ដឹងអំពីគោលលទ្ធិឱ្យបានច្បាស់លាស់។ ចូរស្រាវជ្រាវឯកសារ ដែលគាំទ្រដល់គោលលទ្ធិ នៃមេរៀន។ តាំងចិត្តដើម្បីទន្ទេញចាំគោលការណ៍ នៃគោលលទ្ធិ។ អនុវត្តអ្វីដែល អ្នករៀន។ កត់ត្រាអ្វី ដែលអ្នករៀនទុកនៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក។ ចែកចាយអ្វី ដែលអ្នករៀនជាមួយនឹងអ្នក ផ្សព្វផ្សាយសាសនាដទៃទៀត។



- **រៀបចំ និងសង្ខេបអ្វីដែលអ្នករៀន។** ដើម្បី រៀបចំបង្រៀនគោលលទ្ធិឱ្យបានច្បាស់លាស់ និងដោយអំណាចខាងវិញ្ញាណ ត្រូវរៀបចំ និងសង្ខេបនូវអ្វីដែលអ្នកនឹងបង្រៀននៅក្នុង ផែនការមេរៀន។ ចូរផ្ដោតទៅលើគោលលទ្ធិ សំនួរសម្ភាសន៍ធ្វើពិធីបុណ្យ ជ្រមុជទឹក និងការតាំង ចិត្ត ដែលមាននៅក្នុងមេរៀន។ ពង្រីកផែនការមេ រៀនរបស់អ្នកជាមួយនឹងបទគម្ពីរ សំនួរ និងឧទាហរណ៍។ ទាំងនេះ គួរតែផ្លាស់ប្ដូរទៅតាម រយៈពេល នៃការណាត់ជួបបង្រៀនរបស់អ្នក។ អ្នកមិនគួរបង្កើតផែនការមេរៀនថ្មីទាំងស្រុង សំរាប់សាសនាគន់ការីម្នាក់ៗនោះទេ ប៉ុន្តែអ្នកគួរតែបន្តផុសខាត់ផែនការមេរៀនរបស់អ្នក ហើយកែខៃមេរៀន ឱ្យត្រូវនឹងសេចក្ដីត្រូវការរបស់អ្នកទាំងឡាយណា ដែលអ្នកបង្រៀន។ នៅពេលអ្នក បង្កើតផែនការមេរៀនជាលើកទីមួយ ចូរព្យាយាមធ្វើដោយសាមញ្ញ ហើយសង្ខេប។ ពង្រីកផែនការមេរៀនរបស់អ្នក នៅពេលអ្នកទទួលបានបទពិសោធន៍។

- **ផ្ដោតទៅលើសេចក្ដីត្រូវការ។** នៅពេលគោលលទ្ធិនៃដំណឹងល្អ អនុវត្តចំពោះមនុស្សគ្រប់រូប អ្នកគួរតែសម្រួលក្នុងការចូល ជួបបង្រៀនរបស់អ្នកឱ្យត្រូវនឹងសេចក្ដីត្រូវការរបស់អ្នកទាំងឡាយ ដែលអ្នកបង្រៀន។ នៅពេលអ្នកសិក្សាគោលលទ្ធិ និងបង្កើត

កំណត់ចំណាំ

ផែនការមេរៀន ចូរបញ្ជាក់អំពីតំបន់ ដែលអ្នកអាចកែសម្រួលការជួបនិយាយរបស់អ្នក ឱ្យត្រូវនឹងសេចក្តី ត្រូវការដ៏ចំបង។ ចូររំលឹកឡើងវិញ ហើយកែខៃការផ្លាស់ប្តូរទាំងនេះ នៅពេលអ្នករៀបចំការណាត់ជួប ជាក់លាក់។ សំគាល់អំពីការអញ្ជើញ នោះអ្នកនឹងរីកចំរើន។ ចូរផ្តោតទៅលើគោលដៅចុងក្រោយ ដើម្បីជួយអ្នកទាំងឡាយ ដែលអ្នកបង្រៀនឱ្យទទួលដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ដែលបានសាងឡើងវិញ តាមរយៈពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។

- **រៀបចំឆ្លើយសំនួរ។** ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ អ្នកនឹងជួបសំនួរជាច្រើន។ ចូរកត់ត្រាសំនួរទាំងនេះនៅក្នុង សៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក។ ចូរស្រាវជ្រាវបទគម្ពីរ និងសម្ភារៈផ្សេងទៀតសំរាប់ជួយឆ្លើយ។ អធិស្ឋាន ដើម្បីមានការយល់ដឹង។ កត់ត្រាចំលើយនៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក។ រំលឹកពីអ្វី ដែលអ្នករកបានជាមួយនឹងអ្នកផ្សព្វផ្សាយ សាសនាដទៃទៀត។ បញ្ចូលសំនួរដែលត្រូវបានសួរជារឿយៗ និងចំលើយទៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក សំរាប់ជាសេចក្តីយោង។

- **បង្រៀនមេរៀន។** ការបង្រៀន គឺជាឱកាសដ៏មានអំណាច ដើម្បីពង្រីកចំណេះដឹង និងសមត្ថភាពរបស់អ្នក។ នៅពេលអ្នករៀនគោលលទ្ធិ និងរៀបចំផែនការមេរៀន។ ចូរបង្រៀនដៃគូរបស់អ្នក និងអ្នកផ្សព្វផ្សាយសាសនាផ្សេងទៀត។ ចូរព្យាយាមពន្យល់តាមរបៀបថ្មី វិធីសាស្ត្រ បទពិសោធន៍ សំនួរ និងរបៀបអញ្ជើញថ្មីដល់អ្នកដទៃ ដើម្បីធ្វើការតាំងចិត្ត។ ចូរសុំជា គំនិត និងយោបល់អំពីការបង្រៀនរបស់អ្នក។

- **វិភាគអំពីការបង្រៀនរបស់អ្នក។** បន្ទាប់ពីស្ថានភាពនៃការបង្រៀនទាំងឡាយមក ចូរធ្វើការវិភាគថា តើអ្នកធ្វើបានល្អយ៉ាងណា។ តើអ្នកបានផ្តោតទៅលើគោលលទ្ធិដែរឬទេ? តើអ្នកអញ្ជើញឱ្យសាសនាគន់ការីប្រែចិត្ត ហើយតើធ្វើការតាំងចិត្ត និងគោរពតាមដែរឬទេ? តើអ្នកធ្វើការរៀបចំសាសនាគន់ការីសំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ដែរឬទេ? តើអ្នកប្រើសំនួរមានប្រសិទ្ធភាពដែរឬទេ? តើអ្នកបានចែកចាយទីបន្ទាល់របស់អ្នកដែរឬទេ? តើអ្នកបានសុំឱ្យពួកគេផ្តល់មនុស្សថ្មីដែរឬទេ? កែសំរួលផែនការមេរៀនរបស់អ្នកនៅពេលអ្នករីកចំរើន។

នៅពេលអ្នករៀនមេរៀន ចូរបន្តស្វែងរកចំណេះដឹងជ្រៅជ្រះអំពីគោលលទ្ធិ។ ធ្វើការដោយសកម្មដើម្បីបង្រៀនជាមួយ នឹងអំណាចដ៏អស្ចារ្យ។ នៅពេលអ្នកសិក្សា ដោយអធិស្ឋាន និងជំនឿ ចំណេះដឹង និងទីបន្ទាល់របស់អ្នកនឹងរីកចំរើនឡើង។ ទោះជាយ៉ាងណាក៏ដោយ កុំព្យាយាមបង្រៀនអ្វីៗទាំងអស់ដែលអ្នកដឹង។ បង្រៀនសារលិខិតឱ្យច្បាស់លាស់ សាមញ្ញ និងផ្តែកទៅលើសេចក្តីត្រូវការរបស់បុគ្គលម្នាក់ៗ បង្រៀនតាមព្រះវិញ្ញាណ "នោះចំណែកនោះនឹងបានផ្តល់ឱ្យ ដល់មនុស្សគ្រប់រូប" (គ និងស 84:85)។

### ការឱ្យនិយមន័យរបស់ពាក្យ

យើងជាអ្នកផ្សព្វផ្សាយសាសនា មានសារលិខិតដ៏មានអំណាចជាមួយនឹងវាក្យសព្ទ័ដ៏អស្ចារ្យ។ ដូចជាគ្រូពេទ្យម្នាក់និយាយតាមរបៀបផ្សេងៗ ទៅកាន់គ្រួសារដែលនៅក្នុងបន្ទប់រងចាំ វាខុសពីនៅក្នុងបន្ទប់ប្រតិបត្តិការ ដូច្នេះអ្នកត្រូវ តែរៀននិយាយផងដែរ ដើម្បីឱ្យអ្នក ដែលមិនទាន់ស្គាល់សារលិខិតរបស់យើងអាចយល់ពីអ្វី ដែលអ្នកកំពុងបង្រៀន។

ដើម្បីរៀបចំជួយអ្នកដទៃឱ្យយល់ពាក្យដែលមិនស្គាល់ ចូរសិក្សាបញ្ជីនៃ"និយមន័យសំខាន់ៗ" និងពាក្យនៅក្នុងវគ្គ "គំនិតសំរាប់បង្រៀន"នៃមេរៀននីមួយៗ។ សូមស្គាល់និយមន័យដែលបានផ្តល់ឱ្យ។ ចូរប្រើ *នៅពិតចំពោះសេចក្តីជំនឿ* និង Guide to the Scriptures ដើម្បីស្វែងរកនិយមន័យសំរាប់ពាក្យដទៃទៀត។ សរសេរនិយមន័យទាំងនេះនៅក្នុងសៀវភៅ កត់ត្រាក្នុងការសិក្សារបស់អ្នក។ ចែកចាយនិយមន័យជាមួយនឹងដៃគូរបស់អ្នក និងអ្នកដទៃ ដើម្បីឱ្យដឹងថា យល់ ឬក៏មិនយល់។ បើសិនជានិយមន័យមិនច្បាស់ចំពោះអ្នកដទៃ កែនិយមន័យរបស់អ្នក ដោយផ្អែកលើឯកសារ ដែលអ្នកបានសិក្សា។

នៅពេលអ្នកបង្រៀន ចូរស្វែងយល់ពីកង្វល់ មិនថាឡើយជាពាក្យ ឬគោលការណ៍ថ្មីចំពោះមនុស្ស ដែលអ្នកកំពុងបង្រៀន។ ចំណាយពេល ដើម្បីពន្យល់ពាក្យ ឬគោលការណ៍ដែលមិនស្គាល់។ ចូរចងចាំថា បង្រៀនឱ្យមានការយល់ដឹង ដើម្បីអ្នក និងអ្នកទាំងឡាយ ដែលអ្នកបង្រៀនបាន "បំភ្លឺ និងសប្បាយទាំងអស់គ្នា" (គ និងស 50:22)។

#### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

ត្រឡប់ទៅកាន់មេរៀន "សារលិខិតនៃការសាងឡើងវិញ នៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ" មានទីតាំងនៅក្នុងជំពូកទី 3។ សូមអានបញ្ជីនៃនិយមន័យសំខាន់ៗ នៅក្នុងវគ្គ "គំនិតសំរាប់ការបង្រៀន"។ ចូរដាក់ពាក្យបីផ្សេងទៀតនៅក្នុងមេរៀន ដែលអ្នកចង់ឱ្យ និយមន័យ។ ធ្វើតាមការឱ្យយោបល់ដែលបានផ្តល់ឱ្យនៅខាងលើ នៅក្នុងការបង្កើតនិយមន័យ មួយសំរាប់ពាក្យនីមួយៗ។

កំណត់ចំណាំ

## ការសិក្សាអំពីគំនិត និងយោបល់

គំនិត និងយោបល់ទីមួយៗនៅក្នុងជំពូកនេះ អាចធ្វើឱ្យពេលវេលាសិក្សារបស់អ្នកកាន់តែបានរង្វាន់ និងលើកតំកើងខាងវិញ្ញាណ។ ចូរពិចារណាដូចខាងក្រោមនេះ នៅពេលអ្នកធ្វើផែនការនៃការសិក្សារបស់អ្នកៈ

- ចាប់ផ្តើមជាមួយនឹងការអធិស្ឋានជានិច្ច។
- ធ្វើផែនការសកម្មភាពសិក្សា ដែលនឹងស្ថាបនាសេចក្តីជំនឿរបស់អ្នកនៅក្នុងព្រះអង្គសង្គ្រោះ និងប្រើពេលវេលារបស់អ្នកឱ្យបានល្អ។
- ធ្វើផែនការណ៍ការសិក្សាអំពីមនុស្សនៅជុំវិញអ្នក សេចក្តីត្រូវការរបស់ពួកគេ និងការរៀបចំពួកគេសំរាប់ពិធីបុណ្យជ្រមុជទឹក ពិធីបញ្ជាក់ និងការកាន់ខ្ជាប់ដល់ចុងបំផុត។ កត់ចំណាំផែនការការសិក្សារបស់អ្នកនៅក្នុងកាលវិភាគប្រចាំថ្ងៃរបស់អ្នក។
- ធ្វើផែនការនៃការសិក្សារបស់អ្នកដោយសួរៈ “តើខ្ញុំនឹងបង្រៀនអ្វីនៅថ្ងៃនេះ? តើខ្ញុំអាចធ្វើផែនការនៃការសិក្សារបស់ខ្ញុំ ដើម្បីជាជំនួយសំខាន់បំផុតដល់អ្នកទាំងឡាយ ដែលខ្ញុំបង្រៀនដោយរបៀបណា? តើគំនិត និងយោបល់មួយណា មកពីជំពូកនេះ ដែលខ្ញុំមិនបញ្ចូលនៅក្នុងការសិក្សារបស់ខ្ញុំ?

នៅពេលអ្នកធ្វើផែនការសកម្មភាពនៃការសិក្សារបស់អ្នក ចូរធ្វើការសាកល្បងជាមួយគំនិត និងយោបល់ខ្លះៗ ដែលមានដូចខាងក្រោម ឬជាមួយគំនិតបន្ថែម ដែលអ្នករៀនមកពីអ្នកដទៃ។

### អនុវត្ត និងរស់នៅតាមអ្វីដែលអ្នករៀន

- “ប្រដូច” អ្វីដែលអ្នករៀនមកខ្លួនរបស់អ្នក (សូមមើល នីហ្វៃទី1 19:23)។
- ដាក់គោលដៅដើម្បីរស់នៅតាមអ្វី ដែលអ្នកកំពុងរៀន។
- ដាក់ឈ្មោះរបស់អ្នកនៅក្នុងខគម្ពីរ ដើម្បីធ្វើឱ្យដូចជាមនុស្សនោះ។
- សួរខ្លួនអ្នក “តើខ្ញុំគួរតែផ្លាស់ប្តូរដោយរបៀបណា ដែលជាលទ្ធផលនៃអ្វី ដែលខ្ញុំបានរៀន? ដាក់គោលដៅឱ្យសមរម្យ។

### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

ចូរជ្រើសរើសសេចក្តីយោងមួយ នៃសេចក្តីយោងនៅខាងក្រោយនេះ។ នៅពេលអ្នកអាន និងពិចារណាវគ្គ ដែលអ្នកបានជ្រើសរើស ចូរធ្វើកត់សំគាល់របៀបពីរ ឬបី ដែលអ្នកអាចអនុវត្តនៅក្នុងជីវិតរបស់អ្នក។

- នីហ្វៃទី2 31
- អាលម៉ា 32:26–43
- មរ៉ូណៃ 7:32–48

ចូរវាយតំលៃថា តើអ្នករស់នៅតាមគោលការណ៍ ដែលអ្នកបានបង្រៀនបានល្អយ៉ាងណា។ ជ្រើសរើសរបៀបមួយ ដែលអ្នកអាចពង្រីក ហើយធ្វើផែនការដើម្បីធ្វើដូច្នោះ។

### ស្រាវជ្រាវ ពិចារណា និងចងចាំ

- ត្រូវវាងវៃ។ ហាត់ប្រាណ ងូតទឹក និងអធិស្ឋាន មុនពេលអ្នកសិក្សា។
- ចូរសិក្សានៅតុ ឬនៅទីណា ដែលអ្នកអាចសរសេរបាន (មិនត្រូវដេក ឬអង្គុយនៅលើគ្រែទេ) រៀបចំឯកសារសិក្សារបស់អ្នក ហើយនៅតែមានភាពវាងវៃ។
- អធិស្ឋានសុំការយល់ដឹង។
- សិក្សាតាមប្រធានបទ។
- សួរខ្លួនអ្នក “តើអ្វីខ្លះ ដែលអ្នកនិពន្ធកំពុងនិយាយ? តើចំណុចចំបងនៃសារលិខិតជាអ្វី? តើការណ៍នេះអនុវត្តចំពោះខ្ញុំយ៉ាងណា?”
- នឹកគិតអំពីអ្វី ដែលអ្នកកំពុងសិក្សា។ ឧទាហរណ៍ នឹកគិតអំពី តើអាំម៉ូនមានអារម្មណ៍យ៉ាងណា នៅពេលគាត់ឈរពីមុខ ស្តេចឡាម៉ូណៃ។
- សិក្សាពាក្យរបស់ព្យាការីនៅរស់ (នៅក្នុងបណ្ណាល័យអ្នកផ្សព្វផ្សាយសាសនាដែលបានអនុញ្ញាត និងទស្សនាវដ្តីសាសនាចក្រ)។

កំណត់ចំណាំ

- សរសេរនៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នកនូវសំនួរ ដែលអ្នកមាន ហើយប្រើបទគម្ពីរ ប្រសាសន៍របស់ព្យាការីថ្ងៃចុងក្រោយ និងធនធានសិក្សាដទៃទៀត ដើម្បីរកចំលើយ។
- ខគម្ពីរតែមួយ អាចមានគំនិតច្រើន។ ចូរគូសបន្ទាត់ពីក្រោម ហើយគូសចំណាំពាក្យ ឬឃ្លា ដើម្បីអ្នកអាចស្គាល់រវាងគំនិតទាំងឡាយនៅក្នុងខគម្ពីរតែមួយ។
- ចែកចាយអ្វីដែលអ្នករៀនជាមួយនឹងអ្នកផ្សព្វផ្សាយសាសនាដទៃទៀត។ អ្នកអាចរៀនច្រើនតាមការពន្យល់គោលលទ្ធិ ឬគោលការណ៍មួយទៅកាន់អ្នកដទៃ។
- គូសចំណាំបទគម្ពីររបស់អ្នក ហើយសរសេរចំណាំនៅក្នុងបទគម្ពីរ។ នៅលើរឹមទំព័រ សរសេរបទគម្ពីរយោង ដែលបំភ្លឺវគ្គដែលអ្នកកំពុងសិក្សា។
- ទន្ទេញវគ្គគម្ពីរ ដែលពន្យល់ និងគាំទ្រគោលការណ៍ ដែលអ្នកបង្រៀន។

### ប្រើប្រាស់ធនធានសិក្សា

- ប្រើជំនួយសិក្សានៅក្នុងការបោះពុម្ព LDS អំពីបទគម្ពីរ (Chapter heading, footnotes, and the Guide to Scripters which include the Joseph Smith Translation and maps).
- ប្រើមេរៀនអ្នកផ្សព្វផ្សាយសាសនា បណ្ណាល័យអ្នកផ្សព្វផ្សាយសាសនាដែលបានអនុញ្ញាត ទស្សនាវដ្ដីសាសនាចក្រ និងសៀវភៅសិក្សានេះ។
- រំលឹកក្បាលជំពូកសារឡើងវិញនៅក្នុងព្រះគម្ពីរ។ ការរំលឹកនេះ នឹងផ្ដល់គំនិតឱ្យអ្នកអំពីអ្វី ដែលអ្នកស្វែងរកនៅក្នុងជំពូក។
- ប្រើសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក ដើម្បីកត់ត្រា និងរៀបចំអ្វី ដែលអ្នកកំពុងរៀន។ ជារឿយៗ រំលឹកសារឡើងវិញ អំពីគំនិតទាំងឡាយ ដែលអ្នកបានកត់ត្រា។ រៀបចំកំណត់ហេតុរបស់អ្នក ដើម្បីអ្នកអាចទឹកឃើញដោយស្រួល ពីអ្វីដែលអ្នកបានរៀន។
- ប្រើសៀវភៅសិក្សានេះ ធ្វើជាសៀវភៅមួយ ដែលអាចសរសេរ និងគូសចំណាំ។ ប្រើការដកឃ្លាសំរាប់ជាចំណាំ ដើម្បីកត់ត្រាពីអារម្មណ៍ និងគំនិត។
- សិក្សាវគ្គព្រះគម្ពីរ ដែលបានចុះបញ្ជីនៅក្នុងសៀវភៅសិក្សានេះ។ ចូរកត់ត្រានៅក្នុងសៀវភៅសិក្សានេះ ឬសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នកសំរាប់វគ្គបទគម្ពីរផ្សេងទៀត ដែលអ្នកបានរកឃើញ។

### សូមគិតអំពីរូបភាពធំ

- ទទួលទស្សនៈ មិនថាឡើយមកពីការអានបទគម្ពីរ ជំពូក ឬវគ្គឱ្យរហ័ស ឬតាមការរំលឹកក្បាលជំពូក។ ចូរស្វែងយល់ អំពីបរិបទ និងប្រវត្តិ។
- ព្យាយាមសរសេរគំនិតចំបង នៃសារដំណឹងនៅក្នុងប្រយោគមួយ ឬកថាខ័ណ្ឌមួយខ្លី។
- ប្រើព្រះគម្ពីរបរិសុទ្ធ និងផែនទីប្រវត្តិសាសនាចក្រ ដើម្បីរៀនអំពីភូមិសាស្ត្រ ចំងាយផ្លូវ អាកាសធាតុ និងដី។
- រំលឹកជាបន្តបន្ទាប់ នូវព្រឹត្តិការណ៍ និងវប្បធម៌។ សូមអានពត៌មានប្រវត្តិសាស្ត្រនៅក្នុង Guide to the Scriptures និងជំពូកនិងវគ្គសង្ខេបៗ។

#### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

សូមអានការសង្ខេបក្នុងជំពូក នៃគម្ពីរនៅខាងក្រោម ហើយសរសេរគម្រោង ដែលពិពណ៌នាអំពីការបង្កើត ព្រឹត្តិការណ៍សំខាន់ និងគោលលទ្ធិសំខាន់នៃគម្ពីរនីមួយៗ។

| | | |
|---|---|---|
| នីហ្វៃទី1 | ម៉ូសេ | កិច្ចការ |

កំណត់ចំណាំ

**ពិនិត្យដោយលំអិត**

- សូមរកមើលពាក្យគន្លឹះ និងឱ្យប្រាកដថា អ្នកយល់អត្ថន័យនៃពាក្យទាំងនោះ។ ចូរប្រើសេចក្ដីយោង Guide to the Scriptures ឬវចនានុក្រមផ្សេងទៀត ដើម្បីឱ្យនិយមន័យ។ ពិនិត្យមើលជុំវិញពាក្យ ឬឃ្លាដើម្បីប្រាប់ពីអត្ថន័យ នៃពាក្យគន្លឹះ។
- សូមរកមើលពាក្យដែលមានទំនាក់ទំនងគ្នា ដូចជា *ហេតុដូច្នេះ ហើយជាថ្មីម្ដងទៀត ហេតុដូច្នោះ ហេតុដូច្នោះហើយ* និងផ្សេងៗទៀត។ បន្ទាប់ពីបានឃើញរបៀបវគ្គខាងមុខ និងមានបន្ទទាក់ទងជាមួយនឹងគ្នាដោយរបៀបណា។
- ប្រើប្រាស់ Guide to the Scriptures ដើម្បីឃើញពីរបៀប ដែលពាក្យដូចគ្នា ត្រូវបានប្រើនៅក្នុងបរិបទផ្សេងទៀត ឬរបៀបដែលព្យាការីដទៃទៀតប្រើពាក្យដូចគ្នា។
- សូមរកមើលពាក្យ ឬឃ្លាដែលអ្នកមិនយល់ ហើយត្រូវប្រាកដថា អ្នកយល់ពាក្យ ឬឃ្លាទាំងនោះ។

**ការគូសចំណាំបទគម្ពីរ**

ការគូសចំណាំនៅក្នុងបទគម្ពីរ អាចជួយអ្នកនៅក្នុងការគិតឱ្យបានជ្រៅជ្រះអំពីវគ្គ ឬគោលលទ្ធិនៃដំណឹងល្អ។ អ្នកអាចគូសចំណាំបទគម្ពីររបស់អ្នក ជាច្រើនរបៀប។ ចូរស្វែងរកវិធីសាស្ត្រ ដែលមានប្រសិទ្ធភាពសំរាប់អ្នក។ នៅខាងក្រោមនេះ គឺជាការណែនាំ ខ្លះៗសំរាប់ធ្វើការគូសចំណាំបទគម្ពីរ។

- ប្រើដៃខ្មៅ ឬខ្មៅដៃពណ៌។ ចូរជៀសវាងពីការប្រើប៊ិច ដែលជានជាប់ក្រដាស។
- គូសស្រាលៗ គូសបន្ទាត់ពីក្រោម វង់ក្រចក ឬគ្រោងផ្នែកនៃខគម្ពីរ នៅក្នុងខគម្ពីរទាំងមូល ឬក្រុមខគម្ពីរ។
- ជៀសវាងពីការគូសចំណាំច្រើនពេក។ ផលប្រយោជន៍នឹងត្រូវបាត់បង់ បើអ្នកមិនយល់ពីអ្វី ដែលជាការគូសចំណាំរបស់អ្នក ពីព្រោះអ្នកបានធ្វើចំណាំ គូសបន្ទាត់ និងពណ៌ច្រើនពេក។
- គូសបន្ទាត់ពីក្រោម តែពាក្យគន្លឹះពីរ ឬបីប៉ុណ្ណោះបានហើយ ដើម្បីបង្ហាញថាជាខ វគ្គ ឬជំពូកសំខាន់។
- គូសរង្វង់ ឬគូសបន្ទាត់ពីក្រោមពាក្យគន្លឹះ ហើយបន្ទាប់មកគូសបន្ទាត់ត្រង់ ដើម្បីភ្ជាប់ពាក្យដែលមានទំនាក់ទំនងនឹងគ្នា។
- នៅពេលអនុក្រម នៃចំណុចមួយ នៅក្នុងខគម្ពីរ ឬវគ្គមានទំនាក់ទំនងគ្នា ចូរដាក់រាប់ចំណុចនៅលើរឹមទំព័រ ឬអត្ថបទ។
- ប្រើប្រាស់លេខយោង ធ្វើជាធនធានសំរាប់ការគូសចំណាំ និងការបកប្រែបទគម្ពីរ។
- ដាក់សញ្ញា (ដូចជាសញ្ញាគូសក្បៀស)នៅក្នុងរឹមទំព័រ សំរាប់ខគម្ពីរសំខាន់ ដែលអ្នកមានអារម្មណ៍ថាសំខាន់ ដើម្បីចងចាំ។

ការគូសចំណាំបទគម្ពីរ គួរតែជួយអ្នកឱ្យផ្តោតទៅលើការអនុវត្តនូវអ្វី ដែលអ្នករៀន និងបង្រៀនអ្នកដទៃ។ ធ្វើការពង្រីកការចូលរួម ដែលមានភាពជាប់លាប់ និងជួយអ្នកឱ្យទទួលជោគជ័យតាមគោលបំណងរបស់អ្នកជាអ្នកផ្សព្វផ្សាយសាសនា។

### សកម្មភាព៖ ការសិក្សាផ្ទាល់ខ្លួន

តើយោបល់ណាមួយ ដែលអ្នកមិនទាន់បានសាកល្បងនៅឡើយ? ចូរសំគាល់យោបល់មួយ ដែលបានមកពី "គំនិត និងយោបល់ក្នុងការសិក្សា" ដើម្បីសាកល្បង អំឡុងពេលមានការសិក្សាផ្ទាល់ខ្លួន និងជាមួយដៃគូទៅពេលក្រោយមកទៀត។

### ចូរចងចាំចំណុចនេះ

- ការមានចំណង់ ដើម្បីរៀន គឺជាការសំខាន់ចំពោះសេចក្ដីសង្គ្រោះ និងជោគជ័យរបស់អ្នកក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់។
- អ្នករៀនអំពីដំណឹងល្អ ដោយការសិក្សា ជំនឿ និងអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធ។
- ការរៀនសូត្រ គឺជាសេចក្ដីអំណរមួយ និងនាំមកនូវពរជ័យជាច្រើន។
- ការសិក្សាផ្ទាល់ខ្លួន និងជាមួយដៃគូជាប្រចាំ ពង្រឹងជំនឿ និងសមត្ថភាពរបស់អ្នក ដើម្បីបង្រៀនដោយព្រះវិញ្ញាណ។
- ប្រើវិធីសាស្ត្រសិក្សាផ្សេងៗគ្នា ដែលធ្វើឱ្យបទពិសោធន៍មានន័យ និងមានសេចក្ដីអំណរ។

# គំនិតសំរាប់ការសិក្សា និងការអនុវត្ត

## ការសិក្សាផ្ទាល់ខ្លួន

- ដាក់ពិន្ទុលើខ្លួនរបស់អ្នកដូចខាងក្រោមនេះ (1= មិនធ្លាប់សោះ, 3 = ពេលខ្លះ, និង5 =ស្ទើរតែជានិច្ចកាល)។
  – ខ្ញុំគិតអំពីមនុស្ស ដែលខ្ញុំកំពុងបង្រៀន នៅពេលខ្ញុំសិក្សា។
  – ពេញមួយថ្ងៃ ខ្ញុំគិតអំពីអ្វី ដែលខ្ញុំបានសិក្សានៅពេលព្រឹក។
  – នៅពេលខ្ញុំសិក្សា គំនិតមានមកនៅក្នុងចិត្តរបស់ខ្ញុំ ដែលមិនធ្លាប់កើតឡើងចំពោះខ្ញុំពីមុនទេ។
  – ខ្ញុំកត់ត្រាអំពីអារម្មណ៍ខាងវិញ្ញាណ និងគំនិតនៅក្នុងកន្លែងសមរម្យមួយ។
  – ខ្ញុំគេង នៅពេលខ្ញុំសិក្សា។
  – ខ្ញុំទន្ទឹងចាំឱ្យតែដល់ពេលសិក្សាផ្ទាល់ខ្លួន។
  – ខ្ញុំទន្ទឹងចាំឱ្យតែដល់ពេលសិក្សាជាមួយដៃគូ។

  រំលឹកការឆ្លើយតបរបស់អ្នកសារឡើងវិញ។ តើអ្វីខ្លះដែលអ្នកធ្វើបានល្អ? តើអ្នកចង់ឱ្យការឆ្លើយតបរបស់អ្នកមានភាពខុសពីគ្នាដែរឬទេ? ដាក់គោលដៅមួយ ឬពីរ ដែលនឹងពង្រីកគុណភាព នៃការសិក្សារបស់អ្នក។

- រំលឹកសំនួរនៅក្នុង "ចូរពិចារណាចំណុចនេះ" សារឡើងវិញ ដែលមាននៅដើមជំពូក។ តើសំនួរទាំងនេះមានឥទ្ធិពលមកលើការសិក្សារបស់អ្នកដោយរបៀបណា?

- រំលឹក "ការសិក្សាអំពីគំនិត និងយោបល់។" សំគាល់យោបល់មួយ មកពីផ្នែកនីមួយៗ ដែលអ្នកមិនបានប្រើ ហើយសាកល្បងគំនិតទាំងនេះ អំឡុងពេលការសិក្សាផ្ទាល់ខ្លួនរបស់អ្នក។

- សូមអាន គោលលទ្ធិ និងសេចក្តីសញ្ញា 138៖1–11។ នៅពេលអ្នកអានខគម្ពីរទាំងនេះ ចូរឆ្លើយសំនួរដូចខាងក្រោមនេះ៖
  – តើប្រធាន (យ៉ូសែប អែស្វ) ស្ម៊ីធ ត្រូវធ្វើអ្វីខ្លះ ដើម្បីឱ្យគំនិតរបស់លោកបានបើកចំហរ?
  – តើអ្នកមានអារម្មណ៍យ៉ាងណា អំពីគោលលទ្ធិ ដែលអ្នកកំពុងគិត?

- សូមអាននិយមន័យ នៃចំណេះដឹងនៅក្នុង Guide to the Scriptures និងសេចក្តីយោងដែលបានកត់ត្រា។ នៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក ចូរសរសេរចំលើយមួយ ចំពោះសំនួរ " តើចំណេះដឹងអ្វីខ្លះ ដែលអាចជួយខ្ញុំបំរើជាអ្នកផ្សព្វផ្សាយសាសនាប្រកបដោយប្រសិទ្ធភាព?

- ចូរជ្រើសរើសគោលលទ្ធិមួយ មកពីជំពូកទី3 ដែលអ្នកចង់ឱ្យមានការយល់ដឹងកាន់តែប្រសើរឡើង។ ចូរសរសេរនៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នកនូវសំនួរ ដែលអ្នកចង់ឆ្លើយ។ ចូរសិក្សាដោយយកចិត្តទុកដាក់អំពីគោលលទ្ធិនោះ មួយរយៈពេល (ពីរបីថ្ងៃ) ហើយអធិស្ឋាន ជាពិសេសសំរាប់ការរីកចំរើនការយល់ដឹង។ ចូរសរសេរអ្វី ដែលអ្នកបានរៀន។

- សូមអាននីហ្វៃទី 1 10៖17, 11៖1–6។ នៅពេលអ្នកអានខទាំងនេះ ចូរឆ្លើយសំនួរ "តើហេតុអ្វី នីហ្វៃអាចរៀននូវអ្វី ដែលឪពុករបស់លោកបានដឹងដូច្នេះ?

## ការសិក្សាជាដៃគូ

- សូមអានជាមួយដៃគូអ្នកនូវវគ្គគម្ពីរខាងក្រោមនេះ។ ឆ្លើយសំនួរ "តើហេតុអ្វីយើង ត្រូវស្វែងរកពន្លឺនៃទេវភាពដូច្នេះ?

  គ និងស 11៖11–14　　យ៉ូហាន 8៖12　　ទំនុកដំកើង 119៖105

  គ និងស 84៖43–47

កំណត់ចំណាំ

កំណត់ចំណាំ

- សូមអានជាមួយដៃគូអ្នកនូវវគ្គគម្ពីរមួយចំនួនខាងក្រោមនេះ ហើយពិភាក្សាអំពីពរជ័យ ដែលបានមកពីការសិក្សាបទូលព្រះ។ តើវគ្គគម្ពីរណាមួយ ដែលនឹងជួយអ្នកខ្លាំងបំផុត ដល់អ្នកទាំងឡាយណា ដែលអ្នកបង្រៀន?

| | | |
|---|---|---|
| នីហ្វៃទី 1 10:19 | អាលម៉ា 32:42–43 | គ និងស 130:19 |
| នីហ្វៃទី 2 32:3 | អាលម៉ា 37:44–46 | Guide to the Scriptures, "Scriptures," subheading: "Value of the scriptures," 221–22 |
| ម៉ូសាយ 1:6–7 | អាលម៉ា 49:30 | |
| អាលម៉ា 17:2–3 | គ និងស 90:24 | |

## ការប្រជុំក្នុងមណ្ឌល និងសន្និសីទក្នុងហ្សូន

- ចូរជ្រើសរើសប្រធានបទមកពីមេរៀនអ្នកផ្សព្វផ្សាយសាសនាមួយ ដែលអ្នកបានសិក្សាដោយយកចិត្តទុកដាក់។ ចូរធ្វើដូចខាងក្រោមនេះ៖
  - ចែកចាយចំណុចសំខាន់ពីរ ឬបី ដែលអ្នកបានរៀនមកពីការសិក្សារបស់អ្នក ដែលបានជួយទៅក្នុងការបង្រៀនមេរៀនទនោះ។
  - ចូរពិពណ៌នាអំពីវិធី ដែលអ្នកបាននិយាយបង្ហាញអំពីការសិក្សារបស់អ្នក ដែលជួយអ្នករកឃើញចំណុចទាំងនេះ (របៀប ដែលអ្នកអាន ធនធានដែលអ្នកប្រើ សំនួរអ្នកបានស្រាវជ្រាវ និងមានតទៅទៀត)។
  - បង្ហាញអំពីរបៀប ដែលអ្នកកត់ត្រា និងរៀបចំ ដែលជាលទ្ធផលនៃការសិក្សារបស់អ្នក។

  បើមានពេល សុំឱ្យអ្នកផ្សព្វផ្សាយសាសនាដទៃទៀតពីរ បីនាក់ ឱ្យធ្វើដូចគ្នានេះដែរ។

- សកម្មភាពនេះ អាចធ្វើឡើងជាបុគ្គល ឬជាក្រុមតូចមួយ។ ណែនាំអ្នកផ្សព្វផ្សាយសាសនា ឱ្យជ្រើសរើសសំនួរមួយ ក្នុងសំនួរដូចខាងក្រោមនេះ (ឬអ្នកអាចបង្កើតសំនួរខ្លះៗដោយខ្លួនអ្នកផ្ទាល់)។ ចូរឱ្យពួកគេសរសេរសំនួរ។
  - តើហេតុអ្វីក៏ក្រុមគ្រួសារមានសារៈសំខាន់យ៉ាងនេះ នៅក្នុងផែនការរបស់ព្រះ?
  - ហេតុអ្វីមនុស្សមានការសាកល្បង និងទុក្ខព្រួយដូច្នេះ?
  - តើតួនាទីរបស់ព្រះវិញ្ញាណទៅក្នុងការផ្លាស់ប្ដូរគំនិតជាអ្វី?

  ចូរពន្យល់ថា ពួកគេនឹងមានរយៈពេលប្រាំនាទី ទៅប្រាំពីរនាទី ដើម្បី៖
  - ស្វែងរកយ៉ាងហោចណាស់សេចក្តីយោងបទគម្ពីរចំនួនពីរ ដែលឆ្លើយនឹងសំនួរ។
  - សរសេរជាការបកប្រែដោយងាយៗមួយ អំពីរបៀបដែលបទគម្ពីរ ពួកគេបានជ្រើសរើសឆ្លើយនឹងសំនួរ។
  - ពិពណ៌នាអំពីអ្វី ដែលពួកគេនឹងធ្វើដើម្បីចងចាំចំលើយ។
  - ពិពណ៌នាអំពីអ្វី ដែលពួកគេនឹងធ្វើ ដើម្បីរកបានសំនួរស៊ីជម្រៅបន្ថែមទៀត។

  អញ្ជើញអ្នកផ្សព្វផ្សាយសាសនាពីរបីនាក់ (ឬក្រុមនីមួយៗ) ឱ្យចែកចាយចំលើយរបស់ពួកគេ។ ពិភាក្សាអំពីការឆ្លើយតបរបស់ពួកគេ។

- សុំឱ្យអ្នកផ្សព្វផ្សាយសាសនាសរសេរសំនួរមួយ ឬពីរអំពីគោលការណ៍ដំណឹងល្អ និងគោលលទ្ធិមកពីមេរៀនណាមួយ នៅក្នុងជំពូកទី 3 ដែលពួកគេចង់បានចំលើយ។ អញ្ជើញអ្នកផ្សព្វផ្សាយសាសនាឱ្យ ចែកចាយសំនួររបស់ពួកគេ ជាមួយក្រុម។ ចំពោះសំនួរនីមួយៗ ពិភាក្សាដូចខាងក្រោមនេះ៖
  - តើចំលើយចំពោះសំនួរនេះនឹងប្រទានពរដល់ជីវិតរបស់អ្នកផ្សព្វផ្សាយសាសនាដោយរបៀបណា?
  - តើចំលើយនឹងផ្ដល់ពរជ័យដល់ជីវិតរបស់សាសនាគន់ការីដោយរបៀបណា?
  - តើអ្នកផ្សព្វផ្សាយសាសនាម្នាក់អាចរកចំលើយបានយ៉ាងដូចម្ដេច?

- សួរអ្នកផ្សព្វផ្សាយសាសនាមួយចំនួន ឱ្យចែកចាយគោលការណ៍ដំណឹងល្អ ដែលដៃគូរបស់ពួកគេបានបង្រៀនពួកគេ។ សុំឱ្យពួកគេពន្យល់គោលការណ៍ និងរបៀប ដែលដៃគូរបស់ពួកគេបានបង្រៀនគោលការណ៍ដល់ពួកគេ។

កំណត់ចំណាំ

- រៀបចំអ្នកផ្សព្វផ្សាយសាសនាដាក់ជាដៃគូ ឬក្រុមតូចមួយ។ ចាត់ឱ្យក្រុមនីមួយៗអានជំពូកមួយ មកពីព្រះគម្ពីរមរមន។ ឱ្យក្រុមនីមួយៗ ជ្រើសរើសគំនិតមួយ មកពីផ្នែកទាំងប្រាំនីមួយៗ នៅក្នុងវគ្គ "ការសិក្សាអំពីគំនិត និងយោបល់។" អញ្ជើញឱ្យក្រុមអនុវត្តតាមយោបល់ ដូចដែលពួកគេអានក្នុងជំពូកទាំងអស់គ្នា។ អនុញ្ញាតពេលឱ្យពី 15 ទៅ 20 នាទីសំរាប់អាន និងពិភាក្សា។ ឱ្យក្រុមនីមួយៗពន្យល់អំពីយោបល់ ដែលពួកគេបានប្រើ តើយោបល់ទាំងនោះមានប្រសិទ្ធភាពយ៉ាងណា ហើយតើពួកគេបាន រៀនអ្វីខ្លះ។

- អញ្ជើញអ្នកផ្សព្វផ្សាយសាសនាម្នាក់ៗឱ្យគិតអំពីរឿង ឬព្រឹត្តិការណ៍មួយ នៅក្នុងបទគម្ពីរ ដែលមានអត្ថន័យចំពោះ ពួកគេ (ដូចជា ទស្សនៈនិមិត្តរបស់លីហៃអំពីដើមឈើនៃជីវិត ទេសនកថារបស់ស្ដេចបេនយ៉ាមីន ទេសនកថានៅលើភ្នំ ឬព្រះគ្រីស្ទយាងមកជួបពួកសាសន៍នីហ្វៃ)។ អញ្ជើញអ្នកផ្សព្វផ្សាយសាសនាគូររូបភាពដោយសាមញ្ញ ឬពិពណ៌នាអំពី ដំណើររឿង ដែលពួកគេនឹកគិតក្នុងចិត្ត ដែលពួកគេបានជ្រើសរើសនោះ។ អញ្ជើញអ្នកផ្សព្វផ្សាយសាសនាពីរ ឬបីនាក់ឱ្យចែកចាយនូវអ្វី ដែលពួកគេនឹកគិតក្នុងចិត្ត។ សួរអ្នកផ្សេងទៀតឱ្យប្រាប់រឿង និងភ្ជាប់រឿងទាំងនោះទៅនឹងគោលលទ្ធិនៅក្នុងមេរៀនមួយ នៃមេរៀនទាំងឡាយ។ សូមអានម៉ូរ៉ូណៃ 10:3 ហើយពិភាក្សាអំពីតម្លៃ នៃការពិចារណាឱ្យបានជ្រៅជ្រះអំពីចំណេះដឹងខាងវិញ្ញាណ។

## ប្រធានបេសកកម្ម

- អញ្ជើញអ្នកផ្សព្វផ្សាយសាសនាឱ្យយកសៀវភៅកំណត់ហេតុអំពីការសិក្សារបស់ពួកគេមកក្នុងការសម្ភាសន៍។ អញ្ជើញពួកគេ ដោយចែកចាយកំណត់ត្រាមួយជាមួយអ្នក។

- អំឡុងពេលកំពុងធ្វើការសម្ភាសន៍ សូមសួរសំនួរដូចខាងក្រោម៖
  - តើនៅពេលថ្មីៗនេះមានអ្វីខ្លះ ដែលធ្វើឱ្យអ្នកចាប់អារម្មណ៍ នៅក្នុងការសិក្សាព្រះគម្ពីររបស់អ្នក?
  - តើគោលការណ៍ដំណឹងល្អណាមួយ ដែលដៃគូរបស់អ្នកបានបង្រៀនអ្នកពេលថ្មីៗនេះ?
  - តើជំពូក ឬវគ្គណា នៃសៀវភៅសិក្សានេះបានជួយអ្នកបំផុត កាលពីពីរសប្ដាហ៍កន្លងទៅនេះ?
  - តើអ្នកកំពុងធ្វើអ្វីខ្លះ នៅក្នុងការសិក្សាផ្ទាល់ខ្លួន ដែលជួយអ្នកឱ្យរៀនបានច្រើនបំផុតនោះ?

- អំឡុងពេលសន្និសីទក្នុងហ្សូន អញ្ជើញអ្នកផ្សព្វផ្សាយសាសនាឱ្យចែកចាយបទពិសោធន៍ ដែលប្រកបទៅដោយអត្ថន័យ ដែលពួកគេមាននៅក្នុងការសិក្សាផ្ទាល់ខ្លួន និងជាមួយដៃគូរបស់ពួកគេ។

- អំឡុងពេលសន្និសីទក្នុងហ្សូន អនុញ្ញាតឱ្យអ្នកផ្សព្វផ្សាយសាសនា ចែកចាយគំនិតក្នុងការសិក្សាផ្ទាល់ខ្លួន។

- ចែកចាយជាមួយអ្នកផ្សព្វផ្សាយសាសនា អំពីការយល់ដឹង ដែលអ្នកមាននៅក្នុងការសិក្សាផ្ទាល់ខ្លួនរបស់អ្នក។ ចែកចាយកំណត់ត្រាមកពីសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក និងទីបន្ទាល់របស់អ្នកអំពីសារៈសំខាន់នៃការសិក្សាដំណឹងល្អ។

- បើអ្នកអាចធ្វើបាន សូមចូលរួមជាមួយអ្នកផ្សព្វផ្សាយសាសនានៅក្នុងការសិក្សាជាមួយដៃគូរបស់ពួកគេ។

- អំឡុងពេលសម្ភាសន៍ អញ្ជើញឱ្យអ្នកផ្សព្វផ្សាយសាសនាចែកចាយផែនការមួយ នៃផែនការមេរៀនរបស់ពួកគេ ចេញមកពីមេរៀនអ្នកផ្សព្វផ្សាយសាសនាមួយ។ សួរដល់ពួកគេថា តើគោលលទ្ធិទាំងនេះមានអត្ថន័យយ៉ាងណាខ្លះចំពោះពួកគេ។

កំណត់ចំណាំ



# តើអ្វីដែលខ្ញុំត្រូវសិក្សា និងត្រូវបង្រៀន?

មេរៀននៅក្នុងជំពូកនេះមានផ្ទុកនូវគោលលទ្ធិ គោលការណ៍ និងបទបញ្ញត្តិសំខាន់ៗ ដែលអ្នក ត្រូវសិក្សា ជឿ ស្រលាញ់ រស់នៅតាម និងបង្រៀន។ កិច្ចការទាំងនេះគឺជាអ្វីដែលព្យាការីដែលនៅរស់ និងសាវក បានណែនាំអ្នកឱ្យបង្រៀន។ កិច្ចការទាំងនេះ ត្រូវបានរៀបចំឡើងដើម្បីឱ្យអ្នកអាច ជួយដល់អ្នកដទៃ យល់យ៉ាងច្បាស់ពីគោលលទ្ធិរបស់ព្រះគ្រីស្ទ។

មេរៀននៅក្នុងជំពូកនេះមានដូចតទោះ

- សារដំណឹងនៃការស្តារឡើងវិញ នៃដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ
- ផែនការនៃសេចក្តីសង្គ្រោះ
- ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ
- បទបញ្ញត្តិ
- ក្រិត្យវិន័យ និងពិធីការផ្សេងៗ

បង្រៀនមេរៀនបួនដំបូងពីមុនពិធីបុណ្យជ្រមុជទឹក។ សូមប្រាកដថា អ្នកដែលអ្នកបង្រៀនមានភាពសក្តិសម ដើម្បីទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ដោយការធ្វើតាម និងរក្សាការតាំងចិត្តទាំងអស់ ដែលមាននៅក្នុងមេរៀនទាំងនេះ។

អ្នកផ្សព្វផ្សាយសាសនាពេញម៉ោងគឺជាអ្នកដឹកនាំបង្រៀនមេរៀនមុនពិធីបុណ្យជ្រមុជទឹក ជាមួយនឹងជំនួយពី អ្នកផ្សាយសាសនាប្រចាំ វួដ និងសមាជិកដទៃទៀត។ បន្ទាប់ពីបុណ្យជ្រមុជទឹក សមាជិកថ្មីគឺត្រូវបង្រៀនមេរៀនបួនដំបូងម្តងទៀត ព្រមទាំង "ក្រិត្យវិន័យ និងពិធីការផ្សេងៗ។" អ្នកដឹកនាំនៅក្នុងវួដ ជាអ្នកសំរេចចិត្តថា តើអ្នកផ្សាយសាសនាប្រចាំវួដ ឬអ្នកផ្សាយសាសនា ពេញម៉ោង ធានាទទួលខុសត្រូវថា មេរៀនទាំងនេះគឺត្រូវបានបង្រៀន ហើយតើអ្នកផ្សាយសាសនាពេញម៉ោង ចូលរួមអស់រយៈពេលប៉ុន្មាន។ ចូរលើកទឹកចិត្តសមាជិកថ្មីម្នាក់ៗ ឱ្យរក្សាការតាំងចិត្តទាំងអស់ ដែលមាននៅក្នុងមេរៀននេះ។

អ្នកគួរប្រើមេរៀនទាំងនេះ ផ្ទាល់ខ្លួន និងការសិក្សាជាមួយនឹងដៃគូ ការប្រជុំមណ្ឌល និងការប្រជុំផ្សេងៗទៀត ដែលបានរៀបឡើង។ នៅពេលអ្នកសិក្សាព្រះគម្ពីរ និងរក្សាទុកក្នុងគំនិតរបស់អ្នករាល់គ្នាជាបន្ត នូវព្រះបន្ទូលទាំងឡាយហើយ ព្រះវិញ្ញាណបរិសុទ្ធ និងផ្តល់នូវសេចក្តីដែលត្រូវនិយាយ នឹងបានប្រទានដល់អ្នករាល់គ្នានៅចំម៉ោងនោះឯង និងធ្វើដើម្បីជួយដល់អ្នកដទៃ ទទួលសាក្សីនៃសេចក្តីពិតដ៏ពេញលេញនៃការបង្រៀន។

ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា អ្នកមានការទទួលខុសត្រូវដ៏ធំ ដើម្បីបង្រៀនចេញពីបេះដូង និងដោយព្រះវិញ្ញាណ។ គណៈប្រធានទី មួយនឹងក្រុមសាវកដប់ពីរនាក់ បានលើកឡើងថាៈ" គោលបំណងរបស់យើងគឺ ដើម្បីបង្រៀនសារដំណឹងនៃដំណឹងល្អដែលបានស្តារឡើងវិញ ក្នុងរបៀបដែលទុកឱ្យព្រះវិញ្ញាណជាអ្នកដឹកនាំអ្នកផ្សព្វផ្សាយសាសនា និងអ្នកទាំងឡាយណាដែលត្រូវបានបង្រៀន។ វា ជាការសំខាន់ណាស់ ក្នុងការរៀនពីគំនិតនៃ [មេរៀន] តែការ បង្រៀននេះមិនគួរមកពីការបង្រៀនដោយការទន្ទេញចាំមាត់នោះទេ។ អ្នកផ្សព្វផ្សាយសាសនាគួរមានអារម្មណ៍ទុក ចិត្តក្នុងការប្រើពាក្យសំដីផ្ទាល់របស់គាត់ដែល

កំណត់ចំណាំ

*ទេសនាកបានៅលើភ្នំ* ដោយខាលប្លូច។ ប្រភពមកពីសាលាប្រជុំនៃប្រាសាទ ហ្វ្រេឌើរិច ស្ប៊ើក។ ដាណាម៉ាក។ អាចប្រើបាន ដោយមានការអនុញ្ញាតពីសារមន្ទីរ ហ្វ្រេឌើរិច ស្ប៊ើក។ ហាមថតចំលង។

កំណត់ចំណាំ

មានការណែនាំពី ព្រះវិញ្ញាណ។ អ្នកផ្សាយសាសនាមិនគួរបង្រៀនតាម ការសូត្រចាំទេ តែនិយាយចេញពីបេះដូង ដែលជាពាក្យសំដីផ្ទាល់របស់គាត់។ អ្នកផ្សាយសាសនាប្រហែលជា បង្រៀនខុសពីលំដាប់លំដោយនៃមេរៀន ដោយការផ្ដល់ឱ្យអ្វីដែលគាត់បានទទួល ការបំផុសគំនិតដើម្បីបង្រៀន យោងទៅតាមការចាប់អារម្មណ៍ និងសេចក្ដីត្រូវការរបស់សាសនាគន់ការី។ និយាយចេញមកដោយជឿជាក់ និងដោយពាក្យផ្ទាល់របស់គាត់ គាត់គួរថ្លែងសក្ខីភាពពីសេចក្ដីពិតនៃការបង្រៀនរបស់គាត់” (“Statement on Missionary Work,” សំបុត្ររបស់គណៈប្រធានទីមួយ ថ្ងៃទី 11 ខែធ្នូ ឆ្នាំ 2002)។ នៅពេលដែលអ្នក និងដៃគូរបស់អ្នក សិក្សាមេរៀននេះ ហើយរៀបចំដើម្បីបង្រៀន សូមរក្សាទុកការណែនាំនេះយ៉ាងរឹងប៉ឹងនៅក្នុងគំនិត។ ត្រូវប្រាកដថា អ្នកបង្រៀនគោលលទ្ធិទាំងអស់នៅក្នុងមេរៀនទាំងនេះ។

បើគ្មានការណែនាំដោយព្រះវិញ្ញាណទេ អ្នកគួរបង្រៀនអត្ថន័យទាំងអស់ក្នុងមេរៀននីមួយៗ សំរាប់មេរៀនបីដំបូងតាមលំដាប់លំដោយ ដែលមេរៀនទាំងនោះត្រូវបានសរសេរ។ បទបញ្ញត្តិពីរ ឬបីអាចរួមបញ្ចូលផងដែលតាមដែរសមរម្យ ឬត្រូវបានបង្រៀនជាមេរៀនរបស់ពួកគេផ្ទាល់។

មេរៀនទីមួយៗបង្ហាញជាលំដាប់លំដោយ សំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក ការតាំងចិត្ត និងគោលលទ្ធិដែលអ្នកត្រូវបង្រៀន។ សិក្សាគោលលទ្ធិឱ្យល្អិតល្អន់។ យកចិត្តទុកដាក់ឱ្យបានខ្ជាប់ខ្ជួន ទៅលើការជួយដល់អ្នកទាំងឡាយណាដែល អ្នកបង្រៀនឱ្យធ្វើ និងរក្សាការតាំងចិត្ត។ ប្រើសំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក ដើម្បីរៀបចំអ្នកទាំងឡាយណាដែលអ្នកបង្រៀនសំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។ ក្នុងមេរៀនក៏មានគំនិតសំរាប់បង្រៀនផងដែរ។ ប្រើគំនិតទាំងនេះ ដើម្បីពង្រឹងពីរបៀបដែលអ្នករៀបចំ និងបង្រៀន។

## តួនាទីនៃការទន្ទេញ

ទន្ទេញខគម្ពីរដើម្បីប្រើនៅក្នុងការបង្រៀនរបស់អ្នក។ តាំងចិត្តទន្ទេញនូវចំណុចសំខាន់នៃគោលលទ្ធិនៅក្នុងរាល់ មេរៀនដែលអ្នកផ្សព្វផ្សាយសាសនាបង្រៀន។ អ្នកផ្សព្វផ្សាយសាសនាដែលរៀនភាសាទីពីរ គួរតែយកចិត្តទុកដាក់លើការសិក្សាភាសារបស់គេក្នុងការរៀបចំបង្រៀន មេរៀនដែលអ្នកផ្សព្វផ្សាយសាសនាត្រូវបង្រៀន។ អ្នកផ្សព្វផ្សាយសាសនា គួរតែទន្ទេញវាក្យស័ព្ទឃ្លា ប្រយោគ និងសេចក្ដីថ្លែងខ្លីៗ នៃគោលលទ្ធិនៅពេលដែលលំដាប់នៃគោលលទ្ធិ នោះនឹងលេចឡើងនៅក្នុងមេរៀន តែគ្រាន់តែ អត្ថន័យសំខាន់ដោយផ្ទាល់សំរាប់អ្នកប៉ុណ្ណោះ។ កុំទន្ទេញមេរៀនទាំងមូលឡើយ។

## បង្រៀនដោយភាពច្បាស់លាស់

នៅចុងបញ្ចប់នៃមេរៀនបីដំបូង គឺជាបញ្ជីពាក្យដែលប្រហែលជាអ្នកដែលអ្នកបង្រៀន មិនធ្លាប់ស្គាល់ពីមុន។ ចូររៀនពីរបៀបឱ្យ និយមន័យពាក្យទាំងនេះ ដោយសាមញ្ញ។ ពេលដែលអ្នកបង្រៀន ចូរខំធ្វើឱ្យអស់ពីសមត្ថភាពរបស់អ្នក ដើម្បីធ្វើឱ្យសារដំណឹង មានលក្ខណៈងាយយល់។

## ការសិក្សាព្រះគម្ពីរ

**តើអ្វីជាទិសដៅដែលអ្នកចង់បង្រៀន?**

| | | |
|---|---|---|
| ម៉ូសាយ 18:18–20 | សូមមើល គ និង ស 43:15–16 | សូមមើល គ និង ស 52:9 |

**ហេតុអ្វីអ្នកត្រូវតែសិក្សាគោលលទ្ធិនៅក្នុងមេរៀន?**

| | |
|---|---|
| អាលម៉ា 17:2–3 | សូមមើល គ និង ស 84:85 |

កំណត់ចំណាំ

# សារដំណឹងនៃការស្ដារឡើងវិញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ



© 1991 Greg K. Olsen. ហាមថតចម្លង

## គោលបំណងរបស់អ្នក

ពេលដែលអ្នកបង្រៀន ចូររៀបចំសាសនាគន់ការីរបស់អ្នកឱ្យមានភាពសក្ដិសមសំរាប់ទទួលពិធីបុណ្យជ្រមុជទឹក ដែលបាន បង្រៀននៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា 20៖37 ហើយនៅក្នុងសំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក។ ការងារនេះអាច សំរេចដ៏ប្រសើរបំផុត ដោយការអញ្ជើញសាសនាគន់ការីរបស់អ្នក ឱ្យធ្វើ និងរក្សាការតាំងចិត្ត ដែលបានសរសេរដូចខាងក្រោម។

### សំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក

- តើអ្នកជឿថា ព្រះគឺជាព្រះវរបិតាដ៏អស់កល្បរបស់យើង ដែរឬទេ?
- តើអ្នកជឿថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រារបស់ព្រះ ជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះនៃពិភពលោក ដែរឬទេ?
- តើអ្នកជឿថា សាសនាចក្រ និងដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ត្រូវបានស្ដារឡើងតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ដែរឬទេ?
- តើអ្នកជឿថា [ប្រធានសាសនាចក្របច្ចុប្បន្ន] គឺជាព្យាការីរបស់ព្រះ ដែរឬទេ? តើព្យាការីមានន័យ យ៉ាងដូចម្ដេចចំពោះ អ្នក?

### ការតាំងចិត្ត

- តើអ្នកព្រមអាន និងអធិស្ឋានដើម្បីដឹងថា ព្រះគម្ពីរមរមន គឺជាព្រះបន្ទូលរបស់ព្រះដែរឬទេ?
- តើអ្នកព្រមអធិស្ឋានដើម្បីដឹងថា យ៉ូសែប ស៊្មីធ គឺជាព្យាការីរបស់ព្រះ ដែរឬទេ?
- តើអ្នកព្រមទៅព្រះវិហារជាមួយយើង នៅថ្ងៃអាទិត្យនេះ ដែរឬទេ?
- តើយើងអាចណាត់ជួបសំរាប់ពេលក្រោយ បានទេ?
- បទបញ្ញត្តិផ្សេងៗទៀត ចេញពីមេរៀនទី 4 ដែលអ្នកបានជ្រើសរើសដើម្បីបញ្ចូល។

## ព្រះគឺជា ព្រះវរបិតាសួគ៌ជាទីស្រលាញ់របស់យើង

ព្រះគឺជា ព្រះវរបិតាសួគ៌របស់យើង។ យើងជាកូនរបស់ទ្រង់។ ទ្រង់មានរូបកាយនៃសាច់ និងឆ្អឹង ដែលរុងរឿង និងល្អឥតខ្ចោះ។ ទ្រង់ស្រលាញ់យើង។ ទ្រង់ទួញយំពេលដែលយើងរងទុក្ខវេទនា និងរីករាយ នៅពេលយើងធ្វើអ្វីដែលត្រូវ។ ទ្រង់ចង់ទំនាក់ទំនង ជាមួយយើង ហើយយើងអាចទំនាក់ទំនងជាមួយទ្រង់ តាមរយៈការអធិស្ឋានដោយស្មោះស។

ទ្រង់បានប្រទានឱ្យយើងបទពិសោធន៍នេះនៅលើផែនដី ដើម្បីយើងអាចរៀន និងអាចរីកចំរើន។ យើងអាចបង្ហាញ សេចក្ដីស្រលាញ់របស់យើងចំពោះទ្រង់ តាមរយៈការជ្រើសរើសរបស់យើង និងការគោរពប្រតិបត្តិព្រះបញ្ញត្តិរបស់ទ្រង់។

ព្រះវរបិតាសួគ៌បានផ្ដល់ឱ្យយើង ជាកូនចៅរបស់ទ្រង់ នូវវិធីដើម្បីទទួលបានជោគជ័យនៅក្នុងជីវិតនេះ និងដើម្បីត្រឡប់ទៅរស់នៅក្នុងទីវត្តមានរបស់ទ្រង់។ ទោះជាយ៉ាងណាក៏ដោយ យើងត្រូវតែបរិសុទ្ធ និងស្អាតស្អំ តាមរយៈការគោរពប្រតិបត្តិដើម្បីទទួលបាន

កំណត់ចំណាំ

ជោគជ័យនៅក្នុងជីវិតនេះ។ ការមិនគោរពប្រតិបត្តិ ធ្វើឱ្យយើងឃ្លាតឆ្ងាយពីទ្រង់។ ចំណុច សំខាន់នៅក្នុងផែនការរបស់ព្រះវរបិតា គឺដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ។ ដង្វាយធួន រួមបញ្ចូលទាំងការ រងទុក្ខវេទនា នៅក្នុងច្បារគែតសេម៉ានី ព្រមទាំងការរងទុក្ខវេទនារបស់ទ្រង់ និងការសុគតនៅលើឈើឆ្កាង។ តាមរយៈដង្វាយធួន យើងអាចរួចពីចំណង នៃអំពើបាបរបស់យើង ហើយអភិវឌ្ឍន៍សេចក្តីជំនឿ និងកំលាំងដើម្បីប្រឈមមុខជាមួយនឹងឧបសគ្គរបស់យើង។

## ការជឿអំពីព្រះ

បញ្ជាក់ពីអ្វីដែលមនុស្សម្នាក់ៗ ដែលអ្នកកំពុងបង្រៀនយល់ ពីការជឿរបស់គ្រីស្ទនិកអំពីព្រះ។ មនុស្សជាច្រើននៅក្នុង ពិភពលោកសព្វថ្ងៃនេះ មិនទាំងដឹងអំពីព្រះ ឬក៏មានព្រះសិក្ខាបទខុសគ្នាអំពីអាទិទេពទេ។

អ្នកផ្សព្វផ្សាយសាសនាពីរនាក់នៅក្នុងព្រះគម្ពីរមរមន អាំម៉ូន និងអើរ៉ុន បានបង្រៀនប្រជាជនដែលគ្មានជីវិះប្រវត្តិ ជាគ្រីស្ទនិក។ ពួកគេបង្រៀនសេចក្តីពិតយ៉ាងសាមញ្ញ ហើយអញ្ជើញសាសនាគន់ការីរបស់គេឱ្យអធិស្ឋាន។ ឡាម៉ូណៃ និងឪពុករបស់គាត់ បានផ្លាស់សាសនា។ សូមអាន អាលម៉ា 18៖24–40 និង 22៖4–23 និងឆ្លើយសំនួរដូចខាងក្រោម៖

- តើអ្នកផ្សព្វផ្សាយសាសនាទាំងនេះ បានបង្រៀនអ្វីអំពីនិស្ស័យរបស់ព្រះ?
- តើអ្នកអាចធ្វើតាមគំរូរបស់ពួកគេ ដោយរបៀបណា?

## ការសិក្សាព្រះគម្ពីរ

**តើនិស្ស័យរបស់ព្រះជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ គឺជាអ្វី?**

| | | |
|---|---|---|
| នីហ្វៃទី 1 17៖36 | នីហ្វៃទី 3 27៖13–22 | យ៉ូហាន 3៖16–17 |
| នីហ្វៃទី 2 9៖6 | សូមមើល គ និង ស 38៖1–3 | កិច្ចការពួកសាវក 17៖27–29 |
| ម៉ូសាយ 4៖9 | សូមមើល គ និង ស 130៖22 | រ៉ូម 8៖16 |
| នីហ្វៃទី3 12៖48 | ម៉ូសេ 1៖39 | ហេព្រើរ 12៖9 |
| នីហ្វៃទី 3 14៖9–11 | ម៉ាថាយ 5៖48 | យ៉ូហានទី 1 4៖7–9 |

## ដំណឹងល្អប្រសិទ្ធពរដល់ក្រុមគ្រួសារ

ដំណឹងល្អដែលបានស្តារឡើង ប្រទានពរនិងជួយដល់ប្តីនិងប្រពន្ធ ឪពុកម្តាយនិងកូនចៅ នៅពេលដែលពួកគេព្យាយាម អភិវឌ្ឍន៍ចំណងមិត្តភាពឱ្យកាន់តែរឹងមាំឡើង និងពង្រឹងខាងផ្នែកវិញ្ញាណនៅក្នុងក្រុមគ្រួសាររបស់ពួកគេ។ ពរជ័យទាំងនេះ មាន សំរាប់ពេលឥឡូវ និងសំរាប់ពេលអស់កល្បជានិច្ច។ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ផ្តល់ជំនួយដើម្បី ដោះស្រាយកង្វល់ និងការប្រឈមមុខពេលបច្ចុប្បន្ន។

ព្រោះក្រុមគ្រួសារត្រូវបានតែងតាំងឡើងដោយព្រះ គ្រួសារគឺជាផ្នែកដ៏សំខាន់បំផុតនៅក្នុងសង្គម នៅក្នុងពេលនេះ និងក្នុងពេលអស់កល្បជានិច្ច។ ព្រះបានបង្កើតក្រុមគ្រួសារឡើង ដើម្បីនាំមកនូវសុភមង្គលដល់កូនចៅរបស់ទ្រង់ អនុញ្ញាតឱ្យពួកគេរៀន គោលការណ៍ត្រឹមត្រូវ នៅក្នុងបរិយាកាសដ៏គួរឱ្យស្រលាញ់ ហើយរៀបចំពួកគេសំរាប់ជីវិតអស់កល្បជានិច្ច។ ផ្ទះគឺជាកន្លែងដ៏ ប្រសើរដើម្បី បង្រៀនរៀន និងអនុវត្តគោលការណ៍នៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ ផ្ទះដែលកសាងឡើងនៅលើ គោលការណ៍នៃដំណឹងល្អ នឹងទៅជាកន្លែងនៃជំរក និងសុវត្ថិភាព។ ផ្ទះនឹងទៅជាកន្លែង ដែលព្រះវិញ្ញាណនៃព្រះអម្ចាស់ អាចស្នាក់នៅ ដោយការប្រទានពរជ័យដល់សមាជិកក្រុមគ្រួសារជាមួយនឹងសេចក្តីសុខសាន្ត សេចក្តីអំណរ និងសុភមង្គល។ តាមរយៈព្យាការីនៅគ្រប់ជំនាន់ រួមបញ្ចូលទាំងនៅក្នុងជំនាន់របស់យើង ព្រះបានបើកសម្តែងផែនការនៃសុភមង្គលរបស់ទ្រង់ សំរាប់បុគ្គលម្នាក់ៗ និងជាក្រុមគ្រួសារ។

## ព្រះវរបិតាសួគ៌បើកសម្តែងដំណឹងល្អរបស់ទ្រង់នៅគ្រប់សម័យកាន់កាប់ត្រួតត្រា

របៀបមួយដ៏សំខាន់ដែលព្រះបង្ហាញសេចក្តីស្រលាញ់របស់ទ្រង់ចំពោះយើង គឺតាមរយៈការហៅព្យាការីដែលជាអ្នក ត្រូវបានប្រគល់ឱ្យបព្វជិតភាព —ជាអំណាច និងជាសិទ្ធិអំណាចដែលត្រូវបានឱ្យដល់បុរស ដើម្បីធ្វើកិច្ចការនៅក្នុងព្រះនាម ព្រះសំរាប់សេចក្តីសង្គ្រោះនៃ កូនចៅទ្រង់។ ព្យាការីរៀនពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ តាមរយៈ វិវរណៈ។ ក្រោយមកព្យាការីបង្រៀន ដំណឹងល្អដល់អ្នកដទៃ និងធ្វើទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះ។ ការបង្រៀនរបស់ព្យាការី គឺត្រូវបានរកឃើញ នៅក្នុងសៀវភៅដ៏ពិសិដ្ឋ ដែលបានហៅថា ព្រះគម្ពីរ។

កំណត់ចំណាំ

ផែនការរបស់ព្រះវរបិតាសំរាប់យើង គឺដើម្បីទទួលបានជោគជ័យក្នុងជីវិតនេះ និងត្រឡប់ទៅរស់នៅជាមួយនឹងទ្រង់វិញ ត្រូវបានហៅថា ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ជាមួយនឹងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ដែលជាចំណុចកណ្ដាលនៃផែន ការនេះ។ តាមរយៈ ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ យើងអាចទទួលជីវិតដែលនៅអស់កល្បជានិច្ច បើយើងអនុវត្តសេចក្ដីជំនឿ នៅក្នុងព្រះយេស៊ូវ គ្រីស្ទ ប្រែចិត្ត គឺទទួលបុណ្យជ្រមុជទឹក ដោយពន្លិចក្នុងទឹកសំរាប់ការលាងបាប ទទួលអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ហើយតស៊ូដល់ ទីបញ្ចប់។ “នេះគឺជាផ្លូវ ហើយគ្មានផ្លូវឯណាទៀតទេ ឬក៏ឈ្មោះណាទៀត នៅក្រោមមេឃនេះ ដែលមនុស្សអាចបានសង្គ្រោះនៅ ក្នុងនគរនៃព្រះឡើយ ហើយឥឡូវនេះ មើលចុះ នេះគឺជាគោលលទ្ធិនៃព្រះគ្រីស្ទ” (នីហ្វៃទី 2 31:21)។ មនុស្សទាំងអស់មាន អំណោយទាននៃសេរីភាព ដែលរួមបញ្ចូលទាំងសេរីភាពដើម្បីទទួល ឬបដិសេធដំណឹងល្អ ដូចដែលបានបង្រៀនដោយព្យាការី និងសាវក។ អ្នកទាំងឡាយណាដែលគោរពប្រតិបត្តិ នឹងទទួលបានពរជ័យ តែអ្នកទាំងឡាយណាដែលមិនអើពើរ បដិសេធ ឬធ្វើឱ្យខូចដំណឹងល្អ នឹងមិនទទួលពរជ័យដែលជាការសន្យារបស់ព្រះឡើយ។

នៅពេលដែលមនុស្សជ្រើសរើសមិនយកចិត្តទុកដាក់ មិនគោរពប្រតិបត្តិ ឬធ្វើឱ្យខូចគោលការណ៍នៃដំណឹងល្អណា ឬពិធីការនៅពេលដែលពួកគេបដិសេធព្យាការីរបស់ព្រះអម្ចាស់ ឬនៅពេលដែលពួកគេ ធ្លាក់ចុះក្នុងការតស៊ូនៅ ក្នុងសេចក្ដីជំនឿ ពួកគេធ្វើឱ្យខ្លួនរបស់គេឃ្លាតឆ្ងាយពីព្រះ ហើយចាប់ផ្ដើមរស់នៅក្នុងសេចក្ដីងងឹតខាងព្រលឹងវិញ្ញាណ។ ជាយថាហេតុ ការណ៍នេះនាំទៅកាន់ស្ថានភាពមួយហៅថា ការក្បត់សាសនា។ នៅពេលដែលការក្បត់សាសនា ដ៏ធំបានកើតឡើង ព្រះដកយកសិទ្ធិអំណាចនៃ បព្វជិតភាពសំរាប់បង្រៀន និងពិធីការនៃដំណឹងល្អរបស់ទ្រង់វិញ។



ប្រវត្តិសាស្ត្រព្រះគម្ពីរបរិសុទ្ធបានកត់ត្រាការកើតឡើងជាច្រើន នៃការមានព្រះបន្ទូលរបស់ព្រះទៅកាន់ព្យាការី ហើយប្រវត្តិសាស្ត្រ នោះក៏ប្រាប់ពីការកើតឡើងជាច្រើននៃការក្បត់សាសនាផងដែរ។ ដើម្បីបញ្ចប់រយៈពេលនៃការ ក្បត់សាសនាទូទៅ ព្រះបានបង្ហាញ សេចក្ដីស្រលាញ់របស់ទ្រង់ចំពោះកូនចៅរបស់ទ្រង់ ដោយការហៅព្យាការីផ្សេងទៀត ហើយប្រគល់ឱ្យព្យាការី នូវសិទ្ធិអំណាច បព្វជិតភាព ដើម្បីស្ដារ និងបង្រៀនដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ជាថ្មីម្ដងទៀត។ ជាពិសេស ព្យាការីគឺជាអ្នក គ្រប់គ្រង ដើម្បីមើលខុសត្រូវដំណាក់ព្រះនៅលើផែនដី។ កំឡុងពេលនោះ ការដឹកនាំនៃការទទួលខុសត្រូវដោយព្យាការី គឺត្រូវបានហៅថា សម័យកាន់កាប់ត្រួតត្រា។

ព្រះបើកសម្ដែងដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ចំពោះអ័ដាម ហើយបានឱ្យអ័ដាមនូវសិទ្ធិអំណាចបព្វជិតភាព។ អ័ដាម គឺជាព្យាការីដំបូងនៅលើផែនដី។ ដោយវិវរណៈ អ័ដាមបានរៀនពីចំណងមិត្តភាពរបស់មនុស្សបានយ៉ាងត្រឹមត្រូវ ជាមួយនឹងព្រះជាព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់ព្រះយេស៊ូវគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធ នៃដង្វាយធួន និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទនិងនៃគោលការណ៍ទីមួយ និងពិធីការនៃដំណឹងល្អ។ អ័ដាមនិងអេវ៉ា បានបង្រៀនកូនចៅរបស់គេ ពីសេចក្ដីពិតនេះ ហើយលើកទឹកចិត្តកូនចៅរបស់គេឱ្យបង្កើនសេចក្ដីជំនឿ ហើយរស់នៅ តាមដំណឹងល្អ នៅក្នុងគ្រប់ទិដ្ឋភាពនៃជីវិតរបស់ពួកគេ។ បន្ទាប់ ពីអ័ដាមមានព្យាការីផ្សេងៗទៀត តែកូនចៅជំនាន់ៗ ក្រោយរបស់អ័ដាម បានបដិសេធដំណឹងល្អ ហើយធ្លាក់ចុះ ក្នុងការក្បត់ សាសនាដោយការជ្រើសរើសធ្វើជាមនុស្សទុច្ចរិត។

ហេតុដូច្នោះ ក៏ចាប់ផ្ដើមមានគំរូនៃសម័យកាន់កាប់ត្រួតត្រានៃការព្យាករណ៍ ដែលធ្វើឱ្យមានការកត់ត្រាប្រវត្តិសាស្ត្រជា ច្រើននៃព្រះគម្ពីរសញ្ញាចាស់។ ព្រះវរបិតាសួគ៌ បើកសម្ដែងដំណឹងល្អរបស់ទ្រង់ តាមទាក់ទងផ្ទាល់ជាមួយនឹងព្យាការីរបស់ទ្រង់ ដូចជា ណូអេ អ័ប្រាហាំ និងម៉ូសេ។ រាល់ព្យាការីនីមួយៗ ត្រូវបានហៅដោយព្រះ ដើម្បីចាប់ផ្ដើមសម័យកាន់កាប់ត្រួតត្រានៃដំណឹងល្អថ្មី។ ចំពោះព្យាការីនីមួយៗនេះ ព្រះបានឱ្យនូវសិទ្ធិអំណាចនៃបព្វជិតភាព និងបើកសម្ដែងសេចក្ដីពិត ដ៏នៅអស់កល្បជានិច្ច។ ជាអកុសល នៅរាល់សម័យកាន់កាប់ត្រួតត្រាមនុស្ស តែងតែប្រើ សេរីភាពរបស់គេ ក្នុងការជ្រើសរើស ដើម្បីបដិសេធដំណឹងល្អ និងបន្ទាប់មក ក៏ធ្លាក់ក្នុងការក្បត់សាសនា។

កំណត់ចំណាំ

## ព្យាការី

កំណត់ថាតើមនុស្ស ដែលអ្នកកំពុងបង្រៀន យល់អំពីព្យាការីយ៉ាងដូចម្ដេចខ្លះ។ នៅក្នុងវប្បធម៌ជាច្រើន មនុស្សជឿថា មានមនុស្សបរិសុទ្ធ ឬដែលទទួលការបំផុសគំនិតទទួលទំរង់នៃការដឹកនាំ និងណែនាំពីអទិទេព។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលដែលទទួលការបំផុសគំនិតមិនមែនសុទ្ធតែជាព្យាការីនៃព្រះ ដូចដែលឱ្យនិយមន័យនៅក្នុងដំណឹងល្អដែលបានស្តារឡើង។ ចូរពន្យល់ឱ្យបានច្បាស់ថា ព្រះបានកសាងនគររបស់ទ្រង់នៅលើផែនដី ដោយការហៅព្យាការីឱ្យកសាងសម័យកាន់ កាប់ត្រួតត្រាថ្មី។ ទ្រង់បានប្រគល់ឱ្យព្យាការីនោះ សិទ្ធិអំណាចបព្វជិតភាព។ បន្ទាប់មកព្យាការីជួយដល់មនុស្សឱ្យយល់ ពីចំណងមិត្តភាពរបស់គេជាមួយនឹងអទិទេព ដោយរួមទាំងការបញ្ចូលពីរបៀប ដើម្បីទទួលជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។

អ្នកប្រហែលជាឆ្ងល់ពីរបៀបដែលសម័យកាន់កាប់ត្រួតត្រានៃដំណឹងល្អ មានទំនាក់ទំនងគ្នា នៅពេលកំពុងបង្រៀន មនុស្សដែល មិនមានជីវះប្រវត្តិ ឬមានវប្បធម៌ជាគ្រីស្ទាន។ តែអ្នកនឹងរកឃើញថា ដោយការនិយាយផ្សាភ្ជាប់យ៉ាងសង្ខេបទៅនឹង ប្រវត្តិសាស្ត្រនៃសម័យកាន់កាប់ត្រួតត្រាដំណឹងល្អ អ្នកអាចជួយមនុស្សយល់ថា ព្រះស្រលាញ់កូនចៅរបស់ទ្រង់ ហើយថា ទ្រង់នៅដដែល ទោះជាពីម្សិល ថ្ងៃនេះ និងជារៀងរហូតតទៅ។

## ការសិក្សាព្រះគម្ពីរ

### ព្យាការី

យ៉ាកុប 4៖4, 6
ម៉ូសាយ 8៖13–18
កិច្ចការពួកសាវក 10៖34–43
អេម៉ុស 3៖7

### សម័យកាន់កាប់ត្រួតត្រា

សូមមើល គ និង ស 136៖36–38
ម៉ូសេ 5៖4–12, 55–59
ម៉ូសេ 8៖19–30
Guide to the Scriptures, “Dispensation”

## ការបំរើរបស់ព្រះអង្គសង្គ្រោះនៅលើផែនដី

ពីរបីរយឆ្នាំពីមុនកំណើតរបស់ព្រះយេស៊ូវគ្រីស្ទ មនុស្សបានធ្លាក់ក្នុងការក្បត់សាសនាម្ដងទៀត។ តែនៅពេលដែលព្រះអង្គសង្គ្រោះបានចាប់ផ្ដើមការបំរើនៃជីវិតដែលរមែងតែស្លាប់របស់ទ្រងនៅលើផែនដី ទ្រង់បានកសាងសាសនាចក្ររបស់ ទ្រង់នៅលើ ផែនដីម្ដងទៀត។

ព្រះវរបិតាសួគ៌បានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់មកលើផែនដី ដើម្បីឱ្យធួននឹងអំពើបាបនៃមនុស្សទាំងអស់ ហើយឈ្នះលើ សេចក្ដីស្លាប់៖ “ត្បិតព្រះទ្រង់ស្រលាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ . . . ឱ្យលោកីយ បាន សង្គ្រោះដោយសារទ្រង់វិញ” (យ៉ូហាន 3៖16–17)។ ព្រះវរបិតាសួគ៌របស់យើងបានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ដើម្បីលើកដាក់លើខ្លួនទ្រង់ ដោយការរងទុក្ខវេទនារបស់ទ្រង់ អំពើបាបរបស់អ្នកទាំងឡាយណា ដែលរស់នៅ លើផែនដីនេះ ហើយដើម្បីឈ្នះលើសេចក្ដីស្លាប់ខាងរូបកាយ។ ព្រះអង្គសង្គ្រោះបានធ្វើការបូជាដ៏ធួនដ៏មហិមាដើម្បីឱ្យធួននឹងបាប ដូច្នេះ បើយើងមានជំនឿនៅក្នុងទ្រង់ ប្រែចិត្ត ទទួលបុណ្យជ្រមុជទឹក ទទួលព្រះវិញ្ញាណបរិសុទ្ធ ហើយតស៊ូដល់ទីបញ្ចប់ នោះ យើងអាចទទួលការរំដោះបាបរបស់យើង ហើយចូលធ្វើតាមផ្លូវដែលនឹងនាំយើងទៅកាន់ជីវិតអស់កល្បជានិច្ច នៅក្នុងវត្តមាន របស់ព្រះ (សូមមើល នីហ្វៃទី 2 31៖13–21)។



នៅអំឡុងការបំរើនៅលើផែនដីរបស់ទ្រង់ ព្រះអង្គសង្គ្រោះបានបង្រៀនដំណឹងល្អរបស់ទ្រង់ និងបានធ្វើឱ្យមានអព្ភូតហេតុ ជាច្រើនកើតឡើង។ ទ្រង់បានហៅបុរសដប់ពីរនាក់ ដើម្បីធ្វើជាសាវករបស់ទ្រង់ និងដាក់ព្រះហស្តនៅលើក្បាលរបស់ពួកគេ ដើម្បីប្រទានឱ្យពួកគេសិទ្ធិអំណាចបព្វជិតភាព។ ទ្រង់បានរៀបចំសាសនាចក្រទ្រង់ បានបំពេញការព្យាករណ៍ ហើយទ្រង់ត្រូវ បានគេបដិសេធ និងឆ្កាង។ រឿងសំខាន់បំផុតនោះគឺ ទ្រង់បានបំពេញនូវដង្វាយធួន។ ព្រះរាជបុត្រា ព្រះអម្ចាស់យេស៊ូវគ្រីស្ទ បានបំពេញគ្រប់អ្វីៗទាំងអស់ដែលព្រះបិតាសួគ៌របស់ទ្រង់បានបញ្ជូនទ្រង់មកធ្វើ។

ពីមុនសេចក្ដីស្លាប់របស់ព្រះអង្គសង្គ្រោះ និងការរស់ឡើងវិញ ទ្រង់បានប្រគល់ឱ្យសាវកទ្រង់នូវសិទ្ធិអំណាចដើម្បី បង្រៀនដំណឹងល្អរបស់ទ្រង់ ដើម្បីធ្វើពិធីការនៃសេចក្ដីសង្គ្រោះ និងកសាងសាសនាចក្រទ្រង់នៅលើពិភពលោក។

កំណត់ចំណាំ

**ការសិក្សាព្រះគម្ពីរ**

| | | |
|---|---|---|
| មាត្រានៃសេចក្តីជំនឿ 1៖5 | លូកា 6៖13 | ហេព្រើរ 5៖4 |
| ម៉ាថាយ 10៖1–10 | យ៉ូហាន 15៖16 | |

## ការក្បត់សាសនាដ៏ធំ

បន្ទាប់ពីការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ មនុស្សទុច្ចរិតបានធ្វើទុក្ខបុកម្នេញដល់សាវក និងសមាជិកនៃសាសនាចក្រ និងសំលាប់ពួកគេជាច្រើន។ ជាមួយនឹងសេចក្តីស្លាប់របស់សាវក កូនសោបព្វជិតភាព និងការដឹកនាំសិទ្ធិអំណាចបព្វជិតភាព ត្រូវបានដកយកពីផែនដី។ សាវក បានរក្សាគោលលទ្ធិនៃដំណឹងល្អឱ្យនៅបរិសុទ្ធ និងការពាររបៀបរៀបរយ និងបទដ្ឋាន នៃភាពសក្តិសមសំរាប់សមាជិកសាសនាចក្រ។ ដោយគ្មានសាវក ក្រោយមកគោលលទ្ធិត្រូវបានកែប្រែ ហើយការ ផ្លាស់ប្តូរដែលគ្មានសិទ្ធិអំណាចបានធ្វើឡើងនៅ ក្នុងការរៀបចំសាសនាចក្រ និងពិធីការនៃបព្វជិតភាព ដូចជាបុណ្យជ្រមុជទឹក និងការប្រគល់ឱ្យអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។

ដោយគ្មានវិវរណៈ និងសិទ្ធិអំណាចបព្វជិតភាព មនុស្សបានពឹងលើប្រាជ្ញារបស់មនុស្ស ដើម្បីបកប្រែព្រះគម្ពីរ និង គោលការណ៍ និងពិធីការផ្សេងៗ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។ គំនិតខុសឆ្គងត្រូវបានបង្រៀនដូចជាសេចក្តីពិត។ ចំណេះដឹងលក្ខណៈនៃ សេចក្តីពិត និងនិស្ស័យរបស់ព្រះជាព្រះវរបិតា ព្រះរាជបុត្រារបស់ទ្រង់ព្រះយេស៊ូវគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធ ជាច្រើន ត្រូវបានបាត់បង់។ គោលលទ្ធិនៃសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ការប្រែចិត្ត ពិធីបុណ្យជ្រមុជទឹកនិងអំណោយ ទាននៃព្រះវិញ្ញាណបរិសុទ្ធ បានខូចទ្រង់ទ្រាយ ឬត្រូវបានភ្លេចចោល។ សិទ្ធិអំណាចបព្វជិតភាពដែលបានឱ្យទៅសាវករបស់ ព្រះយេស៊ូវគ្រីស្ទ គឺគ្មានវត្តមាននៅលើផែនដីទៀតទេ។ ការក្បត់សាសនានេះ ជាយថាហេតុ បានធ្វើឱ្យមានការផុស ចេញនូវព្រះវិហារជាច្រើន។

ជាច្រើនសតវត្សរ៍បន្ទាប់ពីភាពខ្មៅងងឹតខាងវិញ្ញាណ បុរស និងស្ត្រីដែលស្វែងរកសេចក្តីពិត ជំទាស់ប្រឆាំងនឹងការអនុវត្ត របស់សាសនាបច្ចុប្បន្ន។ ពួកគេបានដឹងថា គោលលទ្ធិជាច្រើន និងពិធីការនៃដំណឹងល្អត្រូវបានផ្លាស់ប្តូរ ឬបាត់បង់។ ពួក គេស្វែងរកពន្លឺខាងវិញ្ញាណដ៏ប្រសើរជាង ហើយមនុស្សជាច្រើនបាននិយាយពីសេចក្តីត្រូវការសំរាប់ការស្តារឡើងវិញនៃសេចក្តីពិត។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេមិនប្រកាស ថាព្រះបានហៅពួកគេឱ្យធ្វើជាព្យាការីទេ។ ជំនួយទៅវិញ ពួកគេបានព្យាយាមកែទំរង់ការបង្រៀន និងអនុវត្តលើអ្វី ដែលពួកគេជឿថា បានផ្លាស់ប្តូរ ឬកែប្រែ។ ការខិតខំប្រឹងប្រែងរបស់គេ បាននាំទៅរកការបង្កើតព្រះវិហារប្រូតែស្តង់ជាច្រើន។ ការកែសាសនានេះ នាំឱ្យកើនបរិយាកាសសេរីភាពខាងសាសនា ដែលបានបើកផ្លូវសំរាប់ការស្តារឡើងវិញចុងក្រោយបង្អស់។

សាវករបស់ព្រះអង្គសង្គ្រោះ បានប្រាប់ទុកជាមុនអំពីការក្បត់សាសនាជាសកលនេះ។ ពួកគេក៏បានប្រាប់ផងដែរថា ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ និងសាសនាចក្ររបស់ទ្រង់នឹងត្រូវបានសាងឡើងវិញម្តងទៀតនៅលើផែនដី។

**ការសិក្សាព្រះគម្ពីរ**

| | | |
|---|---|---|
| នីហ្វៃទី 1 13 | កិច្ចការពួកសាវក 20៖28–30 | ពេត្រុសទី 2 2៖1–2 |
| នីហ្វៃទី 2 26៖20–21 | កាឡាទី 1៖6–9 | អេម៉ុស 8៖11–12 |
| នីហ្វៃទី 2 28 | ថែស្សាឡូនីចទី2 2៖1–12 (ការបកប្រែរបស់យ៉ូសែប ស្ម៊ីធ ខ 2, 3, 7–9) | Guide to the Scriptures, “Apostasy” |
| នីហ្វៃទី 4 1៖27 | ធីម៉ូថេទី 1 4៖1–3 | *True to the Faith* pages 13–14 |
| សូមមើល គ និង ស 86៖1–3 | ធីម៉ូថេទី 2 4៖3–4 | *Our Search for Happiness*, pages 23–32 |
| ម៉ាថាយ 24៖9–11 | | *Jesus the Christ* ជំពូកទី 40 “The Long Night of Apostasy” |
| ម៉ាកុស 12៖1–9 | | |
| កិច្ចការពួកសាវក 3៖19–21 | | |

កំណត់ចំណាំ

## ការក្បត់សាសនាដ៏ធំ

សាសនាគន់ការីត្រូវតែយល់ថា ការក្បត់សាសនាជាសកលបានកើតឡើងបន្ទាប់ពីសេចក្ដីស្លាប់របស់ព្រះយេស៊ូវគ្រីស្ទ និងសាវករបស់ទ្រង់។ បើគ្មានការក្បត់សាសនាទេ នោះក៏មិនត្រូវការមានការសាងឡើងវិញដែរ។ ដូចជាត្បូងពេជ្រដាក់តាំងលើក្រណាត់កម្ម៉ី គឺធ្វើឱ្យរឹតតែមានពន្លឺភ្លឺត្រចះត្រចង់ ដូច្នេះការសាងឡើងវិញឈរនៅក្នុងពន្លឺ ខុសពីភាពខ្មៅងងឹត ផ្ទៃខាងក្រោយនៃការក្បត់ សាសនាដ៏ធំ។ ដោយការដឹកនាំពីព្រះវិញ្ញាណ បង្រៀនសាសនាគន់ការី អំពីការក្បត់សាសនាដ៏ធំ នៅកំរិតដ៏ច្បាស់លាស់ សមរម្យ តាមសេចក្ដីត្រូវការ និងកាលៈទេសៈរបស់ពួកគេ។ គោលបំណងរបស់អ្នក គឺដើម្បីជួយពួកគេយល់ពីសេចក្ដីត្រូវការ សំរាប់ការសាងឡើងវិញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។

### ចំណុចសំខាន់ៗ

- សាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ គឺបានសាងឡើងនៅលើគ្រឹះនៃសាវកនិងព្យាការី (សូមមើល អេភេសូរ 2:19–20, 4:11–14)។ អ្នកដឹកនាំទាំងនេះមានសិទ្ធិអំណាចដ៏ទេវភាព។ តាមរយៈវិវរណៈពួកគេដឹកនាំកិច្ចការនៃសាសនាចក្រ។ ពួកគេ ធ្វើឱ្យគោលលទ្ធិនៅបរិសុទ្ធ អនុញ្ញាតឱ្យមានការចាត់ចែងពិធីការផ្សេងៗ និងហៅ ហើយប្រគល់ដល់អ្នកផ្សេងទៀតនូវសិទ្ធិអំណាច បព្វជិតភាព។
- ប្រជាជនបានបដិសេធន៍ និងសំលាប់ព្រះយេស៊ូវគ្រីស្ទ និងសាវក (សូមមើល ម៉ាថាយ 24:9, នីហ្វៃទី 1 11:32–34, នីហ្វៃទី 2 27:5)។ ជាមួយនឹងសេចក្ដីស្លាប់របស់សាវក អធិបតីនៃសិទ្ធិអំណាចបព្វជិតភាព បានបាត់វត្តមានពីសាសនាចក្រ។ ដោយហេតុនេះ គ្មានសិទ្ធិអំណាចដើម្បីប្រគល់ព្រះវិញ្ញាណបរិសុទ្ធ ឬធ្វើពិធីការនៃការសង្គ្រោះផ្សេងៗទេ។ វិវរណៈត្រូវ បានបញ្ឈប់ ហើយគោលលទ្ធិ បានត្រូវកែប្រែ។
- សូម្បីតែពីមុនសេចក្ដីស្លាប់របស់ពួកសាវក មានជំលោះជាច្រើនទាក់ទងទៅនឹងការកើនឡើងនៃគោលលទ្ធិ។ ចក្រភពរ៉ូម ដែលដំបូងបានធ្វើទុក្ខបុកម្នេញដល់គ្រីស្ទបរិស័ទ ក្រោយមកឱ្យមានសាសនាគ្រីស្ទ។ សំនួរសាសនាសំខាន់ៗ ត្រូវបាន ដោះស្រាយដោយការប្រឹក្សា។ គោលលទ្ធិ និងពិធីការសាមញ្ញ ដែលបានបង្រៀនដោយព្រះអង្គសង្គ្រោះ ត្រូវបានជជែកវែងញែក ហើយផ្លាស់ប្ដូរដើម្បីឱ្យស្របទៅតាមទស្សនវិជ្ជាខាងលោកីយ៍ (សូមមើល អេសាយ 24:5)។ យោងទៅតាមគំនិតលោកីយ ពួកគេផ្លាស់ប្ដូរខគម្ពីរ ដោយដកចេញគោលលទ្ធិសាមញ្ញនិងអស្ចារ្យចេញពីគម្ពីរ (នីហ្វៃទី 1 13:26–40)។ ពួកគេបាន បង្កើតជំនឿ ឬសេចក្ដីថ្លែងនៃជំនឿ ដោយផ្អែកទៅលើគោលលទ្ធិក្លែងក្លាយ និងដែលបានផ្លាស់ប្ដូរ (សូមមើល ប្រវត្តិ-យ៉ូសែប ស្ម៊ីធ 1:19)។ ព្រោះមកពីភាពឆ្មើងឆ្មៃ មនុស្សខ្លះចង់បានមុខដំណែងមានឥទ្ធិពល (សូមមើល យ៉ូហានទី 3 1:9–10)។ ប្រជាជន ទទួលយកគំនិតក្លែងក្លាយទាំងនេះ ហើយឱ្យកិត្តិយសទៅដល់គ្រូក្លែងក្លាយ ដែលបានបង្រៀនគោលលទ្ធិដែលបំពេញចិត្តជាជាង បង្រៀន សេចក្ដីពិតដ៏ទេវភាព (សូមមើល ធីម៉ូថេទី 2 4:3–4)។
- ក្នុងប្រវត្តិសាស្ត្រទាំងមូល មនុស្សជាច្រើនបានជឿយ៉ាងស្មោះលើគោលជំនឿ និងគោលលទ្ធិក្លែងក្លាយ។ ពួកគេថ្វាយបង្គំ យោងទៅតាមពន្លឺដែលពួកគេមាន ហើយបានទទួលចំលើយចំពោះការអធិស្ឋានរបស់គេ។ តែពួកគេនៅតែត្រូវបាន "ដែលលាក់ពី សេចក្ដីពិត ពីព្រោះពួកគេមិនដឹងជាទៅរកសេចក្ដីពិតនៅឯណាទេ" (សូមមើល គ និង ស 123:12)។
- ហេតុដូច្នេះហើយ ការសាងឡើងវិញ មិនមែនការកែសាសនាទេ។ សិទ្ធិអំណាចបព្វជិតភាព មិនបានបន្តនៅ ក្នុងបន្ទាត់ ដាច់ នៃការទទួលបន្តពីសាវកពេត្រុសទេ។ ការកែទំរង់គឺជាការផ្លាស់ប្ដូរអ្វីដែលមានរួចទៅហើយ ការសាងឡើងវិញ គឺដើម្បីនាំមកវិញ អ្វីមួយជាទំរង់ដើម។ ហេតុដូច្នេះ ការស្ដារឡើងវិញ នៃសិទ្ធិអំណាចបព្វជិតភាព តាមរយៈសារទូតដ៏ទេវភាព គឺជាវិធីតែមួយគត់ ដើម្បីឈ្នះលើការក្បត់សាសនាដ៏ធំ។

## ការស្ដារឡើងវិញដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ តាមរយៈយ៉ូសែប ស្ម៊ីធ

នៅពេលដែលកាលៈទេសៈត្រឹមត្រូវ ព្រះវរបិតាសួគ៌ បានឈោងមករកកូនចៅរបស់ទ្រង់ដោយសេចក្ដីស្រលាញ់។ ទ្រង់បានហៅយុវជនម្នាក់ ឈ្មោះ យ៉ូសែប ស្ម៊ីធ ធ្វើជាព្យាការី។ តាមរយៈលោក ភាពពេញលេញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ត្រូវបានសាងឡើងវិញនៅលើផែនដីម្ដងទៀត។

យ៉ូសែប ស្ម៊ីធ រស់នៅសហរដ្ឋអាមេរិក ដែលប្រហែលជាប្រទេសតែមួយប៉ុណ្ណោះ ដែលមានសេរីភាព ខាងសាសនា នៅពេលនោះ។ គឺនៅពេលនៃការរំជើបរំជួលដ៏ធំនៃសាសនា នៅក្នុងប៉ែកខាងកើត នៃសហរដ្ឋអាមេរិក។ គ្រួសាររបស់លោក គឺជាអ្នកជឿយ៉ាងស៊ប់ទៅលើសាសនា ហើយតែងតែស្វែងរកសេចក្ដីពិត។ តែអ្នកដឹកនាំជាច្រើន បានអះអាងថា មានដំណឹងល្អពិត។ គោលបំណងរបស់យ៉ូសែប "ចង់ដឹងថា បក្សពួកណាមួយទៅដែលត្រូវ" (យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:18)។ ព្រះគម្ពីរបរិសុទ្ធបានបង្រៀនថា "មានព្រះអម្ចាស់តែមួយ សេចក្ដីជំនឿតែមួយ បុណ្យជ្រមុជទឹក តែមួយ" (អេភេសូរ 4:5)។ យ៉ូសែប បានចូលរួមនៅក្នុងព្រះ វិហារផ្សេងៗគ្នា តែនៅតែច្របូកច្របល់ អំពីព្រះវិហារមួយណា ដែលលោកគួរតែចូលរួម។ ក្រោយមកលោក បានសរសេរថា៖

"មានការរំជួល និងការឈ្លោះប្រកែកគ្នាជាខ្លាំង ក្នុងចំណោមបក្សពួកផ្សេងៗ ដល់ម្ល៉េះបានជាពិបាកដល់ជនដូចរូបខ្ញុំ ដែលនៅវ័យក្មេង ហើយមិនសូវស្គាល់មនុស្ស និងដឹងក្ដីឱ្យចេះសំរេចចិត្តថា នរណាមួយត្រូវ ហើយនរណាមួយខុស នោះឡើយ . . . ។ នៅកណ្ដាលចំបាំងខាងពាក្យសំដី និងការជ្រួលច្របល់ខាងគំនិតជឿនេះ ខ្ញុំតែងតែគិតនៅក្នុងចិត្តខ្ញុំថា តើត្រូវធ្វើអ្វីហ្ន៎? តើបក្ស ពួកមួយណាទៅដែល

ត្រូវ ឬក៏គេសុទ្ធតែខុសទាំងអស់គ្នា? បើសិនជាមានបក្សពួកណាមួយដែលត្រូវ នោះតើណាមួយទៅ ហើយតើខ្ញុំនឹងស្គាល់តាមរបៀបណាបាន?” (យ៉ូសែប ស៊្មីធ—ប្រវត្តិ 1:8, 10)។

នៅពេលដែលយ៉ូសែប បានស្វែងរកសេចក្តីពិត នៅក្នុងចំណោមក្រុមដែលមានជំនឿខុសៗគ្នា លោកបានបើកនៅក្នុងព្រះគម្ពីរបរិសុទ្ធសំរាប់ការណែនាំ។ លោកបានអានថា “តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ ដែលទ្រង់ប្រទាន ដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ” (យ៉ាកុប 1:5)។ ពីព្រោះសារដំណឹងនេះ យ៉ូសែប បានប្តេជ្ញាចិត្តសូមដល់ព្រះ ពីអ្វីដែលលោកគួរតែធ្វើ។ នៅក្នុងនិទាឃរដូវ នាឆ្នាំ 1820 លោកបានចូលទៅក្នុងព្រៃនៅជិតផ្ទះ ហើយបានលុតជង្គង់អធិស្ឋាន។ លោកបាន ពិពណ៌នានូវបទពិសោធន៍របស់លោកថាៈ

“ខ្ញុំបានឃើញបង្គោលពន្លឺមួយនៅចំលើក្បាលខ្ញុំ មានរស្មីចែងចាំងលើសជាងសុរិយាទៅទៀត ដែលចុះសន្សឹមមក ចំលើរូបខ្ញុំ . . .។ កាលពន្លឺនោះស្ថិតចំលើរូបខ្ញុំ ខ្ញុំឃើញតួអង្គពីរ ដែលមានរស្មី និងសិរីរុងរឿងដែលពុំអាចពិពណ៌នាបានឡើយ ឈរនៅលើអាកាសពីលើរូបខ្ញុំ។ តួអង្គមួយមានព្រះបន្ទូលមកខ្ញុំ ដោយហៅឈ្មោះខ្ញុំ ហើយចង្អុលទៅ តួអង្គមួយទៀត ដោយមានព្រះបន្ទូលថា—*នេះជាព្រះរាជបុត្រាដ៏សួនភ្ងាររបស់យើង ចូរស្តាប់តាមទ្រង់ចុះ!*” (យ៉ូសែប ស៊្មីធ-ប្រវត្តិ 1:16–17)។



នៅក្នុងទស្សនៈនិមិត្តនេះ ព្រះជាព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ បានយាងមកជួបនឹង យ៉ូសែប ស៊្មីធ។ ព្រះអង្គសង្គ្រោះបានប្រាប់យ៉ូសែប មិនឲ្យចូលរួមនៅក្នុងព្រះវិហារណាមួយឡើយ ត្បិតពួកគេ “សុទ្ធតែខុសទាំង អស់គ្នា” ហើយ “អស់ទាំងគោលជំនឿរបស់គេសុទ្ធតែជាអំពើគួរខ្ពើមឆ្អើម។” ទ្រង់ក៏មានបន្ទូលថា “គេគោរពប្រតិបត្តិដល់យើងតែបបូរមាត់ទេ ឯចិត្តគេនោះនៅឆ្ងាយពីយើងណាស់ គេបង្រៀនសេចក្តីដែលជាបញ្ញត្តិរបស់មនុស្សវិញ ដោយមានឫកពាជាអ្នកគោរពប្រតិបត្តិដល់ ព្រះ ប៉ុន្តែមិនព្រមទទួលស្គាល់ព្រះចេស្តា។” (យ៉ូសែប ស៊្មីធ—ប្រវត្តិ 1:19)។ ទោះបីជាមនុស្សល្អជាច្រើន ជឿនៅក្នុងព្រះគ្រីស្ទ ហើយបានព្យាយាមយល់ និងបង្រៀនដំណឹងល្អរបស់ទ្រង់ ក៏ពួកគេមិនមានភាពពេញលេញនៃសេចក្តីពិត ឬ សិទ្ធិអំណាច បព្វជិតភាព ដើម្បីជ្រមុជទឹក និងធ្វើពិធីការសង្គ្រោះផ្សេងៗទៀតដែរ។ ពួកគេទទួលមរតកសេចក្តីថ្លែងនៃការក្បត់សាសនា នៅពេលដែល ជំនាន់នីមួយៗ បានទទួលឥទ្ធិពលដែលមនុស្សជំនាន់មុនបានទុកឲ្យ ដោយបូករួមទាំងការផ្លាស់ប្តូរនៅក្នុងគោលលទ្ធិ និងពិធីការផ្សេង ដូចជាពិធីបុណ្យជ្រមុជទឹក។ ដូចដែលព្រះបានធ្វើចំពោះ អ័ដាម ណូអេ អ័ប្រាហាំ ម៉ូសេ និងព្យាការីផ្សេងៗទៀត ទ្រង់បានហៅ យ៉ូសែប ស៊្មីធ ឲ្យធ្វើជាព្យាការី តាមរយៈលោកភាពពេញលេញនៃដំណឹងល្អ ត្រូវបានស្តារឡើងវិញ នៅលើផែនដី។

បន្ទាប់ពីការលេចមករបស់ព្រះវរបិតា និងព្រះរាជបុត្រា សារទូតសួគ៌ាផ្សេងៗទៀត ឬទេវតា ត្រូវបានបញ្ជូនមកកាន់យ៉ូសែប ស៊្មីធ និងសហការីរបស់លោក អូលីវើរខៅឌើរី។ យ៉ូហាន បាទីស្ទ បានមកជួប និងប្រគល់ដល់យ៉ូសែប ស៊្មីធ និងអូលីវើរខៅឌើរី នូវបព្វជិតភាពអើរ៉ុន ដែលរួមទាំងសិទ្ធិអំណាចដើម្បីធ្វើពិធីបុណ្យជ្រមុជទឹក។ ពេត្រុស យ៉ាកុប យ៉ូហាន (ជាមនុស្សបីនាក់ ក្នុងចំណោមសាវកដើមរបស់ព្រះគ្រីស្ទ)បានមកជួប ហើយប្រគល់បព្វជិតភាពម៉ិលគីស្សាដែក ឲ្យយ៉ូសែប ស៊្មីធ និង អូលីវើរខៅឌើរី ដោយការសាងឡើងវិញនូវសិទ្ធិអំណាចដូចគ្នានឹងសិទ្ធិអំណាច ដែលបានប្រគល់ឲ្យសាវករបស់ព្រះគ្រីស្ទកាលពីបុរាណ។ ជាមួយនឹង សិទ្ធិអំណាចបព្វជិតភាពនេះ យ៉ូសែប ស៊្មីធ ត្រូវបានដឹកនាំឲ្យរៀបចំសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទម្តងទៀតនៅលើផែនដី។ តាមរយៈលោក ព្រះយេស៊ូវគ្រីស្ទបាន ហៅសាវកដប់ពីរនាក់។

ពេលវេលាដែលយើងរស់នៅសព្វថ្ងៃត្រូវបានប្រាប់តាមព្យាការីព្រះគម្ពីរបរិសុទ្ធថា ជាថ្ងៃចុងក្រោយបង្អស់ ថ្ងៃចុងក្រោយ ឬ សម័យកាន់កាប់ត្រួតត្រានៃភាពពេញលេញនៃពេលវេលា។ វាគឺជារយៈពេលពីមុនការយាងមក ជាលើកទីពីររបស់ព្រះ យេស៊ូវគ្រីស្ទ។ វាគឺជាថ្ងៃចុងក្រោយបង្អស់។ ហេតុនេះហើយ ទើបសាសនាចក្រមានឈ្មោះថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ។

ព្យាការីដែលនៅរស់ ដឹកនាំសាសនាចក្រសព្វថ្ងៃនេះ។ ព្យាការីនេះ គឺជាប្រធាននៃសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺអ្នកស្នងដែលមានសិទ្ធិអំណាចពី យ៉ូសែប ស៊្មីធ។ លោកនិងសាវកបច្ចុប្បន្ននេះ ភ្ជាប់សិទ្ធិអំណាចរបស់ពួកគេ ទៅនឹងព្រះយេស៊ូវគ្រីស្ទ ដូចជាច្រវាក់នៃការតែងតាំងដែលមិនដាច់ពីគ្នា តាមរយៈយ៉ូសែប ស៊្មីធ។

កំណត់ចំណាំ

មេរៀនទី 1៖
ការស្តារឡើងវិញ

កំណត់ចំណាំ

## ទន្ទេញ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1៖16–17

ចូរទន្ទេញការពិពណ៌នារបស់យ៉ូសែប ស្ម៊ីធ នៃការឃើញព្រះវរបិតា និងព្រះរាជបុត្រា (យ៉ូសែបស្ម៊ីធ—ប្រវត្តិ 1៖16–17) ហើយ ត្រូវតែត្រៀមលក្ខណៈរួចជាស្រេច ដើម្បីពិពណ៌នាពីទស្សនៈនិមិត្តដំបូង ដោយប្រើពាក្យពេជចន៍របស់លោកផ្ទាល់។ ចូរកុំប្រញាប់ ប្រញាល់បញ្ចប់ការពិពណ៌នានោះ។ ថ្លែងសក្ខីភាពដោយស្មោះ ដែលអ្នកដឹងថា ទស្សនៈនិមិត្តដំបូង នោះជាការពិត។ ចូរកុំស្ទាក់ស្ទើរ ដើម្បីពន្យល់អំពីរបៀបដែលអ្នកអាចដឹងថា ទស្សនៈនិមិត្តនោះពិត។ ចូរអញ្ជើញដៃគូរបស់អ្នក ឱ្យធ្វើដូច្នេះផងដែរ។

## ថ្លែងសក្ខីភាព

ផ្នែកដ៏សំខាន់នៃករណីកិច្ចរបស់អ្នកផ្សព្វផ្សាយសាសនាគឺ ថ្លែងសក្ខីភាព ពីព្យាការីបច្ចុប្បន្ន និងប្រធាននៃសាសនាចក្រ។

## ការសិក្សាព្រះគម្ពីរ

| | | |
|---|---|---|
| នីហ្វៃទី 2 3 | អេភេសូរ 1៖10 | យ៉ាកុប 1៖5 |
| សូមមើល គ និង ស 112៖30 | អេភេសូរ 4៖5 | កូនសៀវភៅ *សក្ខីភាពរបស់ព្យាការីយ៉ូសែប ស្ម៊ីធ* |

## ព្រះគម្ពីរមរមនៈ សក្ខីភាពមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ



ដោយការដឹងអំពីការសង្ស័យ ការមិនជឿ និងការផ្តល់ព័ត៌មានដែលនៅតែមានបន្ទាប់ពីភាពខ្មៅងងឹតជាច្រើន ព្រះវរបិតាសួគ៌ជាទីស្រលាញ់របស់យើង បាននាំមកវិញ ព្រះគម្ពីរដ៏បរិសុទ្ធពីបុរាណមួយក្បាលដែលអាចប្រៀបធៀប ជាមួយនឹងព្រះគម្ពីរបរិសុទ្ធដែលមាននូវភាពពេញលេញនៃដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទដ៏គ្មានទីបំផុត។ ព្រះគម្ពីរដ៏បរិសុទ្ធមួយក្បាលនេះ ផ្តល់ឱ្យនូវភស្តុតាងថា យ៉ូសែប ស្ម៊ីធគឺជាព្យាការីពិតរបស់ព្រះ។ បញ្ជីប្រវត្តិនេះគឺជា ព្រះគម្ពីរមរមនៈ សក្ខីបទមួយ ទៀតអំពីព្រះយេស៊ូវគ្រីស្ទ។

យ៉ូសែប ស្ម៊ីធ ត្រូវបានដឹកនាំដោយ អ្នកនាំសារសួគ៌ ឈ្មោះ មរ៉ូណៃ ទៅដល់ភ្នំមួយ ដែលជាកន្លែងដែលផ្ទាំងមាសបានកប់ទុក អស់ពេលរាប់សតវត្សន៍។ ផ្ទាំងមាសទាំងនេះ មាននូវការសរសេររបស់ព្យាការី ស្តីពីដំណើររឿងរបស់ព្រះ ជាមួយនឹង មនុស្សនៅ ទ្វីបអាមេរិក ពីបុរាណ។ យ៉ូសែប ស្ម៊ីធ បានបកប្រែបញ្ជីរឿង នៃផ្ទាំងទាំងនេះ ដោយព្រះចេស្តានៃព្រះ។ ព្យាការីនៅក្នុងព្រះ គម្ពីរមរមន បានដឹងអំពីបេសកកម្មរបស់ព្រះអង្គសង្គ្រោះ ហើយបានបង្រៀនដំណឹងល្អរបស់ទ្រង់។ បន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ ព្រះគ្រីស្ទបានយាងមកជួបជាមួយនឹងមនុស្សទាំងនេះ។ ទ្រង់បានបង្រៀន ពួកគេដំណឹងល្អរបស់ទ្រង់ ហើយបានសាងសាសនាចក្ររបស់ទ្រង់។ ព្រះគម្ពីរមរមនបានបំភ្លឺថា “ព្រះទ្រង់បំភ្លឺគំនិត មនុស្សលោក ហើយហៅពួកគេ ឱ្យមករកកិច្ចការ ដ៏បរិសុទ្ធរបស់ទ្រង់ នៅសម័យនិងជំនាន់នេះ ក៏ដូចជានៅជំនាន់បុរាណដែរ” (សូមមើល គ និង ស 20៖11)។ ដើម្បីដឹងថា ព្រះគម្ពីរមរមនពិត បុគ្គលម្នាក់ត្រូវតែអាន ពិចារណា និងអធិស្ឋាន អំពីព្រះគម្ពីរមរមន។ អ្នកដែលស្វែងរកសេចក្តីពិតដ៏ស្មោះត្រង់ នឹងឆាប់ទទួលអារម្មណ៍ថា ព្រះគម្ពីរមរមន គឺជាព្រះបន្ទូលរបស់ព្រះ។

ការអាន ការពិចារណា និងការអធិស្ឋានអំពីព្រះគម្ពីរមរមន គឺជាការចាំបាច់ណាស់ សំរាប់អ្នកផ្លាស់សាសនា ដែលមានចិត្តស៊ូទ្រាំ។ អ្នកទាំងឡាយណាដែលចាប់ផ្តើមអានព្រះគម្ពីរមរមន ពេលដំបូង យកជំហានសំខាន់ឆ្ពោះទៅមុខដើម្បី ដឹងថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីរបស់ព្រះ ហើយថា សាសនាចក្រពិតគឺត្រូវបានសាងឡើងវិញនៅលើផែនដី។

កំណត់ចំណាំ

## ប្រើព្រះគម្ពីរមរមនដើម្បីបញ្ជាក់សេចក្ដីពិតនៃការស្ដារឡើងវិញ

ផ្នែកខាងក្រោមគឺជាគំរូនៃអ្វីដែលអ្នកអាចនិយាយ នៅពេលដែលអ្នកណែនាំពីព្រះគម្ពីរមរមន៖

"ព្រះស្រលាញ់កូនចៅរបស់ទ្រង់ ដូច្នេះទ្រង់ផ្ដល់ឱ្យរបៀបដើម្បីបញ្ជាក់សេចក្ដីពិតនៃអ្វីដែលយើងបាននិយាយ។ នោះ គឺជាព្រះគម្ពីរមរមន។ សូមអ្នកអានកថាខ័ណ្ឌពីរចុងក្រោយនៅក្នុងបុព្វកថា នៃព្រះគម្ពីរ បានទេ?" បើសិនជាបុព្វកថានោះ មិនទាន់មាននៅក្នុងព្រះគម្ពីរមរមនទេ សូមអានកថាខ័ណ្ឌពីរចុងក្រោយ នៃបុព្វកថា នៅក្នុងព្រះគម្ពីរមរមនជាភាសាអង់គ្លេស ហើយផ្ដល់សេចក្ដីសង្ខេបនៃកថាខ័ណ្ឌនោះ។

ពន្យល់ដោយយកចិត្តទុកដាក់ នូវគំនិតនៅក្នុងកថាខ័ណ្ឌទាំងពីរ ហើយចូរអញ្ជើញសាសនទានកៈ តាំងចិត្តដើម្បីអានផ្នែកខ្លះៗ នៃព្រះគម្ពីរមរមន ហើយអនុវត្តគោលការណ៍ដែលបានពិពណ៌នានៅក្នុងកថាខ័ណ្ឌទាំងពីរនេះ។

---

នៅពេលដែលអ្នកណែនាំមនុស្សម្នាក់ឱ្យស្គាល់ព្រះគម្ពីរមរមន វាជាជំនួយដ៏ប្រសើរដើម្បីបង្ហាញពួកគេនូវព្រះគម្ពីរមរមន មួយក្បាល ប្រាប់ត្រួសៗពីប្រវត្តិ ហើយចែកចាយសារដំណឹងមួយឬពីរ ដែលមានន័យចំពោះអ្នក ឬដែលអាចមានន័យចំពោះ ពួកគេ។

## ការសិក្សាព្រះគម្ពីរ

| | | |
|---|---|---|
| ទំព័រចំណងជើងនៃព្រះគម្ពីរមរមន | សូមមើល គ និង ស ១៖១៧–២៣ | យ៉ូសែប ស្ម៊ីធ–ប្រវត្តិ ១៖២៧–៦៤ |
| បុព្វកថានៃព្រះគម្ពីរមរមន កថាខ័ណ្ឌ ១–៧ | គ និង ស ២០៖៥-១២ | |

## អធិស្ឋានដើម្បីដឹងពីសេចក្ដីពិតតាមរយៈព្រះវិញ្ញាណបរិសុទ្ធ

សារដំណឹងនៃការស្ដារឡើងវិញ បើវាមិនមែនជាការពិត គឺវាជាការពិត។ យើងអាចដឹងថា ពិតដោយព្រះវិញ្ញាណបរិសុទ្ធ ដូចដែលបានសន្យានៅក្នុងមរ៉ូណៃ ១០៖៣–៥។ បន្ទាប់ពីអាន ហើយពិចារណាពីសារដំណឹងនៃព្រះគម្ពីរមរមន អ្នកទាំងឡាយណា ដែលប្ដេជ្ញាចិត្តដើម្បីដឹងសេចក្ដីពិត ត្រូវតែសួរនៅក្នុងការអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ បើវាជាការពិត។ ដើម្បីសួរដល់ព្រះអង្គ យើងត្រូវហៅព្រះនាមព្រះវរបិតាសួគ៌របស់យើង។ យើងថ្លែងអំណរគុណដល់ទ្រង់ សំរាប់ពរជ័យដែលយើងទទួល ហើយសួរទ្រង់ដើម្បីដឹងថា សារដំណឹងនៃព្រះគម្ពីរមរមន គឺពិត។ គ្មាននរណាម្នាក់ដឹងវិញ្ញាណនៃសេចក្ដីពិតដោយមិនអធិស្ឋានទេ។

> **ការអធិស្ឋាន**
>
> - ហៅព្រះនាមព្រះវរបិតាសួគ៌យើង ("ព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌ . . . ")
> - បង្ហាញពីអារម្មណ៍នៅក្នុងដួងចិត្តរបស់អ្នក (អំណរគុណ, សំនួរ, ស្នើរដើម្បីបញ្ជាក់ថា ព្រះគម្ពីរមរមន គឺពិត ។ល។)។
> - បិទ ("នៅក្នុងនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន")។

ក្នុងការឆ្លើយចំពោះការអធិស្ឋានរបស់យើង ព្រះវិញ្ញាណបរិសុទ្ធនឹងបង្រៀនយើងសេចក្ដីពិត តាមរយៈអារម្មណ៍ និងគំនិតរបស់យើង។ អារម្មណ៍ដែលមកពីព្រះវិញ្ញាណបរិសុទ្ធ គឺមានអំណាច តែអារម្មណ៍នោះជាធម្មតា ជាអារម្មណ៍ សុភាព និងស្ងប់ស្ងាត់។ នៅពេលដែលយើងចាប់ផ្ដើមទទួលអារម្មណ៍ថា អ្វីដែលយើងរៀន គឺពិត នោះយើងនឹងប្ដេជ្ញាចិត្តចង់ដឹងអ្វីៗដែលយើងអាចដឹង ទៅបានអំពីការស្ដារឡើងវិញ។

ការដឹងថា ព្រះគម្ពីរមរមន គឺពិត នាំទៅកាន់ចំណេះវិជ្ជាដែលថា យ៉ូសែប ស្ម៊ីធ គឺត្រូវបានហៅធ្វើជាព្យាការី ហើយថា ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ត្រូវបានសាងឡើងវិញតាមរយៈលោក។

## ការអធិស្ឋាន

ទោះជាការអធិស្ឋាន មានតួនាទីជាច្រើន នៅក្នុងសាសនានិងវប្បធម៌ជាច្រើនក៏ដោយ តែការអធិស្ឋានកំរត្រូវបានគេចាត់ទុកថា ជារបៀបពីរដើម្បីទំនាក់ទំនងរវាងព្រះ និងមនុស្សណាស់។ ជួយអ្នកទាំងឡាយដែលអ្នកបង្រៀនឱ្យយល់ថា ពួកគេ អាច និយាយជាមួយព្រះ ពីអារម្មណ៍នៅក្នុងដួងចិត្តរបស់ពួកគេ នៅក្នុងការអធិស្ឋាន។ ចូរស្រាយបំភ្លឺការអធិស្ឋាន នៅក្នុងរបៀបដែល អ្នកអធិស្ឋាន នៅពេលចាប់ផ្ដើម ឬបញ្ចប់មេរៀន។ ប្រើភាសាសាមញ្ញ ដែលពួកគេអាចប្រើ នៅពេលគេអធិស្ឋាន។ ជួយពួកគេ យល់ថា ព្រះវរបិតាសួគ៌ របស់យើងនឹងឆ្លើយការអធិស្ឋានរបស់ពួកគេ តាមរយៈអារម្មណ៍នៃ ដួងចិត្ត ហើយការគិតនៅក្នុងគំនិត របស់គេ។ បើពួកគេស្មោះ ហើយពិតជាចង់ដឹងថា ព្រះនៅទីនោះឬអត់ នោះទ្រង់នឹងឆ្លើយការអធិស្ឋានរបស់ពួកគេ។ ចូរអញ្ជើញមេគ្រួសារនៅក្នុងផ្ទះ ឱ្យលុតជង្គង់ចុះហើយអធិស្ឋាននៅចុងបញ្ចប់នៃមេរៀន។

កំណត់ចំណាំ

## ការសិក្សាព្រះគម្ពីរ

អាលម៉ា 5៖45–46
សូមមើល គ និង ស 8៖2–3

យ៉ូហាន 14៖26

បុព្វកថានៃព្រះគម្ពីរមរមន
កថាខ័ណ្ឌ 8–9

## ការអញ្ជើញដើម្បីទទួលបុណ្យជ្រមុជទឹក

នៅកំឡុងនៃមេរៀននេះ ឬមេរៀនផ្សេងទៀត ចូរកុំស្ទាក់ស្ទើរដើម្បីអញ្ជើញមនុស្ស ឱ្យទទួលបុណ្យជ្រមុជទឹក និងទទួលពិធីបញ្ជាក់។

ដើម្បីរៀបចំសាសនាគន់ការឱ្យទទួលការអញ្ជើញដើម្បីទទួលបុណ្យជ្រមុជទឹក និងទទួលពិធីបញ្ជាក់ បង្រៀនគោលលទ្ធិនៃ បុណ្យជ្រមុជទឹក ហើយថ្លែងសក្ខីភាពញឹកញាប់អំពីសារៈសំខាន់ចំពោះមនុស្សទាំងអស់ ក្នុងការទទួលបុណ្យជ្រមុជទឹកដោយ សិទ្ធិអំណាច ដោយការ រំដោះបាប ហើយអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។ អ្នកប្រហែលជានិយាយថា៖ “នៅពេលដែលព្រះ អម្ចាស់ឆ្លើយចំពោះការ អធិស្ឋានរបស់អ្នក ហើយអ្នកមានអារម្មណ៍ថាសារដំណឹងនេះ គឺពិត តើអ្នកព្រមធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ដោយការទទួលបុណ្យជ្រមុជទឹក ដែរឬទេ?”

ការអញ្ជើញដើម្បីទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់គួរតែច្បាស់លាស់ហើយចំពោះ “តើអ្នកព្រមធ្វើតាមគំរូរបស់ ព្រះយេស៊ូវ គ្រីស្ទ ដោយការទទួលបុណ្យជ្រមុជទឹក ដោយនរណាម្នាក់ដែលកាន់សិទ្ធិអំណាចបព្វជិតភាពរបស់ព្រះ ដែរឬទេ? យើងនឹងធ្វើការ បំពេញពិធីបុណ្យជ្រមុជទឹកនៅ (កាលបរិច្ឆេទ)។ តើអ្នកព្រមរៀបចំខ្លួនរបស់អ្នក ដើម្បីទទួលបុណ្យជ្រមុជទឹកនៅតាមកាលបរិច្ឆេទនោះ ដែរឬទេ?

# គំនិតសំរាប់ការបង្រៀន

កំណត់ចំណាំ

កំណ្ឌនេះ មានគំនិតសំរាប់អ្នកដើម្បីប្រើ ក្នុងការរៀបចំ និងការបង្រៀនមេរៀននេះ។ ចូរធ្វើការអធិស្ឋាន ធ្វើតាមព្រះវិញ្ញាណនៅពេលដែល អ្នកសំរេចចិត្តពីរបៀបប្រើគំនិតទាំងនេះ។ បន្ថែមគំនិតដែលអ្នកជ្រើសរើស ចូលទៅក្នុងគំរោងមេរៀនរបស់អ្នក។ សូមចងចាំថា គំនិតទាំងនេះគឺជាយោបល់—មិនចាំបាច់ត្រូវតែធ្វើដូច្នេះទេ—ដើម្បីជួយអ្នកបំពេញសេចក្តីត្រូវការរបស់អ្នកទាំងឡាយណាដែល អ្នកបង្រៀន។

## ផែនការមេរៀនខ្លីៗ (3–5 នាទី)

ក្រោយពីការបាត់បង់ជាច្រើនសតវត្សក្រោយមក ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ បានត្រូវស្តារឡើងវិញនៅលើផែនដីដោយ ព្រះវរបិតាសួគ៌ជាទីស្រលាញ់របស់យើង តាមរយៈព្យាការីដែលនៅរស់។ ព្រះគម្ពីរមរមន គឺជាភស្តុតាងនៃការណ៍នេះ។ អ្នកអាចកាន់ ព្រះគម្ពីរមរមននៅក្នុងដៃរបស់អ្នក។ អ្នកអាចអាន ហើយពិចារណាអំពីរបៀបដែលសារដំណឹងនៅក្នុងព្រះគម្ពីរនេះ អាចកែលំអ ដល់ជីវិតរបស់អ្នក ហើយអធិស្ឋានដើម្បីដឹងថា សារដំណឹងនេះគឺជាព្រះបន្ទូលរបស់ព្រះ។

- ព្រះគឺជាព្រះវរបិតាសួគ៌ជាទីស្រលាញ់របស់យើង
- ដំណឹងល្អប្រសិទ្ធពរដល់ក្រុមគ្រួសារ
- ព្រះវរបិតាសួគ៌បើកសម្តែងដំណឹងល្អរបស់ទ្រង់ នៅគ្រប់សម័យកាន់កាប់ត្រួតត្រា
- ការបំរើរបស់ព្រះអង្គសង្គ្រោះនៅលើផែនដី និងដង្វាយធួន
- ការក្បត់សាសនាដ៏ធំ
- ការស្តារឡើងវិញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ តាមរយៈយ៉ូសែប ស្ម៊ីធ
- ព្រះគម្ពីរមរមនៈ សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ
- អធិស្ឋានដើម្បីដឹងសេចក្តីពិតតាមរយៈព្រះវិញ្ញាណបរិសុទ្ធ

### ការតាំងចិត្តៈ

- តើអ្នកព្រមអាន និងអធិស្ឋានដើម្បីដឹងថា ព្រះគម្ពីរមរមន គឺជាព្រះបន្ទូលរបស់ព្រះ ដែរឬទេ?
- តើអ្នកព្រមអធិស្ឋាន ដើម្បីដឹងថា យ៉ូសែប ស្ម៊ីធ ជាព្យាការី ដែរឬទេ?
- តើអ្នកព្រមទៅព្រះវិហារជាមួយយើង នៅថ្ងៃអាទិត្យនេះ ដែរឬទេ?
- តើយើងអាចណាត់ជួប សំរាប់ពេលក្រោយបានទេ?
- បទបញ្ញត្តិចេញពីមេរៀនទី 4 ដែលអ្នកជ្រើសរើសដើម្បីបញ្ចូល។

## ផែនការមេរៀនមធ្យម (10–15 នាទី)

សារដំណឹងរបស់យើង គឺគួរឱ្យកត់សំគាល់ ហើយសាមញ្ញ។ ព្រះគឺជាព្រះវរបិតារបស់យើង។ យើងជាកូនចៅរបស់ទ្រង់។ យើងគឺជាចំណែកនៃគ្រួសាររបស់ទ្រង់។ ទ្រង់ស្រលាញ់យើង។ តាំងពីការចាប់ផ្តើមនៃពិភពលោក ទ្រង់បានធ្វើតាមគំរូនៃ សេចក្តីស្រលាញ់ និងការខ្វល់ខ្វាយ។ ទ្រង់បានបង្ហាញសេចក្តីស្រលាញ់របស់ទ្រង់ជាច្រើនដង ដើម្បីបើកសម្តែងដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ ដើម្បីឱ្យកូនចៅរបស់ទ្រង់អាចដឹងពីរបៀបត្រឡប់ទៅទ្រង់វិញ។ ទ្រង់បានបើកសម្តែងការណ៍នេះ ទៅព្យាការីរបស់ទ្រង់ ដូចជា អ័ដាម ណូអេ អ័ប្រាហាំ និងម៉ូសេ។ តែមនុស្សបានជ្រើសរើសបដិសេធដំណឹងល្អនោះម្តងហើយ ម្តងទៀត។ ពីរពាន់ឆ្នាំកន្លងទៅហើយ ព្រះយេស៊ូវគ្រីស្ទទ្រង់ ផ្ទាល់បានបង្រៀនដំណឹងល្អរបស់ទ្រង់ និងបានសាងសាសនាចក្រទ្រង់ ហើយធ្វើដង្វាយធួនបានសំរេច។ មិនគួរឱ្យជឿសោះ មនុស្សបដិសេធសូម្បីតែព្រះយេស៊ូវ។ នៅពេលដែលមនុស្សមិនយកចិត្តទុកដាក់ និងធ្វើឱ្យខូចទំរង់គោលលទ្ធិពិតនិងពិធីការផ្សេងៗ នោះព្រះដកយកសិទ្ធិអំណាចដើម្បីបំរើចេញពីសាសនាចក្រ។

មេរៀនទី 1៖
ការស្ដារឡើងវិញ

កំណត់ចំណាំ

ការអញ្ជើញរបស់យើងចំពោះអ្នក និងមនុស្សទាំងអស់ គឺដើម្បីបន្ថែមទៅលើសេចក្ដីពិត ដែលអ្នកបានសន្សំទុករួចទៅហើយ។ សូមពិចារណាពីភស្ដុតាងរបស់យើងដែលថា ព្រះវរបិតាសួគ៌របស់យើង និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវ គ្រីស្ទ បានងាក មករកកូនចៅរបស់ទ្រង់ នៅក្នុងសេចក្ដីស្រលាញ់ម្ដងទៀត ហើយបើកសម្ដែងភាពពេញលេញនៃដំណឹងល្អទៅកាន់ព្យាការីម្នាក់។ ព្យាការីម្នាក់នេះឈ្មោះថា យ៉ូសែប ស្ម៊ីធ។ ភស្ដុតាងនៃភាពរុងរឿងនៃសេចក្ដីពិតនេះ គឺត្រូវបានរកឃើញនៅក្នុងព្រះគម្ពីរ—ព្រះគម្ពីរមរមន—ដែលអ្នកអាចអានពិចារណា ហើយអធិស្ឋាន។ បើអ្នកអធិស្ឋានដោយស្មោះអស់ពីដួងចិត្តជាមួយនឹងគោល បំណងពិត ហើយមានជំនឿនៅក្នុងព្រះគ្រីស្ទ ព្រះនឹងប្រាប់អ្នកដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធថា វាគឺជាការពិត។

### ការតាំងចិត្ត៖

- តើអ្នកព្រមអាន និងអធិស្ឋានដើម្បីដឹងថា ព្រះគម្ពីរមរមន គឺជាព្រះបន្ទូលរបស់ព្រះ ដែរឬទេ?
- តើអ្នកព្រមអធិស្ឋាន ដើម្បីដឹងថា យ៉ូសែប ស្ម៊ីធ ជាព្យាការី ដែរឬទេ?
- តើអ្នកព្រមទៅព្រះវិហារជាមួយយើង នៅថ្ងៃអាទិត្យនេះ ដែរឬទេ?
- តើយើងអាចណាត់ជួប សំរាប់ពេលក្រោយបានទេ?
- បទបញ្ញត្តិចេញពីមេរៀនទី 4 ដែលអ្នកជ្រើសរើសដើម្បីបញ្ចូល។

### ផែនការណ៍មេរៀនទាំងមូល (30-45 នាទី)

- ព្រះគឺជាព្រះវរបិតាសួគ៌ជាទីស្រលាញ់របស់យើង
  - យើងគឺជាកូនចៅរបស់ព្រះ (កិច្ចការពួកសាវក 17៖29)។
  - ព្រះស្រលាញ់យើង ហើយទ្រង់នឹងជួយយើងធ្វើការជ្រើសរើសត្រឹមត្រូវ។
  - តាមរយៈព្រះយេស៊ូវគ្រីស្ទ យើងអាចរស់នៅជាមួយព្រះម្ដងទៀត (សូមមើល យ៉ូហាន 3៖16–17)។
- ដំណឹងល្អប្រសិទ្ធពរដល់ក្រុមគ្រួសារ
  - ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ជួយដល់ក្រុមគ្រួសារបង្កើនចំណងមិត្តភាពកាន់តែរឹងមាំ។
  - ក្រុមគ្រួសារគឺតែងតាំងឡើងដោយព្រះ ក្រុមគ្រួសារសំខាន់បំផុតនៅក្នុងសង្គម សំរាប់បច្ចុប្បន្ន និងសំរាប់ភាពអស់កល្បជានិច្ច (សូមមើល គ និង ស 49៖15–16)។
  - ក្រុមគ្រួសារគឺជាកន្លែងដ៏ប្រសើរបំផុតដើម្បីបង្រៀន រៀន និងអនុវត្តគោលការណ៍ដំណឹងល្អ (សូមមើល គ និង ស 68៖25 លោកុប្បត្តិ 18៖19, ចោទិយកថា 6៖7)។
  - ក្រុមគ្រួសារអាចជាកន្លែងនៃសុវត្ថិភាព សន្តិភាព និងរីករាយ
- ព្រះវរបិតាសួគ៌បើកសម្ដែងដំណឹងល្អរបស់ទ្រង់ នៅគ្រប់សម័យកាន់កាប់ត្រួតត្រា
  - ព្រះហៅព្យាការីដើម្បីបង្រៀនដំណឹងល្អដល់កូនចៅរបស់ទ្រង់ (សូមមើល អេម៉ុស 3៖7)។
  - ការក្បត់សាសនាមានន័យថា ការបដិសេធព្យាការីនឹងដំណឹងល្អ។
  - សម័យកាន់កាប់ត្រួតត្រា គឺជារយៈពេល ដែលព្យាការីបានបង្រៀនដំណឹងល្អ។ សម័យកាន់កាប់ត្រួតត្រាមុន បានបញ្ចប់នៅក្នុងការក្បត់សាសនា (សូមមើល គ និង ស 136៖36–38)។
  - អាលម៉ា ណូអេ អ័ប្រាហាំ ម៉ូសេ និងព្យាការីបុរាណទាំងអស់ផ្សេងៗទៀត បានបង្រៀនដំណឹងល្អ (សូមមើល ម៉ូសេ 5៖4–12)។

កំណត់ចំណាំ

- ការបំរើរបស់ព្រះអង្គសង្គ្រោះនៅលើផែនដី និងដង្វាយធួន
  - ព្រះរាជបុត្រារបស់ព្រះបានស្ដារឡើងវិញ និងបានបង្រៀនដំណឹងល្អ។ ទ្រង់បានធ្វើឱ្យមាន អព្ភូតហេតុជាច្រើនកើតឡើង (សូមមើល Guide to the Scriptures, "Miracle," 165)។
  - ទ្រង់បានហៅសាវក ហើយប្រគល់ដល់ពួកគេសិទ្ធិអំណាចបព្វជិតភាព ដើម្បីប្រៀនប្រដៅពីដំណឹងល្អ ហើយនឹង ធ្វើពិធីការសង្គ្រោះ ដូចជា ពិធីបុណ្យជ្រមុជទឹក (សូមមើល យ៉ូហាន 15៖16)។
  - ព្រះគ្រីស្ទបានសាងសាសនាចក្ររបស់ទ្រង់
  - ព្រះគ្រីស្ទត្រូវបានឆ្កាង ហើយសាវករបស់ទ្រង់ត្រូវបានបដិសេធ ហើយសំលាប់ (សូមមើល ម៉ាថាយ 27៖35 ម៉ាកុស 15៖25)។
  - ព្រះគ្រីស្ទបានសំរេចនូវដង្វាយធួន (សូមមើល Guide to the Scriptures "Atone, Atonement," 22–23)។
- ការក្បត់សាសនាដ៏ធំ
  - គ្មានវិវរណៈតាមរយៈព្យាការីទេ មនុស្សធ្លាក់ក្នុងភាពខ្វាក់ងងឹតខាងវិញ្ញាណ (សូមមើល អេម៉ុស 8៖11–12)។
  - ព្យាការី និងសាវក បានត្រូវប្រាប់ជាមុនអំពីការក្បត់សាសនាដ៏ធំ (សូមមើល ថែស្សាឡូនីចទី 2 2៖1–3)។
- ការស្ដារឡើងវិញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ តាមរយៈយ៉ូសែប ស្ម៊ីធ
  - យ៉ូសែប ស្ម៊ីធ ស្វែងរកសេចក្ដីពិត (សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1៖8, 10)។
  - ព្រះ និងព្រះយេស៊ូវគ្រីស្ទ បានយាងមកជួបយ៉ូសែប ស្ម៊ីធ (សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1៖16–17)។
  - ដូចជាព្យាការីនៅក្នុងសម័យកាន់កាប់ត្រួតត្រាសម័យមុនដែរ យ៉ូសែប ស្ម៊ីធ បានត្រូវហៅដោយព្រះ ធ្វើជាព្យាការីនៅក្នុង សម័យកាន់កាប់ត្រួតត្រា ចុងក្រោយបង្អស់នេះ។
  - ព្រះបានស្ដារឡើងវិញភាពពេញលេញនៃដំណឹងល្អ តាមរយៈយ៉ូសែប ស្ម៊ីធ (សូមមើល គ និង ស 35៖17, 135៖3)។
  - អ្នកនាំសារស្ថគ៌ផ្សេងៗទៀត បានស្ដារបព្វជិតភាពឡើងវិញ ហើយសាសនាចក្ររបស់ព្រះគ្រីស្ទបានត្រូវរៀប ចំឡើង (សូមមើល គ និង ស 13, 27៖12)។
  - ព្យាការីដែលនៅរស់ដឹកនាំសាសនាចក្រសព្វថ្ងៃនេះ។
- ព្រះគម្ពីរមរមនៈ សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ
  - ព្រះគម្ពីរមរមនគឺជាភស្តុតាងដែលបញ្ជាក់ថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការី។
  - យ៉ូសែប បានបកប្រែផ្ទាំង ដោយអំណាចរបស់ព្រះ (សូមមើល បុព្វកថានៃព្រះគម្ពីរមរមន កថាខ័ណ្ឌទី 5)។
  - ព្រះគម្ពីរមរមនបង្ហាញថា ព្រះបំផុសគំនិតព្យាការីនៅក្នុងសម័យរបស់យើង ដូចដែលទ្រង់បាន បំផុសគំនិតព្យាការី នៅគ្រប់សម័យកាន់កាប់ត្រួតត្រា (សូមមើល គ និង ស 20៖5–12)។
  - ព្រះគម្ពីរមរមន មាននូវភាពពេញលេញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ (សូមមើល គ និង ស 20៖8–9)។

មេរៀនទី 1៖
ការស្ដារឡើងវិញ

កំណត់ចំណាំ

- អធិស្ឋានដើម្បីដឹងសេចក្ដីពិតតាមរយៈព្រះវិញ្ញាណបរិសុទ្ធ
  - អ្នកអាចដឹងថា ព្រះគម្ពីរមរមន គឺពិត (សូមមើល ម៉ូរ៉ូណៃ 10៖3–5 បុព្វកថានៃព្រះគម្ពីរមរមន កថាខ័ណ្ឌទី 1 8–9)។
  - ព្រះវិញ្ញាណបរិសុទ្ធ នឹងបង្រៀនអ្នកតាមរយៈគំនិត និងអារម្មណ៍របស់អ្នក (សូមមើល គ និង ស 8៖2–3)។

ការតាំងចិត្ត៖

- តើអ្នកព្រមអាន និងអធិស្ឋានដើម្បីដឹងថា ព្រះគម្ពីរមរមន គឺជាព្រះបន្ទូលរបស់ព្រះ ដែរឬទេ?
- តើអ្នកព្រមអធិស្ឋាន ដើម្បីដឹងថា យ៉ូសែប ស្ម៊ីធ ជាព្យាការី ដែរឬទេ?
- តើអ្នកព្រមទៅព្រះវិហារជាមួយយើង នៅថ្ងៃអាទិត្យនេះ ដែរឬទេ?
- តើយើងអាចណាត់ជួប សំរាប់ពេលក្រោយបានទេ?
- បទបញ្ញត្តិចេញពីមេរៀនទី 4 ដែលអ្នកជ្រើសរើសដើម្បីបញ្ចូល។

## សំនួរដើម្បីសួរបន្ទាប់ពីអ្នកបង្រៀន

- តើអ្នកមានសំនួរអ្វីទេ អំពីអ្វីដែលយើងបានបង្រៀន?
- បើសិនជា មានព្យាការីនៅលើផែនដីសព្វថ្ងៃនេះ តើអ្នកនឹងសួរលោកពីអ្វីខ្លះ?
- តើអ្នកជឿថា ព្រះលឺការអធិស្ឋានរបស់អ្នកដែរឬទេ? ហេតុអ្វី?
- តើអ្នកចង់ដឹងថា ព្រះគម្ពីរមរមនពិតដែរឬទេ? ហេតុអ្វី?

## និយមន័យសំខាន់ៗ

- **សេរីភាព៖** សមត្ថភាព និងឯកសិទ្ធិ ដែលព្រះប្រទានដល់មនុស្សដើម្បីជ្រើសរើស ហើយប្រព្រឹត្តដោយខ្លួនឯង។
- **ការក្បត់សាសនា៖** ការងាកចេញឆ្ងាយពីសេចក្ដីពិត ដោយបុគ្គលម្នាក់ៗ សាសនាចក្រ ឬប្រជាជាតិទាំងមូល។ ការក្បត់សាសនា បូករួមទាំងការប្រឆាំងបះបោរនឹងសិទ្ធិអំណាច ហើយបដិសេធព្យាការី។ ភស្តុតាងនៃការក្បត់សាសនា បូករួមទាំងការបំពានក្រិត្យវិន័យរបស់ព្រះ ការផ្លាស់ប្ដូរពិធីការដំណឹងល្អ និងការក្បត់សេចក្ដីសញ្ញា (សូមមើល អេសាយ 24៖5)។
- **សម័យកាន់កាប់ត្រួតត្រា៖** រយៈពេលដែលព្រះអម្ចាស់ បានផ្ដល់សិទ្ធិអំណាចដល់អ្នកបំរើយ៉ាងហោចណាស់ម្នាក់នៅលើផែនដី ដែលជាអ្នកកាន់កូនសោនៃបព្វជិតភាពបរិសុទ្ធ។ បន្ថែមពីលើព្រះយេស៊ូវគ្រីស្ទ ព្យាការីដូចជា អ័ដាម ហេណុក ណូអេ អ័ប្រាហាំ ម៉ូសេ និងព្យាការីយ៉ូសែប ស្ម៊ីធ សុទ្ធបានចាប់ផ្ដើមថ្មីសម័យកាន់កាប់ត្រួតត្រា ដំណឹងល្អ។ នៅពេលដែលព្រះអម្ចាស់ បានរៀបចំសម័យកាន់កាប់ត្រួតត្រា ដំណឹងល្អគឺត្រូវបានបើកសម្ដែងជាថ្មី ដើម្បីមនុស្សដែលនៅក្នុង សម័យកាន់កាប់ត្រួតត្រា នោះ មិនចាំ បាច់ពឹងទៅលើសម័យកាន់កាប់ត្រួតត្រា មុនសំរាប់ ចំណេះដឹងនៃផែនការនៃសេចក្ដីសង្គ្រោះ។ សម័យកាន់កាប់ត្រួតត្រា ចាប់ផ្ដើមដោយយ៉ូសែប ស្ម៊ីធ គឺត្រូវបាន ដឹងថា "សម័យកាន់កាប់ត្រួតត្រាដែលពេញកំណត់។"
- **បព្វជិតភាព៖** សិទ្ធិ និងអំណាចដែលព្រះប្រគល់ឱ្យដល់បុរសដើម្បីធ្វើកិច្ចការ នៅក្នុងព្រះនាមរបស់ព្រះ យេស៊ូវគ្រីស្ទ នៅក្នុងគ្រប់អ្វីៗទាំងអស់ ដើម្បីសង្គ្រោះដល់មនុស្សលោក។
- **ព្យាការី៖** បុរសដែលត្រូវបានហៅ និងនិយាយជំនួសព្រះ។ ក្នុងនាមជាសារការីរបស់ព្រះ ព្យាការីទទួល សិទ្ធិអំណាច បព្វជិតភាព ព្រះបញ្ញត្តិ ការព្យាករណ៍ និងវិវរណៈមកពីព្រះ។ ការទទួលខុសត្រូវរបស់ព្យាការី គឺដើម្បីធ្វើឱ្យ មនុស្សលោកដឹងពីទ្រង់ បុគ្គលិកលក្ខណៈពិតរបស់ព្រះចំពោះមនុស្សលោក និងដើម្បីបង្ហាញពីអត្ថន័យ ទំនាក់ទំនងរបស់ទ្រង់ជាមួយពួកគេ។ ព្យាការីបរិហារអំពើបាប ហើយប្រាប់ពីមុន នូវលទ្ធផលនៃអំពើបាប។ យូរម្ដងៗ ព្យាការីអាចទទួលការបំផុសគំនិត ដើម្បីប្រាប់ពីអនាគតសំរាប់ជាប្រយោជន៍ដល់មនុស្ស លោកទាំងអស់។ ការទទួលខុសត្រូវជំបូងរបស់លោកគឺ ធ្វើជា សាក្សីនៃព្រះគ្រីស្ទ។

កំណត់ចំណាំ

- **ព្រះប្រោសលោះ៖** ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះប្រោសលោះដ៏មហិមានៃមនុស្សលោក ដោយសារទ្រង់ និងតាម រយៈដង្វាយធួនរបស់ទ្រង់ ទ្រង់បានបង់ថ្លៃសំរាប់អំពើបាបនៃមនុស្សលោក ហើយធ្វើឱ្យការរស់ឡើងវិញអាច កើតមានចំពោះ មនុស្សទាំងអស់។ ការប្រោសលោះ គឺជាការលោះលែង ទិញ ឬលោះ ដូចជារំដោះមនុស្សម្នាក់ឱ្យរួចពីសេវកភាព ដោយការ បង់ថ្លៃ។ ការប្រោសលោះ សំដៅទៅ លើដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និងការដោះឱ្យរួចពីអំពើបាប។ ដង្វាយធួនរបស់ព្រះ យេស៊ូវប្រោសលោះមនុស្សលោកទាំង អស់ឱ្យរួចពីសេចក្ដីស្លាប់ខាងរូបកាយ។ តាមរយៈដង្វាយ ធួនរបស់ទ្រង់ ដែលបូករួមទាំងការទទួលរងទុក្ខនៅក្នុងច្បារគែតសេម៉ានី និងនៅលើឈើឆ្កាង ព្រមទាំងការរស់ឡើង វិញផងដែរ អ្នកទាំងឡាយណាដែលមានសេចក្ដីជំនឿនៅក្នុងទ្រង់ ហើយអ្នកទាំងឡាយ ណាដែលប្រែចិត្ត គឺត្រូវបាន ប្រោសលោះចេញពីសេចក្ដីស្លាប់ខាងវិញ្ញាណ។

- **កែប្រែសាសនា៖** ការកែប្រែគឺជា ការផ្លាស់ប្ដូរអ្វីមួយ ដើម្បីកែលំអវត្ថុនោះ។ ពាក្យថា *កែប្រែសាសនា* សំដៅទៅលើបុរសនិងស្ដ្រី (ដូចជា ម៉ាធីន, លូធើ, ចន ខ្លែវីន, វិលាម ធាយឌល, និង ចន វាយលីហ្វ) ដែលជាអ្នកជំទាស់ ការអនុវត្តរបស់ព្រះ វិហារដែលនៅសល់ ពួកគេទាំងនោះមានអារម្មណ៍ថា គួរតែកែប្រែ។

- **ការស្ដារឡើងវិញ៖** ការស្ដារឡើងវិញមានន័យថា ត្រឡប់ទៅរកភាពដើមវិញ ឬនាំត្រឡប់មកវិញ។ ការស្ដារ ឡើងវិញដូចដែលបានប្រើដោយពួកបរិសុទ្ធថ្ងៃចុងក្រោយ មានន័យថាសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ ដែលបាន បាត់បង់តាមរយៈការក្បត់សាសនា គឺត្រូវបានស្ដារឡើងវិញដូចជាទំរង់ដើម ដូចដែលបានរៀបចំឡើងដោយ ព្រះយេស៊ូវគ្រីស្ទ។ មិនដូចជាការកែប្រែ សាសនាទេ ការស្ដារឡើងវិញគឺត្រូវបានសំរេចដោយសិទ្ធិអំណាចដ៏ទេវភាព តាមរយៈវិវរណៈ។

- **វិវរណៈ** ការទំនាក់ទំនងមកពីព្រះ ចំពោះកូនចៅរបស់ទ្រង់នៅលើផែនដី។ ការស្ដារឡើងវិញអាចមកតាម រយៈពន្លឺរបស់ព្រះគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធ ដោយការបំផុសគំនិត ទស្សនៈនិមិត្ត សុបិន ឬការយាងមកជួបដោយ ទេវតា។ វិវរណៈផ្ដល់នូវ ការណែនាំដែលអាចដឹកនាំទៅរកសេចក្ដីស្មោះត្រង់ ចំពោះសេចក្ដីសង្គ្រោះអស់កល្បជានិច្ចនៅ ក្នុងនគរសេឡេស្ទាល។ ព្រះអម្ចាស់ បើកសម្ដែងកិច្ចការរបស់ទ្រង់ទៅដល់ព្យាការី និងបញ្ជាក់ទៅដល់អ្នក ដែលជឿថា វិវរណៈទៅកាន់ព្យាការី គឺជាការពិត (សូមមើល អេម៉ុស 3៖7)។ តាមរយៈវិវរណៈ ព្រះអម្ចាស់ផ្ដល់នូវ ការណែនាំដល់បុគ្គលម្នាក់ដែលស្វែងរក ហើយអ្នកដែលមាន ជំនឿ ប្រែចិត្ត ហើយគឺគោរពប្រតិបត្តិចំពោះដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។

## ពាក្យផ្សេងៗទៀត ដែលអាចត្រូវការនិយមន័យបន្ថែម សំរាប់អ្នកទាំងឡាយណាដែលអ្នកបង្រៀន

- សាវក
- ព្រះគម្ពីរបរិសុទ្ធ
- ការតស៊ូដល់ទីបញ្ចប់
- អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ
- ដំណឹងល្អ
- ការគោរពប្រតិបត្តិ និងមិនគោរពប្រតិបត្តិចំពោះបទបញ្ញត្តិ
- ពិធីការនៃសេចក្ដីសង្គ្រោះ
- ការអធិស្ឋាន
- ត្រឡប់ទៅរស់នៅក្នុងទីវត្តមានរបស់ទ្រង់
- ព្រះអង្គសង្គ្រោះ
- ព្រះគម្ពីរ
- អំពើបាប
- ការត្រួតត្រា

### អ្នកកែប្រែសាសនា និងអ្នកដឹកនាំសាសនានៅលើពិភពលោក

**ផ្នែកខាងក្រោម គឺជាពត៌មានជីវះប្រវត្តិ ដើម្បីប្រើនៅពេលណាដែលចាំបាច់តែប៉ុណ្ណោះ។**

**ចន វាយលីហ្វ៖** កើតនៅក្នុងសតវត្សរ៍ទី 14 នៅក្នុងប្រទេសអង់គ្លេស។ អ្នកប្រាជ្ញទេវវិទ្យា នៅឯសកលវិទ្យាល័យ អ៊ុខហ្វឺត។ បានបង្រៀនថា ព្រះវិហារការតូលិកមិនមានកូនសោបព្វជិតភាពដើម្បីធ្វើពិធីប្រសិទ្ធពរនំប៉័ងនិងទឹក (ពិធីសាក្រាម៉ង់) មិនមែនជារូបកាយរបស់ព្រះយេស៊ូវគ្រីស្ទពិតប្រាកដទេ ហើយថាព្រះវិហារមិនគួរអនុវត្តអំណាច នយោបាយលើមនុស្សទេ។ បានបកប្រែព្រះគម្ពីរបរិសុទ្ធទៅជាភាសាអង់គ្លេស។ បានស្លាប់នៅថ្ងៃទី 31 ខែធ្នូ ឆ្នាំ 1384)។

កំណត់ចំណាំ

**ម៉ាធីន លូធើរ** កើតនៅថ្ងៃទី 10 ខែវិច្ឆិកា ឆ្នាំ 1483 នៅក្នុងប្រទេសអាឡឺម៉ង់។ ជានិសិត្សនៅសកលវិទ្យាល័យ អ៊ឺហ្វឺឌ និង វីធីនប៊ឺហ្គ។ បានបោះដែកគោលចំនួន 95 ចំណុច នៅលើទ្វារនៃព្រះវិហារខាសស៊ល ដើម្បីប្រឆាំងចំពោះ ការបង្រៀន ជាច្រើន របស់ព្រះវិហារការតូលិករ៉ូម ដោយរួមទាំងការអនុវត្តឱ្យមនុស្សប្រង់លុយ ដើម្បីទទួលការ អភ័យទោស ពីអំពើបាបរបស់ពួកគេ។ បានស្លាប់ នៅថ្ងៃទី 18 ខែកុម្ភៈ ឆ្នាំ 1546។

**វិលាម ធាយឌេលះ** កើតនៅក្នុង វ៉ែលលីស ក្នុងឆ្នាំ 1494។ ជានិសិត្សនៅឯអ៊ិខហ្វឺឌ និងខេមព្រីឌ។ បានបកប្រែព្រះ គម្ពីរសញ្ញាថ្មី ទៅជាភាសាអង់គ្លេស។ ធ្វើឱ្យព្រះគម្ពីរអាចមានចំពោះមនុស្សជាសាធារណៈ ដើម្បីឃើញ គោលលទ្ធិក្លែងក្លាយ និងការពុករលួយ នៃអ្នកដឹកនាំសាសនា។ លោកត្រូវបានគេសំលាប់នៅថ្ងៃទី 6 ខែតុលា ឆ្នាំ 1536។

**ចន វាយលីហ្វះ** កើតនៅថ្ងៃទី 10 ខែកក្កដា ឆ្នាំ 1509 នៅក្នុងប្រទេសបារាំង។ សិក្សានៅប៉ារីស ដើម្បីក្លាយជាសង្ឃ។ មុខវិជ្ជាដឹកនាំ នៅក្នុងការផ្លាស់ប្តូរ ដើម្បីកែប្រែសាសនាព្រះវិហារការតូលិក។ ពេលភាគច្រើននៃជីវិតរបស់លោក គឺរស់នៅក្នុងប្រទេសស្វីលេន។ លោកបានបង្រៀនថា មនុស្សដោយនិស្ស័យពីធម្មជាតិ គឺអាក្រក់ ហើយថា មានតែ សេចក្តីមេត្តាករុណារបស់ព្រះតែប៉ុណ្ណោះអាចសង្គ្រោះមនុស្សបាន។ គាត់បានសរសេរការកោតសរសើរជាច្រើននៅលើព្រះគម្ពីរបរិសុទ្ធ។ បានស្លាប់នៅថ្ងៃទី 27 ខែឧសភា ឆ្នាំ 1564។

សំរាប់ពតិមានបន្ថែមពីការកែប្រែសាសនា សូមមើលប្រភពធនធានដូចខាងក្រោមនៅ ក្នុងបណ្ណាល័យអ្នកផ្សព្វផ្សាយ សាសនា។ James E. Talmage, *Jesus the Christ,* 692–703, M. Russell Ballard, Our Search for Hapiness, 26–32។

ដូចដែលគ្រីស្ទនិកទូទាំងពិភពលោកបានទទួលពរជ័យដោយ ការលើកទឹកចិត្ត និងទស្សនះនិមិត្តនៃអ្នកកែប្រែសាសនា ដើម្បីឱ្យ មនុស្សជាតិ និងវប្បធម៌ជាច្រើន បានទទួលពរជ័យដោយអ្នកទាំងឡាយណាដែលផ្តល់ឱ្យនៅផ្នែកនោះ "ថា [ទ្រង់] ឃើញថាល្អម នឹងឱ្យគេមាន" (អាលម៉ា 29៖8)។ ការបង្រៀនរបស់អ្នកដឹកនាំសាសនាផ្សេងៗទៀត បានជួយដល់ មនុស្សជាច្រើន ឱ្យកាន់តែក្លាយជាជនស៊ីវិល និងកាន់តែមានសីលធម៌។

**ព្រះពុទ្ធ (ហ្គោតាមា)៖** កើត 563 ម.គ.ស. ជាប្រធានលទ្ធិហិណ្ឌូនៅក្នុងប្រទេស លោកប៉ាល់។ ទាក់ទងទៅនឹងការទទួលរង ទុក្ខវេទនា ដែលលោកឃើញនៅជុំវិញខ្លួនរបស់លោក។ ចាកចេញពីកន្លែងដ៏ប្រណិតរបស់ឪពុកលោក បោះបង់ចោល លោកកីយ ហើយទៅ រស់នៅក្នុងភាពក្រីក្រ។ ស្វែងរកការបំភ្លឺ លោកបានរកឃើញអ្វីដែលលោកបានហៅថា "ផ្លូវនៃការ រំដោះ។" បាន ប្រកាសដើម្បីទៅកាន់ទៅកាន់និព្វានជាកន្លែងនៃការមិនដឹងមិនឮនិងការខ្វល់ខ្វាយ ឈឺចាប់ ឬការ ពិតខាងក្រៅ។ បានក្លាយ ជាគ្រូសំរាប់សហគមន៍ព្រះសង្ឃ។

**កុងហ្វាជារះ** កើតនៅក្នុងឆ្នាំ 551 ម.គ. តាំងពីពេលនៅក្មេង។ មានវិជ្ជាជីវះជាគ្រូដំបូង នៅប្រទេសចិន។ ជាអ្នកគិតគូរខាងសង្គម និងខាងសីលធម៌ធំជាងគេបំផុតសំរាប់ប្រទេសចិន។ បាននិយាយបន្តិចបន្តួច អំពីរូបកាយខាងវិញ្ញាណ និងអំណាចដ៏ទេវភាព។ ជឿថាស្ថានសួគ៌ បានប្រគល់លោកជាមួយនឹងបេសកកម្មពិសិដ្ឋ ជាជើងឯកនៃអំពើល្អនិងការពិត។

**មហាមេតះ** កើតនៅ 570 គ.ស. នៅក្នុងប្រទេសមីកា។ តាំងពីពេលនៅក្មេង។ រស់នៅ ក្នុងជីវិតជាអ្នកក្រ។ បានកើនកិត្តិស័ព្ទ ក្នុងនាមជាអ្នកគួរឱ្យទុកចិត្តនៃអ្នកសន្តិភាព។ រៀបការនៅអាយុប្រហែលជា 25 ឆ្នាំ។ នៅក្នុងឆ្នាំ 610 បានអធិស្ឋានហើយតាំង សមាធិនៅលើភ្នំ ហ្សេរេ។ បាននិយាយថា ទេវតាកាព្រីយ៉ែលបានយាងមកជួបលោក និងប្រាប់នូវ សារដំណឹងមកពី អាឡ្លា (ព្រះ)។ បានប្រកាសដើម្បីទទួលការទំនាក់ទំនងពីព្រះតាមរយៈទេវតាកាព្រីយ៉ែលចាប់ពី ឆ្នាំ 620 ទៅ ឆ្នាំ 632។ ការទំនាក់ទំនងនេះ ដែលលោកបាននិទានទៅកាន់សិស្ស របស់លោក ក្រោយមកបានសរសេរនៅក្នុងព្រះគម្ពីរគូរ៉ាន ជាសៀវភៅដ៏ពិសិដ្ឋរបស់អ៊ីស្លាម។

កំណត់ចំណាំ

# ផែនការនៃសេចក្ដីសង្គ្រោះ



## គោលបំណងរបស់អ្នក

នៅពេលដែលអ្នកបង្រៀន ចូររៀបចំសាសនាគន់ការីរបស់អ្នក ឱ្យមានទូវភាពសក្ដិសមសំរាប់ពិធីពុណ្យជ្រមុជទឹក ដែលបាន បង្រៀនទៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា 20៖37 នៅក្នុង សំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក។ នេះគឺជាការសំរេច បានដ៏ប្រសើរបំផុត ដោយការអញ្ជើញសាសនាគន់ការីរបស់អ្នក ឱ្យធ្វើនិងរក្សាការតាំងចិត្ត ដែលសរសេរដូចខាង ក្រោម។

### សំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក

- តើអ្នកជឿថា ព្រះគឺជាព្រះវរបិតាដ៏អស់កល្បរបស់យើង ដែរឬទេ?
- តើអ្នកជឿថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រារបស់ព្រះ ជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះ នៃពិភពលោក ដែរឬទេ?
- តើអ្នកស្ម័គ្រចិត្តដើម្បីរក្សាថ្ងៃសីលឱ្យបរិសុទ្ធ ដោយបូករួមទាំងការទទួលពិធីប្រសិទ្ធពរនំប៉័ងនិងទឹករៀងរាល់ សប្ដាហ៍ និងផ្ដល់ការបំរើដល់សមាជិក ដែរឬទេ?

### ការតាំងចិត្ត

- តើអ្នកព្រមអធិស្ឋានដើម្បីដឹងថា អ្វីដែលយើងបង្រៀនគឺពិត ដែរឬទេ?
- តើអ្នកព្រមប្រែចិត្តពីអំពើបាប ដែរឬទេ?
- តើអ្នកព្រមទៅព្រះវិហារជាមួយយើង នៅថ្ងៃអាទិត្យនេះ ដែរឬទេ?
- តើអ្នកព្រមធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ និងទទួលបុណ្យជ្រមុជទឹកទៅតាម (កាលបរិច្ឆេទ) ដែរឬទេ?
- តើយើងអាចណាត់ជួប សំរាប់ពេលក្រោយបានទេ?
- បទបញ្ញត្តិចេញពីមេរៀនទី 4 ដែលអ្នកជ្រើសរើសដើម្បីបញ្ចូល។

## ជួយដល់អ្នកដទៃរៀនអំពីព្រះយេស៊ូវគ្រីស្ទ

អ្នកផ្សព្វផ្សាយសាសនា គឺថ្លែងអំពីព្រះយេស៊ូវគ្រីស្ទ និងអញ្ជើញមនុស្សទាំងអស់ឱ្យមករកទ្រង់ ដើម្បីពួកគេអាចត្រូវបាន សង្គ្រោះ។ ការផ្ដល់នូវការណែនាំយ៉ាងជាក់លាក់អំពីព្រះអង្គសង្គ្រោះ គឺសំខាន់ចំពោះអ្នកទាំងឡាយណាដែល ដឹងបន្តិចបន្តួច ឬមិនដឹងសោះអំពីទ្រង់។ ព្រះគម្ពីរមរមនៈ សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ គឺរៀបចំឡើងដើម្បីជួយ មនុស្សទាំងអស់ដឹងថា "ព្រះយេស៊ូវគ្រីស្ទ...ទ្រង់បានសម្ដែងឱ្យឃើញព្រះអង្គទ្រង់ដល់គ្រប់សាសន៍" (ទំព័រចំណងជើងនៃ ព្រះគម្ពីរមរមន)។ វិធីមួយ ដ៏មាន ប្រសិទ្ធិភាពក្នុងចំណោមវិធីជាច្រើន ដើម្បីបង្រៀននិងថ្លែងអំពីព្រះអង្គសង្គ្រោះ គឺការអានជាមួយគ្នាចេញពីព្រះគម្ពីរ មរមន។ សារលិខិតមកពីព្រះគម្ពីរបមាណីយបទគម្ពីរ អាចជាជំនួយដ៏ប្រសើរ។

ពិចារណានូវឃោបល់សុំខាងក្រោម។ កិច្ចការនេះអាចធ្វើបានជា ផ្នែកនៅក្នុងមេរៀននេះ ឬមេរៀនផ្សេងទៀត ឬមេរៀន នៅក្នុង មេរៀននេះផ្ទាល់។ នៅពេលដែលមានប្រយោជន៍ សូមអានឡើងវិញពីសកម្មភាពនេះឱ្យបានច្រើនដង ពីមុន និងបន្ទាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។

កំណត់ចំណាំ

| | |
|---|---|
| ទំព័រចំណងជើង និងបុព្វកថា | ធ្វើឱ្យគោលបំណងនៃព្រះគម្ពីរកាន់តែច្បាស់។ |
| នីហ្វៃទី 1 10–11 | លីហៃ និងនីហ្វៃថ្លែងអំពីព្រះអង្គសង្គ្រោះ |
| នីហ្វៃទី 1 19 | នីហ្វៃរ៉ាយរាប់ពីការព្យាករណ៍ នៃការបំរើ និងដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ។ |
| នីហ្វៃទី 2 2 | លីហៃថ្លែងពីព្រះអង្គសង្គ្រោះ ជាព្រះប្រោសលោះ។ |
| នីហ្វៃទី 2 9 | យ៉ាកុបថ្លែងអំពីដង្វាយធួន។ |
| នីហ្វៃទី 2 31–33 | នីហ្វៃបង្រៀនពីគោលលទ្ធិរបស់ព្រះគ្រីស្ទ។ |
| អេណុស | អេណុសទទួលបទពិសោធន៍អំណាចនៃដង្វាយធួន។ |
| ម៉ូសាយ 2–5 | ស្តេចបេនយ៉ាមីនបង្រៀនអំពីព្រះគ្រីស្ទ។ |
| ម៉ូសាយ 12–16 | អ័ប៊ីណាដៃប្រគល់ជីវិតរបស់លោក ក្នុងការថ្លែងអំពីព្រះយេស៊ូវគ្រីស្ទ។ |
| អាលម៉ា 5 7 | អាលម៉ាថ្លែងអំពីព្រះអង្គសង្គ្រោះ។ |
| អាលម៉ា 17–22 | សាសន៍លេមិនទទួលសក្ខីភាពនៃព្រះយេស៊ូវគ្រីស្ទ។ |
| អាលម៉ា 34 | អាមូលេកថ្លែងពីដង្វាយធួន។ |
| អាលម៉ា 36 | អាលម៉ាទទួលបទពិសោធន៍អំណាចនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ។ |
| អាលម៉ា 40–42 | អាលម៉ាថ្លែងពីការរស់ឡើងវិញ និងដង្វាយធួន។ |
| ហេលេមិន 5 | នីហ្វៃនិងលីហៃគឺជាឧបករណ៍នៅក្នុងព្រះហស្តរបស់ព្រះ ដើម្បីធ្វើជាសាក្សីពីព្រះអង្គសង្គ្រោះ។ |
| នីហ្វៃទី 3 9–10 | ព្រះអង្គសង្គ្រោះអញ្ជើញមនុស្សឱ្យមករកទ្រង់។ |
| នីហ្វៃទី 3 11–18 | ព្រះអង្គសង្គ្រោះបង្រៀនសាសន៍នីហ្វៃ ពីព្រះវរបិតា និងពីគោលលទ្ធិរបស់ទ្រង់។ |
| នីហ្វៃទី 3 27 | ព្រះអង្គសង្គ្រោះបង្រៀនដំណឹងល្អរបស់ទ្រង់។ |
| អេធើរ 3 | បងប្រុសយ៉ារេឌឃើញព្រះអង្គសង្គ្រោះ។ |
| អេធើរ 12 | អេធើរនិងម៉ូរ៉ូណៃថ្លែងពីព្រះអង្គសង្គ្រោះ និងអំណាចនៃដង្វាយធួនរបស់ទ្រង់។ |
| ម៉ូរ៉ូណៃ 7–8 | មរមនបង្រៀនពីសេចក្តីស្រលាញ់ដ៏បរិសុទ្ធរបស់ព្រះគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់។ |
| ម៉ូរ៉ូណៃ 10 | ម៉ូរ៉ូណៃអញ្ជើញមនុស្សទាំងអស់ឱ្យមករកព្រះគ្រីស្ទ ហើយបានល្អឥតខ្ចោះនៅក្នុងទ្រង់។ |
| "ព្រះគ្រីស្ទដ៏មានព្រះជន្មរស់" | ព្យាការី និងសាវកថ្លែងពីព្រះអង្គសង្គ្រោះ។ |

## ជីវិតមុនផែនដី៖ គោលបំណងនិងផែនការរបស់ព្រះសំរាប់យើង

មានមនុស្សជាច្រើនឆ្ងល់ថា "តើយើងមកពីណា? ហេតុអ្វីពួកយើងនៅទីនេះ? តើយើងទៅកន្លែងណា?" ផែនការនៃសេចក្តីសង្គ្រោះផ្តល់ឱ្យយើងនូវចំលើយ ចំពោះសំនួរទាំងនេះ។

ព្រះគឺជាព្រះវរបិតារបស់យើង ខាងវិញ្ញាណ។ យើងពិតជាកូនចៅរបស់ទ្រង់ ហើយទ្រង់ស្រលាញ់យើង។ យើងបានរស់នៅ ជាកូនវិញ្ញាណ របស់ព្រះវរបិតារបស់យើងនៅក្នុងស្ថានសួគ៌ ពីមុនយើងកើតលើផែនដីនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏យើងមិនដូចព្រះវរបិតារបស់យើង ហើយក៏មិនអាចក្លាយដូចជាទ្រង់ ហើយរីករាយជាមួយពរជ័យ ដែលទ្រង់រីករាយ ជាមួយនឹងបទពិសោធន៍នៃការរស់នៅ ជាមតភាពនៃរូបកាយដែរ។

គោលបំណងទាំងមូលរបស់ព្រះ—កិច្ចការនិងសេរីល្អរបស់ទ្រង់—គឺអាចធ្វើឱ្យយើងម្នាក់ៗ រីករាយជាមួយនឹងពរជ័យ ទាំងអស់របស់ទ្រង់។ ទ្រង់បានផ្តល់ឱ្យផែនការដ៏ល្អឥតខ្ចោះ ដើម្បីសំរេចបានគោលបំណងរបស់ទ្រង់។ យើងយល់ ហើយបានទទួលយក ផែនការនេះមុនយើងមកផែនដីនេះ។ នៅក្នុងព្រះគម្ពីរ ផែនការរបស់ព្រះគឺត្រូវ បានហៅថា ផែនការនៃការប្រោសប្រណី ផែនការនៃសុភមង្គល ផែនការនៃសេចក្តីប្រោសលោះ និង ផែនការនៃសេចក្តីសង្គ្រោះ។

ព្រះយេស៊ូវគ្រីស្ទគឺជា ចំណុចកណ្តាលនៃផែនការរបស់ព្រះ។ តាមរយៈដង្វាយធួន ព្រះយេស៊ូវគ្រីស្ទបានបំពេញ ផែនការរបស់ ទ្រង់ ហើយឱ្យផែនការនេះអាចកើតមានចំពោះយើងម្នាក់ៗ ដើម្បីទទួលបានជីវិតអមតៈ និងជីវិតអស់កល្បជានិច្ច។ អារក្សសាតាំង គឺជាសត្រូវចំពោះផែនការរបស់ព្រះ។

កំណត់ចំណាំ

សេរីភាព ឬសមត្ថភាពដើម្បីជ្រើសរើស គឺជាអំណោយដ៏ធំបំផុតមួយរបស់ព្រះ ចំពោះកូនចៅរបស់ទ្រង់។ ការរីកចំរើន ដ៏អស់កល្បជានិច្ចរបស់យើងគឺអាស្រ័យទៅលើ របៀបដែលយើងប្រើអំណាចនេះ។ យើងត្រូវតែជ្រើសរើស ដើម្បីធ្វើតាមព្រះយេស៊ូវគ្រីស្ទ បើមិនដូច្នោះទេ គឺយើងធ្វើតាមសាតាំង។

យើងត្រូវបានបំបែកចេញពីព្រះខាងផ្នែកសាច់ឈាម អំឡុងពេលជីវិតនៅលើផែនដីនេះ តែទ្រង់ចង់ឱ្យកូនគ្រប់ពួករបស់ទ្រង់ស្វែងរកសេចក្ដីសុខសាន្ត និងសេចក្ដីរីករាយដ៏ពេញលេញ នៅក្នុងវត្តមានរបស់ទ្រង់ បន្ទាប់ពីជីវិតនេះ។ ទ្រង់ចង់ឱ្យយើងប្រែក្លាយដូចជាទ្រង់ហើយ។

### ការសិក្សាព្រះគម្ពីរ

**កូនចៅរបស់ព្រះ**

| | |
|---|---|
| គ និង ស 93៖29 | ហេព្រើរ 12៖9 |
| កិច្ចការពួកសាវក 17៖29 | |

**គោលបំណងរបស់ព្រះ**

| | |
|---|---|
| ម៉ូសេ 1៖39 | យ៉ូហាន 17៖3 |

**ជីវិតមុនឆាកជីវិតនេះ**

| | | |
|---|---|---|
| គ និង ស 138៖53–56 | អ័ប្រាហាំ 3៖22–26 | Guide to the Scriptures, "Premortal Life" |
| ម៉ូសេ 3៖5 | យេរេមា 1៖5 | |

## ការបង្កបង្កើត

នៅក្រោមការដឹកនាំរបស់ព្រះវរបិតា ព្រះយេស៊ូវគ្រីស្ទ បានបង្កើតផែនដី ជាកន្លែងសំរាប់យើងរស់នៅ និងកើនបទពិសោធន៍។ ដើម្បីរីកចំរើន ហើយប្រែក្លាយដូចជាព្រះ យើងម្នាក់ៗត្រូវតែទទួលរូបកាយ ហើយទទួលការសាកល្បង នៅអំឡុង ពេលនៃសេចក្ដីសាកល្បង នៅលើផែនដី។ នៅពេលយើងនៅលើផែនដី យើងនៅក្រៅវត្តមានខាងសាច់ឈាមរបស់ព្រះ។ យើងមិនចងចាំជីវិតមុនឆាកជីវិតនេះរបស់យើងទេ។ យើងត្រូវតែដើរតាមសេចក្ដីជំនឿ ជាជាងដើរតាមអ្វីដែលមើលឃើញ។

### ការសិក្សាព្រះគម្ពីរ

| | | |
|---|---|---|
| នីហ្វៃទី 1 17៖36 | ម៉ូសេ 2៖1 | JST យ៉ូហាន 1៖1–3 |
| អាលម៉ា 30៖40 | ម៉ូសេ 6៖63 | កូរិនថូសទី 2 5៖6–7 |
| គ និង ស 88៖41–47 | អ័ប្រាហាំ 3៖24–25 | |

## សេរីភាព និងការធ្លាក់របស់អ័ដាម និងអេវ៉ា

អ័ដាមនិងអេវ៉ា គឺជាកូនចៅដំបូងរបស់ព្រះ ដើម្បីមកផែនដី។ ព្រះបានបង្កើតអ័ដាម និងអេវ៉ា ហើយបានទុកពួកគេនៅ ក្នុងសួនច្បារអេដែន។ អ័ដាមនិងអេវ៉ា ត្រូវបានបង្កើតតាមរូបភាពនៃព្រះ ដែលមានរូបកាយជាសាច់និងឆ្អឹង។ នៅពេលដែលអ័ដាម នៅក្នុងសួនច្បារ ពួកគេនៅជាមួយវត្តមានរបស់ព្រះ ហើយអាចរស់នៅជារៀងរហូត។ ពួកគេរស់ នៅដោយពុំដឹងខុសត្រូវ ហើយព្រះ ប្រទានឱ្យរាល់សេចក្ដីត្រូវការរបស់គេ។

នៅក្នុងសួនច្បារអេដែន ព្រះឱ្យសេរីភាពដល់អ័ដាមនិងអេវ៉ា។ ទ្រង់បានបញ្ជា ពួកគេមិនឱ្យបរិភោគផ្លែឈើហាមឃាត់ ឬផ្លែឈើនៃការដឹងល្អនិងអាក្រក់។ ការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិនេះមានន័យថា ពួកគេរស់នៅ ក្នុងសួនច្បារតែពួកគេ មិនអាចរីកចំរើនដោយការទទួលបទពិសោធន៍ផ្ទុយគ្នាក្នុងជីវិតរមែងស្លាប់ទេ។ ពួកគេមិនអាចស្គាល់ ភាពរីករាយ ព្រោះពួកគេមិនអាច មានបទពិសោធន៍នៃការសោកសៅនិងការឈឺចាប់។

អារក្សបានល្បួងអ័ដាម និងអេវ៉ាឱ្យបរិភោគផ្លែឈើហាមឃាត់ ហើយពួកគេក៏ជ្រើសរើសបរិភោគ ផ្លែឈើនោះ។ ការល្បួងនេះគឺជាផ្នែកមួយនៃផែនការរបស់ព្រះ។ ព្រោះមកពីការជ្រើសរើសនេះ ពួកគេត្រូវបានបណ្ដេញចេញ ពីសួនច្បារ ហើយក៏ចេញក្រៅពីវត្តមានខាងសាច់ឈាមរបស់ព្រះ។ ព្រឹត្តិការណ៍នេះហៅថា ការធ្លាក់។ ការបំបែកចេញ ពីវត្តមានរបស់ព្រះ គឺជាការស្លាប់ខាងវិញ្ញាណ។ អ័ដាមនិងអេវ៉ា បានក្លាយជាមនុស្សដែលអាចស្លាប់បាន—ការស្លាប់ខាងរូបកាយ ឬការបំបែក រូបកាយនិងវិញ្ញាណ។ ពួកគេឥឡូវ

កំណត់ចំណាំ

អាចទទួលបទពិសោធន៍ជំងឺ និងទទួលការរងទុក្ខ គ្រប់ប្រភេទទាំងអស់។ ពួកគេមានសេរីភាព មតភាព ឬសមត្ថភាពដើម្បីជ្រើសរើសរវាងល្អនិងអាក្រក់។ ការធ្លាក់នេះ ធ្វើឱ្យពួកគេអាចរៀន និងរីកចំរើន។ ការធ្លាក់នេះក៏អាចធ្វើឱ្យពួកគេជ្រើសរើសខុស ហើយមានអំពើបាបដែរ។ ជាជំនួយបន្ថែម ពួកគេអាចមានកូនចៅឥឡូវ ដើម្បីឱ្យកូនចៅផ្សេងទៀត ខាងវិញ្ញាណរបស់ព្រះ អាចមកលើផែនដីទទួលរូបកាយជាសាច់និងឈាម និងទទួលបានការសាកល្បង។ មានតែតាមរបៀប នេះតែប៉ុណ្ណោះ ដែលកូនចៅរបស់ព្រះអាចរីកចំរើន ហើយប្រែក្លាយដូចជាទ្រង់។

## ការបង្រៀនពីការធ្លាក់

នៅពេលបង្រៀនគោលលទ្ធិនេះដំបូង ចូរកុំបង្រៀនអ្វីៗទាំងអស់ ដែលអ្នកដឹងឡើយ។ ពន្យល់ដោយសាមញ្ញថា ព្រះបានជ្រើសរើសកូនពីរនាក់នៃកូនចៅរបស់ទ្រង់ អ័ដាម និងអេវ៉ា ដើម្បីធ្វើជាឪពុកម្ដាយដំបូងនៅលើផែនដី។ បន្ទាប់ពីការរំលងរបស់ពួកគេ ពួកគេធ្លាក់ក្នុងអំពើបាបនិងសេចក្តីស្លាប់។ ពឹងផ្អែកទៅតាមខ្លួនគេផ្ទាល់ ពួកគេមិនអាចត្រឡប់ទៅ រស់នៅជាមួយព្រះវរបិតាសួគ៌វិញបានទេ។ ព្រះអម្ចាស់បានមានព្រះបន្ទូលទៅកាន់អ័ដាម ហើយបង្រៀនគាត់អំពីផែនការ នៃសេចក្តីសង្គ្រោះ និងផែនការនៃការប្រោសលោះ តាមរយៈព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ។ ដោយការធ្វើតាមផែនការនេះ អ័ដាម និងគ្រួសាររបស់គាត់អាចរីកចំរើនទៅក្នុងជីវិតនេះ និងអាចត្រឡប់ទៅរស់នៅជាមួយព្រះវិញ (សូមមើល អាលម៉ា 18:36, 22:12–14)។

## ការសិក្សាព្រះគម្ពីរ

**នៅក្នុងសួនច្បារ**

| | | |
|---|---|---|
| នីហ្វៃទី 2 2 | ម៉ូសេ 3:15–17 | លោកុប្បត្តិ 1:26–31 |
| ម៉ូសេ 2:26–31 | ម៉ូសេ 5:11 | លោកុប្បត្តិ 2:15–17 |

**ការធ្លាក់**

| | | |
|---|---|---|
| នីហ្វៃទី 2 2:25 | ម៉ូសេ 4 | លោកុប្បត្តិ 3 |
| អាលម៉ា 12:22–34 | ម៉ូសេ 5:10–12 | |

## ជីវិតរបស់យើងនៅលើផែនដី

ជីវិតនៅលើផែនដី គឺជាឱកាសនិងជាពរជ័យ។ គោលបំណងរបស់យើងនៅក្នុងជីវិតនេះគឺដើម្បីរីករាយនិងរៀបចំខ្លួន ដើម្បីត្រឡប់ទៅកាន់ទីវត្តមានរបស់ព្រះ។ នៅក្នុងជីវិតរមែងស្លាប់ យើងរស់នៅក្នុងលក្ខខ័ណ្ឌដែល សេចក្តីស្លាប់ទាំងខាងរូបកាយ និងខាងវិញ្ញាណ។ ព្រះមានសិរីល្អ និងអមតៈ នៃសាច់និងឈាមយ៉ាងល្អឥតខ្ចោះ។ ដើម្បីប្រែក្លាយដូចជាព្រះ និងត្រឡប់ទៅរស់នៅទីវត្តមានរបស់ទ្រង់ យើងក៏ត្រូវតែមានរូបកាយអមតៈនៃសាច់ និងឆ្អឹងយ៉ាងល្អឥតខ្ចោះនិងអមតៈដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រោះមកពីការធ្លាក់របស់អ័ដាម និងអេវ៉ា មនុស្សគ្រប់ៗគ្នា នៅលើផែនដី មិនល្អឥតខ្ចោះ មានរូបកាយដែលអាចស្លាប់បាន ហើយនៅទីបំផុតនឹងស្លាប់។ បើមិនមានព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ សេចក្តីស្លាប់អាចបញ្ចប់សេចក្តីសង្ឃឹម សំរាប់អនាគត ដែលទៅរស់នៅជាមួយព្រះវរបិតាសួគ៌។

រួមជាមួយនឹងសេចក្តីស្លាប់ខាងរូបកាយ អំពើបាបគឺជាឧបសគ្គចំបង ដែលធ្វើឱ្យយើងមិនអាចប្រែក្លាយដូចជាព្រះវរបិតា នៅឯស្ថានសួគ៌របស់យើង ហើយត្រឡប់ទៅក្នុងទីវត្តមានរបស់ទ្រង់បាន។ នៅក្នុងលក្ខខ័ណ្ឌនៃជីវិតរមែងស្លាប់ យើងតែងតែ ធ្លាក់ក្នុងការ ល្បួង ធ្វើខុសព្រះបញ្ញត្តិរបស់ព្រះ ហើយមានបាប។ នៅអំឡុងជីវិតរបស់យើងនៅលើផែនដី យើងម្នាក់ៗមានកំហុស។ ទោះបីពេល ខ្លះអំពើបាបមិនមានផលអាក្រក់ភ្លាមៗក៏ដោយ អំពើបាបតែងតែនាំទៅរក អព្វមង្គល។ អំពើបាបធ្វើឱ្យមានអារម្មណ៍ថា មាន កំហុស និងខ្មាស់អៀន។ ព្រោះមកពីអំពើបាបរបស់យើង យើងមិនអាចត្រឡប់ទៅរស់នៅជាមួយព្រះវរបិតាសួគ៌របស់យើងបានទេ បើយើងមិន ត្រូវទទួលបានការអភ័យ ទោស និងសំអាតខ្លួនជាមុន។

នៅពេលដែលយើងនៅក្នុងជីវិតដែលរមែងស្លាប់ យើងមានបទពិសោធន៍ដែលនាំយើងទៅរកសុភមង្គល។ យើងក៏មាន បទពិសោធន៍ដែលនាំយើងទៅរកការឈឺចាប់និងការសោកសៅ អំពើបាបខ្លះកើតឡើងដោយសកម្មភាព ដែលនាំឱ្យមានបាប ដល់អ្នកដទៃ។ បទពិសោធន៍ទាំងនេះ ផ្តល់ឱ្យយើងនូវឱកាសដើម្បីរៀន និងរីកចំរើន ដើម្បីដឹងពីល្អនិង អាក្រក់ ដើម្បីធ្វើការជ្រើសរើស។ ព្រះមានឥទ្ធិពលមកលើយើងឱ្យធ្វើល្អ អារក្សល្បួងយើងឱ្យប្រព្រឹត្តអំពើបាប។ យោងទៅតាម សេចក្តីស្លាប់ខាងរូប កាយ យើងមិនអាចឈ្នះលើឥទ្ធិពលនៃអំពើបាបដោយខ្លួន យើងបានទេ។ យើងមិនអាចជួយខ្លួនឯងបាន បើគ្មានជំនួយពីដង្វាយ ធួនរបស់ព្រះយេស៊ូវគ្រីស្ទ។

### ការសិក្សាព្រះគម្ពីរ

**សេចក្ដីសាកល្បង ឬរយៈពេលនៃការសាកល្បង**

នីហ្វៃទី 2 2៖21
នីហ្វៃទី 2 9៖27
ម៉ូសាយ 3៖19
អាលម៉ា 12៖21–24
អាលម៉ា 34៖31–35
អាលម៉ា 42៖2–10
អ័ប្រាហាំ 3៖25–26

**ការជ្រើសរើស**

នីហ្វៃទី 2 2៖26–29
យ៉ូស្វេ 24៖15
*ដើម្បីគុណភាពនៃយុវជនយុវនារី*
“សេរីភាព និងការទទួលខុសត្រូវ”

**ល្អនិងអាក្រក់**

មរ៉ូណៃ 7៖12–19

**អំពើបាប**

រ៉ូម 3៖23
យ៉ូហានទី 1 1៖8–10
យ៉ូហានទី 1 3៖4

**អ្វីដែលមិនស្អាតមិនអាចទៅជាមួយព្រះបានទេ**

នីហ្វៃទី 1 10៖20–21
អាលម៉ា 41៖10–11
នីហ្វៃទី 3 27៖19
ម៉ូសេ 6៖57

## ដង្វាយធួន



ពីមុនពិភពលោកត្រូវបានរៀបចំ ព្រះវរបិតាសួគ៌របស់យើង បានជ្រើសរើសព្រះយេស៊ូវគ្រីស្ទ ដើម្បីធ្វើជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះ។ ព្រះយេស៊ូវគ្រីស្ទបានធ្វើឱ្យយើងអាចឈ្នះលើឥទ្ធិពលនៃការធ្លាក់។ ព្យាការីទាំងអស់ តាំងពីការចាប់ផ្ដើមនៃពិភពលោក បានថ្លែងពីព្រះយេស៊ូវគ្រីស្ទ ជាព្រះប្រោសលោះរបស់យើង។

យើងទាំងអស់គ្នានឹងទទួលការស្លាប់ខាងរូបកាយ តែព្រះយេស៊ូវគ្រីស្ទបានឈ្នះលើឧបសគ្គនៃសេចក្ដីស្លាប់ខាងរូបកាយសំរាប់យើង ។ នៅពេលដែលទ្រង់សុគតនៅលើឈើឆ្កាង វិញ្ញាណរបស់ទ្រង់បានបំបែកចេញពីរូបកាយរបស់ទ្រង់។ នៅថ្ងៃទីបីវិញ្ញាណ និងរូបកាយរបស់ទ្រង់បានផ្គុំឡើងវិញជាអស់កល្បជានិច្ច មិនបំបែកគ្នាម្ដងទៀតឡើយ។ ទ្រង់បានយាងទៅជួបមនុស្សជាច្រើន ដោយការបង្ហាញពួកគេថា ទ្រង់មានរូបកាយអមតៈជាសាច់និងឆ្អឹង។ ការផ្គុំឡើងវិញនៃរូបកាយនិងវិញ្ញាណគឺត្រូវបានហៅថា ការរស់ឡើង វិញ ហើយគឺជាអំណោយដែលបានសន្យាចំពោះ យើងម្នាក់ៗ។ ព្រោះមកពីការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ យើងទាំងអស់គ្នានឹងត្រូវបានរស់ឡើងវិញដែរ ដោយមិន គិតថា យើងបានធ្វើល្អឬអាក្រក់នៅក្នុងជីវិតនេះ។ យើងនឹងមានរូបកាយល្អឥតខ្ចោះ អមតៈជាសាច់និងឆ្អឹង ដែលនឹង មិនមានជំងឺ ឈឺចាប់ ឬស្លាប់។ ការរស់ឡើងវិញធ្វើឱ្យយើងអាចត្រឡប់ទៅរស់នៅ ក្នុងវត្តមានរបស់ព្រះ ដើម្បីទទួលការកាត់ក្ដី តែមិនធានាថា យើងនឹងអាចរស់នៅក្នុងវត្តមានរបស់ទ្រង់ទេ។ ដើម្បីទទួលពរជ័យនោះ យើងត្រូវតែ សំអាតពីអំពើបាប។

ព្រះបានបញ្ជូនព្រះរាជបុត្រាជាទីស្រលាញ់របស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ដើម្បីឈ្នះលើឧបសគ្គនៃអំពើបាប ដើម្បីជាជំនួយ ចំពោះការស្លាប់ខាងសាច់ឈាម។ យើងមិនទទួលខុសត្រូវចំពោះការធ្លាក់របស់អ័ដាមនិងអេវ៉ាទេ តែយើងទទួលខុស ត្រូវចំពោះអំពើបាបផ្ទាល់ខ្លួនរបស់យើង។ ព្រះមិនអាចទតមើលអំពើបាប សូម្បីតែបន្តិចបន្តួចបានឡើយ ហើយអំពើបាប បញ្ឈប់យើងចេញពីការរស់នៅក្នុងទីវត្តមានរបស់ព្រះ។ មានតែតាមរយៈព្រះគុណនិងសេចក្ដីមេត្តាករុណារបស់ព្រះអង្គ សង្គ្រោះតែប៉ុណ្ណោះ យើងអាចបានស្អាតស្អំពីអំពើបាប ដើម្បីយើងអាចរស់នៅជាមួយព្រះម្ដងទៀត។ ការណ៍ទាំងអស់ នេះអាចធ្វើទៅបានតាមរយៈ ការអនុវត្តសេចក្ដីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ការប្រែចិត្ត ការទទួលបុណ្យជ្រមុជទឹក ការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ និងការតស៊ូដល់ទីបញ្ចប់។

កំណត់ចំណាំ

កំណត់ចំណាំ

ដើម្បីបំពេញផែនការនៃសេចក្ដីសង្គ្រោះ ព្រះគ្រីស្ទ បានបង់ថ្លៃនៃអំពើបាបរបស់យើង។ ទ្រង់តែម្នាក់ឯង អាចធ្វើ កិច្ចការនេះ។ ទ្រង់បានត្រូវហៅហើយរៀបចំនៅក្នុងអតីតជាតិ។ ទ្រង់គឺជាព្រះរាជបុត្រាពិតរបស់ព្រះជាសាច់ឈាម។ ទ្រង់គ្មានអំពើបាប ហើយ គោរពប្រតិបត្តិយ៉ាងស្មោះស្ម័គ្រចំពោះព្រះវរបិតារបស់ទ្រង់។ ទោះមានការល្បួងទ្រង់មិនដែលបណ្ដោយខ្លួនឱ្យធ្លាក់ក្នុងការល្បួងឡើយ។ នៅពេលដែលព្រះវរបិតាបានសូមឱ្យព្រះបុត្រាសំណប់របស់ទ្រង់ បង់ថ្លៃនៃអំពើបាបរបស់ពិភពលោក ព្រះយេស៊ូវ ត្រូវបានរៀបចំ ហើយស្ម័គ្រចិត្ត។ ដង្វាយធួនគឺរួមទាំងការទទួលរងទុក្ខ នៅក្នុងសួនច្បារគែតសេម៉ានី និងការរងទុក្ខ និង សេចក្ដីស្លាប់ នៅលើឈើឆ្កាង ហើយវាបានបញ្ចប់ជាមួយ នឹងការរស់ឡើងវិញរបស់ទ្រង់។ ថ្វីបើទ្រង់រងទុក្ខហួសពីការយល់—យ៉ាងច្រើនបំផុត រហូតដល់ទ្រង់ចេញឈាមពីគ្រប់គល់រោម ហើយ ទ្រង់បានសួរ បើអាចធ្វើទៅបានថា បន្ទុកនេះត្រូវបានយកចេញពីទ្រង់—ទ្រង់បានទទួលយកឆន្ទៈរបស់ព្រះវរបិតា ជាការបង្ហាញសេចក្ដីស្រលាញ់ដ៏ឧត្ដុងឧត្ដម សំរាប់បិតារបស់ទ្រង់ និងសំរាប់យើង។ ចំពោះការឈ្នះរបស់ព្រះយេស៊ូវគ្រីស្ទ នៅលើសេចក្ដីស្លាប់ខាងវិញ្ញាណ ដោយការទទួលរងទុក្ខ ហើយឈ្នះលើ សេចក្ដីស្លាប់ខាងរូបកាយ ដោយការរស់ឡើងវិញរបស់ទ្រង់ គឺត្រូវបានហៅថា ដង្វាយធួន។

ព្រះគ្រីស្ទសន្យាអភ័យទោសដល់អំពើបាបរបស់យើង ក្នុងលក្ខខ័ណ្ឌដែលយើងទទួលទ្រង់ ដោយការអនុវត្តសេចក្ដីជំនឿ នៅក្នុងទ្រង់ ការប្រែចិត្ត ការទទួលពិធីជ្រមុជទឹក ដោយការពន្លិច និងការដាក់ដៃនៅលើក្បាល សំរាប់អំណោយ ទាននៃព្រះ វិញ្ញាណបរិសុទ្ធ និងការព្យាយាមដោយស្មោះស្ម័គ្រ ដើម្បីរក្សាព្រះបញ្ញត្តិរបស់ទ្រង់ រហូតដល់ទីបញ្ចប់នៃ ជីវិតរបស់យើង។ តាមរយៈការប្រែចិត្ត យើងអាចទទួលការអភ័យទោសនិងជ្រះស្អាតពីអំពើបាបរបស់យើង ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។ យើងបានធូរស្បើយពីបន្ទុក កំហុស និងភាពអាម៉ាស់របស់យើង ហើយតាមរយៈ ព្រះយេស៊ូវគ្រីស្ទ យើងអាចមានភាពសក្ដិសម ដើម្បីត្រឡប់ទៅ កាន់ទីវត្តមានរបស់ព្រះ។

នៅពេលដែលយើងពឹងលើដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ទ្រង់អាចជួយយើងស៊ូទ្រាំចំពោះ ការសាកល្បងរបស់យើង ជំងឺ និងការឈឺចាប់ ។ យើងអាចពោរពេញដោយសេចក្ដីអំណរ សន្តិភាព និងការលួងលោមចិត្ត។ អ្វីៗដែលមិនយុត្តិធម៌ អំពីជីវិត អាចធ្វើឱ្យមានភាពត្រឹមត្រូវ តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ។

ក្នុងការបង់ថ្លៃសំរាប់អំពើបាបរបស់យើង ទោះជាយ៉ាងណាក៏ដោយ ព្រះយេស៊ូវមិនបានបំបាត់ ការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់យើងដែរ។ យើងត្រូវតែបង្ហាញថា យើងទទួលស្គាល់ទ្រង់ ហើយថា យើងនឹងធ្វើតាមព្រះបញ្ញត្តិរបស់ទ្រង់។ មានតែតាមរយៈអំណោយ នៃដង្វាយធួនតែប៉ុណ្ណោះទើប យើងអាចត្រឡប់ទៅរស់នៅជាមួយព្រះវិញ។

### ការសិក្សាព្រះគម្ពីរ

**ការរស់ឡើងវិញ**

| | | |
|---|---|---|
| នីហ្វៃទី 2 9:6–7 | គ និង ស 88:27–32 | JST កូរិនថូសទី 1 15:40–42 |
| អាលម៉ា 11:42–45 | លូកា 24:1–10, 36–39 | Guide to the Scriptures “Death, Physical, “Death Spiritual” “Resurrection” |
| អាលម៉ា 40:23 | កូរិនថូសទី 1 15:20–23 | |
| ហេលេមិន 14:15–19 | | |

**ដង្វាយធួន**

| | | |
|---|---|---|
| នីហ្វៃ 2 2:6–8 | គ និង ស 19:15–19 | យ៉ូហានទី 1 1:7 |
| អាល់ម៉ា 7:11–13 | គ និង ស 45:3–5 | Guide to the Scriptures “Atone, Atonement” |
| អាល់ម៉ា 34:8–10 | យ៉ូហាន 3:16–17 | |

**ដំណឹងល្អ—ផ្លូវ**

| | | |
|---|---|---|
| នីហ្វៃទី 2 9:1–24 | អាលម៉ា 11:40 | នីហ្វៃទី 3 27 |
| នីហ្វៃទី 2 31 | នីហ្វៃទី 3 11:31–41 | មរ៉ូណៃ 7:27–28 |

## ពិភពវិញ្ញាណ

ទោះបីជាព្រះគ្រីស្ទ ឈ្នះលើសេចក្ដីស្លាប់ខាងរូបកាយ មនុស្សទាំងអស់ត្រូវស្លាប់ ព្រោះសេចក្ដីស្លាប់ជាផ្នែកមួយ នៃរបៀបដែលយើងប្រែពីមតភាពទៅជាអមតភាព។ នៅពេលស្លាប់ វិញ្ញាណរបស់យើង ទៅពិភពវិញ្ញាណ។ សេចក្ដីស្លាប់មិនផ្លាស់ប្ដូរបុគ្គលិកលក្ខណៈ ឬសេចក្ដីប៉ងប្រាថ្នារបស់យើង ចំពោះអំពើល្អ ឬអំពើអាក្រក់ទេ។ អ្នកទាំងឡាយណា ជ្រើសរើសដើម្បីគោរពប្រតិបត្តិតាមព្រះ នៅក្នុងជីវិតនេះ រស់នៅក្នុងស្ថានភាពសុភមង្គល សន្តិភាព ហើយសំរាក ពីបញ្ហានិងការខ្វល់ខ្វាយ។ អ្នកទាំងឡាយណា

កំណត់ចំណាំ

ដែលមិនគោរពប្រតិបត្តិព្រះនៅក្នុងជីវិតនេះ ហើយមិនបានប្រែចិត្ត រស់នៅក្នុងស្ថានភាពគ្មានសុភមង្គល។ នៅក្នុងពិភពវិញ្ញាណ ដំណឹងល្អ គឺប្រៀនប្រដៅចំពោះអ្នកទាំងឡាយណា ដែលមិនគោរពប្រតិបត្តិដំណឹងល្អ ឬមានឱកាសលឺដំណឹងល្អនៅក្នុងពេលដែលនៅលើផែនដី។ យើងនៅក្នុងពិភពវិញ្ញាណ រហូតដល់យើងរស់ឡើងវិញ។

**ដំណឹងល្អបង្រៀនដល់មនុស្សដែលស្លាប់**

| | | |
|---|---|---|
| គ និង ស 138 | ពេត្រុសទី 1 3៖19–20 | ពេត្រុសទី 1 4៖6 |

**សេចក្ដីស្លាប់និងពិភពវិញ្ញាណ**

| | | |
|---|---|---|
| អាលម៉ា 34៖34 | អាលម៉ា 40៖11–14 | សាស្ដា 12៖7 |

## ការរស់ឡើងវិញ ការជំនុំជំរះ និងអមតភាព

នៅពេលដែលវិញ្ញាណនិងរូបកាយរបស់យើង ផ្ដុំឡើងវិញតាមរយៈការរស់ឡើងវិញ យើងនឹងនាំទៅខាងមុខវត្តមានរបស់ព្រះ ដើម្បីទទួលការជំនុំជំរះ។ យើងនឹងចងចាំបានយ៉ាងល្អឥតខ្ចោះពីអំពើសុចរិត និងកំហុសរបស់យើង។ បើយើងបានប្រែចិត្ត យើងនឹងទទួលសេចក្ដីមេត្តាករុណា។ យើងនឹងទទួលរង្វាន់យោងទៅតាម កិច្ចការ និងសេចក្ដីប៉ង ប្រាថ្នារបស់យើង។

តាមរយៈការរស់ឡើងវិញ មនុស្សទាំងអស់នឹងក្លាយជាអមតៈ—ពួកគេនឹងរស់ជារៀងរហូត។ អមតភាពគឺជា អំណោយដោយឥតគិតថ្លៃចំពោះមនុស្សទាំងអស់ ទោះជាមនុស្សសុចរិត ឬទុច្ចរិត។ ទោះបីជាយ៉ាងណាក៏ដោយ ជីវិតដ៏នៅអស់កល្បជានិច្ច មិនដូចជាអមតភាពទេ។ ជីវិតដ៏នៅអស់កល្បជានិច្ច គឺជាអំណោយរបស់ព្រះ ដែលប្រទាន ឱ្យដល់អ្នកទាំងឡាយណា ដែលគោរព ប្រតិបត្តិតាមដំណឹងល្អតែប៉ុណ្ណោះ។ ជីវិតដ៏នៅអស់កល្បជានិច្ច គឺជាកន្លែងដ៏ខ្ពស់ បំផុត ដែលយើងអាចសំរេច។ ជីវិតដ៏នៅអស់ កល្បជានិច្ច ឱ្យដល់អ្នកទាំងឡាយណាដែលរួចផុតពីអំពើបាប និងទទួលរង ទុក្ខតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ។ ជីវិតដ៏នៅអស់កល្បជានិច្ចគឺជាការលើកដំកើង មានន័យថា ការរស់នៅជាមួយព្រះ ជារៀងរហូត ជាក្រុមគ្រួសារអស់កល្បជានិច្ច។ ជីវិតដ៏នៅ អស់កល្បជានិច្ច គឺជាការស្គាល់ព្រះ និងព្រះយេស៊ូវគ្រីស្ទ និងដើម្បីទទួលបទពិសោធន៍ ជីវិតដែលពួកគេរីករាយ។

**ការរស់ឡើងវិញ និងការចាប់ជាតិ**

មានមនុស្សជាច្រើនយល់ច្រឡំពីគោលលទ្ធិនិងការរស់ឡើងវិញ ជាមួយនឹងគំនិតនៃការចាប់ជាតិ។ គំនិតនៃការចាប់ជាតិ មានទំនាក់ទំនងទៅនឹងការកើតជាថ្មីនៅក្នុងពិភពលោក ជាទំរង់ខុសគ្នា ហើយគឺជាគោលលទ្ធិក្លែងក្លាយ។ គោលលទ្ធិនៃការ រស់ឡើងវិញ មានទំនាក់ទំនងទៅនឹងការទទួលរង្វាន់អស់កល្បជានិច្ចនៃរូបកាយអមតៈ នៃសាច់និងឆ្អឹង។ នេះគឺជាគោលលទ្ធិពិត។ ត្រូវប្រាកដថា អ្នកដែលអ្នកបង្រៀនយល់យ៉ាងច្បាស់ពីគោលលទ្ធិនៃការរស់ឡើងវិញ។

## នគរនៃភាពរុងរឿង

នៅអំឡុងពេលជីវិតរមែងស្លាប់របស់យើង យើងធ្វើការជ្រើសរើសតាមការយល់ឃើញថា ល្អ និងអាក្រក់។ ព្រះឱ្យរង្វាន់ ដល់យើងយោងតាមកិច្ចការ និងបំណងប្រាថ្នារបស់យើង។ ព្រោះព្រះប្រទានរង្វាន់ឱ្យមនុស្សគ្រប់គ្នា អាស្រ័យទៅលើ អំពើដែលពួកគេបានធ្វើនៅជារូបកាយ មាននគរនៃភាពរុងរឿងខុសពគ្នា ដែលយើងអាចចាត់តាំងទៅបន្ទាប់ពីការជំនុំជំរះ។ អ្នកទាំងឡាយណាដែលបានប្រែចិត្តពីអំពើបាបរបស់ពួកគេ ហើយទទួលពិធីការនៃដំណឹងល្អ ហើយបានរក្សាសេចក្ដីសញ្ញា ដែលបានភ្ជាប់នឹងត្រូវបាន សំអាតដោយដង្វាយធួនរបស់ព្រះគ្រីស្ទ។ ពួកគេនឹងបានទទួលការលើកដំកើង នៅក្នុងនគរខ្ពស់ជាងគេបំផុត នគរនេះត្រូវបានស្គាល់ជានគរសេឡេស្ទាល។ ពួកគេនឹងរស់នៅក្នុងវត្តមានរបស់ព្រះ ក្លាយដូចជាទ្រង់ និងទទួលភាពរីករាយដ៏ពេញលេញ។ ពួកគេនឹងរស់នៅជាមួយគ្នា សំរាប់ភាពអស់កល្បជានិច្ចជាមួយនឹងអ្នកទាំងឡាយណា ដែលក្រុមគ្រួសាររបស់គេមានភាពសក្ដិសម។ នៅក្នុងព្រះគម្ពីរនគរនេះ គឺប្រៀបធៀបទៅនឹងភាពរុងរឿង ឬពន្លឺនៃព្រះអាទិត្យ។

មនុស្សដែលមិនទទួលស្គាល់ភាពពេញលេញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ តែរស់នៅដោយជីវិតសុចរិតនឹងទទួលកន្លែងនៅក្នុងនគរទេរេស្រ្ទាល។ នគរនេះប្រៀបធៀបទៅនឹងភាពរុងរឿងនៃព្រះច័ន្ទ។

មេរៀនទី 2៖
ផែនការនៃសេចក្ដីសង្គ្រោះ

កំណត់ចំណាំ

អ្នកទាំងឡាយណាដែលបន្តប្រព្រឹត្តអំពើបាប ហើយមិនប្រែចិត្តនៅក្នុងជីវិតនេះនឹងទទួលរង្វាន់របស់គេ នៅក្នុងនគរដែលទាបជាងគេបំផុត ដែលត្រូវបានហៅថា នគរទេឡេស្ទាល។ នគរនេះគឺប្រៀបធៀបទៅនឹងភាពរុងរឿងនៃផ្កាយ។

## ការសិក្សាព្រះគម្ពីរ

### ការរស់ឡើងវិញ និងការស្ដារឡើងវិញ

| | | |
|---|---|---|
| នីហ្វៃទី 2 9៖14–15 | យ៉ាកុប 6៖8–9 | អាលម៉ា 42៖13–15, 22–23 |

### ការជំនុំជំរះ

| | | |
|---|---|---|
| នីហ្វៃទី 2 28៖23 | អាលម៉ា 5៖15–21 | សូមមើល គ និង ស 132៖12, 137៖9 |
| ម៉ូសាយ 3៖23–25 | អាលម៉ា 12៖12–14 | យ៉ូហាន 5៖22 |

### នគរនៃភាពរុងរឿង

| | | |
|---|---|---|
| នីហ្វៃទី 3 28៖10 | សូមមើល គ និង ស 76 | ម៉ាថាយ 5៖48 |
| សូមមើល គ និង ស 76៖ បុព្វកថា | សូមមើល គ និង ស 137 | កូរិនថូសទី 1 15៖40–42 |

### ជីវិតដ៏នៅអស់កល្បជានិច្ច

| | | |
|---|---|---|
| នីហ្វៃទី 2 31៖17–21 | សូមមើល គ និង ស 45៖8 | យ៉ូហាន 3៖16 |
| សូមមើល គ និង ស 14៖7 | សូមមើល គ និង ស 93៖19 | យ៉ូហាន 17៖3 |
| សូមមើល គ និង ស 29៖43–44 | | |

## ផែនការនៃសេចក្ដីសង្គ្រោះ




ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ធ្វើឱ្យផែនការនៃសេចក្ដីសង្គ្រោះអាចកើតមានចំពោះយើង។

## ការអញ្ជើញដើម្បីទទួលបុណ្យជ្រមុជទឹក

ការអញ្ជើញដើម្បីទទួលបុណ្យជ្រមុជទឹក ហើយទទួលពិធីបញ្ជាក់គួរតែច្បាស់លាស់ហើយចំពោះ “ តើអ្នកព្រមធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ដោយទទួលបុណ្យជ្រមុជទឹកដោយនរណាម្នាក់ដែល កាន់សិទ្ធិអំណាចបព្វជិតភាពរបស់ព្រះ ដែរឬទេ? យើងនឹងធ្វើ ការបំពេញពិធីបុណ្យជ្រមុជទឹកនៅតាម [កាលបរិច្ឆេទ]។ តើអ្នកព្រមរៀបចំខ្លួនរបស់អ្នក ដើម្បីទទួល បុណ្យជ្រមុជទឹកនៅ កាលបរិច្ឆេទនោះទេ?”

# គំនិតសំរាប់ការបង្រៀន

នៅជំពូកនេះមានគំនិតសំរាប់អ្នកដើម្បីប្រើ ក្នុងការរៀបចំ និងការបង្រៀនមេរៀននេះ។ ដោយមានការអធិស្ឋានចូរធ្វើតាម ព្រះវិញ្ញាណ នៅពេលដែលអ្នកសំរេចចិត្តប្រើគំនិតទាំងនេះ។ បន្ថែមគំនិតដែលអ្នក ជ្រើសរើសជាមួយនឹងផែនការមេរៀន របស់អ្នក។ ចូរចងចាំថា គំនិតនេះគឺគ្រាន់តែជាយោបល់—មិនមែនជាអ្វីដែលតំរូវឱ្យមាន—ដើម្បីជួយអ្នកឱ្យបំពេញ សេចក្ដីត្រូវការនៃអ្នកដែលអ្នកបង្រៀន។

## ផែនការមេរៀនខ្លីៗ (3–5 នាទី)

ផែនការនៃសេចក្ដីសង្គ្រោះ បង្រៀនយើងថា យើងមកពីណា ហេតុអ្វីយើងនៅលើផែនដី ហើយតើកន្លែង ណាដែលយើងនឹងទៅ បន្ទាប់ពីជីវិតនេះ។ វាបង្ហាញផែនទីអំពី ការធ្វើដំណើរដ៏អស់កល្បរបស់យើង ជីវិតរមែងស្លាប់ សេចក្ដីស្លាប់ ការរស់ឡើងវិញ និងចំពោះជីវិត របស់យើងនៅក្នុងភាពអស់កល្បជានិច្ច។ ផែនការក៏បានពន្យល់ផង ដែរពីអ្វីដែលព្រះវរបិតាជាទីស្រលាញ់ របស់យើងនៅស្ថានសួគ៌ធ្វើ ដើម្បីជួយយើង ទទួលបានជ័យជំនះលើការធ្វើដំណើរនេះ ដើម្បីឱ្យយើងអាចត្រឡប់ទៅ កាន់វត្តមានរបស់ទ្រង់ ហើយប្រែក្លាយដូចជាទ្រង់។ ផែនការយកចិត្តទុកដាក់ទៅលើបេសកកម្ម និងដង្វាយធួនរបស់ព្រះ យេស៊ូវគ្រីស្ទ ក្នុងការឈ្នះទៅលើឥទ្ធិពលពីការធ្លាក់ និងធ្វើឱ្យជីវិតអស់កល្បជានិច្ចអាចកើតមាន ចំពោះយើង។ យើងអញ្ជើញ អ្នកឱ្យពិចារណា និងអធិស្ឋានអំពីសារដំណឹងនេះ។

- ជីវិតមុនឆាកជីវិតនេះ៖ គោលបំណងនិងផែនការរបស់ព្រះសំរាប់យើង
- ការបង្កបង្កើត
- សេរីភាព និងការធ្លាក់របស់អ័ដាមនិងអេវ៉ា
- ជីវិតរបស់យើងនៅលើផែនដី
- ដង្វាយធួន
- ពិភពវិញ្ញាណ
- ការរស់ឡើងវិញ ការជំនុំជំរះ និងអមតភាព
- នគរនៃភាពរុងរឿង

### ការតាំងចិត្ត

- តើអ្នកព្រមអធិស្ឋានដើម្បីដឹងថា អ្វីដែលយើងបានបង្រៀន គឺជាពិតដែរឬទេ?
- តើអ្នកព្រមប្រែចិត្តពីអំពើបាបរបស់អ្នកដែរឬទេ?
- តើអ្នកព្រមទៅព្រះវិហារជាមួយយើង នៅថ្ងៃអាទិត្យនេះ ដែរឬទេ?
- តើអ្នកព្រមធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ និងទទួលបុណ្យជ្រមុជទឹកនៅ (កាលបរិច្ឆេទ) ដែរឬទេ?
- តើយើងអាចណាត់ជួបសំរាប់ពេលក្រោយបានទេ?
- បទបញ្ញត្តិចេញពីមេរៀនទី 4 ដែលអ្នកជ្រើសរើសដើម្បីបញ្ចូល

## ផែនការមេរៀនជាមធ្យម (10–15 នាទី)

សារដំណឹងរបស់យើងជួយយើងយល់ពីគោលបំណងនៃជីវិត ហើយដឹងថាយើងជានរណា។ វាផ្ដល់ឱ្យ យើងនូវក្ដីសង្ឃឹម ហើយជួយយើងស្វែងរកសន្តិភាព សេចក្ដីអំណរ និងសុភមង្គល។ វាប្រាប់យើងថា យើងមកពីណា ហេតុអ្វីយើងនៅលើផែនដី ហើយតើយើងនឹងទៅទីណាបន្ទាប់ពីជីវិតនេះ។ ព្រះ គឺជាព្រះវរបិតារបស់យើង ហើយទ្រង់ស្រលាញ់យើង។ យើងជាកូនចៅ របស់ទ្រង់។ យើងគឺជាផ្នែកនៃគ្រួសាររបស់ទ្រង់ ហើយយើងរស់នៅជាមួយទ្រង់ពីមុន យើងចាប់កំណើតនៅលើផែនដីនេះ។ ទ្រង់មានផែនការនៃសុភមង្គល ដែលធ្វើឱ្យយើងអាចត្រឡប់ទៅរស់នៅ

កំណត់ចំណាំ

## មេរៀនទី 2៖ ផែនការនៃសេចក្ដីសង្គ្រោះ

កំណត់ចំណាំ

ក្នុងទីវត្តមានរបស់ទ្រង់បន្ទាប់ពីជីវិតនេះ។ ការរីក ចំរើនរបស់យើងអាស្រ័យ ទៅលើរបៀបដែលយើងប្រើសេរីភាព ដែលព្រះផ្ដល់ឱ្យយើង ឬសមត្ថភាពដើម្បីជ្រើសរើស។ ដោយជា ផ្នែកនៃផែនការ ការធ្លាក់ របស់អ័ដាមបានធ្វើឱ្យផែនការនេះអាចធ្វើទៅបាន សំរាប់យើងមកលើផែនដី មានរូបកាយ មាន បទពិសោធន៍ ហើយមានក្រុមគ្រួសាររបស់យើងផ្ទាល់។ តែការធ្លាក់ ក៏នាំមកនូវការស្លាប់ខាងវិញ្ញាណផងដែរ ដែលបំបែកវិញ្ញាណ ចេញពីរូបកាយ និងសេចក្ដីស្លាប់ខាងវិញ្ញាណ ដែលបំបែកយើងចេញពីព្រះ។

ព្រះយេស៊ូវគ្រីស្ទ គឺជាចំណុចកណ្ដាលនៃផែនការព្រះ។ ការបូជាដ៏ធួនរបស់ព្រះគ្រីស្ទ ឈ្នះលើអនុភាពនៃការស្លាប់ខាងរូបកាយ និងខាងវិញ្ញាណ។ យើងទាំងអស់គ្នានឹងរស់ឡើងវិញ ហើយនឹងរស់នៅជារៀងរហូតជាមួយនឹងរូបកាយ ដែលជៀសផុតពីការ ឈឺចាប់ និងជំងឺ។ ព្រះគ្រីស្ទអាចធ្វើឱ្យយើងឈ្នះលើការស្លាប់ខាងវិញ្ញាណ។ នៅពេលដែលយើង រស់នៅតាមដំណឹងល្អរបស់ទ្រង់ យើងនឹងត្រូវបានអភ័យទោសចំពោះ អំពើបាបរបស់យើងដោយមេត្តាករុណា។ ទ្រង់នឹងព្យាបាលយើង ហើយជំនួសនូវកំហុស និងភាពអាម៉ាស់ ជាមួយនឹងសន្តិភាព ហើយសុភមង្គលនៅក្នុងជីវិតនេះ។

ដោយជាផ្នែកមួយនៃផែនការដ៏មេត្តាករុណារបស់ព្រះ យើងទាំងអស់គ្នានឹងទទួលការស្លាប់ខាងរូបកាយ។ វិញ្ញាណរបស់យើង នឹងបំបែកចេញពីរូបកាយរបស់យើង ហើយនឹងរស់នៅមួយរយៈនៅក្នុងពិភពវិញ្ញាណ។ បន្ទាប់មកយើងនឹងត្រូវបានរស់ឡើងវិញ ជាមួយនឹងរូបកាយអតមះ ហើយនឹងការផ្គុំចូលគ្នាអស់កល្បជានិច្ចរវាងរូបកាយ និងវិញ្ញាណរបស់យើង។ យើងនឹងទទួលការ ជំនុំជំរះយោងទៅតាមកិច្ចការ និងបំណងប្រាថ្នារបស់យើង។ អ្នកទាំងឡាយណាដែលរស់នៅតាមដំណឹងល្អ នឹងទទួលអំណោយដ៏ធំ ជាងគេរបស់ព្រះវរបិតាយើង អំណោយនៃជីវិតអស់កល្បជានិច្ចនៅក្នុងទីវត្តមានរបស់ព្រះ។

ព្រះវរបិតាសួគ៌របស់យើង បានងាកមករកកូនចៅរបស់ទ្រង់ក្នុងក្ដីស្រលាញ់ ដើម្បីបើកសម្ដែងផែនការនៃសុភមង្គលរបស់ទ្រង់។ យើងរៀនអំពីផែនការដ៏អស្ចារ្យនេះ នៅក្នុងព្រះគម្ពីរមរមន ដែលអ្នកអាចអាន ពិចារណា និងអធិស្ឋាន។ យើងសូមអញ្ជើញអ្នក ចូលរួមជាមួយយើងនៅសាសនាចក្រ ហើយថ្វាយបង្គំជាមួយយើង។

### ការតាំងចិត្ត៖

- តើអ្នកព្រមអធិស្ឋានដើម្បីដឹងថា អ្វីដែលយើងបានបង្រៀន គឺជាការពិតដែរឬទេ?
- តើអ្នកព្រមប្រែចិត្តពីអំពើបាបរបស់អ្នកដែរឬទេ?
- តើអ្នកព្រមទៅព្រះវិហារជាមួយយើង នៅថ្ងៃអាទិត្យនេះ ដែរឬទេ?
- តើអ្នកព្រមធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ និងទទួលបុណ្យជ្រមុជទឹកនៅ (កាលបរិច្ឆេទ) ដែរឬទេ?
- តើយើងអាចណាត់ជួបសំរាប់ពេលក្រោយបានទេ?
- បទបញ្ញត្តិចេញពីមេរៀនទី 4 ដែលអ្នកជ្រើសរើសដើម្បីបញ្ចូល

### ផែនការមេរៀនទាំងមូល (30–45 នាទី)

- ជីវិតមុនផែនដី៖ គោលបំណងនិងផែនការរបស់ព្រះសំរាប់យើង
  - ព្រះគឺជាព្រះវរបិតាសួគ៌របស់យើង ហើយយើងជាកូនចៅរបស់ទ្រង់ (សូមមើល កិច្ចការពួកសាវក 17៖16–34 ហេព្រើរ 12៖9)។
  - ព្រះមានផែនការសំរាប់សុភមង្គលរបស់យើង។ ព្រះយេស៊ូវគ្រីស្ទគឺជាចំណុចកណ្ដាលនៃផែនការនេះ។
  - ផែនការនៃសុភមង្គលរបស់ព្រះធ្វើឱ្យយើងអាចត្រឡប់ទៅរស់នៅក្នុងទីវត្តមានរបស់ទ្រង់ (សូមមើល ម៉ូសេ 1៖39)។

កំណត់ចំណាំ

- ការរីកចំរើនដ៏អស់កល្បរបស់យើង អាស្រ័យទៅលើការប្រើសេរីភាពរបស់យើង (សូមមើល នីហ្វៃទី 2 2៖27–29)។

• ការបង្កបង្កើត

- ក្រោមការដឹកនាំរបស់ព្រះវរបិតា ព្រះយេស៊ូវគ្រីស្ទ បានបង្កើតផែនដី (សូមមើល ហេព្រើរ 1៖1–3)។

• សេរីភាព និងការធ្លាក់របស់អ័ដាម និងអេវ៉ា

- អ័ដាមនិងអេវ៉ាត្រូវបានបង្កើតទៅតាមរូបភាពរបស់ព្រះ (សូមមើល លោកុប្បត្តិ 1៖26–27)។
- នៅក្នុងសួនច្បារអេដែន ពួកគេពុំបានដឹងខុសត្រូវ និងរស់នៅក្នុងវត្តមានរបស់ព្រះ។
- ព្រោះពួកគេទទួលទានផ្លែឈើហាមឃាត់ ពួកគេត្រូវបានបណ្ដេញចេញពីសួនច្បារ (សូមមើល ម៉ូសេ 4៖19–31)។ ហេតុការណ៍នេះត្រូវបានហៅថា ការធ្លាក់។
- អ័ដាមនិងអេវ៉ាក្លាយជាមតៈ អាចមានកូនចៅ ហើយរងអំពើបាប និងស្លាប់ (សូមមើល នីហ្វៃទី 2 2៖22–25, ម៉ូសេ 5៖11)។

• ជីវិតរបស់យើងនៅលើផែនដី

- គោលបំណងរបស់យើងនៅក្នុងជីវិតនេះ គឺដើម្បីស្វែងរកសន្តិភាព សេចក្ដីអំណរ និងសុភមង្គលជា ក្រុមគ្រួសារ ដ៏យូរអង្វែង និងរៀបចំខ្លួនដើម្បីត្រឡប់ទៅរស់នៅជាមួយព្រះ។
- យើងបានមកផែនដី ដើម្បីទទួលការសាកល្បង (សូមមើល អ័ប្រាហាំ 3៖24–25)។
- យើងមានរូបកាយនៃសាច់និងឆ្អឹង តែយើងទទួលការស្លាប់ខាងរូបកាយ។
- ព្រះផ្ដល់ឱ្យព្រះបញ្ញត្តិ។ បើយើងគោរពប្រតិបត្តិ យើងនឹងទទួលពរជ័យ។ បើយើងមិនគោរពប្រតិបត្តិយើងមានបាប ហើយទទួលផលនៃបាបកម្ម។
- អំពើបាបទាំងអស់ត្រូវតែបង់ថ្លៃ ដោយខ្លួនរបស់យើងផ្ទាល់ ឬដោយព្រះយេស៊ូវគ្រីស្ទ (សូមមើល គ និង ស 19៖15–20)។
- យើងធ្វើការជ្រើសរើស ហើយយើងទាំងអស់គ្នាប្រព្រឹត្តអំពើបាប (សូមមើល រ៉ូម 3៖23)។
- យើងមានបទពិសោធន៍ដែលនាំមកនូវ សុភមង្គល និងទុក្ខព្រួយផងដែរ។
- យើងមិនអាចយកឈ្នះទាំងការស្លាប់ខាងរូបកាយ ឬការស្លាប់ខាងវិញ្ញាណ ដោយគ្មានព្រះគ្រីស្ទ។

• ដង្វាយធួន

- ព្រោះព្រះយេស៊ូវគ្រីស្ទឈ្នះលើសេចក្ដីស្លាប់ខាងរូបកាយ យើងទាំងអស់គ្នា នឹងបានរស់ឡើងវិញ (សូមមើល អាលម៉ា 11៖41–43)។
- តាមរយៈដង្វាយធួនរបស់ព្រះគ្រីស្ទ យើងអាចជ្រះស្អាតពីអំពើបាប ដើម្បីយើងអាចត្រឡប់ទៅរស់នៅក្នុងវត្ត មានរបស់ព្រះ (សូមមើល នីហ្វៃទី 2 9៖8–9)។
- ព្រះគ្រីស្ទនឹងអភ័យទោសដល់យើង នៅពេលដែលយើងមានសេចក្ដីជំនឿនៅក្នុងទ្រង់ ប្រែចិត្ត ទទួលពិធីបុណ្យ ជ្រមុជទឹក និងទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ហើយតស៊ូរហូតដល់ទីបញ្ចប់។

• ពិភពវិញ្ញាណ

- មនុស្សទាំងអស់ត្រូវតែស្លាប់។
- នៅពេលស្លាប់ វិញ្ញាណរបស់យើងទៅពិភពវិញ្ញាណ។

មេរៀនទី 2៖
ផែនការនៃសេចក្ដីសង្គ្រោះ

កំណត់ចំណាំ

- បើយើងមិនរស់នៅក្នុងស្ថានភាពមហន្តរាយទេ យើងរស់នៅក្នុងស្ថានភាពសុខសាន្ត និងសំរាក គឺអាស្រ័យទៅ លើរបៀបដែលយើងរស់នៅក្នុងជីវិតនេះ។

- ការស្ដារឡើងវិញ ការជំនុំជំរះ និងអមតភាព
  - វិញ្ញាណ និងរូបកាយរបស់យើងនឹងផ្គុំចូលគ្នានៅពេលយើងរស់ឡើងវិញ (សូមមើល អាលម៉ា 11៖42–45, 40៖23)។
  - យើងនឹងត្រឡប់ទៅកាន់វត្តមានរបស់ព្រះ ដើម្បីទទួលការជំនុំជំរះ អាស្រ័យទៅនឹងកិច្ចការនិងបំណងប្រាថ្នារបស់យើង។
  - បើយើងបានប្រែចិត្ត យើងនឹងទទួលសេចក្ដីមេត្តាករុណា។
  - ជីវិតនៅអស់កល្បជានិច្ច គឺជាអំណោយមកពីព្រះ ឱ្យដល់អ្នកទាំងឡាយណាដែលគោរពប្រតិបត្តិដំណឹងល្អ របស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល គ និង ស 14៖7)។

- នគរនៃភាពរុងរឿង (សូមមើល គ និង ស 76, 137, កូរិនថូសទី 1 15៖40–42)។
  - យើងទទួលរង្វាន់អាស្រ័យទៅលើកិច្ចការ និងបំណងប្រាថ្នារបស់យើង (សូមមើល គ និង ស 137៖9)។
  - អ្នកទាំងឡាយណាដែលទទួលស្គាល់ដំណឹងល្អ ហើយរស់នៅដោយក្លាហានក្នុងមួយជីវិតរបស់គេ នឹងទទួល បាននគរសេឡេស្ទាល (សូមមើល គ និង ស 76៖50–70)។
  - មនុស្សដែលមានកិត្តិយសគឺជាមនុស្សដែល “ខ្វាក់ដោយសារឧបាយកលនៃមនុស្ស” ហើយអ្នកដែល “ពុំក្លាហាន ក្នុងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ [គ្រីស្ទ]” ទទួលនគរទេរេស្ទ្រាល (សូមមើល គ និង ស 76៖75, 79)។
  - អ្នកទាំងឡាយណាដែលមានបាប ហើយមិនប្រែចិត្តនឹងទទួលភាពរុងរឿងនៃនគរទេឡេស្ទាល បន្ទាប់ពីការ ទទួលរងទុក្ខ និងបង់ថ្លៃចំពោះអំពើបាបរបស់គេ។

### ការតាំងចិត្ត

- តើអ្នកព្រមអធិស្ឋាន ដើម្បីដឹងថា អ្វីដែលយើងបានបង្រៀន គឺជា ការពិត ដែរឬទេ?
- តើអ្នកព្រមប្រែចិត្ត ពីអំពើបាបរបស់អ្នក ដែរឬទេ?
- តើអ្នកព្រមទៅព្រះវិហារជាមួយយើង នៅថ្ងៃអាទិត្យនេះ ដែរឬទេ?
- តើអ្នកព្រមធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ និងទទួលបុណ្យជ្រមុជទឹក (កាលបរិច្ឆេទ) ដែរឬទេ?
- តើយើងអាចណាត់ពេលជួប សំរាប់ពេលក្រោយបានទេ?
- បទបញ្ញត្តិចេញពីមេរៀនទី 4 ដែលអ្នកជ្រើសរើសដើម្បីបញ្ចូល។

## សំនួរដើម្បីសួរបន្ទាប់ពីអ្នកបង្រៀន

- តើអ្នកមានសំនួរពីអ្វីដែលយើងបានបង្រៀន ដែរឬទេ?
- តើអ្នកយល់អ្វីខ្លះ អំពីផែនការរបស់ព្រះសំរាប់អ្នក និងក្រុមគ្រួសាររបស់អ្នក?
- យោងតាមអ្វីដែលយើងបានបង្រៀនដល់អ្នក តើអ្នកយល់តួនាទីរបស់ព្រះយេស៊ូវគ្រីស្ទគឺជាអ្វី? តើអ្វីដែលយើង បានបង្រៀននេះ មានអត្ថន័យចំពោះអ្នកយ៉ាងដូចម្ដេចដែរ?

កំណត់ចំណាំ

## និយមន័យសំខាន់ៗ

នៅខាងក្រោមនេះ ជាញឹកញាប់ គឺជាពាក្យមិនយល់។ ចូរប្រាកដថា អ្នកពន្យល់ពួកគេយ៉ាងច្បាស់ និងស្វែងយល់ ថាតើពួកគេយល់ពីអ្វីដែលអ្នកបង្រៀនដែរទេ។

- **ដង្វាយធួន៖** ដូចដែលបានប្រើនៅក្នុងព្រះគម្ពីរ ការធួន គឺជាការទទួលរងទណ្ឌកម្ម សំរាប់សកម្មភាពនៃ អំពើបាប ដើម្បីដកចេញនៃឥទ្ធិពលអំពើបាប ពីអ្នកដែលមានបាបហើយប្រែចិត្ត ហើយអនុញ្ញាតឱ្យពួកគេ មកផ្សះផ្សាជាមួយនឹងព្រះ។ ព្រះយេស៊ូវគ្រីស្ទ ទទួលរងទុក្ខក្នុងសួនច្បារគែតសេម៉ានី និងនៅលើឈើឆ្កាង។ ទ្រង់គឺជាមនុស្សតែម្នាក់ប៉ុណ្ណោះដែលមាន សមត្ថភាព ធ្វើឱ្យដង្វាយធួនបានល្អឥតខ្ចោះសំរាប់មនុស្សទាំងអស់។ ទ្រង់បានទទួលរងទណ្ឌកម្ម សំរាប់អំពើបាបរបស់យើងនៅក្នុង សួនច្បារគែតសេម៉ានី ហើយបានសុគតនៅលើឈើឆ្កាង។ ទ្រង់បានទទួលដាក់លើខ្លួន របស់ទ្រង់ការឈឺចាប់ ជំងឺ ការល្បួង ទុក្ខព្រួយ និងពិការភាពនៃយើងទាំងអស់គ្នា (សូមមើល អាលម៉ា 7៖11–12)។
- **ការលើកតំកើង៖** ជីវិតអស់កល្បជានិច្ច គឺជាការរស់ក្នុងវត្តមានរបស់ព្រះ ដើម្បីក្លាយដូចជាព្រះវរបិតារបស់ យើងនៅស្ថានសួគ៌ ហើយរស់នៅជាមួយវត្តមានរបស់ទ្រង់។ ជាអំណោយដ៏ធំជាងគេនៃអំណោយទាំងអស់របស់ព្រះ។ ការលើកដំកើងបានមកតាមរយៈដង្វាយធួននៃព្រះគ្រីស្ទ ហើយតាមរយៈការគោរពប្រតិបត្តិចំពោះក្រិត្យវិន័យ និងពិធីការទាំងអស់នៃដំណឹងល្អ។
- **ការធ្លាក់ (អ័ដាម និងអេវ៉ា)៖** នៅពេលអ័ដាម និងអេវ៉ាបានបរិភោគផ្លែឈើហាមឃាត់ ពួកគេបានក្លាយ ជាមានរូបកាយ ដែលអាចស្លាប់បាន—មានន័យថា ធ្លាក់ក្នុងសេចក្ដីស្លាប់ និងអំពើបាប។ អ័ដាមក្លាយជា "សាច់ទីមួយ"នៅលើផែនដី (ម៉ូសេ 3៖7)។ វិវរណៈសម័យ ចុងក្រោយបានធ្វើឱ្យច្បាស់ថា ការធ្លាក់ គឺជាពរជ័យ ហើយថាអ័ដាម និងអេវ៉ា គួរតែបានទទួលកិត្តិយស ក្នុងនាមជាឪពុកម្ដាយដំបូងនៃមនុស្សទាំងអស់។
- **ការជំនុំជំរះ៖** តាមរយៈព្រះយេស៊ូវគ្រីស្ទព្រះនឹងកាត់ក្ដីយើងម្នាក់ៗ ដើម្បីកំណត់ភាពរុងរឿងអស់កល្បជានិច្ច ដែលយើងនឹងទទួល។ ជំនុំជំរះនេះនឹងយោងទៅលើការគោរពប្រតិបត្តិរបស់យើងចំពោះបទបញ្ញត្តិរបស់ព្រះ ដោយបូករួមទាំង ការទទួលស្គាល់របស់យើង ការបូជាដ៏ធួនរបស់ព្រះយេស៊ូវគ្រីស្ទ។ យើងនឹងទទួលរង្វាន់អស់កល្បជានិច្ច របស់យើងអាស្រ័យលើកិច្ចការ និង បំណងប្រាថ្នារបស់យើងល្អឬអាក្រក់។
- **អមតភាព៖** លក្ខខ័ណ្ឌដែលរស់នៅជារៀងរហូត ក្នុងស្ថានភាពនៃការរស់ឡើងវិញ មិនធ្លាក់ក្នុងការស្លាប់ខាង រូបកាយទេ។
- **មតភាព៖** រយៈពេលចាប់ពីការកំណើតរហូតដល់សេចក្ដីស្លាប់ខាងរូបកាយ។
- **សេចក្ដីស្លាប់ខាងរូបកាយ៖** ការបំបែកវិញ្ញាណរបស់យើង ដែលរស់នៅជារៀងរហូត ហើយមិនអាចស្លាប់ពីសេចក្ដីស្លាប់ ខាងរូបកាយរបស់យើង។
- **ជីវិតមុនឆាកជីវិតនេះ** (មុនជីវិតរមែងស្លាប់ ជីវិតមុនកើត)៖ ដោយជាកូនចៅខាងវិញ្ញាណរបស់ព្រះវរបិតារបស់យើងនៅស្ថានសួគ៌ យើងបានរស់នៅក្នុងវត្តមានរបស់ទ្រង់ ពីមុនយើងកើតនៅលើផែនដីនេះ។ នៅក្នុងជីវិតមុនឆាកជីវិតនេះ យើងមិនមានរូបកាយទេ។
- **សេចក្ដីប្រោសលោះការរំដោះ** ការទិញ ឬការលោះ ដូចជា រំដោះមនុស្សចេញពីសេវកភាពដោយការបង់ថ្លៃ។ សេចក្ដី ប្រោសលោះសំដៅទៅដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និងការរំដោះពីអំពើបាប។ ដង្វាយធួនរបស់ព្រះគ្រីស្ទប្រោសលោះដល់ មនុស្សទាំងអស់ពីសេចក្ដីស្លាប់ខាងរូបកាយ។ តាមរយៈដង្វាយធួនរបស់ទ្រង់ អ្នកទាំងឡាយណា ដែលមានជំនឿហើយប្រែចិត្ត នៅក្នុងទ្រង់ ក៏ត្រូវបានប្រោសលោះពីសេចក្ដីស្លាប់ខាងវិញ្ញាណផងដែរ។
- **ការរស់ឡើងវិញ៖** ការផ្គុំឡើងវិញនៃវិញ្ញាណជារូបកាយ ជាមួយនឹងរូបកាយនៃសាច់និងឆ្អឹងក្រោយ ពីសេចក្ដីស្លាប់។ បន្ទាប់ពីការរស់ឡើងវិញ វិញ្ញាណនិងរូបកាយនឹងមិនបំបែកចេញពីគ្នាទៀតទេ ហើយយើងនឹងក្លាយជាអមតៈ។ មនុស្សគ្រប់រូបដែលកើតនៅលើផែនដីនឹងបានរស់ឡើងវិញ ព្រោះព្រះយេស៊ូវគ្រីស្ទ បានឈ្នះលើសេចក្ដីស្លាប់។
- **សេចក្ដីសង្គ្រោះ៖** ដើម្បីសង្គ្រោះពីសេចក្ដីស្លាប់ខាងរូបកាយ និងសេចក្ដីស្លាប់ខាងវិញ្ញាណ។ មនុស្សទាំងអស់នឹងត្រូវបានសង្គ្រោះពីសេចក្ដីស្លាប់ខាងរូបកាយ ដោយព្រះគុណនៃព្រះ សេចក្ដីស្លាប់ និងការរស់ឡើងវិញនៃព្រះយេស៊ូវគ្រីស្ទ។ សេចក្ដីជំនឿនេះ គឺបង្ហាញក្នុងជីវិត នៃការគោរពប្រតិបត្តិចំពោះក្រិត្យវិន័យ និងពិធីការនៃដំណឹងល្អ និងបំរើដល់ព្រះគ្រីស្ទ។
- **ការស្លាប់ខាងវិញ្ញាណ៖** គឺជាការបំបែកចេញពីព្រះ និងឥទ្ធិពលរបស់ទ្រង់ ស្លាប់ជារឿងដែលទាក់ទងនឹងសេចក្ដីសុចរិត។ ការស្លាប់ខាងវិញ្ញាណត្រូវបាននាំឱ្យស្គាល់ដល់ពិភពលោក ដោយការធ្លាក់របស់អ័ដាម (សូមមើល អាលម៉ា 42៖6–7)។

កំណត់ចំណាំ

រូបកាយ ដែលរមែងស្លាប់ ជាមួយនឹងគំនិត ពាក្យសំដី និងកិច្ចការអាក្រក់ គឺជាការស្លាប់ខាង វិញ្ញាណ នៅពេលដែលយើងកំពុងមានជីវិតនៅ លើផែនដី (សូមមើល នីហ្វៃទី 2 9៖39)។ តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និងការគោរពចំពោះគោលការណ៍ និងពិធី ការនៃដំណឹងល្អ បុរសនិងស្ត្រីអាចបានជ្រះស្អាត ពីអំពើបាប និងឈ្នះលើសេចក្ដីស្លាប់ខាងវិញ្ញាណ។

## ពាក្យផ្សេងៗទៀត ដែលអាចត្រូវការនិយមន័យបន្ថែម សំរាប់អ្នកទាំងឡាយណាដែលអ្នកបង្រៀន

- ពិធីបុណ្យជ្រមុជទឹកដោយការពន្លិច
- សេឡេស្ទាល
- បានជ្រះស្អាត [ពីអំពើបាប]
- ការបង្កបង្កើត
- ការរីកចំរើនដ៏អស់កល្បជានិច្ច
- ជីវិតអស់កល្បជានិច្ច
- សេចក្ដីជំនឿ
- ផ្លែឈើហាមឃាត់
- ការអភ័យ [បាប]
- សួនច្បារអេដែន
- នគរនៃភាពរុងរឿង
- ការប្រឆាំង
- សេចក្ដីស្លាប់ខាងរូបកាយ
- ផែនការនៃសេចក្ដីសង្គ្រោះ
- ការសាកល្បង
- ការប្រែចិត្ត
- អំពើបាប
- ពិភពវិញ្ញាណ
- ទេឡេស្ទាល
- ទេរេស្ទ្រាល
- ដើមឈើនៃការចេះដឹង ល្អនិងអាក្រក់

# ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ



## គោលបំណងរបស់អ្នក

នៅពេលដែលអ្នកបង្រៀន ចូររៀបចំសាសនាគន់ការីរបស់អ្នក ឱ្យមានភាពសក្ដិសមសំរាប់ពិធីបុណ្យជ្រមុជទឹក ដែលបានបង្រៀនទៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា 20៖37 និងទៅក្នុងសំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក។ នេះអាចសំរេច បានប្រសើរ ដោយការអញ្ជើញសាសនាគន់ការីរបស់អ្នក ដើម្បីធ្វើនិងរក្សាការតាំងចិត្តដែលបានសរសេរដូចខាងក្រោម។

### សំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក

- តើអ្នកជឿថា ព្រះគឺជាព្រះវរបិតាដ៏អស់កល្បរបស់យើង ដែរឬទេ?
- តើអ្នកជឿថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ ជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះនៃពិភពលោក ដែរឬទេ?
- តើអ្នកជឿថា សាសនាចក្រ និងដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ត្រូវបានស្តារឡើងវិញ តាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ដែរឬទេ?

### ការតាំងចិត្ត

- តើអ្នកព្រមបន្តអភិវឌ្ឍន៍សេចក្ដីជំនឿទៅក្នុងព្រះយេស៊ូវគ្រីស្ទ ដោយការបន្តរៀនអំពីដំណឹងល្អរបស់ទ្រង់ ដែរឬទេ?
- តើអ្នកព្រមប្រែចិត្ត និងអធិស្ឋានសុំការអភ័យបាបដែរឬទេ?
- តើអ្នកព្រមទទួលបុណ្យជ្រមុជទឹក ដើម្បីក្លាយជាសមាជិក នៃសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយនៅ (កាលបរិច្ឆេទ) ដែរឬទេ? តើអ្នកព្រមទទួលការបញ្ជាក់ និងទទួលអំណោយទាន នៃព្រះវិញ្ញាណបរិសុទ្ធដែរឬទេ?
- តើអ្នកព្រមទៅព្រះវិហារជាមួយយើង នៅថ្ងៃអាទិត្យនេះ ដែរឬទេ?
- តើយើងអាចណាត់ពេលជួបសំរាប់ពេលក្រោយបានទេ?
- បទបញ្ញត្តិចេញពីមេរៀនទី 4 ដែលអ្នកជ្រើសរើសដើម្បីរួមបញ្ចូល

## តាមរយៈព្រះគ្រីស្ទយើងអាចជ្រះស្អាតពីអំពើបាប

ព្រះបានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ មកពិភពលោកនេះ ដើម្បីឱ្យកូនចៅរបស់ព្រះទាំងអស់ អាចត្រឡប់ទៅរស់នៅក្នុងទីវត្តមានរបស់ទ្រង់ បន្ទាប់ពីពួកគេបានស្លាប់។ មានតែតាមរយៈព្រះគុណ និងសេចក្ដីមេត្តាករុណារបស់ព្រះ អង្គសង្គ្រោះតែប៉ុណ្ណោះ ទើបយើងអាចជ្រះស្អាតពីអំពើបាប ដើម្បីយើងអាចរស់នៅក្នុងទីវត្តមានរបស់ព្រះវរបិតាសួគ៌។ ការជ្រះស្អាតពីអំពើបាប គឺជាការជាសះស្បើយខាងវិញ្ញាណ (សូមមើល នីហ្វៃទី 3 9៖13, 18៖32)។

ព្រោះដង្វាយធួន និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទមនុស្សទាំងអស់នឹងនាំមកឈរនៅក្នុងទីវត្តមានរបស់ព្រះអម្ចាស់ ដើម្បីទទួលការជំនុំជំរះ យោងទៅតាមកិច្ចការ និងបំណងប្រាថ្នារបស់ពួកគេ (សូមមើល នីហ្វៃទី 2 9៖10–16, ហេលេមិន 14៖15–18, នីហ្វៃទី 3 27៖14–22, គ និង ស 137៖9)។ យើងនឹងទទួលការជំនុំជំរះស្របទៅតាមក្រិត្យវិន័យនៃយុត្តិធម៌ និងមេត្តាករុណា។

កំណត់ចំណាំ

យុត្តិធម៌មានរួមទាំងក្រិត្យវិន័យ ដែលមិនផ្លាស់ប្ដូរ ដែលនាំមកនូវផលសំរាប់សកម្មភាព—ការប្រទានពរសំរាប់ការប្រតិបត្តិតាមព្រះបញ្ញត្តិ និងទណ្ឌកម្មចំពោះការមិនគោរពប្រតិបត្តិ។ យើងទាំងអស់គ្នាប្រព្រឹត្តអំពើបាប។ អំពើបាបធ្វើឲ្យយើងមិនជ្រះស្អាត ហើយគ្មានវត្ថុមិនស្អាតណា អាចរស់នៅក្នុងវត្តមានរបស់ព្រះបានឡើយ (សូមមើល នីហ្វៃទី 1 10ៈ12, នីហ្វៃទី 3 27ៈ19, ម៉ូសេ 6ៈ57)។

ព្រះអង្គសង្គ្រោះពេញចិត្តចំពោះការទាមទារយុត្តិធម៌ ឲ្យអ្នកទាំងឡាយណាដែលប្រែចិត្តពីអំពើបាបរបស់ពួកគេ ហើយព្យាយាមគោរពព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ នៅពេលដែលទ្រង់ឈរជំនួសយើង ហើយទទួលរងការ ដាក់ទោសចំពោះអំពើបាបរបស់យើង។ ដោយសារតែទង្វើដែលមិនគិតពីខ្លួនឯងដូច្នេះទើប ព្រះគ្រីស្ទអាចសូមអង្វរ ព្រះវរបិតាជំនួសយើង។ ព្រះវរបិតាសួគ៌អាច ប្រទានសេចក្ដីមេត្តាករុណា ដោយការដកយកការដាក់ទោសពីយើង ហើយស្វាគមន៍យើងចូលទៅក្នុងវត្តមានរបស់ទ្រង់។ ព្រះវរបិតាសួគ៌របស់យើង បង្ហាញសេចក្ដីមេត្តាករុណា នៅពេលដែលទ្រង់អភ័យទោសចំពោះអំពើបាបរបស់យើង ហើយនាំយើង ត្រឡប់ទៅរស់នៅក្នុងទីវត្តមានរបស់ទ្រង់។

ទោះបីជាយ៉ាងណាក៏ដោយ ព្រះយេស៊ូវមិនបានដកយកនូវការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់យើងទេ។ ទ្រង់អភ័យទោសចំពោះអំពើបាបរបស់យើង ពេលយើងទទួលស្គាល់ទ្រង់ ប្រែចិត្ត និងគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់។ តាមរយៈដង្វាយធួន និងការរស់នៅតាមដំណឹងល្អ យើងអាចមានភាពសក្ដិសម ដើម្បីចូលទៅ ក្នុងវត្តមានរបស់ព្រះវរបិតាសួគ៌របស់យើងជាអចិន្ត្រៃយ៍។ យើងត្រូវតែបង្ហាញថា យើងទទួលព្រះគ្រីស្ទ ហើយថា យើងមានសេចក្ដីជំនឿលើទ្រង់ ដោយការគោរពព្រះបញ្ញត្តិរបស់ទ្រង់ និងការគោរពប្រតិបត្តិតាមគោលការណ៍ទីមួយ និងពិធីការនៃដំណឹងល្អ។

### អំពើបាប

សញ្ញាណនៃ "អំពើបាប" មានន័យខុសពីគ្នានៅក្នុងវប្បធម៌ខុសពីគ្នា។ នៅក្នុងវប្បធម៌ខ្លះ អំពើបាបមានន័យដូច នឹងគំនិតនៃការ ប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម។ នៅក្នុងវប្បធម៌ផ្សេងៗ អំពើបាបគឺអនុវត្តបាន តែពេលណាគេ ចាប់បានជននោះកំពុងធ្វើអ្វីមួយខុស ហើយនាំមកនូវភាពអាម៉ាស់ចំពោះក្រុមគ្រួសារ ឬសហគមន៍។ បញ្ជាក់ឲ្យច្បាស់អំពើបាប គឺជាការមិនគោរពប្រតិបត្តិ ចំពោះព្រះ បញ្ញត្តិរបស់ព្រះ ហើយនាំមកនូវការបំបែកចេញពីព្រះ។ ព្រះជ្រាបដឹងគ្រប់អ្វីៗ ដែលយើងធ្វើនិងគិត ហើយយើងធ្វើឲ្យទ្រង់មិន សព្វព្រះទ័យ ពេលយើងមានបាបកម្ម។ ចូរកុំពិភាក្សាពីសេចក្ដីរំលង របស់អ្នកពីអតីតកាល។ លើកទឹកចិត្ត ឬសួរ សាសនាទាគន់ការី ឲ្យពិភាក្សាពីការរំលងរបស់ពួកគេ។

### ការសិក្សាព្រះគម្ពីរ

**ព្រះបាទបញ្ជូនព្រះរាជបុត្រារបស់ទ្រង់**

អាលម៉ា 11ៈ40 — យ៉ូហាន 3ៈ16–17

**ព្រះគ្រីស្ទគឺជាអង្គជំនួយរបស់យើង**

សូមមើល គ និង ស 45ៈ3–5

**សេចក្ដីសង្គ្រោះតាមរយៈព្រះគ្រីស្ទ**

នីហ្វៃទី 2 2ៈ6–8 — អាលម៉ា 34ៈ8–9, 14–16
នីហ្វៃទី 2 9ៈ21–24

**សេចក្ដីមេត្តាករុណា និងសេចក្ដីយុត្តិធម៌**

ម៉ូសាយ 15ៈ9 — អាលម៉ា 42ៈ22–25

## សេចក្ដីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ



គោលការណ៍ទីមួយនៃដំណឹងល្អ គឺជាសេចក្ដីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ។ ការមានជំនឿនៅក្នុងព្រះគ្រីស្ទ រួមទាំង ការជឿដោយ មុតមាំថា ទ្រង់គឺជាព្រះរាជបុត្រាបង្កើតតែមួយរបស់ព្រះ និងជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះនៃពិភពលោក។ យើង បានដឹងថា យើងអាចត្រឡប់ទៅរស់នៅជាមួយព្រះវរបិតាសួគ៌របស់យើង តែតាមរយៈការពឹងលើព្រះគុណ និងសេចក្ដីមេត្តាករុណា របស់ព្រះរាជបុត្រានៃទ្រង់តែប៉ុណ្ណោះ។ ពេលដែលយើងមានជំនឿនៅលើព្រះគ្រីស្ទ យើងទទួលហើយអនុវត្តតាម ដង្វាយធួន និងការបង្រៀនរបស់ទ្រង់។ យើងទុកចិត្តទ្រង់នូវអ្វីដែលទ្រង់មានព្រះបន្ទូល។ យើងដឹងថា ទ្រង់មានអំណាច ដើម្បីរក្សាសេចក្ដីសន្យារបស់ទ្រង់។ ព្រះវរបិតាសួគ៌ ប្រទានពរដល់អ្នកទាំងឡាយណាដែលមានជំនឿ និងគោរពប្រតិបត្តិតាម ព្រះរាជបុត្រារបស់ទ្រង់។

នាំឲ្យមាន ការមានជំនឿនៅក្នុងព្រះគ្រីស្ទ។ សេចក្ដីជំនឿនាំទៅរកការប្រែចិត្តដោយស្មោះ និងជារៀងរហូត។ ការមានសេចក្ដីជំនឿធ្វើឲ្យមានសេចក្ដីព្យាយាម

កំណត់ចំណាំ

យ៉ាងខ្លាំងក្លា ដើម្បីរៀន និងការក្លាយឱ្យកាន់តែដូចជាព្រះអង្គសង្គ្រោះ។ យើងចង់រៀន ពីអ្វីទៅដែលជាព្រះបញ្ញត្តិរបស់ទ្រង់ និងបន្ទាប់មកប្រតិបត្តិតាមព្រះបញ្ញត្តិទាំងនោះ។ ទោះបីជា យើងនៅតែមានកំហុស យើងបង្ហាញសេចក្ដីស្រលាញ់របស់យើងចំពោះទ្រង់ ដោយការព្យាយាមធ្វើតាមព្រះបញ្ញត្តិរបស់ទ្រង់ និងជៀសវាងពីអំពើបាប។

យើងជឿលើព្រះគ្រីស្ទ ហើយយើងជឿថា ទ្រង់ចង់ឱ្យយើងចង់គោរពតាមព្រះបញ្ញត្តិទាំងអស់របស់ទ្រង់។ យើងចង់ បង្ហាញសេចក្ដីជំនឿរបស់យើង ដោយការគោរពប្រតិបត្តិតាមទ្រង់។ យើងអធិស្ឋាននៅក្នុងសេចក្ដីជំនឿ សំរាប់កំលាំង ហើយដើម្បីយកឈ្នះលើការល្បួង។ យើងក៏អាចបង្កើនសេចក្ដីជំនឿផងដែរ នៅក្នុងគោលការណ៍ដ៏ច្បាស់លាស់ ដូចជា ពាក្យគតិបណ្ឌិត ឬដង្វាយមួយភាគក្នុងដប់ ដោយការជឿលើព្រះគ្រីស្ទជាមុនឱ្យ ខ្លាំងល្មមគ្រប់គ្រាន់ដើម្បីគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់។ ពេលដែល យើងរស់នៅក្នុងព្រះបញ្ញត្តិដ៏ច្បាស់លាស់ យើងរៀនពីសេចក្ដីពិតដ៏ពេញលេញ នៃព្រះបញ្ញត្តិតាមរយៈបទពិសោធន៍ (យ៉ូហាន 7៖17)។ យើងក៏រីកចំរើននៅក្នុងសេចក្ដីជំនឿផងដែរ ដោយការស្ដាប់តាមព្រះបន្ទូលនៃព្រះ (សូមមើល រ៉ូម 10៖17) និងដោយ ការអានព្រះបន្ទូលរបស់ព្រះ (សូមមើល ហេលេមិន 15៖7–8)។

នៅពេលដែលយើងគោរពតាមព្រះ ទ្រង់ប្រទានពរដល់យើង។ ទ្រង់ប្រទានអំណាចដល់យើង ដើម្បីឈ្នះលើការប្រឈម មុខនៃជីវិត។ ទ្រង់ជួយយើងផ្លាស់ប្ដូរបំណងប្រាថ្នានៃដួងចិត្ត។ តាមរយៈសេចក្ដីជំនឿរបស់យើងនៅក្នុងព្រះយេស៊ូវគ្រីស្ទ ទ្រង់អាចព្យាបាលឱ្យយើងទាំងខាងរូបកាយ និងខាងវិញ្ញាណ។

### ការសិក្សាព្រះគម្ពីរ

**សេចក្ដីជំនឿ អំណាច និងសេចក្ដីសង្គ្រោះ**

នីហ្វៃទី 1 7៖12
នីហ្វៃទី 2 9៖23
នីហ្វៃទី 2 25៖23
មរ៉ូណៃ 7៖33–34
មរ៉ូណៃ 10៖7

**គោលលទ្ធិនៃសេចក្ដីជំនឿ**

អាលម៉ា 32
អេធើរ 2៖8
Guide to the Scriptures, “Faith”

**គំរូនៃសេចក្ដីជំនឿ**

អេធើរ 12
ហេព្រើរ 11

**កិច្ចការ និងការប្រតិបត្តិតាម**

នីហ្វៃទី 1 3៖7
គ និង ស 130៖20–21
យ៉ាកុប 2៖17–26

**សេចក្ដីជំនឿនាំទៅរកការប្រែចិត្ត**

អាលម៉ា 34

## ការប្រែចិត្ត

គោលការណ៍ទីពីរនៃដំណឹងល្អ គឺជាការប្រែចិត្ត។ សេចក្ដីជំនឿ និងសេចក្ដីស្រលាញ់របស់យើងចំពោះទ្រង់ នាំឱ្យយើងប្រែចិត្ត ឬផ្លាស់ប្ដូរការគិតរបស់យើង ជឿ និងការប្រព្រឹត្តដែលមិនចុះសំរុងនឹងឆន្ទៈរបស់ទ្រង់។ ការប្រែចិត្ត ប៉ូករួមទាំងទំរង់ នៃការមើលឃើញនៃព្រះ ខ្លួនយើង និងពិភពលោក។ ពេលដែលយើងប្រែចិត្ត យើងមានអារម្មណ៍សោកស្ដាយ ចំពោះព្រះ ក្រោយមកយើងឈប់ធ្វើអ្វីដែលខុស ហើយបន្តធ្វើអ្វីដែលត្រូវ។ ការនាំយកជីវិតរបស់យើង នៅក្នុង ខ្សែបន្ទាត់ជាមួយនឹងឆន្ទៈរបស់ព្រះ តាមរយៈការប្រែចិត្ត គឺជាចំណុចកណ្ដាលនៃគោលបំណងនៃជីវិតរបស់យើង។ យើង អាចត្រឡប់ទៅរស់នៅជាមួយនឹងព្រះជាព្រះវរបិតា មានតែតាមរយៈសេចក្ដីមេត្តាករុណារបស់ព្រះគ្រីស្ទតែប៉ុណ្ណោះ យើងអាចទទួលសេចក្ដីមេត្តាករុណារបស់ព្រះគ្រីស្ទ មានតែតាមលក្ខខ័ណ្ឌនៃការប្រែចិត្តតែប៉ុណ្ណោះ។

ដើម្បីប្រែចិត្ត យើងត្រូវទទួលស្គាល់អំពើបាបរបស់យើង ហើយមានវិប្បដិសារី ឬមានអារម្មណ៍សោកស្ដាយចំពោះព្រះ។ យើងសារភាពអំពើបាបរបស់យើងចំពោះព្រះ។ យើងក៏សារភាពនូវទោស កំហុសដ៏ធ្ងន់ធ្ងរចំពោះអ្នកដឹកនាំសាសនាចក្រ ដែលមានសិទ្ធិអំណាចពីព្រះ ដែលជាអ្នកអាចជួយយើងឱ្យប្រែចិត្ត។ យើងសូមដល់ព្រះនៅក្នុងការអធិស្ឋាន ដើម្បីឱ្យទ្រង់ អភ័យទោសដល់យើង។ យើងធ្វើអ្វីៗ ដែលយើងអាចធ្វើបាន ដើម្បីកែនូវបញ្ហា ដែលអំពើរបស់យើងអាច បង្កឱ្យមានការណ៍ នេះត្រូវបានហៅថា ការធ្វើឱ្យដូចដើមវិញ។ ពេលយើងប្រែចិត្ត ការមើលឃើញនៃខ្លួនរបស់យើង និងពិភពលោកផ្លាស់ប្ដូរ។ ពេលដែលយើងផ្លាស់ប្ដូរ យើងដឹងថា យើងជាកូនចៅរបស់ព្រះ ហើយថា យើងមិនត្រូវការបន្ត ធ្វើកំហុសដូចគ្នាដដែលៗនោះទេ។ បើយើងប្រែចិត្តដោយស្មោះ យើងត្រឡប់ចេញពីអំពើបាបរបស់យើង ហើយមិនធ្វើបាបទៀតឡើយ។ យើងមិនមានបំណង ចង់ប្រព្រឹត្តអំពើបាបទៀតឡើយ។ បំណងប្រាថ្នារបស់យើងគឺដើម្បីធ្វើតាមព្រះ កាន់តែខ្លាំងឡើង និងជ្រៅឡើង។

កំណត់ចំណាំ

ការប្រែចិត្តដោយស្មោះ នាំមកនូវលទ្ធផលជាច្រើន។ យើងទទួលអារម្មណ៍អភ័យទោសរបស់ព្រះ ហើយមានសេចក្តីសុខសាន្ត របស់ទ្រង់នៅក្នុងជីវិតរបស់យើង។ កំហុស និងការសោកសៅរបស់យើងត្រូវបានដកយកចេញឆ្ងាយ។ យើងទទួលអារម្មណ៍ ពីឥទ្ធិពលនៃព្រះវិញ្ញាណ នៅក្នុងភាពសម្បូរសប្បាយដ៏ធំ។ ហើយនៅពេលដែលយើងស្លាប់ពីជីវិតនេះទៅ យើងនឹងរឹតតែបានរៀបចំខ្លួនដើម្បីរស់នៅជាមួយព្រះវរបិតាសួគ៌ និងព្រះរាជបុត្រារបស់ទ្រង់។

ទោះបីជាបន្ទាប់ពីយើងបានទទួលស្គាល់ព្រះគ្រីស្ទ និងបានប្រែចិត្តពីអំពើបាបរបស់យើង យើងអាចធ្លាក់ក្នុងអំពើបាបម្តងទៀត។ យើងគួរតែបន្តព្យាយាមកែនូវការរំលងទាំងនេះ។ លើសពីនេះទៀត យើងគួរតែបន្តអភិវឌ្ឍន៍—ដើម្បីអភិវឌ្ឍន៍គុណសម្បត្តិដូច ព្រះគ្រីស្ទ ដើម្បីរីកចំរើនខាងការចេះដឹង និងធ្វើឱ្យការបំរើកាន់តែមានប្រសិទ្ធភាព។ ពេលដែលយើង រៀនបន្ថែមទៀត អំពីអ្វីដែល ព្រះអង្គសង្គ្រោះសង្ឃឹមទុកពីយើង នោះយើងនឹងចង់បង្ហាញសេចក្តីស្រលាញ់របស់យើង ដោយការគោរពប្រតិបត្តិតាមទ្រង់។ ហេតុដូច្នេះ ពេលដែលយើងប្រែចិត្តជារៀងរាល់ថ្ងៃ យើងនឹងស្វែងរកឃើញថា ជីវិតរបស់យើងនឹងផ្លាស់ប្តូរ ហើយអភិវឌ្ឍន៍ទៅមុខ។ ដួងចិត្ត និងការប្រព្រឹត្តរបស់យើង នឹងកាន់តែដូចព្រះគ្រីស្ទ។ យើងនឹងមកទទួលអារម្មណ៍នៃ សេចក្តីអំណរដ៏អស្ចារ្យ នៅក្នុងការប្រែចិត្តជារៀងរាល់ថ្ងៃ។

### ការសិក្សាព្រះគម្ពីរ

**យើងទាំងអស់គ្នាមានអំពើបាប**

រ៉ូម 3៖23
យ៉ូហានទី 1 1៖7–8

**សេចក្តីប្រោសលោះ និងការអភ័យទោស**

ហេលេមិន 5៖10–11

**ការប្រែចិត្ត**

អាលម៉ា 34៖8–17
សូមមើល គ និង ស 58៖42–43
សូមមើល គ និង ស 61៖2
កូរិនថូសទី2 7៖9–10
Guide to the Scriptures, "Repent, Repentance"

**សេចក្តីមេត្តាករុណាទាមទារការសោកស្តាយ**

អាលម៉ា 12៖32–35
អាលម៉ា 42៖13, 21–24
សូមមើល គ និង ស 18៖10–13

## ពិធីបុណ្យជ្រមុជទឹក សេចក្តីសញ្ញាទីមួយរបស់យើង



សេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ និងការប្រែចិត្ត រៀបចំយើងសំរាប់ពិធីការនៃពិធីបុណ្យជ្រមុជទឹក និងការបញ្ជាក់។ ពិធីការ គឺជាពិធីពិសិដ្ឋ ឬជាការបង្ហាញថា យើងបានចូលទៅក្នុងសេចក្តីសញ្ញាជាមួយព្រះ។

ព្រះតែងតែទាមទារឱ្យកូនចៅរបស់ទ្រង់ចុះសេចក្តីសញ្ញា។ សេចក្តីសញ្ញា គឺជាការចង និងជាការយល់ព្រមគ្នាយ៉ាងមុតមាំ រវាងព្រះ និងមនុស្ស។ ព្រះសន្យាថា ទ្រង់នឹងប្រទានពរដល់យើង ហើយយើងសន្យាថា នឹងគោរពប្រតិបត្តិតាមទ្រង់។ ព្រះទ្រង់នៃសេចក្តី សញ្ញាដំណឹងល្អ ដែលយើងត្រូវតែជ្រើសរើស ឬបដិសេធន៍។ ការរក្សាសេចក្តីសញ្ញា នាំមកពរជ័យនៅក្នុងជីវិតនេះ និងជីវិតនៃការ លើកដំកើងដែលនឹងមក។

សេចក្តីសញ្ញាដាក់យើងស្ថិតនៅក្រោមកាតព្វកិច្ច ដើម្បីគោរពការតាំងចិត្តរបស់យើងចំពោះព្រះ។ ដើម្បីរក្សាសេចក្តីសញ្ញា របស់យើង យើងត្រូវតែបោះបង់ចោលនូវសកម្មភាព ឬប្រយោជន៍ដែលបញ្ឈប់យើងពីការគោរពសេចក្តីសញ្ញាទាំងនោះ។ ឧទាហរណ៍ យើងបោះបង់ចោលការទិញឥវ៉ាន់ និងការប្រកបការងារនៅថ្ងៃអាទិត្យ ដើម្បីឱ្យយើងអាច រក្សាថ្ងៃសីលឱ្យ បានបរិសុទ្ធ។ យើងគួរតែមានបំណងប្រាថ្នាដើម្បីទទួលសេចក្តីសញ្ញាដែលព្រះ ប្រទានដល់យើង ហើយព្យាយាម ដើម្បីរក្សាសេចក្តីសញ្ញាដោយសក្តិសមនោះ។ សេចក្តីសញ្ញារំលឹកយើងឱ្យប្រែចិត្តរាល់ថ្ងៃ នៅក្នុងជីវិតរបស់យើង។ ដោយការ រក្សាព្រះបញ្ញត្តិ និងការបំរើ ដល់អ្នកដទៃ នោះយើងនឹងទទួល និងរក្សាការរំដោះបាបរបស់យើង។

សេចក្តីសញ្ញា គឺតែងតែត្រូវបានធ្វើឡើង តាមមធ្យោបាយនៃពិធីការពិសិដ្ឋ ដូចជា ពិធីបុណ្យជ្រមុជទឹក។ ពិធីការទាំងនេះ គឺត្រូវបានបំរើដោយអ្នកកាន់សិទ្ធិអំណាចបព្វជិតភាព។ តាមរយៈពិធីការបុណ្យជ្រមុជទឹក ឧទាហរណ៍ យើងចុះសេចក្តីសញ្ញា ដើម្បីព្រមលើកដាក់លើខ្លួននូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ហើយចងចាំទ្រង់ជានិច្ច ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយ របស់ទ្រង់។ ពេលដែលយើង រក្សាផ្នែកនៃសេចក្តីសញ្ញារបស់យើង ព្រះសន្យាប្រទានភាពជាដៃ គូរនៃព្រះវិញ្ញាណបរិសុទ្ធ រំដោះបាបរបស់យើង ហើយកើតម្តងទៀត។

តាមរយៈពិធីការពិសិដ្ឋ ដូចជាពិធីបុណ្យជ្រមុជទឹក និងការបញ្ជាក់ ដែលយើងរៀន និងមានបទពិសោធន៍នៃអំណាចរបស់ព្រះ (សូមមើល គ និង ស 84៖20)។ ព្រះយេស៊ូវបានបង្រៀនថា យើងត្រូវតែទទួលបុណ្យជ្រមុជទឹក ដោយការជ្រមុជទឹក សំរាប់ការ រំដោះបាប

ឬការអភ័យទោសនៃអំពើបាបរបស់យើង។ ពិធីបុណ្យជ្រមុជទឹក គឺជាផ្នែក សំខាន់នៃពិធីការនៃសេចក្ដីសង្គ្រោះ។ គ្មាននរណាម្នាក់អាចចូលទៅក្នុងនគររបស់ព្រះ ដោយគ្មានបុណ្យជ្រមុជទឹកនោះទេ។ ព្រះគ្រីស្ទ បានធ្វើជាគំរូសំរាប់យើង ដោយការ ទទួលបុណ្យជ្រមុជទឹក។

បុណ្យជ្រមុជទឹកដោយការជ្រមុជទឹក គឺជានិមិត្តសញ្ញានៃសេចក្ដីស្លាប់ បញ្ចុះសព និងការរស់ឡើងវិញនៃព្រះអង្គសង្គ្រោះ។ នៅក្នុងវិធីស្រដៀងគ្នានោះផងដែរ ពិធីបុណ្យជ្រមុជទឹក តំណាងឱ្យទីបញ្ចប់នៃជីវិតចាស់នៃអំពើបាបរបស់យើង និងការតាំងចិត្តដើម្បីរស់នៅក្នុងជីវិតថ្មី ក្នុងនាមជាសិស្សរបស់ព្រះគ្រីស្ទ។ ព្រះអង្គសង្គ្រោះបានបង្រៀនថា ពិធីបុណ្យជ្រមុជទឹកគឺជាការចាប់កំណើតម្ដងទៀត។ ពេលដែលយើងទទួលបុណ្យជ្រមុជទឹក យើងចាប់ផ្ដើមជំហាននៃការកើតម្ដងទៀត និងក្លាយជាកូនប្រុស កូនស្រីខាងវិញ្ញាណរបស់ព្រះគ្រីស្ទ (សូមមើល ម៉ូសាយ 5៖7–8, រ៉ូម 8៖14–17)។

យើងត្រូវតែទទួលបុណ្យជ្រមុជទឹកដើម្បីក្លាយជាសមាជិក នៃសាសនាចក្រដែលបានសាងឡើងវិញ គឺសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយដើម្បីចូលទៅក្នុងនគរស្ថានសួគ៌។ ពិធីការនេះ គឺជាក្រិត្យវិន័យរបស់ព្រះ ត្រូវតែធ្វើឡើងដោយសិទ្ធិអំណាចរបស់ទ្រង់។ ប៊ីស្សប ឬប្រធានបេសកកម្ម ត្រូវតែផ្ដល់ឱ្យនូវការអនុញ្ញាតដល់អ្នកកាន់បព្វជិតភាព ដើម្បី ធ្វើពិធីបុណ្យជ្រមុជទឹក ឬការបញ្ជាក់។

ក្មេងតូចៗ ពុំចាំបាច់ទទួលបុណ្យជ្រមុជទឹកទេ ហើយពួកគេត្រូវបានប្រោសលោះដោយសេចក្ដីមេត្តាករុណារបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល ម៉រ៉ូណៃ 8៖4–24)។ ពួកគេមិនទទួលបុណ្យជ្រមុជទឹករហូតដល់ ពួកគេមានវ័យដែល មានការទទួលខុសត្រូវ គឺមាន អាយុប្រាំបីឆ្នាំ (សូមមើល គ និង ស 68៖27)។

មុនពិធីបុណ្យជ្រមុជទឹក យើងបង្ហាញឆន្ទះរបស់យើងដើម្បីចូលទៅក្នុងសេចក្ដីសញ្ញា ដោយាការប្រកាន់ខ្ជាប់ព្រះបញ្ញត្តិ ទាំងអស់អស់មួយជីវិតរបស់យើង។ បន្ទាប់ពីពិធីបុណ្យជ្រមុជទឹក យើងបង្ហាញសេចក្ដីជំនឿរបស់យើង ដោយការរក្សាសេចក្ដីសញ្ញារបស់យើង។ យើងក៏រំលឹកសេចក្ដីសញ្ញារបស់យើងយ៉ាងទៀងទាត់ ដែលយើងបានធ្វើនៅពេលយើង ទទួលបុណ្យជ្រមុជទឹក ដោយការទទួលទាន នំប៉័ងនិងទឹក។ ការទទួលទាននំប៉័ងនិងទឹក ជារៀងរាល់សប្ដាហ៍ គឺជាព្រះបញ្ញត្តិមួយ។ វាធ្វើឱ្យយើងមាន ភាពសក្ដិសមដើម្បីព្រះវិញ្ញាណស្ថិតនៅជាមួយយើងជានិច្ច។ វាគឺជាការរំលឹកសេចក្ដីសញ្ញារបស់យើងជារៀងរាល់ សប្ដាហ៍។ ព្រះយេស៊ូវគ្រីស្ទបានណែនាំពិធីការនេះទៅ កាន់កូនសិស្សរបស់ទ្រង់ មុនដង្វាយធួនរបស់ទ្រង់។ ទ្រង់បានសាងពិធីការ នេះឡើងវិញតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ។ ព្រះអង្គសង្គ្រោះបានបញ្ជាថា អ្នកកាន់បព្វជិតភាពគួរតែ បំរើពិធីប្រសិទ្ធពរ នំប៉័ងនិងទឹក ក្នុងការរំលឹកចាំដល់រូបកាយនិងលោហិតរបស់ទ្រង់ ដែលទ្រង់បានបង្ហូរសំរាប់យើង។ តាមរយៈការទទួលទាន នំប៉័ងនិងទឹកដោយ មានភាពសក្ដិសម យើងសន្យាថា ចងចាំការពលិកម្មរបស់ទ្រង់ជានិច្ច យើងរំលឹកការសន្យារបស់ យើងឡើងវិញ ហើយយើងទទួលការសន្យាជាថ្មី ដែលថាព្រះវិញ្ញាណនឹងស្ថិតនៅជាមួយយើងជានិច្ច។

## មុនពិធីបុណ្យជ្រមុជទឹក

“ចូរប្រាកដថា [សាសនាគន់ការី] បានអភិវឌ្ឍន៍ជំនឿនៅក្នុងព្រះគ្រីស្ទ បានប្រែចិត្តពីការរំលង ហើយបានធ្វើការផ្លាស់ ប្ដូរនៅក្នុងជីវិតរបស់គេ គុណសម្បត្តិដូចដែលបានបញ្ជានៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា 20៖37។ សាសនាគន់ការី គួរតែរស់នៅក្នុងគោលការណ៍នៃភាពសក្ដិសមខាងសីលធម៌ ពាក្យគតិបណ្ឌិត ហើយតាំងចិត្តដើម្បីបង់ដង្វាយមួយភាគក្នុងដប់។ បើអ្នកផ្សព្វផ្សាយសាសនាមានអារម្មណ៍ថា ការរៀបចំបន្ថែមគឺចាំបាច់ ពួកគេគួរតែផ្អាក ពិធីបុណ្យជ្រមុជទឹក រហូតដល់សាសនាគន់ការី បំពេញទៅតាមបទដ្ឋាន។

“មុនពិធីបុណ្យជ្រមុជទឹក សាសនាគន់ការីម្នាក់ៗ គួរតែទទួល [មេរៀន] ទាំងអស់របស់អ្នកផ្សព្វផ្សាយសាសនា ជួបជាមួយនឹង ប៊ីស្សបរបស់គេ ឬប្រធានសាខា ហើយចូលរួមនៅក្នុងការប្រជុំពិធីប្រសិទ្ធពរនំប៉័ងនិងទឹកឱ្យបានច្រើនដង” (“Statement on Missionary Work,” First Presidentcy Letter ថ្ងៃទី 11 ខែធ្នូ ឆ្នាំ 2002)។

## ការសិក្សាព្រះគម្ពីរ

### គំរូរបស់ព្រះគ្រីស្ទ

នីហ្វៃទី 2 31៖4–18
ម៉ាថាយ 3៖13–17

### សេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក

ម៉ូសាយ 5៖8–10
ម៉ូសាយ 18៖8–10
សូមមើល គ និង ស 20៖37

### លក្ខណៈសម្បត្តិសក្ដិសមសំរាប់បុណ្យជ្រមុជទឹក

នីហ្វៃទី 2 9៖23
ម៉ូសាយ 18៖8–10
អាលម៉ា 7៖14–15
នីហ្វៃទី 3 11៖23–27
ម៉រ៉ូណៃ 6៖1–4
សូមមើល គ និង ស 20៖37
កិច្ចការពួកសាវក 2៖37–39

កំណត់ចំណាំ

| | |
|---|---|
| **ព្រះអម្ចាស់ធ្វើពិធីប្រសិទ្ធពរនំប៉័ងនិងទឹក** | |
| នីហ្វៃទី 3 18៖1–18 | លូកា 22៖15–20 |
| **ពរជ័យដែលបានសន្យានៃពិធីបុណ្យជ្រមុជទឹក** | |
| ម៉ូសាយ 4៖11–12, 26 | យ៉ូហាន 3៖5 |
| មរ៉ូណៃ 8៖25–26 | រ៉ូម 6៖4 |
| **ការអធិស្ឋាននំប៉័ងនិងទឹក** | |
| មរ៉ូណៃ 4 និង 5 | សូមមើល គ និង ស 20៖75–79 |
| **ការទទួលទាននំប៉័ងនិងទឹក** | |
| សូមមើល គ និង ស 27៖2 | កូរិនថូសទី 1 11៖23–29 |
| **ការចាំបាច់សំរាប់សិទ្ធិអំណាច** | |
| សូមមើល គ និង ស 22 | ហេព្រើរ 5៖4 |

## អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ

ព្រះយេស៊ូវបានបង្រៀនថា យើងត្រូវតែទទួលបុណ្យជ្រមុជទឹកដោយទឹក និងព្រមទាំងដោយវិញ្ញាណ។ ពិធីបុណ្យជ្រមុជទឹកដោយទឹកត្រូវតែទទួលពិធីបុណ្យជ្រមុជទឹកនៃព្រះវិញ្ញាណ បើមិនដូច្នេះទេ មិនទាន់ពេញលេញឡើយ។ មានតែការទទួលបុណ្យជ្រមុជទឹក និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធតែប៉ុណ្ណោះ ដែលយើងអាចទទួលការរំដោះបាបរបស់យើង ហើយក្លាយជាការកើតខាងវិញ្ញាណយ៉ាងពេញលេញម្ដងទៀត។ បន្ទាប់មកយើងចាប់ផ្ដើមជីវិតខាងវិញ្ញាណជាថ្មី ជាកូនសិស្សរបស់ព្រះគ្រីស្ទ។

បន្ទាប់ពីមនុស្សម្នាក់ទទួលបុណ្យជ្រមុជទឹកដោយទឹក អ្នកកាន់បព្វជិតភាពដែលមានសិទ្ធិអំណាច ម្នាក់ឬច្រើនជាងនោះ ដាក់ដៃរបស់គេ នៅលើក្បាលមនុស្សម្នាក់នោះ ហើយបញ្ជាក់មនុស្សម្នាក់នោះ ជាសមាជិកនៃសាសនចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ។ បន្ទាប់មកពួកគេប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។

អ្នកទាំងឡាយណាដែលទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ហើយនៅដោយមានភាពសក្ដិសម អាចរីករាយ ជាមួយនឹងភាពជាដៃគូរបស់ទ្រង់នៅក្នុងជីវិតរបស់គេ។ ព្រះវិញ្ញាណបរិសុទ្ធ មានឥទ្ធិពលញែកចេញជាបរិសុទ្ធ នៃភាពស្អាតស្អំចំពោះ លើយើង។ ព្រះវិញ្ញាណបរិសុទ្ធថ្លែងពីព្រះគ្រីស្ទ ហើយជួយយើងដឹងពីសេចក្ដីពិត។ ទ្រង់ផ្ដល់នូវការពង្រឹងខាងវិញ្ញាណ និងជួយ យើងធ្វើអ្វីដែលត្រូវ។ ទ្រង់លួងលោមចិត្តយើងនៅគ្រាដែលមានឧបសគ្គ ឬពេលដែលមានទុក្ខព្រួយ។ ទ្រង់ព្រមានដល់យើង អំពីគ្រោះថ្នាក់ខាងវិញ្ញាណ ឬខាងរាងកាយ។ ព្រះវិញ្ញាណបរិសុទ្ធ ប្រទានអំណាច ដែលយើងអាចបង្រៀន និងរៀន។ អំណោយ ទានព្រះវិញ្ញាណបរិសុទ្ធ គឺជាអំណោយទានដ៏មានតម្លៃបំផុតមួយរបស់ព្រះវរបិតានៃយើង។ តាមរយៈអំណាច នៃព្រះវិញ្ញាណបរិសុទ្ធ យើងអាចមានអារម្មណ៍សេចក្ដីស្រឡាញ់របស់ព្រះ និងការដឹកនាំចំពោះយើង។ អំណោយនេះ គឺជាគំរូតូចមួយ នៃសេចក្ដីស្រឡាញ់ដ៏អស់កល្បជានិច្ច និងសេចក្ដីសន្យាមួយ នៃជីវិតដ៏អស់កល្បជានិច្ច។

សិទ្ធិអំណាចបព្វជិតភាព គឺចាំបាច់ដើម្បីសម្ដែងនៅក្នុងពិធីការនេះ ដែលបានបាត់បង់ជាច្រើនសតវត្សរ៍កន្លងទៅ ដោយសារការក្បត់សាសនា ដែលត្រូវបានសាងឡើងវិញតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ។ មានតែតាមរយៈ សមាជិកភាពប៉ុណ្ណោះ នៅក្នុងសាសនាចក្រទើបមនុស្សម្នាក់ អាចទទួលអំណោយទានព្រះវិញ្ញាណបរិសុទ្ធ។ សិទ្ធិអំណាចនេះ ធ្វើឱ្យសាសនាចក្រខុសប្លែកពីសាសនាដទៃទៀត នៅក្នុងពិភពលោក។ តាមសេចក្ដីប្រកាសរបស់ព្រះអម្ចាស់ដោយផ្ទាល់សាសនាចក្រនេះ គឺជាសាសនាដែលពិត និងមានជីវិតតែមួយគត់នៅលើផែនដីទាំងមូល (សូមមើល គ និង ស 1៖30)។

### ការណែនាំមកពីព្រះវិញ្ញាណបរិសុទ្ធ

ចូរពន្យល់ទៅកាន់អ្នកទាំងឡាយណា ដែលអ្នកកំពុងបង្រៀនថា សាតាំង ជំទាស់នឹងព្រះ ហើយល្បួងមនុស្ស ឱ្យប្រព្រឹត្តអំពើបាប។ ដើម្បីរក្សាទុកអារម្មណ៍ល្អ ដែលពួកគេមាននៅក្នុងការប្រជុំអ្នកផ្សព្វផ្សាយសាសនា ពួកគេគួរតែ អានព្រះគម្ពីរមរមន អធិស្ឋាន ចូលរួមព្រះវិហារ និងគោរពបទបញ្ញត្តិទាំងឡាយ។ ចូរពន្យល់ថា ការមានបន្តនូវការណែនាំនៃព្រះវិញ្ញាណបរិសុទ្ធ គឺជាគុណប្រយោជន៍មួយនៃការធ្វើបុណ្យជ្រមុជទឹក និងទទួលពិធីបញ្ជាក់។

### ការសិក្សាព្រះគម្ពីរ

**និស្ស័យនៃព្រះវិញ្ញាណបរិសុទ្ធ**

| | | |
|---|---|---|
| សូមមើល គ និងស 130៖22-33 | កាឡាទី 5៖22–23 | Guide to the Scriptures, “Holy Ghost” |
| យ៉ូហាន 3៖1–8 | | |

**ពរជ័យ និងឥទ្ធិពលមកពីព្រះវិញ្ញាណបរិសុទ្ធ**

នីហ្វៃទី2 32៖1–5
នីហ្វៃទី2 33៖1–2
ម៉ូសេ 6៖61
យ៉ូហាន 14៖26
Guide to the Scriptures, "Holy Ghost"

**សារៈសំខាន់នៃអំណោយទានព្រះវិញ្ញាណបរិសុទ្ធ**

នីហ្វៃទី 2 31៖11–12,18, 21
នីហ្វៃទី3 18៖36–37
នីហ្វៃទី3 19៖13
នីហ្វៃទី3 27៖19–20
សូមមើល គ និងស 19៖31
សូមមើល គ និងស 33៖15
កិច្ចការពួកសាវក 19៖1–6

## ការស៊ូទ្រាំដល់ទីបំផុត

កាលណា យើងបានចូលទៅក្នុងផ្លូវត្រង់ និងចង្អៀត ដោយជំនឿរបស់យើង ទៅលើព្រះយេស៊ូវគ្រីស្ទ ការប្រែចិត្ត និងពិធីការ ទាំងឡាយនៃពិធីបុណ្យជ្រមុជទឹក និងពិធីការបញ្ជាក់ យើងត្រូវតែដាក់ការខិតខំប្រឹងប្រែងគ្រប់យ៉ាង ដើម្បីឱ្យស្ថិតនៅលើផ្លូវ ជាបន្តទៅទៀត។ យើងធ្វើដូច្នោះ ដោយការបន្តធ្វើការអនុវត្តសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ការប្រែចិត្ត ការធ្វើការតាំងចិត្ត និងធ្វើតាមព្រះវិញ្ញាណ។

កាលណាយើងត្រូវបានទទួលការអភ័យទោសចំពោះអំពើបាបរបស់យើង យើងគួរតែព្យាយាមជារៀងរាល់ថ្ងៃ ដើម្បីកុំឱ្យមានអំពើបាប ដើម្បីយើងអាចមានព្រះវិញ្ញាណបរិសុទ្ធជាមួយនឹងយើងជានិច្ច។ នៅក្នុងសេចក្តីសញ្ញា នៃពិធីបុណ្យជ្រមុជទឹក យើងសន្យានឹងព្រះវរបិតានៅស្ថានសួគ៌របស់យើងថា យើងនឹងគោរពព្រះបញ្ញត្តិរបស់ទ្រង់មួយជីវិត។ បើយើងធ្លាក់ចុះ យើង ត្រូវតែប្រែចិត្ត ដើម្បីរក្សាទុកពរជ័យ នៃសេចក្តីសញ្ញា។ យើងសន្យាដើម្បីធ្វើកិច្ចការល្អ បំរើអ្នកដទៃ និងធ្វើតាមគំរូរបស់ ព្រះអង្គសង្គ្រោះ។ នៅក្នុងបទគម្ពីរ ការធ្វើការតាំងចិត្ត ដ៏យូរអង្វែងនេះ គឺជារឿយៗត្រូវបានហៅថា "ការស៊ូទ្រាំដល់ទីបំផុត"។

ដោយការដើរតាមផ្លូវដំណឹងល្អ យើងអាចខិតទៅជិតនឹងព្រះ យកឈ្នះលើសេចក្តីល្បួង និងអំពើបាប ហើយរីករាយនឹងអំណោយទាន នៃព្រះវិញ្ញាណបរិសុទ្ធកាន់តែបរិបូណ៌ឡើង។ នៅពេលយើងមានការអត់ធ្មត់ ស្មោះត្រង់ និងប្រកាន់ភ្ជាប់ ដើរតាមផ្លូវនេះយ៉ាងខ្ជាប់ខ្ជួនអស់មួយជីវិត យើងនឹងមានគុណសម្បត្តិគ្រប់គ្រាន់សំរាប់ជីវិតអស់កល្បជានិច្ច។

ជំនឿទៅលើព្រះគ្រីស្ទ ការប្រែចិត្ត ការធ្វើ និងការរក្សាសេចក្តីសញ្ញាទាំងឡាយ និងជំរះឱ្យស្អាត ដោយព្រះវិញ្ញាណ ក្លាយទៅជាគំរូមួយនៃការរស់នៅ។ សកម្មភាពរបស់យើងនៅក្នុងជីវិតប្រចាំថ្ងៃ គឺត្រូវបានធ្វើឱ្យមានសណ្ឋាន និងគ្រប់គ្រង ដោយគោលការណ៍ទាំងនេះ។ សន្តិភាព និងសេចក្តីអំណរ មកដោយសារការដើរតាមផ្លូវនេះ ហើយយើងលូតលាស់បន្តិចម្តងៗ នៅក្នុងគុណសម្បត្តិដូចជាព្រះគ្រីស្ទ។ ដាយថាហេតុ នៅពេលយើងដើរតាមផ្លូវនេះ ហើយ"ត្រូវឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ . . . ហើយនឹងកាន់ខ្ជាប់ដរាបដល់ចុងបំផុត"។ យើងត្រូវបានសន្យាថា "អ្នករាល់គ្នានឹងមានជីវិតដ៏អស់កល្បជានិច្ច" (នីហ្វៃទី2 31៖20)។

### ការសិក្សាព្រះគម្ពីរ

**ការស៊ូទ្រាំដល់ទីបំផុត**

នីហ្វៃទី2 9៖24
នីហ្វៃទី2 31៖14–20
នីហ្វៃទី3 27៖16–17
ម៉ាថាយ 10៖22

**ពរជ័យសំរាប់អ្នកទាំងឡាយ ដែលស៊ូទ្រាំ**

នីហ្វៃទី1 13៖37
នីហ្វៃទី3 15៖9
សូមមើល គ និងស 14៖7

### ការអញ្ជើញឱ្យទទួលបុណ្យជ្រមុជទឹក

ការអញ្ជើញឱ្យទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់គួរតែច្បាស់លាស់ហើយចំពុះ "តើអ្នកព្រមធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ដោយទទួលបុណ្យជ្រមុជទឹក ដោយនរណាម្នាក់កាន់សិទ្ធិអំណាចបព្វជិតភាពរបស់ព្រះ ដែរឬទេ? យើងនឹងធ្វើពិធីការបំរើ នៃពិធីបុណ្យជ្រមុជទឹកនៅ [កាលបរិច្ឆេទ]។ តើអ្នកព្រមរៀបចំខ្លួនរបស់អ្នក ដើម្បីទទួលបុណ្យជ្រមុជទឹកទៅតាមកាលបរិច្ឆេទ នោះ ដែរឬទេ?

កំណត់ចំណាំ

កំណត់ចំណាំ

# គំនិតសំរាប់ការបង្រៀន

កណ្ឌនេះ មានគំនិតសំរាប់អ្នកដើម្បីប្រើ ក្នុងការរៀបចំ និងការបង្រៀនមេរៀននេះ។ អធិស្ឋាន ធ្វើតាមព្រះវិញ្ញាណ នៅពេលដែលអ្នកសំរេចចិត្តពីរបៀបប្រើគំនិតទាំងនេះ។ បន្ថែមគំនិតដែលអ្នកជ្រើសរើស ចូលទៅក្នុងគំរោងមេរៀនរបស់អ្នក។ សូមចងចាំថា គំនិតទាំងនេះគឺជាការស្នើសុំ—មិនមែនជាការតម្រូវឱ្យមានទេ—ដើម្បីជួយអ្នកជួប សេចក្ដីត្រូវការរបស់អ្នកទាំងឡាយណាដែលអ្នកបង្រៀននោះទេ។

## ផែនការមេរៀនខ្លីៗ (3–5 នាទី)

ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាផ្លូវតែមួយប៉ុណ្ណោះដែលនាំទៅកាន់ជីវិតអស់កល្បជានិច្ច។ គោលការណ៍ និងពិធីការទីមួយនៃ ដំណឹងល្អរបស់ទ្រង់គឺ សេចក្ដីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ប្រែចិត្ត ពិធីបុណ្យជ្រមុជទឹក សំរាប់ផ្ដាច់បាប និងអំណោយ ទាននៃព្រះវិញ្ញាណបរិសុទ្ធ។ បន្ទាប់មកយើងត្រូវតែស៊ូទ្រាំដល់ទីបញ្ចប់។ ដោយការអនុវត្ត គោលការណ៍ទាំងនេះ អស់មួយជីវិត របស់យើង យើងធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ រៀនដើម្បី រស់នៅតាមព្រះបញ្ញត្តិរបស់ទ្រង់ ហើយអភិវឌ្ឍន៍ឱ្យដូចជាព្រះគ្រីស្ទ។ យើងអាចទទួលការអភ័យទោសចំពោះ អំពើបាបរបស់យើង ហើយយើងនឹងអាចត្រឡប់ទៅរស់នៅក្នុងទីវត្តមានរបស់ព្រះវរបិតា របស់យើងនៅស្ថានសួគ៌។

- តាមរយៈព្រះគ្រីស្ទយើងអាចជ្រះស្អាតពីបាប
- សេចក្ដីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ
- ការប្រែចិត្ត
- ពិធីបុណ្យជ្រមុជទឹក សេចក្ដីសញ្ញាដំបូងរបស់យើង
- អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ
- ការស៊ូទ្រាំដល់ទីបញ្ចប់

### ការតាំងចិត្ត

- តើអ្នកព្រមបន្តអភិវឌ្ឍន៍សេចក្ដីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ដោយការបន្តរៀនអំពីដំណឹងល្អរបស់ទ្រង់ ដែរឬទេ?
- តើអ្នកព្រមប្រែចិត្ត និងអធិស្ឋានសុំការអភ័យបាបដែរឬទេ?
- តើអ្នកព្រមទទួលបុណ្យជ្រមុជទឹក ដើម្បីក្លាយជាសមាជិក នៃសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយនៅ (កាលបរិច្ឆេទ) ដែរឬទេ? តើអ្នកព្រមទទួលការបញ្ជាក់ និងទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដែរឬទេ?
- តើអ្នកព្រមទៅព្រះវិហារជាមួយយើង នៅថ្ងៃអាទិត្យនេះ ដែរឬទេ?
- តើយើងអាចណាត់ជួប សំរាប់ពេលក្រោយបានទេ?
- បទបញ្ញត្តិចេញពីមេរៀនទី 4 ដែលអ្នកជ្រើសរើសដើម្បីបញ្ចូល។

## ផែនការមេរៀនមធ្យម (10–15 នាទី)

សារដំណឹងរបស់យើង គឺជាសារដំណឹងមួយនៃ សេចក្ដីជំនឿ និងសេចក្ដីសង្ឃឹម។ យើងស្រលាញ់ និងថ្វាយបង្គំព្រះយេស៊ូវគ្រីស្ទ។ ទ្រង់ចំណុចកណ្ដាលនៃផែនការរបស់ព្រះសំរាប់សុភមង្គលរបស់យើង។ ការបូជាឱ្យធួន របស់ព្រះគ្រីស្ទធ្វើឱ្យយើងអាចមានជីវិត អស់កល្បជានិច្ច នៅក្នុងវត្តមានរបស់ព្រះ។ ពេលដែលយើងរស់នៅតាមដំណឹងល្អរបស់ទ្រង់ ទ្រង់នឹងមានសេចក្ដីមេត្តាករុណា អភ័យទោសចំពោះអំពើបាបរបស់យើង។ ទ្រង់នឹងព្យាបាលយើង ហើយប្ដូរទោសកំហុស និងភាពអាម៉ាស់ ជាមួយនឹងសេចក្ដី សុខសាន្ត និងសុភមង្គលនៅក្នុងជីវិតនេះ។

ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ គឺសាមញ្ញ។ ដំណឹងល្អនេះចាប់ផ្ដើមជាមួយសេចក្ដីជំនឿនៅក្នុងព្រះគ្រីស្ទ។ យើងជឿទ្រង់ ទុកចិត្តលើទ្រង់ ហើយពឹងទៅលើទ្រង់។ សេចក្ដីជំនឿដូច្នេះ នាំទៅកាន់ការប្រែចិត្ត—ឈប់ធ្វើអ្វីដែលខុស ហើយបន្តធ្វើអ្វីដែល ត្រឹមត្រូវ។ សេចក្ដីជំនឿនៅក្នុងទ្រង់ ក៏ធ្វើឱ្យយើងចង់បង្ហាញសេចក្ដីស្រលាញ់របស់យើង ដោយការកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ ដោយរាប់ទាំងពិធីបុណ្យជ្រមុជទឹក។ បន្ទាប់ពីពិធីបុណ្យជ្រមុជទឹក ទ្រង់សន្យាថា

កំណត់ចំណាំ

ផ្ដល់ឱ្យយើងនូវអំណោយទាននៃ ព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងដឹកនាំយើង លួងលោមយើង និងជួយយើងដឹងពីសេចក្ដីពិត។ យើងអាចដឹងនៅក្នុង បេះដូង និងគំនិតរបស់យើង នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយយើង។ យើងនឹងមានអារម្មណ៍នៃសេចក្ដីសុខសាន្ត សេចក្ដីស្រលាញ់ និងសេចក្ដីអំណរ។ យើងនឹង ចង់បំរើដល់អ្នកដទៃ។ យើងនឹងព្យាយាមនៅក្នុងជីវិតរបស់យើង ដើម្បីផ្គាប់ចិត្ត ព្រះអម្ចាស់។

ព្រះយេស៊ូវគ្រីស្ទបានស្ដារដំណឹងល្អរបស់ទ្រង់ តាមរយៈព្យាការីថ្ងៃចុងក្រោយ។ យើងរៀនអំពីដំណឹងល្អនៅ ក្នុងព្រះគម្ពីរមរមន ដែលអ្នកអាចអាន ពិចារណា និងអធិស្ឋាន។ ព្រះនឹងប្រាប់អ្នកដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធថា វាគឺជាការពិត។ នៅពេល ដែលអ្នកដឹងថា វាគឺជាការពិត អ្នកនឹងចង់ប្រែចិត្ត និងទទួលបុណ្យជ្រមុជទឹក ដើម្បីអ្នកអាច ទទួលការផ្ដាច់បាបរបស់អ្នក ហើយ ទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។

## ការតាំងចិត្ត

- តើអ្នកព្រមបន្តអភិវឌ្ឍន៍សេចក្ដីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ដោយការបន្តរៀនអំពីដំណឹងល្អរបស់ទ្រង់ ដែរឬទេ?
- តើអ្នកព្រមប្រែចិត្ត និងអធិស្ឋានសុំការអភ័យបាបដែរឬទេ?
- តើអ្នកព្រមទទួលបុណ្យជ្រមុជទឹក ដើម្បីក្លាយជាសមាជិក នៃសាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយនៅ (កាលបរិច្ឆេទ) ដែរឬទេ? តើអ្នកព្រមទទួលការបញ្ជាក់ និងទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដែរឬទេ?
- តើអ្នកព្រមទៅព្រះវិហារជាមួយយើង នៅថ្ងៃអាទិត្យនេះ ដែរឬទេ?
- តើយើងអាចណាត់ជួប សំរាប់ពេលក្រោយបានទេ?
- ព្រះបញ្ញត្តិចេញពីមេរៀនទី 4 ដែលអ្នកជ្រើសរើសដើម្បីបញ្ចូល។

## ផែនការមេរៀនទាំងមូល (30–45 នាទី)

- តាមរយៈព្រះគ្រីស្ទយើងអាចជ្រះស្អាតពីអំពើបាប
  - ព្រះបានបញ្ជូន ព្រះរាជបុត្រាជាទីស្រលាញ់របស់ទ្រង់ ដែលជាព្រះយេស៊ូវគ្រីស្ទ ទៅកាន់ពិភពលោក (សូមមើល យ៉ូហាន 3៖16–17)។
  - មានតែតាមរយៈព្រះគុណ និងសេចក្ដីមេត្តាករុណារបស់ព្រះគ្រីស្ទ តែប៉ុណ្ណោះទើបយើងអាច ជ្រះស្អាតពីអំពើបាប (សូមមើល នីហ្វៃទី 2 2៖6–8)។
  - យើងទទួលខុសត្រូវដើម្បីទទួលព្រះគ្រីស្ទ ប្រែចិត្ត និងគោរពប្រតិបត្តិ។
- សេចក្ដីជំនឿនៅក្នុងព្រះគ្រីស្ទ
  - យើងជឿទៅលើព្រះគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃពិភពលោក។
  - យើងចង់ទទួលស្គាល់ទ្រង់ ហើយធ្វើតាមការបង្រៀនរបស់ទ្រង់។
  - យើងទទួលពរជ័យពេលដែលយើងគោរពប្រតិបត្តិ (សូមមើល គ និង ស 130៖20–21)។
- ការប្រែចិត្ត
  - សេចក្ដីជំនឿនៅក្នុងព្រះគ្រីស្ទ នាំទៅរកការប្រែចិត្ត (សូមមើល អាលម៉ា 34)។
  - យើងមានអារម្មណ៍ទុក្ខព្រួយចំពោះព្រះ (សូមមើល កូរិនថូសទី 2 7៖9–10)។
  - យើងឈប់ធ្វើអ្វីដែលខុស ហើយបន្តធ្វើអ្វីដែលត្រឹមត្រូវ។
  - យើងសារភាពចំពោះអំពើបាបរបស់យើង ហើយសារភាពចំពោះអំពើបាបដែលធ្ងន់ធ្ងរ ចំពោះអ្នកដឹកនាំសាសនាចក្រ ដែលជាអ្នកដែលអាចជួយយើងឱ្យប្រែចិត្ត (សូមមើល គ និង ស 58៖43)។

មេរៀនទី 3៖
ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ

កំណត់ចំណាំ

- យើងទទួលការអភ័យទោសកំហុស និងសេចក្តីទុក្ខព្រួយ ដែលជំនួសដោយសេចក្តីសុខសាន្ត (សូមមើល អាលម៉ា 36៖17–21)។

- ពិធីបុណ្យជ្រមុជទឹក សេចក្តីសញ្ញាដំបូងរបស់យើង
  - ពិធីការគឺជា ពិធីពិសិដ្ឋ ដែលយើងធ្វើចុះសេចក្តីសញ្ញាជាមួយព្រះ។
  - សេចក្តីសញ្ញាគឺជា ការយល់ព្រមយ៉ាងម៉ឺងម៉ាត់ រវាងព្រះនិងកូនចៅរបស់ទ្រង់។
  - ការរក្សាសេចក្តីសញ្ញានាំមកនូវពរជ័យ។
  - យើងទទួលបុណ្យជ្រមុជទឹក ដោយជ្រមុជទឹក សំរាប់ការផ្តាច់បាប (សូមមើល មាត្រានៃសេចក្តី ជំនឿ 1៖4)។
  - ពេលដែលយើងទទួលបុណ្យជ្រមុជទឹក យើងចាប់ផ្តើមជីវិតថ្មី នៃការតាំងចិត្តចំពោះព្រះគ្រីស្ទ (សូមមើល រ៉ូម 6៖3–8)។
  - ពិធីបុណ្យជ្រមុជទឹកត្រូវតែ ធ្វើឡើងដោយនរណាម្នាក់ដែលមានសិទ្ធិអំណាចបព្វជិតភាព។
  - យើងរំលឹកសេចក្តីសញ្ញារបស់យើង ដោយការទទួលទាននំប៉័ង និងទឹកជារៀងរាល់សប្តាហ៍ (សូមមើល គ និង ស 20៖77, 79)។

- អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ
  - ពិធីបុណ្យជ្រមុជទឹកដោយទឹក គឺត្រូវធ្វើបន្ទាប់ពី ពិធីបុណ្យជ្រមុជទឹក ដោយព្រះវិញ្ញាណ គឺមិនផ្តាច់ពីគ្នាបានទេ។
  - អ្នកកាន់បព្វជិតភាព ប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដោយការដាក់ដៃ។
  - ព្រះវិញ្ញាណបរិសុទ្ធបង្រៀនយើង លាងជំរះយើង លួងលោមយើង ហើយថ្លែងពីសេចក្តីពិត ព្រមានយើង ហើយណែនាំយើង (សូមមើល នីហ្វៃ 2 32៖1–5 ម៉ូសាយ 5៖1–6 ម៉ូរ៉ូណៃ 10៖5 គ និង ស 36៖2)។

- ការស៊ូទ្រាំដល់ទីបំផុត
  - យើងត្រូវតែបន្តនៅលើផ្លូវ ទោះជាយើងបានទទួលបុណ្យជ្រមុជទឹក និងទទួលពិធីបញ្ជាក់ រួចហើយ។
  - យើងធ្វើឱ្យអស់ពីសមត្ថភាពរបស់យើង ដើម្បីនៅឆ្ងាយពីអំពើបាប ដើម្បីយើងអាចរីករាយជាមួយ អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។
  - ដោយការធ្វើតាមយ៉ាងស្មោះត្រង់ចំពោះផ្លូវនៃសេចក្តីជំនឿ ការប្រែចិត្ត ការធ្វើ និងរក្សាសេចក្តីសញ្ញា និងការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ យើងអាចមានភាពសក្តិសម សំរាប់ជីវិតអស់កល្បជានិច្ច (សូមមើល នីហ្វៃទី 2 31៖14–20)។
  - យើងត្រូវតែបន្តប្រែចិត្ត នៅក្នុងជីវិតរបស់យើង (សូមមើល គ និង ស 19៖15–20)។

## ការតាំងចិត្ត

- តើអ្នកព្រមបន្តដើម្បីអភិវឌ្ឍន៍សេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ដោយការបន្តរៀនអំពីដំណឹងល្អរបស់ទ្រង់ ដែរឬទេ?
- តើអ្នកព្រមប្រែចិត្ត និងអធិស្ឋានសុំការអភ័យបាបដែរឬទេ?
- តើអ្នកព្រមទទួលបុណ្យជ្រមុជទឹក ដើម្បីក្លាយជាសមាជិក នៃសាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ នៅ (កាលបរិច្ឆេទ) ដែរឬទេ? តើអ្នកព្រមទទួលការបញ្ជាក់ និងទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដែរឬទេ?
- តើអ្នកព្រមទៅព្រះវិហារជាមួយយើង នៅថ្ងៃអាទិត្យនេះ ដែរឬទេ?
- តើយើងអាចណាត់ជួបសំរាប់ពេលក្រោយបានទេ?
- បទបញ្ញត្តិចេញពីមេរៀនទី 4 ដែលអ្នកជ្រើសរើសដើម្បីបញ្ចូល

កំណត់ចំណាំ

## សំនួរដើម្បីសួរបន្ទាប់ពីអ្នកបង្រៀន

- តើអ្នកមានសំនួរពីអ្វីដែលយើងបានបង្រៀន ដែរឬទេ?
- តើការប្រែចិត្ត មានអត្ថន័យយ៉ាងដូចម្ដេច?
- ហេតុអ្វីបានជាអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ គឺជាផ្នែកចាំបាច់ខ្វះមិនបាន សំរាប់នៃដំណឹងល្អ?
- ហេតុអ្វី វាសំខាន់សំរាប់អ្នក ដើម្បីទទួលបុណ្យជ្រមុជទឹក និងទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ?
- តើមានមានបញ្ហាអ្វីមួយ អំពីការប្រជុំនៅព្រះវិហារ ដែលអ្នកមិនទាន់បានយល់ ដែរឬទេ?
- តើអ្នកបានរីករាយទេ អំពីការប្រជុំនៅព្រះវិហាររបស់យើង?

## និយមន័យសំខាន់ៗ

- **ពិធីបញ្ជាក់៖** ការដាក់ដៃដោយអ្នកកាន់ បព្វជិតភាពម៉ិលគីស្សាដែក ដើម្បីក្លាយជាសមាជិក នៃសាសនាចក្រ និងដើម្បីប្រគល់ឱ្យអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។
- **សេចក្ដីសញ្ញា៖** ជាការព្រមព្រៀងគ្នារវាងព្រះ និងកូនចៅរបស់ទ្រង់។ យើងម្នាក់ៗ មិនប្រព្រឹត្តដូចគ្នានៅក្នុងការព្រមព្រៀងទេ។ ព្រះប្រទានលក្ខខ័ណ្ឌសំរាប់សេចក្ដីសញ្ញា ហើយយើងព្រមធ្វើអ្វីដែលទ្រង់បញ្ជារយើងឱ្យធ្វើ។ បន្ទាប់មកព្រះបានសន្យាយើង នូវពរជ័យខ្លះៗ សំរាប់ការគោរពប្រតិបត្តិរបស់យើង។ យើងទទួលពិធីការផ្សេងៗ ដោយសេចក្ដីសញ្ញា។ ពេលដែលយើងចុះសេចក្ដីសញ្ញា យើងសន្យាដើម្បីធ្វើតាម។ ឧទាហរណ៍ សមាជិកនៃសាសនាចក្រ ចុះសេចក្ដីសញ្ញាជាមួយព្រះអម្ចាស់នៅពិធីបុណ្យជ្រមុជទឹក និងរំលឹកសេចក្ដីសញ្ញានោះ ដោយការទទួលទាន នំប៉័ងនិងទឹក។ យើងធ្វើសេចក្ដីសញ្ញាផ្សេងទៀតនៅក្នុងព្រះវិហារបរិសុទ្ធ។ ប្រជារាស្ត្ររបស់ព្រះអម្ចាស់ គឺជារាស្ត្រ នៃសេចក្ដីសញ្ញា។ យើងត្រូវបានប្រទានពរជ័យយ៉ាងមហិមា នៅពេលដែលយើងរក្សាសេចក្ដីសញ្ញារបស់យើងជាមួយ ព្រះអម្ចាស់។
- **ការស៊ូទ្រាំដល់ទីបំផុត៖** នៅពិតចំពោះព្រះបញ្ញត្តិរបស់ព្រះ ទោះបីជាមានការល្បួង ការជំទាស់ និងការខ្វះខាតក្នុងជីវិត។
- **ជីវិតអស់កល្បជានិច្ច៖** ការរស់នៅជាមួយគ្នាជារៀងរហូតជាក្រុមគ្រួសារ នៅក្នុងទីវត្តមានរបស់ព្រះ (សូមមើល គ និង ស 132៖19–20)។ ជីវិតអស់កល្បជានិច្ច គឺជាអំណោយដ៏ធំជាងគេរបស់ព្រះចំពោះមនុស្ស។
- **ដំណឹងល្អ៖** ផែនការនៃសេចក្ដីសង្គ្រោះរបស់ព្រះ បានធ្វើឱ្យកើតមានបាន តាមរយៈដង្វាយធួន របស់ព្រះយេស៊ូវគ្រីស្ទ។ ដំណឹងល្អបូករួមទាំង សេចក្ដីពិតដ៏នៅអស់កល្បជានិច្ច ឬក្រិត្យវិន័យ សេចក្ដីសញ្ញា និងពិធីការដែលចាំបាច់ សំរាប់មនុស្សលោកដើម្បីត្រឡប់ទៅកាន់ទីវត្តមាននៃព្រះ។
- **ព្រះគុណ៖** អំណាចដែលអាចធ្វើទៅបានមកពីព្រះយេស៊ូវគ្រីស្ទ ដែលអនុញ្ញាតឱ្យយើងទទួលពរជ័យនៅក្នុងជីវិតនេះ និងដើម្បីទទួលជីវិតនៅអស់កល្បជានិច្ច និងការលើកដំកើង បន្ទាប់ពីយើងបានអនុវត្តសេចក្ដីជំនឿ ប្រែចិត្ត និងធ្វើឱ្យអស់ពីការខិតខំប្រឹងប្រែងរបស់យើង ដើម្បីកាន់តាមព្រះបញ្ញត្តិ។ ជំនួយ និងកំលាំងដ៏ទេវភាព ត្រូវបានផ្ដល់ឱ្យតាមរយៈ ព្រះគុណ និងសេចក្ដីស្រលាញ់នៃព្រះយេស៊ូវគ្រីស្ទ។ យើងទាំងអស់គ្នាត្រូវការព្រះគុណដ៏ទេវភាព ព្រោះមកពីការធ្លាក់ របស់អ័ដាម និងមកពីភាពទន់ខ្សោយរបស់យើង។
- **សេចក្ដីមេត្តាករុណា៖** ព្រះវិញ្ញាណនៃសេចក្ដីអាណិតអាសូរ ទន់ភ្លន់ និងអភ័យទោស។ សេចក្ដីមេត្តាករុណាគឺជា បុគ្គលិកលក្ខណៈមួយរបស់ព្រះ។ ព្រះយេស៊ូវគ្រីស្ទ ប្រទានសេចក្ដីមេត្តាករុណាចំពោះយើង តាមរយៈការបូជាដ៏ធួន នៅក្នុងលក្ខខ័ណ្ឌនៃការប្រែចិត្ត។
- **ការផ្ដុំឡើងវិញ៖** ការត្រឡប់ពីអ្វីមួយដែលបានត្រូវយកចេញឆ្ងាយ ឬបាត់បង់។ ឧទាហរណ៍ ការស្ដារឡើងវិញនៃ ដំណឹងល្អ គឺត្រូវបានហៅថា ការផ្ដុំឡើងវិញ (សូមមើល កិច្ចការពួកសាវក 3៖19-21)។ ពាក្យ *ស្ដារឡើងវិញ* ក៏សំដៅទៅលើការរស់ឡើងវិញផងដែរ (សូមមើល អាលម៉ា 41៖10-15)។

## អត្ថន័យនៃពាក្យផ្សេងៗទៀត ដែលអាចត្រូវការនៅពេលក្រោយ សំរាប់អ្នកទាំងឡាយណាដែលអ្នកបង្រៀន

- ជ្រះស្អាតពីអំពើបាប
- ការសារភាព
- ការអភ័យទោស
- ការអធិស្ឋាន
- ពិធីប្រសិទ្ធពរនំប៉័ង និងទឹក
- ផ្លូវតូចនិងចង្អៀត
- ការល្បួង

កំណត់ចំណាំ

# បទបញ្ញត្តិ

## *ការរៀបចំ សំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់*



### ការបង្រៀនមេរៀននេះ

មានវិធីជាច្រើន ដើម្បីបង្រៀនអំពីបទបញ្ញត្តិ ដែលអាចរកបាននៅក្នុងមេរៀននេះ។ ឧទាហរណ៍ អ្នកអាចបង្រៀន បទបញ្ញត្តិពីរបីមកពីមេរៀននេះ ដែលជាផ្នែកនៃមេរៀនទាំងបីមុន ឬអ្នកអាចបង្រៀនបទបញ្ញត្តិមួយចំនួន ធ្វើជាមេរៀនតែមួយ។ អ្វី ដែលអ្នកធ្វើ គួរតែកំណត់តាមសេចក្ដីត្រូវការរបស់សាសនាគន់ការី និងការដឹកនាំមកពីព្រះវិញ្ញាណ។

## រៀបចំ ដើម្បីបង្រៀន

គោលបំណងរបស់អ្នក នៅក្នុងការបង្រៀនបទបញ្ញត្តិ គឺដើម្បីជួយមនុស្សឱ្យរស់នៅតាមដំណឹងល្អ ដោយការអនុវត្តសេចក្ដីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ និងការប្រែចិត្ត នៅពេលពួកគេរៀបចំ សំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។ ដោយការគោរពបទបញ្ញត្តិ មនុស្សនឹងរីកចំរើននៅក្នុងទីបន្ទាល់នៃដំណឹងល្អរបស់ពួកគេ នេះបង្ហាញថាពួកគេមាន“ចិត្តសង្រេង និងវិញ្ញាណទន់ទាប” ហើយចាប់ផ្ដើមប្រែចិត្តពីអំពើបាបរបស់ពួកគេទាំងអស់ (សូមមើលម៉ូរ៉ូណៃ 6៖1–4, គ និងស 20៖37)។

មេរៀននេះ គឺត្រូវបានរៀបចំឡើងផ្សេងគ្នាពីមេរៀនបីមុន។ មេរៀនទាំងបីមុន បានពន្យល់អំពីគ្រឹះនៃគោលលទ្ធិ សំរាប់ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។ មេរៀននេះ បានពន្យល់អំពីបទបញ្ញត្តិជាក់លាក់ ដែលព្រះបានប្រទានឱ្យ ដើម្បីជួយយើងឱ្យអនុវត្តន៍ គោលការណ៍ដំណឹងល្អនៅក្នុងជីវិតរបស់យើង។

មានវិធីជាច្រើន ដើម្បីបង្រៀនមេរៀននេះ។ វិធីដែលអ្នកប្រើប្រាស់ គួរតែកំណត់យកមកប្រើ គួរតែស្របទៅតាម សេចក្ដីត្រូវការរបស់សាសនាគន់ការី និងការដឹកនាំមកពីព្រះវិញ្ញាណ។ គិត និងអធិស្ឋានជានិច្ចអំពីរបៀប ដើម្បីជួយដល់សាសនាគន់ការី ឱ្យរស់នៅតាមដំណឹងល្អ។ គំនិតទាំងឡាយរួមមាន៖

- ការបង្រៀនបទបញ្ញត្តិមួយ ឬក៏ច្រើន ដែលជាផ្នែក នៃមេរៀនទាំងបីមុន។ នៅពេលធ្វើដូច្នោះហើយ ចូរពិចារណាអំពីគោលការណ៍ ដែលបានបង្រៀននៅក្នុងអាលម៉ា 12៖32៖ “ព្រះទ្រង់ប្រទានបញ្ញត្តិទាំងឡាយដល់គេ *បន្ទាប់ពី* បានប្រាប់ដល់គេនូវផែនការនៃសេចក្ដីប្រោសលោះ” (អក្សរទ្រេតត្រូវបានបន្ថែម)។ បទបញ្ញត្តិទាំងឡាយជាក់លាក់ ដូចជា ការអធិស្ឋាន និងការសិក្សាព្រះគម្ពីរ អាចត្រូវបានបង្រៀនល្អបំផុត ធ្វើជាផ្នែក នៃមេរៀនទាំងបីមុន។ បទបញ្ញត្តិដទៃទៀត អាចត្រូវបានបង្រៀនល្អបំផុត បន្ទាប់ពីអ្នកបានដាក់គោលលទ្ធិគ្រឹះ នៃដំណឹងល្អ ដែលអាចរកបាននៅក្នុងមេរៀនទាំងបីមុន។
- ការបង្រៀនបទបញ្ញត្តិពីរ ឬបី ធ្វើជាមេរៀនតែមួយ។
- ការបង្រៀនបទបញ្ញត្តិតែមួយ ធ្វើជាមេរៀនមួយ។

កំណត់ចំណាំ

- ការបង្រៀនបទបញ្ញត្តិ នៅក្នុងបរិបទ នៃដំណឹងល្អ។ ចូរធ្វើការរំលឹកដោយសង្ខេប អំពីមេរៀននៃដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ មុនពេលបង្រៀនបទបញ្ញត្តិមួយ ឬច្រើន។ នៅពេលអ្នកធ្វើដូច្នោះ អ្នកអាចជួយដល់សាសនាគន់ការី ឱ្យឃើញថា តើបទបញ្ញត្តិស៊ីគ្នានឹងរូបភាពធំ នៃការអនុវត្តន៍សេចក្តីជំនឿ នៅក្នុងព្រះអង្គសង្គ្រោះ និងការប្រែចិត្តនៅក្នុង ការរៀបចំសំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់យ៉ាងដូចម្តេចខ្លះ។ ជីវិតរស់នៅរបស់ពួកគេអាចទទួលបានពរជ័យ នៅពេលពួកគេមើលឃើញថា ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ជាគំរូមួយសំរាប់ការរស់នៅ។

អ្នកអាចមានលទ្ធភាព ដើម្បីបង្រៀនសាសនាគន់ការីខ្លះៗ នៅពេលជួបគ្នាបានពីរបីដង អ្នកដទៃទៀត ប្រហែលជាត្រូវឱ្យមានការជួបគ្នាច្រើន។ អ្នកមានភាពបត់បែន ដើម្បីបង្រៀនមេរៀននៅក្នុងវិធីណាក៏ដោយ ដែលជាជំនួយធំបំផុតដល់អ្នករៀន ឱ្យរៀបចំឱ្យបានស្រេច សំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់របស់ពួកគេ។ គោលបំណងរបស់អ្នកមិនមែនត្រឹមតែបង្រៀន តែមេរៀនប៉ុណ្ណោះទេ គឺដើម្បីជួយអ្នកដទៃទៀតឱ្យមកឯព្រះគ្រីស្ទ តាមរយៈសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ការប្រែចិត្ត ពិធីបុណ្យជ្រមុជទឹក ការទទួលអំណោយទានព្រះវិញ្ញាណបរិសុទ្ធ និងការកាន់ខ្ជាប់ដល់ចុងបំផុត។

ដោយកម្រណាស់ ដែលមេរៀនមួយបង្រៀនទៅហួសពី 45 នាទី។ អ្នកនឹងរកឃើញថា ពេលវេលា ប្រហែលជាអនុញ្ញាតឱ្យជួបបង្រៀនក្នុងរយៈពេលមួយដ៏ខ្លីតែប៉ុណ្ណោះ។ នៅក្នុងករណីនេះ ជារឿយៗ អ្នកត្រូវការជួបបង្រៀនក្នុងរយៈពេលខ្លីក្នុងការបង្រៀនផ្នែកតូចៗនៃមេរៀន។

មានវិធីជាច្រើន ដែលអ្នកអាចយកមកប្រើប្រាស់ ដើម្បីបង្រៀនមេរៀននេះ។ បទបញ្ញត្តិណា ដែលអ្នកបង្រៀន នៅពេលណា ដែលអ្នកបង្រៀនបទបញ្ញត្តិ ហើយរយៈពេលប៉ុន្មាន ដែលអ្នកគួរផ្តល់មេរៀន ដែលជាការកំណត់ល្អបំផុត តាមសេចក្តីត្រូវការរបស់សាសនាគន់ការី និងការដឹកនាំនៃព្រះវិញ្ញាណ។

## រៀនអំពីបទបញ្ញត្តិ និងការតាំងចិត្ត

នៅពេលអ្នកសិក្សាមេរៀននេះ ចូរធ្វើតាមគំរូនៅខាងក្រោមនេះ៖

- សិក្សាវគ្គ ដែលពិពណ៌នាអំពីបទបញ្ញត្តិ ហើយសរសេរផែនការមេរៀនសាមញ្ញមួយ ជាមួយនឹងចំណុចសំខាន់ពីរ បីទៅប្រាំចំណុច។
- បង្រៀនតាមកំណែពីរ ឬបីនាទី ទៅដល់ដៃគូរបស់អ្នក។ ចូរអនុវត្តន៍របៀប ដែលអ្នកនឹងពង្រីកការអញ្ជើញឱ្យធ្វើការតាំងចិត្តនីមួយៗ និងរបៀប ដែលអ្នកនឹងដោះស្រាយកង្វល់។
- ពិភាក្សាអំពីមធ្យោបាយ ដើម្បីតាមដានការតាំងចិត្ត ឱ្យចប់ចុងចប់ដើម ដែលសាសនាគន់ការីបានទទួល។

## ការគោរពប្រតិបត្តិ

ព្រះប្រទានដល់យើង នូវបទបញ្ញត្តិសំរាប់ជាប្រយោជន៍របស់យើង។ បទបញ្ញត្តិ គឺជាការណែនាំ មកពីព្រះវរបិតាជាទីស្រឡាញ់នៅស្ថានសួគ៌ ដើម្បីជួយយើងឱ្យមានជីវិតសប្បាយរីករាយ។ ទ្រង់ប្រទានឱ្យយើង នូវសិទ្ធិសេរីភាព ឬសមត្ថភាព និងឱកាស ដើម្បីជ្រើសរើស រវាងល្អ និងអាក្រក់ផងដែរ។ នៅពេលយើងប្រតិបត្តិតាមព្រះ យើងធ្វើតាមឥទ្ធិពលនៃព្រះវិញ្ញាណ ហើយជ្រើសរើស ដើម្បីប្រតិបត្តិតាម ព្រះទ័យរបស់ទ្រង់។ ការគោរពប្រតិបត្តិ ចំពោះបទបញ្ញត្តិ នាំមកឱ្យយើងនូវសន្តិភាព នៅក្នុងជីវិតនេះ និងជីវិតអស់កល្បជានិច្ច នៅក្នុងពិភពលោកខាងមុខ។ ការគោរពប្រតិបត្តិ បង្ហាញពីសេចក្តីស្រលាញ់របស់យើងចំពោះព្រះ។ ការមិនគោរពប្រតិបត្តិ នាំមកឱ្យយើងនូវទុក្ខព្រួយ។

ព្រះវរបិតាសួគ៌ ដឹងនូវភាពទន់ខ្សោយរបស់យើង ហើយអត់ធ្មត់ជាមួយនឹងយើង។ ទ្រង់ប្រទានពរដល់យើង នៅពេល ដែលយើងព្យាយាមគោរពបទបញ្ញត្តិរបស់ទ្រង់។ ទ្រង់សង្ឃឹមថាយើងប្រតិបត្តិតាមទ្រង់ ដើម្បីទ្រង់អាចប្រទានពរដល់យើង។

### ការសិក្សាព្រះគម្ពីរ

**សេរីភាព**

| | | |
|---|---|---|
| នីហ្វៃទី2 2៖26–29 | គ និងស 58៖26–29 | Guide to the Scriptures, “Agency” |
| អាលម៉ា 12៖31 | គ និងស 82៖8–10 | |

**ការគោរពប្រតិបត្តិ**

| | | |
|---|---|---|
| គ និងស 130៖ 20–21 | យ៉ូហាន 14៖15, 21 | សាស្តា 12៖13 |

មេរៀនទី 4៖
បទបញ្ញត្តិ

កំណត់ចំណាំ

**ការតាំងចិត្ត**

- តើអ្នកព្រមប្រតិបត្តិតាមច្បាប់នៃព្រះដែរឬទេ?

## អធិស្ឋានជាញឹកញាប់

ព្រះបញ្ជាឱ្យយើងអធិស្ឋានទៅកាន់ទ្រង់។ អ្នកអាចអធិស្ឋាននៅគ្រប់ពេល និងនៅគ្រប់កន្លែង។ ព្រះអម្ចាស់ បានបង្រៀនឱ្យយើងលុតជង្គង់ ហើយអធិស្ឋាននៅពេលព្រឹក និងពេលល្ងាច ជាបុគ្គល និងជាមួយគ្រួសាររបស់យើង។ ព្រះវរបិតាសួគ៌របស់យើងស្តាប់ និងឆ្លើយការអធិស្ឋានរបស់យើង។ តាមរយៈការអធិស្ឋានជាប្រចាំ យើងទទួលបានការណែនាំ និងពរជ័យនៃទេវភាព។ យើងគួរតែអធិស្ឋានជានិច្ចដោយអស់ពីចិត្ត។ យើងគួរតែអធិស្ឋានដោយ“ចិត្តស្មោះត្រង់”ផងដែរ នោះមានន័យថា យើងបានតាំងចិត្ត ដើម្បីធ្វើទង្វើរនៅលើចម្លើយ ដែលយើងបានទទួល។

យើងអធិស្ឋានដោយជំនឿ ចំពោះព្រះវរបិតានៅស្ថានសួគ៌របស់យើង នៅក្នុងនាមនៃព្រះយេស៊ូវគ្រីស្ទ (សូមមើល ម៉ូសេ 5៖8)។ ពីព្រោះទ្រង់ គឺជាព្រះវរបិតារបស់យើង ហើយយើងគឺជាកូនចៅរបស់ទ្រង់ ទ្រង់នឹងឆ្លើយការអធិស្ឋានរបស់យើង។ យើងចាប់ផ្តើមការអធិស្ឋាន ដោយនិយាយដល់ព្រះវរបិតានៅស្ថានសួគ៌របស់យើង។ យើងបញ្ចប់ការអធិស្ឋានរបស់យើង ដោយនិយាយ ព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន។”

នៅក្នុងការអធិស្ឋាន យើងនិយាយដោយបើកចំហរ និងដោយស្មោះត្រង់ ជាមួយនឹងព្រះវរបិតានៅស្ថានសួគ៌ ជាទីស្រឡាញ់ របស់យើង។ យើង បង្ហាញការដឹងគុណ និងថ្លែងអំណរគុណសំរាប់ពរជ័យរបស់យើង។ យើងអាចទទួលស្គាល់សេចក្តីស្រឡាញ់របស់យើងចំពោះទ្រង់។ យើងសុំជំនួយ ការការពារ និងការដឹកនាំតាមសេចក្តីត្រូវការរបស់យើងផងដែរ។

នៅពេលយើងអធិស្ឋានដោយសេចក្តីជំនឿ អស់ពីចិត្ត និងដោយចិត្តស្មោះត្រង់ យើងនឹងឃើញពីឥទ្ធិពលរបស់ព្រះ មាននៅក្នុងជីវិតរបស់យើង។ ទ្រង់នឹងដឹកនាំយើងនៅក្នុងជីវិតរស់នៅជាប្រចាំ និងជួយយើងឱ្យធ្វើការសំរេចចិត្តត្រឹមត្រូវ។ ទ្រង់នឹងប្រទានពរដល់យើងជាមួយនឹងអារម្មណ៍សុខសាន្ត និងសន្តិភាព។ ទ្រង់នឹងព្រមានយើង អំពីគ្រោះថ្នាក់ និងពង្រឹងយើង ដើម្បីតស៊ូនឹងសេចក្តីល្បួង។ ទ្រង់នឹងអភ័យទោសអំពើបាបរបស់យើង។ យើងនឹងមានអារម្មណ៍ខិតទៅជិតទ្រង់។ យើងត្រូវតែ រៀនដើម្បីស្គាល់ឥទ្ធិពលរបស់ទ្រង់នៅក្នុងជីវិតរបស់យើង។ យើងត្រូវតែរៀនស្តាប់សំលេងតូចរហៀងរបស់ព្រះវិញ្ញាណ។

យើងអាចដឹង នៅពេលព្រះវិញ្ញាណបរិសុទ្ធ កំពុងបង្រៀនយើងពីសេចក្តីពិត។ ចិត្តរបស់យើង នឹងពេញដោយការបំផុសគំនិត និងគំនិតលើកតំកើង។ យើងនឹងបានបំភ្លឺ ឬផ្តល់ការចេះដឹងថ្មី។ ដួងចិត្តរបស់យើងនឹងមានអារម្មណ៍សន្តិភាព សេចក្តីអំណរ និងសេចក្តីស្រលាញ់។ យើងនឹងចង់ធ្វើល្អ ហើយជាជំនួយដល់អ្នកដទៃ។ អារម្មណ៍ទាំងនេះ ពិបាក ដើម្បីធ្វើការពិពណ៌នា ប៉ុន្តែអាចស្គាល់នៅពេលយើងមានបទពិសោធន៍អំពីអារម្មណ៍ទាំងនោះ។

**ការសិក្សាព្រះគម្ពីរ**

| | | |
|---|---|---|
| នីហ្វៃទី 2 32៖8–9 | គ និងស 6៖22–23 | គ និងស 19៖28 |
| អេណុស 1៖1–12 | គ និងស 8៖2–3 | ពង្សាវតារក្សត្រទី1 19៖11–12 |
| អាលម៉ា 34៖17–28 | គ និងស 9៖7–9 | Guide to the Scriptures, “Prayer” |
| ម៉ូរ៉ូណៃ 10៖3–5 | | |

**ការតាំងចិត្ត**

- តើអ្នកព្រមលុតជង្គង់អធិស្ឋានជាប្រចាំថ្ងៃ ជាបុគ្គល និងជាគ្រួសារដែរឬទេ?

## ការសិក្សាព្រះគម្ពីរ

បទគម្ពីរ ត្រូវបានសរសេរជាបញ្ជីប្រវត្តិ អំពីទំនាក់ទំនងរបស់ព្រះ ជាមួយនឹងកូនចៅរបស់ទ្រង់ ដូចបានកត់ត្រា ដោយព្យាការីនៅក្រោមឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ។ យើងបង្ហាញសេចក្តីជំនឿរបស់យើង ដោយការសិក្សា ការជឿ និងការប្រតិបត្តិតាមពាក្យ ដែលបានបើកសំដែងដោយព្រះ។ យើងឧស្សាហ៍ក្នុងការស្ទង់មើលបទគម្ពីរ ដើម្បីយល់ពីសេចក្តីពិត។ យើងទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទ ពីព្រោះបទគម្ពីរ បើកទ្វារទៅកាន់វិវរណៈ ហើយបង្ហាញយើងពីអ្វី ដែលយើងត្រូវការ ដើម្បីធ្វើ និងប្រែក្លាយ។

កំណត់ចំណាំ

យើងស្ទង់មើលបទគម្ពីរ ដើម្បីរៀនអំពីព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់។ ជំនឿនៅលើព្រះយេស៊ូវគ្រីស្ទ គឺជាអំណោយទានមួយ មកពីព្រះ ហើយមានតាមរយៈការសិក្សា និងការរស់នៅតាមព្រះបន្ទូលទ្រង់ និងដំណឹងល្អរបស់ទ្រង់។ បទគម្ពីរដែលបានអនុម័តដោយសាសនាចក្រ ក៏ត្រូវបានហៅថាជាព្រះគម្ពីរបមាណិយ មានដូចជាព្រះគម្ពីរបរិសុទ្ធ ព្រះគម្ពីរមរមន គោលលទ្ធិ និងសេចក្ដីសញ្ញា និងមុក្ដាដ៏មានតម្លៃ។ យើងគួរតែសិក្សាសៀវភៅពិសិដ្ឋទាំងនេះជាប្រចាំថ្ងៃ។

### ការសិក្សាព្រះគម្ពីរ

នីហ្វៃទី1 19៖22–23
នីហ្វៃទី2 9៖50–51
នីហ្វៃទី2 25៖26
នីហ្វៃទី2 29៖1–13
នីហ្វៃទី2 31៖19–20
នីហ្វៃទី2 32៖3–5
អាលម៉ា 32៖28–30
យ៉ូហាន 5៖39
យ៉ូហាន 20៖31
ធីម៉ូថេទី2 3៖14–17
ពេត្រុសទី2 1៖20–21

### ការតាំងចិត្ត

- តើអ្នកព្រមអានបទគម្ពីរមរមនជាប្រចាំ ដោយផ្ទាល់ខ្លួន និងជាគ្រួសារដែរឬទេ?

## រក្សាថ្ងៃឈប់សំរាកឱ្យបរិសុទ្ធ

ឥរិយាបទរបស់យើងនៅ ថ្ងៃឈប់សំរាក គឺជាការឆ្លុះបញ្ចាំងអំពី ការតាំងចិត្តរបស់យើង ចំពោះការគោរព និងថ្វាយបង្គំព្រះ។ ដោយការថែរក្សាថ្ងៃឈប់សំរាកឱ្យបរិសុទ្ធ យើងបង្ហាញដល់ព្រះនូវឆន្ទះរបស់យើង ដើម្បីរក្សាសេចក្ដីសញ្ញារបស់យើង។ ថ្ងៃឈប់សំរាកនីមួយៗ យើងទៅជំណាក់ព្រះអម្ចាស់ ដើម្បីថ្វាយបង្គំទ្រង់។ ពេលនៅទីនោះ យើងទទួលទាននំប៉័ង និងទឹក ដើម្បីចងចាំដល់ព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់។ យើងរំលឹកសេចក្ដីសញ្ញារបស់យើង និងបង្ហាញថា យើងមានចំណង់ដើម្បីប្រែចិត្តអំពីអំពើបាប និងកំហុសរបស់យើង។

នៅក្នុងថ្ងៃនេះ យើងរីករាយនឹងការសំរាកពីកិច្ចការរបស់យើង។ នៅពេលយើងចូលរួមក្នុងការបំរើនៃសាសនាចក្រ និងថ្វាយបង្គំរួមគ្នា យើងពង្រឹងគ្នាទៅវិញទៅមក។ យើងធ្វើទំនាក់ទំនងជាថ្មី ជាមួយមិត្តភក្តិ និងគ្រួសាររបស់យើង។ សេចក្ដីជំនឿរបស់យើង ត្រូវបានពង្រឹង នៅពេលយើងសិក្សាបទគម្ពីរ និងរៀនបន្ថែមទៀត អំពីដំណឹងល្អ ដែលបានស្ដារឡើងវិញ។

នៅពេលសហគមន៍ ឬជាតិសាសន៍ កាន់តែមិនយកចិត្តទុកដាក់ ទៅលើសកម្មភាពថ្ងៃឈប់សំរាក នោះជីវិតខាងសាសនានឹងរលួយ ហើយទិដ្ឋភាពទាំងអស់នៃជីវិត គឺរងឥទ្ធិពលអាក្រក់។ ពរជ័យទាំងឡាយ មានទាក់ទងនឹងការរក្សាថ្ងៃឈប់សំរាកឱ្យបរិសុទ្ធ ត្រូវបាត់បង់។ យើងគួរជៀសវាង ការទិញដូរនៅថ្ងៃឈប់សំរាក និងការចូលរួម ក្នុងសកម្មភាពពាណិជ្ជកម្ម និងកីឡាផ្សេងៗទៀត ដែលរមែងធ្វើឱ្យថ្ងៃឈប់សំរាក មិនបរិសុទ្ធ។

ពួកបរិសុទ្ធថ្ងៃចុងក្រោយ គួរតែញែកថ្ងៃបរិសុទ្ធនេះពីសកម្មភាព ខាងលោកិយ៍ ដោយការចូលរួមនៅក្នុង វិញ្ញាណនៃការថ្វាយបង្គំថ្លែងអំណរគុណ ការបំរើ និងសកម្មភាពសមរម្យ ដែលពាក់ពន្ធ័នឹងគ្រួសារ នៅថ្ងៃឈប់សំរាក។ នៅពេលសមាជិកសាសនាចក្រព្យាយាមធ្វើឱ្យ សកម្មភាពថ្ងៃឈប់សំរាករបស់ពួក ស្របទៅនឹងព្រះទ័យ និងព្រះវិញ្ញាណនៃព្រះអម្ចាស់ នោះជីវិតរបស់ពួកគេនឹងពោរពេញទៅដោយសេចក្ដីអំណរ និងសន្តិភាព។

### ការសិក្សាព្រះគម្ពីរ

នីហ្វៃទី3 18៖1–25
គ និងស 59៖9–15
និក្ខមនំ 20៖8–11
និក្ខមនំ 31៖12–17
អេសាយ 58៖13–14

### អង្គុយជាមួយសាសនាគន់ការី ឬសមាជិកនៅព្រះវិហារ

នៅពេលចូលរួមនៅក្នុងការប្រជុំពិធីប្រសិទ្ធិពរនំប៉័ង និងទឹក ឬសន្និសីទក្នុងស្តេក ដៃគូនៃអ្នកផ្សព្វផ្សាយសាសនា គួរតែអង្គុយជាមួយនឹងសាសនាគន់ការី អ្នកផ្លាស់សាសនាថ្មី ឬសមាជិកទាំងឡាយ។ ពួកគេមិនគួរអង្គុយជាមួយអ្នកផ្សព្វផ្សាយ សាសនាផ្សេងទៀតទេ។

កំណត់ចំណាំ

### ការតាំងចិត្ត

- តើអ្នកព្រមរក្សាថ្ងៃឈប់សំរាកឱ្យបរិសុទ្ធដែរឬទេ?
- តើអ្នកព្រមរៀបចំខ្លួនអ្នក ដើម្បីទទួលទានទំប៉័ង និងទឹកដោយសក្តិសមដែរឬទេ?

**សំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក ដែលអនុវត្តន៍**

- តើអ្នកយល់អ្វីខ្លះអំពីថ្ងៃឈប់សំរាក រួមទាំងការទទួលទានទំប៉័ង និងទឹករាល់សប្តាហ៍ និងការផ្តល់នូវការបំរើ ដល់អ្នកដទៃ? តើអ្នកយល់ព្រមគោរពតាមច្បាប់នេះ [មុនពេលពិធីបុណ្យជ្រមុជទឹករបស់អ្នក] ដែរឬទេ?

## ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់

របៀប ដែលយើងបង្ហាញអំពីចំណង់របស់យើង ដើម្បីធ្វើតាមផ្លូវរបស់ព្រះ គឺតាមរយៈពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។ នៅពេលយើងទទួលបុណ្យជ្រមុជទឹក និងធ្វើពិធីបញ្ជាក់ យើងចូលទៅក្នុងសេចក្តីសញ្ញាមួយជាមួយព្រះ ថាយើងព្រមយកដាក់លើខ្លួនពួកយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ហើយថា យើងនឹងចងចាំទ្រង់ជានិច្ច និងរក្សាបទបញ្ញត្តិរបស់ទ្រង់។ យើងក៏សន្យា ផងដែរថា ឈរធ្វើជាសាក្សីនៃព្រះនៅគ្រប់ពេលទាំងអស់ និងជួយអ្នកទុរគត (សូម មើលម៉ូសាយ 18៖ 8–9)។ ត្រឡប់មកវិញ ព្រះសន្យាថានឹងមានភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធជានិច្ច ការអភ័យទោសពីបាប របស់យើង និងចាប់ផ្តើមកើតម្តងទៀត។

### ការតាំងចិត្ត

- តើអ្នកព្រមទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ដែរឬទេ?
- តើអ្នកព្រមអញ្ជើញមិត្ត និងគ្រួសាររបស់អ្នកសាសនាគន់ការីឱ្យចូលរួមនៅក្នុងពិធីបុណ្យជ្រមុជទឹករបស់អ្នកដែរឬទេ?
- បើអាចធ្វើទៅបាន សូមអញ្ជើញសាសនាគន់ការីឱ្យចូលរួមនៅក្នុងពិធីបុណ្យជ្រមុជទឹក និងការប្រជុំពិធីប្រសិទ្ធិពរទំប៉័ង និងទឹកអំឡុងពេលដែលមាននរណាម្នាក់ទទួលពិធីបញ្ជាក់។

**សំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក ដែលអនុវត្ត**

- រាល់ សំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹកទាំងអស់។

### ការអញ្ជើញសំរាប់ទទួលបុណ្យជ្រមុជទឹក

ការអញ្ជើញដើម្បីទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ គួរតែច្បាស់លាស់ និងចំពុះ "តើអ្នកព្រមធ្វើតាមគំរូនៃព្រះយេស៊ូវគ្រីស្ទ ដោយការធ្វើបុណ្យជ្រមុជទឹក ដោយនរណាម្នាក់ ដែលកាន់សិទ្ធិអំណាចបព្វជិតភាពរបស់ព្រះដែរឬទេ? យើងនឹងធ្វើពិធីបុណ្យ ជ្រមុជទឹកនៅ [កាលបរិច្ឆេទ]។ តើអ្នកព្រមរៀបចំខ្លួន ដើម្បីទទួលបុណ្យជ្រមុជទឹកនៅថ្ងៃនោះដែរឬទេ?"

## ធ្វើតាមព្យាការី

សេចក្តីពិតគឺជាចំណេះដឹងអំពីអ្វីមួយ ដែលវាជាការពិត ធ្លាប់ពិត ហើយនឹងនៅតែពិត។ វាមិនបានផ្លាស់ប្តូរ ទៅតាមស្ថានភាព ឬពេលវេលាទេ។ សេចក្តីពិតគឺនៅពិតគ្រប់ពេលវេលា និងគ្រប់វប្បធម៌។ ព្រះគឺជាប្រភពនៃសេចក្តីពិត។ យើងអាចមានជំនឿ នៅក្នុងទ្រង់ពីព្រោះ យើងដឹងថាទ្រង់នឹងបង្រៀនយើងសេចក្តីពិតតែប៉ុណ្ណោះ។ ព្រះចង់ឱ្យកូនចៅរបស់ទ្រង់ទាំងអស់ដឹង អំពីសេចក្តីពិត។ ហេតុដូច្នោះហើយ ទ្រង់បើកបង្ហាញសេចក្តីពិតទាំងឡាយ ដែលចាំបាច់សំរាប់សេចក្តីសង្គ្រោះ តាមរយៈព្យាការី និងសាវក។ ទ្រង់ បើកបង្ហាញសេចក្តីពិតដល់យើងដោយផ្ទាល់តាមរយៈបទគម្ពីរ និងវិវរណៈផ្ទាល់ខ្លួន។

ព្យាការីម្នាក់ត្រូវបានហៅ និងជ្រើសរើសដោយព្រះ ហើយគឺជាបុរសសុចរិតម្នាក់ ដែលមានជំនឿខ្លាំង។ ព្រះអម្ចាស់ បើកបង្ហាញសេចក្តីពិតទៅព្យាការី តាមរយៈព្រះវិញ្ញាណបរិសុទ្ធ។ ទ្រង់បញ្ជាដល់ព្យាការីរបស់ទ្រង់ឱ្យបង្រៀនសេចក្តីពិតដល់មនុស្សទាំងអស់។ អ្នកទាំងឡាយណា ដែលជឿបន្ទូលរបស់ព្រះ ដូចដែលបានបើកបង្ហាញតាមរយៈព្យាការីរបស់ទ្រង់ ត្រូវបានទទួលពរជ័យ។

សាសនាចក្ររបស់ព្រះគ្រីស្ទ គឺត្រូវស្ថាបនាឡើងនៅលើគ្រឹះ នៃសាវក ព្យាការី ដែលដឹកនាំសាសនាចក្រដោយវិវរណៈ។ ព្រះអម្ចាស់ បានហៅយ៉ូសែប ស្ម៊ីធ ជាព្យាការីតំបូង និងជាអ្នកដឹកនាំនៅក្នុងជំនាន់ចុងក្រោយនេះ។ អ្នកស្នងរបស់លោក ដែលដឹកនាំ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយសព្វថ្ងៃនេះ គឺជាព្យាការី និងសាវកផងដែរ។ ប្រធាននៃ សាសនាចក្រ

កំណត់ចំណាំ

សព្វថ្ងៃនេះ គឺជាព្យាការីម្នាក់ដែលនៅរស់។ យើងត្រូវមានសេចក្ដីជំនឿ ទៅលើការជ្រើសរើសព្យាការីរបស់ព្រះ ដើម្បីលើមុខងារដ៏ទេវភាពរបស់លោក និងធ្វើតាមការបង្រៀនរបស់លោក។

យើងមានឱកាសជារឿយៗ ដើម្បីគាំទ្រដល់អ្នកដឹកនាំសាសនាចក្រជាសាធារណៈ។ *ការគាំទ្រ* មានន័យថាទ្រទ្រង់។ យើងត្រូវរៀបចំខ្លួនរបស់យើង ដើម្បីនៅពេលព្យាការី និងសាវកនិយាយ ព្រះវិញ្ញាណបរិសុទ្ធ អាចបញ្ជាក់សេចក្ដីពិត ដែលពួកគេបង្រៀន ហើយយើងអាចប្ដេជ្ញា ដើម្បីធ្វើតាមដំបូន្មាន ផ្ដល់មកឱ្យយើង។

អ្នកទាំងឡាយណា ដែលស្ដាប់ និងធ្វើតាមដំបូន្មាន នៃព្យាការី និងសាវកដែលនៅរស់ នឹងមិនវង្វេងឡើយ។ ការបង្រៀន របស់ព្យាការីនៅរស់ផ្ដល់សេចក្ដីពិតដ៏អស់កល្បជានិច្ចដោយខ្ជាប់ខ្ជួន នៅក្នុងពិភពលោក ផ្លាស់ប្ដូរតម្លៃ និងជួយយើង ឱ្យជៀសវាងពីទុក្ខវេទនា និងសោកស្ដាយ។ ការភាន់ច្រឡំ និងការវិវាទនៃពិភពលោក នឹងមិនធ្វើឱ្យយើងមាន ការរន្ធត់ចិត្តទេ ហើយយើងនៅតែអាចរីករាយ ជាមួយនឹងការទុកចិត្ត ចំពោះឆន្ទៈព្រះ។

## ការសិក្សាព្រះគម្ពីរ

| | | |
|---|---|---|
| ម៉ូសាយ 15៖11–12 | គ និងស 21៖1–7 | អេភេសូរ 2៖19–20 |
| អាលម៉ា 13៖1–16 | គ និងស 136៖37–38 | អេភេសូរ 4៖11–14 |
| នីហ្វៃទី3 12៖1–2 | យ៉ូហាន 15៖16 | ហេព្រើរ 5៖4 |
| គ និងស 1៖37–38 | កិច្ចការ 10៖34–44 | អេម៉ុស 3៖7 |

## ការតាំងចិត្ត

- តើអ្នកព្រមជួបជាមួយប៊ីស្សុបដែរឬទេ?
- តើអ្នកព្រមគាំទ្រ និងធ្វើតាមដំបូន្មានរបស់អ្នកដឹកនាំសាសនាចក្រដែរឬទេ?

**សំនួរសម្ភាសន៍សំរាប់ពិធីបុណ្យជ្រមុជទឹក ដែលអនុវត្តន៍**

- តើអ្នកជឿថា [ប្រធានសាសនាចក្របច្ចុប្បន្ន] គឺជាព្យាការីម្នាក់របស់ព្រះដែរឬទេ? តើនោះមានន័យយ៉ាងណាចំពោះអ្នក?

## គោរពតាមក្រិត្យវិន័យទាំងដប់ប្រការ

ព្រះវរបិតាសួគ៌ ប្រទានដល់យើងនូវបទបញ្ញត្តិ ដើម្បីយើងនឹងដឹង អ្វីដែលត្រូវធ្វើ ហើយអ្វី ដែលត្រូវជៀសវាង ដើម្បីទទួលពរជ័យដែលទ្រង់សព្វព្រះទ័យប្រទានឱ្យយើង (សេចក្ដីអំណរ សន្តិភាពខាងមនសិកា សុភមង្គលដ៏យូរអង្វែង)។ ព្រះទ្រង់បានបើកបង្ហាញដល់ម៉ូសេនូវក្រិត្យវិន័យដប់ប្រការ ដើម្បីដឹកនាំប្រជាជនរបស់ទ្រង់៖

- “កុំឱ្យមានព្រះឯណាទៀតនៅចំពោះអញឱ្យសោះ” (និកម្ពនំ 20៖3)។ “ព្រះ” ឯណាទៀត អាចរួមមានដូចជា ទ្រព្យសម្បត្តិ អំណាច ឬភាពហ៊ឺហារ។
- “កុំឱ្យឆ្លាក់ធ្វើរូបណាសំរាប់ឯងឱ្យសោះ” (និកម្ពនំ 20៖4)។
- “កុំឱ្យចេញព្រះនាមរបស់ព្រះយេហូវ៉ា ជាព្រះនៃឯងជាអសាឥតការឡើយ” (និកម្ពនំ 20៖7)។
- “ចូរឱ្យនឹកចាំពីថ្ងៃឈប់សំរាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ” (និកម្ពនំ 20៖8)។
- “ចូរឱ្យគោរពប្រតិបត្តិដល់ឪពុកម្ដាយ” (និកម្ពនំ 20៖12)។
- “កុំឱ្យសំឡាប់មនុស្សឱ្យសោះ” (និកម្ពនំ 20៖13)។
- “កុំឱ្យផិតគ្នាឱ្យសោះ” (និកម្ពនំ 20៖14)។
- “កុំឱ្យលួចប្លន់ឱ្យសោះ” (និកម្ពនំ 20៖15)។
- “កុំឱ្យធ្វើជាទីបន្ទាល់ក្លែងទាស់នឹងអ្នកជិតខាងខ្លួនឱ្យសោះ” (និកម្ពនំ 20៖16)។
- “កុំឱ្យលោភចង់បាន” (និកម្ពនំ 20៖ 17)។

កំណត់ចំណាំ

ក្រិត្យវិន័យដប់ប្រការ គឺនៅតែមានសុពលភាពបច្ចុប្បន្ននេះ។ ក្រិត្យវិន័យដប់ប្រការបង្រៀនយើងឱ្យថ្វាយបង្គំ និងបង្ហាញគារវភាពចំពោះព្រះ។ ក្រិត្យវិន័យដប់ប្រការក៏បង្រៀនយើងផងដែរ អំពីរបៀប ដើម្បីប្រព្រឹត្តជាមួយនឹងគ្នាទៅវិញទៅមក។

## គ្មានព្រះឯណាទៀតទេ

មនុស្សនៅក្នុងវប្បធម៌ជាច្រើន តែងតែមាន ឬសំដែងការគោរពចំពោះវត្ថុ ដែលរំលឹកពួកគេអំពីទេវតា ឬជីដូនជីតា។ នៅពេលខ្លះកម្មវត្ថុទាំងនេះមានដូចជារូបសំណាក បដិរូបសាសនា បចេតិយស្ថានតូចៗ អាចជាចំណុចផ្ដោតយកចិត្តទុកដាក់ សំរាប់ការថ្វាយបង្គំ របស់ពួកគេផងដែរ។ សូមជួយពួកគេឱ្យយល់ថា ព្រះអម្ចាស់បានបញ្ជាកុំឱ្យយើងថ្វាយបង្គំរូបសំណាក។ លើកទឹកចិត្តពួក គេឱ្យយកវត្ថុទាំងឡាយដែលពួកគេថ្វាយបង្គំ ឬអ្វីដែលពួកគេអធិស្ឋានចំពោះនោះ ចេញពីផ្ទះរបស់ពួកគេ។ សូមជួយពួកគេឱ្យផ្ដោត សេចក្ដីជំនឿ និងការថ្វាយបង្គំរបស់ពួកគេទៅលើព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ។ បង្រៀនពួកគេថា ដំណឹងល្អ ដែលបានសាងឡើងវិញ របស់ព្រះយេស៊ូវគ្រីស្ទ ផ្ដោតទៅលើព្រះគ្រីស្ទដ៏មានព្រះជន្មរស់។

នៅក្នុងដំណឹងល្អដែលបានសាងឡើងវិញ ព្រះអម្ចាស់ បានបង្រៀនយើងពីរបៀប ដើម្បីនឹកចាំទ្រង់។ យើងចងចាំទ្រង់ តាមរយៈការអធិស្ឋាន ការប្រសិទ្ធពរនំប៉័ង និងទឹក និងការថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធ។ ប្រធានបេសកកម្មរបស់អ្នក នឹងផ្ដល់ជាការណែនាំទៅតាមតំបន់ជាក់លាក់។

## ការសិក្សាព្រះគម្ពីរ

| | | |
|---|---|---|
| ម៉ូសាយ 13 | ម៉ាថាយ 22៖36–40 | ចោទិយកថា 5៖6–21 |
| គ និងស 59៖5–6 | និក្ខមនំ 20៖1–17 | |

## ការតាំងចិត្ត

- តើអ្នកព្រមគោរពតាមក្រិត្យវិន័យដប់ប្រការដែរឬទេ?

## រស់នៅតាមច្បាប់ព្រហ្មចារីយភាព

ព្រះមានសេចក្ដីអំណរនៅក្នុងព្រហ្មចារីយភាព ហើយស្អប់អំពើបាបខាងផ្លូវភេទ។ ព្រហ្មចារីយភាពរួមមាន ការជៀសវាងយ៉ាងដាច់ខាតពីទំនាក់ទំនងខាងផ្លូវភេទមុនពេលរៀបអាពាហ៍ពិពាហ៍ និងស្វាមីភក្ដិពេញលេញ និងភក្ដីភាពចំពោះប្ដីប្រពន្ធ បន្ទាប់ពីរៀបការ។ អ្នកទាំងឡាយណា ដែលរស់នៅតាមច្បាប់ព្រហ្មចារីយភាព នឹងសប្បាយជាមួយនឹងកម្លាំង ដែលមកពី ការគ្រប់គ្រងលើខ្លួនឯង។ ពួកគេសប្បាយរីករាយនឹងការជឿជាក់ និងទុកចិត្តនៅក្នុងទំនាក់ទំនងក្រុមគ្រួសាររបស់ពួកគេ។ ពួកគេអាចរីករាយនឹងឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធកាន់តែពេញលេញ នៅក្នុងជីវិតរបស់ពួកគេ។ អ្នកទាំងឡាយណា ដែលមិនគោរពតាមច្បាប់នេះ គឺនឹងស្ថិតនៅក្រោមអារម្មណ៍នៃភាពខ្មាស់អៀន និងមានកំហុសជារៀងរហូត ចំពោះអំរែកនៅ ក្នុងជីវិតរស់នៅរបស់ពួកគេ។

ព្រហ្មចារីយភាព តំរូវឱ្យមានសេចក្ដីស្មោះត្រង់នៅក្នុងគំនិត និងសកម្មភាព។ យើងត្រូវតែរក្សាគំនិតរបស់យើងឱ្យស្អាតស្អំ និងស្លៀកពាក់សមរម្យ ហើយនិយាយស្ដី និងធ្វើសកម្មភាពឱ្យត្រឹមត្រូវ។ យើងត្រូវតែជៀសវាងពីរូបអាសក្រាមគ្រប់ប្រភេទ។ យើងគួរតែចាត់ទុក អំណាចនៃការបង្កើតដែលព្រះប្រទានឱ្យ និងរាងកាយរបស់យើងឱ្យពិសិដ្ឋ។ បេក្ខជនទទួលបុណ្យជ្រមុជទឹក គឺត្រូវរស់នៅតាមច្បាប់ព្រហ្មចារីយភាព ដែលហាមឃាត់ពីទំនាក់ទំនងខាងផ្លូវភេទគ្រប់ប្រភេទ ក្រៅពីអាពាហ៍ពិពាហ៍ស្របច្បាប់ រវាងបុរស និងស្ត្រី។ ពួកគេមិនត្រូវចូលរួមនៅក្នុងការពន្លូតកូន ឬរួមភេទដូចគ្នា ឬទំនាក់ទំនងស្ត្រីដែលរួមប្រតិពន្ធ័ស្ត្រីដូចគ្នាទេ។ អ្នកទាំងឡាយណា ដែលប្រព្រឹត្តអំពើបាបខាងផ្លូវភេទ អាចប្រែចិត្ត និងទទួលការអភ័យទោស។

## គូរស្វាមីរស់នៅជាមួយគ្នា

បុរស និងស្ត្រី ដែលរស់នៅជាមួយគ្នា ប៉ុន្ដែមិនទាន់រៀបការ មិនអនុញ្ញាតឱ្យទទួលបុណ្យជ្រមុជទឹក ដោយគ្មានការរៀបការជាមុន ឬរស់នៅបែកពីគ្នានោះទេ។ អ្នកទាំងឡាយណា ដែលរៀបការច្រើនជាងមួយនាក់ ក្នុងពេលតែមួយ មិនអនុញ្ញាតឱ្យទទួលបុណ្យជ្រមុជទឹកទេ។ សូមស្វែងរកតំបូន្មានមកពីប្រធានបេសកកម្មរបស់អ្នក ដែលនឹងផ្ដល់ឱ្យអ្នកនូវការដឹកនាំជាក់លាក់ នៅក្នុងករណី នីមួយៗ។

កំណត់ចំណាំ

### ការសិក្សាព្រះគម្ពីរ

| | | |
|---|---|---|
| យ៉ាកុប 2៖28 | នីហ្វៃទី3 12៖27–30 | ម៉ាថាយ 5៖27–28 |
| ម៉ូសាយ 13៖22 | គ និងស 42៖22–24 | រ៉ូម 1៖26–32 |
| អាលម៉ា 39៖3–5 | គ និងស 63៖16 | អេភេសូរ 5៖3–5 |

### ការតាំងចិត្ត

- តើអ្នកព្រមរស់នៅតាមច្បាប់បរិសុទ្ធភាពដែរឬទេ?

**សំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក ដែលអនុវត្តន៍**

- តើអ្នកយល់អំពីច្បាប់បរិសុទ្ធភាព ដែលហាមឃាត់មិនឱ្យមានទំនាក់ទំនងខាងផ្លូវភេទ ក្រៅចំណងច្បាប់ អាពាហ៍ពិពាហ៍ ស្របច្បាប់ រវាងបុរស និងស្ត្រីដែរឬទេ? តើអ្នកយល់ព្រមគោរពតាមច្បាប់នេះ [មុនពេលពិធីបុណ្យជ្រមុជទឹករបស់ អ្នក] ដែរឬទេ?
- តើអ្នកធ្លាប់មានចូលរួមក្នុងការពន្លូតកូនដែរឬទេ? តើអ្នកមានទំនាក់ទំនងខាងផ្លូវភេទដូចគ្នាដែរឬទេ? [កំណត់ចំណាំ៖ អ្នកដែលនិយាយថា បាទ ចំពោះសំនួរទាំងនេះណាមួយក៏ដោយ ត្រូវតែធ្វើការសម្ភាសន៍ដោយប្រធានបេសកកម្ម មុនពេលធ្វើបុណ្យជ្រមុជទឹក។]

## គោរពច្បាប់គតិបណ្ឌិត

ព្រះអម្ចាស់ បានបើកបង្ហាញដល់ព្យាការីយ៉ូសែប ស្ម៊ីធនូវច្បាប់សុខភាព ដែលហៅថាពាក្យគតិបណ្ឌិត។ ច្បាប់នេះ បង្រៀនយើង អំពីអាហារ និងសារធាតុណា ដែលយើងគួរតែ ឬមិនគួរប្រើ ដើម្បីរក្សាសុខភាពរាងកាយរបស់យើង និងដើម្បីរក្សាខ្លួនយើង ឱ្យរួចពីឥទ្ធិពលរបស់អារក្ស។ ព្រះអម្ចាស់សន្យាពរជ័យ នៃសុខភាព កម្លាំង ការការពារប្រឆាំងនឹងអារក្ស និងកាន់តែទទួលយក សេចក្ដីពិតខាងវិញ្ញាណខ្លាំងឡើង។

ចូរចងចាំថា រាងកាយរបស់យើងពិសិដ្ឋ។ យើងគួរតែប្រព្រឹត្តនឹងរាងកាយដោយការគោរព និងគារវភាព។ ពាក្យគតិបណ្ឌិត បង្រៀនថា យើងគួរញ៉ាំអាហារដែលមានសុខភាព។ ពាក្យគតិបណ្ឌិតបង្រៀនយើងដោយជាក់លាក់ណាស់ថា យើងគួរជៀស វាងពីសារធាតុដែលនាំឱ្យមានគ្រោះថ្នាក់ រួមមានជាតិស្រវឹង ថ្នាំជក់ តែ កាហ្វេ។ យើងត្រូវតែជៀសវាងពីឱសថដែលនាំឱ្យ មហន្តរាយគ្រប់ប្រភេទ។ ដើម្បីទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ អ្នកទាំងនោះ ដែលអ្នកបង្រៀនត្រូវតែឈប់ប្រព្រឹត្ត នូវគ្រឿងទាំងនេះ។ មនុស្ស ដែលគោរពច្បាប់គតិបណ្ឌិត គឺងាយទទួលសេចក្ដីពិតខាងវិញ្ញាណច្រើនជាង។

ប្រធានបេសកកម្មរបស់អ្នកនឹងឆ្លើយសំនួរទាំងឡាយ ទោះជាសារធាតុជាក់លាក់ផ្សេងទៀត នៅក្នុងវប្បធម៌របស់អ្នក គឺមានបញ្ចូល នៅក្នុងពាក្យនៃគតិបណ្ឌិត។

### ការយកឈ្នះលើការញៀន

អ្នកអាចជាជំនួយដ៏ខ្លាំងបំផុតដល់អ្នកទាំងឡាយ ដែលកំពុងព្យាយាម ដើម្បីយកឈ្នះលើការជក់បារី គ្រឿងស្រវឹង និងទំលាប់ដទៃទៀត តាមគោលការណ៍ទាំងនេះដូចខាងក្រោម។ យោបល់ខាងក្រោមនេះ នឹងអនុវត្តបានជាពិសេស ចំពោះពាក្យគតិបណ្ឌិត ប៉ុន្តែអាចប្រែប្រួលទៅតាម ការញៀនដទៃទៀតផងដែរ។

1. ជួយពួកគេឱ្យដាក់គោលដៅដូចជា នៅពេលណា និងរបៀបណា ដែលពួកគេនឹងរស់នៅតាមពាក្យគតិបណ្ឌិត។
2. អធិស្ឋានសំរាប់ពួកគេនៅក្នុងការអធិស្ឋានផ្ទាល់ខ្លួនរបស់អ្នក និងនៅពេលអ្នកនៅជាមួយពួកគេ។
3. រក្សាគំនិតជាវិជ្ជមាន និងគាំទ្រ—សូម្បីតែពួកគេធ្លាក់ចុះក្នុងទំលាប់ចាស់ក៏ដោយ
4. បន្តបង្រៀនដំណឹងល្អដល់ពួកគេ។ បង្រៀនពួកគេពីរបៀប ដើម្បីប្រើការអធិស្ឋាន និងជំនឿ ធ្វើជាប្រភពនៃកម្លាំង។
5. ជួយពួកគេឱ្យមកព្រះវិហារជាទៀងទាត់ និងពង្រីកមិត្តភាពជាមួយអ្នក ដែលរស់នៅតាមពាក្យគតិបណ្ឌិត ហើយបានយកឈ្នះលើការញៀនដូចគ្នានេះ។
6. នៅពេលសមរម្យ ចូរស្នើរសុំផ្ដល់ដល់ពួកគេនូវពរជ័យនៃបព្វជិតភាព។
7. ចូរលើកទឹកចិត្តពួកគេឱ្យបោះចោលសារធាតុ ដែលនាំឱ្យមហន្តរាយចេញពីផ្ទះរបស់ពួកគេ។

សូមមើលជំពូកទី 10 សំរាប់ការណែនាំបន្ថែម អំពីការជួយមនុស្សឱ្យយកឈ្នះលើការញៀន។

មេរៀនទី 4៖
បទបញ្ញត្តិ

កំណត់ចំណាំ

## ការសិក្សាព្រះគម្ពីរ

| | | |
|---|---|---|
| គ និងស 89 | កូរិនថូសទី1 3៖16–17 | កូរិនថូសទី1 6៖19–20 |

## ការតាំងចិត្ត

- តើអ្នកព្រមរស់នៅតាមពាក្យនៃគតិបណ្ឌិតដែរទេ?

**សំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក ដែលអនុវត្តន៍**

- តើអ្នកយល់អ្វីខ្លះ អំពីពាក្យគតិបណ្ឌិត? តើអ្នកយល់ព្រមគោរពតាមច្បាប់នេះ [មុនពេលពិធីបុណ្យជ្រមុជទឹករបស់អ្នក] ដែរឬទេ?

## គោរពតាមច្បាប់ដង្វាយមួយភាគក្នុងដប់

ពរជ័យមួយ នៃពរជ័យធំៗទាំងឡាយ នៃភាពជាសមាជិក នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធ ថ្ងៃចុងក្រោយ គឺជាឯកសិទ្ធិ នៃការនាំឱ្យមានភាពរីកចំរើននៃនគរព្រះ តាមរយៈការបង់ដង្វាយមួយភាគក្នុងដប់។ ដង្វាយមួយភាគក្នុងដប់ គឺមានមកពីបូរាណ ច្បាប់នៃទេវភាព។ ឧទាហរណ៍ ព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់ លោកអ័ប្រាហាំ បានបង់ដង្វាយមួយភាគក្នុងដប់ នូវអ្វីៗ ដែលលោកមានដែរ (សូមមើល អាលម៉ា 13៖15)។

ចំពោះអ្នកទាំងឡាយណា ដែលបង់ដង្វាយមួយភាគក្នុងដប់ ព្រះអម្ចាស់សន្យាថា ទ្រង់នឹង "បើក . . . ទ្វារស្ថានសួគ៌ ដើម្បីចាក់ . . . ព្រះពរ មកលើយើង ដែលនឹងគ្មានកន្លែងល្មមទុកបានទេ" (ម៉ាឡាគី 3៖10)។ ពរជ័យទាំងនេះអាចជាខាងសាច់ឈាម ឬខាងវិញ្ញាណ ប៉ុន្តែពរជ័យនឹងមានមកដល់អ្នកទាំងឡាយណា ដែលគោរពតាមច្បាប់ទេវភាពនេះ។

ដង្វាយមួយភាគក្នុងដប់មានន័យថាមួយក្នុងដប់ ហើយព្រះអម្ចាស់បានបញ្ជាដល់យើងឱ្យប្រគល់មួយភាគក្នុងដប់ នៃកំណើនរបស់យើង ដែលត្រូវបានយល់ថាជាចំណូល ដែលយើងអាចនឹងទទួលពរជ័យ។ ច្បាប់ដង្វាយមួយភាគក្នុងដប់ ផ្ដល់ឱ្យយើងជាឱកាស ដើម្បីជួយស្ថាបនានគររបស់ទ្រង់។ ដង្វាយមួយភាគក្នុងដប់របស់យើង គឺបរិសុទ្ធចំពោះព្រះអម្ចាស់ ហើយយើងគោរពទ្រង់ ដោយការបង់ដង្វាយមួយភាគក្នុងដប់។ ព្រះសន្យានឹងប្រទានពរដ៏បរិបូរណ៍ ដល់អ្នកទាំងឡាយណា ដែលបង់ដង្វាយដោយស្មោះត្រង់។ អ្នកទាំងឡាយណា ដែលមិនបង់ដង្វាយមួយភាគក្នុងដប់កោងយករបស់ព្រះ (សូមមើល ម៉ាឡាគី 3៖8)។ ពួកគេរក្សាទុកនូវអ្វី ដែលជាកម្មសិទ្ធិរបស់ទ្រង់ សំរាប់ខ្លួនពួកគេ។ យើងគួរតែស្វែងរកនគរនៃព្រះជាមុនសិន ហើយដង្វាយមួយភាគក្នុងដប់ គឺជាវិធីមួយដ៏សំខាន់ដើម្បីធ្វើដូច្នោះ។ ការបង់ដង្វាយមួយភាគក្នុងដប់ គឺជាការបញ្ជាក់អំពី ជំនឿរបស់យើង។ វាជាសញ្ញា ដែលបង្ហាញមកខាងក្រៅ អំពីជំនឿរបស់យើងទៅលើព្រះ និងកិច្ចការរបស់ទ្រង់។

មូលនិធិដង្វាយមួយភាគក្នុងដប់ ត្រូវបានប្រើដើម្បីផ្គត់ផ្គង់ដល់សកម្មភាពដែលកំពុងកើតមានរបស់សាសនាចក្រ ដូចជាស្ថាបនា និងថែរក្សាព្រះវិហារបរិសុទ្ធ និងសាលាប្រជុំ ការនាំយកដំណឹងល្អទៅដល់ពិភពលោកទាំងមូល ការដឹកនាំព្រះវិហារបរិសុទ្ធ និងកិច្ចការពង្សប្រវត្តិ និងសកម្មភាពដទៃផ្សេងទៀតជាច្រើននៅទូទាំងពិភពលោក។ ដង្វាយមួយភាគក្នុងដប់ មិនបង់ថ្លៃឱ្យអ្នកដឹកនាំក្នុងសាសនាចក្រប្រចាំតំបន់ទេ ដែលពួកគេបំរើដោយគ្មានទទួលបានទូរកំរៃអ្វីទាំងអស់។

អ្នកដឹកនាំសាសនាចក្រប្រចាំតំបន់ បញ្ជូនដង្វាយមួយភាគក្នុងដប់ ដែលបានទទួលរាល់សប្ដាហ៍ទៅកាន់ទីស្នាក់ការសាសនាចក្រ ដោយផ្ទាល់។ ក្រុមប្រឹក្សាមួយ ដែលរួមមាន គណៈប្រធានទីមួយ ក្រុមសាវកដប់ពីរនាក់ និងគណៈប្រធានប៊ីស្សព បានកំណត់វិធី ជាក់លាក់ ដើម្បីប្រើប្រាស់មូលនិធិដង្វាយមួយភាគក្នុងដប់ដ៏ពិសិដ្ឋ។

## ការសិក្សាព្រះគម្ពីរ

**ដង្វាយមួយភាគក្នុងដប់**

| | | |
|---|---|---|
| គ និស 119 | ហេព្រើរ 7៖1–2 | លេវីវិន័យ 27៖30–33 |
| គ និង ស 120 | ទិក្ខមទំ 14៖18–20 | ម៉ាឡាគី 3៖7–12 |

**ជំនឿ**

| | |
|---|---|
| នីហ្វៃទី3 13៖33 | អេធើរ 12៖6 |

កំណត់ចំណាំ

### ការតាំងចិត្ត

- តើអ្នកព្រមរស់នៅតាមច្បាប់ដង្វាយមួយភាគក្នុងដប់ នៅពេលអ្នកទទួលបុណ្យជ្រមុជទឹកដែរឬទេ?

**សំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក ដែលអនុវត្តន៍**

- តើអ្នកយល់អ្វីខ្លះ អំពីដង្វាយមួយភាគក្នុងដប់? តើអ្នកយល់ព្រមគោរពតាមច្បាប់នេះដែរឬទេ?

## ប្រតិបត្តិតាមច្បាប់តមអាហារ

ពរជ័យធំៗ មានសំរាប់អ្នកទាំងឡាយណា ដែលគោរពតាមបទបញ្ញត្តិរបស់ព្រះ ដើម្បីតមអាហារ។ ការតមអាហារ មានន័យថាមិនញាំុអាហារ ឬផឹកទឹកសំរាប់មួយរយៈពេល។ ជាធម្មតានៅថ្ងៃអាទិត្យទីមួយ នៃខែនីមួយៗ គឺត្រូវបានចាត់តាំងឡើង ជាថ្ងៃពិសេស ដើម្បីតមសំរាប់អាហារពីរពេលជាប់គ្នា អធិស្ឋាន និងថ្លែងទីបន្ទាល់។ ការតមអាហារ និងការអធិស្ឋានធ្វើទៅព្រមគ្នា។ នៅពេលយើងតមអាហារ និងអធិស្ឋានដោយសេចក្ដីជំនឿ យើងកាន់តែងាយទទួលយកចំលើយ ចំពោះការអធិស្ឋាន និងពរជ័យរបស់យើង មកពីព្រះអម្ចាស់។ ទ្រង់សន្យានឹងយើង ទ្រង់នឹងដឹកនាំយើងជានិច្ច។ យើងគួរតែតមអាហារ និងអធិស្ឋានសំរាប់គោលបំណងជាក់លាក់។ ការតមអាហារ គឺជាការសំងាត់ផ្ទាល់ខ្លួន និងខាងវិញ្ញាណ ហើយ យើងមិនគួរបន្ថែមការយកចិត្តទុកដាក់ចំពោះ ការពិតនៃការអាហារទេ។

សាសនាចបរិសុទ្ធ រួមបញ្ចូលទាំងការយកចិត្តទុកដាក់ចំពោះអ្នកក្រីក្រ។ យើងគឺដើម្បីជួយដល់ពួកគេឱ្យបំពេញសេចក្ដីត្រូវការខាងរាងកាយ និងខាងវិញ្ញាណ។ នៅពេលយើងតមអាហារ យើងបរិច្ចាគលុយកាក់ ទៅដល់សាសនាចក្រ សំរាប់យកចិត្តទុកដាក់ លើអ្នកក្រីក្រ និងអ្នកខ្វះខាត។ យើងហៅការណ៍នេះថា ដង្វាយតមអាហារ។ យើងផ្ដល់លុយយ៉ាងហោចណាស់តាមតម្លៃ អាហារពីរពេល ដែលយើងសន្សំដោយការតមអាហារ។ ទោះជាយ៉ាងណាក៏ដោយ យើងមិនត្រូវការកំណត់ ទៅលើការបរិច្ចាគ របស់យើងចំពោះតម្លៃអាហារពីរពេលនោះទេ។ យើងត្រូវបានលើកទឹកចិត្តឱ្យមានចិត្តសទ្ធា តាមដែលមធ្យោបាយរបស់យើង អនុញ្ញាតឱ្យ។ ដោយការខ្វល់ចំពោះអ្នកក្រីក្រ យើងជួយបំពេញតាមសេចក្ដីសញ្ញាបុណ្យជ្រមុជទឹករបស់យើង ហើយរក្សានូវការ អត់ទោសចំពោះ យើងពី អំពើបាបរបស់យើង។

### ការសិក្សាព្រះគម្ពីរ

**ការតមអាហារ**

| | | |
|---|---|---|
| អោមណៃ 1:26 | អាលម៉ា 17:2–3 | គ និងស 88:76 |
| អាលម៉ា 5:45–46 | មូរ៉ូណៃ 6:5 | ម៉ាថាយ 6:1–4, 16–18 |
| អាលម៉ា 6:6 | គ និងស 59:12–16 | អេសាយ 58:6–11 |

**យកចិត្តទុកដាក់ដល់អ្នកក្រីក្រ**

| | | |
|---|---|---|
| ម៉ូសាយ 4:16–27 | អាលម៉ា 4:12–13 | យ៉ាកុប 1:27 |
| ម៉ូសាយ 18:8–10 | ម៉ាថាយ 25:34–46 | អេសាយ 58:3–12 |

### ការតាំងចិត្ត

- តើអ្នកព្រមតមអាហារ និងអធិស្ឋាននៅថ្ងៃអាទិត្យតមអាហារក្រោយនេះ សំរាប់សេចក្ដីត្រូវការជាក់លាក់ខ្លះៗដែរឬទេ?
- តើអ្នកព្រមបរិច្ចាគជាដង្វាយតមអាហារដោយសទ្ធា [បន្ទាប់ពីអ្នកបានទទួលបុណ្យជ្រមុជទឹក] ដែរឬទេ?

## របៀប ដើម្បីបរិច្ចាគដង្វាយមួយភាគក្នុងដប់ និងដង្វាយតមអាហារ

ដង្វាយមួយភាគក្នុងដប់ និងដង្វាយតមអាហារ គឺត្រូវបានបង់ដោយស្ម័គ្រចិត្ត និងដោយផ្ទាល់ខ្លួន។ សមាជិក អាចបង់ដង្វាយមួយភាគក្នុងដប់ និងដង្វាយតមអាហារនៅគ្រប់ពេល ប៉ុន្តែជាធម្មតា សំខាន់បំផុត ដើម្បីបង់ដង្វាយមួយភាគក្នុងដប់នៅលើចំណូលដែលទទួលបាន ហើយដង្វាយតមអាហារនៅថ្ងៃតមអាហារ។ សមាជិកធ្វើការបរិច្ចាគ ដោយការបំពេញក្រដាសបរិច្ចាគ ដែលទទួលបានមកពីគណៈប៊ីស្សប។ សមាជិករក្សាក្រដាសពណ៌លឿង រួចដាក់ក្រដាសពណ៌ស នៅក្នុងស្រោមសំបុត្របិទជិត ដែលបានផ្ដល់ឱ្យ។ ស្រោមសំបុត្រ ត្រូវបានផ្ដល់ដល់សមាជិកនៃគណៈប៊ីស្សបម្នាក់។ ការបរិច្ចាគទាំងនេះ គឺចាត់ជាពិសិដ្ឋ ហើយជាកម្មសិទ្ធិរបស់ព្រះអម្ចាស់។ សមាជិកនៃគណៈប៊ីស្សបម្នាក់ និងស្មៀនម្នាក់រក្សាទុកដោយប្រុងប្រយ័ត្ន និងដោយសម្ងាត់ នៅរាល់ការបរិច្ចាគទាំងអស់។

មេរៀនទី 4៖
បទបញ្ញត្តិ

កំណត់ចំណាំ

សមាជិកចូលរួមនៅក្នុងការផ្ទៀងផ្ទាត់ដង្វាយមួយភាគក្នុងដប់ជាមួយនឹងប៊ីស្សប នៅចុងឆ្នាំនីមួយៗ ដើម្បីអះអាងអំពីដង្វាយមួយភាគក្នុងដប់ស្មោះត្រង់របស់ពួកគេ។ នៅក្នុងការប្រជុំដោយឯកជននេះ សមាជិកទទួលបានរបាយការណ៍ចុងឆ្នាំនៃគ្រប់ការបរិច្ចាគរបស់ពួកគេ។ រាល់ពត៌មានអំពីថវិការ ត្រូវបានរក្សាទុកដោយសម្ងាត់បំផុត។

## បង្រៀនពីរបៀប ដើម្បីបរិច្ចាគដង្វាយមួយភាគក្នុងដប់ និងដង្វាយតមអាហារ

ចូរបង្ហាញទំរង់ការបរិច្ចាគមួយ រួចពន្យល់ពីរបៀបប្រើទំរង់។ បន្ទាប់ពីអ្នកផ្លាស់សាសនា បានទទួលបុណ្យជ្រមុជទឹក អ្នកត្រូវការជួយពួកគេបំពេញទំរង់នោះ។

# ប្រតិបត្តិ និងគោរពច្បាប់

ពួកបរិសុទ្ធថ្ងៃចុងក្រោយ នៅគ្រប់កន្លែងជឿនៅក្នុងការគោរពតាមច្បាប់ទាំងឡាយរបស់ប្រទេស ដែលពួកគេរស់នៅ។ សមាជិកនៃសាសនាចក្រ ត្រូវបានប្រឹក្សាឱ្យធ្វើជាប្រជាជនល្អ ឱ្យចូលរួមនៅក្នុងរដ្ឋាភិបាលស៊ីវិល និងបែបនយោបាយ និងផ្តល់ឱ្យការបំរើដល់សមាគមន៍។ ទោះជាយ៉ាងណាក៏ដោយ ពួកគេធ្វើដូច្នោះ គឺក្នុងនាមជាប្រជាជន មិនមែនជាតំណាងឱ្យ សាសនាចក្រទេ។

## ការសិក្សាព្រះគម្ពីរ

| | | |
|---|---|---|
| គ និង ស 58៖21 | គ និង ស 130៖20–21 | មាត្រា នៃសេចក្តីជំនឿ1៖12 |
| គ និង ស 98៖5 | គ និង ស 134 | |

## ការតាំងចិត្ត

- តើអ្នកព្រមគោរពតាមច្បាប់របស់ប្រទេស ដែលអ្នករស់នៅដែរឬទេ?

### សំនួរសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក ដែលអនុវត្ត

- តើអ្នកធ្លាប់ប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែរឬទេ? បើដូច្នោះ តើអ្នកសព្វថ្ងៃនៅក្នុងការពិសោធន៍មើល ឬដោះលែង? [កំណត់ចំណាំ៖ មនុស្សម្នាក់ដែលឆ្លើយបាទ ចំពោះសំនួរទាំងនេះ ត្រូវតែធ្វើការសម្ភាសន៍ ដោយប្រធានបេសកកម្ម មុនពេលធ្វើបុណ្យជ្រមុជទឹក។]

## សកម្មភាព

ចំពោះបទបញ្ញត្តិនីមួយៗនៅក្នុងមេរៀននេះ ចូរធ្វើបញ្ជីសេចក្តីសន្យាក្នុងព្រះគម្ពីរ ដែលព្រះអម្ចាស់បានធ្វើចំពោះអ្នកទាំងឡាយណាដែលរក្សាបទបញ្ញត្តិ។ ចូរកត់ត្រានៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សានូវសេចក្តីសន្យា ដែលបានដឹង នៅក្នុងជីវិតរស់នៅរបស់អ្នក។

កំណត់ចំណាំ

# ច្បាប់ និងពិធីការទាំងឡាយ

*បន្ទាប់ពីពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់*



© 1998 Del Parson។

## រៀបចំ ដើម្បីបង្រៀន

បន្ទាប់ពីអ្នកផ្លាស់សាសនា ទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ អ្នកដឹកនាំក្នុងវួដ ត្រូវកំណត់ថា តើអ្នកផ្សព្វផ្សាយសាសនាក្នុងវួដ ឬអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ជាអ្នកដឹកនាំក្នុងការបង្រៀន ហើយមានរយៈពេលប៉ុន្មាន ដែលអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ត្រូវចូលរួមជាមួយនោះ។ មេរៀននេះ គួរតែបង្រៀនដល់សមាជិកថ្មីឱ្យបានឆាប់រហ័ស បន្ទាប់ពីពួកគេទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។ អ្នកអាចចាប់ផ្ដើមបង្រៀនពួកគេអំពីច្បាប់ និងពិធីការទាំងឡាយរវាងពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ឬ សូម្បីតែមុនពេលពួកគេធ្វើបុណ្យជ្រមុជទឹក។ អ្នកដែលទទួលបុណ្យជ្រមុជទឹក យ៉ាងហោចណាស់គួរតែដឹងអំពីច្បាប់ និងពិធីការ ទាំងនេះ មុនពេលពិធីបុណ្យជ្រមុជទឹក។

មេរៀននេះ ស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងមេរៀនទី4។ ការជួបបង្រៀន អ្នកគួរតែកំណត់តាមសេចក្ដីត្រូវការរបស់អ្នកផ្លាស់សាសនាថ្មី ហើយដឹកនាំមកពីព្រះវិញ្ញាណ។ ចូរគិត និងអធិស្ឋានជានិច្ចអំពីរបៀប ដើម្បីជួយអ្នកផ្លាស់សាសនាថ្មីឱ្យរស់នៅតាមដំណឹងល្អ។ គំនិតរួមមានដូចខាងក្រោមៈ

- បង្រៀនសមាជិកថ្មីអំពីច្បាប់ និងពិធីការនីមួយៗមកពីមេរៀននេះ នៅពេលធ្វើការរំលឹកអំពីមេរៀន “សារលិខិត នៃការស្ដារឡើងវិញ” “ផែនការនៃសេចក្ដីសង្គ្រោះ” និង“ដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ”។ ឧទាហរណ៍ នៅពេលធ្វើការរំលឹកសារលិខិត នៃការសាងឡើងវិញ អ្នកអាចចង់បង្រៀនអំពីបព្វជិតភាព និងកិច្ចការផ្សព្វផ្សាយសាសនា នៅពេលរំលឹកអំពី ផែនការនៃសេចក្ដីសង្គ្រោះ អ្នកអាចបង្រៀនអំពីអាពាហ៍ពិពាហ៍ដ៏អស់កល្បជានិច្ច ព្រះវិហារបរិសុទ្ធ និងកិច្ចការពង្សប្រវត្តិ និងការបង្រៀន និងការរៀន នៅក្នុងសាសនាចក្រ។ នៅពេលរំលឹកអំពីដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ អ្នកអាចចង់បង្រៀនអំពីផ្លូវតូច និងត្រង់ចង្អៀត និងការបំរើនៅក្នុងសាសនាចក្រ។
- បង្រៀនច្បាប់ពីរ ឬបី និងពិធីការទាំងឡាយជាមេរៀនតែមួយ។
- បង្រៀនច្បាប់ ឬពិធីការមួយ ជាមេរៀនមួយ។

ធ្វើការជាមួយនឹងសមាជិក ដើម្បីជួយសមាជិកថ្មីទទួលយក និងចាប់ផ្ដើមរស់នៅតាមច្បាប់ និងពិធីការទាំងនេះ។ សូមជួយសមាជិកថ្មីយល់ថា ដោយការរក្សាតាមច្បាប់របស់ព្រះ ពួកគេនឹងទទួលការរំដោះបាបរបស់ពួកគេ ហើយស្ថិតនៅ លើផ្លូវឆ្ពោះទៅរកជីវិតអស់កល្បជានិច្ច។ ពួកគេនឹងមានបទពិសោធន៍នៃសន្តិភាព និងសេចក្ដីអំណរកាន់តែល្អប្រសើរជាង។ ពួកគេ នឹងរកឃើញចំលើយចំពោះសំនួរនៅក្នុងជីវិត និងសន្តិសុខនៅចំណេះដឹង ដែលថា ពួកគេជាសមាជិកនៃសាសនាចក្រពិត នៃព្រះយេស៊ូវគ្រីស្ទ។ ច្បាប់ និងពិធីការទាំងឡាយ បំរើជាការដឹកនាំសំរាប់ការរស់នៅដែលពោរពេញដោយអំណរ ជាមួយនឹង ជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ និងសេចក្ដីសង្ឃឹមមុតមាំមួយ នៃការទទួលជីវិតដ៏អស់កល្បជានិច្ច ជាមួយព្រះវរបិតារបស់យើងនៅក្នុងស្ថានសួគ៌។

កំណត់ចំណាំ

## រៀនអំពីច្បាប់ ពិធីការទាំងឡាយ និងការតាំងចិត្ត

នៅពេលអ្នកសិក្សាអំពី "ច្បាប់ និងពិធីការទាំងឡាយ" គឺជាជំនួយដ៏ប្រសើរ ដើម្បីធ្វើតាមគំរូដូចខាងក្រោម។

- សិក្សាវគ្គ ដែលពិពណ៌នាអំពីគោលលទ្ធិ ហើយសរសេរផែនការមេរៀនសមញ្ញមួយជាមួយនឹងចំណុចសំខាន់ពីបី ទៅប្រាំចំណុច។
- បង្រៀនកំណែថ្មីរយៈពេលពីរ ឬបីនាទី ទៅកាន់ដៃគូរបស់អ្នក។ អនុវត្តន៍ ថាតើអ្នកព្រមធ្វើការពង្រីកការ អញ្ជើញឱ្យធ្វើការតាំងចិត្ត ដោយរបៀបណា ហើយអ្នកនឹងដោះស្រាយកង្វល់ដោយរបៀបណា។
- ពិភាក្សាអំពីវិធីដែលមានប្រសិទ្ធភាព ដើម្បីធ្វើតាមការតាំងចិត្តនីមួយៗ ដែលអ្នកផ្លាស់សាសនាថ្មីបានទទួលយក។

## បព្វជិតភាព និងអង្គការជំនួយ

បព្វជិតភាព គឺជាអំណាច និងសិទ្ធិអំណាច ដែលផ្ដល់ឱ្យបុរស ដើម្បីធ្វើកិច្ចការនៅក្នុងព្រះនាមរបស់ព្រះ សំរាប់សេចក្ដីសង្គ្រោះនៃកូនចៅរបស់ទ្រង់។ តាមរយៈបព្វជិតភាពយើងទទួលពិធីការនៃសេចក្ដីសង្គ្រោះ ក៏ដូចជាពរជ័យ នៃការព្យាបាល កំសាន្តចិត្ត និងតំបូន្មាន។

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺដឹកនាំដោយព្រះយេស៊ូវគ្រីស្ទ តាមរយៈសាវក និងព្យាការី។ អ្នកទាំងនេះ គឺជាបុរសសុចរិត ដែលត្រូវបានហៅដោយព្រះអម្ចាស់ និងត្រូវបានផ្ដល់ឱ្យបព្វជិតភាព។ កាលពីបុរាណ ព្រះគ្រីស្ទ តែងតាំងសាវករបស់ទ្រង់ និងផ្ដល់ដល់ពួកគេនូវបព្វជិតភាព។ សិទ្ធិអំណាចនោះ ត្រូវបានបាត់បង់ នៅពេលមនុស្សបដិសេធ ដំណឹងល្អ ហើយសំលាប់ព្រះគ្រីស្ទ និងសាវក។

សិទ្ធិអំណាចបព្វជិតភាព ត្រូវបានសាងឡើងវិញនៅក្នុងឆ្នាំ 1829 នៅពេលយ៉ូហាន បាទីស្ទមកជួបព្យាការីយ៉ូសែប ស៊្មីធ និងអូលីវើរ ខៅឌើរី។ លោកដាក់ដៃរបស់លោកនៅលើក្បាលពួកគេប្រគល់ដល់ពួកគេនូវបព្វជិតភាពអើរ៉ុន (សូមមើល គ និង ស 13)។ ក្នុងពេលបន្តិចក្រោយមក លោកពេត្រុស យ៉ាកុប និងយ៉ូហាន ដែលជាសាវកដប់ពីរនាក់ពីដំបូង ដាក់ដៃពួកគេលើយ៉ូសែប ស៊្មីធ និងអូលីវើរ ខៅឌើរី ហើយប្រគល់ដល់ពួកគេនូវបព្វជិតភាពមិលគីស្សាដែក ដែលពេត្រុស យ៉ាកុប យ៉ូហាន បានទទួលមកពី ព្រះយេស៊ូវគ្រីស្ទ (សូមមើល គ និង ស 27:12–13)។

បុរសម្នាក់អាចទទួលសិទ្ធិអំណាចបព្វជិតភាព បានតាមការតែងតាំងដោយត្រឹមត្រូវតែប៉ុណ្ណោះ ដោយការដាក់ដៃដោយម្នាក់ដែលមានសិទ្ធិអំណាច។ បុរសម្នាក់ ដែលទទួលបព្វជិតភាព គឺត្រូវបានផ្ដល់ឱកាសដ៏មហិមាមួយ។ គាត់ចូលនៅក្នុងសេចក្ដីសញ្ញា ដើម្បីបំពេញកាតព្វកិច្ចដ៏ពិសិដ្ឋ បំរើអ្នកដទៃ និងជួយស្ថាបនាសាសនាចក្រ។ គាត់ត្រូវតែមានបំណង ដើម្បីបំរើព្រះ ហើយត្រូវតែ តែងតាំងដោយអំណាចនេះ (សូមមើល គ និង ស4:3, 63:57)។ វាក៏ជាការចាំបាច់ផងដែរសំរាប់អ្នកកាន់បព្វជិតភាព ដើម្បីធ្វើពិធីការពិសិដ្ឋ ដូចជា ពិធីបុណ្យជ្រមុជទឹក និងពិធីការបញ្ជាក់។ នៅពេលសិទ្ធិអំណាចបព្វជិតភាពត្រូវបានប្រើដោយ សក្ដិសម អំណាចនៃព្រះត្រូវបានបង្ហាញ។ អំណាចបព្វជិតភាពអាចប្រើបានតែនៅក្នុងសេចក្ដីសុចរិត សេចក្ដីស្រឡាញ់ និងសេចក្ដីអត់ធ្មត់ប៉ុណ្ណោះ។

បព្វជិតភាពទាំងអស់មកពីព្រះ។ មានបព្វជិតភាពចែកចេញជាពីរនៅក្នុងសាសនាចក្រៈ បព្វជិតភាពអើរ៉ុន និងបព្វជិតភាពមិលគីស្សាដែក។ បព្វជិតភាពអើរ៉ុនធ្វើពិធីការដូចជា ពិធីបុណ្យជ្រមុជទឹក និងការប្រសិទ្ធិពរនំបុ័ង និងទឹក។ មនុស្សប្រុស ដែលមានភាពសក្ដិសមអាយុ 12 ឆ្នាំ និងច្រើនជាង ទទួលបព្វជិតភាពអើរ៉ុនភ្លាមបន្ទាប់ពីពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។

មនុស្សប្រុសជំទង់ ដែលមានភាពសក្ដិសម នឹងទទួលបព្វជិតភាពមិលគីស្សាដែក ឬបព្វជិតដែលខ្ពស់ជាង។ សមាជិកនៃសាសនាចក្រទទួលពរជ័យ ខាងវិញ្ញាណ និងខាងរាងកាយជាច្រើន តាមរយៈអំណាចនៃបព្វជិតភាពនេះ។ អ្នកកាន់បព្វជិតភាពមិលគីស្សាដែក ដែលសក្ដិសមអាចផ្ដល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ តែងតាំងអ្នកផ្សេងទៀតនូវបព្វជិតភាព ដូចបានចាត់ តាំងចាក់ប្រេងតាំងអ្នកឈឺជាមួយនឹងប្រេងឧទ្ទិស និងផ្ដល់ពរជ័យនៃការព្យាបាល និងកំសាន្តចិត្ត។ ស្វាមី និងឪពុកដែលមាន ភាពសក្ដិសមដែលកាន់បព្វជិតភាពមិលគីស្សាដែក អាចផ្ដល់ឱ្យប្រពន្ធ កូន នៃសមាជិកគ្រួសារដទៃទៀតនូវពរជ័យពិសេស។ គ្រូបង្រៀនតាមផ្ទះ សួរសុខទុក្ខតាមផ្ទះ នៃសមាជិកសាសនាចក្រ និងបារម្ភចំពោះបុគ្គលម្នាក់ៗ និងគ្រួសារទាំងនោះ។ ប៊ីស្សប និងប្រធានស្ដេក ត្រូវវិនិច្ឆ័យនៅក្នុងសាសនាចក្រ។ ពួកគេមានសិទ្ធិអំណាចដើម្បីជួយពួកបរិសុទ្ធដែលមានអំពើបាបឱ្យប្រែចិត្ត និងរីករាយជាមួយពរជ័យពេញលេញនៃភាពជាសមាជិកសាសនាចក្រ។ ពួកគេសម្ភាសន៍អ្នកទាំងឡាយ ដើម្បីឱ្យប្រាកដ អំពីភាពសក្ដិសមរបស់ពួកគេ ដើម្បីចូលរួមក្នុងព្រះវិហារបរិសុទ្ធ។

នៅក្រោមការដឹកនាំបព្វជិតភាព អង្គការជំនួយ ជួយនៅក្នុងការពង្រឹងសមាជិក។ អង្គការទាំងនេះ គឺជាធនធានដ៏រឹងមាំនៅក្នុងកិច្ចការអ្នកផ្សព្វផ្សាយសាសនា នៅពេលដែលអង្គការទាំងនេះជួយនៅក្នុងការស្វែងរក និងបង្រៀនដល់សាសនាគន់ការី និង រាប់អានជាមួយនឹង អ្នកផ្លាស់សាសនាថ្មី។ ស្ត្រីអាយុ 18 ឆ្នាំ និងច្រើជាង គឺជាសមាជិកនៃស្ត្រីសង្គ្រោះ ដែលជួយនៅក្នុងការបំរើ ដល់ក្រុមគ្រួសារ បុគ្គលម្នាក់ៗ និងសហគមន៍។ យុវនារី មានអាយុពី 12 ទៅ 18 ឆ្នាំ គឺជាសមាជិកនៃកម្មវិធីយុវនារី។ ក្មេងប្រុស ដែលមាន

កំណត់ចំណាំ

អាយុ ស្រដៀងគ្នានេះចូលរួមនៅក្នុងកម្មវិធីយុវជន។ រាល់កុមារដែលមានអាយុពី 3 ឆ្នាំ ទៅ11 ឆ្នាំ គឺជាផ្នែក នៃអង្គការបឋមសិក្សា។ សមាជិកទាំងអស់ ដែលមានអាយុ 12 ឆ្នាំ និងច្រើនជាង ត្រូវចុះឈ្មោះចូលទៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យ។

### ការសិក្សាព្រះគម្ពីរ

| | | |
|---|---|---|
| ម៉ូសាយ 18:17 | គ និង ស 84:19–20 | លូកា 9:1–6 |
| អាលម៉ា 13:1–19 | គ និង ស 107 | យ៉ូហាន 15:16 |
| គ និង ស 20:38–65 | គ និង ស 121:34–46 | យ៉ាកុប 5:14–15 |

### ការតាំងចិត្ត

- តើអ្នកព្រមរៀបចំ ដើម្បីទទួលបព្វជិតភាពអើរ៉ុន (បុរសមានអាយុ12 ឆ្នាំ និងច្រើនជាង ដែលមានភាពសក្តិសម អាចជ្រើសតាំងបាន)ដែរឬទេ?
- តើអ្នកព្រមរៀបចំ ដើម្បីទទួលបព្វជិតភាពម៉ិលគីស្សាដែក (បុរសជំទង់ ដែលមានភាពសក្តិសម អាចជ្រើសតាំងបាន)ដែរឬទេ?
- តើអ្នកព្រមចូលរួមដោយសកម្មនៅក្នុងអង្គការជំនួយដែលសមរម្យដែរឬទេ?

## កិច្ចការផ្សព្វផ្សាយសាសនា

សមាជិក ដែលចែកចាយបទពិសោធន៍សេចក្តីអំណរនៃដំណឹងល្អ និងមានព្រះវិញ្ញាណ នៃព្រះអម្ចាស់កាន់តែច្រើនបរិបូណ៌។ នៅពេលយើងចែកចាយដំណឹងល្អ យើងមានអំណរគុណអំពីតម្លៃ និងអត្ថន័យ ដែលដំណឹងល្អមានចំពោះយើង ហើយយើងមាន អារម្មណ៍សេចក្តីស្រឡាញ់កាន់តែច្រើនចំពោះព្រះ និងអ្នកដទៃ។ ព្រះអម្ចាស់បញ្ជាដល់អ្នកដើរតាមទ្រង់ឱ្យប្រកាសដំណឹងល្អ នៅក្នុងពិភពលោកទាំងមូល ដោយផ្តល់ឱកាសដល់មនុស្សគ្រប់រូបដើម្បីទទួលយក ឬបដិសេធដំណឹងល្អ។ នៅពេលមនុស្ស ទទួល បុណ្យជ្រមុជទឹក ពួកគេធ្វើសេចក្តីសញ្ញាមួយ ដើម្បីឈរធ្វើជាសាក្សីនៃព្រះជានិច្ច។ ពួកគេត្រូវបានបញ្ជាឱ្យចែកចាយដំណឹងល្អ ជាមួយអ្នកទាំងឡាយណា ដែលមិនទាន់ទទួលដំណឹងល្អនៅឡើយ។ នៅពេលពួកគេរស់នៅតាមដំណឹងល្អដោយស្មោះត្រង់ ពួកគេ នឹងធ្វើជាគំរូមួយ ដោយបង្ហាញដល់សមាជិកគ្រួសារ និងមិត្តភក្តិរបស់ពួកគេនូវពរជ័យដ៏អស្ចារ្យ ដែលបានមកពីការរស់នៅតាម ដំណឹងល្អ។ ពួកគេគួរតែទាញយកឱកាសផងដែរ ដើម្បីឆ្លើយសំនួរ ចែកចាយកូនសៀវភៅ សម្ភារៈសោតទស្សន៍ ហើយអញ្ជើញអ្នកដទៃ ឱ្យរៀនកាន់តែច្រើនអំពីសារលិខិតដំណឹងល្អ ដែលបានស្តារឡើងវិញ។ សមាជិកគួរតែអធិស្ឋាន សំរាប់អ្នកទាំងឡាយណា ដែលមិនមែនជាសមាជិកនៃសាសនាចក្រ។ ពួកគេគួរតែអធិស្ឋានសំរាប់ឱកាសអ្នកផ្សព្វផ្សាយសាសនា—ដើម្បីបំរើអ្នកទាំងឡាយ ដែលមិនមានសេចក្តីជំនឿរបស់យើង ហើយចែកចាយអំពីអ្វី ដែលពួកគេជឿ។ ព្រះអម្ចាស់សន្យាថា នឹងជួយដល់សមាជិកឱ្យដឹងនូវ អ្វី ដែលពួកគេគួរនិយាយ និងធ្វើ នៅពេលពួកគេចែកចាយដំណឹងល្អ។

### ការសិក្សាព្រះគម្ពីរ

| | | |
|---|---|---|
| យ៉ាកុប 5:70–75 | គ និង ស 19:29 | គ និង ស 84:74–76, 88 |
| ម៉ូសាយ 28:3 | គ និង ស 33:8–11 | គ និង ស 88:81 |
| គ និង ស 18:10–16 | គ និង ស 38:40–42 | គ និង ស 100:5–8 |

### ការតាំងចិត្ត

- តើអ្នកព្រមរៀបចំអញ្ជើញមិត្តភក្តិ និងសាច់ញាតិ ដែលមិនមែនជាសមាជិកនៃសាសនាចក្រឱ្យជួបជាមួយ អ្នកផ្សព្វផ្សាយសាសនា ដើម្បីបង្រៀនដំណឹងល្អដែរឬទេ?
- តើអ្នកព្រមអធិស្ឋានសំរាប់អ្នកផ្សព្វផ្សាយសាសនា និងសំរាប់ឱកាស ដើម្បីចែកចាយដំណឹងល្អដែរឬទេ?
- តើអ្នកព្រមរៀបចំដើម្បីបំរើបេសកកម្មដែរឬទេ?

កំណត់ចំណាំ

## អាពាហ៍ពិពាហ៍ដ៏អស់កល្បជានិច្ច

មូលដ្ឋានគ្រឹះនៃសាសនាចក្រ គឺគ្រួសារ។ នៅក្នុងរង្វង់គ្រួសារ មនុស្សមានបទពិសោធន៍ជាច្រើនអំពីសេចក្ដីអំណរ និងទុក្ខព្រួយដ៏ធំបំផុតក្នុងជីវិត។ អាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី គឺត្រូវបានតែងតាំងឡើងដោយព្រះ ហើយគឺជាផ្នែកដ៏សំខាន់ ក្នុងផែនការក៏អស់កល្បជានិច្ចរបស់ព្រះ សំរាប់សេចក្ដីសង្គ្រោះនៃកូនចៅរបស់ទ្រង់។ អត្ថន័យនៃជីវិតរមែងស្លាប់ គឺត្រូវបានបង្កើត គឺត្រូវបានតាំងដោយទេវភាព និងត្រូវបានការពារដោយអាពាហ៍ពិពាហ៍។ ផែនការនៃសុភមង្គលដ៏ទេវភាព អាចធ្វើឱ្យទំនាក់ទំនងគ្រួសារ កាន់ខ្ជាប់បន្ទាប់ពីសេចក្ដីស្លាប់ខាងរាងកាយ។ ទោះជាយ៉ាងណាក៏ដោយ អាពាហ៍ពិពាហ៍ អាចជាភាព អស់កល្បជានិច្ច តែប៉ុណ្ណោះ នៅពេលត្រូវបានអនុញ្ញាតដោយអ្នកកាន់បព្វជិតភាព ធ្វើពិធីការផ្សាភ្ជាប់ នៅក្នុងព្រះវិហារបរិសុទ្ធ ដ៏ពិសិដ្ឋ ហើយនៅពេលស្វាមី និងភរិយា ដែលបានធ្វើការផ្សារភ្ជាប់ជាមួយគ្នា ត្រូវរក្សាសេចក្ដីសញ្ញាទាំងឡាយ ដែលពួកគេបាន ធ្វើ។ ស្វាមី និងភរិយា ត្រូវស្រឡាញ់គ្នាទៅវិញទៅមក។ នៅពេលពួកគេរក្សាបទបញ្ញត្តិ និងរស់នៅតាមគោលការណ៍ នៃដំណឹងល្អ ពួកគេត្រូវគោរពតាមសច្ចាជាប្ដីប្រពន្ធរបស់ពួកគេដោយស្មោះត្រង់ទាំងស្រុង (សូមមើល“គ្រួសារៈ សេចក្ដីប្រកាសដល់ពិភពលោក” *Ensign*, ខែវិច្ឆិកា ឆ្នាំ 1995, 102 សូមមើល គ និងស 42:22 ផងដែរ)។

សុភមង្គលនៅក្នុងជីវិតគ្រួសារ អាចសំរេចបានយ៉ាងល្អបំផុត នៅពេលត្រូវបានធ្វើតាមការបង្រៀននៃព្រះយេស៊ូវគ្រីស្ទ និងនៅពេលឪពុកម្ដាយធ្វើឱ្យគ្រួសាររបស់ពួកគេមានឯកសិទ្ធិខ្ពស់បំផុត។ “តាមគំរោងការណ៍ព្រះ ឪពុកបានចាត់ឱ្យធ្វើប្រធានដឹកនាំ គ្រួសាររបស់ខ្លួនដោយសេចក្ដីស្រឡាញ់ និងសុចរិត ហើយមានភារកិច្ចក្នុងការផ្ដល់នូវសេចក្ដីត្រូវការក្នុងជីវិត ព្រមទាំងការពារគ្រួសារខ្លួនផង។ ម្ដាយមានភារកិច្ចទី1 ដើម្បីថែទាំបីបាច់កូនចៅរបស់ខ្លួន។ នៅក្នុងភារៈកិច្ច ដ៏ពិសិដ្ឋទាំងនេះ ឪពុក និងម្ដាយមានកាតព្វកិច្ច ដើម្បីជួយគ្នាទៅវិញទៅមកជាដៃគូស្មើគ្នា” (*Ensign*, ខែវិច្ឆិកា ឆ្នាំ1995, 102)។ ទាំងអស់គ្នា ឪពុកម្ដាយ គឺដើម្បីបង្រៀនកូនឰរបស់ពួកគេអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ហើយជួយពួកគេឱ្យរស់នៅតាមដំណឹងល្អ។

សាតាំង គឺកំពុងសញ្ជឹងគិត ដើម្បីវាយប្រហារទៅលើក្រុមគ្រួសារ។ ជាច្រើនឆ្នាំកន្លងទៅ អ្នកដឹកនាំសាសនាចក្រ បានតាំង ពេលល្ងាចថ្ងៃច័ន្ទ ជាពេលមួយសំរាប់ការប្រជុំរាត្រីក្រុមគ្រួសារ។ ឪពុកម្ដាយ គួរតែប្រើពេលនេះ ដើម្បីបង្រៀនដំណឹងល្អ ដល់កូនឰរបស់ពួកគេ ពង្រឹងទំនាក់ទំនងរបស់ពួកគេជាមួយនឹងកូនឰ និងសប្បាយជាមួយគ្នា។ មធ្យោបាយមួយផ្សេងទៀត នៃការពង្រឹងគ្រួសារ រួមមានការអធិស្ឋានជាគ្រួសារជាប្រចាំ និងសិក្សាព្រះគម្ពីរ ថ្វាយបង្គំនៅព្រះវិហារជាគ្រួសារ និងបំរើអ្នកដទៃ។ ស្ថានសួគ៌គឺជាការបន្តនៃគ្រួសារដ៏ឥតខ្ចោះ។ តាមរយៈពិធីការបព្វជិតភាព និងការរស់នៅសុចរិត យើងអាចរស់នៅជា ក្រុមគ្រួសារនៅក្នុងទីវត្តមានរបស់ព្រះដោយភាពអស់កល្បជានិច្ច។

### ការសិក្សាព្រះគម្ពីរ

**អាពាហ៍ពិពាហ៍**

| | | |
|---|---|---|
| គ និង ស 42:22 | គ និង ស 132:7 | “គ្រួសារៈ សេចក្ដីប្រកាសដល់ពិភពលោក” |
| គ និង ស 49:15 | លោកុប្បត្តិ 2:24 | |
| គ និង ស 131:1–4 | អេភេសូរ 5:25 | |

**គ្រួសារ**

| | | |
|---|---|---|
| ម៉ូសាយ 4:14–15 | គ និងស 130:2 | “គ្រួសារៈ សេចក្ដីប្រកាសដល់ពិភពលោក” |
| នីហ្វៃទី3 18:21 | ធីម៉ូថេទី1 5:8 | |

**បង្រៀនកូនឰ**

| | | |
|---|---|---|
| អាលម៉ា 56:47 | គ និងស 68:25–30 | អេភេសូរ 6:4 |
| អាលម៉ា 57:21 | ម៉ូសេ 6:55–62 | សុភាសិត 22:6 |

### ការតាំងចិត្ត

- តើអ្នកព្រមធ្វើការប្រជុំរាត្រីក្រុមគ្រួសាររាល់សប្ដាហ៍ អធិស្ឋានជាគ្រួសារជាប្រចាំ សិក្សាព្រះគម្ពីរជាគ្រួសារជាប្រចាំ និងសកម្មភាពគ្រួសារដទៃទៀតដែរឬទេ?
- តើអ្នកព្រមរៀបចំខ្លួន ដើម្បីចូលទៅព្រះវិហារបរិសុទ្ធ (1)ទទួលអំណោយទានពិសិដ្ឋរបស់អ្នកដែរឬទេ? (2) ព្រមរៀបអាពាហ៍ពិពាហ៍សំរាប់ជីវិតនេះ និងភាពអស់កល្បជានិច្ចដែរឬទេ? (3) បើរៀបអាពាហ៍ពិពាហ៍ អ្នកព្រមផ្សាភ្ជាប់ជាស្វាមី និងភរិយាសំរាប់ភាពអស់កល្បជានិច្ចដែរឬទេ? និង (4) ព្រមឱ្យកូនឰរបស់អ្នកផ្សាភ្ជាប់នឹងអ្នកដែរឬទេ?
- តើអ្នកព្រមថ្វាយបង្គំនៅថ្ងៃឈប់សំរាកជាគ្រួសារដែរឬទេ?
- តើអ្នកព្រមបំរើអ្នកដទៃដែរឬទេ?

កំណត់ចំណាំ

## ព្រះវិហារបរិសុទ្ធ និងពង្សប្រវត្តិ

ព្រះបានបញ្ជាដល់ប្រជាជនរបស់ទ្រង់ឱ្យស្ថាបនាព្រះវិហារបរិសុទ្ធ។ នៅក្នុងព្រះវិហារបរិសុទ្ធ យើងធ្វើសេចក្តីសញ្ញាពិសិដ្ឋ និងត្រូវបានទទួលអំណោយទានពិសិដ្ឋ ឬត្រូវបានផ្តល់អំណោយទាននៃអំណាច និងចំណេះដឹងមកពីទីខ្ពស់។ អំណាចនេះ ជួយយើងនៅក្នុងជីវិតជាប្រចាំ និងអាចឱ្យយើងស្ថាបនានគររបស់ព្រះ។ នៅក្នុងព្រះវិហារបរិសុទ្ធ យើងអាចរៀបអាពាហ៍ពិពាហ៍ សំរាប់ជីវិតនេះ និងភាពអស់កល្បជានិច្ច ដូច្នេះធ្វើឱ្យក្រុមគ្រួសារអាចនៅជាមួយគ្នាជានិច្ចតទៅនៅក្នុងទីវត្តមានរបស់ព្រះ។ បន្ទាប់ពីក្លាយជាសមាជិកភាពយ៉ាងតិចបានមួយឆ្នាំ យុវវ័យដែលមានភាពសក្តិសម អាចមានសិទ្ធិទទួលអនុសាសន៍មួយ មកពីប៊ីស្សុបរបស់ពួកគេ ដើម្បីទទួលអំណោយទានពិសិដ្ឋរបស់ពួកគេ។ បន្ទាប់ពីការទទួលអំណោយទានពិសិដ្ឋរបស់ ពួកគេមក គូរស្វាមីភរិយាអាចផ្សាភ្ជាប់ ឬរៀបការសំរាប់ភាពអស់កល្បជានិច្ច។

ព្រះអង្គសង្គ្រោះស្រលាញ់មនុស្សទាំងអស់ ហើយមានព្រះទ័យចង់ឱ្យសេចក្តីសង្គ្រោះដល់ពួកគេ។ តែមានមនុស្សរាប់លាននាក់បានស្លាប់ទៅហើយ ដោយគ្មានឱកាសដើម្បីស្តាប់សារលិខិតនៃដំណឹងល្អ ដែលបានស្តារឡើងវិញ នៃព្រះយេស៊ូវគ្រីស្ទ ឬទទួលពិធីការនៃសេចក្តីសង្គ្រោះ។ តាមរយៈព្រះគុណសេចក្តីស្រឡាញ់របស់ទ្រង់ និងមេត្តាករុណា ព្រះអម្ចាស់បានធ្វើឱ្យសេចក្តីសង្គ្រោះមានសំរាប់មនុស្សគ្រប់រូប ដែលមិនមានឱកាសដើម្បីទទួលយល់ដឹង និងគោរពតាមដំណឹងល្អ អំឡុងពេលនៃជីវិតរស់នៅ របស់ពួក គេ។ ដំណឹងល្អ ត្រូវបានប្រកាស ទៅដល់មនុស្សដែលបានស្លាប់ទាំងនោះនៅក្នុងពិភពវិញ្ញាណ។ សមាជិកនៃសាសនាចក្រ នៅលើផែនដីធ្វើពិធីការនៃសេចក្តីសង្គ្រោះ ជំនួសឱ្យជីដូនជីតារបស់ពួកគេ ដែលស្លាប់ទៅ និងអ្នកដទៃទៀត។ មនុស្សដែលស្លាប់ទៅ កំពុងរស់នៅក្នុងពិភពវិញ្ញាណ មានឱកាសដើម្បីទទួល ឬបដិសេធដំណឹងល្អ និងពិធីការ ដែលបានធ្វើឡើងជំនួសពួកគេ។

ចំពោះមូលហេតុនេះ សមាជិកនៃសាសនាចក្រ ស្រាវជ្រាវពត៌មានអំពីជីដូនជីតារបស់ពួកគេ។ ពួកគេបំពេញតារាងពង្សាវលី និងបញ្ជីប្រវត្តិក្រុមគ្រួសារ រួចដាក់ឈ្មោះរបស់សាច់ញាតិដែលស្លាប់ទៅ ដែលត្រូវការមាន ពិធីការនៃសេចក្តីសង្គ្រោះ ធ្វើឡើងជំនួសពួកគេនៅក្នុងព្រះវិហារបរិសុទ្ធដ៏ពិសិដ្ឋ។ នេះគឺជាកិច្ចការពង្សប្រវត្តិ។ សមាជិកដែលមាន ភាពសក្តិសមអាយុ 12 ឆ្នាំ និងលើសពីនេះ រួមមានទាំងសមាជិកថ្មី អាចទទួលពីប៊ីស្សុបរបស់ពួកគេ នូវអនុសាសន៍មួយ ដើម្បីធ្វើពិធីបុណ្យជ្រមុជទឹក សំរាប់អ្នកស្លាប់។

### ពង្សប្រវត្តិ

អញ្ជើញសមាជិកថ្មីឱ្យជួបសមាជិកម្នាក់ ឬទៅទីតាំងមជ្ឈមណ្ឌលពង្សប្រវត្តិ (កន្លែងដែលអាចរកបាន) សំរាប់ណែនាំអំពីកិច្ចការ ពង្សប្រវត្តិ និងធនធានដែលអាចរកបានសំរាប់ពួកគេ។ សូមផ្តល់ដល់ពួកគេនូវឯកសារពង្សប្រវត្តិមួយច្បាប់។

### ការសិក្សាព្រះគម្ពីរ

| | | | |
|---|---|---|---|
| គ និង ស 43:16 | គ និង ស 128 | គ និង ស 138 | កូរិនថូសទី1 15:29 |
| គ និង ស 95:8–9 | គ និង ស 131 | ទំនុកដំកើង 65:4 | Brochure, *Welcome to the Family History* |
| គ និង ស 124:22–42 | គ និង ស 132 | ពេត្រុសទី1 3:18–21 | *Center* (សៀវភៅតូច *ស្វាគមន៍មកកាន់មជ្ឈមណ្ឌលពង្សប្រវត្តិ*) |

### ការតាំងចិត្ត

- តើអ្នកព្រមរៀបចំដើម្បីទទួលពិធីការព្រះវិហារបរិសុទ្ធដែរឬទេ? (ភ្លាមៗបន្ទាប់ពីពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ សមាជិកមានភាពសក្តិសម ដែលមានអាយុច្រើនជាង 12 ឆ្នាំ អាចទទួលអនុសាសន៍ ដើម្បីទៅព្រះវិហារបរិសុទ្ធ និងចូលរួម នៅក្នុងពិធីបុណ្យជ្រមុជទឹកសំរាប់អ្នកស្លាប់។)
- តើអ្នកព្រមចូលរួមនៅក្នុងកិច្ចការពង្សប្រវត្តិ និងដាក់ឈ្មោះរបស់ជីដូនជីតា ដើម្បីទទួលពិធីការជំនួសក្នុង ព្រះវិហារបរិសុទ្ធដែរឬទេ?

## ការបំរើ

ពរជ័យធំមួយ នៃពរជ័យទាំងឡាយរបស់សមាជិកភាពនៅក្នុងសាសនាចក្រ គឺឱកាសដើម្បីបំរើ។ នៅពេលយើងផ្តល់ការបំរើដោយសេចក្តីស្រឡាញ់ដល់អ្នកដទៃ គឺយើងកំពុងបំរើព្រះ។ នៅពេលយើងធ្វើបុណ្យជ្រមុជទឹក យើងធ្វើសេចក្តីសញ្ញា ថា ផ្តល់ការបំរើដូច្នេះ (សូមមើល ម៉ូសាយ 18:8–10)។ យើងបានដឹងអំពីសេចក្តីត្រូវការរបស់អ្នកដទៃ ខាងរាងកាយ និងខាងវិញ្ញាណ។ បន្ទាប់មកយើងផ្តល់ពេលវេលា ទេពកោសល្យ និងមធ្យោបាយរបស់យើង ដើម្បីបំពេញសេចក្តីត្រូវការរបស់ អ្នកទាំងនោះ។ យើងធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ដែលមកដើម្បីបំរើអ្នកដទៃ។ យើងត្រូវធ្វើអ្វី ដែលព្រះយេស៊ូវបានធ្វើ ហើយប្រែក្លាយដូចជាទ្រង់។

ក្នុងពេលភ្លាមៗ បន្ទាប់ពីពិធីបុណ្យជ្រមុជទឹក សមាជិកថ្មីទទួលមកពីអ្នកដឹកនាំបព្វជិតភាពនូវពរជ័យ នៃការទទួលខុសត្រូវមួយ ដើម្បីជួយនៅក្នុងសាសនាចក្រ។ នេះគឺសំដៅទៅលើមុខងារមួយ។ កិច្ចការទាំងអស់នៅក្នុងសាសនាចក្រ គឺជាការស្ម័គ្រចិត្ត។ គ្មាននរណាម្នាក់ត្រូវ

កំណត់ចំណាំ

បានបង់ថ្លៃសំរាប់ការបំរើដូចនេះទេ។ នៅពេលយើងទទួលមុខងារ យើងត្រូវបានគាំទ្រជាសាធារណៈនៅក្នុង ការប្រជុំសាសនាចក្រ ដើម្បីឱ្យសមាជិកដទៃទៀតអាចស្គាល់មុខងាររបស់យើង និងផ្តល់ការគាំទ្រ។ យើងធ្វើការតែងតាំងផងដែរ ដោយអ្នកដឹកនាំបព្វជិតភាពម្នាក់ និងផ្តល់ពរជ័យដាក់លាក់ ដើម្បីជួយយើងបំពេញមុខងាររបស់យើង។ សាសនាចក្រត្រូវការ ទេពកោសល្យ និងសមត្ថភាពរបស់សមាជិកគ្រប់រូប ដើម្បីបំពេញមុខងារផ្សេងៗយ៉ាងធំទូលាយ។ មុខងារទាំងអស់ មានសារៈសំខាន់ និងជួយស្ថាបនានគរនៃព្រះ។ យើងត្រូវបានទទួលមុខងារដូច្នេះ និងធ្វើការដោយឧស្សាហ៍ព្យាយាម ដើម្បីរៀន និងបំពេញកាតព្វកិច្ចរបស់យើង។ នៅពេលយើងធ្វើដូច្នេះ យើងរីកចំរើននៅក្នុងសេចក្តីជំនឿ អភិវឌ្ឍន៍ទេពកោសល្យថ្មី និងសមត្ថភាពបំរើអ្នកដទៃកាន់តែខ្លាំង និងទទួលពរជ័យផ្សេងទៀតយ៉ាងច្រើន។

អ្នកកាន់បព្វជិតភាព អាចត្រូវបានហៅឱ្យធ្វើជាគ្រូបង្រៀនតាមផ្ទះ។ គ្រូបង្រៀនតាមផ្ទះ ធ្វើការសួរសុខទុក្ខយ៉ាងហោចណាស់មួយខែម្តង របស់គ្រួសារសមាជិកដែលបានចាត់ឱ្យទៅ។ ពួកគេបង្រៀនដំណឹងល្អ គាំទ្រដល់ឪពុកម្តាយ ចិញ្ចឹមបីបាច់មិត្តភាព និងជួយក្រុមគ្រួសាររៀបចំទទួល និងរក្សាសេចក្តីសញ្ញាព្រះវិហារបរិសុទ្ធ។ គ្រូបង្រៀនសួរសុខទុក្ខ តំណាងឱ្យសមាគមសង្គ្រោះ ដោយការធ្វើការសួរសុខទុក្ខរាល់ខែជាមួយនឹងបងប្អូនស្រីពេញវ័យ ដូចដែលបានចាត់ឱ្យទៅ។

### ការសិក្សាព្រះគម្ពីរ

**សេចក្តីសប្បុរស**

| | | | |
|---|---|---|---|
| មរ៉ូណៃ 7:43–48 | គ និងស 88:125 | ម៉ាថាយ 22:36–40 | កូរិនថូសទី1 13:1–8 |

**យកចិត្តទុកដាក់នឹងអ្នកក្រីក្រ**

| | | | |
|---|---|---|---|
| ម៉ូសាយ 4:26 | អាលម៉ា 34:28–29 | គ និងស 52:40 | ម៉ាថាយ 25:40 |

**យើងត្រូវបំរើ**

| | | | |
|---|---|---|---|
| ម៉ូសាយ 2:17 | ម៉ូសាយ 18:8–10 | គ និងស 42:29 | គ និងស 107:99–100 |

### ការតាំងចិត្ត

- តើអ្នកព្រមទទួលយក និងបំពេញកាតព្វកិច្ចនៃមុខងារមួយ (រួមមានទាំងកិច្ចការជាគ្រូបង្រៀនតាមផ្ទះ ឬគ្រូសួរសុខទុក្ខតាមផ្ទះ)ដែរឬទេ?
- តើអ្នកព្រមគាំទ្រអ្នកដទៃនៅក្នុងមុខងាររបស់ពួកគេដែរឬទេ?

## ការបង្រៀន និងការរៀននៅក្នុងសាសនាចក្រ

សាសនាចក្រត្រូវបានរៀបចំឡើង ដើម្បីប្រទានពរជ័យ និងធ្វើឱ្យសមាជិកបានល្អឥតខ្ចោះ។ សាសនាចក្រ បានផ្តល់ឱកាស ដល់យើងដើម្បីបង្រៀនគ្នាទៅវិញទៅមកនូវដំណឹងល្អ រាប់អាន និងបំរើគ្នាទៅវិញទៅមក ហើយគាំទ្រគ្នា នៅក្នុងដំណើរស្វែងរក របស់យើងសំរាប់សេចក្តីសង្គ្រោះ។ នៅក្នុងគ្រួសារ និងតាមរយៈសាសនាចក្រ សមាជិកម្នាក់ៗ ត្រូវបានបង្រៀនគោលលទ្ធិ នៃដំណឹងល្អ។ នៅពេលសមាជិក ត្រូវបានហៅឱ្យទទួលការងារបង្រៀន ពួកគេត្រូវបានផ្តល់សម្ភារៈ និងជួយ ដើម្បីធ្វើឱ្យពួកគេបង្រៀនបានជោគជ័យ។

### ការសិក្សាព្រះគម្ពីរ

| | |
|---|---|
| គ និង ស 88:77–79 | អេភេសូរ 4:11–14 |

### ការតាំងចិត្ត

- តើអ្នកព្រមមកព្រះវិហារដែរឬទេ?

## ការស៊ូទ្រាំដល់ទីបំផុត

នៅពេលយើងបន្តរស់នៅតាមដំណឹងល្អ យើងលូតលាស់កាន់តែជិតព្រះវរបិតាសួគ៌របស់យើង។ យើងសប្បាយរីករាយ និងថ្លែងអំណរគុណកាន់តែច្រើនចំពោះដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ។ ក្រុមគ្រួសាររបស់យើង គឺខិតទៅជិតគ្នា។ យើងមានបទពិសោធន៍

អារម្មណ៍នៃសេចក្ដីស្រឡាញ់កាន់តែអស្ចារ្យ នៃសេចក្ដីអំណរ និងសន្តិភាព ដែលមានមកពីដង្វាយធួន។ ដួងចិត្តរបស់យើង ត្រូវបានផ្លាស់ប្ដូរ ហើយយើងរកបានសន្តិសុខនៅក្នុងការរស់នៅតាមដំណឹងល្អ ដែលបានស្ដារឡើងវិញ។

នៅពេលយើងបន្តអនុវត្តសេចក្ដីជំនឿនៅក្នុងព្រះគ្រីស្ទ ប្រែចិត្ត និងរំលឹកសេចក្ដីសញ្ញារបស់យើង យើងរីករាយបន្តតាមការណែនាំមកពីព្រះវិញ្ញាណបរិសុទ្ធ។ បើយើងស៊ូទ្រាំងដល់ទីបំផុតនៃជីវិតរស់នៅរបស់យើង នៅក្នុងការពិតចំពោះសេចក្ដីសញ្ញារបស់យើង យើងនឹងទទួលបានជីវិតដ៏អស់កល្បជានិច្ច។

សមាជិកមួយចំនួន មិនបានស៊ូទ្រាំដល់ទីបំផុត ឬបន្តនៅសកម្មបានពេញលេញទេ។ ទោះជាយ៉ាងណាក៏ដោយ ការស៊ូទ្រាំដល់ទីបំផុត គឺជាការទទួលខុសត្រូវផ្ទាល់ខ្លួន។ យើង“បង្ហើយសេចក្ដីសង្គ្រោះ [របស់យើង] ដោយផ្ទាល់” (ភីលីព 2៖12) ហើយយើងបំរើ និងស្រឡាញ់អ្នកទាំងឡាយណា ដែលសេចក្ដីជំនឿត្រូវបានធ្លាក់ចុះខ្សោយដោយសារការអសកម្ម។

## ការសិក្សាព្រះគម្ពីរ

| | | | |
|---|---|---|---|
| នីហ្វៃទី2 31៖20–21 | គ និងស 20៖37 | យ៉ូហាន 14៖15, 21 | ភីលីព 2៖12 |
| ម្ញ៉ូរ៉ូណៃ 6៖4 | មាត្រា នៃសេចក្ដីជំនឿ 1៖3 | អេភេសូរ 4៖11–14 | |

## ការតាំងចិត្ត

- តើអ្នកព្រមបន្តរស់នៅតាមដំណឹងល្អ ដោយការរក្សានូវសេចក្ដីសញ្ញាពិធីបុណ្យជ្រមុជទឹកអស់មួយជីវិតរបស់អ្នកដែរឬទេ?

កំណត់ចំណាំ

កំណត់ចំណាំ



# តើខ្ញុំអាចស្គាល់ ហើយយល់ពីព្រះវិញ្ញាណយ៉ាងដូចម្ដេច?

កំណត់ចំណាំ

**ចូរពិចារណាចំណុចនេះ**

- ហេតុអ្វីបានជាខ្ញុំ ត្រូវការទទួលវិវរណៈផ្ទាល់ខ្លួន?
- តើព្រះវិញ្ញាណបរិសុទ្ធជានរណា ហើយតើទ្រង់ធ្វើការដូចម្ដេច?
- ហេតុអ្វីខ្ញុំត្រូវតែអធិស្ឋាននៅក្នុងសេចក្ដីជំនឿ?
- តើតួនាទីរបស់ព្រះវិញ្ញាណ នៅក្នុងកិច្ចការអ្នកផ្សព្វផ្សាយសាសនា ជាអ្វី?
- តើខ្ញុំអាចស្គាល់ការបំផុសពីព្រះវិញ្ញាណ យ៉ាងដូចម្ដេច?

## វិវរណៈផ្ទាល់ខ្លួន

យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថាៈ “សេចក្ដីសង្គ្រោះមិនអាចមក ដោយគ្មានវិវរណៈទេ វាគ្មានប្រយោជន៍សំរាប់នរណាដែលបង្រៀនដោយគ្មានវិវរណៈ” (*History of the Church*, 3ៈ389)។ អ្នកនឹងទទួលជោគជ័យនៅក្នុងកិច្ចការរបស់អ្នក នៅពេល ដែលអ្នករៀនដើម្បីទទួលវិវរណៈ និងធ្វើតាមវិវរណៈផ្ទាល់ខ្លួន។ យ៉ូសែប ស្ម៊ីធ ក៏បានបង្រៀនផងដែរថា វិវរណៈគឺសំខាន់សំរាប់ការងារប្រចាំថ្ងៃរបស់អ្នកៈ “នេះគឺជាគោលការណ៍ ដែលអ្នកគ្រប់គ្រងនៃស្ថានសួគ៌ គឺត្រូវបានដឹកនាំ—ដោយវិវរណៈ ផ្លាស់ប្ដូរតាមកាលៈទេសៈ ដែលមនុស្សរបស់នគរស្ថានសួគ៌ត្រូវបានដឹកនាំ” (*History of the Church*, 5ៈ135)។

ព្រះស្រលាញ់អ្នក និងកូនចៅរបស់ទ្រង់ទាំងអស់។ ទ្រង់មានចិត្តខ្វល់ខ្វាយចង់ជួយអ្នក នៅក្នុងការប្រតិបត្តិ និងការប្រឈមមុខដ៏ពិបាកៗ។ អ្នកត្រូវបានសន្យា ទទួលការបំផុសគំនិតដើម្បីដឹងពីអ្វីដែលត្រូវធ្វើ និងត្រូវបានប្រទានអំណាចដើម្បីធ្វើ (សូមមើល គ និង ស 43ៈ15–16)។ ទ្រង់នឹងជួយអ្នក ពេលដែលអ្នកព្យាយាមដើម្បីស្គាល់ និងយល់ពីព្រះវិញ្ញាណ តាមរយៈការព្យាយាម សិក្សាព្រះគម្ពីរ។ ទ្រង់នឹងដឹកនាំអ្នក ទៅកាន់មនុស្សដែលនឹងទទួលសារដំណឹង នៃការស្ដារឡើងវិញ។ ទ្រង់នឹងប្រទានដល់អ្នក នូវអំណាច ដើម្បីបញ្ជូនសារដំណឹង និងដើម្បីថ្លែងពីព្រះគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់។ ទ្រង់នឹងបាចពរជ័យរបស់ទ្រង់មកលើអ្នក តាមរយៈអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។ ទ្រង់ប្រាប់ថា អ្នកត្រូវមានភាពសក្តិសម ចំពោះអំណោយទាន ដែលអ្នក ស្វែងរក និងគោះនេះ (សូមមើល គ និង ស 4ៈ7 ម៉ាថាយ 7ៈ7–8)។

យើងរស់នៅក្នុងសម័យដែលបានព្យាករដោយព្យាការីនៃព្រះគម្ពីរមរមន—សម័យដែលមនុស្សនឹង “ឈ្លោះប្រកែកគ្នា ហើយគេនឹងបង្រៀនអំពីចំណេះគេផ្ទាល់ តែមិនទទួលស្គាល់ព្រះវិញ្ញាណបរិសុទ្ធដែលបានប្រទានសំដីនោះទេ” (នីហ្វៃទី 2 28ៈ4 សូមមើលផងដែរ

កំណត់ចំណាំ

នីហ្វៃទី 3 29:6 មរ៉ូណៃ 9:7–8)។ ប៉ុន្តែមនុស្សជាច្រើនក៏ចង់ទទួលបានរឿងខាងវិញ្ញាណយ៉ាងខ្លាំងដែរ។ នៅពេលដែលអ្នករៀនដើម្បីទទួលវិវរណៈផ្ទាល់ខ្លួន អ្នកនឹងបង្រៀនជាមួយអំណាច និងសិទ្ធិអំណាច (សូមមើលអាលម៉ា 17:3) ព្រោះព្រះវិញ្ញាណបរិសុទ្ធផ្ដល់នូវអំណាចដល់អ្នកដើម្បីនិយាយ (សូមមើល នីហ្វៃទី 1 10:22)។

អ្នកត្រូវការស្វែងរក និងទទួលវិវរណៈផ្ទាល់ខ្លួន តាមរយៈវិវរណៈព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកជួយដល់មនុស្សឱ្យទទួលបុណ្យជ្រមុជទឹក និងទទួលពិធីបញ្ជាក់។ ចូរមានជំនឿថា អ្នកនឹងទទួលវិវរណៈផ្ទាល់ខ្លួន ដើម្បីដឹកនាំអ្នកពីមួយថ្ងៃទៅមួយថ្ងៃ។ ព្រះវិញ្ញាណបរិសុទ្ធ នឹងជួយអ្នក នៅក្នុងទិដ្ឋភាពកិច្ចការរបស់អ្នក។

### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

នៅក្នុងសេចក្ដីបញ្ចប់នៃសក្ខីភាពរបស់មរ៉ូណៃ លោកបានសរសេរ " ពាក្យពីរបីម៉ាត់ ជារបៀបទូន្មាន" (មរ៉ូណៃ 10:2)។ សូមអានមរ៉ូណៃ 10 ហើយសរសេរជាពាក្យពេជចន៍របស់អ្នកផ្ទាល់ ពីអ្វីដែលមរ៉ូណៃ ទូន្មានដល់អ្នកអានព្រះគម្ពីរមរមន ដើម្បីធ្វើ។ (*ទូន្មាន* មានន័យថា លើកទឹកចិត្ត ឬជម្រុញនរណាម្នាក់យ៉ាងខ្លាំង ឱ្យធ្វើអ្វីមួយ។)

## ពន្លឺនៃព្រះគ្រីស្ទ

មនុស្សគ្រប់រូប អាចទទួលការណែនាំពីព្រះវិញ្ញាណពីមុនទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។ ឥទ្ធិពលនៃព្រះវិញ្ញាណនេះចាប់ផ្ដើមជាមួយនឹងពន្លឺនៃព្រះគ្រីស្ទ ដែល "ត្រូវបានប្រទានដល់មនុស្សគ្រប់រូប ដើម្បីឱ្យគេដឹងខុស និងត្រូវ" (មរ៉ូណៃ 7:16 សូមមើលផងដែរ ខទី 14–19)។

ពន្លឺនៃព្រះគ្រីស្ទគឺជា " កំលាំង អំណាច [ដ៏ទេវភាព] ឬជាឥទ្ធិពលដែលមកពីព្រះ តាមរយៈព្រះគ្រីស្ទ ហើយប្រទានជីវិត និងពន្លឺដល់គ្រប់វត្ថុទាំងអស់។ វាគឺជាក្រិត្យវិន័យដែលគ្រប់វត្ថុទាំងអស់ គឺត្រូវបានគ្រប់គ្រងនៅក្នុងស្ថានសួគ៌ និងលើផែនដី។ ពន្លឺនៃ ព្រះគ្រីស្ទក៏ជួយដល់មនុស្សយល់ពីសេចក្ដីពិតនៃដំណឹងល្អ និងជួយពួកគេរស់នៅតាមផ្លូវនៃដំណឹងល្អ ដែលនាំទៅកាន់សេចក្ដី សង្គ្រោះ។

"ពន្លឺនៃព្រះគ្រីស្ទ មិនគួរត្រូវបានយល់ច្រឡំជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធទេ។ ពន្លឺនៃព្រះគ្រីស្ទ មិនមែនជាមនុស្សទេ។ វាគឺជា ឥទ្ធិពលដែលមកពីព្រះ ហើយរៀបចំមនុស្សដើម្បីទទួលព្រះវិញ្ញាណបរិសុទ្ធ។ វាគឺជាឥទ្ធិពល សំរាប់អំពើល្អនៅក្នុងជីវិតនៃមនុស្សទាំងអស់។

"ការបង្ហាញមួយ ពីពន្លឺនៃព្រះគ្រីស្ទ គឺជាមនសិកា ដែលជួយមនុស្សម្នាក់ឱ្យជ្រើសរើសរវាងត្រូវ និងខុស។ ពេលដែលមនុស្សរៀនច្រើនអំពីដំណឹងល្អ មនសិការបស់ពួកគេកាន់តែយល់ច្រើន។ អ្នកទាំងឡាយណាដែលស្ដាប់តាម ពន្លឺនៃព្រះគ្រីស្ទ គឺត្រូវបានដឹកនាំទៅកាន់ដំណឹងល្អនៃព្រះគ្រីស្ទ" (The Guide to the Scriptures, "Light, Light of Christ;" សូមមើលផងដែរ គ និង ស 84:46–47)។

ប្រធាន ប៊យ ឃេ ផាកកឺ បានមានប្រសាសន៍ថាៈ "វាសំខាន់ណាស់សំរាប់ . . . អ្នកផ្សព្វផ្សាយសាសនាម្នាក់ . . . ដើម្បីដឹងថាព្រះវិញ្ញាណ បរិសុទ្ធអាចធ្វើការតាមរយៈពន្លឺនៃព្រះគ្រីស្ទ។ គ្រូបង្រៀននៃដំណឹងល្អពិត គឺមិនមែនត្រឹមតែ បណ្ដុះបណ្ដាលរឿងមួយ ឬប្រព្រឹត្តការណ៍ថ្មី ចំពោះមនុស្សពេញវ័យ និងកូនក្មេង តែផ្នែកខាងក្រៅទេ។ តែអ្នកផ្សព្វផ្សាយសាសនា ឬគ្រូបង្រៀន គឺមានទំនាក់ទំនងជាមួយ នឹងព្រះវិញ្ញាណនៃព្រះគ្រីស្ទ ដែលនៅទីនោះរួចទៅហើយ។ ដំណឹងល្អនឹង "ហាក់" ដូចជាមានភាពស្រដៀងគ្នាចំពោះពួកគេ (ពន្លឺនៃព្រះគ្រីស្ទ" សន្ទកថាធ្វើនៅ សិក្ខាសាលាសំរាប់ប្រធានបេសកកម្មថ្មី ថ្ងៃទី 22 ខែមិថុនា ឆ្នាំ 2004, 2)។

## ព្រះវិញ្ញាណបរិសុទ្ធ

**តួអង្គនៃព្រះវិញ្ញាណបរិសុទ្ធ។** ព្រះវិញ្ញាណបរិសុទ្ធ គឺជាតួអង្គទីបីនៃសមាជិកក្រុមព្រះ។ ទ្រង់ជាតួអង្គនៃព្រះវិញ្ញាណ ហើយគ្មាន រូបកាយជាសាច់ និងឆ្អឹងទេ (សូមមើល គ និង ស 130:22)។ ទ្រង់ជាតួអង្គល្បួងលោម ដែលជាតួអង្គដែលព្រះអង្គសង្គ្រោះបាន សន្យាថានឹងបង្រៀនអ្នកដើរតាមរបស់ទ្រង់នូវគ្រប់អ្វីៗទាំងអស់ ហើយនាំមកចូលក្នុងការចងចាំរបស់គេគ្រប់អ្វីៗទាំងអស់ ដែលទ្រង់ បានបង្រៀនពួកគេ (សូមមើល យ៉ូហាន 14:26)។

**ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ។** សាក្សីដែលនាំមកកាន់សាសនាគន់ការីដែលមានចិត្តស្មោះ មុនពិធីបុណ្យជ្រមុជទឹក គឺមកតាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ។ "ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ អាចមកសន្ថិតលើសាសនាគន់ការី មុនពិធី បុណ្យជ្រមុជទឹក ហើយថ្លែងជាសាក្សីថា ដំណឹងល្អ គឺពិត" (Guide to the Scriptures, "Holy Ghost")។ ព្រះចេស្ដានៃ ព្រះវិញ្ញាណ

កំណត់ចំណាំ

បរិសុទ្ធ ផ្ដល់ឱ្យសក្ខីភាពនៃព្រះយេស៊ូវគ្រីស្ទ និងកិច្ចការរបស់ទ្រង់ និងកិច្ចការនៃអ្នកបំរើរបស់ទ្រង់នៅលើផែនដី។ ព្រះវិញ្ញាណបរិសុទ្ធ ថ្លែងពីសេចក្ដីពិត។ មនុស្សទាំងអស់អាចដឹងពីភាពពេញលេញ នៃព្រះគម្ពីរមរមន តាមរយៈព្រះចេស្ដានៃ ព្រះវិញ្ញាណបរិសុទ្ធ។ "ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះអ្នករាល់គ្នានឹងបានដឹង នូវសេចក្ដីពិតនៃការណ៍គ្រប់យ៉ាង" (មរ៉ូណៃ 10:5)។

> *"អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធកើតមាន បន្ទាប់ពីមនុស្សម្នាក់ប្រែចិត្ត ហើយក្លាយជាមានភាពសក្ដិសម . . .។ ព្រះវិញ្ញាណបរិសុទ្ធថ្លែងជាសាក្សីនៃសេចក្ដីពិត និងបង្ហាញនៅលើដួងចិត្ត ពីសេចក្ដីពិតនៃព្រះជាព្រះវរបិតា និងព្រះរាជបុត្រា ព្រះយេស៊ូវគ្រីស្ទ យ៉ាងជ្រៅដែលគ្មានអំណាច ឬសិទ្ធិអំណាចណា នៅលើផែនដី អាចបំបែកទ្រង់ចេញពីចំណេះដឹងនេះបានទេ។"*
>
> — ប្រធាន ជេម អ៊ី ហ្វោស៍
> "THE GIFT OF THE HOLY GHOST—A SURE COMPASS,"
> *ENSIGN*, APR. 1996, 4

**អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។** សាសនាគន់ការី ដែលទទួលសាក្សី មិនទាន់ទទួលការសន្យានៃភាពជាដៃគូខ្ជាប់ខ្ជួននៃព្រះវិញ្ញាណបរិសុទ្ធទេ។ យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា៖ "មានចំណុចខុសគ្នា រវាងព្រះវិញ្ញាណបរិសុទ្ធ និងអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ។ កូនេលាស បានទទួលព្រះវិញ្ញាណបរិសុទ្ធ មុនទទួលបុណ្យជ្រមុជទឹក ដែលជាការបញ្ជាក់នៃព្រះចេស្ដា នៃព្រះចំពោះលោក ពីសេចក្ដីពិតនៃដំណឹងល្អ តែលោកមិនអាចទទួលអំណោទាននៃព្រះវិញ្ញាណបរិសុទ្ធទេ រហូតបន្ទាប់ពី លោកទទួលបុណ្យជ្រមុជទឹក។ លោកមិនទាន់ទទួលសញ្ញា ឬពិធីការនេះនៅលើខ្លួនលោកនៅឡើយទេ ព្រះវិញ្ញាណបរិសុទ្ធដែល បញ្ជាក់ដល់លោកពីសេចក្ដីពិតនៃព្រះ អាចចាកចេញពីលោកបាន" (*ប្រវត្តិនៃសាសនាចក្រ* 4:555)។

"... សិទ្ធិដើម្បីទទួលបានភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ គឺនៅពេលដែលមនុស្សមានភាពសក្ដិសម ព្រះវិញ្ញាណបរិសុទ្ធ ជាអំណោយទានដែល អាចទទួលបានមានតែតាមរយៈការដាក់ដៃ ដោយអ្នកកាន់បព្វជិតភាពម៉ិលគីស្សាដែក បន្ទាប់ពីពិធីបុណ្យ ជ្រមុជទឹកតាម សិទ្ធិអំណាច នៅក្នុងសាសនាចក្រពិតនៃព្រះយេស៊ូវគ្រីស្ទ។ (The Guide to the Scriptures, "Holy Ghost")។

ក្នុងនាមជាសមាជិកនៃសាសនាចក្រ អ្នកបានទទួលព្រះវិញ្ញាណបរិសុទ្ធ ដោយសិទ្ធិអំណាចបព្វជិតភាព។ អំណោយទាននេះ ប្រគល់ឱ្យអ្នកនូវភាពជាដៃគូខ្ជាប់ខ្ជួននៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលដែលអ្នកបន្តរស់នៅដោយមានភាពសក្ដិសមចំពោះ អំណោយទាននេះ។ ចូរអធិស្ឋានសំរាប់ការដឹកនាំពីព្រះវិញ្ញាណ ហើយធ្វើតាមការណែនាំ ដែលអ្នកទទួល ដោយក្លាហាន។

**ព្រះវិញ្ញាណបរិសុទ្ធនៃការសន្យា។** ព្រះវិញ្ញាណបរិសុទ្ធ ក៏សំដៅពីព្រះវិញ្ញាណបរិសុទ្ធនៃការសន្យាដែរ (សូមមើល គ និង ស 88:3)។ បានផ្សាភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃការសន្យា មានន័យថា ព្រះវិញ្ញាណបរិសុទ្ធសណ្ឋិតនៅលើសកម្មភាព សុចរិតនោះ ឬពិធីការផ្សេងៗ និងសេចក្ដីសញ្ញាដែលអាចទទួលបានពីព្រះ។ ព្រះវិញ្ញាណបរិសុទ្ធនៃការសន្យាថ្លែង ចំពោះព្រះវរបិតាថា ពិធីការនៃសេចក្ដីសង្គ្រោះត្រូវបានធ្វើឡើងដោយត្រឹមត្រូវ ហើយថា សេចក្ដីសញ្ញាដែលមានទំនាក់ទំនងជា មួយពួកគេ ត្រូវបានរក្សា។ អ្នកទាំងឡាយណាដែលបានផ្សាភ្ជាប់ដោយព្រះវិញ្ញាណនៃការសន្យា ទទួលបានអ្វីៗដែលព្រះវរបិតា មាន (សូមមើល គ និង ស 76:51–60, អេភេសូរ 1:13–14)។ សេចក្ដីសញ្ញា និងការសម្ដែងទាំងអស់ ត្រូវតែបានផ្សាភ្ជាប់ ដោយព្រះវិញ្ញាណនៃការសន្យា បើសេចក្ដីសញ្ញា និងការសម្ដែងត្រឹមត្រូវបន្ទាប់ពីជីវិតនេះ (សូមមើល គ និង ស 132:7, 18–19, 26)។ ការបំបាក់សេចក្ដីសញ្ញា អាចផ្លាស់ប្ដូរការផ្សាភ្ជាប់។

**អំណោយទាននៃព្រះវិញ្ញាណ។** អំណោយទាននៃព្រះវិញ្ញាណ គឺពរជ័យខាងវិញ្ញាណយ៉ាងពិសេស ដែលព្រះអម្ចាស់ប្រទានចំពោះ បុគ្គលម្នាក់ៗ ដែលមានភាពស័ក្ដសម សំរាប់ប្រយោជន៍របស់គេផ្ទាល់ និងសំរាប់ប្រើក្នុងការប្រសិទ្ធិពរដល់អ្នកដទៃ។ ឧទាហរណ៍ អ្នកផ្សព្វផ្សាយសាសនាដែលត្រូវតែរៀនភាសាថ្មី អាចទទួលបានអំណោយទានខាងភាសា ដើម្បីប្រទានឱ្យពួកគេនូវជំនួយដ៏ទេវភាព ក្នុងការរៀនភាសា។ អំណោយទាននៃព្រះវិញ្ញាណជាច្រើនទៀត គឺត្រូវបានពិពណ៌នា នៅក្នុង មរ៉ូណៃ 10:8–18, គោលលទ្ធិ និងសេចក្ដីសញ្ញា 46:11–33 និងកូរិនថូសទី 1 12:1–12។ ទាំងនេះគ្រាន់តែជាឧទាហរណ៍ខ្លះៗ តែប៉ុណ្ណោះ នៃគំរូ ជាច្រើន អំពីអំណោយទាននៃព្រះវិញ្ញាណ។ ព្រះអម្ចាស់អាចប្រទានពរដល់អ្នក ក្នុងវិធីផ្សេងៗទៀត អាស្រ័យទៅលើសេចក្ដីស្មោះ ត្រង់របស់អ្នក សេចក្ដីត្រូវការរបស់អ្នក និងសេចក្ដីត្រូវការអ្នកទាំងឡាយណាដែលអ្នកបំរើ។ អ្នកគួរមានបំណងប្រាថ្នាចង់បាន អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ និងស្វែងរកអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដោយស្មោះត្រង់ (សូមមើល គ និង ស 46:8, កូរិនថូសទី1 12:31, 14:1, 12)។ អំណោយទានទាំងនេះមកតាមរយៈការអធិស្ឋាន សេចក្ដីជំនឿ និងកិច្ចការ យោងទៅតាមឆន្ទៈរបស់ព្រះ (សូមមើល គ និង ស 63:9–12, 84:64–73)។

កំណត់ចំណាំ

### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន ឬការសិក្សាជាមួយដៃគូ

ចូរអានឯកសារយោងខាងក្រោមនេះៈ

- The Guide to the Scriptures, “Holy Ghost,” “Light, Light of Christ,” and “Spirit.”
- *Our Search for Happiness*, 84–86, 91–92។
- *True to the Faith*, 81–84, 165–67។

ចូរសរសេរពីការពិពណ៌នា នៃនិស្ស័យ និងតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធ

---

ចូរអាន កិច្ចការពួកសាវក 4ៈ23–33។

- តើពេត្រុស និងយ៉ូហាន បានស្វែងរកអំណោយទានខាងវិញ្ញាណ យ៉ាងដូចម្តេច?
- តើព្រះអម្ចាស់ឆ្លើយការអធិស្ឋានរបស់ពួកគេ យ៉ាងដូចម្តេច?
- តើអ្វីខ្លះ អ្នកអាចរៀនពីបទពិសោធន៍នេះ អំពីជីវិតរបស់អ្នកផ្ទាល់?

## ព្រះចេស្តានៃព្រះវិញ្ញាណ ក្នុងការផ្លាស់គំនិត

អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ គឺសំខាន់នៅក្នុងការផ្លាស់គំនិត។ ចូរខិតខំដើម្បីយល់ពីគោលលទ្ធិ នៃការផ្លាស់គំនិត និងព្រមទាំងបទពិសោធន៍នៃការផ្លាស់គំនិត។ អែលឌើរ ប៊យ ឃេ ផាកកឺ បានពន្យល់តួនាទីសំខាន់នៃព្រះវិញ្ញាណ ក្នុងការផ្លាស់គំនិតៈ

“នៅពេលការផ្លាស់គំនិតកើតមាន គឺវាកើតមានតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណ។ ដើម្បីទទួលបានជោគជ័យនៅក្នុងកិច្ចការអ្នកផ្សព្វផ្សាយសាសនា ចំណុចទាំងបីនេះ ត្រូវតែកើតឡើងៈ

“យើងត្រូវតែយល់ពីអ្វីដែលសាសនាគន់ការី អាចទទួលអារម្មណ៍ ដើម្បីទទួលការផ្លាស់គំនិត។

“យើងត្រូវតែយល់ ពីរបៀបដែលអ្នកផ្សព្វផ្សាយសាសនាត្រូវតែទទួលអារម្មណ៍ ដើម្បីបង្រៀនជាមួយនឹង អំណាចដើម្បីផ្លាស់គំនិតនៃព្រះវិញ្ញាណ។

“ហើយបន្ទាប់មកយើងត្រូវតែយល់ពី របៀបដែលសមាជិកម្នាក់ ត្រូវតែទទួលអារម្មណ៍ ដើម្បីទទួលជោគជ័យ ក្នុងការចូលរួមចំណែកបទពិសោធន៍ផ្លាស់គំនិត” (សន្និសីទប្រធានបេសកកម្ម ថ្ងៃទី 3 ខែមេសា ឆ្នាំ 1985)។



ការយល់កាន់តែប្រសើរពីរបៀបដែល សាសនាគន់ការី អ្នកផ្សព្វផ្សាយសាសនា និងសមាជិកទទួលអារម្មណ៍ នៅពេលដែលពួក គេទទួលសាក្សីនៃព្រះវិញ្ញាណ នោះអ្នកនឹងកាន់តែយល់ពីតួនាទីរបស់អ្នកផ្ទាល់ ដើម្បីៈ

- មានគ្រឹះ ហើយធ្វើឱ្យគំនិតរបស់អ្នកភ្លឺ នៅពេលអ្នកស្វែងយល់ពីព្រះគម្ពីរ និងបង្រៀនគោលលទ្ធិ។
- ធ្វើឱ្យមានបរិយាកាសល្អនៅពេលអ្នកបង្រៀន ដែលព្រះវិញ្ញាណបរិសុទ្ធអាចថ្លែងជាសាក្សី។ អ្នកអាចធ្វើដូច្នេះ ដោយការ បង្រៀន និងការថ្លែងសក្ខីភាពនៃសារដំណឹងនៃការស្តារឡើងវិញ។ បង្រៀនដូចដែលបានណែនាំពីព្រះវិញ្ញាណ ហើយថ្លែងថា អ្នកដឹងដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធថា អ្វីដែលអ្នកបង្រៀន គឺពិត។
- ធ្វើតាមការដឹកនាំពីព្រះវិញ្ញាណ ដើម្បីផ្លាស់ប្តូរសារដំណឹងទៅតាមសេចក្តីត្រូវការ របស់មនុស្សម្នាក់ៗ។
- អញ្ជើញមនុស្សឱ្យធ្វើតាម។ សេចក្តីជំនឿរបស់គេនឹងរីកចំរើន នៅពេលដែលពួកគេប្រែចិត្ត គោរពប្រតិបត្តិតាមព្រះបញ្ញត្តិ ហើយធ្វើនិងរក្សាសេចក្តីសញ្ញា។

កំណត់ចំណាំ

អែលឌើរ អិម រ័សសល បាឡាដ បានមានប្រសាសន៍ពីព្រះវិញ្ញាណថាៈ “ការផ្លាស់គំនិតពិតប្រាកដមកតាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណ។ នៅពេលដែលព្រះវិញ្ញាណប៉ះដល់ដួងចិត្ត នោះដួងចិត្តនឹងត្រូវបានផ្លាស់ប្ដូរ។ នៅពេលដែលបុគ្គលម្នាក់ៗ . . . ទទួលអារម្មណ៍ថា ព្រះវិញ្ញាណនៅជាមួយគេ ឬនៅពេលពួកគេឃើញសាក្សីនៃសេចក្ដីស្រលាញ់ និងមេត្តាករុណារបស់ព្រះអម្ចាស់ នៅក្នុងជីវិតរបស់គេ នោះពួកគេនឹងរឹងមាំ ហើយត្រូវបានពង្រឹងខាងវិញ្ញាណ ហើយសេចក្ដីជំនឿរបស់គេនៅក្នុងទ្រង់នឹង កើតឡើង។ បទពិសោធន៍ទាំងនេះ ជាមួយនឹងព្រះវិញ្ញាណកើតឡើងជាធម្មតា នៅពេលដែលមនុស្សម្នាក់មានឆន្ទៈ ដើម្បី ពិសោធន៍ដល់ពាក្យសំដី។ នេះជារបៀបដែលយើងអាចទទួល *អារម្មណ៍* ថាដំណឹងល្អ គឺពិត” (“Now Is the Time,” *Ensign*, Nov. 2000, 75)។

ព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងដួងចិត្តរបស់មនុស្ស ដើម្បីនាំមកដល់មនុស្សនូវការផ្លាស់ប្ដូរនេះ។ នៅពេលដែលមនុស្សជ្រើសរើសដើម្បីរក្សាការតាំងចិត្ត ពួកគេនឹងទទួលអារម្មណ៍នៃព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ កាន់តែខ្លាំងឡើង ហើយនឹងអភិវឌ្ឍន៍ សេចក្ដីជំនឿដើម្បីគោរពប្រតិបត្តិតាមព្រះគ្រីស្ទ។ ហេតុដូច្នេះ អ្នកគួរតែជួយដល់មនុស្ស ដែលអ្នកធ្វើការជាមួយឱ្យរីកចំរើន ខាងសេចក្ដីជំនឿ ដោយការអញ្ជើញពួកគេ ឱ្យប្រែចិត្ត និងធ្វើ និងរក្សាការតាំងចិត្ត។

### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

- ចូរអានសារដំណឹងមួយ ឬពីរដូចខាងក្រោម ហើយពិចារណាពីអ្វីដែលសាសនាគន់ការី ត្រូវតែទទួលអារម្មណ៍ដើម្បីធ្វើ ការផ្លាស់គំនិត។ សរសេរពីអារម្មណ៍ និងការបរិយាយរបស់អ្នកនៅក្នុងសៀវភៅសិក្សារបស់អ្នក។ ពិភាក្សាគំនិតរបស់អ្នក ជាមួយនឹង អ្នកផ្សព្វផ្សាយសាសនា និងសមាជិកដទៃទៀត។

  នីហ្វៃទី 2 4៖16–35, អេណុស 1, ម៉ូសាយ 4–5, 18៖7–14, 27–28, អាលម៉ា 5, 17–22, 32, 36, 38

- ចូរអានសារដំណឹងមួយឬពីរដូចខាងក្រោម ហើយពិចារណាពីអ្វីដែលអ្នក ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ និងជាសមាជិកត្រូវតែទទួលអារម្មណ៍ ដើម្បីបង្រៀនជាមួយនឹងព្រះចេស្ដានៃការផ្លាស់គំនិត។ សរសេរអារម្មណ៍ និងការបរិយាយ របស់អ្នកនៅក្នុងសៀវភៅសិក្សារបស់អ្នក។ ពិភាក្សាគំនិតរបស់អ្នកជាមួយនឹង អ្នកផ្សព្វផ្សាយសាសនា និងសមាជិកដទៃទៀត។

  នីហ្វៃទី 18 ៖11–12, ម៉ូសាយ 28៖1–4, អាលម៉ា 26, 29, 31៖26–38, 32, ម៉រ៉ូណៃ 7៖43–48, គ និង ស 4, 18៖10–16, 50៖21–22

### ការសិក្សាខគម្ពីរ

**តើព្រះគម្ពីរទាំងនេះ បង្រៀនអ្វី អំពីព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងកិច្ចការរបស់អ្នក?**

| | | |
|---|---|---|
| នីហ្វៃទី 2 33៖1–2 | គ និងស 50៖13–22 | កូរិនថូសទី 1 2៖11–14 |
| គ និង ស 42៖11–17 | កិច្ចការពួកសាវក 2៖37–38 | Guide to the Scriptures, “Conversion, Convert” |

**តើអ្នកអាចធ្វើអ្វីដើម្បីរីករាយ ជាមួយព្រះចេស្ដានៃព្រះវិញ្ញាណ នៅក្នុងកិច្ចការរបស់អ្នក?**

| | | |
|---|---|---|
| អាលម៉ា 32៖27–28 | គ និង ស 42៖14 | យ៉ូហាន 7៖17 |

**ហេតុអ្វីសំខាន់ចំពោះអ្នក ដើម្បីបង្រៀនពីអ្វីដែលអ្នកដឹង និងជឿ?**

| | | |
|---|---|---|
| អាលម៉ា 5៖43–47 | គ និង ស 52៖9 | គ និង ស 80៖4 |

## អធិស្ឋាននៅក្នុងសេចក្ដីជំនឿ

អ្នកអាចបង្រៀននៅក្នុងវិធីរបស់ព្រះអម្ចាស់ មានតែតាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណតែប៉ុណ្ណោះ ហើយអ្នកទទួលព្រះវិញ្ញាណតាមរយៈការអធិស្ឋាននៃសេចក្ដីជំនឿ។ ព្រះអម្ចាស់បានមានបន្ទូលថាៈ “ហើយព្រះវិញ្ញាណត្រូវបានប្រទានដល់អ្នក ដោយ ពាក្យអធិស្ឋាននៃសេចក្ដីជំនឿ ហើយបើសិនជាអ្នករាល់គ្នាមិនបានទទួលព្រះវិញ្ញាណទេ នោះអ្នករាល់គ្នានឹងមិនត្រូវបង្រៀន ឡើយ” (គ និង ស 42៖14)។ នៅពេលដែលអ្នកអធិស្ឋានសុំជំនួយនៅក្នុងការបង្រៀនរបស់អ្នក ព្រះចេស្ដានៃព្រះវិញ្ញាណ បរិសុទ្ធ នឹងដឹកនាំការបង្រៀនរបស់អ្នក “ចូលទៅក្នុងដួងចិត្តនៃកូនចៅមនុស្ស” (នីហ្វៃទី 2 33៖1)

ប្រធាន គរដុន ប៊ី ហ៊ីងឃ្លី បង្រៀនគោលការណ៍នេះ ដោយការប្រៀបធៀបបទពិសោធន៍ចេញពីបេសកកម្មរបស់លោកៈ

“ខ្ញុំតែងតែចងចាំយុវជនពីរនាក់ ដែលបានបំរើនៅក្នុងបេសកកម្មរបស់ខ្ញុំ។ ម្នាក់ជាតួកុន។ គាត់មានចំណេះវិជ្ជា។ គាត់ឆ្លាត។ គាត់រហ័ស។ គាត់អួតអាងបន្តិច។ យើងមានយុវជនម្នាក់ទៀត ដែលជាជាងគំនូរឃើហោ។ គាត់ធ្វើការនៅហាងគូសសញ្ញា ជាមួយនឹងចំណេះវិជ្ជាដ៏តិចតួច តែគាត់ស្គាល់ពីចំណុចខ្វះខាតរបស់គាត់ ហើយគាត់ពឹងលើព្រះអម្ចាស់។ ពេលដែលគាត់អធិស្ឋាន គាត់បានដឹងថា

កំណត់ចំណាំ

គាត់កំពុងនិយាយជាមួយព្រះអម្ចាស់។ ការអធិស្ឋានមិនមែនជាការទន្ទេញទេ វាគឺជាការសន្ទនា ហើយ យុវជនម្នាក់នោះបានសំរេចយ៉ាងប្រសើរ ខណៈដែលយុវជនម្នាក់ទៀតធ្វើអ្វីទៅតាមតែតំរូវការ។ ព្រះចេស្ដានៅក្នុងយុវជន ម្នាក់នោះ ហើយអវត្តមាននៃព្រះចេស្ដាអាចមើលឃើញយ៉ាងប្រាកដនៅក្នុងយុវជនម្នាក់ទៀត។ ចូរអំពាវនាវដល់ព្រះអម្ចាស់។ ទ្រង់ទទួលការអំពាវនាវ ហើយទ្រង់នឹងឆ្លើយ” (*Teachings of Gordon B. Hinckley* [1997], 469)។

ព្យាយាមអធិស្ឋានដោយស្មោះ ជាមួយគោលបំណងពិត ហើយដោយ “អស់ពីកំលាំងចិត្ត” (មរ៉ូណៃ 7៖48)។ ការអធិស្ឋានដែលមានប្រសិទ្ធិភាពតំរូវឱ្យមានការខិតខំប្រឹងប្រែងដ៏ធំ (សូមមើល មរ៉ូណៃ 10៖3–4, គ និង ស 8៖10, 9៖7)។ ផ្ដល់នូវការគិតដ៏ម៉ឺងម៉ាត់ចំពោះអត្តចរិត និងការប្រើពាក្យសំដីរបស់អ្នក។ ចូរពិចារណា ដូចខាងក្រោមនៅពេលដែលអ្នកអធិស្ឋាន៖



- ប្រើភាសានៃការអធិស្ឋាន ដែលបង្ហាញថា អ្នកស្រលាញ់ និងគោរពព្រះវរបិតាសួគ៌អ្នក។ ប្រើភាសាដែលសមរម្យ និងពោរពេញដោយការគោរព នៅក្នុងភាសាអ្វីក៏ដោយដែលអ្នកនិយាយ។ ឧទាហរណ៍ នៅក្នុងភាសាអង់គ្លេស ប្រើពាក្យនៅក្នុង ព្រះគម្ពីរ ដូចជា *ទ្រង់* និង *របស់ទ្រង់*។
- តែងតែបង្ហាញអំណរគុណចំពោះពរជ័យរបស់អ្នក។ ការមានស្មារតីខិតខំប្រឹងប្រែង ដើម្បីថ្លែងអំណរគុណ នឹងជួយអ្នក ដឹងពីរបៀបដែលសេចក្ដីមេត្តាករុណារបស់ព្រះអម្ចាស់ មាននៅក្នុងជីវិតរបស់អ្នក។
- អធិស្ឋានដោយជាក់ច្បាស់សំរាប់ការដឹកនាំ និងជំនួយនៃព្រះវិញ្ញាណបរិសុទ្ធ។ បង្ហាញថា អ្នកឱ្យតំលៃចំពោះ ពរជ័យនេះ ដោយការមានចិត្តទន់ភ្លន់ចំពោះព្រះវិញ្ញាណ និងការយកចិត្តទុកដាក់លើការបំផុសខាងព្រះវិញ្ញាណ។ បន្ទាប់មក ធ្វើតាមការបំផុសទាំងនោះដោយក្លាហាន។
- អធិស្ឋានដោយសេចក្ដីស្រលាញ់ និងសេចក្ដីសប្បុរស។ អធិស្ឋានសំរាប់មនុស្សម្នាក់ៗ តាមឈ្មោះ។ សូមឱ្យមានការបំផុសគំនិត ដើម្បីជួយអ្នកយល់ និងបំពេញសេចក្ដីត្រូវការពួកគេ។ អធិស្ឋានសំរាប់កិច្ចការទំនាក់ទំនង ជាមួយសាសនាគន់ការី អ្នកផ្លាស់គំនិតថ្មី និងសមាជិកមិនសូវសកម្ម។ អធិស្ឋានសំរាប់សមាជិក និងអ្នកកាន់បព្វជិតភាព និងអ្នកដឹកនាំអង្គការជំនួយ នៅក្នុងតំបន់អ្នក។ អធិស្ឋានសំរាប់ក្រុមគ្រួសារអ្នកនៅឯផ្ទះ។ អធិស្ឋានសំរាប់ដៃគូអ្នក និងអ្នកផ្សព្វផ្សាយសាសនាដទៃទៀត និងប្រធាន បេសកកម្មអ្នក។ អធិស្ឋានដើម្បីដឹងពីរបៀបដែលអ្នកអាចជួយដល់អ្នកដទៃ ហើយបន្ទាប់មកមានឆន្ទះដើម្បី ពលិកម្មទៅតាម ធុរកិច្ចរបស់គេ។

*“ជារៀងរាល់ព្រឹក . . . អ្នកផ្សព្វផ្សាយសាសនាគួរតែលុតជង្គង់ចុះ ហើយសូមដល់ព្រះអម្ចាស់ ដើម្បីបន្ធូរដល់អណ្ដាតរបស់គេ ហើយនិយាយតាមរយៈពួកគេសំរាប់ពរជ័យនៃអ្នកទាំងឡាយណា ដែលពួកគេនឹងបង្រៀន។ បើពួកគេនឹងធ្វើដូច្នេះ ពន្លឺថ្មី នឹងមកក្នុងជីវិតរបស់គេ។ នោះនឹងមានការរីករាយយ៉ាងខ្លាំងចំពោះកិច្ចការ។ ពួកគេនឹងដឹងថា ក្នុងញាណដ៏ពិត ពួកគេគឺជា អ្នកបំរើនៃព្រះអម្ចាស់ដោយការនិយាយក្នុងធុរកិច្ចទ្រង់។ ពួកគេនឹងស្វែងរកការឆ្លើយតបខុសពីគ្នា ពីអ្នកទាំងឡាយណាដែលគេបង្រៀន។ នៅពេលដែលពួកគេធ្វើតាមព្រះវិញ្ញាណសាសនាគន់ការីរបស់គេ នឹងឆ្លើយតបនៅក្រោមឥទ្ធិពលព្រះវិញ្ញាណដូចគ្នា ។”*

— ប្រធាន គរដុន ប៊ី ហ៊ីងគ្លី
“MISSIONARY SERVICE,” *FIRST WORLDWIDE LEADERSHIP TRAINING MEETING*, 11 JAN. 2003, 20

- អធិស្ឋានដើម្បីអ្នកនឹងត្រូវបានបង្ហាញពីទីកន្លែងដែលត្រូវទៅ និងអ្វីដែលត្រូវធ្វើ។ អធិស្ឋានដើម្បីអ្នកត្រូវបានដឹកនាំទៅកាន់អ្នកទាំងឡាយណា ដែលនឹងទទួលស្គាល់សារដំណឹងនៃការស្ដារឡើងវិញ។ អធិស្ឋានដើម្បីអ្នកស្គាល់ពួកគេ។
- ត្រូវដឹងថា ព្រះវរបិតាសួគ៌របស់អ្នក ដឹងពីអ្វីដែលអ្នកត្រូវការជាងអ្នកដឹងទៅទៀត។ ពឹងផ្អែកទៅលើព្រះវិញ្ញាណ ដើម្បីដឹងពីអ្វីដែលត្រូវអធិស្ឋាន (សូមមើល នីហ្វៃទី 3 19៖24, គ និង ស 46៖28, 30)។

កំណត់ចំណាំ

- ក្នុងការអធិស្ឋានរបស់អ្នកនៅពេលយប់ ចូរទូលដល់ព្រះអម្ចាស់នូវសកម្មភាពនៃដំណើររឿងពេញមួយថ្ងៃរបស់អ្នក។ បន្ទាប់មកទូលដល់ទ្រង់ឡើងវិញពីផែនការរបស់អ្នកសំរាប់ថ្ងៃស្អែក។ ចូរស្ដាប់តាមការបំផុសគំនិតនៃព្រះវិញ្ញាណ។
- អធិស្ឋានដើម្បីឈ្នះលើការល្បួង។ យកឈ្នះលើការល្បួងដែលបង្អាក់ព្រះវិញ្ញាណ។
- អធិស្ឋាននៅពេលដែលសមរម្យ តមអាហារសំរាប់ពរជ័យពិសេស។
- អធិស្ឋាន និងពិចារណាពីព្រះគម្ពីរ។ ព្រះគម្ពីរធ្វើឱ្យមានវិវរណៈ។
- ជឿថា ព្រះនឹងឆ្លើយចំពោះការអធិស្ឋានរបស់អ្នក។ ត្រូវដឹងថា គំនិតរបស់ព្រះ គឺមិនមែនជាគំនិតរបស់អ្នកទេ (សូមមើល អេសាយ 55៖8–9) ហើយទុកចិត្តទៅលើព្រះ ដើម្បីឆ្លើយតបចំពោះការអធិស្ឋានរបស់អ្នក ទៅតាមកម្មវិធី និងពេល វេលារបស់ទ្រង់ផ្ទាល់។

## សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

ពិចារណាសេចក្ដីថ្លែងដូចខាងក្រោម ទាក់ទងនឹងការអធិស្ឋានដោយស្មោះ

"បញ្ហាភាគច្រើននៅក្នុងការអធិស្ឋានរបស់យើង គឺថា យើងអធិស្ឋានដូចជាយើងលើកទូរសព្ទ ហើយបញ្ជាទិញម្ហូបអាហារ—យើងបញ្ជាទិញម្ហូបអាហាររបស់យើងរួចហើយ ក៏ដាក់ទូរសព្ទចុះ។ យើងត្រូវការ តាំងស្មារតី សញ្ជឹងគិត គិតពីអ្វីដែលយើង កំពុងអធិស្ឋានអំពី និងដើម្បីអ្វី ហើយបន្ទាប់មក និយាយជាមួយព្រះអម្ចាស់ ដូចជាមនុស្សម្នាក់និយាយជាមួយនឹងមនុស្ស ម្នាក់ទៀត" ( គរដុន ប៊ី ហ៊ិងឃ្លី, *Teachings of Gordon B. Hinckley*, 469)។

"បើការអធិស្ឋានគ្រាន់តែដូចជាការត្រូវការភ្លាមៗ នៅពេលដែលមានវិបត្តិតែប៉ុណ្ណោះ នោះការអធិស្ឋានគឺអាត្មានិយមយ៉ាងខ្លាំង ហើយយើងចាប់ផ្ដើមគិតអំពីព្រះ ដូចជាជាងជួសជុលម្នាក់ ឬសេវាកម្មបំរើជាបន្ទាន់ ដើម្បីជួយយើងនៅពេលដែល យើងមានអាសន្នតែប៉ុណ្ណោះ។ យើងគួរតែចងចាំ ពេលថ្ងៃ និងយប់ដ៏ខ្ពស់បំផុត—ជានិច្ច—មិនមែននៅពេលដែលជំនួយឧបត្ថម្ភទាំងអស់ ត្រូវបរាជ័យ ហើយយើងត្រូវការជំនួយឧបត្ថម្ភដោយអស់សង្ឃឹមប៉ុណ្ណោះទេ" ( ហាវើត ដបុលយូ ហឺនធើរ *The Teachings of Howard W. Hunter*, ed. Clyde J. Williams [1997], 39)។

---

ប្រើជញ្ជីងដូចខាងក្រោម ដើម្បីវាយតំលៃការអធិស្ឋានរបស់អ្នកដោយផ្ទាល់។ នៅក្នុងសៀវភៅសិក្សារបស់អ្នក សរសេរចំលើយ ចំពោះសំនួរទាំងនេះ តើអ្នកអាចដាក់ខ្លួនអ្នកនៅលើជញ្ជីងនេះ កន្លែងណា? តើអ្នកចង់ដូចជាអ្វីនៅលើជញ្ជីងនេះ? តើអ្នកនឹង ផ្លាស់ប្ដូរយ៉ាងដូចម្ដេច?

| | អន់ | មធ្យម | ល្អ | |
|---|---|---|---|---|
| សេចក្ដីជំនឿក្នុងព្រះគ្រីស្ទខ្សោយ | ◄ | — | ► | សេចក្ដីជំនឿក្នុងព្រះគ្រីស្ទខ្លាំង |
| មិនថ្លែងអំណរគុណ | ◄ | — | ► | ពេញដោយអំណរគុណ |
| គំនិតមិនយកចិត្តទុកដាក់លើកិច្ចការ | ◄ | — | ► | គំនិតយកចិត្តទុកដាក់លើកិច្ចការ |
| គ្មានទំនាក់ទំនងជាមួយនឹងសកម្មភាព | ◄ | — | ► | សកម្មភាពពេញដោយការអធិស្ឋាន |
| និយាយដដែលៗ | ◄ | — | ► | យកចិត្តទុកដាក់លើសេចក្ដីត្រូវការថ្ងៃនេះ |
| អារម្មណ៍មិនសូវល្អ | ◄ | — | ► | មានចិត្តនិងអាកប្បកិរិយាល្អ, ការធ្វើឱ្យស្រស់បស់ |
| យកចិត្តទុកដាក់ទៅលើគំនិតមិនបរិសុទ្ធ | ◄ | — | ► | យកចិត្តទុកដាក់ទៅលើគំនិតបរិសុទ្ធ |
| ការពឹងលើខ្លួនឯង | ◄ | — | ► | យកចិត្តទុកដាក់ដល់អ្នកដទៃ |
| ទូទៅ, មិនច្បាស់លាស់ | ◄ | — | ► | ច្បាស់លាស់, មិនទូទៅ |
| អវត្តមានព្រះវិញ្ញាណ | ◄ | — | ► | ព្រះវិញ្ញាណដឹកនាំអ្នកអធិស្ឋាន |
| មិនស្គាល់ចំលើយ | ◄ | — | ► | ទុកចិត្តថា ព្រះឆ្លើយចំពោះការអធិស្ឋាន |

## ការសិក្សាព្រះគម្ពីរ

**ហេតុអ្វីអ្នកត្រូវតែអធិស្ឋាន ដើម្បីព្រះវិញ្ញាណ?**

នីហ្វៃទី 2 32៖8–9　　គ និង ស 42៖14　　គ និង ស 50៖13–22

កំណត់ចំណាំ

**តើអ្នកគួរអធិស្ឋានដើម្បីអ្វី?**

| | | |
|---|---|---|
| អាលម៉ា 6៖6 | អាលម៉ា 37៖36–37 | គ និង ស 50៖29–30 |
| អាលម៉ា 13៖28 | នីហ្វៃទី 3 18៖20 | Guide to the Scriptures, “Prayer” |
| អាលម៉ា 34៖17–27 | នីហ្វៃទី 3 19៖9 | |

## រៀនដើម្បីដឹងពីការបំផុសនៃព្រះវិញ្ញាណ

ព្រះវិញ្ញាណតែងតែអាចដឹកនាំអ្នក និងណែនាំអ្នក។ ទោះជាយ៉ាងណាក៏ដោយ ព្រះវិញ្ញាណមានបន្ទូលយ៉ាងស្ងាត់ស្ងៀម តាមរយៈអារម្មណ៍ ព្រមទាំងគំនិតអ្នក។ ការប្រឈមមុខមួយ សំរាប់អ្នក និងអ្នកដែលអ្នកធ្វើការជាមួយគឺ ដើម្បីដឹងពីភាពស្ងប់ស្ងាត់ ការបំផុសគំនិតយ៉ាងល្អិតល្អន់នៃព្រះវិញ្ញាណបរិសុទ្ធ។

ប្រធាន ប៊យ ឃេ ផាកកឺ បានបង្រៀនថា៖ “សំលេងនៃព្រះវិញ្ញាណ គឺបានពិពណ៌នាទៅក្នុងព្រះគម្ពីរ ថាមិនមែនជាសំលេង ‘ខ្លាំង’ ឬ ‘ស្អក’។ វាក៏ ‘ពុំមែនជាសូរផ្គរលាន់ទេ ពុំមែន . . . ជាសម្លេងអឺងកង។’ តែជា ‘សម្លេងរហៀងៗ នៃភាពស្រទន់ឥតខ្ចោះ ហាក់ដូចជាពាក្យខ្សឹប’ ហើយវាអាច ‘ជ្រួតជ្រាបទៅក្នុងព្រលឹង’ ហើយ ‘ធ្វើឲ្យ [ចិត្ត] របស់គេឆេះរោលរាល។’ (នីហ្វៃទី 3 11៖3, ហេលេមិន 5៖30, គ និង ស 85៖6–7)។ ចងចាំថា អេលីយ៉ា បានរកឃើញសំលេងនៃព្រះអម្ចាស់មិននៅក្នុងខ្យល់ ឬនៅក្នុងការរញ្ជួយដី ឬនៅក្នុងភ្លើងទេ តែគឺជា ‘សំលេងតូចរហៀង។’ ពង្សាវតារក្សត្រទី 1 19៖12)។

“ព្រះវិញ្ញាណមិនទទួលការចាប់អារម្មណ៍របស់យើង ដោយការស្រែក ឬធ្វើឲ្យយើងញ័រជាមួយនឹងដៃធ្ងន់ៗទេ។ តែជាសំលេងខ្សឹប។ ព្រះវិញ្ញាណទន់ភ្លន់ បើយើងមិនយកចិត្តទុកដាក់ នោះយើងមិនអាចទទួលអារម្មណ៍បានទេ (វាគ្មានចំងល់ទេ ដែលពាក្យគតិបណ្ឌិត ត្រូវបានបើកសម្ដែងចំពោះយើង តើមនុស្សស្រវឹង ម្នាក់ ឬមនុស្សញៀនម្នាក់ អាចលឺសំលេងនោះយ៉ាងដូចម្ដេចទៅ?)

“ជារឿយៗ ព្រះវិញ្ញាណនឹងប៉ះយើងល្មមគ្រប់គ្រាន់ ដើម្បីឲ្យយើងអាចយកចិត្តទុកដាក់ស្ដាប់។ តែភាគច្រើន បើយើងមិនស្ដាប់ចំពោះអារម្មណ៍ដ៏ស្រទន់ ព្រះវិញ្ញាណនឹងដកខ្លួនចេញ ហើយរង់ចាំរហូតដល់យើងមកស្វែងរក ហើយស្ដាប់ ហើយ និយាយជាឫកពារ និងការបង្ហាញរបស់យើង ដូចជាសាំយូអែលពីសម័យបុរាណ ‘សូម [ទ្រង់] មានបន្ទូលមកចុះ ត្បិតទូលបង្គំជាអ្នកបំរើទ្រង់ ប្រុងស្ដាប់ហើយ។’ (សាំយូអែលទី 1 3៖10)” (“The Candle of the Lord,” *Ensign*, Jan. 1983, 53)។

មានសំលេងជាច្រើនប្រណាំងប្រជែងទៅក្នុងពិភពលោក ដើម្បីទទួលបានចំណាប់អារម្មណ៍ពីអ្នក ហើយពួកគេអាចទាញយកអារម្មណ៍ខាងវិញ្ញាណរបស់អ្នក យ៉ាងងាយស្រួល បើអ្នកមិនយកចិត្តទុកដាក់។

### សកម្មភាព៖ ការសិក្សាផ្ទាល់ខ្លួន ឬការសិក្សាជាមួយដៃគូ

សិក្សាតារាងដូចខាងក្រោម។ គិតអំពីពេលដែលអ្នកមានបទពិសោធន៍ទទួលនូវអារម្មណ៍ គំនិត ឬអារម្មណ៍ណាមួយ ដែលបាន ពិពណ៌នាទៅក្នុងសារជំណឹងខាងក្រោម។ នៅពេលដែលអ្នកសិក្សា ហើយទទួលបទពិសោធន៍ បន្ថែមសារដំណឹងផ្សេងទៀតទៅ ក្នុងបញ្ជីនេះ។ គិតអំពីរបៀបដែលអ្នកអាចប្រើគោលការណ៍នេះ ដើម្បីជួយដល់អ្នកដទៃទទួលអារម្មណ៍ និងស្គាល់ពី ព្រះវិញ្ញាណ។

| | |
|---|---|
| គ និង ស 6៖23, 11៖12–14, | ចែកចាយអារម្មណ៍នៃសេចក្ដីស្រលាញ់ សេចក្ដីអំណរ សេចក្ដីសុខសាន្ត សេចក្ដីអំណត់ |
| រ៉ូម 15៖13, កាឡាទី 5៖22–23 | ការអោនលំទោន សុភាព សេចក្ដីជំនឿ និងសេចក្ដីសង្ឃឹម។ |
| គ និង ស 8៖2–3 | ចែកចាយយោបល់ទៅក្នុងគំនិត និងអារម្មណ៍ទៅក្នុងដួងចិត្ត។ |
| គ និង ស 128៖1 | ជាប់ក្នុងសតិ ហើយជ្រួតជ្រាបក្នុងអារម្មណ៍។ |
| យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1៖11–12 | ជួយឲ្យខគម្ពីរមានឥទ្ធិពលខ្លាំង។ |
| គ និង ស 9៖8–9 | ធ្វើឲ្យមានអារម្មណ៍ល្អដើម្បីបង្រៀន បើអ្វីមួយជាការពិត។ |
| អាលម៉ា 32៖28, គ និង ស 6៖14–15, កូរិនថូសទី 1 2៖9–11 | បំភ្លឺគំនិត។ |
| អាលម៉ា 19៖6 | ប្ដូរភាពងងឹតទៅជាពន្លឺ។ |
| ម៉ូសាយ 5៖2–5 | ពង្រឹងសេចក្ដីប៉ងប្រាថ្នាដើម្បីជៀសវាងអំពើអាក្រក់ និងគោរពប្រតិបត្តិតាមព្រះបញ្ញត្តិ។ |
| យ៉ូហាន 14៖26 | បង្រៀនសេចក្ដីពិត ហើយធ្វើឲ្យចងចាំសេចក្ដីពិត។ |
| យ៉ូហាន 14៖27 | ធ្វើឲ្យមានអារម្មណ៍នៃសេចក្ដីសុខសាន្ត និងល្ហល្ហេលោម។ |
| យ៉ូហាន 16៖13 | ណែនាំទៅកាន់សេចក្ដីពិត និងបង្ហាញអ្វីដែលនឹងមក។ |

កំណត់ចំណាំ

| | |
|---|---|
| ម៉ូរ៉ូណៃ 10:5 | បើកសម្ដែងសេចក្ដីពិត។ |
| គ និង ស 45:57 | ណែនាំ និងការពារពីការបំភាន់។ |
| នីហ្វៃទី 2 31:18, គ និង ស 20:27, យ៉ូហាន 16:14 | លើកដំកើង និងថ្លែងពីព្រះជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ។ |
| គ និង ស 42:16, 84:85, 100:5–8, លូកា 12:11–12 | ការដឹកនាំពាក្យនៃគ្រូដែលសុភាពរាបសា។ |
| យ៉ូហាន 16:8 | ស្គាល់ និងកែលំអពីអំពើបាប។ |
| ម៉ូរ៉ូណៃ 10:8–17, គ និង ស 46:8–26, កូរិនថូសទី 1 12 | ផ្ដល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។ |
| អាលម៉ា 10:17, 12:3, 18:16, 20, 32, 35, គ និង ស 63:41 | ជួយដើម្បីសង្កេត ឬមើលឃើញគំនិតអ្នកដទៃ។ |
| គ និង ស 46:30, 50:29–30 | ប្រាប់អ្វីដែលត្រូវអធិស្ឋាន។ |
| នីហ្វៃទី 2 32:1–5, គ និង ស 28:15 | ប្រាប់អ្វីដែលត្រូវធ្វើ។ |
| នីហ្វៃទី 1 10:22, អាលម៉ា 18:35 | ជួយមនុស្សសុចរិតនិយាយជាមួយនឹងអំណាច និងសិទ្ធិអំណាច។ |
| គ និង ស 21:9, 100:8, យ៉ូហាន 15:26 | ថ្លែងពីសេចក្ដីពិត។ |
| នីហ្វៃទី 2 31:17, អាលម៉ា 13:12, នីហ្វៃទី 3 27:20 | អភិសេក និងនាំមកនូវការរំដោះបាប។ |
| នីហ្វៃទី 1 2:16–17, នីហ្វៃទី 2 33:1, អាលម៉ា 24:8 | នាំយកសេចក្ដីពិតទៅកាន់ដួងចិត្តនៃអ្នកស្ដាប់។ |
| នីហ្វៃទី 1 1:1–3, និក្ខមនំ 31:3–5 | បង្កើនជំនាញ និងសមត្ថភាព។ |
| នីហ្វៃទី 1 7:15, នីហ្វៃទី 2 28:1, 32:7, អាលម៉ា 14:11, មរមន 3:16, អេធើរ 12:2 | បង្គាប់ (ជម្រុញទៅមុខ) ឬ បញ្ឈប់ (បន្ថយ)។ |
| គ និង ស 50:13–22 | ទាំងគ្រូទាំងសិស្សត្រូវតែមានគ្រឹះ |
| គ និង ស 88:3, យ៉ូហាន 14:26 | ផ្ដល់ឱ្យការលួងលោម |
| | |
| | |
| | |
| | |

ក្នុងការឆ្លើយចំពោះសំនួរដែលថា “តើយើងអាចស្គាល់ការបំផុសនៃព្រះវិញ្ញាណបាន យ៉ាងដូចម្ដេច?” ប្រធាន គរដុន ប៊ី ហ៊ិងគ្លី បានអានទៅក្នុងម៉ូរ៉ូណៃ 7:13, 16–17 ហើយបន្ទាប់មកលោកបានមានប្រសាសន៍ថា: “នោះគឺជាការសាកល្បង នៅពេលដែលអ្វីៗត្រូវបាននិយាយ និងត្រូវបានធ្វើ។ តើវាបញ្ចុះបញ្ចូលមនុស្សម្នាក់ឱ្យធ្វើល្អ ឱ្យរីកចំរើន ឱ្យឈរខ្ពស់ ឱ្យធ្វើអ្វីដែលត្រូវ ឱ្យមានចិត្តល្អ ឱ្យមានចិត្តសប្បុរស ដែរឬទេ? នោះគឺជាព្រះវិញ្ញាណនៃព្រះ . . . ។

“អ្វីដែលនាំឱ្យធ្វើល្អ គឺមកពីព្រះ។ អ្វីដែលនាំឱ្យធ្វើអាក្រក់ គឺមកពីអារក្ស . . . ។ ហើយបើអ្នកធ្វើអ្វីដែលត្រូវ ហើយបើអ្នករស់នៅក្នុងផ្លូវដែលត្រូវ អ្នកនឹងដឹងនៅក្នុងដួងចិត្តរបស់អ្នក ពីអ្វីដែលព្រះវិញ្ញាណបរិសុទ្ធកំពុងនិយាយមកកាន់អ្នក។

“អ្នកអាចស្គាល់ ការបំផុសពីព្រះវិញ្ញាណ ដោយផលផ្លែនៃព្រះវិញ្ញាណ—ដែលបំភ្លឺ ដែលកសាងឡើង ដែលវិជ្ជមាន និងបញ្ជាក់ និងលើកដំកើង និងដឹកនាំយើងទៅកាន់គំនិតដែលប្រសើរជាង និងពាក្យដែលល្អជាង និងអំពើដែលល្អជាង នោះគឺជាព្រះវិញ្ញាណនៃព្រះ” (*Teachings of Gordon B. Hinckley*, 260–61)។

ព្រះឆ្លើយតបការអធិស្ឋានរបស់អ្នក តាមរយៈការបំផុសគំនិត និងវិវរណៈផ្ទាល់ខ្លួន។ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ទ្រង់នឹង ដឹកនាំអ្នកនៅក្នុងការខិតខំស្វែងរករបស់អ្នក នៅពេលដែលអ្នកបង្រៀនដំណឹងល្អដែលបានស្ដារឡើងវិញ ហើយនៅពេលដែល អ្នកពង្រឹងសមាជិកដែលមិនសូវសកម្ម និងអ្នកផ្លាស់សាសនាថ្មី។ កិច្ចការរបស់អ្នក គឺដើម្បីរស់នៅឱ្យមានភាពសក្តិសម អធិស្ឋាន ឱ្យបានញឹកញាប់ និងរៀនដើម្បីស្គាល់ និងធ្វើតាមដោយក្លាហានតាមការដឹកនាំរបស់ព្រះវិញ្ញាណ។

## ពឹងផ្អែកទៅលើព្រះវិញ្ញាណ

ក្នុងនាមជាអ្នកបំរើរបស់ព្រះអម្ចាស់ អ្នកគឺត្រូវធ្វើកិច្ចការរបស់ទ្រង់ នៅក្នុងផ្លូវរបស់ទ្រង់ និងអំណាចរបស់ទ្រង់។ អ្នកផ្សព្វផ្សាយសាសនាខ្លះ មានអារម្មណ៍ជឿជាក់ថា ពួកគេដឹងពីរបៀបដើម្បីទទួលបានជោគជ័យ។ អ្នកខ្លះបាត់បង់នូវការទុកចិត្តនោះ។ ទោះបីជាយ៉ាងណាក៏ដោយ សូមចងចាំថា ការជឿជាក់ និងសេចក្ដីជំនឿរបស់អ្នក គួរតែមាននៅក្នុងព្រះគ្រីស្ទ មិនមែននៅ លើខ្លួនឯងទេ។ ពឹងផ្អែកទៅ

កំណត់ចំណាំ

លើព្រះវិញ្ញាណ ជាជាងនៅលើទេព្យកោសល និងសមត្ថភាពផ្ទាល់ខ្លួនរបស់អ្នក។ ទុកចិត្តនៅលើព្រះវិញ្ញាណ ដើម្បីដឹកនាំអ្នកនៅគ្រប់ស្ថានភាពទាំងអស់នៃកិច្ចការរបស់អ្នក។ ព្យាការីយ៉ូសែប ស៊្មីធ បានបង្រៀនថា ព្រះវិញ្ញាណ គឺជាគ្រឹះក្នុងការបង្រៀន និងការផ្សព្វផ្សាយៈ

គ្មានមនុស្សណាម្នាក់អាចផ្សាយដំណឹងល្អដោយគ្មានព្រះវិញ្ញាណទេ” (*History of the Church*, 2៖477)។

“អ្នកខ្លះត្រូវបានហៅ និងតែងតាំងដោយព្រះវិញ្ញាណនៃវិវរណៈ និងព្យាករណ៍ ហើយចាប់ផ្ដើមផ្សាយដូចជាព្រះវិញ្ញាណផ្ដល់ឱ្យគេនូវសូរសំលេង និងទោះជាពួកគេខ្សោយ តែពួកគេត្រូវបានពង្រឹងដោយព្រះចេស្ដានៃព្រះ” (*ប្រវត្តិនៃសាសនាចក្រ 4៖538)*។

“[យ៉ូសែប ស៊្មីធ] បណ្ដាលឱ្យផ្ដល់ការណែនាំចំពោះក្រុមអែលឌើរ ដែលគាំទ្រផ្សាយដំណឹងល្អ និងសង្កត់ធ្ងន់ទៅលើពួកគេ ពីការចាំបាច់ដើម្បីទទួលបានព្រះវិញ្ញាណ ដើម្បីពួកគេអាចផ្សាយជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធ ដែលបានបញ្ជូនមកពីស្ថានសួគ៌” (*History of the Church*, 4៖13)។

នៅកំឡុងសម័យប្រជុំផែនការជារៀងរាល់សប្ដាហ៍ និងប្រចាំថ្ងៃរបស់អ្នក អ្នកនឹងត្រូវការសួរសំនួរមូលដ្ឋានខ្លះៗជារៀងរាល់ថ្ងៃ—ទោះច្រើនដងរាល់ថ្ងៃ (សូមមើលប្រអប់ការសិក្សាព្រះគម្ពីរដែលមានដូចខាងក្រោម សំរាប់គំរូនៃសំនួរ)។ ចូរស្វែងរក ការបំផុសគំនិតដើម្បីឆ្លើយតបចំពោះសំនួរទាំងនេះ ក្នុងរបៀបដែលស្គាល់ពីស្ថានភាពនីមួយៗ។ ចំលើយគួរតែយកមកប្រើនៅ ក្នុងផែនការរបស់អ្នក។ តែអ្នកក៏ត្រូវមានឆន្ទៈដើម្បីធ្វើតាមព្រះវិញ្ញាណ និងផ្លាស់ប្ដូរផែនការរបស់អ្នក នៅពេលដែលមិន អាចមើលឃើញឱកាសរីកចំរើន។

ចូរសិក្សាខគម្ពីរដូចខាងក្រោម និងពិចារណាពីរបៀបដែលខគម្ពីរទាំងនេះ ឆ្លើយតបចំពោះសំនួរសំខាន់ៗ ទាំងនេះ ដែលអ្នកគួរតែសួររាល់ថ្ងៃ។ ចូរពិចារណាពីសារលិខិតទាំងនេះ វាមានអត្ថន័យសំរាប់ការខិតខំស្វែងរករបស់អ្នក ពេលប្រជុំធ្វើផែនការ និងសិក្សាផ្ទាល់ខ្លួន និងជាមួយដៃគូ។ ផងដែរ សូមពិចារណាពីអត្ថន័យនៃសំនួរទាំងនេះ នៅពេលដែល អ្នកបង្រៀនមេរៀន អញ្ជើញពួកគេឱ្យធ្វើការតាំងចិត្ត តាមដាននូវការតាំងចិត្ត ពង្រឹងសមាជិកថ្មី និងសមាជិកមិនសូវសកម្ម និងធ្វើការជាមួយសមាជិក។

## ការសិក្សាព្រះគម្ពីរ

### តើខ្ញុំគួរតែទៅកន្លែងណា?

| | |
|---|---|
| ហេលេមិន 10៖17 | គ និង ស 75៖26–27 |
| គ និង ស 31៖11 | គ និង ស 79៖1–2 |

### តើខ្ញុំគួរតែធ្វើអ្វី?

| | |
|---|---|
| នីហ្វៃទី 1 4៖6 | គ និង ស 28៖15 |
| នីហ្វៃទី 2 32៖2–5 | គ និង ស 52៖3–4 |

### តើខ្ញុំគួរតែនិយាយអ្វី?

| | | |
|---|---|---|
| នីហ្វៃទី 2 33៖1 | គ និង ស 33៖8–10 | ម៉ាថាយ 10៖19–20 |
| អាលម៉ា 5៖43–46 | គ និង ស 50៖13–22 | ម៉ាកុស 13៖11 |
| អាលម៉ា 11៖22 | គ និង ស 68៖1–4 | កូរិនថូសទី 1 2៖4–5, 12–13 |
| ហេលេមិន 5៖18 | គ និង ស 75៖3–11 | ទិក្ខុមទំ 4៖10–12 |
| ហេលេមិន 13៖3–5 | គ និង ស 100៖5–8 | |

### តើខ្ញុំអាចធ្វើឱ្យការបង្រៀនរបស់ខ្ញុំ ប្រែប្រួលទៅតាមសេចក្ដីត្រូវការនៃសាសនាគន់ការី យ៉ាងដូចម្ដេច?

| | | |
|---|---|---|
| អាលម៉ា 12៖7 | នីហ្វៃទី 3 17៖2–3 | គ និង ស 84៖85 |
| អាលម៉ា 41៖1 | គ និង ស 71៖1 | |

### តើព្រះខគម្ពីរមួយណាដែលខ្ញុំគួរតែប្រើ ហើយតើខ្ញុំគួរតែប្រើខគម្ពីរទាំងនោះ ដោយរបៀបណា?

| | | |
|---|---|---|
| ម៉ូសាយ 18៖19–20 | គ និង ស 32៖4 | គ និង ស 71៖1 |
| ម៉ូសាយ 27៖35 | គ និង ស 42៖11–17 | គ និង ស 80៖4 |
| គ និង ស 18៖32–36 | គ និង ស 68៖1–4 | លូកា 24៖13–32 |

កំណត់ចំណាំ

## ពាក្យនៃការដាស់តឿន

នៅពេលដែលអ្នកអធិស្ឋានសំរាប់ការបំផុសគំនិត អ្នកគួរតែបញ្ជាក់អារម្មណ៍របស់អ្នក។ ឧទាហរណ៍ ប្រៀបធៀបការសំរេចចិត្ត របស់អ្នកជាមួយនឹងព្រះគម្ពីរ និងការបង្រៀនពៃព្យាការីដែលនៅរស់។ ចូរប្រាកដថា អារម្មណ៍គឺដូចគ្នានឹងកិច្ចការដែលអ្នកមាន ឧទាហរណ៍ អ្នកនឹងមិនទទួលវិវរណៈដើម្បីប្រាប់ប៊ីស្សពនៅក្នុងតំបន់ ពីរបៀបដែលគាត់គួរតែដឹកនាំក្នុងការហៅបំរើរបស់គាត់ទេ។ ពិភាក្សាការសំរេចចិត្ត និងដំណោះស្រាយរបស់អ្នកជាមួយនឹងដៃគូ អ្នកដឹកនាំមណ្ឌល ឬប្រធានបេសកកម្មរបស់ អ្នកនៅពេលដែលសមរម្យ។

ប្រធាន ហាវើដ ដបុលយូ ហីនធើរ បានបានផ្តល់ឱ្យនូវពាក្យទូន្មាននេះៈ “ខ្ញុំសូមចែកចាយពាក្យទូន្មានខ្លះៗ . . . ខ្ញុំគិតថា បើយើងមិនប្រយត្ន . . . យើងប្រហែលជាចាប់ផ្តើមព្យាយាមធ្វើឱ្យឥទ្ធិពលពិតនៃព្រះវិញ្ញាណនៃព្រះអម្ចាស់មានលក្ខណៈក្លែងក្លាយដោយគ្មានភាពសក្តិសម និងអត្ថន័យបោកបញ្ឆោត។ ខ្ញុំមានចំងល់ នៅពេលដែលការណ៍នេះលេចឡើងនូវការរំជួលចិត្ត យ៉ាងខ្លាំង ឬទឹកភ្នែកហូរមក គឺស្មើគ្នានឹងវត្តមាននៃព្រះវិញ្ញាណ។ ពិតប្រាកដណាស់ ព្រះវិញ្ញាណនៃព្រះអម្ចាស់អាចនាំមកនូវអារម្មណ៍ រំជួលចិត្តយ៉ាងខ្លាំង ដោយមានទាំងទឹកភ្នែក តែការបង្ហាញខាងក្រៅនោះ មិនត្រូវយល់ច្រឡំជាមួយនឹងវត្តមាននៃព្រះវិញ្ញាណ ទ្រង់ផ្ទាល់ឡើយ” (*The Teachings of Howard W. Hunter*, 184)។ ព្រះវិញ្ញាណនៃព្រះអម្ចាស់ តែងតែបំភ្លឺ។

> *“បើមានភាពសក្តិសម យើងមានសិទ្ធិទទួលវិវរណៈសំរាប់ខ្លួនរបស់យើងផ្ទាល់ ឪពុកម្តាយសំរាប់កូនចៅ និងសមាជិកនៃសាសនាចក្រ នៅក្នុងការហៅបំរើរបស់គេ។ តែសិទ្ធិនៃវិវរណៈសំរាប់អ្នកដទៃមិនមែនជាការទទួលខុសត្រូវរបស់យើងទេ។”*
>
> — ប្រធាន ជេម អ៊ី ហ្វោស៍
> “COMMUNION WITH THE HOLY SPIRIT,”
> *ENSIGN*, MAR. 2002, 4

វិវរណៈ និងបទពិសោធន៍ខាងវិញ្ញាណ គឺពិសិដ្ឋ។ វិវរណៈ និងបទពិសោធន៍ខាងវិញ្ញាណគួរតែរក្សាផ្ទាល់ខ្លួន និងលើកមកពិភាក្សាតែក្នុងស្ថានភាពសមរម្យប៉ុណ្ណោះ។ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា អ្នកប្រហែលជាដឹងពីបទពិសោធន៍ខាងវិញ្ញាណជាងអ្នក ធ្លាប់មានពីមុននៅក្នុងជីវិតរបស់អ្នក។ មិនព្រមចុះចាញ់ការល្បួង ដើម្បីនិយាយដោយសេរីអំពីបទពិសោធន៍ទាំងនេះ។

ប្រធាន ប៊យឃេ ផាកកឺ បានទូន្មានថាៈ “ខ្ញុំបានរៀនយ៉ាងច្រើនថា ការបង្ហាញបទពិសោធន៍ខាងវិញ្ញាណមិនមកចំពោះយើងជាញឹកញាប់ទេ។ បើបទពិសោធន៍នោះមក បទពិសោធន៍នោះគឺជាទូទៅ សំរាប់ស្ថាបនា ការដឹកនាំ ការកែលំអរបស់យើង។ លើកលែងតែយើងត្រូវបានហៅដោយសិទ្ធិអំណាចដែលត្រឹមត្រូវដើម្បីធ្វើដូច្នេះ បទពិសោធន៍ទាំងនោះមិនមែនផ្តល់សិទ្ធិឱ្យ យើងដើម្បីទូន្មាន ឬដើម្បីកែលំអដល់អ្នកដទៃទេ។

“ខ្ញុំក៏ជឿផងដែរថា វាមិនមែនជាភាពឆ្លាតវៃទេ ដើម្បីបន្តនិយាយពីបទពិសោធន៍ខាងវិញ្ញាណដែលមិនធម្មតា។ បទពិសោធន៍ទាំងនោះត្រូវតែការពារថែរក្សា និងចែកចាយតែពេលណាដែលព្រះវិញ្ញាណបំផុសអ្នក ឱ្យប្រើបទពិសោធន៍ទាំងនោះ ដើម្បីប្រទានពរដល់អ្នកដទៃ” (*Ensign*, Jan. 1983, 53)។

### ការសិក្សាព្រះគម្ពីរ

ការពឹងផ្អែកទៅលើព្រះវិញ្ញាណគឺសំខាន់ខ្លាំងណាស់ ដែលព្រះអម្ចាស់បានព្រមានដល់យើងយ៉ាងខ្លាំង កុំបដិសេធន៍ ឬធ្វើឱ្យព្រះវិញ្ញាណថាកចេញ។ តើអ្នករៀនអ្វីខ្លះ ចេញពីសារលិខិតនៃព្រះគម្ពីរដូចខាងក្រោម?

| | | |
|---|---|---|
| យ៉ាកុប 6:8–9 | មរមន 9:7–9 | គ និង ស 11:25–26 |
| នីហ្វៃទី 3 29:5–6 | ម៉ូរ៉ូណៃ 10:7–8 | ថែស្សាឡូនីចទី1 5:19–20 |

### ចូរចងចាំចំណុចនេះ

- អធិស្ឋានជាមួយសេចក្តីជំនឿ ការអធិស្ឋានរបស់អ្នកនឹងត្រូវបានឆ្លើយ។
- រៀនដើម្បីយល់ ស្គាល់ និងធ្វើតាមការបំផុសនៃព្រះវិញ្ញាណ។
- រៀនដើម្បីពឹងទៅលើព្រះវិញ្ញាណ ដើម្បីបង្ហាញអ្នកកន្លែងដែលត្រូវទៅ អ្វីដែលត្រូវធ្វើ និងអ្វីដែលត្រូវនិយាយ។
- បង្រៀនអ្នកដទៃពីរបៀបដើម្បីស្គាល់ព្រះវិញ្ញាណ។

កំណត់ចំណាំ

# គំនិតសំរាប់ការសិក្សា និងការអនុវត្ត

## ការសិក្សាផ្ទាល់ខ្លួន

- កត់ត្រាបទពិសោធន៍ខាងវិញ្ញាណរបស់អ្នកនៅក្នុងសៀវភៅទិន្នានុប្បវត្តិរបស់អ្នក។ ឧទាហរណ៍ ឆ្លើយនូវសំនួរដូចជា៖ តើខ្ញុំយល់អ្វីមួយ ប្រសើរជាងដែរឬទេ នៅពេលដែលខ្ញុំសិក្សាពីព្រះគម្ពីរ? តើខ្ញុំមានឱកាសមិនធម្មតាទៅជួបនរណាម្នាក់ ដែលខ្ញុំអាចចែកចាយសារដំណឹងជាមួយ ដែរឬទេ? តើខ្ញុំត្រូវបានប្រទានឱ្យដោយពាក្យសំដីដើម្បីនិយាយ នៅពេលដែលខ្ញុំត្រូវការដែរឬទេ? តើខ្ញុំមានអារម្មណ៍នៃសេចក្ដីស្រលាញ់យ៉ាងខ្លាំង សំរាប់មនុស្សដែលខ្ញុំបានជួប ដែរឬទេ? តើការអធិស្ឋានរបស់ខ្ញុំបានឆ្លើយតបដែរឬទេ?

- បំបែកក្រដាសចេញជាពីរកូឡោន។ ដាក់កូឡោនម្ខាង "អ្វីដែលព្រះអម្ចាស់បានធ្វើ" និងកូឡោនម្ខាងទៀត "អ្វីដែល លីហៃ និងនីហ្វៃបានធ្វើ។" អានរឿងនៃលេអាហូណា និងធ្នូបាក់ (នីហ្វៃទី 1 16៖9–30) ឬរឿងនៃនីហ្វៃសាងសំពៅ (នីហ្វៃទី 1 17៖7–16, 18៖1–6)។ នៅពេលដែលអ្នកអាន សរសេរនូវព្រឹត្តិការណ៍ចេញពីរឿង នៅក្នុងកូឡោនដែលសមរម្យ។ ពិចារណារឿងអ្វីដែលអាចបង្រៀនអ្នក អំពីនិស្ស័យនៃការបំផុសគំនិត។

- មើលនៅក្នុងសៀវភៅទិន្នានុប្បវត្តិរបស់អ្នក និងស្វែងរកឱកាសដែលអ្នក ត្រូវបានដឹកនាំដោយព្រះវិញ្ញាណ ឬបទពិសោធន៍នៃការទទួលវិវរណៈ ឬអំណោយទាននៃព្រះវិញ្ញាណផ្សេងទៀត។ គិតអំពីពេលវេលា ទីកន្លែង និងហេតុអ្វី បទពិសោធន៍ទាំងនេះកើតឡើង។ តើអ្នកមានបានធ្វើអ្វីមួយជាក់លាក់ ដើម្បីរៀបចំខ្លួនរបស់អ្នក សំរាប់បទពិសោធន៍ដូច្នោះទេ? តើព្រះហស្តរបស់ព្រះអម្ចាស់បានបង្ហាញយ៉ាងដូចម្ដេច នៅក្នុងបទពិសោធន៍នេះ? តើអ្នកមានអារម្មណ៍ដូចម្ដេច? តើអ្នកអាច ធ្វើអ្វី ដើម្បីទទួលបានបទពិសោធន៍ស្រដៀងគ្នានេះ? ចូរចងចាំថា បទពិសោធន៍ទាំងនេះ អាចជួយអ្នកស្គាល់ និងទទួលព្រះវិញ្ញាណម្ដងទៀត។

- ព្រះគម្ពីរកិច្ចការនៃពួកសាវកនៅក្នុងព្រះគម្ពីរបរិសុទ្ធត្រូវបានហៅថា៖ "ព្រះគម្ពីរនៃកិច្ចការពួកសាវក នៃព្រះវិញ្ញាណ បរិសុទ្ធតាមរយៈសាវក។" ចូរអានជំពូកត្បាល់រឿងនៃព្រះគម្ពីរកិច្ចការនៃពួកសាវក និងពន្យល់ហេតុអ្វីចំណងជើងនេះ ត្រឹមត្រូវ។ ស្វែងរកភស្ដុតាង ដើម្បីបញ្ជាក់ពីការពន្យល់របស់អ្នក។

- សិក្សា និងពិចារណានូវតំបូន្មានដូចខាងក្រោម។ តើតំបូន្មាននោះអាចអនុវត្តនៅក្នុងសកម្មភាពផ្សព្វផ្សាយប្រចាំថ្ងៃ របស់អ្នកបានយ៉ាងដូចម្ដេច?

  > "ប្រាប់បងប្អូនប្រុសឱ្យបន្ទាបខ្លួន និងស្មោះត្រង់ និងប្រាកដក្នុងការធ្វើតាមព្រះវិញ្ញាណនៃព្រះអម្ចាស់ ដែលព្រះវិញ្ញាណនឹងដឹកនាំពួកគេត្រឹមត្រូវ។ ចូរប្រយ័ត្ន ហើយមិនងាកចេញពីសំលេងតូចរហៀង សំលេងតូចរហៀងនឹងបង្រៀនពួកគេ ពីអ្វីដែលត្រូវធ្វើ និងទីកន្លែងដែលត្រូវទៅ សំលេងតូចរហៀងនឹងនាំមកនូវផលផ្លែនៃនគរ។ ប្រាប់ដល់បងប្អូនប្រុស ឱ្យរក្សាដួងចិត្តរបស់គេបើកចំហរចំពោះភាពពិតប្រាកដ ដើម្បីនៅពេលដែលព្រះវិញ្ញាណបរិសុទ្ធយាងមកកាន់ពួកគេ ដួងចិត្តរបស់គេ នឹងត្រៀមលក្ខណៈជាស្រេចដើម្បីទទួលព្រះវិញ្ញាណ។ ពួកគេអាចដឹងពីព្រះវិញ្ញាណនៃព្រះអម្ចាស់ ខុសពីវិញ្ញាណផ្សេងៗទាំងអស់ —ព្រះវិញ្ញាណនឹងខ្សឹបប្រាប់សេចក្ដីសុខសាន្ត និងសេចក្ដីអំណរទៅក្នុងដួងព្រលឹងរបស់ពួកគេ ព្រះវិញ្ញាណនឹងយកចេញនូវ អារម្មណ៍ព្យាបាទ ទោសៈ ការលំបាក និងអារក្សចេញពីដួងចិត្តរបស់គេ និងបំណងប្រាថ្នាទាំងមូលរបស់គេគឺដើម្បីធ្វើល្អ" (ដកស្រង់ចេញពី *Juvenile Instructor*, 19 July 1873, 114)។

  ព្យាការីយ៉ូសែប ស្ម៊ីធ បានចែកចាយនូវតំបូន្មាននេះទៅកាន់ ព្រីហ្គាំ យ៉ង់ នៅក្នុងសុបិនជិតបីឆ្នាំបន្ទាប់ពីសេចក្ដីស្លាប់ របស់យ៉ូសែប ស្ម៊ីធ។ បើអ្នកជា ព្រីហ្គាំ យ៉ង់ ហើយទទួលតំបូន្មាននេះ តើអ្នកនឹងធ្វើអ្វី?

- សិក្សាអាលម៉ា 33៖1–12, 34៖17–29, 38។ តើសំនួរអ្វីដែលអាលម៉ាកំពុងឆ្លើយ? (រំលឹកឡើងវិញ អាលម៉ា 33៖ 1–2។) តើអាលម៉ាបានឆ្លើយសំនួរទាំងនេះ ដោយរបៀបណា? តើការអះអាងអ្វី ដែលគាត់បានបញ្ជាក់ថា ព្រះលី និងឆ្លើយការ អធិស្ឋាន?

- ព្រះអម្ចាស់បានសន្យាថា ព្រះវិញ្ញាណនឹងដឹកនាំយើងតាមវិធីសំខាន់ៗជាច្រើន។ នៅពេលដែលអ្នកអានសារលិខិត ដូចខាងក្រោម ដើម្បីស្គាល់ពីទិដ្ឋិភាពនៃកិច្ចការរបស់អ្នក ដែលត្រូវការ ការដឹកនាំនៃព្រះវិញ្ញាណ។ តើព្រះបញ្ញត្តិ និងការសន្យា នៅក្នុងព្រះគម្ពីរ មានអត្ថន័យសំរាប់ការសិក្សាផ្ទាល់ខ្លួន និងជាមួយដៃគូរបស់អ្នកយ៉ាងណាខ្លះ? សំរាប់ការប្រជុំមណ្ឌល សន្និសីទ ហ្សូន ការបំរើពិធីបុណ្យជ្រមុជទឹក និងសំរាប់ការប្រជុំផ្សេងៗទៀត អ្វីខ្លះ?

### ការអធិស្ឋាន

| | |
|---|---|
| នីហ្វៃទី 3 19៖24 | គ និង ស 50៖30 |
| គ និង ស 46៖30 | រ៉ូម 8៖26 |

**ការដឹកនាំការប្រជុំ**

| | | |
|---|---|---|
| មរ៉ូណៃ 6:9 | គ និង ស 20:45 | គ និង ស 46:2 |

**ការសរសេរ**

| | | |
|---|---|---|
| គ និង ស 9:9 | គ និង ស 47:4 | គ និង ស 124:4 |
| គ និង ស 24:6 | គ និង ស 104:81 | ម៉ូសេ 6:6 |

- ចូរអានសារលិខិតខគម្ពីរដូចខាងក្រោម (បូករួមទាំងកណ្ឌក្បាល់រឿងទាំងនេះ)។

| | | |
|---|---|---|
| គ និង ស 60:1–5 | គ និង ស 61:1–4, 21–22 | គ និង ស 62:4–8 |

នៅក្នុងដំណើររឿងនេះ តើអ្វីសំខាន់ចំពោះព្រះអម្ចាស់?

តើអ្វីដែលមិនសំខាន់ចំពោះព្រះអម្ចាស់?

ពិចារណាសេចក្តីថ្លែងដូចខាងក្រោម ដោយអែលឌើរ ដាល់លិន អេចអូក្ស៍:

"[មនុស្សម្នាក់អាចមាន] បំណងប្រាថ្នាយ៉ាងខ្លាំង ដើម្បីទទួលបានការដឹកនាំពីព្រះវិញ្ញាណនៃព្រះអម្ចាស់តែ . . . ភាពមិនឆ្លាតវៃពង្រីកបំណងប្រាថ្នានោះ ដល់ចំនុចមួយដែលត្រូវបានដឹកនាំនៅក្នុងគ្រប់រឿង *ទាំងអស់* ។ បំណងប្រាថ្នា ដើម្បី ទទួលបានការដឹកនាំដោយព្រះអម្ចាស់ គឺជាកំលាំង តែវាត្រូវការចូលរួមដោយការយល់ដឹងថា ព្រះវរបិតាសួគ៌បាន ផ្តល់ឱ្យនូវការសំរេចចិត្តជាច្រើន សំរាប់ការជ្រើសរើសផ្ទាល់ខ្លួនរបស់យើង។ ការធ្វើការសំរេចចិត្តផ្ទាល់ខ្លួន គឺជាធនធានមួយ នៃការរីកចំរើនរបស់យើង ដែលមានន័យជាបទពិសោធន៍នៅក្នុងជីវិតរមែងស្លាប់។ មនុស្សដែលព្យាយាមផ្លាស់ប្តូរ នូវការសំរេចចិត្តទាំងអស់ចំពោះព្រះអម្ចាស់ និងសូមសំរាប់វិវរណៈនៅក្នុងគ្រប់ការជ្រើសរើសទាំងអស់ឆាប់ៗនឹងធ្លាក់ក្នុង កាលៈទេសៈមួយដែលគេអធិស្ឋានសំរាប់ការដឹកនាំ ហើយមិនទទួលចំលើយ។ ឧទាហរណ៍ រឿងនេះដូចជាការកើតឡើងក្នុងការ កាលៈទេសៈជាច្រើនដែលការជ្រើសរើសមិនមានតំលៃ ឬការជ្រើសរើសគឺមិនអាចទទួលស្គាល់បាន។

"យើងគួរតែសិក្សាពីរឿងនៅក្នុងគំនិតរបស់យើង ដោយការប្រើការពិចារណាលើអំណាចនៃអ្នកបង្កើតរបស់យើង ដែលមាននៅជាមួយយើង។ បន្ទាប់មកយើងគួរអធិស្ឋាន សំរាប់ការដឹកនាំ និងប្រព្រឹត្តតាមនៅពេលដែលយើងទទួលអារម្មណ៍ នោះ។ បើយើងមិនទទួលការដឹកនាំ យើងគួរតែធ្វើតាមការវិនិច្ឆ័យដ៏ប្រសើររបស់យើង។ មនុស្សដែលមានចិត្តមានះក្នុងការស្វែងរកការដឹកនាំដោយវិវរណៈនៅក្រោមអំណាច ដែលព្រះអម្ចាស់មិនបានជ្រើសរើស ដើម្បីដឹកនាំយើងអាចប្រើចំលើយដែលប្រឌិត ចេញពីចិត្តរបស់គេ ឬគំនិតវៀចវេ ឬពួកគេប្រហែលជាទទួលវិវរណៈតាមរយៈរូបអារក្សនៃវិវរណៈក្លែងក្លាយ។" ("Our Strengths Can Become Our Downfall," *Ensign*, Oct. 1994, 13–14)។

តើទំនាក់ទំនងរវាង ការធ្វើតាមការវិនិច្ឆ័យផ្ទាល់ខ្លួនរបស់អ្នក និងការពឹងទៅលើព្រះវិញ្ញាណ ជាអ្វី?

## ការសិក្សាជាមួយដៃគូ

- និយាយអំពីការអធិស្ឋានដែលអ្នកបានធ្វើ ក្នុងនាមជាដៃគូ។ តើការអធិស្ឋាននោះ ត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធឬ? តើអ្នកបានទទួលចំលើយចំពោះការអធិស្ឋានរបស់អ្នក ដែរឬទេ? ពេលដែលអ្នកអធិស្ឋានក្នុងនាមជាដៃគូ តើអ្នកមានះ
  - ជំនឿថា ព្រះនឹងផ្តល់ឱ្យអ្នក អ្វីដែលអ្នកសូមសំរាប់ការណ៍សុចរិត ដែរឬទេ?
  - ទទួលស្គាល់ និងថ្លែងអំណរគុណសំរាប់ចំលើយចំពោះការអធិស្ឋានរបស់អ្នក ដែរឬទេ?
  - អធិស្ឋានសំរាប់មនុស្សទូទៅ ដោយហៅឈ្មោះម្នាក់ៗ និងពិចារណាទៅលើសេចក្តីត្រូវការរបស់គេដែរឬទេ?
  - អធិស្ឋានឱ្យគ្នាទៅវិញទៅមក និងសំរាប់ការណែនាំពីព្រះវិញ្ញាណ ដែរឬទេ?
  - ទទួលចំលើយចំពោះការអធិស្ឋានរបស់អ្នក ដែរឬទេ?

  ពិភាក្សាជាមួយដៃគូ ពីរបៀបដែលអ្នកនឹង ស្វែងរកព្រះវិញ្ញាណឱ្យរឹតតែអស់ពីដួងចិត្ត។

- ពិភាក្សាពីវិធីខុសៗគ្នា ដែលមនុស្សបានពិពណ៌នាពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ។ សរសេរពាក្យអធិប្បាយដែល សាសនាគន់ការីបាននិយាយអំពីបទពិសោធន៍ដែលបានទទួលពីព្រះវិញ្ញាណ នៅក្នុងការសិក្សាដំណឹងល្អ និងការព្យាយាម ដើម្បីរក្សាការតាំងចិត្ត។ តើអ្នកអាចជួយអ្នកដទៃស្គាល់ពីឥទ្ធិពលដ៏ពិសិដ្ឋនេះបាន យ៉ាងដូចម្តេច? តើអ្នកអាចជៀសវាង ពីការគ្រប់គ្រងនេះ ដោយរបៀបណា នៅពេលដែលអ្នកធ្វើដូច្នេះ?

កំណត់ចំណាំ

កំណត់ចំណាំ

- ពិចារណា និងពិភាក្សាពីពាក្យតំបូន្មានខាងក្រោមនេះដែលអនុវត្តចំពោះអ្នកៈ “អ្នកមិនអាចបង្ខំរឿងខាងវិញ្ញាណទេ។ ដូចជាពាក្យ *បង្គាប់ បង្ខិតបង្ខំ បញ្ជា ការគាបសង្កត់ ទាមទារ* មិនបានពិពណ៌នានូវឯកសិទ្ធិរបស់យើងជាមួយនឹងព្រះវិញ្ញាណទេ។ អ្នកមិនអាចបង្ខិតបង្ខំព្រះវិញ្ញាណដើម្បីឆ្លើយតប ដូចជាអ្នកមិនអាចធ្វើឱ្យសណ្ដែកមានពន្លក ឬស៊ុតឱ្យញាស់មុនពេលកំណត់នោះទេ។ អ្នកអាចបង្កើតបរិយាកាសដើម្បីចិញ្ចឹម រីកលូតលាស់ បីបាច់ និងការពារ តែអ្នកមិនអាចបង្ខិតបង្ខំ ឬបង្គាប់ៈ អ្នកត្រូវរង់ចាំការរីកលូតលាស់” ( ប៊ីយ ឃេ ផាកកឺ “The Candle of the Lord,” *Ensign*, Jan. 1983, 53)។

- ពិភាក្សានូវការអធិប្បាយដូចខាងក្រោម និងរបៀបដែលគោលការណ៍ទាំងនេះអាចផ្លាស់ប្តូរ ទាំងការអធិស្ឋាន និងកិច្ចការរបស់អ្នក។ តើការអធិស្ឋានរបស់អ្នក មានឥទ្ធិពលលើផែនការ ការដាក់គោលដៅ កិច្ចការ និងសកម្មភាព រាល់ថ្ងៃ របស់អ្នកយ៉ាងដូចម្ដេច?

  “អំពើរបស់យើង នៅក្នុងការរស់នៅដ៏ធំ គឺជាលទ្ធផលពីការអធិស្ឋានរបស់យើង។ ការធ្វើការអធិស្ឋាន សកម្មភាព ការសុំដ៏ត្រឹមត្រូវរបស់យើង មានប្រសិទ្ធិភាពទៅលើផែនការសុចរិតនៃការដឹកនាំរបស់យើង” (ប្រ៊ូស អរ មិកខនឃី “Why the Lord Ordained Prayer,” *Ensign*, Jan. 1976, 12)។

  “ការអធិស្ឋានដោយស្មោះបញ្ជាក់ថា នៅពេលដែលអ្នកសុំ សំរាប់ពរជ័យ ឬគុណធមិ យើងគួរខិតខំប្រឹងប្រែងដើម្បី ទទួលបានពរជ័យ និងខិតខំប្រឹងប្រែងដើម្បីទទួលបានគុណធមិ”(David O. McKay, *Secrets of a Happy Life*, 114–15)។

  “សួរដល់ [ព្រះ] ឱ្យដាក់អ្នកនៅកន្លែងដែលទ្រង់ចង់ឱ្យអ្នកនៅ និងប្រាប់អ្នកអ្វីដែលទ្រង់ចង់ឱ្យអ្នកធ្វើ និងទទួលអារម្មណ៍ថាអ្នកអាចធ្វើវាបាន” (Brigham Young, *Discourses of Brigham Young*, sel. John A. Widtsoe [1954], 46)។

## ការប្រជុំមណ្ឌល និងសន្និសីទហ្សូន

- បង្ហាញមេរៀនមួយ ក្នុងការប្រើភាសាសមរម្យ និងគោរពនៅក្នុងការអធិស្ឋានរបស់អ្នក។

- នៅពេលសមរម្យ ឱ្យអ្នកផ្សព្វផ្សាយសាសនាចែកចាយរឿង ឬបទពិសោធន៍ ដែលពួកគេបានស្ដាប់នៅក្នុងការប្រជុំ ការថ្លែងសក្ខីភាពក្នុងពេលថ្មីៗ បទពិសោធន៍នៃការបង្រៀន ឬគោលដៅផ្សេងៗទៀត។ រឿង និងបទពិសោធន៍ខាងវិញ្ញាណដែលមនុស្សដទៃទៀតប្រាប់អ្នក អាចជួយអ្នកអភិវឌ្ឍន៍សេចក្ដីជំនឿ និងស្គាល់ថា ឥទ្ធិពលនៃព្រះវិញ្ញាណគឺធំទូលាយ និងត្រូវ បានង្ហាញជាញឹកញាប់។

- បង្ហាញអំណរគុណចំពោះការសំដែង នៃព្រះហស្តរបស់ព្រះអម្ចាស់នៅក្នុងកិច្ចការរបស់អ្នក (សូមមើល គ និង ស 59:21)។ ពិភាក្សាពីការបង្ហាញអំណរគុណជួយអ្នក មើលឃើញចំណុចតូច តែជារបៀបដ៏ជាក់លាក់មួយដែលព្រះអម្ចាស់ ប្រទានពរជ័យដល់អ្នក (សូមមើល អេធើរ 3:5)។

- សួរអ្នកផ្សព្វផ្សាយសាសនាឱ្យធ្វើការនិយាយអំពី បេសកកម្ម និងព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ។

- សួរដល់អ្នកផ្លាស់សាសនាថ្មី ឱ្យនិយាយអំពីរបៀបដែលពួកគេ ទទួលឥទ្ធិពលដោយព្រះវិញ្ញាណ ក្នុងនាមជាសាសនាគន់ការីម្នាក់។

## ប្រធានបេសកកម្ម

- តាមពេលវេលាដែលអាចធ្វើទៅបាន សួរអ្នកផ្សព្វផ្សាយសាសនា សរសេរបទពិសោធន៍ខាងវិញ្ញាណ នៅក្នុងសំបុត្រ ប្រចាំសប្ដាហ៍របស់គេ ទៅកាន់អ្នក។

- នៅក្នុងការសម្ភាស តាមពេលវេលាដែលអាចធ្វើទៅបាន សួរអ្នកផ្សព្វផ្សាយសាសនាអំពីការអធិស្ឋាននៅពេលព្រឹក និងពេលល្ងាចរបស់គេ។ សួរពួកគេបើការអធិស្ឋានរបស់គេ គឺមានអត្ថន័យចំពោះពួកគេ។

- សួរអ្នកផ្សព្វផ្សាយសាសនាទាំងឡាយ ពីរបៀបដែលពួកគេជួយដល់សាសនាគន់ការីរបស់គេទទួលអារម្មណ៍ និងស្គាល់ព្រះវិញ្ញាណ។

- តាមដែលពេលសមរម្យ និយាយពីទំនាក់ទំនងជាមួយអ្នកផ្សព្វផ្សាយសាសនា ពីរបៀបដែលអ្នកទទួលវិវរណៈនៅពេលមានការផ្លាស់ប្តូរតំបន់ ចំពោះអ្នកផ្សព្វផ្សាយសាសនាដែលមិនគោរពប្រតិបត្តិ ឬត្រូវការជំនួយ និងត្រូវការគោលលទ្ធិដើម្បីបង្រៀន។



# តើតួនាទីរបស់ព្រះគម្ពីរមរមនគឺជាអ្វី?

កំណត់ចំណាំ

**ចូរពិចារណាចំណុចនេះ**

- តើព្រះគម្ពីរមរមន គឺជាមូលដ្ឋាន នៃសាសនារបស់យើងយ៉ាងដូចម្ដេចដែរ?
- តើព្រះគម្ពីរមរមនឆ្លើយសំនួរធំៗ ខាងព្រលឹងវិញ្ញាណរបស់មនុស្សដោយរបៀបណា?
- តើហេតុអ្វី បានជាព្រះគម្ពីរមរមនមានឥទ្ធិពលយ៉ាងខ្លាំង នៅក្នុងការផ្លាស់សាសនាដូច្នេះ?
- តើខ្ញុំគួរប្រើព្រះគម្ពីរមរមន ដើម្បីសង់សេចក្ដីជំនឿ និងជួយមនុស្សផ្សេងទៀត ឱ្យខិតកាន់តែជិតព្រះដោយរបៀបណា?
- តើហេតុអ្វីក៏ សេចក្ដីសន្យានៅក្នុងមរ៉ូណៃ 10:3–5 សំខាន់នៅក្នុងកិច្ចការអ្នកផ្សព្វផ្សាយសាសនា?

ព្រះគម្ពីរមរមន គឺជាភស្តុតាងដ៏មានឥទ្ធិពល អំពីទេវភាពនៃព្រះគ្រីស្ទ។ ព្រះគម្ពីរ ក៏ជាភស្តុតាងនៃការស្ដារឡើងវិញ តាមរយៈព្យាការីយ៉ូសែប ស្ម៊ីធផងដែរ។ ផ្នែកសំខាន់មួយ នៃការផ្លាស់សាសនា គឺជាការទទួលសាក្សីមួយ មកពីព្រះវិញ្ញាណបរិសុទ្ធថាព្រះគម្ពីរមរមនពិត។ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ អ្នកត្រូវតែមានទីបន្ទាល់ផ្ទាល់ខ្លួនជាមុនសិនថា ព្រះគម្ពីរមរមនពិត។ ទីបន្ទាល់នេះអាចនាំទៅកាន់សេចក្ដីជំនឿរឹងមាំ និងខ្ជាប់ខ្ជួន នៅក្នុងអំណាច នៃព្រះគម្ពីរមរមន អំឡុងពេលធ្វើការ នៃការផ្លាស់សាសនា។ ចូរមានទំនុកចិត្តថា ព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើទីបន្ទាល់ទៅកាន់មនុស្សគ្រប់រូប ដែលអាន និងពិចារណា ព្រះគម្ពីរមរមន ហើយសួរដល់ព្រះ បើព្រះគម្ពីរនេះពិត ដោយចិត្តស្មោះស ដោយចេតនាពិត ដោយមានសេចក្ដីជំនឿ ជឿដល់ ព្រះគ្រីស្ទ។ សាក្សីនៃព្រះវិញ្ញាណបរិសុទ្ធនេះ គួរតែផ្ដោតយ៉ាងសំខាន់នៅក្នុងការបង្រៀនរបស់អ្នក។

## ព្រះគម្ពីរមរមនគឺជាមូលដ្ឋាននៃសាសនារបស់យើង




ព្យាការីយ៉ូសែប ស្ម៊ីធ បង្រៀនថាព្រះគម្ពីរមរមន គឺជា"មូលដ្ឋាននៃសាសនារបស់យើង" (បុព្វកថាព្រះគម្ពីរមរមន)។ នៅក្នុង ឱកាសផ្សេងៗទៀត លោកមានប្រសាសន៍ថាៈ "បើដកព្រះគម្ពីរមរមន និងវិវរណៈចេញ តើសាសនារបស់យើង នៅឯណា? យើងគ្មានសាសនាទេ" (*History of the Church*, 2:52)។

ថៃវទ្វារ គឺជារចនាសម្ព័ន្ធស្ថាបត្យកម្ម ដ៏រឹងមាំមួយ ដែលធ្វើឡើងមកពីបំណែកឈើ ដែលដាក់ត្រួតលើគ្នា។ បំណែកកណ្ដាល ដែលជាសិលាគន្លិះ ជាធម្មតាមានទំហំធំជាងឈើផ្សេងទៀត ហើយដាក់បិទជាមួយនឹងថ្មផ្សេងទៀតនៅហ្នឹងកន្លែង។ នៅពេល យ៉ូសែប ស្ម៊ីធ បានហៅព្រះគម្ពីរមរមនថា "សិលាគន្លិះនៃសាសនារបស់យើង" លោកបង្រៀនថា ព្រះគម្ពីរមរមនភ្ជាប់សាសនា របស់យើងជាមួយគ្នា។ ប្រធានអ៊ិស្រា ថាហ្វ បែនសិន មានប្រសាសន៍ថា ព្រះគម្ពីរមរមន គឺជាសិលាគន្លិះ តាមរបៀបបីយ៉ាងៈ

កំណត់ចំណាំ

**សាក្សីនៃព្រះគ្រីស្ទ។** “ព្រះគម្ពីរមរមន គឺជាមូលដ្ឋាននៅក្នុងសាក្សីរបស់យើងចំពោះព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់ផ្ទាល់ជា គ្រឹះនៃអ្វីៗទាំងអស់ ដែលយើងធ្វើ។ ព្រះគម្ពីរមរមន ធ្វើជាសាក្សីអំពីតថភាពពិតរបស់ទ្រង់ដោយអំណាច និងសេចក្តីសប្បុរស។”

**គោលលទ្ធិពេញលេញ។** ព្រះអម្ចាស់ផ្ទាល់ មានព្រះបន្ទូលថា ព្រះគម្ពីរមរមនមានទូវ ‘សេចក្តីពិតពេញលេញ នៃដំណឹងល្អដ៏ពេញលេញនៃព្រះយេស៊ូវគ្រីស្ទ’ (សូមមើល គ និង ស 20៖9។) … នៅក្នុងព្រះគម្ពីរមរមន យើងនឹងរកបានសេចក្តីពិត ពេញលេញនៃគោលលទ្ធិទាំងឡាយ ដែលជាតំរូវការសំរាប់សេចក្តីសង្គ្រោះរបស់យើង។ ហើយគោលលទ្ធិទាំងនោះ បានបង្រៀន យ៉ាងច្បាស់លាស់ ហើយយ៉ាងសាមញ្ញ ដើម្បីឱ្យកុមារ អាចរៀនយល់ អំពីរបៀបនៃសេចក្តីសង្គ្រោះ និងការលើកតំកើង។”




**មូលដ្ឋានគ្រឹះនៃទីបន្ទាល់។** “ដូចជាក្លោងទ្វារនឹងត្រូវបាក់បែក បើសិនជាសិលាគន្លឹះ ឬមូលដ្ឋានត្រូវដកចេញ ដូចគ្នានេះដែរ សាសនាចក្រ នឹងឈរ ឬរលំចុះដោយសារ សេចក្តីពិតពេញលេញ នៃព្រះគម្ពីរមរមន។ ពួកសត្រូវរបស់សាសនាចក្រ យល់យ៉ាងច្បាស់ អំពីរឿងនេះ។ នេះគឺជាមូលហេតុ ដែលពួកគេព្យាយាមយ៉ាងខ្លាំង នឹងយូរអង្វែង ដើម្បីបង្ហាញថា ព្រះគម្ពីរ មរមនមិនពិត បើសិនជាព្រះគម្ពីរមរមន អាចត្រូវបង្ខូចកិត្យានុភាព នោះព្យាការីយ៉ូសែប ស៊្មីធ នឹងត្រូវបង្ខូចដែរ។ ដូច្នេះហើយទើបយើងអះអាង ចំពោះកូនសោបព្វជិតភាព និងវិវរណៈ និងសាសនាចក្រ ដែលបានស្តារឡើងវិញ។ ប៉ុន្តែក្នុងលក្ខណៈនេះ បើព្រះគម្ពីរមរមនពិត—ហើយមនុស្សរាប់លាននាក់ បច្ចុប្បន្ននេះបាន ធ្វើទីបន្ទាល់ថា ពួកគេមានសាក្សី នៃព្រះវិញ្ញាណ ថាព្រះគម្ពីរមរមនគឺពិតយ៉ាងប្រាកដ—ដូច្នេះ មនុស្សម្នាក់ៗ ត្រូវតែទទួលយក នូវការអះអាង នៃការស្តារឡើងវិញ និងអ្វីៗទាំងអស់ ដែលមានជាប់ទាក់ទងនឹង ព្រះគម្ពីរមរមនផងដែរ” (*A Witness and a Warning* [ឆ្នាំ 1988], 18–19)។

ព្រះគម្ពីរមរមន ត្រូវបានប្រមូលផ្តុំជាមួយនឹងព្រះវិញ្ញាណ គឺជាប្រភពដ៏មានឥទ្ធិពលបំផុតរបស់អ្នក នៅក្នុងការផ្លាស់សាសនា។ ព្រះគម្ពីរមរមនគឺជាគម្ពីរដ៏ត្រឹមត្រូវបំផុត ជាងគម្ពីរនានាទាំងអស់នៅលើផែនដីនេះ (សូមមើលបុព្វកថាព្រះគម្ពីរមរមន)។ គម្ពីរមរមន បង្រៀនអំពីគោលលទ្ធិ នៃព្រះគ្រីស្ទយ៉ាងច្បាស់ ជាពិសេសនៅក្នុងមេរៀន ដែលអ្នកបង្រៀនសាសនាគន់ការី។ សូមប្រើគម្ពីរមរមន ជាប្រភពដ៏សំខាន់សំរាប់ការបង្រៀនដំណឹងល្អដែលបានស្តារឡើងវិញ។ នៅខាងក្រោមនេះ គឺជាគំរូ នៃសេចក្តីពិត ដែលបានបង្រៀនយ៉ាងច្បាស់ នៅក្នុងព្រះគម្ពីរមរមន ដែលអ្នកនឹងបង្រៀន ដល់សាសនាគន់ការី។

| មេរៀនអ្នកផ្សព្វផ្សាយសាសនា | គោលលទ្ធិ | ឯកសារយោង |
|---|---|---|
| សារលិខិតនៃការស្តារឡើងវិញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ | ការក្បត់សាសនា, ការស្តារឡើងវិញ, យ៉ូសែប ស៊្មីធ, សិទ្ធិអំណាចបព្វជិតភាព | នីហ្វៃទី1 12–14<br>នីហ្វៃទី2 3, 26–29<br>ម៉ូសាយ 18 |
| ផែនការនៃសេចក្តីសង្គ្រោះ | “ផែនការដ៏មហិមានៃព្រះ ដ៏នៅអស់កល្បជានិច្ច” រួមមានទាំងការធ្លាក់នៃលោកអ័ដាម ដង្វាយធួន ការរស់ឡើងវិញ និងការជំនុំជំរះ | នីហ្វៃទី2 2, 9<br>ម៉ូសាយ 3, 15<br>អាលម៉ា 12, 40–42 |
| ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ | ជំនឿនៅក្នុងព្រះគ្រីស្ទ ការប្រែចិត្ត ពិធីបុណ្យជ្រមុជទឹក អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ និងការស៊ូទ្រាំទីបំផុត។ | នីហ្វៃទី2 31–32<br>នីហ្វៃទី3 11, 27 |
| បទបញ្ញត្តិ ក្រិត្យវិន័យ និងពិធីការទាំងឡាយ | ពិធីការទាំងឡាយ មានដូចជា ពិធីបុណ្យជ្រមុជទឹក ពិធីបញ្ជាក់ ពិធីតែងតាំងបព្វជិតភាព និងពិធីប្រសិទ្ធិពរនំប៉័ង និងទឹក | នីហ្វៃទី3 11៖22–28, 18<br>មរ៉ូណៃ 2–6 |

## សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

ចូរសរសេរចំលើយចំពោះសំនួរទាំងឡាយ ដូចខាងក្រោមនៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នកៈ

- តើការសិក្សាព្រះគម្ពីរមរមន មានឥទ្ធិពលចំពោះទីបន្ទាល់របស់អ្នក ដូចម្តេចខ្លះ អំពីព្រះយេស៊ូវគ្រីស្ទ?
- តើអ្នកអាចប្រើព្រះគម្ពីរមរមន ដើម្បីជួយពង្រឹង ទីបន្ទាល់របស់អ្នកដទៃ ដោយរបៀបណា?

កំណត់ចំណាំ

### ការសិក្សាព្រះគម្ពីរ

**តើព្រះអង្គសង្គ្រោះមានព្រះបន្ទូលអ្វីខ្លះ អំពីព្រះគម្ពីរមរមន?**

| | | |
|---|---|---|
| គ និង ស 1:29 | គ និង ស 19:26–27 | គ និង ស 42:12 |
| គ និង ស 3:19–20 | គ និង ស 20:5–16 | ម៉ូសេ 7:62 |
| គ និង ស 17:6 | គ និង ស 33:16 | |



រូបភាព ដកស្រង់ពី C. Harrison Conroy Co., Inc. ហាមថតចម្លង។

## ព្រះគម្ពីរមរមនធ្វើទីបន្ទាល់អំពីព្រះគ្រីស្ទ

គោលបំណងសំខាន់ នៃព្រះគម្ពីរមរមន គឺដើម្បីផ្លាស់គំនិតមនុស្សទាំងអស់ឱ្យជឿថា ព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ (សូមមើលទំព័រ ចំណងជើង នៃព្រះគម្ពីរមរមន)។ ព្រះគម្ពីរមរមនធ្វើទីបន្ទាល់ អំពីព្រះគ្រីស្ទ ដោយអះអាងពីតថភាពនៃជីវិតបេសកកម្ម និងព្រះចេស្តារបស់ទ្រង់។ ព្រះគម្ពីរមរមនបង្រៀនគោលលទ្ធិពិត អំពីដង្វាយធួន—គ្រឹះសំរាប់ផែនការ នៃសេចក្ដីសង្គ្រោះ។ អ្នកទាំងប៉ុន្មាន ដែលបានសរសេរ ត្រូវបានការពារនៅក្នុងព្រះគម្ពីរមរមនបានឃើញព្រះគ្រីស្ទដោយផ្ទាល់។ បងប្រុសរបស់យ៉ារេឌ នីហ្វៃ និងយ៉ាកុបបានឃើញព្រះគ្រីស្ទ មុនជីវិតទ្រង់នៅលើផែនដី។ លោកមរមន និងលោកម៉ូរ៉ូណៃបានឃើញព្រះគ្រីស្ទ មានព្រះជន្មរស់ឡើងវិញ។ លើសពីនោះទៅទៀតមនុស្សយ៉ាងច្រើន មានវត្តមាន អំឡុងពេល ដែលព្រះអង្គសង្គ្រោះបង្រៀនខ្លីៗតែជាការបំរើប្រកបដោយព្រះចេស្ដា នៅក្នុងចំណោមពួកសាសន៍នីហ្វៃ (សូមមើល នីហ្វៃទី3 11–28)។ អ្នកទាំងឡាយណា ដែលស្គាល់ឬមិនស្គាល់ទាល់តែសោះអំពីព្រះអង្គសង្គ្រោះ នឹងមកស្គាល់ទ្រង់ តាមការអាន និងពិចារណា និងអធិស្ឋានអំពីព្រះគម្ពីរមរមន។

ទីបន្ទាល់នៃព្រះគម្ពីរមរមន អះអាងបន្ថែមអំពីព្រះគម្ពីរបរិសុទ្ធថា ព្រះយេស៊ូវ គឺជាព្រះរាជបុត្រានៃព្រះតែមួយគត់ និងជាព្រះអង្គសង្គ្រោះនៃពិភពលោក។ នៅពេលអ្នកបង្រៀនដំណឹងល្អ ដ៏ពេញលេញ នៃព្រះយេស៊ូវគ្រីស្ទ អ្នកនឹងធ្វើទីបន្ទាល់ជារឿយៗ អំពីព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះនៃពិភពលោក។ ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ អ្នកនឹងធ្វើជាសាក្សីថែមទៀត អំពីសេចក្ដីពិតដ៏ពេញលេញនៃសារលិខិតនេះ។

### ការសិក្សាព្រះគម្ពីរ

**តើមូលហេតុអ្វីខ្លះ ដែលព្យាការីក្នុងព្រះគម្ពីរមរមន ប្រគល់បញ្ជីប្រវត្តិរបស់ពួកគាត់?**

| | | |
|---|---|---|
| នីហ្វៃទី 1 6:4–6 | នីហ្វៃទី 2 33:13–15 | ពាក្យសំដីនៃមរមន 1:3–8 |
| នីហ្វៃទី 1 9:3–5 | យ៉ាកុប 1:4–7 | អាលម៉ា 37:2, 14 |
| នីហ្វៃទី 2 4:15–16 | យ៉ាកុប 4:1–6, 12 | នីហ្វៃទី 3 5:14–15 |
| នីហ្វៃទី 2 25:23–29 | អេណុស 1:13 | មរមន 8:35 |
| នីហ្វៃទី 2 26:15–16 | យ៉ារ៉ុម 1:2 | គ និង ស 3:16–20 |
| នីហ្វៃទី 2 29:11-14 | អោមណៃ 1:25–26 | គ និង ស 10:46–48 |

## ព្រះគម្ពីរមរមន និងព្រះគម្ពីរបរិសុទ្ធគាំទ្រគ្នាទៅវិញទៅមក

ជំនឿរបស់មនុស្សអំពីព្រះគម្ពីរបរិសុទ្ធគឺខុសៗគ្នាយ៉ាងខ្លាំង។ មនុស្សខ្លះជឿថាព្រះគម្ពីរបរិសុទ្ធគឺល្អឥតខ្ចោះទាំងស្រុង គ្មានកំហុស ហើយគម្ពីរតែមួយគត់ ដែលយើងត្រូវការ ដើម្បីបានសង្គ្រោះ។ អ្នកដទៃទៀតគិតថា ព្រះគម្ពីរបរិសុទ្ធគឺជាការសិក្សា អក្សរសាស្ត្រដ៏មានតម្លៃ ប៉ុន្តែពួកគេបដិសេធថា ព្រះគម្ពីរបរិសុទ្ធគឺជាភស្តុតាងនៃទេវភាពរបស់ព្រះគ្រីស្ទ និងអព្ភូតហេតុ ឬវិវរណៈដោយផ្ទាល់មកពីព្រះ។ មនុស្សខ្លះជ្រើសរើសមិនអើពើ អំពីគម្ពីរបរិសុទ្ធហើយអ្នកដទៃទៀត មិនដែលបានឃើញ ព្រះគម្ពីរបរិសុទ្ធ ឬមានឱកាសដើម្បីអានបានម្ដងឡើយ។

កំណត់ចំណាំ

ពួកបរិសុទ្ធថ្ងៃចុងក្រោយ “ជឿថា ព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះ បើសិនជាបានបកប្រែត្រឹមត្រូវ យើងក៏ជឿដែរថា សៀវភៅមរមនគឺជាព្រះបន្ទូលរបស់ព្រះផងដែរ” (មាត្រានៃសេចក្ដីជំនឿ 1:8)។ ព្រះគម្ពីរមរមនមិនប្រកួតនឹង ព្រះគម្ពីរបរិសុទ្ធទេ ព្រះគម្ពីរមរមនគាំទ្រព្រះគម្ពីរបរិសុទ្ធ ហើយដាស់តឿនយើងឱ្យអានព្រះគម្ពីរបរិសុទ្ធ និងធ្វើទីបន្ទាល់ អំពីសេចក្ដីពិតពេញលេញ នៃសារលិខិតរបស់ព្រះគម្ពីរបរិសុទ្ធ។ អ្នកគួរតែប្រើព្រះគម្ពីរមរមន និងព្រះគម្ពីរបរិសុទ្ធដើម្បី គាំទ្រគ្នាទៅវិញទៅមក។

ព្រះគម្ពីរមរមននិយាយអំពីសេចក្ដីសញ្ញាពីបុរាណ ដែលព្រះបានធ្វើជាមួយនឹងកូនចៅរបស់ទ្រង់។ ព្រះគម្ពីរបរិសុទ្ធប្រាប់អំពីព្យាការីអស្ចារ្យ ដែលទទួលសេចក្ដីសញ្ញាទាំងនេះដោយសេចក្ដីជំនឿផងដែរ។ ព្រះគម្ពីរមរមន ធ្វើទីបន្ទាល់អំពីព្រះគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ព្រះគម្ពីរបរិសុទ្ធផ្ដល់ដំណើររឿងនៃកំណើត កិច្ចការបំរើ ការសុគត ដង្វាយធួន និងការរស់ឡើងវិញ។ ហេតុដូច្នេះ ព្រះគម្ពីរបរិសុទ្ធ និងព្រះគម្ពីរមរមនបំពេញ និងបន្ថែមឱ្យគ្នាទៅវិញទៅមក។

ការបោះពុម្ពព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសរបស់ ពួកបរិសុទ្ធថ្ងៃចុងក្រោយ ដោយមានស្ដេចជេមស៍ និងព្រះគម្ពីរមរមន មានយោងបទគម្ពីរ និងជំនួយក្នុងការសិក្សា ដែលធ្វើឱ្យផលនៃពោះយូដា (ព្រះគម្ពីរបរិសុទ្ធ) និងផលនៃពោះយ៉ូសែប (ព្រះគម្ពីរមរមន)ជាផលពោះតែមួយ នៅក្នុងដៃរបស់យើង (សូមមើល អេសេគាល 37:15–17, សូមមើលផងដែរនៅក្នុង នីហ្វៃទី1 13:34–41, នីហ្វៃទី2 3:12, 29:8)។ សូមផ្ដល់អាទិភាពដល់វគ្គព្រះគម្ពីរមរមន នៅពេលអ្នកបង្រៀន ប៉ុន្តែត្រូវបង្ហាញផងដែរពីរបៀប ដែលព្រះគម្ពីរមរមន និងព្រះគម្ពីរបរិសុទ្ធបង្រៀនគោលការណ៍ដូចគ្នា។

សូមប្រើព្រះគម្ពីរមរមន ដើម្បីបញ្ជាក់ និងពន្យល់វគ្គក្នុងព្រះគម្ពីរបរិសុទ្ធ។ ឧទាហរណ៍ ព្រះគម្ពីរសញ្ញាថ្មី និយាយថា ព្រះគ្រីស្ទ ត្រូវបានទទួលបុណ្យជ្រមុជទឹក ដើម្បីសំរេចតាមគ្រប់ទាំងសេចក្ដីសុចរិត (សូមមើលម៉ាថាយ 3:14–15)។ ព្រះគម្ពីរមរមន ពន្យល់អំពីអត្ថន័យដើម្បីសំរេចតាមគ្រប់ទាំងសេចក្ដីសុចរិត (សូមមើលនីហ្វៃទី2 31:5–9)។

នៅពេលអ្នកប្រើព្រះគម្ពីរមរមន និងព្រះគម្ពីរបរិសុទ្ធជាដៃគូនឹងគ្នា ព្រះគម្ពីរទាំងពីរនេះ នឹងយកឈ្នះលើការទាស់ទែងគ្នា និងតទល់នឹងគោលលទ្ធិក្លែងក្លាយទាំងឡាយ (សូមមើលនីហ្វៃទី2 3:12)។

ព្រះគម្ពីរបរិសុទ្ធបង្រៀនអំពីច្បាប់នៃសាក្សីភាពថា ដោយនូវស្មបន្ទាល់ពីរ ឬបីនាក់ គ្រប់ការណ៍ទាំងអស់នឹងបានសំរេច (សូមមើលកូរិនថូសទី2 13:1)។ ស្របតាមច្បាប់នេះ ទាំងព្រះគម្ពីរមរមន និងព្រះគម្ពីរបរិសុទ្ធធ្វើបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ។

## សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន និងជាមួយដៃគូ

ចូរស្វែងរកសេចក្ដីយោងបទគម្ពីរតាមប្រធានបទដូចខាងក្រោមនេះ នៅក្នុងព្រះគម្ពីរមរមន និងព្រះគម្ពីរបរិសុទ្ធ។ ឧទាហរណ៍ទាំងឡាយត្រូវបានផ្ដល់ឱ្យនៅក្នុងរង្វង់ក្រចក បន្ទាប់ពីប្រធានបទនីមួយៗ។ ចូរបន្ថែមវគ្គ និងប្រធានបទដោយខ្លួនអ្នក។

- ព្យាការី (អេម៉ុស 3:7 និងយ៉ាកុប 4:4–6)
- ការក្បត់សាសនា (ធីម៉ូថេទី2 4:3–4 និងនីហ្វៃទី2 28)
- ការស្ដារឡើងវិញ (កិច្ចការ 3:19–21 និង នីហ្វៃទី 1 13:34–42)
- កូនចៅនៃព្រះ (កិច្ចការពួកសាវក 17:29 និង នីហ្វៃទី 1 17:36)

## ការសិក្សាព្រះគម្ពីរ

### តើព្រះគម្ពីរបរិសុទ្ធនិយាយអ្វីខ្លះ អំពីព្រះគម្ពីរមរមន?

យ៉ូហាន 10:16
អេសាយ 29:4, 11–18
អេសេគាល 37:15–17
Guide to the Scriptures, “Ephraim,” ក្រោមចំណងជើងៈ *The Stick of Ephraim or Joseph*)

### តើព្រះគម្ពីរមរមននិយាយអ្វីខ្លះ អំពីព្រះគម្ពីរបរិសុទ្ធ?

នីហ្វៃទី 1 13:20–29, 40–41
នីហ្វៃទី2 29:3–14
នីហ្វៃទី3 23:1
មរមន 7:8–9

### តើដោយវិធីណា ដែលគម្ពីរទាំងពីរនេះធ្វើជាសក្ខីបទអំពីព្រះគ្រីស្ទ?

នីហ្វៃទី2 29:8
យ៉ូហាន 20:31
កិច្ចការពួកសាវក 10:43

កំណត់ចំណាំ

## ព្រះគម្ពីរមរមនឆ្លើយសំនួរខាងព្រលឹងវិញ្ញាណ

ប្រធានអែសរ៉ា ថាប ប៊ែនសិន មានប្រសាសន៍ថា អ្នកផ្សព្វផ្សាយសាសនា "ត្រូវការបង្ហាញអំពីរបៀបដែល [ព្រះគម្ពីរមរមន] ឆ្លើយសំនួរធំៗជាច្រើនខាងព្រលឹងវិញ្ញាណ" ("Flooding the Earth with the Book of Mormon," *Ensign*, ខែវិច្ឆិកា ឆ្នាំ 1988, 5)។

"សំនួរធំៗជាច្រើនខាងព្រលឹងវិញ្ញាណ" អាចរាប់បញ្ចូលទាំងសំនួរដូចតទៅនេះ៖ តើពិតជាមានព្រះឬ? តើខ្ញុំរស់នៅកន្លែងណា មុនពេលខ្ញុំ ចាប់កំណើត? តើខ្ញុំនឹងទៅរស់នៅកន្លែងណា បន្ទាប់ពីខ្ញុំស្លាប់ទៅ? តើគោលបំណងនៃជីវិតនេះ គឺជាអ្វី? តើព្រះយេស៊ូវ ពិតជា ព្រះអង្គសង្គ្រោះឬ?



សំនួរផ្សេងទៀត អាចផ្តោតទៅលើសេចក្តីត្រូវការខាងសាច់ឈាមច្រើន៖ តើខ្ញុំអាចកែលំអទំនាក់ទំនងជាមួយនឹងប្តីប្រពន្ធរបស់ខ្ញុំ បានដោយរបៀបណា? តើខ្ញុំអាចជួយដល់យុវវ័យរបស់ខ្ញុំជៀសវាងពីថ្នាំញៀន ឬផ្ទុយពីសីលធម៌បានដោយរបៀបណា? តើខ្ញុំអាចស្វែងរកការងារដើម្បីឧបត្ថម្ភដល់គ្រួសាររបស់ខ្ញុំដោយរបៀបណា?

ដំណឹងល្អ នៃព្រះយេស៊ូវគ្រីស្ទ ជួយយើងឱ្យឆ្លើយសំនួរទាំងពីរប្រភេទនេះ។ នៅពេលយើងទទួលបានសេចក្តីជំនឿថា ព្រះគម្ពីរមរមនពិត យើងអាចចាប់ផ្តើមឆ្លើយនឹងសំនួរអំពីគោលបំណងនៃជីវិត និងសេចក្តីសង្ឃឹមនៃជីវិតដ៏នៅអស់កល្បជានិច្ច។ ព្រះគម្ពីរមរមន ពិពណ៌នាអំពីផែនការនៃសុភមង្គល ដែលផ្តល់អត្ថន័យ និងទស្សនវិស័យចំពោះជីវិត។ ចូរឆ្លើយសំនួរទាំងឡាយ ដែលមានដូចខាងក្រោមនេះ គឺត្រូវបានបង្រៀនយ៉ាងច្បាស់លាស់នៅក្នុងព្រះគម្ពីរមរមន។

- តើមានព្រះឬ? (អាលម៉ា 22)
- តើព្រះយេស៊ូវគ្រីស្ទសង្គ្រោះអ្វីពីខ្ញុំ? (នីហ្វៃទី2 9)
- តើការជឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ អាចជួយខ្ញុំបានដោយរបៀបណា? (អាលម៉ា 36)
- តើមានជីវិតបន្ទាប់ពីសេចក្តីស្លាប់ឬ? (អាលម៉ា 40)
- តើគោលបំណងនៃជីវិតនេះគឺជាអ្វី? (អាលម៉ា 34)
- តើហេតុអ្វីព្រះ អនុញ្ញាតឱ្យអារក្ស និងទុក្ខព្រួយកើតមានឡើងដូច្នេះ? (នីហ្វៃទី2 2, អាលម៉ា 14៖9–11, 60៖13)
- តើកូនតូចរបស់ខ្ញុំត្រូវការទទួលបុណ្យជ្រមុជទឹកដែរឬទេ? (មរ៉ូណៃ 8)
- តើព្រះស្គាល់ខ្ញុំឬទេ? (អាលម៉ា 5៖38, 58)
- តើព្រះឆ្លើយការអធិស្ឋានឬទេ? (អេណុស 1)
- តើខ្ញុំអាចរកបានសេចក្តីសុខសាន្ត និងសេចក្តីអំណរបានដោយរបៀបណា? (ម៉ូសាយ 2, 4)
- តើគ្រួសាររបស់ខ្ញុំអាចកាន់តែមានសុភមង្គល និងសាមគ្គីភាពគ្នាកាន់តែច្រើនឡើងដោយរបៀបណា? (ម៉ូសាយ 2)
- តើខ្ញុំអាចមានថ្លឹងថ្លែងរវាងគ្រួសារ និងអាជីព របស់ខ្ញុំដោយរបៀបណា? (នីហ្វៃទី3 13)
- តើខ្ញុំអាចពង្រឹងទំនាក់ទំនងរបស់ខ្ញុំជាមួយប្តីប្រពន្ធយ៉ាងដូចម្តេច? (នីហ្វៃទី3 14)
- តើខ្ញុំអាចជៀសវាងពីអំពើអាក្រក់ទាំងឡាយ ដែលគំរាមគំហែងដល់គ្រួសាររបស់ខ្ញុំតាមរបៀបណា? (អាលម៉ា 39)
- តើខ្ញុំអាចជៀសវាងពីអំពើបាបយ៉ាងដូចម្តេច? (ហេលេមិន 5)

នៅពេលយើងអានព្រះគម្ពីរមរមនដោយការដឹកនាំពីព្រះវិញ្ញាណ នោះនឹងជួយយើងឱ្យឆ្លើយសំនួរផ្ទាល់ខ្លួន។ ព្រះគម្ពីរមរមន បង្រៀនថា ការអធិស្ឋាន និងវិវរណៈ គឺជាកូនសោ ដើម្បីដោះស្រាយបញ្ហាពិសេសៗ។ ព្រះគម្ពីរជួយយើងឱ្យមានជំនឿ ថា ព្រះនឹងឆ្លើយការអធិស្ឋានរបស់យើង។

កំណត់ចំណាំ

ព្រះគម្ពីរមរមនជួយយើងឱ្យយល់ផងដែរថា បទបញ្ញត្តិទាំងឡាយនៃព្រះ មិនមែនជាបញ្ជីតឹងរឹង នៃអ្វីដែលយើងគួរធ្វើ និងអ្វីដែលយើង មិនគួរធ្វើ នោះទេ ប៉ុន្តែជាព្រួញបង្ហលបង្ហាញផ្លូវទៅកាន់ ជីវិតសម្បូរណ៍សប្បាយ។ នៅពេលយើង ចាប់ផ្តើម យល់ដឹងថា គោលការណ៍ និងពិធីការទីមួយនៃ ដំណឹងល្អ គឺជាផ្លូវទៅកាន់ជីវិតដ៏បរិបូណ៌ យើងនឹងស្ងើចសរសើរយ៉ាងខ្លាំង ចំពោះ គោលការណ៍ទាំងនេះ ដែលបានជួយឆ្លើយគ្រប់សំនួរ និងបំពេញរាល់ សេចក្តីត្រូវការទាំងឡាយ។ ឧទាហរណ៍ យើងយល់ថា ការប្រែចិត្ត ការអភ័យទោស និងសេចក្តីសញ្ញាដើម្បីបំរើអ្នកដទៃ មានសារៈសំខាន់នៅ ក្នុងការពង្រីក ទំនាក់ទំនងជាមួយប្តីប្រពន្ធ របស់យើង។ យើងឃើញថា សេចក្តីជំនឿនៅក្នុងព្រះគ្រីស្ទ ការទទួលយក និងការរក្សាសេចក្តីសញ្ញា ទាំងឡាយ និងការដើរតាម ការបំផុសគំនិត នៃព្រះវិញ្ញាណ អាចជួយយុវវ័យ ទាំងឡាយ ឱ្យជៀសវាងពីអំណាចនៃសេចក្តីល្បួង ដែលនៅពទ្ធ័ជុំវិញពួកគេ។

> *“នៅក្នុងពិភពលោកកាន់តែគ្រោះថ្នាក់ . . . ព្រះគម្ពីរមរមនគឺជាៈសក្ខីបទមួយទៀតអំពី ព្រះយេស៊ូវគ្រីស្ទ មាននូវចេស្តានៃការចិញ្ចឹម បីបាច់ ដើម្បីព្យាបាលវិញ្ញាណអត់ឃ្លាន នៃពិភពលោកនេះ។*
>
> — ប្រធាន ប៊យ ខេ. ផាកកឺ
> “ព្រះគម្ពីរមរមនៈ សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ”
> *ENSIGN*, ខែវិច្ឆិកា ឆ្នាំ 2001, 64)

ដំណឹងល្អអាចដោះស្រាយស្ទើរគ្រប់សំនួរ ឬសេចក្តីត្រូវការគ្រប់យ៉ាង។ នេះគឺជាមូលហេតុ ដែលអ្នកត្រូវបង្រៀន គោលការណ៍ ទាំងឡាយ នៃដំណឹងល្អ ដែលមាននៅក្នុងព្រះគម្ពីរបរិសុទ្ធ និងព្រះគម្ពីរមរមន ដែលមានសេចក្តីពិតនៃដំណឹងល្អពេញលេញ (សូមមើល គ និង ស 42ៈ12)។

**សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន ឬជាមួយដៃគូ**

ចូរធ្វើបញ្ជីនៃ “សំនួរធំៗខាងព្រលឹងវិញ្ញាណ”ខ្លះៗ ដែលសាសនាតន់ការីបានសួរ។ ចូរស្វែងរកខគម្ពីរ នៅក្នុងព្រះគម្ពីរមរមន ដើម្បីឆ្លើយសំនួរ ទាំងនេះ។ សូមសរសេរចំលើយ នៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក ហើយប្រើខគម្ពីរទាំងនេះ នៅពេលអ្នកបង្រៀន។

## ព្រះគម្ពីរមរមននាំមនុស្សអោយខិតកាន់តែមកជិតព្រះ

ចំពោះព្រះគម្ពីរមរមន ព្យាការីយ៉ូសែប ស្ម៊ីធមានប្រសាសន៍ថា “បុគ្គលម្នាក់ៗអាចចូលទៅជិតព្រះបាន ដោយសារធ្វើតាមសិក្ខាបទ ទាំងឡាយនៃគម្ពីរនេះ ជាជាងគម្ពីរដទៃទាំងអស់” (បុព្វកថាព្រះគម្ពីរមរមន)។ ព្រះគម្ពីរមរមនគឺជាវត្ថុមួយ ដែលនាំទៅកាន់ ទីបន្ទាល់ និងវិវរណៈផ្ទាល់ខ្លួន។ ចូរប្រើព្រះគម្ពីរមរមន ដើម្បីជួយមនុស្សឱ្យមានបទពិសោធន៍ខាងវិញ្ញាណ ជាពិសេសជាសាក្សីមួយ មកពី ព្រះវិញ្ញាណបរិសុទ្ធថា គម្ពីរនេះពិត។ ដោយការអញ្ជើញមនុស្ស ឱ្យរស់នៅជាប្រចាំ តាមគោលការណ៍ នៅក្នុងព្រះគម្ពីរមរមន នោះ អ្នកជួយពួកគេឱ្យអភិវឌ្ឍន៍សេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ និងខិតកាន់តែជិតព្រះ។

ប្រធានគរដឹន ប៊ី ហ៊ីងឃ្លីបានប្រកាសថាៈ “អ្នកទាំងឡាយណា ដែលបានអាន [ព្រះគម្ពីរមរមន] ដោយការអធិស្ឋាន ទោះជា ពួកគេមាន ឬក្រ អ្នកមានចំណេះវិជ្ជា ឬគ្មាន បានរីកចំរើននៅក្រោមអំណាចនៃព្រះគម្ពីរ...។ ដោយគ្មានការបម្រុងទុក ខ្ញុំសន្យានឹង អ្នកថា បើអ្នកនឹងអានព្រះគម្ពីរមរមនដោយការអធិស្ឋាន មិនថាមានចំនួនប៉ុន្មានដងដង ដែលអ្នកបានអានពីមុនទេ នោះនឹងមកសណ្ឋិតក្នុង ដួងចិត្តរបស់អ្នកនូវ...ព្រះវិញ្ញាណនៃព្រះអម្ចាស់។ នឹងមានដំណោះស្រាយយ៉ាងរឹងមាំ ដើម្បីឱ្យដើរក្នុងការគោរពប្រតិបត្តិ ចំពោះ បទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ហើយនឹងមានទីបន្ទាល់កាន់តែរឹងមាំ អំពីព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ដោយពិត” (“The Power of the Book of Mormon,” *Ensign,* ខែមិថុនា ឆ្នាំ1988, 6)។

## ការប្រើប្រាស់ព្រះគម្ពីរមរមន ដើម្បីឆ្លើយតបចំពោះការជំទាស់ទាំងឡាយ

មនុស្សជាច្រើននឹងមិនជឿអ្វីៗ ដែលអ្នកបង្រៀននោះទេ។ ប្រធាន អែសរ៉ា ថាប់ បែនសឹន បានបង្រៀនពីរបៀប ដែលព្រះគម្ពីរ មរមនអាចជាប្រភពសំខាន់ នៅក្នុងការឆ្លើយតបចំពោះស្ថានភាពដូចខាងក្រោមៈ

“យើងត្រូវប្រើព្រះគម្ពីរមរមន នៅក្នុងការបកស្រាយនឹងការជំទាស់ចំពោះសាសនាចក្រ . . . ។

“. . . ការជំទាស់ទាំងអស់ មិនថាអំពីការពន្លូតកូន របៀបអាពាហ៍ពិពាហ៍ច្រើនដង ការថ្វាយបង្គំនៅថ្ងៃទីប្រាំពីរ ជាដើម។ ជាមូលដ្ឋានអាស្រ័យទៅលើយ៉ូសែប ស្ម៊ីធ និងអ្នកស្នងរបស់លោក និងព្យាការីរបស់ព្រះ ដែលទទួលវិវរណៈដ៏ទេវភាព . . .។

កំណត់ចំណាំ

“. . . បញ្ហាតែមួយគត់ ដែលអ្នកជំទាស់ត្រូវតែដោះស្រាយសំរាប់ខ្លួនឯងនោះ គឺថាតើព្រះគម្ពីរមរមនពិតឬទេ។ បើព្រះគម្ពីរមរមន ពិត នោះព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ យ៉ូសែប ស្ម៊ីធគឺជាព្យាការីរបស់ទ្រង់ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុង ក្រោយ គឺពិត ហើយដែលសព្វថ្ងៃត្រូវបានដឹកនាំដោយព្យាការីម្នាក់តាមការទទួលវិវរណៈ។

“កិច្ចការដ៏ចំបងរបស់យើង គឺ ដើម្បីប្រកាសដំណឹងល្អ និងធ្វើកិច្ចការប្រកបដោយប្រសិទ្ធភាព។ យើងមិនមានកាតព្វកិច្ច ដើម្បីឆ្លើយរាល់គ្រប់ការជំទាស់នោះទេ។ ជាយថាហេតុ មនុស្សគ្រប់រូប ត្រូវត្រឡប់ទៅកាន់ជញ្ជាំងនៃសេចក្តីជំនឿ ហើយនៅទីនោះពួកគេត្រូវតែក្រោកឈរដោយខ្លួនឯង”(*A Witness and a Warning*, 4–5)។


My Servant Joseph © ឆ្នាំ2004 ដោយ លីស្ស គ្រីនស៊ីធ។ រូបភាពនេះគឺដោយមានការអនុញ្ញាតពី Foundation Arts, អាមេរីកាំង ហ្វក, អ៊ូថាហ៍ 84003។

ឧទាហរណ៍ មានសាសនាគន់ការីចិត្តស្មោះម្នាក់ អាចជំទាស់នឹងអ្វី ដែលអ្នកបានបង្រៀនអំពីពាក្យគតិបណ្ឌិត។ សូមជួយពួកគេឱ្យ មើលឃើញថា សំនួរពិតរបស់ពួកគេគឺថា តើយ៉ូសែប ស្ម៊ីធ កំពុងនិយាយក្នុងនាមជាព្យាការីរបស់ព្រះ នៅពេលបទបញ្ញត្តិនេះ ត្រូវបានបន្តនៅក្នុងការកាន់កាប់ត្រួតត្រានេះឬទេ។ អ្នកអាចនិយាយថា៖ “ការមានជំនឿ ដើម្បីទទួលការបង្រៀននេះ នឹងគួរឱ្យ មានសេចក្តីប្រាកដថា បទបញ្ញត្តិនេះ មានមកដល់យើងតាមរយៈវិវរណៈមកពីព្រះទៅកាន់ព្យាការីយ៉ូសែប ស្ម៊ីធ។ របៀប ដើម្បីដឹងថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីរបស់ព្រះម្នាក់ គឺត្រូវអាន និងអធិស្ឋានអំពីព្រះគម្ពីរមរមន។”

សាសនាគន់ការី ត្រូវតែដោះស្រាយបញ្ហាសំរាប់ខ្លួនពួកគេ អំពីកង្វល់ និងការជំទាស់របស់ពួកគេ។ អ្នកអាចជួយ នៅពេលអ្នកផ្តោតទៅលើអ្វី ដែលនឹងពង្រឹងជំនឿរបស់ពួកគេនៅក្នុងព្រះយេស៊ូវគ្រីស្ទ—ការអាន និងការអធិស្ឋាន អំពីព្រះគម្ពីរមរមន។ នៅពេលពួកគេពង្រឹងទីបន្ទាល់របស់ពួកគេអំពីការស្តារឡើងវិញ ពួកគេនឹងមានកម្លាំង ដើម្បីយកឈ្នះ ទៅលើការជំទាស់ និងកង្វល់របស់ពួកគេ។

នៅពេលអ្នកផ្តល់ចំលើយចំពោះកង្វល់ទាំងឡាយ ចូរចាំថា ការយល់ដឹងរបស់យើងមកពីព្យាការីសម័យបច្ចុប្បន្ន—យ៉ូសែប ស្ម៊ីធ និងអ្នកស្នងរបស់លោក—ដែលទទួលវិវរណៈដោយផ្ទាល់មកពីព្រះ។ ហេតុដូច្នេះហើយ សំនួរដំបូង សំរាប់សាសនាគន់ការី ឆ្លើយ គឺថាតើយ៉ូសែប ស្ម៊ីធគឺជាព្យាការីម្នាក់ឬទេ ហើយពួកគេអាចឆ្លើយសំនួរនេះបានដោយការអាន និងអធិស្ឋានអំពី ព្រះគម្ពីរមរមន។

### យ៉ូសែប ស្ម៊ីធ និងព្រះគម្ពីរមរមន

របៀបមួយ ដើម្បីដឹងថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីម្នាក់របស់ព្រះ គឺត្រូវអាន និងអធិស្ឋានអំពីព្រះគម្ពីរមរមន។

### សកម្មភាព៖ ការសិក្សាផ្ទាល់ខ្លួន

នៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក ចូរសរសេរអំពីរបៀប ដែលអ្នកនឹងសំដៅទៅលើយ៉ូសែប ស្ម៊ីធ និងព្រះគម្ពីរមរមន ដើម្បីឆ្លើយតបនឹងការជំទាស់ ឬកង្វល់ទាំងឡាយដូចខាងក្រោម៖

- “ខ្ញុំមិនជឿថា ព្រះមានបន្ទូលជាមួយមនុស្សទៀតទេ។”
- “ខ្ញុំជឿថា ខ្ញុំអាចថ្វាយបង្គំព្រះតាមរបៀបរបស់ខ្ញុំ ជាជាងតាមរយៈការស្គាល់សាសនាខ្លះ។”
- “តើហេតុអ្វីខ្ញុំត្រូវឈប់ផឹកស្រាជាមួយនឹងអាហាររបស់ខ្ញុំ បើខ្ញុំចូលរួមនៅក្នុងព្រះវិហាររបស់អ្នក?”
- “ហេតុអ្វីក៏ខ្ញុំត្រូវការមានសាសនាដូច្នេះ?”

## តើអ្នកគួរប្រើប្រាស់ព្រះគម្ពីរមរមនដោយរបៀបណា?

សាសនាគន់ការីជាច្រើន អាចមិនអានព្រះគម្ពីរមរមន ឬមិនយល់ពីអ្វី ដែលពួកគេអាន។ អស់អ្នកទាំងឡាយណា ដែលមិនអាន ឬយល់ពីព្រះគម្ពីរមរមន នឹងមានការលំបាកក្នុងការទទួលសាក្សីថា ព្រះគម្ពីរគឺពិត។

កំណត់ចំណាំ

## អានព្រះគម្ពីរមរមនជាមួយនឹងសាសនាទាគន់ការីរបស់អ្នក

នៅពេលអ្នកអានជាមួយគ្នា ចូរអធិស្ឋាន ដើម្បីឱ្យមានព្រះវិញ្ញាណបរិសុទ្ធ នឹងធ្វើទីបន្ទាល់ចំពោះសាសនាទាគន់ការី ថាព្រះគម្ពីរមរមន ពិត។



អ្នកអាចជួយសាសនាទាគន់ការីដោយការអានព្រះគម្ពីរមរមនជាមួយពួកគេ។ ចូរអធិស្ឋានសុំជំនួយ នៅពេលអ្នកជ្រើសរើសវគ្គដែលមាននិយាយអំពីកង្វល់ និងបញ្ហារបស់ពួកគេ។ អ្នកអាចអានជាមួយពួកគេ ជាផ្នែកនៃការណាត់ជួបបង្រៀន ឬអំឡុងពេល ធ្វើការជួបតាមដាន។ អ្នកអាចរៀបចំសំរាប់ឱ្យសមាជិកអានជាមួយនឹងសាសនាទាគន់ការីផងដែរ។

វគ្គគម្ពីរសំខាន់ជាក់លាក់មួយចំនួន មានបញ្ចូលនៅក្នុងទំព័រចំណងជើង បុព្វកថា (ជាពិសេសកថាខ័ណ្ឌពីរចុងក្រោយ) និងម៉ូរ៉ូណៃ 10:3–5។ វគ្គគម្ពីរទាំងនេះជួយសាសនាទាគន់ការីយល់អំពីរបៀប ដើម្បីទទួលបានទីបន្ទាល់ នៃព្រះគម្ពីរមរមន។ លើកទឹកចិត្តពួកគេឱ្យអានព្រះគម្ពីរមរមនមកពីដំបូង រួមទាំងទីបន្ទាល់របស់សាក្សីបីនាក់ និងសាក្សីប្រាំបីនាក់ និងទីបន្ទាល់របស់ព្យាការីយ៉ូសែប ស្ម៊ីធ។

សូមអាន និងពិភាក្សាវគ្គគម្ពីរខ្លីៗ (ដូចជានីហ្វៃទី1 3:7 ឬម៉ូសាយ2:17) និងវគ្គគម្ពីរវែងៗ ឬមួយជំពូកទាំងមូល (ដូចជានីហ្វៃទី2 31 អាលម៉ា 7, ឬនីហ្វៃទី3 18)។

នៅពេលអ្នកអានជាមួយនឹងសាសនាទាគន់ការី យូរៗម្តង ចូរឈប់ ហើយពិភាក្សាអំពីអ្វី ដែលអ្នកអាន។ ចូរបង្ហាញអំពី សារលិខិតគន្លឹះ ឬគោលលទ្ធិសំខាន់ៗ ដើម្បីរកមើល នៅពេលអ្នកអានជាមួយពួកគេ។ ចែកចាយការយល់ដឹង អារម្មណ៍ ទីបន្ទាល់ និងបទពិសោធន៍ផ្ទាល់ខ្លួនឱ្យសមរម្យ។ សូមជួយអ្នកដទៃឱ្យមានអារម្មណ៍ពីអំណាចព្រះវិញ្ញាណនៃព្រះគម្ពីរមរមន។ តាមរបៀបនេះ អ្នកអាចបង្រៀនពួកគេអំពីគោលលទ្ធិពិតដោយត្រង់ៗមកពីព្រះគម្ពីរមរមន។ ចូរបន្តអនុវត្តដូច្នេះ នៅក្នុងការជួបនៅពេល ក្រោយទៀត ដើម្បីឱ្យមនុស្សដែលអ្នកបង្រៀនអាចពង្រីកសមត្ថភាព ដើម្បីអាន និងអធិស្ឋានដោយខ្លួនឯង។

> “សូមកុំឱ្យយកព្រះគម្ពីរមរមន ដើម្បីចែកអោយដោយឥតប្រយោជន៍។អធិស្ឋានសំរាប់គំនិតទស្សនៈមួយ អំពីរបៀបដែលព្រះគម្ពីរមរមនអាចត្រូវបាន ប្រើកាន់តែមានប្រសិទ្ធភាពនៅក្នុងបេសកកម្មរបស់អ្នក។ ខ្ញុំសន្យាថា អ្នកអាចធ្វើដូច្នោះបាន គំនិតរបស់អ្នកនឹងត្រូវ បានបំភ្លឺឡើងជាមួយនឹងការដឹកនាំ ដែលអ្នកគួរតែទទួលយក។”
>
> — អែលឌើរ យ៉ូសែប ប៊ី វើរ្ស៊ីន
> សិក្ខាសាលាសំរាប់ប្រធានបេសកកម្មថ្មី ថ្ងៃទី 23 ខែមិថុនា ឆ្នាំ1999

បង្រៀនគោលការណ៍ និងគោលលទ្ធិ ដោយប្រើពាក្យ និងឃ្លារបស់ព្យាការីក្នុងព្រះគម្ពីរមរមន។ ចូរពន្យល់អំពីប្រវត្តិ និងបរិបទនៃវគ្គគម្ពីរ។ ចូរពន្យល់ពាក្យ ឬឃ្លា ដែលមិនធ្លាប់ស្គាល់។

“ប្រដូច” ទៅនឹងខ្លួនរបស់អ្នក និងសាសនាទាគន់ការីរបស់អ្នក នូវអ្វីដែលអ្នកបានអាន ដោយការស្វែងរកអនុវត្តនូវអ្វី ដែលទាក់ទងនឹងខ្លួនរបស់អ្នក និងសាសនាទាគន់ការីរបស់អ្នក (សូមមើលនីហ្វៃទី1 19:23)។ ដើម្បី “ប្រដូច” គឺត្រូវបង្កើតទំនាក់ទំនងខាងអារម្មណ៍រវាងការយល់ដឹងអំពីគោលលទ្ធិ និងការរស់នៅតាមគោលលទ្ធិ។ ដើម្បីអានដោយអស់ពីចិត្ត ដោយចិត្តស្មោះ អ្នក និងអ្នកទាំងឡាយណា ដែលអ្នកបង្រៀន ត្រូវតែយល់ព្រមដើម្បីរស់នៅតាមគោលលទ្ធិនោះ ដើម្បីអនុវត្ត គោលលទ្ធិទៅក្នុងជីវិតរស់ នៅជាប្រចាំរបស់អ្នក ហើយជាចាំបាច់នោះ គឺត្រូវប្រែចិត្ត។ ដោយការរស់នៅតាម គោលលទ្ធិ អ្នកនឹងទទួលបានការអះអាងថា គោលលទ្ធិនេះពិត។ ឧទាហរណ៍ អ្នកអាចនិយាយទៅកាន់ សាសនាទាគន់ការីម្នាក់ថា៖

- “នីហ្វៃ គឺដូចជាអ្នក ត្រូវបានប្រឈមមុខជាមួយនឹងបញ្ហាដ៏លំបាក។ ប៉ុន្តែនៅពេលលោក អនុវត្តសេចក្តីជំនឿ ដើម្បី ‘ទៅ ហើយធ្វើ’ អ្វីៗដែលព្រះអម្ចាស់ទ្រង់បានបញ្ជាដល់លោក លោកអាចធ្វើបានសំរេច។ (សូមអាននីហ្វៃទី1 3:7។) ខ្ញុំដឹងថា ព្រះនឹងរៀបចំផ្លូវមួយសំរាប់អ្នកឱ្យរស់នៅតាម ពាក្យសំដីនៃប្រាជ្ញាវាងវៃ។”
- “យ៉ូហាន នោះគឺជាការល្អ ដែលអ្នកចង់បានសេរីភាព ពីកំហុសដែលអ្នកទទួលអារម្មណ៍នោះ។ ក៏ដូចជាព្រះអង្គសង្គ្រោះ បានសន្យាចំពោះពួកសាសន៍នីហ្វៃដែរ បើអ្នកប្រែចិត្ត ហើយបានទទួលបុណ្យជ្រមុជទឹក និងទទួលព្រះវិញ្ញាណបរិសុទ្ធ អ្នកនឹង“ទុកជាឥតទោសនៅចំពោះព្រះវរបិតា” (សូមអាននីហ្វៃទី3 27:16។)

អាស្រ័យទៅលើសេចក្តីសន្យានៅក្នុងមរ៉ូណៃ 10៖3–5។ មនុស្សគ្រប់រូប ដែលអាន និងអធិស្ឋានដោយចិត្តស្មោះអំពីព្រះគម្ពីរនេះ គេអាចដឹង ដោយពិតប្រាកដអំពីសេចក្តីពិតពេញលេញដោយចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ។ ចូរធ្វើឱ្យអស់ពីសមត្ថភាព ដែលអ្នកធ្វើទៅបានដើម្បីជួយសាសនាគន់ការិះ

- អានព្រះគម្ពីរមរមន និងពិចារណាទៅលើសារលិខិតព្រះគម្ពីរ អំពីព្រះយេស៊ូវគ្រីស្ទ។
- ចូរអធិស្ឋានទៅកាន់ព្រះជាមួយនឹងជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ដើម្បីទទួលទីបន្ទាល់ថា ព្រះគម្ពីរមរមនគឺជាការពិត ហើយថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីនៃការស្តារឡើងវិញ។
- អធិស្ឋានដោយចិត្តស្មោះ និងមានបំណងពិត ដែលមានន័យថា ពួកគេចង់ធ្វើទៅតាមចំលើយ ដែលពួកគេបាន ទទួលមកពីព្រះ។

អ្នកគួរតែអនុវត្តសេចក្តីសន្យានេះឱ្យទៀងទាត់ផងដែរ ដើម្បីពង្រឹង និងរំលឹកទីបន្ទាល់របស់អ្នកផ្ទាល់ អំពីព្រះគម្ពីរមរមន។ ការរំលឹកទីបន្ទាល់នេះនឹងជួយអ្នកឱ្យរក្សាទំនុកចិត្តឱ្យរឹងមាំថា មនុស្សណាក៏ដោយឱ្យតែអនុវត្តតាមសេចក្តីសន្យានេះនឹងទទួល បានចំលើយ។

## ប្រើប្រាស់ព្រះគម្ពីរមរមននៅគ្រប់ទិដ្ឋភាពទាំងអស់នៃកិច្ចការរបស់អ្នក

ព្រះគម្ពីរមរមន គឺជាធនធានដ៏មានឥទ្ធិពល នៅក្នុងការផ្លាស់ប្តូរគំនិត។ ចូរប្រើព្រះគម្ពីរមរមនជាប្រភពសំខាន់ សំរាប់ការបង្រៀនអំពីសេចក្តីពិត ដែលបានស្តារឡើងវិញ។

## ចូរចងចាំចំណុចនេះៈ

- ព្រះគម្ពីរមរមន គឺជាមូលដ្ឋាននៃសាក្សីរបស់យើងអំពីព្រះគ្រីស្ទ គោលលទ្ធិរបស់យើង និងទីបន្ទាល់របស់យើង។
- ព្រះគម្ពីរមរមនបង្រៀនយ៉ាងច្បាស់អំពីគោលលទ្ធិ ដែលអាចរកបាននៅក្នុងមេរៀនអ្នកផ្សព្វផ្សាយសាសនា។
- ចូរប្រើព្រះគម្ពីរមរមន ដើម្បីឆ្លើយសំនួរខាងព្រលឹងវិញ្ញាណ និងដើម្បីឆ្លើយតបចំពោះការជំទាស់នឹងសាសនាចក្រ។
- សូមអានព្រះគម្ពីរមរមនដោយខ្ជាប់ខ្ជួនជាមួយនឹង សាសនាគន់ការីរបស់អ្នក និងអ្នកផ្លាស់ប្រែគំនិតថ្មី។ ចូរធ្វើឱ្យអស់ពីសមត្ថភាព ដែលអ្នកអាចធ្វើបានដើម្បីជួយពួកគេអាន ដោយខ្លួនឯងជារៀងរាល់ថ្ងៃ និងអនុវត្តនូវអ្វី ដែលពួកគេរៀននៅក្នុងជីវិតរបស់ពួកគេ។
- ចូរទុកចិត្តទៅលើសេចក្តីសន្យារបស់ព្រះអម្ចាស់ថា មនុស្សគ្រប់រូប ដែលអាន និងអធិស្ឋានដោយចិត្តស្មោះ អំពីព្រះគម្ពីរនេះ នោះអាចដឹងដោយពិតប្រាកដអំពីសេចក្តីពិតពេញលេញដោយចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ។

កំណត់ចំណាំ

# គំនិតសំរាប់ការសិក្សា និងការអនុវត្ត

## ការសិក្សាផ្ទាល់ខ្លួន

- សូមអានទីហ្វៃទី2 2, 9, 30, 31, 32 ហើយគូសពណ៌ចំណាំនៅគ្រប់ឯកសារយោង ចំពោះព្រះយេស៊ូវគ្រីស្ទ។ ចូរធ្វើបញ្ជីមួយ ដែលមានឈ្មោះ និងចំណងជើងខុសៗគ្នា សំរាប់ព្រះគ្រីស្ទ ដែលប្រើនៅក្នុងជំពូកទាំងនេះ។ ចូរគូសបន្ទាត់ ពាក្យដែលបាន និយាយអំពីព្រះគ្រីស្ទ។ ចូរគូសពណ៌ទៅលើមុខនាទី និងសកម្មភាពរបស់ទ្រង់។ អ្នកអាចបន្តការអនុវត្តនេះ នៅពេលអ្នកអាន ព្រះគម្ពីរមរមនទាំងមូល។

- ចូរសរសេរនៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក អំពីអារម្មណ៍របស់អ្នកជាយ៉ាងណា នៅពេល អ្នកទទួលបានជាតំបូង នូវសាក្សីខាងវិញ្ញាណថា ព្រះគម្ពីរមរមនពិត។

- គ និង ស 20:17 ប្រើឃ្លា "ដោយរឿងទាំងនេះ នោះយើងដឹង" ដើម្បីណែនាំពីគោលលទ្ធិ ដែលបានបង្រៀន និងបញ្ជាក់ ដោយព្រះគម្ពីរមរមន។ សូមអាន គ និង ស 20:15–35 ហើយធ្វើបញ្ជីមួយ នៃគោលលទ្ធិទាំងឡាយ ដែលបាននិយាយមក ហើយនោះ។ ចូរជ្រើសរើស គោលលទ្ធិមួយ ពីគោលលទ្ធិទាំងឡាយ ហើយប្រើ Guide to the Scriptures ដើម្បីប្រៀប ធៀបបញ្ជីរបស់អ្នកទៅនឹងអ្វី ដែលព្រះគម្ពីរបរិសុទ្ធបានបង្រៀនអំពីគោលលទ្ធិទាំងនេះ។

- ចូរប្រៀបធៀបទេសនកថានៅលើភ្នំ នៅក្នុងម៉ាថាយ 5–7 និងទេសនកថារបស់ព្រះគ្រីស្ទ នៅក្នុងព្រះវិហារ ក្នុងនីហ្វៃទី3 12–14។ ចូរធ្វើបញ្ជីមួយអំពីសេចក្តីពិតដ៏ច្បាស់ និងពិសេសៗជាច្រើន ដែលបានស្តារឡើងវិញ តាមរយៈ ព្រះគម្ពីរមរមន។

- ចូរធ្វើបញ្ជីមួយ អំពីសំនួរ ដែលសាសនាគន់ការីបានសួរ។ ចូរស្វែងរកវគ្គព្រះគម្ពីរមរមន ដែលឆ្លើយនឹងសំនួរទាំងនោះ ហើយចូរ ប្រើវគ្គគម្ពីរទាំងឡាយ នៅពេលត្រូវការ នៅក្នុងការបង្រៀនជាប្រចាំរបស់អ្នក។

- ចូរស្វែងរកបទគម្ពីរមួយពីព្រះគម្ពីរមរមន ដែលបានផ្លាស់ប្តូរជីវិតរបស់អ្នក។ ចូរកត់ត្រាអំពីអារម្មណ៍របស់អ្នក អំពីបទគម្ពីរនេះ នៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក។

- តាំងនូវចំណុច ដែលកើតឡើងនីមួយៗនៅក្នុងព្រះគម្ពីរមរមន ដែលពាក្យនៃការអធិស្ឋានរបស់នរណាម្នាក់ ត្រូវបានកត់ត្រាទុក។ នៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក ចូរសរសេរទំរង់ទូទៅនៃការអធិស្ឋានទាំងនេះ។

- សូមអាននីហ្វៃទី2 33:10–15 និងមរ៉ូណៃ 10:27–29, 34។ តើអ្នកនឹងប្រាប់ដល់នីហ្វៃ និងមរ៉ូណៃ អ្វីខ្លះ នៅវេទិកាជំនុំជំរះ អំពីការប្រើព្រះគម្ពីរមរមនរបស់អ្នក? ចូរសរសេរនូវចំលើយរបស់អ្នក និងដាក់គោលដៅ ដើម្បីកែលំអ។

- មកពីក្បាលជំពូក នៃម៉ូសាយ 11–16 ចូរសរសេរសង្ខេបអំពីអ្វី ដែលអាប៊ីណាដៃបានបង្រៀន។ សូមអានជំពូកទាំងនេះ ហើយ ពង្រីកនូវការសង្ខេបរបស់អ្នក។

- មកពីក្បាលជំពូក នៃម៉ូសាយ 2–5 ចូរសរសេរដោយសង្ខេបអំពីអ្វី ដែលស្តេចបេនយ៉ាមីន បានបង្រៀន។ សូមអានជំពូក ទាំងនេះ ហើយពង្រីកនូវការសង្ខេបរបស់អ្នក។

- នៅពេលអ្នកអានជាប្រចាំថ្ងៃពីព្រះគម្ពីរមរមន ចូរកត់ត្រានៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក អំពីវគ្គ ដែលធ្វើឱ្យ អ្នកចាប់អារម្មណ៍។ ចូរសរសេរអំពីរបៀប ដែលអ្នកនឹងអនុវត្តវគ្គទាំងនោះនៅក្នុងជីវិតរបស់អ្នក។

## ការសិក្សាជាមួយដៃគូ

- សូមអានវគ្គព្រះគម្ពីរមរមនជាមួយគ្នា។ ចែកចាយអ្វីដែលអ្នកបានរៀន និងទទួលអារម្មណ៍។ សូមថ្លែងទីបន្ទាល់របស់អ្នក ចំពោះ គ្នាទៅវិញទៅមកផងដែរ។

- តើព្យាការី និងអ្នកផ្សព្វផ្សាយសាសនានៅក្នុងព្រះគម្ពីរមរមនមួយណា ដែលអ្នកចង់ក្លាយឱ្យដូច ហេតុអ្វី? ចូរចែកចាយចំលើយ របស់អ្នក ជាមួយនឹងដៃគូរបស់អ្នក។

- សូមអានអាលម៉ា 26 និង 29 ជាដៃគូ។ ចែកចាយអារម្មណ៍ ដែលអ្នកមានអំពី បេសកកម្មរបស់អ្នក។ ចូរសរសេរអំពីអារម្មណ៍ របស់អ្នក នៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក។

កំណត់ចំណាំ

- សូមអានអាលម៉ា 37:9 ហើយពិភាក្សាថា តើបទគម្ពីរសំខាន់យ៉ាងណា ចំពោះអាំម៉ូន និងអ្នកផ្សព្វផ្សាយសាសនា ប្អូនរបស់លោក។ ចូរស្វែងរកឯកសារយោង ដែលពិពណ៌នាអំពីរបៀប ដែលពួកគេប្រើបទគម្ពីរ។

- សូមអានអាលម៉ា 11–14 ជាមួយដៃគូរបស់អ្នក ម្នាក់ដើរតួជាអាលម៉ា ឬអាមូលេក ហើយម្នាក់ទៀតធ្វើជាអ្នកបង្ខូច។ ចូរកត់ចំណាំពីរបៀប ដែលអ្នកផ្សព្វផ្សាយសាសនាទាំងនេះ ឆ្លើយតបចំពោះសំនួរពិបាកៗ។

- សូមអានដំណើររឿងពិតដូចខាងក្រោម ហើយពិភាក្សាអំពីអ្វី ដែលអ្នកបានរៀនអំពីសារៈសំខាន់ ហើយនឹងចេស្តានៃព្រះគម្ពីរមរមន (ឈ្មោះត្រូវបានផ្លាស់ប្តូរ)។

  "នៅពេលយើង ត្រូវបានអញ្ជើញ ស្នាសឌើរ ឱ្យទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ បងស្រីស្នាយឌើរ បានរៀបចំរួចស្រេចហើយ ប៉ុន្តែបងប្រុសស្នាយឌើរ និយាយថា 'កុំទាន់មានសង្ឃឹមច្រើនពេក អែលឌើរ។ ខ្ញុំមិនដឹងថា បើខ្ញុំអាចធ្វើដូចនេះបានឬអត់ទេ!' ទោះបីជាបងប្រុស ស្នាយឌើរ ទទួលបាននូវអ្វី ដែលយើងបង្រៀន ហើយតែងតែល្អ និងរាក់ទាក់ក៏ដោយ ក៏គាត់នៅមានកង្វល់យ៉ាងខ្លាំងអំពីគ្រួសាររបស់គាត់ ថានឹងមានប្រតិកម្មយ៉ាងណា ពេលគាត់ចូលរួមជាមួយ នឹងព្រះវិហារមួយផ្សេងទៀតដូច្នេះ។

  "ក្រោយពីរង់ចាំមើល បងប្រុស ស្នាយឌើរ អស់រយៈពេលពីរបីអាទិត្យ ដៃគូរបស់ខ្ញុំ និងខ្ញុំយល់ឃើញយ៉ាងខ្លាំងថា ត្រូវអាននីហ្វៃទី3 11 ម្តងទៀតជាមួយនឹងគ្រួសារបងប្រុសស្នាយឌើរ។ ខ្ញុំនឹងមិនដែលភ្លេចអំពីអ្វី ដែលបានកើតឡើង នៅយប់នោះទេ។ នៅពេលយើងបើកព្រះគម្ពីរមរមន ដៃគូរបស់ខ្ញុំបានពន្យល់ថា 'ជំពូកនេះ ប្រហែលជាអ្នកនៅចាំ គឺជាដំណើររឿងនៃ ការយាងមកជួប ប្រជាជននៅក្នុងព្រះគម្ពីរមរមនរបស់ព្រះអង្គសង្គ្រោះ។ នៅកន្លែងនេះ យើងអានអំពីសេចក្តី ស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ចំពោះប្រជាជនទាំងនោះ និងអ្វី ដែលទ្រង់បង្រៀនដល់ពួកគេ។' យើងចែកគ្នាអានខគម្ពីរមួយ ឬពីរ។ បន្ទាប់ពីបានអានដល់ខទី5 ដៃគូរបស់ខ្ញុំបាននិយាយកាត់ ហើយនិយាយថា 'ខ្ញុំតែងតែចាប់អារម្មណ៍ជាមួយនឹងការពិពណ៌នា ដែលបានផ្តល់ឱ្យនៅទីនេះ អំពីសំលេង ដែលពួកគេបានឮ។ មិនមែនជាសម្លេងស្អក ឬសម្លេងខ្លាំងទេ ក៏ប៉ុន្តែទោះបីជា សម្លេងតូចក៏ដោយ គង់តែចាក់ទំលុះទៅក្នុងខ្លួនពួកគេ។ សម្លេងនេះមិនមែនឮតែនឹងត្រចៀកប៉ុណ្ណោះទេ ប៉ុន្តែសម្លេងនេះ និយាយនៅក្នុងចិត្តពួកគេវិញ។' ខ្ញុំមើលទៅគ្រួសារបងប្រុសស្នាយឌើរ នៅពេលពួកគេស្តាប់ ដោយយកចិត្តទុកដាក់ ចំពោះដៃគូរបស់ខ្ញុំ។

  "បន្ទាប់ពីការពិភាក្សាខ្លះៗ អំពីការអធិស្ឋាន និងការស្តាប់តាមព្រះវិញ្ញាណ នោះគឺជាវេនរបស់បងប្រុសស្នាយឌើរអានៈ 'ហើយមើលចុះនៅលើកទីបី ទើបពួកគេយល់នូវសម្លេង ដែលគេបានឮ ហើយសម្លេងនោះនិយាយទៅកាន់គេថាៈ មើលន៍បុត្រាដ៏ជាទីស្រឡាញ់របស់យើង ដែលយើងគាប់ចិត្តជាអនេក ដែលបានសរសើរដំកើងដល់នាមរបស់យើង ចូរស្តាប់តាមបុត្រាយើងចុះ។' បងប្រុសស្នាយឌើរ ក៏ឈប់អាន ហើយមើលដោយយកចិត្តទុកដាក់ នៅក្នុងព្រះគម្ពីរមរមនរបស់គាត់។ បន្ទាប់មកគាត់មើលមក ខ្ញុំ ហើយនិយាយថា 'ព្រះវរបិតាសួគ៌ ពិតជាមានមោទនភាព ចំពោះបុត្រារបស់ទ្រង់ណាស់ មែនទេ?' ខ្ញុំនិយាយថា 'បាទ'។ បងប្រុស ស្នាយឌើរមើលនៅក្នុងព្រះគម្ពីរគាត់ម្តងទៀត ហើយសំឡឹងមើលនៅទំព័រនោះ ដោយគិតស៊ីជំរៅ។ ទីបញ្ចប់គាត់និយាយថា 'ខ្ញុំចង់ឱ្យព្រះវរបិតាសួគ៌ មានមោទនភាពចំពោះខ្ញុំដែរ។ ខ្ញុំឆ្ងល់ថា តើទ្រង់ណែនាំពីខ្ញុំយ៉ាងណាដែរ។ ខ្ញុំស្មានថា បើខ្ញុំ...ល្អ ដូចដែលខ្ញុំចង់ឱ្យទ្រង់មោទនភាពចំពោះខ្ញុំ នោះខ្ញុំគួរតែធ្វើអ្វី ដែលទ្រង់ចង់ឱ្យខ្ញុំធ្វើ។' ខ្ញុំឆ្លើយតបថា 'បាទ ខ្ញុំគិតថានោះសំខាន់'។ បងប្រុសស្នាយឌើរបន្តថា 'ល្អ'។ 'ខ្ញុំគិតថា ខ្ញុំគិតច្រើនពេកហើយ អំពីអ្វីដែលអ្នកដទៃទៀតគិត ហើយមិនគ្រប់គ្រាន់អំពីអ្វី ដែលព្រះគិតនោះទេ។' បន្ទាប់ពីឈប់មួយភ្លែត បងប្រុសស្នាយឌើរងក់ក្បាលហើយដោយទឹកមុខម៉ឺងម៉ាត់ គាត់និយាយថា 'ខ្ញុំគិតថា ខ្ញុំគួរតែទទួលបុណ្យជ្រមុជទឹក។' ការឆ្លើយតបរបស់គាត់ គឺជាការមិនស្មានដល់ ដែលដៃគូរបស់ខ្ញុំ និងខ្ញុំមើលទៅគាត់ឡើងភ្លឹក។ ទីបំផុតដៃគូ ខ្ញុំនិយាយថា 'បាទ នោះគឺជារឿងត្រឹមត្រូវ ដើម្បីធ្វើ។ តាមការពិត ក្រោយមកនៅក្នុងជំពូកនេះ ព្រះអង្គសង្គ្រោះបង្រៀនថា...' នៅពេលដៃគូរបស់ខ្ញុំនិយាយ ខ្ញុំមានអារម្មណ៍ឆេះរោល នៅក្នុងចិត្តរបស់ខ្ញុំ ហើយដឹងគុណ ចំពោះចេស្តានៃព្រះគម្ពីរមរមន។"

តើអ្នកផ្សព្វផ្សាយសាសនាទាំងនេះ ប្រើព្រះគម្ពីរមរមនយ៉ាងដូចម្តេចដែរ? តើអ្នក និងដៃគូរបស់អ្នកប្រើព្រះគម្ពីរយ៉ាងដូចម្តេច ដើម្បីឱ្យកាន់តែមានប្រសិទ្ធភាពនៅក្នុងការខិតខំប្រឹងប្រែងជាអ្នកផ្សព្វផ្សាយសាសនានោះ?

## ការប្រជុំមណ្ឌល និងសន្និសីទហ្សូន

- ហាត់ប្រើព្រះគម្ពីរមរមន នៅក្នុងរបៀបនីមួយៗ ដែលបាននិយាយនៅក្នុងក្បាលជំពូកដ៏សំខាន់នេះ។

- ធ្វើបញ្ជីអំពីការជំទាស់ ឬសំនួរទាំងឡាយ ដែលបានលើកឡើងដោយសាសនាគ់នការី។ ចូរពន្យល់ដល់គ្នាទៅវិញទៅមក អំពីរបៀប ដែលអ្នកអាចឆ្លើយសំនួរទាំងនេះដោយការប្រើព្រះគម្ពីរមរមន។

- អានវគ្គព្រះគម្ពីរជាមួយគ្នា។ ចែកចាយចំណេះដឹង អារម្មណ៍ និងទីបន្ទាល់។

កំណត់ចំណាំ

- ហាត់ប្រើព្រះគម្ពីរមរមន ដើម្បីបញ្ជាក់អំពីសារលិខិតនៃការស្ដារឡើងវិញ។

- ចូរជ្រើសរើសអ្នកផ្សព្វផ្សាយសាសនាអស្ចារ្យម្នាក់ នៅក្នុងព្រះគម្ពីរមរមន។ ពិភាក្សា ហើយឱ្យអ្នកផ្សព្វផ្សាយសាសនា ធ្វើបញ្ជីពីបុគ្គលិកលក្ខណៈនៃអ្នកផ្សព្វផ្សាយសាសនានេះ។ អញ្ជើញអ្នកផ្សព្វផ្សាយសាសនាម្នាក់ៗ ឱ្យដាក់គោលដៅ ដើម្បីអនុវត្តតាមបុគ្គលិកលក្ខណៈមួយ។ ចូរធ្វើសកម្មភាពនេះសារឡើងវិញ ជាទៀងទាត់ ដោយការប្រើអ្នកផ្សព្វផ្សាយសាសនា ក្នុងព្រះគម្ពីរមរមន។

- អញ្ជើញអ្នកផ្សព្វផ្សាយសាសនា ឱ្យចែកចាយអំពីបទពិសោធន៍ ដែលព្រះគម្ពីរមរមនបានជួយ ដល់សាសនាគន់ការី របស់ពួកគេនៅក្នុងដំណើរការ នៃការផ្លាស់ប្រែគំនិតរបស់ពួកគេ។

- ឱ្យអ្នកផ្សព្វផ្សាយសាសនា ចែកចាយចំលើយក្នុងព្រះគម្ពីរមរមន ដែលល្អជាងគេ ចំពោះសំនួរខាងវិញ្ញាណ។

## ប្រធានបេសកកម្ម

- បង្រៀនអ្នកផ្សព្វផ្សាយសាសនាអំពីរបៀប ប្រើព្រះគម្ពីរមរមន ដើម្បីបញ្ជាក់អំពីសេចក្ដីពិតពេញលេញ នៃសារលិខិតនៃការស្ដារឡើងវិញ។

- អានទីហ្វៃទី1 1 ជាមួយអ្នកផ្សព្វផ្សាយសាសនា ហើយប្រៀបធៀបជាមួយនឹងបទពិសោធន៍របស់យ៉ូសែប ស្ម៊ីធ។

- ផ្ដល់ ក្រដាសស្អាតនៅខាងក្រោយព្រះគម្ពីរមរមនមួយច្បាប់ ឱ្យអ្នកផ្សព្វផ្សាយសាសនា។ សូមឱ្យពួកគេគូសពណ៌ចំណាំផ្សេងៗគ្នាដូចជា៖
  - ឯកសារយោងនីមួយៗចំពោះព្រះយេស៊ូវគ្រីស្ទ (ព្រះនាមរបស់ទ្រង់ណាក៏ដោយ ឬប្រសិទ្ធិនាម ដែលសំដៅទៅលើទ្រង់)។
  - ព្រះបន្ទូលរបស់ទ្រង់ (មានបន្ទូលដោយទ្រង់ ឬដោយព្យាការី នៅពេលពួកគេនិយាយថា “ទ្រង់មានព្រះបន្ទូលដូច្នេះថា”។
  - មុខនាទីរបស់ទ្រង់។
  - គោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលមាននៅក្នុងព្រះគម្ពីរមរមន។

  នៅខាងក្រោមទំព័រនីមួយៗ ចូរសួរអ្នកផ្សព្វផ្សាយសាសនាឱ្យរាប់ចំនួនគោលការណ៍ និងគោលលទ្ធិសរុប ដែលមានយោង។ នៅក្នុងការសម្ភាសន៍ និងអំឡុងពេលប្រជុំក្នុងមណ្ឌល ដែលមានពេលពីរ ឬបីខែម្ដងសំរាប់សកម្មភាពនេះ ចូរឱ្យអ្នកផ្សព្វផ្សាយសាសនា ចែកចាយគ្នាទៅវិញទៅមកអំពីអ្វី ដែលពួកគេបានរៀន។ អ្នកអាចគិតថាធ្វើសកម្មភាពស្រដៀងនេះ ជាមួយនឹងបេសកកម្ម ទាំងមូល ដែលផ្ដោតសំខាន់យោងទៅលើសេចក្ដីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ការប្រែចិត្ត ពិធីបុណ្យជ្រមុជទឹក អំណោយទាន នៃព្រះវិញ្ញាណបរិសុទ្ធ ឬគោលការណ៍គ្រឹះណាមួយ នៃដំណឹងល្អ។

- អំឡុងធ្វើការសម្ភាសន៍ អញ្ជើញអ្នកផ្សព្វផ្សាយសាសនាឱ្យចែកចាយជាមួយអ្នកនូវបទគម្ពីរទាំងឡាយ ក្នុងព្រះគម្ពីរមរមន ដែលបានផ្លាស់ប្ដូរជីវិតរបស់ពួកគេ។

- ជួយអ្នកផ្សព្វផ្សាយសាសនាយល់ពីរបៀប ដែលព្រះគម្ពីរមរមន បានបង្រៀនអំពីគោលលទ្ធិ ចេញមកពីមេរៀន អ្នកផ្សព្វផ្សាយសាសនា។ ឧទាហរណ៍ បើប្រធានបទអំពីដង្វាយធួន ចូរឱ្យអ្នកផ្សព្វផ្សាយសាសនា សរសេរនៅក្នុងកូឡោនមួយ អំពីផ្នែកសំខាន់ៗនៃដង្វាយធួន ដែលបានបង្រៀននៅក្នុងព្រះគម្ពីរមរមន ដែលរួមមានទាំងឯកសារយោងរបស់វា។ បន្ទាប់មក នៅក្នុងកូឡោនទីពីរ ឱ្យពួកគេធ្វើបញ្ជី ឱ្យនៅក្បែរនឹងផ្នែកដូចគ្នាទាំងនោះ ដូចដែលបានបង្រៀននៅក្នុងព្រះគម្ពីរបរិសុទ្ធ។ ចូរឱ្យអ្នកផ្សព្វផ្សាយសាសនារបស់អ្នកទុកចន្លោះទំនេរ ចំពោះធាតុទាំងឡាយណា ដែលបានបាត់ ឬមិនបានបង្រៀននៅក្នុងព្រះគម្ពីរបរិសុទ្ធ។ នោះនឹងក្លាយទៅជាភស្ដុតាងយ៉ាងសំខាន់ ចំពោះអ្នកផ្សព្វផ្សាយសាសនា អំពីរបៀប ដែលព្រះគម្ពីរមរមន គឺជាមូលដ្ឋាននៃគោលលទ្ធិរបស់យើង។ សកម្មភាពដូចគ្នានេះ អាចធ្វើបានជាមួយនឹងគោលលទ្ធិផ្សេងទៀត ដែលអ្នកផ្សព្វផ្សាយសាសនាបង្រៀន។

- ត្រូវស្គាល់សំនួរ ដែលមានទាក់ទងនឹងវិញ្ញាណ សំរាប់មនុស្សនៅក្នុងបេសកកម្មរបស់អ្នក។ សូម អញ្ជើញអ្នកផ្សព្វផ្សាយសាសនាឱ្យស្វែងរកចំលើយនៅក្នុងព្រះគម្ពីរមរមន។



# តើខ្ញុំអាចអភិវឌ្ឍន៍លក្ខណៈឱ្យដូចជា ព្រះគ្រីស្ទ យ៉ាងដូចម្ដេច?

កំណត់ចំណាំ

### ចូរពិចារណាការណ៍នេះ

- តើខ្ញុំអាចអភិវឌ្ឍន៍លក្ខណៈដែលនឹងធ្វើឱ្យខ្ញុំ កាន់តែមានអំណាច និងមានប្រសិទ្ធិភាពជាអ្នកបំរើនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ យ៉ាងដូចម្ដេច?
- តើការអភិវឌ្ឍន៍លក្ខណៈដូចជាព្រះគ្រីស្ទ នឹងជួយខ្ញុំបំពេញគោលបំណងរបស់ខ្ញុំ ជាអ្នកផ្សព្វផ្សាយសាសនា យ៉ាងដូចម្ដេច?
- តើលក្ខណៈមួយណា ដែលខ្ញុំត្រូវការអភិវឌ្ឍន៍ ចាំបាច់បំផុត?

នៅឯកសារចាប់ផ្ដើមនៃការបំរើ នៃជីវិតរមែងស្លាប់របស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ បានដើរទៅមាត់សមុទ្រកាលីឡេ ហើយបានស្រែកទៅកាន់អ្នកនេសាទពីរនាក់ គឺពេត្រុស និងអនទ្រេ។ ទ្រង់បានមានបន្ទូលថា៖ "ចូរមកតាមខ្ញុំ" "ខ្ញុំនឹងតាំងអ្នក ឱ្យជាអ្នកនេសាទ មនុស្សវិញ" (ម៉ាថាយ 4:19 សូមមើលផងដែរ ម៉ាកុស 1:17)។ ព្រះអម្ចាស់ក៏បានហៅអ្នក ឱ្យបំរើកិច្ចការរបស់ទ្រង់ផងដែរ ហើយ ទ្រង់អញ្ជើញអ្នកឱ្យធ្វើតាមទ្រង់។ ការអញ្ជើញដើម្បីធ្វើតាមព្រះគ្រីស្ទ គឺជាការអញ្ជើញដើម្បីធ្វើតាមគំរូរបស់ទ្រង់ និងដើម្បី ប្រែក្លាយ ដូចជាទ្រង់។

ជំពូកខ្លះនៅក្នុង "*ប្រកាសដំណឹងល្អរបស់យើង*" គឺផ្ដោតទៅលើអ្វីដែលអ្នកត្រូវធ្វើ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា—របៀបសិក្សា របៀបបង្រៀន របៀបគ្រប់គ្រងពេលយ៉ាងឆ្លាតវៃ។ ទោះជាយ៉ាងណាក៏ដោយអ្វីដែលអ្នកធ្វើ គឺសំខាន់ដូច ជាខ្លួនរបស់អ្នកអញ្ចឹង។

ដំណឹងល្អដែលបានស្ដារឡើងវិញ អាចធ្វើឱ្យអ្នកប្រែក្លាយដូចជាព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ។ ព្រះអង្គសង្គ្រោះ បានបង្ហាញផ្លូវ។ ទ្រង់បានធ្វើជាគំរូដ៏ល្អឥតខ្ចោះ ហើយទ្រង់បញ្ជាយើងឱ្យប្រែក្លាយដូចជាទ្រង់ (សូមមើល នីហ្វៃទី 3 27:27)។ វៀនពីទ្រង់ នឹងស្វែងរកដើម្បីភ្ជាប់លក្ខណៈរបស់ទ្រង់នៅក្នុងជីវិតរបស់អ្នក។ តាមរយៈអំណាចនៃដង្វាយធួនរបស់ទ្រង់ អ្នកអាចសំរេច គោលដៅនេះ ហើយនឹងនាំឱ្យអ្នកដទៃសំរេចគោលដៅនេះផងដែរ។

ព្រះគម្ពីរបានពិពណ៌នាពីលក្ខណៈដូចជាព្រះគ្រីស្ទថា ជាចំណុចសំខាន់សំរាប់អ្នក ដើម្បីអភិវឌ្ឍន៍តាម ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ម្នាក់ និងក្នុងឆាកជីវិតរបស់អ្នក។ ចូរសិក្សាវគ្គព្រះគម្ពីរនៅក្នុងជំពូកនេះ និងស្វែងរកគំរូ នៃលក្ខណៈផ្សេងទៀត ដែលដូចជាព្រះគ្រីស្ទ នៅពេលដែលអ្នកសិក្សាវគ្គផ្សេងទៀត។

លក្ខណៈដូចជាព្រះគ្រីស្ទ គឺជាអំណោយទានមកពីព្រះ។ លក្ខណៈដូចជាព្រះគ្រីស្ទ មានមកនៅពេលដែលអ្នកប្រើសេរីភាពរបស់អ្នក ដោយសុចរិត។ សូមដល់ព្រះវរបិតាសួគ៌របស់អ្នក ឱ្យប្រទានពរដល់អ្នកជាមួយនឹងលក្ខណៈទាំងនេះ អ្នកមិនអាចអភិវឌ្ឍន៍លក្ខណៈ ដូចជាព្រះគ្រីស្ទ ដោយគ្មានជំនួយពីទ្រង់ឡើយ។ ជាមួយនឹងសេចក្ដីប៉ងប្រាថ្នាដើម្បីផ្គាប់ព្រះហឫទ័យព្រះ គឺត្រូវស្គាល់ភាព ទន់ខ្សោយរបស់អ្នក និងត្រូវមានឆន្ទៈ ហើយមានចិត្តអន្ទះសារ ដើម្បីអភិវឌ្ឍន៍ចំណុចទន់ខ្សោយទាំងនោះ។

កំណត់ចំណាំ

## ការសិក្សាព្រះគម្ពីរ

**តើខគម្ពីរទាំងនេះ ប្រាប់អ្វីខ្លះអំពីការធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ?**

នីហ្វៃទី 3 12:48 យ៉ូហាន 13:1–16 ពេត្រុសទី 1 2:21
នីហ្វៃទី 3 27:21, 27

**តើគោលការណ៍ ដំបូងនៃដំណឹងល្អ និងលក្ខណៈដូចជាព្រះគ្រីស្ទ មានទំនាក់ទំនងជាមួយនឹងគ្នាដូចម្ដេចខ្លះ?**

មរ៉ូណៃ 8:25–26

## គំនិតសំរាប់សិក្សាជំពូកនេះ

មានរបៀបជាច្រើនសំរាប់សិក្សាជំពូកនេះ។ ចូរសាកល្បងប្រើគំនិតមួយនៃគំនិតដូចខាងក្រោមៈ

- នៅពេលដែលអ្នកបំពេញ "សកម្មភាពនៃលក្ខណៈ" នៅចុងនៃជំពូកនេះ បញ្ជាក់ពីលក្ខណៈដែលអ្នកត្រូវការ ឬចង់ អភិវឌ្ឍន៍ជាទីបំផុត។ សិក្សាជំពូកនេះ អំពីលក្ខណៈនោះ និងដាក់គោលដៅដើម្បីអភិវឌ្ឍន៍តាម។
- អានជំពូកទាំងមូលដោយមិនបាច់សិក្សាព្រះគម្ពីរ ហើយកំណត់យកលក្ខណៈមួយណា ដែលអ្នកចង់សិក្សាបន្ថែម ឱ្យបានពេញលេញ។ បន្ទាប់មកសិក្សាបទគម្ពីរសំខាន់ៗ ដែលមានទំនាក់ទំនងនឹងលក្ខណៈនោះ។ ស្វែងរកបន្ថែមបទគម្ពីរ ដែលមិនបាន សរសេរនៅក្នុងជំពូក ដែលបង្រៀនអំពីលក្ខណៈនោះ។ សរសេរនៅក្នុងសៀវភៅសិក្សារបស់អ្នក នូវគំនិតទាំងឡាយ ដើម្បីអភិវឌ្ឍន៍លក្ខណៈទាំងនោះ។
- បញ្ជាក់ពីលក្ខណៈមួយដែលអ្នកចង់សិក្សា។ ធ្វើតាមទំរង់គំនិត នៅក្រោមចំណងជើង "ការអភិវឌ្ឍន៍លក្ខណៈដូចជា ព្រះគ្រីស្ទ" ដែលមាននៅចុងបញ្ចប់នៃជំពូក។

## សេចក្ដីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ



© 1989 Conception Unlimited Investment, Inc. ហាមថតចំលង។

ពេលអ្នកមានជំនឿទៅលើព្រះគ្រីស្ទ អ្នកជឿទៅលើទ្រង់ ជាព្រះរាជបុត្រានៃព្រះ ជាបុត្របង្កើតតែមួយ នៃព្រះវរបិតាខាង សាច់ឈាម។ អ្នកទទួលស្គាល់ទ្រង់ថា ជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះ និងធ្វើតាមការបង្រៀនរបស់ទ្រង់។ អ្នកជឿថា អំពើបាបរបស់អ្នក អាចត្រូវបានអភ័យទោសតាមរយៈដង្វាយធួនរបស់ទ្រង់។ មានសេចក្ដីជំនឿទៅលើទ្រង់ មានន័យថា អ្នកទុក ចិត្តទ្រង់ និងជឿជាក់ថា ទ្រង់ស្រឡាញ់អ្នក។

សេចក្ដីជំនឿ នាំទៅរកការធ្វើសកម្មភាពរួម ការប្រែចិត្ត ការគោរពប្រតិបត្តិ និងការលះបង់។ ពេលដែលអ្នកមានសេចក្ដីជំនឿ ទៅលើ ព្រះយេស៊ូវគ្រីស្ទ អ្នកទុកចិត្តលើទ្រង់ល្មមគ្រប់គ្រាន់ ដើម្បីធ្វើតាមព្រះបញ្ញត្តិរបស់ទ្រង់—ទោះបីជាអ្នក មិនបានយល់ពីមូលហេតុ ដែលអ្នកត្រូវធ្វើតាមក៏ដោយ។ អ្នកបំពេញអ្វីដែលព្រះអម្ចាស់ ចង់ឱ្យអ្នកបំពេញ។ អ្នកជួយនាំមកនូវសេចក្ដីល្អ ដល់ជីវិតអ្នកផ្ទាល់ ដ៏ដូចជាជីវិតអ្នកដទៃ។ អ្នកអាចធ្វើឱ្យមានអព្ភូតហេតុកើតឡើង ស្របតាមឆន្ទៈព្រះអម្ចាស់។ សេចក្ដីជំនឿរបស់អ្នកនឹងបង្ហាញតាមរយៈ សេចក្ដីព្យាយាម និងកិច្ចការទាំងឡាយ។

សេចក្ដីជំនឿ គឺជាគោលការណ៍នៃព្រះចេស្ដា។ ព្រះធ្វើកិច្ចការរបស់ទ្រង់ដោយព្រះចេស្ដា តែព្រះចេស្ដាទ្រង់ តែងតែអនុវត្ត ក្នុងការឆ្លើយតបចំពោះសេចក្ដីជំនឿ (សូមមើល មរ៉ូណៃ 10:7)។ ទ្រង់ធ្វើកិច្ចការយោងទៅតាមសេចក្ដីជំនឿ នៃកូនចៅទ្រង់។ ការសង្ស័យ និងសេចក្ដីភ័យខ្លាច គឺប្រឆាំងនឹងសេចក្ដីជំនឿ។

សេចក្ដីជំនឿរបស់អ្នក នឹងកើនឡើងតាមរយៈ ការសិក្សាដោយព្យាយាម ការអធិស្ឋាន ការលះបង់បំរើ និងការគោរពប្រតិបត្តិ ការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ និងព្រះបញ្ញត្តិ។

សេចក្ដីជំនឿរបស់អ្នក នៅក្នុងព្រះគ្រីស្ទ រីកចំរើន នៅពេលអ្នកស្គាល់កាន់តែច្រើនពីទ្រង់ និងការបង្រៀនរបស់ទ្រង់។ នៅពេលដែលអ្នករុករក និងស្វែងយល់ពីព្រះគម្ពីរ អ្នករៀនពីផ្លូវរបស់ទ្រង់ សេចក្ដីស្រលាញ់របស់ទ្រង់សំរាប់មនុស្សទាំងអស់ និងព្រះបញ្ញត្តិរបស់ទ្រង់។

សេចក្ដីជំនឿប្រួបរួមទាំង ការជឿជាក់នៅក្នុងបេសកកម្ម និងព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ។ តាមរយៈសេចក្ដីជំនឿ អ្នកទទួលចំលើយចំពោះការអធិស្ឋានរបស់អ្នក និងការបំផុសគំនិតផ្ទាល់ខ្លួន ដើម្បីដឹកនាំអ្នក នៅក្នុងកិច្ចការរបស់ព្រះអម្ចាស់។

កំណត់ចំណាំ

### ការសិក្សាព្រះគម្ពីរ

**តើជំនឿជាអ្វី?**

អាលម៉ា 32:21
អេធើរ 12:6
ហេព្រើរ 11:1
*True to the Faith*, "សេចក្តីជំនឿ" 176–178
Guide to the Scriptures, "Faith"

**តើអ្នកទទួលសេចក្តីជំនឿដោយរបៀបណា ហើយអ្នកអាចធ្វើអ្វី តាមរយៈសេចក្តីជំនឿ?**

នីហ្វៃទី 2 25:29
នីហ្វៃទី 2 26:13
ម៉ូសាយ 4:6–12
អាលម៉ា 32
ហេលេមិន 15:7–8
អេធើរ 12:7–22
មរ៉ូណៃ 7:33
រ៉ូម 10:17
ហេព្រើរ 11

**តើពរជ័យអ្វីខ្លះ ដែលកើតមានដោយសារសេចក្តីជំនឿ?**

ម៉ូសាយ 3:7
ម៉ូសាយ 5:1–15
ហេលេមិន 5:9–12
យ៉ូហាន 14:6

## សេចក្តីសង្ឃឹម

សេចក្តីសង្ឃឹម គឺការទុកចិត្តជាប់ជានិច្ចថា ព្រះអម្ចាស់នឹងបំពេញការសន្យារបស់ទ្រង់ចំពោះអ្នក។ វាបង្ហាញឱ្យឃើញនៅក្នុងការជឿជាក់ សុទិដ្ឋិនិយម ភាពសប្បាយរីករាយ និងការអត់ធ្មត់។ គេជឿ និងសង្ឃឹមទុកថា នឹងមានរឿងអ្វីមួយកើតឡើងពិតមែន។ ពេលដែលអ្នកមានសេចក្តីសង្ឃឹម អ្នកធ្វើការ ពុះពារឆ្លងកាត់ឧបស័គ្គ និងភាពលំបាកទាំងឡាយ ជាមួយនឹងការជឿជាក់ និងការអះអាងថា គ្រប់ការណ៍ ទាំងអស់ផ្សំគ្នា សំរាប់សេចក្តីល្អដល់អ្នក។ សេចក្តីសង្ឃឹមជួយអ្នកឈ្នះលើការបាក់ទឹកចិត្ត។ ព្រះគម្ពីរតែងតែពិពណ៌នា ពីសេចក្តី សង្ឃឹមនៅក្នុងព្រះយេស៊ូវគ្រីស្ទ ដូចជាការអះអាងថា អ្នកនឹងទទួលជីវិតអស់កល្បជានិច្ច នៅក្នុងនគរសេឡេស្ទាល។

> "ដើម្បីទទួលបានពរជ័យជាមួយនឹងសេចក្តីសង្ឃឹម ចូរយើង ដែលជាកូនសិស្ស ឈោងទៅរកមនុស្សទាំងនោះ ដែល 'ងាកបែរចេញ ពីសេចក្តីសង្ឃឹមរបស់ដំណឹងល្អ ទោះជាក្នុងមូលហេតុអ្វីក៏ដោយ' (កូល៉ុស 1:23)។ ចូរយើងលើកដៃដែលស្រពន់ឡើង នឹងជង្គង់ ដែល ស្ពុតដែរ។"
>
> — អែលឌើរ នៀល អេ ម៉ាកស្វែល
> "BRIGHTNESS OF HOPE," *ENSIGN*, ខែវិច្ឆិកា ឆ្នាំ 1994, 36។

ប្រធាន ដេម អ៊ី ហ្វៅស៍ បានបង្រៀនថា៖

"សេចក្តីសង្ឃឹម គឺជាយុថ្កានៃព្រលឹងរបស់យើង . . .។

"សេចក្តីសង្ឃឹម គឺជាការទុកចិត្ត ទៅលើការសន្យារបស់ព្រះ ដោយការមានជំនឿថា បើយើងប្រព្រឹត្តក្នុងពេលឥឡូវនេះ នោះពរជ័យដែលជាបំណងប្រាថ្នា នឹងត្រូវបានទទួលនៅពេលអនាគត . . .។

"ប្រភពដែលមិនចេះបរាជ័យ នៃសេចក្តីសង្ឃឹមរបស់យើង គឺថា យើងជាបុត្រាបុត្រីនៃព្រះ ហើយព្រះរាជបុត្រារបស់ទ្រង់ ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ បានសង្គ្រោះយើងពីសេចក្តីស្លាប់ " ("Hope, an Anchor of the Soul," *Ensign*, ខែវិច្ឆិកា ឆ្នាំ 1999 59–60)។

### ការសិក្សាព្រះគម្ពីរ

**តើសេចក្តីសង្ឃឹមគឺជាអ្វី ហើយតើយើងសង្ឃឹមអ្វី?**

នីហ្វៃទី 2 31:20
អាលម៉ា 58:10–11
អេធើរ 12:4, 32
មរ៉ូណៃ 7:40–48
គ និង ស 59:23
គ និង ស 138:14
រ៉ូម 8:24–25
ហេព្រើរ 6:10–20
Guide to the Scriptures, "Hope"

កំណត់ចំណាំ

## សេចក្ដីសប្បុរស និងសេចក្ដីស្រលាញ់


© 2001 Simon Dewey. រក្សាសិទ្ធិ។

មានបុរសម្នាក់បានសួរព្រះយេស៊ូវថាះ “តើព្រះបញ្ញត្តិណាដែលសំខាន់ជាងគេបំផុត?” ព្រះយេស៊ូវបានឆ្លើយថាះ“ត្រូវស្រលាញ់ ព្រះអម្ចាស់ ជាព្រះនៃឯងឱ្យអស់ពីដួងចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង។ នេះជាបញ្ញត្តិយ៉ាងធំទីមួយ ហើយបញ្ញត្តិទីពីរ ក៏បែបដូចគ្នា គឺថា ឱ្យស្រលាញ់អ្នកជិតខាងខ្លួនដូចខ្លួនឯង” (ម៉ាថាយ 22ះ36–39)។

សេចក្ដីសប្បុរសគឺជា “សេចក្ដីស្រលាញ់ដ៏សុទ្ធសាតនៃព្រះគ្រីស្ទ” (មរ៉ូណៃ 7ះ47)។ សេចក្ដីសប្បុរស បូករួមទាំងសេចក្ដីស្រលាញ់ ដ៏អស់កល្បរបស់ព្រះ ចំពោះកូនចៅរបស់ទ្រង់។ យើងទាំងអស់គ្នា គឺត្រូវស្វែងរក ដើម្បីអភិវឌ្ឍន៍សេចក្ដីស្រលាញ់ប្រភេទនោះ។ ពេលដែលអ្នកពោរពេញទៅដោយសេចក្ដីសប្បុរស អ្នកគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះ និងធ្វើអ្វីដែលអ្នកអាចធ្វើបាន ដើម្បីបំរើអ្នកដទៃ និងជួយពួកគេឱ្យទទួលដំណឹងល្អដែលបានស្ដារឡើងវិញ។

សេចក្ដីសប្បុរស គឺជាអំណោយមកពីព្រះ។ ព្យាការីមរ៉ូណៃបាននិយាយថាះ យើងគួរតែ “អធិស្ឋានដល់ព្រះវរបិតា ដោយអស់ពីកំលាំងចិត្ត ដើម្បីឱ្យ [អ្នករាល់គ្នា ]បានពោរពេញ ដោយសេចក្ដីស្រលាញ់នេះ” (មរ៉ូណៃ 7ះ48)។ នៅពេលដែលអ្នកធ្វើតាមពាក្យដំបូន្មាននេះ ហើយព្យាយាមធ្វើកិច្ចការសុចរិត នោះសេចក្ដីស្រលាញ់របស់អ្នកសំរាប់មនុស្សទាំងអស់នឹងកើនឡើង ជាពិសេសអ្នកទាំងឡាយណាដែលនៅក្នុងចំណោមកដែលអ្នកធ្វើការជាមួយ។ អ្នកនឹងមានអារម្មណ៍ខ្វល់ខ្វាយដោយស្មោះត្រង់ ចំពោះសុខុមាលភាពដ៏អស់កល្ប និងសុភមង្គលសំរាប់មនុស្សដទៃ។ អ្នកនឹងមើលឃើញពួកគេ ជាកូនចៅរបស់ព្រះ ជាមួយនឹងសក្ដានុពលនៃការក្លាយដូចជាព្រះវរបិតាសួគ៌របស់យើង ហើយអ្នកនឹងធ្វើការងារក្នុងធុរៈកិច្ចរបស់ពួកគេ។ អ្នកនឹងជៀសវាងពីអារម្មណ៍អវិជ្ជមាន ដូចជា ខឹង ច្រណែន តណ្ហា ឬលោភចង់បាន។ អ្នកនឹងជៀសវាងពីការវិនិច្ឆ័យអ្នកដទៃ ដោយការរិះគន់ពួកគេ ឬនិយាយអ្វីដែលអវិជ្ជមាន អំពីពួកគេ។ អ្នកនឹងព្យាយាមដើម្បីយល់ពីពួកគេ និងទស្សនៈរបស់ពួកគេ។ អ្នកនឹងមានចិត្តអត់ធ្មត់ជាមួយពួកគេ និង ព្យាយាមដើម្បីជួយពួកគេ នៅពេលដែលពួកគេស្មុគស្មាញ ឬបាក់ទឹកចិត្ត។ សេចក្ដីសប្បុរស ក៏ដូចជាសេចក្ដីជំនឿ គឺដឹកនាំទៅរកសកម្មភាព។ អ្នកនឹងអភិវឌ្ឍន៍សេចក្ដីសប្បុរស នៅពេលដែលអ្នកស្វែងរកឱកាសដើម្បីបំរើអ្នកដទៃ និងលះបង់អ្វីដែលអ្នកមាន។

### ការសិក្សាព្រះគម្ពីរ

**តើសេចក្ដីសប្បុរសគឺជាអ្វី?**

| | | |
|---|---|---|
| មរ៉ូណៃ 7ះ45–48 | កូរិនថូសទី 1 13 | Guide to the Scriptures, “Charity” |

**តើព្រះយេស៊ូវបានបង្ហាញពីសេចក្ដីសប្បុរស យ៉ាងដូចម្ដេច?**

| | | |
|---|---|---|
| នីហ្វៃទី1 19ះ9 | អេធើរ 12ះ33–34 | លូកា 7ះ12–15 |
| អាលម៉ា 7ះ11–13 | | |

**តើខទាំងនេះបង្រៀនអ្នកដល់អ្វីខ្លះ អំពីសេចក្ដីសប្បុរស?**

| | | |
|---|---|---|
| នីហ្វៃទី 2 26ះ30 | អាលម៉ា 7ះ24 | ធីម៉ូថេទី 1 4ះ12 |
| ម៉ូសាយ 2ះ17 | អេធើរ 12ះ28 | ពេត្រុសទី 1 4ះ8 |
| ម៉ូសាយ 28ះ3 | គ និង ស 88ះ125 | |

## គុណធម៌

គុណធម៌កើតនៅក្នុងគំនិត និងបំណងប្រាថ្នាដ៏ជ្រៅរបស់អ្នក។ វាគឺជាទំរង់នៃគំនិត និងការប្រព្រឹត្ត យោងទៅលើបទដ្ឋាន សីលធម៌ដ៏ខ្ពង់ខ្ពស់។ ព្រោះព្រះវិញ្ញាណបរិសុទ្ធ ពុំអាស្រ័យនៅក្នុងព្រះវិហារណាដែលឥតបរិសុទ្ធ ដូច្នេះគុណធម៌ គឺជាតំរូវការ ដើម្បីទទួលបាន

កំណត់ចំណាំ

នូវការណែនាំពីព្រះវិញ្ញាណ។ អ្វីដែលអ្នកជ្រើសរើសដើម្បីគិត និងធ្វើ ពេលដែលអ្នកនៅតែម្នាក់ឯង ហើយអ្នកមិន ជឿថាបានទរណាម្នាក់រំពឹងមើលមកនោះ គឺជារង្វាស់ដ៏ធំនៃគុណធម៌របស់អ្នក។

មនុស្សដែលមានគុណធម៌ គឺជ្រះស្អាត និងបរិសុទ្ធខាងវិញ្ញាណ។ ពួកគេយកចិត្តទុកដាក់នៅលើសេចក្ដីសុចរិត គំនិតលើកដំកើង និងបោះបង់ចោលគំនិតដែលមិនសក្ដិសម ដែលដឹកនាំទៅរកសកម្មភាពដែលមិនសមរម្យ ចេញពីគំនិតរបស់គេ។ ពួកគេគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះ និងធ្វើតាមដំបូន្មាននៃអ្នកដឹកនាំសាសនាចក្រ។ ពួកគេអធិស្ឋាន សំរាប់កំលាំង និងទប់ទល់ជាមួយនឹងការល្បួង និងធ្វើអ្វីដែលត្រឹមត្រូវ។ ពួកគេប្រែចិត្តភ្លាមៗនៃអំពើបាប ឬការធ្វើអ្វីខុសណាក៏ដោយ។ ពួកគេរស់នៅ ដោយមានភាពសក្ដិសមនៃបណ្ណ័ចូលព្រះវិហារបរិសុទ្ធ។

គំនិតរបស់អ្នកដូចជាឆាកនៅក្នុងរោងល្ខោន នៅក្នុងរោងល្ខោននៃគំនិតរបស់អ្នក ទោះជាយ៉ាងណាក៏ដោយ មានតែអ្នកសម្ដែងម្នាក់តែប៉ុណ្ណោះ ដែលអាចនៅលើឆាកមួយ។ បើឆាក គ្មានអ្វីបិទបាំង គំនិតនៃភាពខ្មៅងងឹត និងអំពើបាប តែងតែចូលទៅក្នុងឆាកដើម្បីល្បួង។ តែគំនិតទាំងនេះគ្មានអំណាចទេ បើឆាកនៃគំនិតរបស់អ្នក គឺរវល់ដោយគំនិតដែលល្អ ដូចជា ការទន្ទេញទំនុកដំកើង ឬខគម្ពីរដែល អ្នកអាចធ្វើនៅពេលដែលមានការល្បួង។ ដោយការគ្រប់គ្រងឆាកនៃគំនិតរបស់អ្នក អ្នកអាចទទួលបានជោគជ័យ ក្នុងការទប់ទល់នឹងការជំរុញឱ្យមានភាពមានៈ ដើម្បីទាំមកនូវការល្បួង និងបណ្ដោយឱ្យមានបាប។ អ្នកអាចក្លាយជាបរិសុទ្ធ និងមានគុណធម៌។

### ការសិក្សាព្រះគម្ពីរ

**តើគុណធម៌មានអត្ថន័យដូចម្ដេច?**

| | | |
|---|---|---|
| គ និង ស 4:6 | គ និង ស 46:33 | ពេត្រុសទី 2 1:3–8 |
| គ និង ស 25:2 | គ និង ស 121:45–46 | Guide to the Scriptures, “Virtue” |
| គ និង ស 38:24 | មាត្រានៃសេចក្ដីជំនឿ 1:13 | |

## ចំណេះវិជ្ជា

ព្រះអម្ចាស់បានបញ្ជាថា ចូរស្វែងរក ការរៀនសូត្រ គឺដោយការសិក្សា និងដោយសារសេចក្ដីជំនឿផង (សូមមើល គ និង ស 88:118)។ ទ្រង់ក៏បានព្រមានផងដែរថា គឺគ្មានផ្លូវទេ សំរាប់មនុស្សបានសង្គ្រោះ ក្នុងការល្ងង់ខ្លៅ (សូមមើល គ និង ស 131:6)។ ចូរស្វែងរកចំណេះវិជ្ជា ជាពិសេសនោះ គឺចំណេះវិជ្ជាខាងវិញ្ញាណ។ សិក្សាព្រះគម្ពីររាល់ថ្ងៃ ហើយព្រមទាំងសិក្សាពាក្យ របស់ព្យាការីដែលនៅរស់។ តាមរយៈការសិក្សា និងការអធិស្ឋាន ចូរធ្វើការស្វែងរកជំនួយសំរាប់សំនួរជាក់លាក់ ការប្រឈមមុខ និងឱកាសទាំងឡាយរបស់ អ្នក។ ចូរចាប់អារម្មណ៍យ៉ាងពិសេសចំពោះវគ្គគម្ពីរ ដែលអ្នកអាចប្រើវា នៅពេលដែលអ្នកបង្រៀន និងពេលដែលអ្នកឆ្លើយសំនួរ អំពីដំណឹងល្អដែលបានស្ដារឡើងវិញ។

គិតអំពីរបៀបដែលអ្នកអាចអនុវត្តគោលការណ៍នៃដំណឹងល្អទៅក្នុងជីវិតរបស់អ្នក។ នៅពេលដែលអ្នកសិក្សាដោយព្យាយាម ដោយអធិស្ឋាន និងមានគោលបំណងពិត នោះព្រះវិញ្ញាណបរិសុទ្ធ នឹងបំភ្លឺគំនិតរបស់អ្នក បង្រៀនអ្នក និងជួយអ្នកយល់ពីអត្ថន័យ នៃព្រះគម្ពីរ និងការបង្រៀនទៃព្យាការីដែលនៅរស់។ អ្នកអាចកើនចំណេះវិជ្ជាផងដែរ ដោយការមើល និងការស្ដាប់អ្នកដទៃ ជាពិសេសអ្នកដឹកនាំនៃសាសនាចក្រ។ ដូចជានីហ្វៃ អ្នកអាចនិយាយថា: “ត្បិតព្រលឹងខ្ញុំរីករាយ នៅក្នុងបទគម្ពីរទាំងឡាយ ឯចិត្តខ្ញុំពិចារណាអំពីបទគម្ពីរទាំងនោះ...។ មើលចុះ ព្រលឹងខ្ញុំរីករាយ ចំពោះកិច្ចការទាំងឡាយរបស់ព្រះអម្ចាស់ ហើយចិត្តខ្ញុំ ពិចារណាជារៀងរហូត អំពីហេតុការណ៍ ដែលខ្ញុំបានឃើញ ហើយបានឮជានិច្ច” (នីហ្វៃទី 2 4:15–16)។

### ការសិក្សាព្រះគម្ពីរ

**តើចំណេះវិជ្ជាជួយក្នុងការធ្វើ កិច្ចការព្រះអម្ចាស់ យ៉ាងដូចម្ដេច?**

| | |
|---|---|
| អាលម៉ា 17:2–3 | គ និង ស 88:77–80 |

**តើអ្នកអាចទទួលបានចំណេះវិជ្ជាយ៉ាងដូចម្ដេច?**

| | | |
|---|---|---|
| នីហ្វៃទី 2 32:1–5 | គ និង ស 42:61 | គ និង ស 88:118 |
| ម៉ូរ៉ូណៃ 10:5 | គ និង ស 76:5–10 | Guide to the Scriptures, “Knowledge” |

កំណត់ចំណាំ

## ការអត់ធ្មត់

ការអត់ធ្មត់ គឺជាសមត្ថភាពដើម្បីតស៊ូនឹងការពន្យាពេល បញ្ហា ការជំទាស់ ឬការធ្វើឈឺចាប់ដោយគ្មានកំហឹង ការស្មុគស្មាញ ឬការមានចិត្តអន្ទះសារ។ វាគឺជា សមត្ថភាពដើម្បីធ្វើតាមឆន្ទៈរបស់ព្រះ និងទទួលស្គាល់ ពេលវេលារបស់ទ្រង់។ ពេលដែលអ្នកមានចិត្តអត់ធ្មត់ អ្នកស៊ូទ្រាំ នឹងការសាកល្បងទាំងឡាយដែលមានមកលើអ្នក ទុក្ខវេទនាដោយស្ងាត់ស្ងៀម និងមានសេចក្តីសង្ឃឹម។ ការអត់ធ្មត់ គឺមានទំនាក់ ទំនងនឹងសេចក្តីសង្ឃឹម និងសេចក្តីជំនឿ—អ្នកត្រូវតែរង់ចាំ ពរជ័យរបស់ព្រះអម្ចាស់ដែលបានសន្យា ដើម្បីបំពេញ។

អ្នកត្រូវមានចិត្តអត់ធ្មត់នៅក្នុងបទពិសោធន៍ជារៀងរាល់ថ្ងៃ និងការទំនាក់ទំនងរបស់អ្នក ជាពិសេសជាមួយនឹងដៃគូរបស់អ្នក។ អ្នកត្រូវមានចិត្តអត់ធ្មត់ ជាមួយនឹងមនុស្សទាំងអស់ បូករួមទាំងខ្លួនរបស់អ្នក នៅពេលដែលអ្នកធ្វើការ ដើម្បីយកឈ្នះលើ គុណវិប្បត្តិ និងភាពទន់ខ្សោយនោះ។

> *"ជីវិតគឺពោរពេញទៅដោយការលំបាក ខ្លះមានបន្តិចបន្តួច ឯអ្នកខ្លះទៀតមានសភាពធ្ងន់ធ្ងរ។ វាហាក់ដូចជាគ្មាន ទីបញ្ចប់នៃការប្រឈមមុខរបស់មនុស្សទាំងអស់សោះ។ បញ្ហារបស់យើង គឺថា យើងតែងតែសង្ឃឹមលើដំណោះស្រាយកើតឡើង ភ្លាមៗ ចំពោះការប្រឈមមុខ ការភ្លេចដែលជាញឹកញាប់ថា គុណធមិស្ថគានៃការអត់ធ្មត់ ដែលត្រូវឱ្យមាន។"*
>
> — ប្រធាន ថូមាស អេស៍ មនសុន
> "PATIENCE—A HEAVENLY VIRTUE," *ENSIGN,* ខែវិច្ឆិកា ឆ្នាំ 1995, 59

### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

- សិក្សាម៉ូសាយ 28:1–9។ តើបុត្រានៃម៉ូសាយ មានបំណងប្រាថ្នាអ្វី?
- តើដំបូន្មានរបស់ព្រះអម្ចាស់ ចំពោះអ្នកផ្សព្វផ្សាយសាសនាទាំងនោះ គឺជាអ្វី? (សូមមើល អាលម៉ា 17:10–11 និង 26:27)។
- តើលទ្ធផល នៃការអត់ធ្មត់ និងការព្យាយាមរបស់ពួកគេមានអ្វីខ្លះ? (សូមមើល អាលម៉ា 26)។
- សរសេរចំលើយនៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក។

### ការសិក្សាព្រះគម្ពីរ

**តើហេតុអ្វី បានជាការអត់ធ្មត់ សំខាន់? តើការអត់ធ្មត់ និងសេចក្តីជំនឿ មានទំនាក់ទំនងគ្នា យ៉ាងដូចម្តេច?**

| | | |
|---|---|---|
| ម៉ូសាយ 23:21 | អាលម៉ា 34:40–41 | កូរិនថូសទី2 6:1–10 |
| ម៉ូសាយ 24:9–16 | គ និង ស 101:38 | យ៉ាកុប 5:10–11 |
| អាលម៉ា 31:31 | រ៉ូម 5:3–5 | ទំនុកដំកើង 46:10 |
| អាលម៉ា 32:41–43 | រ៉ូម 8:24–25 | Guide to the Scriptures, "Patience" |

## ការបន្ទាបខ្លួន



ការបន្ទាបខ្លួន គឺជាឆន្ទៈដើម្បីចុះចូលនឹងឆន្ទៈនៃព្រះអម្ចាស់ និងថ្វាយការគោរពដល់ព្រះអម្ចាស់សំរាប់អ្វីដែលបានសំរេច។ វាបូករួមទាំងអំណរគុណសំរាប់ពរជ័យរបស់ទ្រង់ និងការទទួលស្គាល់សេចក្តីត្រូវការចាំបាច់របស់អ្នក សំរាប់ជំនួយដ៏ទេវភាព របស់ទ្រង់។ ការបន្ទាបខ្លួន គឺមិនមែនជាសញ្ញានៃភាពទន់ខ្សោយទេ វាគឺជានិមិត្តរូបនៃកំលាំងខាងវិញ្ញាណ។ ពេលដែលអ្នក បន្ទាបខ្លួន ទុកចិត្តលើទ្រង់ និងស្គាល់ពីអំណាច និងសេចក្តីមេត្តាករុណារបស់ទ្រង់ អ្នកអាចមានការអះអាងថា ព្រះបញ្ញត្តិរបស់ទ្រង់ គឺសំរាប់សេចក្តីល្អរបស់អ្នក។ អ្នកទុកចិត្តថា អ្នកអាចធ្វើអ្វីៗបានទាំងអស់ ដែលព្រះអម្ចាស់តំរូវឱ្យអ្នកធ្វើ បើអ្នកពឹងផ្អែកទៅលើទ្រង់។ អ្នកក៏ត្រូវមានឆន្ទៈ ដើម្បីទុកចិត្តលើអ្នកបំរើដែលទ្រង់ជ្រើសរើស និងធ្វើតាមដំបូន្មានរបស់ពួកគេផងដែរ។ ការបន្ទាបខ្លួន នឹងជួយអ្នក ពេលដែលអ្នកព្យាយាមដើម្បីគោរពប្រតិបត្តិ ដោយឧស្សាហ៍ និងមិនបំរើខ្លួនឯង។

ពាក្យផ្ទុយនៃការបន្ទាបខ្លួន គឺភាពឆ្មើងឆ្មៃ ដែលត្រូវបានដាក់ទោសនៅក្នុងព្រះគម្ពីរ។ ដើម្បីមានភាពឆ្មើងឆ្មៃមានន័យថា ដាក់ការទុកចិត្តលើមនុស្ស ច្រើន

កំណត់ចំណាំ

ជាងព្រះ និងអ្នកបំរើរបស់ទ្រង់។ វាក៏មានន័យផងដែរថា ជាការទុកកិច្ចការនៃលោកិយ ពីលើកិច្ចការរបស់ព្រះ។ មនុស្សដែលមានភាពឆ្មើងឆ្មៃ ផ្ដល់កិត្តិយសឱ្យខ្លួនឯង ជាជាងថ្វាយដល់ព្រះនូវភាពរុងរឿង។ ភាពឆ្មើងឆ្មៃ គឺជាការប្រកួតប្រជែង អ្នកណាដែលពោរពេញដោយភាពឆ្មើងឆ្មៃ រិតតែស្វែងរកភាពឆ្មើងឆ្មៃបន្ថែមទៀត ហើយស្មានថា ខ្លួនគេប្រសើរ ជាងអ្នកដទៃ។ ភាពឆ្មើងឆ្មៃ តែងតែ កើតមកពីអារម្មណ៍នៃកំហឹង ការស្អប់ ហើយវាជាជំពប់ដ៏ធំ។

## ការសិក្សាព្រះគម្ពីរ

**តើការបន្ទាបខ្លួន មានអត្ថន័យយ៉ាងដូចម្ដេច?**

| | | |
|---|---|---|
| នីហ្វៃទី 2 9៖28–29 | អាលម៉ា 5៖26–29 | ម៉ាថាយ 26៖39 |
| ម៉ូសាយ 4៖11–12 | អាលម៉ា 26៖12 | Guide to the Scriptures, "Humble, Humility" |

**តើអ្នកទទួលពរជ័យអ្វីខ្លះ ពេលដែលអ្នកបន្ទាបខ្លួន?**

| | | |
|---|---|---|
| អាលម៉ា 32៖1–16 | គ និង ស 67៖10 | ម៉ាថាយ 23៖12 |
| អេធើរ 12៖27 | គ និង ស 112៖10 | |
| គ និង ស 12៖8 | គ និង ស 136៖32–33 | |

**តើអ្នកអាចស្គាល់ភាពឆ្មើងឆ្មៃនៅក្នុងខ្លួនរបស់អ្នក យ៉ាងដូចម្ដេច?**

| | | |
|---|---|---|
| នីហ្វៃទី 1 15៖7–11 | ធីម៉ូថេទី2 3៖1–4 | សុភាសិត 15៖10 |
| នីហ្វៃទី 1 16៖1–3 | សុភាសិត 13៖10 | សុភាសិត 28៖25 |

## ការឧស្សាហ៍ព្យាយាម

ការឧស្សាហ៍ព្យាយាមគឺជា ការខិតខំប្រឹងប្រែងដែលខ្ជាប់ខ្ជួន ជាប់ជានិច្ច ស្មោះអស់ពីចិត្ត និងស្វាហាប់ ក្នុងការធ្វើកិច្ចការ របស់ព្រះអម្ចាស់។ ព្រះអម្ចាស់ចង់ឱ្យអ្នកធ្វើកិច្ចការដោយឧស្សាហ៍ព្យាយាម—ដោយការមិនចុះចាញ់ និងការដោយខិតខំប្រឹង ប្រែង និងការយកចិត្តទុកដាក់ដ៏ខ្លាំងក្លា។ អ្នកផ្សព្វផ្សាយសាសនាដែលឧស្សាហ៍ព្យាយាម ធ្វើកិច្ចការដោយមានប្រសិទ្ធិភាព និងសមត្ថភាព។ ការឧស្សាហ៍ព្យាយាមក្នុងកិច្ចការអ្នកផ្សព្វផ្សាយសាសនា គឺជាការបង្ហាញនៃសេចក្ដីស្រលាញ់របស់អ្នកចំពោះ ព្រះអម្ចាស់ និងកិច្ចការរបស់ទ្រង់។ ពេលដែលអ្នកឧស្សាហ៍ព្យាយាម អ្នកនឹងមានសេចក្ដីអំណរ ហើយការពេញចិត្តនៅក្នុងកិច្ចការ របស់អ្នក។

> *"ខ្ញុំតែងតែនិយាយថាៈ រឿងសង្ងាត់ដ៏ធំបំផុតមួយនៃកិច្ចការអ្នកផ្សព្វផ្សាយសាសនា គឺធ្វើការ! បើអ្នកផ្សព្វផ្សាយសាសនាធ្វើការ នោះ គាត់នឹងទទួលបានព្រះវិញ្ញាណ បើគាត់ទទួលបានព្រះវិញ្ញាណ គាត់នឹងបង្រៀនដោយព្រះវិញ្ញាណ គាត់នឹងប៉ះដួងចិត្តមនុស្សជា ច្រើន ហើយគាត់នឹងសប្បាយ។ ហេតុនោះហើយ វានឹងគ្មានការនឹកផ្ទះ គ្មានការព្រួយបារម្ភអំពីគ្រួសារ ត្បិតពេលវេលា និងទេពកោសល្យ និងចំណាប់អារម្មណ៍ទាំងអស់ គឺជាចំណុចចំបងនៃកិច្ចការបំរើ។ ធ្វើការ ធ្វើការ ធ្វើការ—វាគ្មានការ ជំនួសណា ដែលគ្រប់គ្រាន់ជាងនេះទេ ជាពិសេសនៅក្នុងកិច្ចការអ្នកផ្សព្វផ្សាយសាសនា។*
>
> — ប្រធាន អែសរ៉ា ថាហ្វ បែនសឹន
> THE TEACHINGS OF EZRA TAFT BENSON (1988), 200

ចូរធ្វើអំពើល្អឱ្យបានច្រើន ដោយចេញពីឆន្ទៈរបស់អ្នក (សូមមើល គ និង ស 58៖27)។ ចូរកុំរង់ចាំអ្នកដឹកនាំរបស់អ្នកប្រាប់អ្នក អំពីអ្វី ដែលត្រូវធ្វើ។ ចូរបន្តរហូតដល់អ្នកធ្វើបានសំរេចអ្វីដែលអ្នកអាចធ្វើបាន ទោះបីជានៅពេលអ្នកអស់កំលាំងក៏ដោយ។ ត្រូវយកចិត្តទុកដាក់ អ្វីដែលសំខាន់បំផុត និងជៀសវាងពីការចំណាយពេលឥតប្រយោជន៍។ អធិស្ឋានសំរាប់ការណែនាំ និងកំលាំង។ រៀបផែនការឱ្យបានច្បាស់លាស់ និងមានប្រសិទ្ធិភាព។ ជៀសវាងអ្វីៗ ដែលធ្វើឱ្យខូចគំនិត ឬសកម្មភាពរបស់អ្នក។

កំណត់ចំណាំ

### ការសិក្សាព្រះគម្ពីរ

**តើការឧស្សាហ៍ព្យាយាមមានអត្ថន័យ យ៉ាងដូចម្តេច?**

ម័រ៉ូណៃ 9:6
គ និង ស 10:4
គ និង ស 107:99–100
Guide to the Scriptures, "Diligence"

**តើហេតុអ្វីបានជាព្រះអម្ចាស់ចង់ឱ្យអ្នកឧស្សាហ៍?**

គ និង ស 75:2–5
គ និង ស 123:12–14
គ និង ស 127:4
គ និង ស 130:20–21

**តើការឧស្សាហ៍ព្យាយាមមានទំនាក់ទំនងយ៉ាងដូចម្តេច ជាមួយនឹងសេរីភាព?**

ម៉ូសាយ 4:26–27
គ និង ស 58:26–29

## ការគោរពប្រតិបត្តិ

ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ អ្នកត្រូវបានរំពឹងទុកថា រក្សាព្រះបញ្ញត្តិដោយពេញចិត្ត គោរពតាមច្បាប់ បេសកកម្ម និងធ្វើតាមដំបូន្មាននៃអ្នកដឹកនាំរបស់អ្នក។ ការគោរពប្រតិបត្តិ គឺជាក្រិត្យវិន័យទីមួយនៃស្ថានសួគ៌។ វាគឺជា សកម្មភាព នៃសេចក្តីជំនឿ។ ពេលខ្លះអ្នកអាចបានតំរូវឱ្យធ្វើអ្វីមួយ ដែលអ្នកមិនយល់ទាល់តែសោះ។ ពេលដែលអ្នក គោរពប្រតិបត្តិ នោះអ្នករីកចំរើនក្នុង សេចក្តីជំនឿ ចំណេះវិជ្ជា ប្រាជ្ញា សក្ខីភាព ការការពារ និងសេរីភាព។ ចូរព្យាយាមដើម្បីគោរព ប្រតិបត្តិព្រះអម្ចាស់ ព្យាការ និងប្រធានបេសកកម្មរបស់អ្នក។

> *"វិន័យមានទូវការគោរពប្រតិបត្តិប្រចាំថ្ងៃ និងការរស់នៅស្អាតស្អំ ហើយការរស់ត្រឹមត្រូវ បានសាងឡើងនូវ គ្រឿងសឹកមួយ និងផ្តល់សុវត្ថិភាពពីការល្បួង ដែលព័ទ្ធជុំវិញអ្នក ពេលដែលអ្នកនៅក្នុងជីវិតដែលរមែងស្លាប់នេះ។"*
>
> — អែលឌើរ អិល ថូម ផែរី
> "CALLED TO SERVE," *ENSIGN*, ខែឧសភា 1991, 39

### ការសិក្សាព្រះគម្ពីរ

**តើការគោរពប្រតិបត្តិមានអត្ថន័យ យ៉ាងដូចម្តេច?**

នីហ្វៃទី 1 2:3
ម៉ូសាយ 5:8
ម៉ូសាយ 15:7
គ និង ស 82:8–10
ម៉ាថាយ 7:24–27
យ៉ូហាន 7:17
យ៉ូហាន 14:15
Guide to the Scriptures, "Obedience, Obedient, Obey"

**តើអ្នកអាចរៀនអ្វីខ្លះ អំពីការគោរពប្រតិបត្តិចេញពីព្រះគម្ពីរទាំងនេះ?**

នីហ្វៃទី 1 3:7
គ និង ស 105:6
ពង្សាវតាក្សត្រទី2 5:1–14

**ហេតុអ្វីអ្នកចម្បាំងក្មេងនៅក្នុងកងទ័ពរបស់ហេលេមិន គោរពប្រតិបត្តិ ដោយត្រឹមត្រូវដូច្នេះ? តើពួកគេទទួលពរជ័យ យ៉ាងដូចម្តេច?**

អាលម៉ា 56:45–48
អាលម៉ា 57:21–27

## ការអភិវឌ្ឍន៍លក្ខណៈដូចជាព្រះគ្រីស្ទ

នៅពេលដែលអ្នកសិក្សា និងចង់អភិវឌ្ឍន៍លក្ខណៈដូចជាព្រះគ្រីស្ទ ដែលបានពិពណ៌នានៅក្នុងជំពូកនេះ និងលក្ខណៈផ្សេងទៀតដែលបានរកឃើញនៅក្នុងព្រះគម្ពីរ គំរូខាងក្រោមអាចជាជំនួយដ៏ប្រសើរ

- បញ្ជាក់ពីលក្ខណៈដែលអ្នកចង់អភិវឌ្ឍន៍។
- សរសេរពីនិយមន័យ និងការពិពណ៌នានៃបុគ្គលិកលក្ខណៈ។

- កត់ត្រាសំនួរដើម្បីឆ្លើយនៅពេលដែលអ្នកសិក្សា។
- សរសេរ និងសិក្សាតាមរយៈសារលិខិតនៃព្រះគម្ពីរ ដែលបង្រៀនអំពីលក្ខណៈនោះ។
- សរសេរពីអារម្មណ៍ និងការបង្ហាញរបស់អ្នក។
- ដាក់គោលដៅ និងធ្វើផែនការដើម្បីអនុវត្តលក្ខណៈនោះ នៅក្នុងជីវិតរបស់អ្នក។
- អធិស្ឋាន សុំពីព្រះអម្ចាស់ឱ្យជួយអ្នកអភិវឌ្ឍន៍លក្ខណៈនោះ។
- វាយតំលៃទៅលើការកំណត់ពេលរីកចំរើនរបស់អ្នក នៅក្នុងការអភិវឌ្ឍន៍លក្ខណៈនីមួយៗ។

## សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

បញ្ជាក់ពីលក្ខណៈមួយចេញពីជំពូកនេះ ឬចេញពីព្រះគម្ពីរ។ ធ្វើតាមគំរូដែលបានរកឃើញមកពីខាងលើ ដើម្បីយល់បានកាន់តែប្រសើរ និងរៀបផែនការសំរាប់អភិវឌ្ឍន៍លក្ខណៈនោះ។




ចូរមើលទៅលើរូបភាពនៃផ្លាកឈ្មោះ។ តើផ្លាកឈ្មោះរបស់អ្នកខុសពីផ្លាកឈ្មោះរបស់និយោជិកក្នុងក្រុមហ៊ុន ដោយរបៀបណា? ចូរចំណាំថា ផ្នែកពីរសំខាន់បំផុតដែលលេចធ្លោគឺ ឈ្មោះរបស់អ្នក និងព្រះនាមរបស់ព្រះអង្គសង្គ្រោះ។ តើអ្នកអាច អះអាងថា អ្នកជាអ្នកតំណាងរបស់ព្រះអង្គសង្គ្រោះ ដូចជាកូនសិស្សម្នាក់របស់ទ្រង់ យ៉ាងដូចម្តេច? ហេតុអ្វីបានជាវា សំខាន់សំរាប់មនុស្ស ដើម្បីប្រដូចឈ្មោះរបស់អ្នក ជាមួយនឹងព្រះនាមរបស់ព្រះអង្គសង្គ្រោះ ក្នុងរបៀបដ៏វិជ្ជមានដូច្នោះ? សរសេរគំនិតរបស់អ្នក នៅក្នុងសៀវភៅសិក្សារបស់អ្នក។

## ការសិក្សាព្រះគម្ពីរ

**តើលក្ខណៈអ្វីខ្លះដែលបានសរសេរនៅក្នុងព្រះគម្ពីរ?**

| | | |
|---|---|---|
| ម៉ូសាយ 3:19 | គ និង ស 121:41–45 | ពេត្រុសទី 2 1:5–8 |
| អាលម៉ា 7:23 | មាត្រានៃសេចក្តីជំនឿ 1:13 | |
| គ និង ស 4 | ភីលីព 4:8 | |

## ចូរស្វែងចងចាំចំនុចនេះ

- អ្នកត្រូវធ្វើ *ជា* អ្នកផ្សព្វផ្សាយសាសនាដូចជាព្រះគ្រីស្ទ មិនត្រឹមតែធ្វើ កិច្ចការអ្នកផ្សព្វផ្សាយសាសនានោះទេ។
- ការរៀនដើម្បីធ្វើដូចជាព្រះគ្រីស្ទ គឺជាការប្រតិបត្តិពេញមួយជីវិត។
- អ្នកធ្វើតាមគំរូរបស់ព្រះគ្រីស្ទ—អភិវឌ្ឍន៍លក្ខណៈដូចជាទ្រង់—សកម្មភាព និងការសំរេចចិត្តមួយពេលតែម្តង។
- ការផ្លាស់ប្តូរដើម្បីប្រែក្លាយដូចជាព្រះគ្រីស្ទ—តំរូវឱ្យមានការអនុវត្តសេចក្តីជំនឿ ការប្រែចិត្ត ការរក្សាសេចក្តីសញ្ញា ការទទួល និងបង្កើនព្រះវិញ្ញាណបរិសុទ្ធ និងការស៊ូទ្រាំដល់ទីបំផុត។

កំណត់ចំណាំ

កំណត់ចំណាំ

# គំនិតសំរាប់សិក្សា និងសំរាប់អនុវត្ត

## ការសិក្សាផ្ទាល់ខ្លួន

- រៀបចំការនិយាយរយៈពេលប្រាំនាទី អំពីលក្ខណៈមួយនៅក្នុងចំណោមលក្ខណៈទាំងឡាយដែលបានពិភាក្សា នៅក្នុងជំពូកនេះ។
- ប្រើ Guide to the Scriptures ដើម្បីស្វែងរកវិធីដែលព្រះអង្គសង្គ្រោះបានលើកជាឧទាហរណ៍ពីលក្ខណៈ ដែលបានពិពណ៌នានៅក្នុងជំពូកនេះ។ សរសេរពីអ្វីដែលអ្នករៀន នៅក្នុងសៀវភៅសិក្សារបស់អ្នក។
- កំណត់បំពេញ "សកម្មភាពលក្ខណៈ" នៅចុងបញ្ចប់នៃជំពូកនេះ។
- កំណត់ការបញ្ជាក់លក្ខណៈមួយនៅក្នុងជំពូកនេះ។ សួរខ្លួនឯងថាៈ
  - តើខ្ញុំអាចអភិវឌ្ឍន៍លក្ខណៈនេះបានយ៉ាងដូចម្ដេច?
  - តើអ្វីដែលខ្ញុំត្រូវតែផ្លាស់ប្ដូរនៅក្នុងដួងចិត្ត គំនិតនិងសកម្មភាពរបស់ខ្ញុំ ដើម្បីអភិវឌ្ឍន៍លក្ខណៈនេះ?
  - តើការរក្សាសេចក្ដីសញ្ញា នឹងជួយខ្ញុំអភិវឌ្ឍន៍លក្ខណៈនេះ យ៉ាងដូចម្ដេច?
  - តើការអភិវឌ្ឍន៍លក្ខណៈនេះជួយខ្ញុំ មានភាពសក្ដិសមសំរាប់ព្រះវិញ្ញាណបរិសុទ្ធ និងប្រែក្លាយជាអ្នកបំរើនៃដំណឹងល្អនៃព្រះយេស៊ូវកាន់តែមានអំណាច យ៉ាងដូចម្ដេច?
- ស្វែងរកគំរូនៃលក្ខណៈដូចជាព្រះគ្រីស្ទ នៅក្នុងជីវិតនៃបុរស និងស្ត្រីនៅក្នុងព្រះគម្ពីរ។ សរសេរការចាប់អារម្មណ៍របស់ អ្នកនៅក្នុងសៀវភៅសិក្សារបស់អ្នក។

## ការសិក្សាជាមួយដៃគូ

- សិក្សាឯកសារយោងអំពីលក្ខណៈដូចជាព្រះគ្រីស្ទនៅក្នុងបណ្ណាល័យអ្នកផ្សព្វផ្សាយសាសនា។
- ពិភាក្សាអំពីទំនាក់ទំនងគ្នាក្នុងចំណោមលក្ខណៈខុសៗគ្នា។ ឧទាហរណ៍ៈ
  - តើសេចក្ដីជំនឿមានទំនាក់ទំនងនឹងការឧស្សាហ៍ព្យាយាម យ៉ាងដូចម្ដេច?
  - តើដែលការបន្ទាបខ្លួន និងសេចក្ដីស្រលាញ់ មានទំនាក់ទំនងគ្នាដោយរបៀបណាខ្លះ?
  - តើចំណេះវិជ្ជាពង្រឹងសេចក្ដីអត់ធ្មត់ យ៉ាងដូចម្ដេច?

## ការប្រជុំមណ្ឌល និងសន្និសីទហ្សូន

- រយៈពេលពីរបីថ្ងៃពីមុនការប្រជុំមណ្ឌល ឬសន្និសីទហ្សូន សូមសួរអ្នកផ្សព្វផ្សាយសាសនាម្នាក់ៗ ឱ្យជ្រើសរើសលក្ខណៈ មួយនៃលក្ខណៈទាំងនោះនៅក្នុងជំពូកនេះ ឬនៅក្នុងព្រះគម្ពីរ និងរៀបចំការនិយាយរយៈពេលប្រាំនាទីពីលក្ខណៈនោះ ដោយរួមទាំងព្រះគម្ពីរដែលបានជួយពួកគេ។

  ទុកពេលក្នុងការប្រជុំសំរាប់អ្នកផ្សព្វផ្សាយសាសនាពីរបីនាក់ចែកចាយការនិយាយរបស់គេ។

- ចែកពួកអ្នកផ្សព្វផ្សាយសាសនាចេញពីបីក្រុម ហើយចែកឱ្យពួកគេនូវកិច្ចការដូចខាងក្រោមៈ

  *ក្រុមទី 1ៈ* អានទីហ្វៃទី 1 17ៈ7–16 និងឆ្លើយសំនួរដូចខាងក្រោមៈ
  - តើនីហ្វៃបានអនុវត្តសេចក្ដីជំនឿរបស់គាត់ យ៉ាងដូចម្ដេចដែរ?
  - តើនីហ្វៃបានធ្វើអ្វីខ្លះ ដែលជាលក្ខណៈដូចជាព្រះគ្រីស្ទ?
  - តើការសន្យាអ្វីដែលព្រះអម្ចាស់ ធ្វើចំពោះនីហ្វៃ បើគាត់ស្មោះត្រង់ និងគោរពតាមព្រះបញ្ញត្តិ?
  - តើដំណើររឿងនេះ អាចអនុវត្តចំពោះកិច្ចការអ្នកផ្សព្វផ្សាយសាសនា យ៉ាងដូចម្ដេច?

  *ក្រុមទី 2 ៈ* អានយ៉ាកុប 7ៈ1–15 ហើយឆ្លើយសំនួរដូចខាងក្រោមៈ
  - តើហេតុអ្វីជំនឿរបស់យ៉ាកុបខ្លាំងល្មមគ្រប់គ្រាន់ ដើម្បីទប់ទល់នឹងការវាយប្រហាររបស់សេរេម?
  - តើយ៉ាកុបអនុវត្តសេចក្ដីជំនឿ យ៉ាងដូចម្ដេច ពេលដែលយ៉ាកុបនិយាយជាមួយសេរេម?
  - តើសកម្មភាពដូចជាព្រះគ្រីស្ទរបស់យ៉ាកុប យ៉ាងដូចម្ដេច?
  - តើយើងអាចធ្វើអ្វី ដើម្បីអភិវឌ្ឍន៍សេចក្ដីជំនឿដូចជាយ៉ាកុប?

កំណត់ចំណាំ

*ក្រុមទី 3 ៖* អានយ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:8–18 ហើយឆ្លើយសំនួរដូចខាងក្រោម៖
– តើក្នុងរបៀបអ្វីដែល យ៉ូសែប ស្ម៊ីធ បានអនុវត្តសេចក្ដីជំនឿទៅក្នុងព្រះគ្រីស្ទដោយរបៀបណាខ្លះ?
– តើសេចក្ដីជំនឿរបស់គាត់បានសាកល្បងយ៉ាងដូចម្ដេច?
– តើគាត់បានធ្វើអ្វីដែលជាលក្ខណៈដូចជាព្រះគ្រីស្ទឬទេ?
– តើយើងអាចធ្វើអ្វីខ្លះ ដើម្បីធ្វើតាមគំរូរបស់យ៉ូសែប ស្ម៊ីធ?

បន្ទាប់ពីក្រុមនីមួយៗបញ្ចប់ ប្រមូលអ្នកផ្សព្វផ្សាយសាសនាទាំងអស់រួមគ្នា ហើយសួរឱ្យពួកគេចែកចាយអំពីអ្វីដែលពួកគេបានពិភាក្សាគ្នា។

- ចែកចាយបទពិសោធន៍មួយ នៃគ្រាដែលអ្នកទទួលពរជ័យ និងទទួលការបំផុសគំនិត ដោយសេចក្ដីជំនឿរបស់មនុស្ស ដទៃទៀត។

- ឱ្យអ្នកផ្សព្វផ្សាយសាសនាយកតាម "សកម្មភាពនៃលក្ខណៈ"។ ឱ្យក្រដាសមួយសន្លឹក ដល់អ្នកផ្សព្វផ្សាយសាសនាម្នាក់ៗ ដើម្បីសរសេរចំលើយរបស់ពួកគេ។

  ពេលដែលពួកគេបានបំពេញលើក្រដាសកិច្ចការ ចូរអញ្ជើញពួកគេ ដោគោលដៅផ្ទាល់ខ្លួន។

  សួរអ្នកផ្សព្វផ្សាយសាសនាពីរបីនាក់ ដើម្បីចែកចាយពីអ្វីដែលពួកគេបានរៀន និងទទួលអារម្មណ៍ នៅពេលដែលពួកគេបានបំពេញក្រដាសកិច្ចការ។

  ចែកចាយសក្ខីភាពរបស់អ្នក ទាក់ទងនឹងសារៈសំខាន់នៃការអភិវឌ្ឍន៍ លក្ខណៈដូចជាព្រះគ្រីស្ទ។

## ប្រធានបេសកកម្ម

- សុំឱ្យអ្នកផ្សព្វផ្សាយសាសនាអាន ដំណឹងល្អមួយនៅក្នុងដំណឹងល្អទាំងបួន នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ឬនីហ្វៃទី 3 11–28។ ឱ្យពួកគេគូសបន្ទាត់ពីអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើ ដែលពួកគេអាចធ្វើបានផងដែរ។

- ប្រើប្រាស់គោលដៅនិងផែនការដែលបានដាក់ ដើម្បីបង្រៀនអ្នកផ្សព្វផ្សាយសាសនាអំពីការឧស្សាហ៍ព្យាយាម។ បង្ហាញពីការឧស្សាហ៍ព្យាយាមក្នុងរបៀបយកចិត្តទុកដាក់ទៅលើមនុស្ស គឺជាការបង្ហាញសេចក្ដីស្រលាញ់។

- នៅពេលធ្វើការសម្ភាសន៍ ចូរសួរអ្នកផ្សព្វផ្សាយសាសនា ឱ្យនិយាយអំពីលក្ខណៈដូចជាព្រះគ្រីស្ទ ដែលពួកគេព្យាយាម អភិវឌ្ឍន៍។

- នៅក្នុងសន្និសីទហ្សូន អញ្ជើញអ្នកផ្សព្វផ្សាយសាសនា ឱ្យប្រាប់អំពីលក្ខណៈដូចជាព្រះគ្រីស្ទ ដែលពួកគេកោតសរសើរ នៅក្នុងដៃគូរបស់គេទេ។

# សកម្មភាពកំណត់

អានរឿងរាវខាងក្រោមដោយយកចិត្តទុកដាក់។ សំរេចចិត្តថា តើសេចក្ដីថ្លែងនោះពិតយ៉ាងណាចំពោះអ្នក និងជ្រើសរើសការ ឆ្លើយតបដ៏សមរម្យបំផុតចេញពីគន្លឹះឆ្លើយតប។ សរសេរការឆ្លើយតបរបស់អ្នក ចំពោះរឿងរ៉ាវនីមួយៗ នៅក្នុង សៀវភៅសិក្សា របស់អ្នក។ ការរីកចំរើនខាងវិញ្ញាណ គឺជាការរីកចំរើនបន្តិចម្ដងៗ ហើយគ្មាននរណាម្នាក់ល្អឥតខ្ចោះនោះទេ ដូច្នេះ អ្នកគួរតែ សង្ឃឹមទុកដើម្បីធ្វើការវាយតំលៃខ្លួនរបស់អ្នក លើរឿងរាវខ្លះប្រសើរជាងរឿងរ៉ាវដទៃទៀត។

គន្លឹះឆ្លើយតប 1= មិនដែល 2= ពេលខ្លះ 3= ជាញឹកញាប់ 4= ស្ទើរតែជានិច្ចកាល 5= ជានិច្ច

## សេចក្ដីជំនឿ

____ 1. ខ្ញុំជឿលើព្រះគ្រីស្ទ និងទទួលស្គាល់ទ្រង់ជាព្រះអង្គសង្គ្រោះរបស់ខ្ញុំ។ (នីហ្វៃទី 2 25:29)

____ 2. ខ្ញុំមានអារម្មណ៍ទុកចិត្តថា ព្រះស្រលាញ់ខ្ញុំ។ (នីហ្វៃទី1 11:17)

____ 3. ខ្ញុំទុកចិត្តលើព្រះអង្គសង្គ្រោះគ្រប់គ្រាន់ល្មម ដើម្បីទទួលឆន្ទៈរបស់ទ្រង់ ហើយធ្វើអ្វីក៏ដោយដែលទ្រង់សុំធ្វើ។ (នីហ្វៃទី 1 3:7)។

____ 4. ខ្ញុំជឿជាក់យ៉ាងមុតមាំថា តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ខ្ញុំអាចទទួលការអភ័យទោសនៃអំពើបាបទាំងអស់របស់ខ្ញុំ។ (អេណុស 1:5–8)

____ 5. ខ្ញុំមានសេចក្ដីជំនឿក្នុងព្រះយេស៊ូវគ្រីស្ទល្មមគ្រប់គ្រាន់ ដើម្បីទទួលចំលើយចំពោះការអធិស្ឋានរបស់ខ្ញុំ។ (ម៉ូសាយ 27:14)

____ 6. ខ្ញុំគិតអំពីព្រះអង្គសង្គ្រោះនៅពេលថ្ងៃ និងចងចាំពីអ្វីដែលទ្រង់បានធ្វើសំរាប់ខ្ញុំ។ (គ និង ស 20:77, 79)

____ 7. ខ្ញុំមានជំនឿដែលចាំបាច់ដើម្បីជួយធ្វើឱ្យ សេចក្ដីល្អកើតឡើងនៅក្នុងជីវិតរបស់ខ្ញុំ ឬជីវិតរបស់អ្នកដទៃ។ (អេធើរ 12:12)

____ 8. ខ្ញុំដឹងដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធថា ព្រះគម្ពីរមរមន គឺពិត។ (មរ៉ូណៃ 10:3–5)

____ 9. ខ្ញុំមានជំនឿលើព្រះគ្រីស្ទគ្រប់គ្រាន់ល្មមដើម្បីសំរេចអ្វីៗ ដែលទ្រង់ចង់ឱ្យខ្ញុំធ្វើ—ទោះជាអព្ភូតហេតុ បើចាំបាច់។ (មរ៉ូណៃ 7:33)

## សេចក្ដីសង្ឃឹម

____ 10. សេចក្ដីប៉ងប្រាថ្នាដ៏ធំមួយនៃបំណងប្រាថ្នារបស់ខ្ញុំ គឺទទួលជីវិតដ៏អស់កល្បជានិច្ច នៅក្នុងនគរសេឡេស្ទាលនៃព្រះ។ (មរ៉ូណៃ 7:41)

____ 11. ខ្ញុំជឿជាក់ថា ខ្ញុំនឹងសប្បាយរីករាយ និងមានជោគជ័យក្នុងបេសកកម្ម។ (គ និង ស 31:3–5)

____ 12. ខ្ញុំមានអារម្មណ៍សុខសាន្ត និងសុទិដ្ឋិនិយមអំពីអនាគត។ (គ និង ស 59:23)

____ 13. ខ្ញុំជឿយ៉ាងមុតមាំថា នៅថ្ងៃណាមួយ ខ្ញុំនឹងរស់នៅជាមួយព្រះ និងប្រែក្លាយដូចជាទ្រង់។ (អេធើរ 12:4)

## សេចក្ដីសប្បុរស និងសេចក្ដីស្រលាញ់

____ 14. ខ្ញុំមានបំណងប្រាថ្នាដ៏ស្មោះសសំរាប់សុខុមាលភាពដ៏អស់កល្ប និងសុភមង្គលរបស់អ្នកដទៃ។ (ម៉ូសាយ 28:3)

____ 15. ពេលខ្ញុំអធិស្ឋាន ខ្ញុំបានសុំសំរាប់សេចក្ដីសប្បុរស—សេចក្ដីស្រលាញ់ដ៏សុទ្ធសាតនៃព្រះគ្រីស្ទ។ (មរ៉ូណៃ 7:47–48)

____ 16. ខ្ញុំព្យាយាមយល់ពីអារម្មណ៍របស់អ្នកដទៃ និងយល់ពីទស្សនៈរបស់ពួកគេ។ (យ៉ូស្វេ 1:22)

____ 17. ខ្ញុំអភ័យទោសដល់អ្នកដទៃ ដែលប្រមាថ ឬធ្វើខុសនឹង។ (អេភេសូរ 4:32)

____ 18. ខ្ញុំព្យាយាមដើម្បីជួយអ្នកដទៃ ពេលដែលពួកគេស្មុគស្មាញ ឬបាក់ទឹកចិត្ត។ (ម៉ូសាយ 18:9)

____ 19. ខ្ញុំប្រាប់អ្នកដទៃថា ខ្ញុំស្រលាញ់ពួកគេ និងខ្វល់អំពីពួកគេពេលដែលសមរម្យ។ (លូកា 7:12–15)

____ 20. ខ្ញុំស្វែងរកឱកាសដើម្បីបំរើអ្នកដទៃ។ (ម៉ូសាយ 2:17)

____ 21. ខ្ញុំនិយាយរឿងដែលវិជ្ជមានអំពីអ្នកដទៃ។ (គ និង ស 42:27)

____ 22. ខ្ញុំមានចិត្តល្អ ហើយចិត្តអត់ធ្មត់ជាមួយអ្នកដទៃ ទោះបីជាពេលដែលពួកគេចុះសម្រុងជាមួយក៏ដោយ។ (មរ៉ូណៃ 7:45)

____ 23. ខ្ញុំស្វែងរកសេចក្ដីអំណរ នៅក្នុងការសំរេចរបស់អ្នកដទៃ។ (អាលម៉ា 17:2–4)

## គុណធម៌

____ 24. ខ្ញុំជ្រះស្អាត និងបរិសុទ្ធនៅក្នុងដួងចិត្ត (ទំនុកដំកើង 24:3–4)

____ 25. ខ្ញុំគ្មានបំណងប្រាថ្នា ដើម្បីធ្វើអាក្រក់ តែធ្វើល្អ។ (ម៉ូសាយ 5:2)

____ 26. ខ្ញុំអាចទុកចិត្តបាន—ខ្ញុំធ្វើអ្វីដែលខ្ញុំនិយាយថា ខ្ញុំនឹងធ្វើ។ (អាលម៉ា 53:20)

____ 27. ខ្ញុំយកចិត្តទុកដាក់លើសេចក្ដីសុចរិត គំនិតលើកដំកើង និងដកគំនិតមិនសប្បាយចេញពីគំនិតរបស់ខ្ញុំ។ (គ និង ស 12:45)

____ 28. ខ្ញុំប្រែចិត្តពីអំពើបាបរបស់ខ្ញុំ និងព្យាយាមយកឈ្នះលើភាពទន់ខ្សោយរបស់ខ្ញុំ។ (គ និង ស 49:26–28)

____ 29. ខ្ញុំទទួលអារម្មណ៍ឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងជីវិតរបស់ខ្ញុំ។ (គ និង ស 11:12–13)

## ចំណេះវិជ្ជា

____ 30. ខ្ញុំមានអារម្មណ៍ទុកចិត្តនៅក្នុងការយល់ដឹងអំពីគោលលទ្ធិនៃដំណឹងល្អ និងគោលការណ៍ទាំងឡាយ។ (អេធើរ 3:19–20)

____ 31. ខ្ញុំសិក្សាព្រះគម្ពីរជារៀងរាល់ថ្ងៃ។ (យ៉ូហាន 5:39)

____ 32. ខ្ញុំយកចិត្តទុកដាក់លើការស្វែងយល់សេចក្ដីពិត និងស្វែងរកចំលើយចំពោះសំនួររបស់ខ្ញុំ។ (គ និង ស 6:7)

____ 33. ខ្ញុំទទួលចំណេះវិជ្ជា និងការណែនាំតាមរយៈព្រះវិញ្ញាណ។ (នីហ្វៃទី 1 4:6)

____ 34. ខ្ញុំស្រលាញ់ ហើយស្រលាញ់ជាទីបំផុត នូវគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អ។ (នីហ្វៃទី 2 4:15)

## ការអត់ធ្មត់

____ 35. ខ្ញុំរង់ចាំដោយមានចិត្តអត់ធ្មត់សំរាប់ពរជ័យ និងការសន្យានៃព្រះអម្ចាស់ ត្រូវបានបំពេញ។ (នីហ្វៃទី 2 10:17)

____ 36. ខ្ញុំអាចរង់ចាំរឿងអ្វីមួយដោយគ្មានការសោកសៅ និងមិនសប្បាយចិត្ត។ (រ៉ូម 8:25)

____ 37. ខ្ញុំអត់ធន់គ្រប់យ៉ាងដោយអំណរ ជាមួយនឹងការប្រឈមមុខនៃការធ្វើជាអ្នកផ្សព្វផ្សាយសាសនា។ (អាលម៉ា 17:11)

____ 38. ខ្ញុំអត់ធ្មត់ជាមួយនឹងកំហុស និងភាពទន់ខ្សោយរបស់អ្នកដទៃ។ (រ៉ូម 15:1)

____ 39. ខ្ញុំមានចិត្តអត់ធ្មត់ជាមួយនឹងខ្លួនរបស់ខ្ញុំ និងពឹងផ្អែកលើព្រះអម្ចាស់ ពេលដែលខ្ញុំខិតខំយកឈ្នះលើភាពទន់ខ្សោយរបស់ ខ្ញុំ។ (អេធើរ 12:27)

____ 40. ខ្ញុំប្រឈមមុខនឹងមារសត្រូវ និងទុក្ខវេទនាដោយស្ងប់ស្ងាត់ និងពោរពេញដោយសេចក្ដីសង្ឃឹម។ (អាលម៉ា 34:40–41)

## ការបន្ទាបខ្លួន

____ 41. ខ្ញុំស្លូតបូត ហើយមានចិត្តសុភាព។ (ម៉ាថាយ 11:29)

____ 42. ខ្ញុំពឹងផ្អែកលើព្រះអម្ចាស់សំរាប់ជំនួយ។ (អាលម៉ា 26:12)

____ 43. ខ្ញុំមានអំណរគុណសំរាប់ពរជ័យ ដែលខ្ញុំបានទទួលពីព្រះអម្ចាស់ ដោយស្មោះស។ (អាលម៉ា 7:23)

____ 44. ការអធិស្ឋានរបស់ខ្ញុំ គឺពិតប្រាកដ និងអស់ពីដួងចិត្ត។ (អេណុស 1:4)

____ 45. ខ្ញុំថ្លែងអំណរគុណសំរាប់ការណែនាំមកពីអ្នកដឹកនាំ និងគ្រូរបស់ខ្ញុំ។ (នីហ្វៃទី 2 9:28)

____ 46. ខ្ញុំព្យាយាមចុះចូលតាមឆន្ទៈរបស់ព្រះអម្ចាស់មិនថាអ្វីក៏ដោយ។ (ម៉ូសាយ 24:15))

## ការឧស្សាហ៍ព្យាយាម

____ 47. ខ្ញុំធ្វើការដោយមានប្រសិទ្ធិភាព ទោះបីជាខ្ញុំមិនស្ថិតនៅក្រោមការគៀបសង្កត់ ឬក្រោមការគ្រប់គ្រងតឹងរឹងក៏ដោយ។ (គ និង ស 58:26–27)

____ 48. ខ្ញុំផ្ដោតការខិតខំប្រឹងប្រែងរបស់ខ្ញុំ ទៅលើរឿងសំខាន់បំផុត។ (ម៉ាថាយ 23:23)

____ 49. ខ្ញុំមានការអធិស្ឋានផ្ទាល់ខ្លួន យ៉ាងតិចពីរដងក្នុងមួយថ្ងៃ។ (អាលម៉ា 34:18–27)

____ 50. ខ្ញុំផ្ចង់គំនិតរបស់ខ្ញុំលើមុខងារ ជាអ្នកផ្សព្វផ្សាយសាសនារបស់ខ្ញុំ។ (គ និង ស 4:2, 5)

____ 51. ខ្ញុំខំដាក់គោលដៅនិងរៀបផែនការជាទៀងទាត់។ (គ និង ស 88:119)

____ 52. ខ្ញុំធ្វើការយ៉ាងខ្លាំង រហូតដល់កិច្ចការត្រូវបានបំពេញដោយជោគជ័យ។ (គ និង ស 10:4)

____ 53. ខ្ញុំស្វែងរកសេចក្ដីអំណរ និងភាពពេញចិត្តនៅក្នុងកិច្ចការរបស់ខ្ញុំ។ (អាលម៉ា 36:24–25)

## ការគោរពប្រតិបត្តិ

____ 54. ពេលដែលខ្ញុំអធិស្ឋាន ខ្ញុំសូមសំរាប់កំលាំងដើម្បីតទល់នឹងការល្បួង និងដើម្បីធ្វើអ្វីដែលត្រូវ។ (នីហ្វៃទី 3 18:15)

____ 55. ខ្ញុំរក្សារាល់តំរូវការនៃព្រះបញ្ញត្តិ ដើម្បីមានភាពសក្ដិសមចំពោះបណ្ណ័ចូលព្រះវិហារបរិសុទ្ធ។ (គ និង ស 97:8)

____ 56. ខ្ញុំមានឆន្ទៈគោរពប្រតិបត្តិ តាមច្បាប់នៃបេសកកម្ម និងធ្វើតាមពាក្យដំបូន្មាននៃអ្នកដឹកនាំរបស់ខ្ញុំ។ (ហេព្រើរ 13:17)

____ 57. ខ្ញុំព្យាយាមដើម្បីរស់នៅ ស្របតាមច្បាប់ និងពិធីការទាំងឡាយនៃដំណឹងល្អ។ (គ និង ស 41:5)



# តើខ្ញុំអាចរៀនភាសាក្នុងបេសកកម្មរបស់ខ្ញុំ ឱ្យបានល្អដោយរបៀបណា?

កំណត់ចំណាំ

## ចូរពិចារណាចំណុចនេះ

- តើហេតុអ្វីបានជាខ្ញុំត្រូវតែកែលំអ សមត្ថភាពខាងភាសា ជាបន្តបន្ទាប់?
- តើខ្ញុំអាចកែលំអសមត្ថភាពដើម្បីនិយាយ និងបង្រៀនទៅក្នុងភាសាបេសកកម្មរបស់ខ្ញុំដោយរបៀបណា?
- តើខ្ញុំអាចទទួលអំណោយទានខាងភាសាដោយរបៀបណា?

## ចូររៀបចំខ្លួនអ្នកខាងវិញ្ញាណ

ព្រះអម្ចាស់បានប្រកាសថា មនុស្សគ្រប់រូបនឹងបានឮភាពពេញលេញនៃដំណឹងល្អ ដោយនូវអណ្ដាតរបស់ខ្លួន និងដោយភាសារបស់ខ្លួន តាមរយៈពួកអ្នកដែលត្រូវតែងតាំងចំពោះអំណាចនេះ (សូមមើល គ និង ស 90៖11)។ ចូរពង្រឹងទីបន្ទាល់របស់អ្នក ដើម្បី នាំអំណាច នៃការផ្លាស់ប្រែគំនិតចូលមកក្នុងពាក្យសំដីអ្នក។ ជាដំបូងអ្នកត្រូវសិក្សាគោលលទ្ធិ និងមេរៀនទាំងឡាយ នៅក្នុងភាសាកំណើត អ្នកជាមុនសិន។ ការយល់ដឹងទាំងអស់នោះនឹងពង្រឹងទីបន្ទាល់ និងសមត្ថភាពរបស់អ្នកក្នុងការបង្រៀន ហើយ ធ្វើទីបន្ទាល់ដោយជឿជាក់។ បន្ទាប់មកអ្នកអាចរៀន ដើម្បីបញ្ជាក់អំពីសារដំណឹងនៃ ការស្ដារឡើងវិញ នៅក្នុង ភាសា បេសកកម្មរបស់អ្នក នៅក្រោមការណែនាំពីព្រះវិញ្ញាណ។

បញ្ជីខាងក្រោមនេះជារបៀបដែលអ្នកអាចពង្រឹងសេចក្ដីជំនឿរបស់អ្នក ថាព្រះអម្ចាស់នឹងជួយអ្នកបង្រៀន ហើយនឹង ធ្វើទីបន្ទាល់នៅក្នុងភាសាបេសកកម្មរបស់អ្នក៖

- ចូរដឹងថាអ្នកត្រូវបានហៅបំរើដោយព្រះ តាមរយៈព្យាការីមួយរូប។
- រស់នៅដោយមានភាពសក្ដិសម ជាដៃគូនឹងព្រះវិញ្ញាណបរិសុទ្ធ។
- ត្រូវគោរពបទបញ្ញាត្តិ និងបទដ្ឋានទាំងឡាយនៃអ្នកផ្សព្វផ្សាយសាសនា។
- អធិស្ឋានដោយចិត្តស្មោះ សំរាប់ជំនួយទេវភាព។
- សិក្សា អនុវត្ត និងប្រើប្រាស់ភាសាបេសកកម្ម ជារៀងរាល់ថ្ងៃ។

រូបថត៖ GettImages.com ។ ហាមថតចំលង។

កំណត់ចំណាំ

## ចូរឧទ្ទិស និងឧស្សាហ៍ព្យាយាម

ការសិក្សា អំពីរបៀបបង្រៀន ដោយមានប្រសិទ្ធភាព នៅក្នុងភាសានៃបេសកកម្មរបស់អ្នក តម្រូវឱ្យមានការឧស្សាហ៍ព្យាយាម។ សូមកុំភ្ញាក់ផ្អើល បើសិនជាការងារហាក់ដូចជាពិបាក នាពេលដំបូង។ ការសិក្សាភាសា ត្រូវការពេលវេលា។ សូមមានចិត្តអំណត់ ចំពោះខ្លួនឯង។ សូមសុំជំនួយពីដៃគូអ្នក សមាជិក សាសនាគន់ការី និងអ្នកផ្សព្វផ្សាយសាសនាដទៃទៀត។

សូមកុំបញ្ឈប់ការកែលំអជំនាញ នៃភាសារបស់អ្នកឡើយ នៅពេលមនុស្សនឹងចាប់ផ្ដើមយល់អ្នកនិយាយ។ កាលដែលមានការរីកចំរើន ក្នុងសមត្ថភាព នៃការនិយាយហើយ មនុស្សនឹងស្ដាប់ច្រើន អំពីអ្វីដែលអ្នកនិយាយ ជាជាងអំពីរបៀប ដែលអ្នកនិយាយ។ អ្នកនឹងមិនសូវ មានការខ្វល់ខ្វាយច្រើនទៀតទេ ចំពោះរបៀបនៃការប្រាស្រ័យទាក់ទង អារម្មណ៍ដែលមាននៅក្នុង ដួងចិត្តអ្នក។ អ្នកនឹងអាចឆ្លើយតប បានប្រសើរជាងមុន ទៅតាមសេចក្ដីត្រូវការរបស់គន់ការី និងការបំផុសគំនិតនៃព្រះវិញ្ញាណ។

ខិតខំព្យាយាមរៀនភាសា ឱ្យចេះបានច្រើនក្នុងបេសកកម្មទាំងមូលរបស់អ្នក និងបន្ទាប់ពីអ្នកត្រឡប់ទៅផ្ទះវិញ។ ព្រះអម្ចាស់ បានប្រទានពរយ៉ាងសន្ធឹកសន្ធាប់ដល់អ្នក ហើយទ្រង់អាចនឹងប្រើសមត្ថភាពខាងភាសារបស់អ្នក នាពេលក្រោយទៀត នៃជីវិតរបស់អ្នក។ អែលឌើរ ជេហ្វ្រី អរ. ហូលេន បានពន្យល់ថា៖ “ យើង . . . សង្ឃឹមថា រាល់អ្នកផ្សព្វផ្សាយសាសនាគ្រប់រូប ដែលរៀនភាសាថ្មី ដើម្បីផ្សព្វផ្សាយនឹងចេះបានច្រើនដោយគ្រប់មធ្យោបាយទាំងអស់ . . .។ កាលដែលអ្នកធ្វើដូច្នោះ ការផ្សព្វផ្សាយ និងជំនាញនៃការធ្វើទីបន្ទាល់របស់អ្នកនឹងរីកចំរើន។ អ្នកនឹងត្រូវទទួលបានព្រះវិញ្ញាណ ប្រសើរជាងមុន និងមានព្រះវិញ្ញាណច្រើនជាងមុន ដែលនឹងធ្វើ ឱ្យគន់ការី របស់អ្នកដឹតជាប់ក្នុងអារម្មណ៍ . . .។ កុំគ្រាន់តែបំពេញចិត្តនូវអ្វី ដែលយើងហៅថា ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា ម្នាក់ប៉ុណ្ណោះ។ ព្យាយាមរៀនភាសាដោយអស់ពីសមត្ថភាព ហើយអ្នកនឹងអាចបាន ទំលុះចូលទៅក្នុងដួងចិត្ត របស់មនុស្សបាន កាន់តែប្រសើរ” (ការចាក់ផ្សាយតាមប្រព័ន្ធផ្កាយរណប អំពីអ្នកផ្សព្វផ្សាយសាសនា ខែសីហា ឆ្នាំ 1998)។

អ្នកមិនឯកកោទេ ក្នុងការរៀនភាសាបេសកកម្មរបស់អ្នក។ នៅពេលណាក៏ដោយដែលព្រះអម្ចាស់ បានបញ្ជា ទ្រង់នឹងរៀបចំផ្លូវដើម្បីឱ្យអាចសំរេច (សូមមើល នីហ្វៃ ទី1 3:7)។ សូមរកជំនួយពីទ្រង់។ សូមមានការលះបង់ ក្នុងការសិក្សារបស់អ្នក។ នៅពេលមួយអ្នកនឹងចេះជំនាញភាសា ដើម្បីបំពេញគោលបំណងរបស់អ្នក ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់។

## រៀនភាសាអង់គ្លេស

បើសិនជាអ្នកមិនចេះនិយាយភាសាអង់គ្លេសទេ អ្នកគួរតែរៀនវា ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់។ ការធ្វើដូច្នេះនឹង ផ្ដល់ពរជ័យក្នុងបេសកកម្មអ្នក និងពេញមួយជីវិតរបស់អ្នក។ ការសិក្សាភាសាអង់គ្លេសនឹង ធ្វើឱ្យអ្នកអាចជួយកសាងនគរ នៃព្រះអម្ចាស់នៅក្នុងរបៀបមួយទៀត ហើយនឹងក្លាយជាពរជ័យដល់អ្នក និងគ្រួសាររបស់អ្នក។ មានការផ្ដល់យោបល់ ជាច្រើនដែលអាចរកបាននៅក្នុងជំពូកនេះ ដែលនឹងជួយអ្នក។ សូមផ្ដោតការយកចិត្តទុកដាក់យ៉ាង ពិសេស ចំពោះចំណុចពិសេស ខាងក្រោមនេះ៖

- ដាក់គោលដៅ ថានឹងត្រូវនិយាយភាសាអង់គ្លេស ជាមួយនឹងដៃគូអ្នក។ បើសិនជាដៃគូអ្នក ចេះអង់គ្លេសហើយ ហើយព្យាយាម រៀនភាសារបស់អ្នក អ្នកអាចជ្រើសនិយាយភាសាអង់គ្លេស នៅក្នុងផ្ទះ ហើយនឹងនិយាយភាសាបេសកកម្ម ពេលដែលអ្នកទៅផ្សព្វផ្សាយ។
- ចូរអានព្រះគម្ពីរមរមនជាភាសាអង់គ្លេស ជាមួយនឹងដៃគូអ្នក។ អ្នកអាចជ្រើសដើម្បីអានឆ្លាស់គ្នាផងដែរ៖ អ្នកអានខ មួយជាភាសាអង់គ្លេស ហើយបន្ទាប់ដៃគូអ្នក មកអានខមួយទៀតនៅក្នុងភាសាបេសកកម្ម។ សូមជួយកែការបញ្ចេញសំលេង និងការលើកដាក់សំលេងគ្នាទៅវិញទៅមក។
- សូមសួរប្រធានបេសកកម្មរបស់អ្នក ឱ្យផ្ដល់យោបល់ អំពីវេយ្យាករណ៍ភាសាអង់គ្លេស បើសិនជាអ្នកមិនយល់។

## គោលការណ៍នៃការសិក្សាភាសា

ជំពូកនេះពិពណ៌នាអំពីគោលការណ៍នានា ដើម្បីជួយអ្នកឱ្យរៀន និងសិក្សាភាសាឱ្យកាន់តែប្រកបដោយប្រសិទ្ធភាពថែមទៀត។

- **ត្រូវមានការទទួលខុសត្រូវ។** ត្រូវបង្កើតឬ កែសម្រួលនូវជាទៀងទាត់ គោលដៅក្នុងការរៀនភាសា និងផែនការសិក្សារបស់អ្នក។ ព្យាយាមប្រើភាសានូវគ្រប់ឱកាសទាំងអស់។
- **ធ្វើឱ្យការសិក្សារបស់អ្នកពោរពេញដោយខ្លឹមសារ។** សួរខ្លួនឯងថា៖ តើហេតុអ្វីបានជាខ្ញុំរៀនវា? តើវានឹងជួយខ្ញុំដោយរបៀបណាដើម្បីឱ្យការទាក់ទងគ្នាបានកាន់តែប្រសើរឡើង? ចូរទាញពីអ្វីដែលអ្នករៀនផ្សារភ្ជាប់ទៅនឹងស្ថានភាពជីវិតផ្ទាល់ និង សកម្មភាពរាល់ថ្ងៃ។ សិក្សាផ្នែកខ្លះៗនៃភាសា ដែលនឹងជួយអ្នកឱ្យចេះនិយាយអ្វីដែលអ្នកចង់និយាយ។ ឧទាហរណ៍ បើសិនជា មានរឿងមួយក្នុងព្រះគម្ពីរដែលអ្នកចង់បញ្ចូលទៅក្នុងការបង្រៀនអ្នក ចូររៀនអំពី វាក្យស័ព្ទ និងវេយ្យាករណ៍ណា ដែលសំខាន់ៗ ដើម្បីជួយអ្នកផ្សារភ្ជាប់គ្នា។

កំណត់ចំណាំ

- **ស្វែងរកឱកាសប្រាស្រ័យទាក់ទង។** ស្វែងរកតុល្យភាពដ៏សមរម្យរវាង ការសិក្សាវេយ្យាករណ៍ និងអំពីសំណង់ប្រយោគ ខាងភាសា ហើយនឹងការសិក្សាទូវរាល់គ្រប់សកម្មភាពប្រចាំថ្ងៃ។ គ្មានទរណាជំនួសយើងបានទេ ពេលនិយាយជាមួយនឹងអ្នក និយាយភាសាដើម កំណើត។
- **ចូររៀនពីគំនិតថ្មីដោយហ្មត់ចត់។** អ្នកនឹងមានសមត្ថភាពអាចនឹកឃើញ និងប្រើគោលការណ៍នានានៃភាសា ប្រកបដោយប្រសិទ្ធភាព បើសិនជាអ្នករំឭកជាទៀងទាត់ ពីអ្វីដែលអ្នកបានសិក្សា ហើយបើសិនជាអ្នកអនុវត្តម្ដងទៀតនៅក្នុងស្ថានភាពថ្មី។

## ចូរបង្កើតផែនការសិក្សាភាសា

ផែនការសិក្សាភាសា ជួយទាំងអ្នកផ្សព្វផ្សាយសាសនា ដែលថ្មី និងដែលមានបទពិសោធន៍ហើយ ឱ្យផ្ដោតទៅលើអ្វីដែលពួកគេអាចធ្វើបាន ក្នុងថ្ងៃនីមួយៗ ដើម្បីកែលំអសមត្ថភាពរបស់ពួកគេ ក្នុងការនិយាយភាសាបេសកកម្ម។ ផែនការអ្នកនឹងរួមបញ្ចូល អ្វីដែលអ្នកនឹងធ្វើ ក្នុងអំឡុងពេលសិក្សាភាសា ហើយនឹងអ្វីដែលអ្នកនឹងធ្វើពេញមួយថ្ងៃ។

តាមសេចក្ដីត្រូវការ ប្រើពេលខ្លះនៃពេលរៀនភាសារបស់អ្នក យកទៅបង្កើត ឬកែសម្រួលផែនការនៃការសិក្សារបស់អ្នក។ បន្ទាប់មករៀងរាល់ព្រឹក អំឡុងពេលសិក្សាភាសា ចូររៀនភាសាដែលត្រូវការប្រើសំរាប់សកម្មភាពនៃថ្ងៃនោះ។ ការណែនាំ ខាងក្រោមនេះនឹងជួយអ្នកនៅក្នុងការបង្កើត ផែនការសិក្សាដោយខ្លួនឯងៈ

1. **ដាក់គោលដៅ។** គោលដៅប្រចាំសប្ដាហ៍ និងប្រចាំថ្ងៃ នឹងជួយអ្នករៀនភាសាបេសកកម្មរបស់អ្នក។ ផ្ដោតអារម្មណ៍ ទៅលើគោលដៅ នៅក្នុងការកែលំអសមត្ថភាព ដើម្បីទាក់ទង និងបង្រៀននៅក្នុងអំឡុងពេលសកម្មភាពដែលបានណាត់ជួប ដូចជាការបង្រៀនដែលបានណាត់ជាមុន ឱកាសសំរាប់ស្វែងរកសាសនទាគន់ការីថ្មី និងក្នុងការប្រជុំក្រុមប្រឹក្សាវួដ។ ត្រួតពិនិត្យមើលឡើងវិញអំពីការរីកចំរើន ក្នុងការសំរេចគោលដៅភាសារបស់អ្នក។ សួរខ្លួនឯង តើអ្នកអាចធ្វើអ្វីខ្លះដើម្បីឱ្យការទាក់ទងរឹតតែមានភាពច្បាស់លាស់ និងរឹត តែមានអំណាច នៅក្នុងសកម្មភាពដែលបានណាត់ទុក?
2. **ជ្រើសរើសឧបករណ៍ណាមួយដែលត្រូវប្រើ។** ពិនិត្យឡើងវិញពីឧបករណ៍ភាសាខាងក្រោមនេះ និងធ្វើការសំរេចចិត្ត ថាឧបករណ៍មួយណាដែលអ្នក អាចប្រើ ដើម្បីសំរេចគោលដៅរបស់អ្នកៈ




- បទដ្ឋានបទគម្ពីរ នៅក្នុងភាសាបេសកកម្មរបស់អ្នក។
- មេរៀននៅក្នុងភាសាបេសកកម្មរបស់អ្នក។
- សៀវភៅវចនានុក្រមដាក់ហោប៉ៅ។
- សៀវភៅវេយ្យាករណ៍តូចមួយ។
- ឯកសារភាសាបេសកកម្ម ពីមជ្ឈមណ្ឌលហ្វឹកហ្វឺនអ្នកផ្សព្វផ្សាយសាសនា។
- ក្រដាសសំរាប់កត់ចំណាំ។
- កូនសៀវភៅកត់ត្រាតូចមួយអាចដាក់ក្នុងហោប៉ៅបាន។
- ឯកសារសាសនាចក្រផ្សេងទៀត នៅក្នុងភាសាបេសកកម្ម។

3. **ទន្ទេញវាក្យស័ព្ទ និងឃ្លាខ្លះៗ។** ស្គាល់ វាក្យស័ព្ទ និងឃ្លាដែលនឹងជួយអ្នកសំរេចគោលដៅរបស់អ្នក។ ផែនការភាសារបស់អ្នកអាចរួមបញ្ចូលនូវគំនិតខាងក្រោមនេះៈ

- ស្គាល់វាក្យស័ព្ទ និងឃ្លានៅក្នុងមេរៀន កូនសៀវភៅតូចៗ ព្រះគម្ពីរ និងការបោះពុម្ពផ្សាយផ្សេងទៀតរបស់សាសនាចក្រដែលអ្នកអាចប្រើនៅក្នុងការបង្រៀន។
- កត់ពាក្យ ឬឃ្លាដែលអ្នកមិនស្គាល់ដាក់ក្នុងកូនសៀវភៅកំណត់ត្រារបស់អ្នក។ យកកូនសៀវភៅវចនានុក្រមតាមខ្លួន ហើយបើកមើលពាក្យទាំងអស់នេះ។
- យកក្រដាសតូចៗសំរាប់កត់ចំណាំ មករៀនពេញមួយថ្ងៃ។ សរសេរពាក្យ ឬឃ្លាមួយនៅមួយចំហៀង និងនិយមន័យ នៅមួយចំហៀងទៀត។ ទុកពាក្យដែលអ្នកចេះមួយអន្លើរសិន។ ប្រឹងរៀនពាក្យដែលនៅសល់រហូតអ្នកចេះពាក្យទាំងអស់នោះ។
- ប្រើពាក្យ និងឃ្លាថ្មី នៅក្នុងប្រយោគអំឡុងពេលសិក្សាផ្ទាល់ខ្លួន ការបង្រៀន និងជារៀងរាល់ថ្ងៃ។

កំណត់ចំណាំ

- អនុវត្តការបញ្ចេញសំលេង ដោយការនិយាយពាក្យ និងឃ្លាថ្មីៗឱ្យឮៗ។
- ទន្ទេញបទគម្ពីរដែលសំខាន់ៗនៅក្នុងភាសាបេសកកម្ម។
- ទន្ទេញសេចក្ដីថ្លែងការណ៍សាមញ្ញៗចេញពីមេរៀន ឬពីកូនសៀវភៅតូចៗ ដែលជាពាក្យគន្លឹះនាំទៅដល់ គោលការណ៍នៃដំណឹងល្អ។ ស្វែងរកវិធីផ្សេងទៀតដើម្បីបញ្ជាក់គំនិតទាំងនេះ។

4. **សិក្សាវេយ្យាករណ៍។** ប្រើឧបករណ៍ភាសា ដើម្បីស្គាល់គោលការណ៍នៃវេយ្យាករណ៍ ដែលអាចជួយអ្នកសំរេចគោលដៅរបស់អ្នក។ តាមសេចក្ដីត្រូវការ សួរដៃគូអ្នក អ្នកផ្សព្វផ្សាយសាសនាដែលមានបទពិសោធន៍ ឬក៏ជាសមាជិក ឱ្យជួយអ្នក។ ចូរគិតពិចារណា នៅក្នុងការរួមបញ្ចូលគំនិតមួយចំនួនដូចខាងក្រោមនេះៈ

- ប្រើអត្ថបទវេយ្យាករណ៍ ដែលអ្នកបានទទួលនៅឯមជ្ឈមណ្ឌលហ្វឹកហ្វឺនអ្នកផ្សព្វផ្សាយសាសនា ឬក៏អត្ថបទដែលបាន អនុម័តដោយប្រធានបេសកកម្មរបស់អ្នក ដើម្បីជួយអ្នកឱ្យយល់វេយ្យាករណ៍ និងគំរូនៃឃ្លាប្រយោគ ដែលមាននៅក្នុងមេរៀន កូនសៀវភៅតូចៗ និងព្រះគម្ពីរ។
- ចូររៀបចំឃ្លាប្រយោគ ដើម្បីប្រើនៅក្នុងសកម្មភាពបានណាត់ទុក ដែលអនុវត្តនូវគោលការណ៍វេយ្យាករណ៍ទាំងនេះ។ អនុវត្តការនិយាយ និងការសរសេរឃ្លាប្រយោគទាំងនោះ។
- ចូរយកចិត្តទុកដាក់ចំពោះលំដាប់លំដោយពាក្យ នៅក្នុងភាសា និងក្បួនខ្នាតរបស់វា។
- ចូរស្វែងរកឱកាស ដើម្បីអនុវត្ត និងប្រើក្បួនវេយ្យាករណ៍ ដែលអ្នករៀនជារៀងរាល់ថ្ងៃ។

5. **ចូរឧស្សាហ៍ស្ដាប់។** ចូរពិចារណា នៅក្នុងការរួមបញ្ចូលគំនិតដូចខាងក្រោមៈ

- ចូរស្ដាប់ដោយយកចិត្តទុកដាក់ ចំពោះជនជាតិនិយាយភាសាដើមកំណើត។ ត្រាប់សំលេងតាមដែលអ្នកឮ។
- នៅពេលដែលអ្នកឮ អ្វីមួយដែលអ្នកមិនយល់ សូមសរសេរវាទុក ហើយស្វែងយល់ថា តើវាមានន័យយ៉ាងដូចម្ដេច។ ត្រូវអនុវត្តដោយការប្រើវាក្យស័ព្ទ ឬទំរង់ឃ្លាប្រយោគគំរូ។
- ពេលស្ដាប់ ត្រូវស្គាល់វាក្យស័ព្ទ និងទំរង់គំរូ ដែលអ្នកទើបតែរៀនទាពេលថ្មីៗនេះ។
- ពេលដែលអ្នកឮឃ្លាមួយ ដែលបាននិយាយខុសពីអ្នក ចូរកត់វាទុក ហើយអនុវត្តតាមវា។ ទោះជា យ៉ាងណាក៏ដោយ ក្នុងនាមជាអ្នកបំរើរបស់ព្រះអម្ចាស់ អ្នកត្រូវតែប្រើភាសាសមរម្យជានិច្ច និងមិនត្រូវប្រើគ្រៀមភាសាទេ។
- ចូរធ្វើជាបញ្ជី ពាក្យមួយចំនួនដែលមនុស្សអាច នឹងនិយាយក្នុងអំឡុងពេលធ្វើសកម្មភាពដែលបានគ្រោងទុកមុន។ បើកមើលពាក្យ និងឃ្លាដែលទាក់ទងទៅនឹងការឆ្លើយតបទាំងនេះ។ រៀបចំគំរោង និងអនុវត្តពីរបៀបដែលអ្នកអាចឆ្លើយ តប។

6. **បង្កើនសមត្ថភាពខាងអាន និងសរសេរ។** អានព្រះគម្ពីរមរមន នៅក្នុងភាសាបេសកកម្មរបស់អ្នក ដើម្បីរៀនវាក្យស័ព្ទ និងឃ្លា និងដើម្បីអនុវត្តវេយ្យាករណ៍ ការបញ្ចេញសំលេង និងភាពស្ទាត់ជំនាញ។ មានអំណាចមួយដ៏អស្ចារ្យ ចំពោះការប្រើព្រះគម្ពីរ នៅក្នុងការសិក្សាភាសារបស់អ្នក។ ចូរពិចារណា នូវគំនិតដូចខាងក្រោមនេះផងដែរៈ

- រៀនអាន និងសរសេរព្យាង្គ អក្សរ ឬតួអក្សរនៃភាសារបស់អ្នក។ ពីព្រោះតួអក្សរ ផ្ដោតទៅលើប្រព័ន្ធ ក្នុងការសរសេរ ត្រូវផ្ដោតទៅលើជំនាញក្នុងការអាន ដូចជាការអានព្រះគម្ពីរ ដែលវានឹងជួយអ្នកពេលអ្នកទៅបង្រៀន។
- អានព្រះគម្ពីរមរមន និងព្រះគម្ពីរផ្សេងទៀត ឬជាទស្សនាវដ្ដីសាសនាចក្រឱ្យឮៗ នៅក្នុងភាសាបេសកកម្មរបស់អ្នក។ ចូរផ្ដោតការយកចិត្តទុកដាក់ទៅលើវាក្យស័ព្ទ ឃ្លា ហើយនឹងវេយ្យាករណ៍ ដែលអ្នកមិនធ្លាប់ស្គាល់។ បើសិនជាអ្នកមិនយល់ ពាក្យមួយ សូមព្យាយាមឱ្យយល់ពីអត្ថន័យរបស់វាពីអត្ថបទវាផ្ទាល់ ពីមុនអ្នកបើកវចនានុក្រមមើល។ បន្ថែមពាក្យទៀត ទៅក្នុង ក្រដាសតូចៗសំរាប់កត់ចំណាំរបស់អ្នក។ ចូរប្រើព្រះគម្ពីរ ភាសាកំណើត និងភាសាបេសកកម្ម ដាក់មើលទន្ទឹមគ្នា បើសិនវាចាំបាច់។
- សូមឱ្យនរណាម្នាក់ជួយកែតម្រូវអ្នក ពេលបញ្ចេញសំលេង ការលើកដាក់សំលេង និងផ្អាក ពេលអ្នកអាន។
- អនុវត្តការសរសេរនៅក្នុងភាសាបេសកកម្មរបស់អ្នក— ឧទាហរណ៍ កំណត់ត្រាផ្ទាល់ខ្លួន និងសំរាប់រំឮក សំបុត្រ លិខិតអរគុណ និងលិខិតលើកទឹកចិត្ត។ ចូរសរសេរទីបន្ទាល់អ្នក នៅក្នុងភាសាបេសកកម្ម ទៅក្នុងព្រះគម្ពីរមរមន ដែលអ្នកចែកចាយ។

កំណត់ចំណាំ

7. **សុំអ្នកដទៃឱ្យជួយអ្នក។** ចូរពិចារណារួមបញ្ចូល នូវគំនិតដូចខាងក្រោម៖



- បើសិនជាដៃគូអ្នកជាជនជាតិនិយាយភាសាដើមកំណើត ចូរទាញយកប្រយោជន៍ពីឱកាសដ៏ល្អនេះ ដោយការសួរសំណួរជាញយៗ និងស្វែងរកគំនិតច្រាស។
- សួរដៃគូអ្នក និងជនជាតិនិយាយភាសាដើមកំណើត ឱ្យកែអ្នក និងឱ្យផ្តល់គំនិតនូវរបៀប ទាំងឡាយដើម្បីកែលំអ។ បើសិនជាពួកគេ ប្រើពាក្យដែលអ្នកមិនយល់ សួរពួកគេឱ្យបកស្រាយឱ្យអ្នក។ ជាញឹកញាប់កុមារ និងជីដូនជីតា តែងតែចង់ជួយ ជានិច្ច។
- ចូរអញ្ជើញមនុស្សទាំងឡាយដែលអ្នកបង្រៀនឱ្យជួយអ្នក។ បកស្រាយថា " ខ្ញុំកំពុងរៀនភាសារបស់អ្នក។ សូមមេត្តាជួយខ្ញុំផង។ បើសិនជាខ្ញុំមានបញ្ហាក្នុងការ រកពាក្យមួយមកនិយាយមិនឃើញ សូមជួយខ្ញុំផង។"
- កុំរារែក ក្នុងការសុំជំនួយដ៏ជាក់លាក់មួយ៖ "តើពាក្យ ___________ អ្នកនិយាយយ៉ាងដូចម្តេច?" "តើពាក្យ ___________ អ្នក ត្រូវ បញ្ចេញសំលេងយ៉ាងណា?" "តើពាក្យ ___________ មានន័យយ៉ាងដូចម្តេច?" "តើអ្នកអាចនិយាយវាម្តងទៀតបានទេ?" សូម សរសេរចំលើយ និងសិក្សាពីវា។
- សុំសមាជិកឱ្យសួរសំណួរនៅលើក្រដាសតូចៗដែលអ្នកបានកត់ចំណាំ ឬពីបញ្ជីវាក្យស័ព្ទ ហើយដើម្បីជួយអ្នកអានព្រះគម្ពីរ ៗៗ។

8. **វាយតំលៃ និងកែសំរួលផែនការសិក្សារបស់អ្នក។** ត្រួតពិនិត្យផែនការសិក្សារបស់អ្នក ជារៀងរាល់សប្តាហ៍ ដើម្បី វាយតំលៃ ប្រសិនបើអាចជួយអ្នករៀនភាសានោះ។ អញ្ជើញដៃគូអ្នក និងអ្នកដឹកនាំបេសកកម្ម ឱ្យផ្តល់យោបល់ អំពីចំណុច ដែលត្រូវកែលំអ។

ប្រើភាសាបេសកកម្មរបស់អ្នកនូវគ្រប់ឱកាសទាំងអស់។ និយាយភាសានោះជាមួយនឹងដៃគូ ឱ្យបានច្រើនដែលអាចធ្វើទៅបាន ពេញមួយថ្ងៃ។ អធិស្ឋាននៅក្នុងភាសានោះ ទាំងជាលក្ខណៈបុគ្គល និងសាធារណៈ សំរាប់ជាការរៀន និយាយភាសាសមរម្យ ក្នុងការអធិស្ឋាន និងដើម្បីរៀននិយាយចេញពីអ្វីដែលមាននៅក្នុងចិត្តអ្នក។

ចូរកុំខ្លាចក្នុងការនិយាយទៅខុស។ មនុស្សម្នាក់ៗ ដែលរៀនភាសាថ្មី តែងតែមានកំហុសជានិច្ច។ មនុស្សនឹងយល់ ហើយពួកគេនឹងពេញចិត្តចំពោះការខិតខំប្រឹងប្រែងរបស់អ្នក ក្នុងការរៀននិយាយភាសារបស់ពួកគេ។ ការទន្ទេញឃ្លា និងព្រះគម្ពីរនឹងជួយអ្នក ជៀសវាង ពីការមានកំហុស ប៉ុន្តែអ្នកមិនគួរទន្ទេញឃ្លាប្រយោគយ៉ាងវែង ឬរៀបចំក្រដាសប្រយោគសំរាប់និយាយទេ ដោយគិតថាធ្វើដូច្នោះជា វិធីសំរាប់ជៀសវាង ពីកំហុស។

**សកម្មភាព៖ ការសិក្សាផ្ទាល់ខ្លួន**

ប្រើប្រាស់ការណែនាំដែលបានពិពណ៌នាខាងលើ ចូរបង្កើតផែនការសិក្សា។ ត្រួតពិនិត្យផែនការអ្នក ជាមួយដៃគូអ្នក ឬអ្នកដឹកនាំបេសកកម្ម។

## សិក្សាជាមួយនឹងដៃគូអ្នក

ជួយដៃគូអ្នកឱ្យទទួលបានជោគជ័យ ហើយ ទទួលបានការជឿជាក់ក្នុងការរៀនភាសា ឱ្យឆាប់ចេះ កាន់តែប្រសើរឡើង។ អ្នក ត្រូវសរសើរដៃគូអ្នក ដោយស្មោះត្រង់ និងជាញឹកញាប់ និងអ្នកផ្សព្វផ្សាយសាសនាដទៃទៀត ចំពោះការរីកចំរើនរបស់ពួកគេ។ ត្រូវមានគំនិតវិជ្ជមាន ដើម្បីមិននិយាយ ឬធ្វើអ្វីមួយ ដែលនឹងធ្វើឱ្យការជឿជាក់របស់ពួកគេធ្លាក់ចុះ ប៉ុន្តែចូរកុំការពារពួកគេ ខ្លាំងពេក រហូតធ្វើឱ្យពួកគេមិនរៀនពីកំហុសឆ្គងពួកគេ។ កុំធ្វើកន្តើយ នៅពេលគាត់ត្រូវការជំនួយ។ ត្រូវផ្តល់ឱកាសដល់ពួកគេ ឱ្យបានច្រើន សំរាប់បង្រៀន និងថ្លែងទីបន្ទាល់ ដោយមានជោគជ័យ។ ចូរគិតពិចារណាអំពីគំនិតខាងក្រោមនេះ សំរាប់ ជាការ សិក្សាស្រាវជ្រាវ ជាមួយនឹងដៃគូអ្នក៖

- បង្រៀនអ្នកដទៃអំពី វេយ្យាករណ៍ និងវាក្យស័ព្ទដែលអ្នកបានរៀន។

កំណត់ចំណាំ

- ហាត់បង្រៀនទៅក្នុងភាសាបេសកកម្ម។ នៅលើកដំបូង អ្នកផ្សព្វផ្សាយសាសនាថ្មីអាចនឹងបង្រៀន ដោយរបៀបយ៉ាងសាមញ្ញ ចែកចាយទីបន្ទាល់របៀបសាមញ្ញ និងសូត្រខគម្ពីរដែលបានទន្ទេញ។ ពេលដែលការជឿជាក់ និងសមត្ថភាព របស់ពួកគេ មានការរីកចំរើនហើយនោះ ពួកគេនឹងមានសមត្ថភាព ចូលរួមយ៉ាងពេញលេញ ក្នុងការបង្រៀនសាសនាទាគន់ការី។
- អនុវត្តប្រើភាសានោះ ដើម្បីធ្វើការប្រាស្រ័យទាក់ទង នៅក្នុងស្ថានភាពទូទៅរបស់អ្នកផ្សព្វផ្សាយសាសនា។
- ផ្តល់នូវគំនិតប្រាស់គ្នាទៅវិញទៅមកដើម្បីកែលំអ ដោយសណ្តានចិត្តល្អ។ វាជាការ សំខាន់ផងដែរ ដែលអ្នកអាចទទួលពាក្យ កែលំអ ដោយគ្មានការអាក់អន់ចិត្ត។

កត់សំគាល់អំពីរបៀបដែលអ្នកផ្សព្វផ្សាយសាសនាមានបទពិសោធន៍ ជួយដៃគូរបស់គាត់ តាមរឿងរ៉ាវពិតខាងក្រោមនេះ។

*ខ្ញុំទើបតែមកដល់តំបន់ទីពីរ នៅពេលដែលដៃគូខ្ញុំបានប្រាប់ខ្ញុំថាវា ជាវេនខ្ញុំដើម្បីផ្តល់គំនិតខាងវិញ្ញាណ សំរាប់ការ ណាត់ញ៉ាំអាហារពេលល្ងាច។ ខ្ញុំហាក់ដូចជាភ័យបន្តិច។ ដៃគូទីមួយរបស់ខ្ញុំ តែងតែរីករាយនឹងបង្រៀនជានិច្ច ហើយខ្ញុំធ្លាប់តែធ្វើ ចំណែកតូចមួយប៉ុណ្ណោះ ក្នុងការផ្តល់មេរៀន ហើយបន្ទាប់មកគឺអង្គុយស្តាប់ ហើយគាត់បរិយាយ និងឆ្លើយរាល់សំណួរ។*

*ខ្ញុំព្យាយាមលួងលោមទៅដៃគូខ្ញុំ ឱ្យផ្តល់គំនិតខាងវិញ្ញាណទៅ ប៉ុន្តែគាត់បានលើកទឹកចិត្តខ្ញុំឱ្យធ្វើវា។ ខ្ញុំបានហាត់ ដោយមានជំនួយពីគាត់។ ឱកាសនោះបានមកដល់ ខ្ញុំបានបើកព្រះគម្ពីរ ហើយអាន នីហ្វៃ ទី3 5 និង 7។ ខ្ញុំមានការលំបាក ប៉ុន្តែខ្ញុំបានតាំងអារម្មណ៍ ដើម្បីពន្យល់ពីមូលហេតុអ្វីបានជាខ្ញុំរើសយកសារដំណឹងនេះ ថាវាសំខាន់ ហើយខ្ញុំមានអារម្មណ៍ធូរស្បើយ នៅពេលខ្ញុំពន្យល់ ចប់។ នៅពេលមានសំណួរមួយបានសួរមក ខ្ញុំបានងាកទៅដៃគូខ្ញុំ ឱ្យឆ្លើយ ប៉ុន្តែគាត់មិនបើកមាត់សោះ។ នៅពេលនោះហើយ ដែលខ្ញុំ មានក្តីរំភើបចំពោះខ្លួនឯង ដោយបានផ្តល់ចំលើយ ដែលអាចយល់បានទៅក្នុងភាសាបារាំង។ ខ្ញុំរឹតតែមានក្តីរំភើបថែមទៀត នៅ ពេលដែល សមាជិកហាក់ដូចជា មិនដឹងថា ខ្ញុំគ្មានការទុកចិត្តលើខ្លួនឯងចំពោះជំនាញ នៃការប្រាស្រ័យទាក់ទងរបស់ខ្ញុំទេ។ ការ ជឿជាក់លើខ្លួនឯង របស់ខ្ញុំបានកើនឡើង ហើយខ្ញុំចាប់ផ្តើមយល់ថា ភាសាបារាំងរបស់ខ្ញុំ វាល្អជាងការគិតរបស់ខ្ញុំ។*

*ច្រើនសប្តាហ៍ក្រោយមកទៀត ហើយដៃគូខ្ញុំនៅតែឱ្យខ្ញុំបង្រៀន—សូម្បីតែខ្ញុំមិនគិតថាខ្ញុំអាចធ្វើបាន សូម្បី នៅពេលដែលគាត់មានការសង្ស័យថាតើខ្ញុំអាចធ្វើបានដែរឬទេ។ ហើយពីព្រោះតែគាត់បានលើកទឹកចិត្តខ្ញុំឱ្យនិយាយ ស្តាប់ និង បង្រៀន ជំនាញខាងភាសាខ្ញុំចាប់ផ្តើមរីកចំរើនយ៉ាងលឿន ហើយខ្ញុំមានអារម្មណ៍ថា ខ្ញុំក្លាយជាឧបករណ៍មួយនៅក្នុង ព្រះហស្ត របស់ព្រះវរបិតា ដែលគង់នៅឋានសួគ៌ មិនមែនគ្រាន់តែធ្វើជាដៃគូ ដ៏ស្ងាត់ស្ងៀមរបស់អែលឌើរម្នាក់នោះទេ។*

### សកម្មភាព: ការសិក្សាផ្ទាល់ខ្លួន ឬការសិក្សាជាមួយដៃគូ

- បើសិនជាអ្នកកំពុងតែធ្វើការជាមួយនឹងអ្នកផ្សព្វផ្សាយសាសនាថ្មី តើអ្នកអាចជួយដៃគូអ្នកឱ្យរៀនភាសា ឱ្យបានកាន់តែល្អប្រសើរឡើងដោយរបៀបណា?
- បើអ្នកជា ជាអ្នកផ្សព្វផ្សាយសាសនាថ្មី តើអ្នកអាចសុំជំនួយបែបណា ពីដៃគូច្បងរបស់អ្នក?

## សិក្សាអំពី វប្បធម៌ និងភាសា

វប្បធម៌ និងភាសា មានទំនាក់ទំនងយ៉ាងជិតនឹងគ្នា។ ការយល់អំពីវប្បធម៌ នឹងជួយពន្យល់ពីមូលហេតុដែលភាសាត្រូវបាន យកមកប្រើប្រាស់ តាមរបៀបជាភាសាមួយ។ ព្យាយាមយល់អំពីវប្បធម៌របស់ប្រជាជន ដូច្នេះអ្នកអាចប្រាស្រ័យ ទាក់ទងនៅក្នុងទិដ្ឋភាពតែមួយ នៃការស្តារឡើងវិញ នៅក្នុងវិធីមួយដែលធ្វើឱ្យពួកគេមានការយល់ដឹងយ៉ាងច្បាស់។

ចំណុចមួយដែលពិសេសជាងគេ ដែលអ្នកអាចធ្វើដើម្បីបង្កើនការទុកចិត្ត និងក្តីស្រឡាញ់ពីប្រជាជន គឺការគោរពវប្បធម៌របស់ពួកគេ នៅក្នុងរបៀបមួយដ៏សមរម្យ។ មានអ្នកផ្សព្វផ្សាយសាសនាល្អៗជាច្រើនបានធ្វើដូច្នោះ (សូមមើល កូរិនថូស ទី 1 9:20–23)។ ចូរធ្វើយ៉ាងណាឱ្យមនុស្សមានអារម្មណ៍រីករាយ ជាមួយអ្នក និងភាសារបស់អ្នក។

កំណត់ចំណាំ

### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន ឬការសិក្សាជាមួយដៃគូ

- ចូរស្រមៃថា អ្នកកំពុងបំរើបេសកកម្មនៅក្នុងតំបន់អាស៊ី។ អ្នកកំពុងត្រៀមខ្លួនបង្រៀនទរណាម្នាក់ អំពីការរស់ឡើងវិញ ហើយអ្នកដឹងថា សាសនាព្រះពុទ្ធ ជឿទៅលើការចាប់ជាតិជាថ្មី។ តើអ្នកនឹងបង្រៀនអំពីការរស់ឡើងវិញ ទៅសាសនាគន់ការីដែល យល់ថា គោលលទ្ធិនេះខុសប្លែកគ្នាយ៉ាងឆ្ងាយ ពីការចាប់ជាតិជាថ្មី ដោយរបៀបណាទៅ? តើពាក្យ ឬឃ្លាប្រយោគអ្វី ដែលអ្នកត្រូវការរៀន ដើម្បីសំរេចចំពោះកិច្ចការនេះ?

- ចូរគិតអំពី វប្បធម៌ និងប្រវត្តិសាសនា របស់មនុស្សដែលអ្នកបង្រៀន។ ស្គាល់ពីទ្រង់ទ្រាយនៃជីវប្រវត្តិរបស់ពួកគេ ដែល ប្រហែលជាវានាំឱ្យពួកគេ យល់ខុសអំពីគោលលទ្ធិនៃដំណឹងល្អ។ រៀបចំផែនការ ដើម្បីបង្រៀនគោលលទ្ធិទាំងនេះ ឱ្យបានច្បាស់លាស់។

## អំណោយទានខាងភាសា

ព្យាយាមរកអំណោយទាននៃព្រះវិញ្ញាណ រួមបញ្ចូលទាំងអំណោយទានខាងភាសា និងខាងការបកប្រែភាសា។ វាសំខាន់ជាងអំណោយណាៗទាំងអស់ ព្រោះវានឹងជួយអ្នកឱ្យនិយាយនិង ឱ្យយល់ភាសាមនុស្សនៅក្នុងបេសកកម្មរបស់អ្នក។ អ្នកនឹងមិនអាចមានអំណោយទាននេះទេ បើសិនជាអ្នកមិនខិតខំប្រឹងប្រែង អ្នកត្រូវតែសកម្មរុករកវា។ ផ្នែកនៃការរុករកអំណោយទានខាងភាសានេះ នោះគឺជាការខិតខំធ្វើ និងការតស៊ូ ហើយនឹងធ្វើនូវរាល់អ្វីដែលអ្នកអាចធ្វើ ដើម្បីរៀនភាសា។ ចូរទុកចិត្តថាព្រះវិញ្ញាណ នឹង ជួយអ្នកក្នុងពេលដែលអ្នករស់នៅតាមរបៀបដែលអ្នកគួររស់នៅ និងធ្វើដោយអស់ពីសមត្ថភាពដែលអ្នកអាចធ្វើបាន។ ចូរ មានជំនឿថាអ្នកអាចមានអំណោយទានខាងភាសា ដែលនោះជាការពិត ហើយនឹងមានវិញ្ញាណយល់ដឹងយ៉ាងទូលំទូលាយ។

នៅពេលដែលអ្នកមានអារម្មណ៍ថា អ្នកកំពុងតែពុះពារនឹងការលំបាកដើម្បីបញ្ជាក់ អំពីអ្វីដែលអ្នកចង់និយាយ ឱ្យអស់សេចក្ដីនោះ ចូរចងចាំថា ព្រះវិញ្ញាណ មានសមត្ថភាពអាចនិយាយចាក់ចូលទៅក្នុងដួងចិត្តកូនៗ របស់ព្រះ។ ប្រធាន ថូម៉ាស អេស. ម៉នសិន បានបង្រៀនថាៈ “ មានភាសាមួយ . . . ដែលវាជាភាសាទូទៅចំពោះអ្នកផ្សព្វផ្សាយសាសនាម្នាក់ៗ—នោះគឺភាសាព្រះវិញ្ញាណ។ វាមិនបាន រៀនមកពីសៀវភៅសិក្សា ដែលសរសេរដោយ ដៃមនុស្សចំណានៗនោះទេ ឬបានមកដោយការអាន និងការទន្ទេញចាំម៉ាត់នោះ ក៏មិនមែនដែរ។ ភាសានៃព្រះវិញ្ញាណនឹងមានដល់មនុស្សណាដែល ស្វែងរក ដោយអស់ពីដួងចិត្តរបស់គាត់ ដើម្បីដឹងពីព្រះ និងកាន់តាមបទបញ្ញាតិដ៏ទេវភាពរបស់ទ្រង់។ ភាពប៉ិនប្រសព្វនៅក្នុងភាសានេះ នឹងធ្វើឱ្យមនុស្សម្នាក់យកឈ្នះ លើឧបសគ្គ និងធ្វើឱ្យដកជាប់ក្នុងដួងចិត្តមនុស្ស។ (“The Spirit Giveth Life,” *Ensign,* ខែមិថុនា ឆ្នាំ1997, 2)។

### ចូរចងចាំចំណុចនេះ

- រៀនគោលលទ្ធិ និងមេរៀនទាំងឡាយដែលអ្នកត្រូវបង្រៀន នៅក្នុងភាសាដើមកំណើតរបស់អ្នកជាមុនសិន។
- រៀនដើម្បីបញ្ជាក់ពីគោលលទ្ធិ និងអារម្មណ៍របស់អ្នក អំពីគោលលទ្ធិទាំងនេះ នៅក្នុងភាសាបេសកកម្មរបស់អ្នក។
- បង្កើតផែនការសិក្សាភាសា និងជាញឹកញាប់ ព្យាយាមប្រើគំនិតថ្មី ពេលស្វែងរកការកែលំអភាសា បេសកកម្ម។
- ស្វែងរកការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីជួយអ្នកឱ្យយល់ និងអាចធ្វើការប្រាស្រ័យទាក់ទងជាមួយមនុស្ស នៅក្នុងបេសកកម្មរបស់អ្នក។

កំណត់ចំណាំ

## គំនិតសំរាប់ការសិក្សា និងការអនុវត្ត

### ការសិក្សាផ្ទាល់ខ្លួន

- ត្រួតពិនិត្យមើលពីការផ្ដល់ជាយោបល់ ដែលមាននៅក្នុងជំពូកនេះ។ កត់សំគាល់ជាយោបល់ មួយដែលអ្នកមិនធ្លាប់សាកល្បង សោះ ហើយដាក់គោលដៅ ដើម្បីសាកល្បងវាក្នុងពេលពីរបីថ្ងៃទៀតនេះ។

- សំរាប់ការប្រជុំមណ្ឌលពេលក្រោយ សូមសួរអ្នកផ្សព្វផ្សាយសាសនា ដែលមានបទពិសោធន៍ ដែលនិយាយភាសាបានល្អ ថាតើ គាត់បានធ្វើយ៉ាងដូចម្ដេចក្នុងការរៀនភាសា។

- អាននិងពិភាក្សា សេចក្ដីថ្លែងការណ៍ ខាងក្រោម ដែលថ្លែងដោយ អែលឌើរ រីឆាត ជី. ស្កត៖" ទីណាដែល . . . ប្រពៃណី ឬទំនៀមទំលាប់ជាតិ ប៉ះទង្គិចនឹងការបង្រៀនរបស់ព្រះ ចូរទុកបញ្ហានោះមួយឡែកសិន។ ទីណា ដែលប្រពៃណី និងទំនៀម ទំលាប់ ស្របគ្នានឹងការបង្រៀនរបស់ទ្រង់ នោះយើងគួរតែលើកដំកើងឡើង" ("Removing Barriers to Happiness," *Ensign*, ខែ ឧសភា ឆ្នាំ 1998, 87)។ ចូរគិតអំពីរបៀប ដែលវប្បធម៌នៅក្នុងតំបន់ ដែលអ្នកបំរើ មានភាពខុសប្លែកគ្នា ពីវប្បធម៌របស់អ្នកផ្ទាល់។ សូមធ្វើបញ្ជីពីភាពខុសគ្នា។ បន្ទាប់មកឆូតចោលវប្បធម៌ណា ដែលប៉ះទង្គិចនឹង ការបង្រៀននៃ ដំណឹងល្អ។ គិតពិចារណា ទំនៀមទំលាប់ឬប្រពៃណីទាំងឡាយណាដែល នៅសល់ ពីការឆូតចោល ហើយ គិតថា តើអ្នក អាចធ្វើយ៉ាងណា ដើម្បីឱ្យអ្នកអាចចូលចុះនឹងប្រពៃណី ដែលនៅសល់ទាំងនេះបាន។

- រៀបចំផែនការសិក្សា ដើម្បីរៀបចំអ្នកឱ្យធ្វើកិច្ចការមួយ នៃកិច្ចការខាងក្រោមនេះ នៅក្នុង ភាសាបេសកកម្មរបស់អ្នក៖
  - ប្រាប់រឿងអំពីលោក យ៉ូសែប ស្ម៊ីធ។
  - សង្ខេប នីហ្វៃ ទី3 11។
  - សង្ខេប អាលម៉ា 32។
  - ប្រាប់រឿងរបស់នីហ្វៃ និងអំពីផ្ទាំងលង្ហិន (សូមមើល នីហ្វៃ ទី 1 3:5)។
  - ចូរពន្យល់អំពីសម័យកាន់កាប់ត្រួតត្រា។
  - ចែកចាយបទពិសោធន៍ផ្ទាល់ខ្លួន។

- ចូរធ្វើសំរាប់កត់ចំណាំ ពាក្យដែលអ្នកមិនស្គាល់នៅក្នុងមេរៀន។ យកវាតាម ខ្លួនអ្នក រហូតដល់អ្នកចេះចាំទាំងអស់។

### ការសិក្សាជាមួយដៃគូ

- ហាត់បង្រៀនគ្នាទៅវិញទៅមក អំពីមេរៀនសំរាប់អ្នកផ្សព្វផ្សាយសាសនា នៅក្នុងភាសាបេសកកម្មរបស់អ្នក។

- សុំដៃគូអ្នកឱ្យស្ដាប់ការបញ្ចេញសំលេងរបស់អ្នក និងជួយអ្នកឱ្យធ្វើល្អជាង។

- ជ្រើសរើសរឿងនៅក្នុងព្រះគម្ពីរ ឬវគ្គគម្ពីរដែលអ្នកចង់ប្រើនៅក្នុងការបង្រៀន។ សង្ខេបរឿងទាំងនោះ ហើយហាត់វា នៅក្នុង ពាក្យសំដីផ្ទាល់របស់អ្នក។

- រំឭកឡើងវិញអំពីគំនិតនៅក្នុងជំពូកនេះ។ ពិភាក្សាថាតើការផ្ដល់ជាយោបល់ណាមួយ ដែលអ្នកអាចប្រើ នៅក្នុងការ សិក្សាជាដៃគូ នៅសប្ដាហ៍ក្រោយ។

- បើសិនជាអ្នកកំពុងហ្វឹកហ្វឺនអ្នកផ្សព្វផ្សាយសាសនាថ្មី ចូរកត់ត្រាពីស្ថានភាពនានា ពេលដែលដៃគូអ្នក មិនយល់។ ចូរធ្វើ បញ្ជីពាក្យ ឃ្លា ឬវេយ្យាករណ៍ ដែលមានទំនាក់ទំនងគ្នា ដែលអាចជួយដៃគូអ្នក។ ចូរពន្យល់ និងហាត់ អំពីរបៀបប្រើ ពីអ្វីដែល នឹងមាននៅក្នុងបញ្ជី ផែនការសកម្មភាពដែលមានគ្រោងមុន។

### ការប្រជុំមណ្ឌល និងសន្និសីទហ្សូន

- អញ្ជើញជនជាតិនិយាយភាសាដើមកំណើតមក ចូលរួមប្រជុំ។ ចាត់ចែងអ្នកផ្សព្វផ្សាយសាសនា ឱ្យបង្រៀនពួកគេ ជា ក្រុម តូចៗ។ អញ្ជើញជនជាតិនិយាយភាសាដើមកំណើតកត់ត្រា និងផ្ដល់ជាគំនិតច្រាសអំពីភាសារបស់អ្នកផ្សព្វផ្សាយសាសនា។

- ចាត់តាំងអ្នកផ្សព្វផ្សាយសាសនាមួយ ឬពីរនាក់ពីមុនពេលកំណត់ ឱ្យប្រាប់អំពីជោគជ័យដែលពួកគេមាននៅក្នុង ការសិក្សាភាសា។ អញ្ជើញឱ្យពួកគេឱ្យយោបល់។
- ចាត់តាំងអ្នកផ្សព្វផ្សាយសាសនាដែលមានបទពិសោធន៍ ឱ្យឧទ្ទិសនាមត្រូវសព្ទ ពីផ្នែកខ្លះនៃភាសាជាធម្មតា ដែលញឹកញាប់វាតែងតែជាការលំបាក សំរាប់អ្នកផ្សព្វផ្សាយសាសនា។ បង្ហាញជាឧទាហរណ៍ នៃការប្រើប្រាស់ភាសាល្អៗ ហើយឱ្យអ្នកផ្សព្វផ្សាយសាសនា អនុវត្ត។
- ចូរឱ្យអ្នកផ្សព្វផ្សាយសាសនា ដែលជាជនជាតិដើម នៃវប្បធម៌នោះ ចែកចាយពីគំនិតការយល់ឆ្លុះជ្រៅដ៏ជាជំនួយ។

## ប្រធានបេសកកម្ម

- ត្រូវកំណត់ពេលវេលាជាទៀងទាត់ សម្ភាសជាមួយអ្នកផ្សព្វផ្សាយសាសនា នៅក្នុងភាសាដែលពួកគេកំពុងរៀន។
- សុំគំនិតពីអ្នកដឹកនាំបព្វជិតភាព ក្នុងតំបន់ដើម្បីប្រាប់ពីរបៀបដែលអ្នកផ្សព្វផ្សាយសាសនា អាចកែលំអភាសា របស់ពួកគេ ។
- កត់ចំណាំពីកំហុសដដែលៗ ដែលអ្នកផ្សព្វផ្សាយសាសនាកំពុងតែរៀនភាសាបេសកកម្ម តែងតែជួបប្រទះ។ ផ្តល់ការណែនាំនៅក្នុងសន្និសីទហ្សូន ដើម្បីកែលំអកំហុសឆ្គងទាំងនេះ។
- បង្រៀនអ្នកផ្សព្វផ្សាយសាសនាអំពីគោលលទ្ធិនៃអំណោយទានខាងវិញ្ញាណ។
- សង្កេតអ្នកផ្សព្វផ្សាយសាសនារបស់អ្នក ពេលពួកគេបង្រៀនភាសា។
- ស្វែងរកគ្រប់ឱកាសដើម្បីប្រើភាសា ជាមួយនឹងអ្នកផ្សព្វផ្សាយសាសនារបស់អ្នក។

កំណត់ចំណាំ

កំណត់សំគាល់



# តើខ្ញុំត្រូវប្រើពេលវេលាដោយឆ្លាតវៃដោយរបៀបណា?

កំណត់ចំណាំ

## ចូរពិចារណាចំណុចនេះ

- តើគោលដៅ អាចជួយខ្ញុំធ្វើជាអ្នកផ្សព្វផ្សាយសាសនា ដ៏មានប្រសិទ្ធិភាពកាន់តែច្រើនឡើង ដោយរបៀបណា?
- តើខ្ញុំគួរផ្តោតយកចិត្តទុកដាក់លើអ្វីខ្លះ នៅក្នុងគោលដៅរបស់ខ្ញុំ?
- តើឧបករណ៍ផែនការ និងធនធានទាំងឡាយរបស់ខ្ញុំមានអ្វីខ្លះ ហើយតើខ្ញុំត្រូវប្រើវាដោយរបៀបណា?
- តើហេតុអ្វីបានជា សៀវភៅតំបន់ មានសារៈសំខាន់?
- តើខ្ញុំត្រូវដឹកនាំសម័យប្រជុំផែនការ ប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ ដោយរបៀបណា?
- តើខ្ញុំនឹងដឹងដោយរបៀបណា ប្រសិនបើគោលដៅ និងផែនការរបស់ខ្ញុំ កំពុងជួយបន្ថែមដល់កិច្ចការនៃព្រះអម្ចាស់?

អ្នកត្រូវបានចាត់តាំង អោយធ្វើកិច្ចការនៃព្រះអម្ចាស់ នៅក្នុងតំបន់មួយជាក់លាក់។ ទ្រង់ចង់អោយអ្នក មើលខុសត្រូវលើតំបន់របស់អ្នក ដោយសេចក្តីស្រលាញ់ និងការយកចិត្តទុកដាក់ដ៏ធំ។ គោលបំណងរបស់អ្នក គឺត្រូវជួយដល់អ្នកដទៃ ឱ្យមកឯទ្រង់ តាមរយៈពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។

ចូរធ្វើកិច្ចការឱ្យអស់ពីសមត្ថភាព ដើម្បីអោយតំបន់របស់អ្នកកាន់តែខ្លាំងឡើង ជាងពេលអ្នកចាប់ផ្តើមវាទៅទៀត។ គោលដៅដ៏មានខ្លឹមសារ និងផែនការដ៏មានការយកចិត្តទុកដាក់ នឹងជួយអ្នកសំរេចនូវអ្វី ដែលព្រះអម្ចាស់ តំរូវអោយអ្នកធ្វើ។ ពេលអ្នកយកចិត្តទុកដាក់ចំពោះមនុស្ស នៅក្នុងតំបន់ចាត់តាំងរបស់អ្នក នោះអ្នកនឹងមានការទទួលខុសត្រូវចំពោះទ្រង់ និងចំពោះអ្នកដឹកនាំបេសកកម្មរបស់អ្នក។

ក្នុងលិខិតហៅឱ្យបំរើជាអ្នកផ្សព្វផ្សាយសាសនារបស់អ្នក បានចែងថាៈ “អ្នកនឹងត្រូវបានរំពឹងទុកផងដែរ ដើម្បីលះបង់ពេលវេលាទាំងអស់របស់អ្នក និងការយកចិត្តទុកដាក់ ចំពោះការបំរើព្រះអម្ចាស់ ដោយទុកកិច្ចការផ្ទាល់ខ្លួនទាំងអស់ផ្សេងទៀត នៅមួយ ឡែកសិន។ ពេលអ្នកធ្វើកិច្ចការទាំងឡាយនេះ ព្រះអម្ចាស់ នឹងប្រទានពរជ័យដល់អ្នក ហើយអ្នកនឹងក្លាយជាអ្នកជួយ គាំទ្រម្នាក់ ដ៏មានប្រសិទ្ធិភាព និងជាសារទូតនៃសេចក្តីពិត។ យើងមានទំនុកចិត្តលើអ្នក ហើយយើងសូមអធិស្ឋាន ដល់ព្រះអម្ចាស់ ដើម្បីជួយ ប្រទានពរជ័យដល់អ្នក ចំពោះទំនួលខុសត្រូវរបស់អ្នក ក្នុងការបំពេញនូវការចាត់តាំងដ៏ពិសិដ្ឋនេះ។” ជំពូកនេះនឹងជួយអ្នកដឹង អំពីរបៀបដាក់គោលដៅ ការដាក់ផែនការ និងការទទួលខុសត្រូវ ដែលអាចជួយដល់មនុស្សច្រើននាក់ អោយទទួលដំណឹងល្អ ដែលបានស្តារឡើងវិញ។

កំណត់ចំណាំ

### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន ឬការសិក្សាជាមួយដៃគូ

សូមអាន យ៉ាកុប 5:11–13, 61–64, 74–75, ហើយឆ្លើយនូវសំនួរទាំងនេះ:

- តើព្រះអម្ចាស់មានអារម្មណ៍យ៉ាងដូចម្ដេចដែរ ចំពោះកូនចៅរបស់ទ្រង់?
- តើកិច្ចប្រឹងប្រែងបែបណាខ្លះ ដែលព្រះអម្ចាស់ តំរូវអោយអ្នកបំរើទាំងឡាយរបស់ទ្រង់ធ្វើ?

## សញ្ញាណសំគាល់សំខាន់ៗ សំរាប់ការផ្លាស់គំនិត

ប្រហែលជាអ្នកមានចំងល់ថា ក្នុងចំណោមករណីយកិច្ចយ៉ាងច្រើននោះ តើករណីយកិច្ចណាខ្លះ សំខាន់បំផុត។ ដើម្បីអាចឆ្លើយនឹងសំនួរនេះ អ្នកត្រូវយល់ពីគោលបំណងរបស់អ្នក ហើយដឹងពីរបៀបប្រើប្រាស់ពេលវេលា ដ៏មានប្រសិទ្ធិភាព ដែលអាចជួយអ្នកបំពេញគោលបំណងនេះបាន។

គោលបំណងរបស់អ្នកគឺ [អញ្ជើញអ្នកដទៃទៀត ឱ្យមកឯព្រះគ្រីស្ទ ដោយជួយអោយពួកគេទទួលដំណឹងល្អ ដែលបានស្ដារឡើងវិញ តាមរយះសេចក្ដីជំនឿ ចំពោះព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ការប្រែចិត្ត ពិធីបុណ្យជ្រមុជទឹក ការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ហើយនិងការស៊ូទ្រាំរហូតដល់ទីបញ្ចប់។] សញ្ញាណសំគាល់សំខាន់ៗ ត្រូវបានបង្ហាញឱ្យស្គាល់ ដោយអ្នកដឹកនាំសាសនាចក្រ ដើម្បីជួយអ្នកផ្ដោតទៅលើគោលបំណងនេះ។ ពេលអ្នកផ្ដោតទៅលើ សញ្ញាណសំគាល់ទាំងនេះ អ្នកនឹងជួយមនុស្សចំរើនឡើង ឆ្ពោះទៅកាន់ពិធីបុណ្យជ្រមុជទឹក ពិធីបញ្ជាក់ ហើយមានសកម្មភាពជាបន្តបន្ទាប់ នៅក្នុងសាសនាចក្រព្រមការផ្លាស់គំនិតជានិរន្ដ។

### សញ្ញាណសំគាល់សំខាន់ៗ ដើម្បីកត់ត្រា រាយការ

- អ្នកផ្លាស់ប្រែគំនិតបានទទួលបុណ្យជ្រមុជទឹក និងបានទទួលពិធីបញ្ជាក់
- សាសនាគន់ការីដែលមានកាលបរិច្ឆេទពិធីបុណ្យជ្រមុជទឹក
- សាសនាគន់ការីដែលបានចូលរួមនៅក្នុង ពិធីប្រសិទ្ធពរនំប៉័ង និងទឹក
- មេរៀនដែលបានបង្រៀនសាសនាគន់ការី ដែលមានវត្តមាន របស់សមាជិក
- មេរៀនដទៃទៀត ដែលបានបង្រៀន
- សាសនាគន់ការីដែលកំពុងរីកចំរើន
- បានទទួលឈ្មោះមនុស្សថ្មីដែលត្រូវទៅជួប និងបានទាក់ទង
- សាសនាគន់ការីថ្មី
- មេរៀនដែលបានបង្រៀនដល់អ្នកផ្លាស់ប្រែគំនិតថ្មី និងសមាជិកមិនសូវសកម្ម

សញ្ញាណសំគាល់ទាំងនេះ បង្ហាញអំពីព្រឹត្តិការណ៍ និងស្ថានភាពទាំងឡាយ ដែលបង្ហាញពីការរីកចំរើន របស់មនុស្សម្នាក់ ឆ្ពោះទៅរកការផ្លាស់គំនិត រយះពេលយូរអង្វែង។ សញ្ញាណសំគាល់ បង្ហាញចំណុចសំខាន់ៗ ដូចខាងក្រោមនេះៈ

**អ្នកប្រែគំនិតបានទទួលបុណ្យជ្រមុជទឹក និងបានទទួលពិធីបញ្ជាក់ៈ** អ្នកប្រែគំនិតម្នាក់ៗដែលបានទទួល ពិធីការទាំងឡាយ នៃពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។

**សាសនាគន់ការីដែលមានកាលបរិច្ឆេទពិធីបុណ្យជ្រមុជទឹកៈ** សាសនាគន់ការីម្នាក់ៗដែលបានយល់ព្រម ទទួលបុណ្យជ្រមុជទឹក និងបានទទួលពិធីបញ្ជាក់ តាមបរិច្ឆេទមួយជាក់លាក់។

**សាសនាគន់ការីដែលបានចូលរួមនៅក្នុង ពិធីប្រសិទ្ធពរនំប៉័ង និងទឹកៈ** សាសនាគន់ការីម្នាក់ៗ ដែលបានចូលរួមនៅក្នុង ពិធីប្រសិទ្ធពរនំប៉័ង និងទឹក។

**មេរៀនដែលបានបង្រៀនសាសនាគន់ការី ដែលមានវត្តមាន របស់សមាជិកៈ** ចំនួនមេរៀនសរុប ដែលបានបង្រៀនដល់ សាសនាគន់ការីដែលមានវត្តមានរបស់សមាជិក។ តាមធម្មតា មេរៀនដែលមានរួមបញ្ចូលនូវការបង្រៀន គោលការណ៍មួយ នៃដំណឹងល្អ ឬច្រើនមកពីមេរៀន ដែលមានការអធិស្ឋានបើក និងបិទ និងការអញ្ជើញដើម្បីធ្វើការតាំងចិត្ត។ អ្នកមិនចាំបាច់បង្រៀន គោលការណ៍ទាំងអស់

កំណត់ចំណាំ

នៅក្នុងមេរៀនតែមួយទេ ដើម្បីរាប់ថា ជាមេរៀនដែលបង្រៀន រួចហើយ។ ប្រសិទ្ធិភាពនៅក្នុងការបង្រៀនរបស់អ្នក អាចត្រូវបានវាស់វែងដោយសាសនាគន់ការី ថាតើពួកគេកំពុងតែ រីកចំរើនក្នុង សេចក្ដីជំនឿ ចំពោះព្រះអង្គសង្គ្រោះ ការប្រែចិត្តពីការរំលងរបស់ពួកគេ និងការរៀបចំយ៉ាងស្មោះស្ម័គ្រ ដើម្បីទទួលពិធីការ នៃបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ដែរឬទេ។

**មេរៀនដទៃទៀត ដែលបានបង្រៀនៈ** ចំនួនមេរៀនសរុប ដែលបានបង្រៀនដល់សាសនាគន់ការី ដោយគ្មានវត្តមានសមាជិក។ តាមធម្មតា សញ្ញាណសំគាល់នេះ សំដៅទៅលើឱកាសដើម្បីបង្រៀន ក្នុងកាលៈទេសៈនៃការស្វែងរកសាសនាគន់ការីថ្មី។

**សាសនាគន់ការីដែលកំពុងរីកចំរើនៈ** ចំនួនសាសនាគន់ការីសរុប ដែលត្រូវបានបង្រៀនមេរៀនចំនួនពីរ ឬច្រើនជាងនោះ ហើយ កំពុងរក្សាការតាំងចិត្ត ដូចជាៈ អធិស្ឋាន អានព្រះគម្ពីរមរមន ចូលរួមសាសនាចក្រ និងរៀបចំខ្លួន ដើម្បីទទួលពិធីបុណ្យ ជ្រមុជទឹក និងពិធីបញ្ជាក់។ សាសនាគន់ការីដែលមានបំណងចង់បន្តរៀនអំពី ដំណឹងល្អ តែកំពុងតែពុះពារ ដើម្បីរក្សាការតាំងចិត្ត មិនមែនជា សាសនាគន់ការីដែលកំពុងរីកចំរើន ដូចដែលបានបញ្ជាក់សេចក្ដីនៅត្រង់នេះទេ។ ពួកគេត្រូវបានចាត់ចូលជា សាសនាគន់ការីថ្មី ឬក៏ជាសាសនាគន់ការីផ្សេងទៀតផងដែរ។

**បានទទួលឈ្មោះមនុស្សថ្មីដែលត្រូវទៅជួប និងបានទាក់ទងៈ** ចំនួនសរុបនៃ មនុស្សថ្មីដែលត្រូវទៅជួប ដែលអ្នកបានទំនាក់ទំនង ហើយក៏បានបង្រៀន ឬក៏បានសុំអោយមានការណាត់ជួបជាក់លាក់ជាថ្មី។ ពេលអ្នកទាក់ទង មនុស្សថ្មីដែលត្រូវទៅជួបម្ដងៗ មនុស្សថ្មីនោះ គឺត្រូវយកចេញពី បញ្ជីនៃក្រុមមនុស្សថ្មីដែលត្រូវទៅជួប ហើយក៏បានក្លាយជាសាសនាគន់ការីថ្មី ដើម្បីតាមដាន បន្ថែម ឬក៏ត្រូវបានទំលាក់ចោល។ មនុស្សថ្មីដែលត្រូវទៅជួប ក៏ត្រូវបានចាត់ទុកថាបានទាក់ទងដែរ ទោះបីជាអ្នកទាក់ទងមិនបាន ដោយសារតែអាស័យដ្ឋានមិនត្រឹមត្រូវ។ មនុស្សថ្មីដែលត្រូវទៅជួបទាំងនេះ ត្រូវបញ្ជូនត្រឡប់ទៅឱ្យ ការិយាល័យបេសកកម្មវិញ ដោយមានចំណារសំគាល់ អំពីមូលហេតុដែល មិនអាចទាក់ទងបាន។

ចំនួនសរុបមនុស្សថ្មីដែលត្រូវទៅជួប គឺសំដៅទៅលើមនុស្សថ្មីដែលត្រូវទៅជួបទាំងអស់ ដែលអ្នកបានទទួល ទោះមិនទាន់បានទាក់ទង (មនុស្សថ្មីដែលត្រូវទៅជួបទទួលពី សមាជិក សាសនាគន់ការី ទីស្នាក់ការសាសនាចក្រ និងបានទទួលតាមរយៈផ្សេងៗទៀត)។ ចំពោះគោលបំណងនៃការរាយការណ៍ ចំនួនមនុស្សថ្មី ដែលមិនទាន់បានទាក់ទងត្រូវនៅពីមួយសប្ដាហ៍ ទៅមួយសប្ដាហ៍។ រាល់មនុស្សថ្មីត្រូវបានបន្ថែមចំនួននេះ ហើយមនុស្សថ្មីម្នាក់ៗ ដែលបានទាក់ទងហើយ ត្រូវបានដកចេញពីវា។ ចូរចាំថា ទោះជាយ៉ាងណាក៏ដោយ "មនុស្សថ្មីដែលបានទាក់ទងហើយ" សំដៅទៅលើចំនួនដែលបានទាក់ទងនៅក្នុងសប្ដាហ៍ ត្រូវបានរាយការណ៍។

**សាសនាគន់ការីថ្មីៈ** ចំនួនសរុបនៃ សាសនាគន់ការី ដែលបានរៀនមេរៀនមួយ និងបានទទួលយកការណាត់ជួបជាថ្មី។

**មេរៀនដែលបានបង្រៀន ដល់អ្នកផ្លាស់ប្រែគំនិតថ្មី និងសមាជិកមិនសូវសកម្មៈ** ចំនួនមេរៀនសរុប ដែលបានបង្រៀនដល់ អ្នកផ្លាស់ប្រែគំនិតទាំងឡាយ ដែលបានក្លាយជាសមាជិកតិចជាងមួយឆ្នាំ និងចំពោះសមាជិកទាំងឡាយ ដែលមិនសូវសកម្ម។

ពេលអ្នកដាក់គោលដៅ និងធ្វើផែនការ ចូរវាយតំលៃពីអ្វីដែលអ្នកធ្វើ ថាតើវានឹងជួយបន្ថែម ចំនួនមនុស្ស នៅក្នុង សញ្ញាណសំគាល់សំខាន់ៗ យ៉ាងដូចម្ដេចខ្លះ។ គោលដៅរបស់អ្នក គួរតែដើម្បី បង្កើនចំនួន ឱ្យកើនឡើង សំរាប់សញ្ញាណសំគាល់សំខាន់ៗ។

អ្នកនឹងធ្វើកិច្ចការជាច្រើន ដែលមិនត្រូវបានរៀបរាប់នៅក្នុង សញ្ញាណសំគាល់សំខាន់ៗ ដូចជាៈ ការទាក់ទងតាមផ្លូវ ឬការសិក្សាផ្ទាល់ខ្លួន និងការសិក្សាជាមួយដៃគូ។ សកម្មភាពសំខាន់ៗទាំងនេះ ផ្ដល់អោយនូវសញ្ញាណសំគាល់សំខាន់ៗមួយ ឬច្រើន។ ឧទាហរណ៍ ពេលអ្នកបង្រៀនអ្នកទាំងឡាយណា ដែលអ្នករកបានដោយកិច្ចប្រឹងប្រែងផ្ទាល់ខ្លួន អ្នកបន្ថែមសាសនាគន់ការីថ្មី ទៅកាន់ក្រុមមនុស្សដែលអ្នកបង្រៀន។ ជាមួយគ្នាផងនោះដែរ គុណភាពនៃការសិក្សាផ្ទាល់ខ្លួន និងការសិក្សាជាមួយដៃគូ នឹងកែលំអ សមត្ថភាពរបស់អ្នកដើម្បីបង្រៀនដោយព្រះវិញ្ញាណ ដែលនឹងប្រសិទ្ធិពរជ័យដល់ សាសនាគន់ការីថ្មី និងសាសនាគន់ការី ដែលកំពុងរីកចំរើនរបស់អ្នក។ អំណាចនៃការស្វែងរក និងការបង្រៀនរបស់អ្នក នឹងជះឥទ្ធិពលដល់គ្រប់ សញ្ញាណសំគាល់ សំខាន់ៗ។ ចូរវាយតំលៃគ្រប់កិច្ចការដែលអ្នកធ្វើ ដោយផ្អែកទៅលើ ថាតើវាបានបន្ថែមចំនួនមនុស្សនៅក្នុងផ្នែកទាំងនេះរឺទេ។ ប្រសិនបើអ្នក និង ដៃគូរបស់អ្នកមិនអាចឃើញពីរបៀប នៅក្នុងសកម្មភាពផ្សព្វផ្សាយ ដែលអាចជួយបង្កើនចំនួនមនុស្ស នៅក្នុងសញ្ញាណសំគាល់សំខាន់ៗមួយ ឬច្រើនជាងនោះទេ អ្នកត្រូវចោទសួរ ថាតើសកម្មភាពនោះ សមទៅនឹងពេលវេលារបស់អ្នករឺទេ។

### សកម្មភាពៈ ការសិក្សាជាមួយដៃគូ

នៅក្នុងសៀវភៅការសិក្សារបស់អ្នក សូមកត់ទុកនូវទាំងសកម្មភាពផ្សព្វផ្សាយទាំងអស់ ដែលអ្នកបានធ្វើ ក្នុងរយៈពេលបីថ្ងៃ កន្លងមក។ សំរាប់សកម្មភាពនីមួយៗ ចូរបញ្ជាក់ ប្រសិនបើវាបានជះឥទ្ធិពលដល់ សញ្ញាណសំគាល់សំខាន់ៗមួយក្នុងចំណោម សញ្ញាណសំគាល់ សំខាន់ៗជាច្រើន។ ប្រសិនបើវាបានធ្វើសកម្មភាព សរសេរថា *បានធ្វើ* នៅក្បែរវា។ ប្រសិនបើវាមិនបានធ្វើសកម្មភាពទេ សរសេរថា *មិនបានធ្វើ*។ សំរាប់សកម្មភាពនីមួយៗ ដែលមានសរសេរ *បានធ្វើ* ចូររៀបរាប់ថាតើ វាមានឥទ្ធិពល យ៉ាងដូចម្ដេច។ សំរាប់សកម្មភាពនីមួយៗ ដែលមានសរសេរ

កំណត់ចំណាំ

*មិនបានធ្វើ* ចូរប្រាប់ពីមូលហេតុដែលអ្នកមិនបានធ្វើ ហើយថាតើអ្នកនឹងបន្ត ដើម្បីធ្វើសកម្មភាពក្នុងពេលខាងមុខទៀត។ ចូរពិភាក្សាអំពីបញ្ជីរបស់អ្នកជាមួយដៃគូរបស់អ្នក ហើយពន្យល់ពីមូលហេតុដែល បានបញ្ជាក់ សកម្មភាពមួយចំនួន *បានធ្វើ* និងសកម្មភាពមួយចំនួន *មិនបានធ្វើ*។ ពិភាក្សាថាសកម្មភាពមួយណា ដែលអ្នកត្រូវ ឈប់ធ្វើ។

## សៀវភៅតំបន់ និងការរៀបផែនការ និងឧបករណ៍រាយការណ៍

ទាក់ទងទៅនឹងអស់អ្នក ដែលត្រូវបានទទួលឱ្យចូលទៅក្នុងសាសនាចក្រ ដោយទទួលពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ នៅក្នុងសម័យរបស់គាត់ ម៉ូរ៉ូណៃបានបង្រៀនថា៖ “ឈ្មោះរបស់ពួកគេត្រូវបានយកទៅ ដើម្បីអោយពួកគេ អាចបានចងចាំ ហើយចិញ្ចឹមបីបាច់ដោយព្រះបន្ទូលដ៏ល្អនៃព្រះ ដើម្បីរក្សាពួកគេ ឱ្យនៅក្នុងផ្លូវត្រូវ” (ម៉ូរ៉ូណៃ 6:4)។

អ្នកត្រូវបានផ្តល់នូវឧបករណ៍ជាច្រើន ដើម្បីសំរួលការកត់ត្រាទុកពត៌មានសំខាន់ៗ អំពីមនុស្សដែលអ្នកបង្រៀន។ ឧបករណ៍ ទាំងនេះក៏អនុញ្ញាតដល់អ្នកផងដែរ ដើម្បីចែកចាយចំនួនពត៌មានមួយត្រឹមត្រូវ ជាមួយអស់អ្នក ដែលត្រូវការវា ដូចដែលបាន បង្ហាញនៅក្នុងការបញ្ជាក់បង្ហាញខាងក្រោមនេះ។




ឧបករណ៍ទាំងនេះ និងពត៌មានទាំងអស់ ចាំបាច់ដើម្បីធ្វើ នៅក្នុងកិច្ចការរបស់អ្នក ដោយត្រូវរក្សាទុកនៅក្នុង សៀវភៅតំបន់ និងកាលវិភាគប្រចាំថ្ងៃ របស់អ្នកផ្សព្វផ្សាយសាសនា។ សៀវភៅតំបន់ត្រូវបានរៀបចំឡើងដូចខាងក្រោមនេះ៖

- ផែនទីតំបន់
  - ផែនទីតំបន់ដែលមាន ដែនសីមា
- កំណត់ហេតុស្តីពីការរីកចំរើន
  - បែបបទកំណត់ហេតុស្តីពីការរីកចំរើន
- សាសនាគន់ការីដែលមានកាលបរិច្ឆេទពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់
  - បែបបទកំណត់ហេតុសំរាប់បង្រៀន
- សាសនាគន់ការីដែលកំពុងរីកចំរើន
  - បែបបទ កំណត់ហេតុសំរាប់បង្រៀន
- សាសនាគន់ការីថ្មី និងសាសនាគន់ការីដទៃទៀត
  - បែបបទ កំណត់ហេតុសំរាប់បង្រៀន
- សាសនាគន់ការីដ៏មានសក្តានុពល
  - បែបបទសំរាប់សាសនាគន់ការី ដ៏មានសក្តានុពល
  - ពត៌មានសំរាប់មនុស្សថ្មីដែលត្រូវទៅជួប និងកំណត់ហេតុសំរាប់មនុស្សថ្មីដែលត្រូវទៅជួបផ្សេងទៀត
- សាសនាគន់ការីមុន
  - បែបបទ កំណត់ហេតុសំរាប់បង្រៀន
- សាសនាគន់ការីថ្មី និងសមាជិកមិនសូវសកម្ម
  - បែបបទ កំណត់ហេតុសំរាប់បង្រៀន
  - បែបបទបញ្ជីសកម្មភាព សំរាប់អ្នកផ្លាស់គំនិត
- ព័ត៌មាន វួដ និង បេសកកម្ម
  - បញ្ជីវួដ
  - សៀវភៅបញ្ជីមុខងារក្នុងវួដ
  - តារាងពេលក្នុងវួដ និងកិច្ចប្រជុំអ្នកផ្សព្វផ្សាយសាសនា
  - បញ្ជីនៃផ្នែកជាសមាជិកនៅក្នុងគ្រួសារ
  - សៀវភៅបញ្ជីនៃអ្នកផ្សព្វផ្សាយសាសនា នៅក្នុងមណ្ឌល ឬហ្សូនរបស់អ្នក
- ភាពជាអ្នកដឹកនាំ
  - សេចក្តីរាយការណ៍សង្ខេបតាមទូរស័ព្ទ

កំណត់ចំណាំ

- **ពត៌មានស្តីអំពីតំបន់**
  - ពត៌មានស្តីអំពីផ្ទះ
  - ការដឹកជញ្ជូនសាធារណៈ
  - កាត់សក់
  - បោកគក់
  - ទីកន្លែងដែលបានទិញឥវ៉ាន់
  - ទីកន្លែងដែលត្រូវចៀសវាង
  - ទំនាក់ទំនងផ្សេងៗ

### សៀវភៅតំបន់

គ្រប់តំបន់ផ្សព្វផ្សាយ មានសៀវភៅតំបន់មួយ ដែលនឹងត្រូវទុកជាកំណត់ហេតុដ៏យូរអង្វែង សំរាប់ជាកិច្ចប្រឹងប្រែងពីមួយថ្ងៃទៅ មួយថ្ងៃរបស់អ្នក។ សំរួលឡើងវិញនូវ ពត៌មានសំខាន់ៗប្រចាំថ្ងៃ និងពិនិត្យមើលពត៌មានសំខាន់ៗប្រចាំសប្តាហ៍ពេលធ្វើ ផែនការណាត់ជួបប្រចាំសប្តាហ៍របស់អ្នក។ ចូររក្សាទុកវាឱ្យបានស្អាត នៅថ្មី និងត្រឹមត្រូវ ដើម្បីអោយអ្នកផ្សព្វផ្សាយសាសនា ក្រោយអាចស្ថាបនាឡើងនូវការបំរើដ៏មានការបំផុស ដែលអ្នកបានផ្តល់អោយនោះ។ ពេលមានការអញ្ជើញ សូមយកសៀវភៅ តំបន់របស់អ្នក ទៅកាន់ការសម្ភាសន៍ ឬសន្និសីទហ្សូន នៅកន្លែងណាដែលអ្នកដឹកនាំបេសកកម្មអាចរំលឹកវាសារឡើងវិញ ហើយ ជួយអ្នកឱ្យដឹងពីរបៀបដើម្បីប្រើប្រាស់វា យ៉ាងមានប្រសិទ្ធិភាពបំផុត។

អ្នកគួរតែរៀបចំផ្នែកមួយចំនួន នៅក្នុងសៀវភៅតំបន់ ជារៀងរាល់ថ្ងៃ ពេលអ្នកសំរួលឡើងវិញ និងផ្លាស់ប្តូរផែនការរបស់អ្នក។ នៅពេលបានអញ្ជើញ ចូរយកសៀវភៅតំបន់របស់អ្នក ទៅចូលរួមក្នុងសន្និសីទហ្សូន និងការសម្ភាសន៍នានា ដើម្បីអោយអ្នកដឹកនាំបេសកកម្មរបស់អ្នកអាចរំលឹកវាសារឡើងវិញ។ សៀវភៅតំបន់គួរតែរក្សាទុកក្នុងផ្ទះរបស់អ្នក ក្រោយពីអ្នកត្រូវបានផ្លាស់ប្តូរនោះ ដើម្បីអោយអ្នកផ្សព្វផ្សាយសាសនាក្រោយ អាចប្រើប្រាស់ពត៌មានបាន។

នៅក្នុងសៀវភៅតំបន់របស់អ្នក សូមរក្សាទុកអោយបានត្រឹមត្រូវ ពេញលេញ និងកំណត់ហេតុរបស់មនុស្សទាំងអស់ ក្នុងពេលបច្ចុប្បន្ន ដែលអ្នកធ្វើការជាមួយនោះ។ សេចក្តីពន្យល់អំពីឧបករណ៍ទាំងឡាយ ដែលបានផ្តល់ជូន មានដូចខាងក្រោមនេះ៖

កំណត់ចំណាំ

**កំណត់ហេតុបង្រៀន** បែបបទនេះជួយអ្នកកត់ត្រាទុក នូវព័ត៌មានពិស្ដារ ទាក់ទងទៅនឹងការរីកចំរើនរបស់ សាសនាទាគន់ការី អ្នកផ្លាស់ប្រែគំនិតថ្មី និងសមាជិកមិនសូវសកម្ម ដែលអ្នកកំពុងតែបង្រៀន។

- ពត៌មានផ្ទាល់ខ្លួន
- កាលបរិច្ឆេទនៃពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់




**កំណត់ហេតុនៃការបង្រៀន**

តំបន់ផ្សព្វផ្សាយ | វួដ ឬ សាខា | សង្កាត់ ឬ មណ្ឌល

**ពត៌មានផ្ទាល់ខ្លួន** (សូមមើល ផ្នែកម្ខាងទៀតសំរាប់បន្ថែមពត៌មានផ្ទាល់ខ្លួន។)

| ឈ្មោះ បុគ្គល ឬដៃគូ | អក្សរកាត់* | អាយុ | កាលបរិច្ឆេទ នៃការទាក់ទងលើកដំបូង | ព្រៀបចំ កាលបរិច្ឆេទពិធីបុណ្យ ជ្រមុជទឹក | កាលបរិច្ឆេទ ពិតប្រាកដនៃពិធីបុណ្យ ជ្រមុជទឹក | កាលបរិច្ឆេទ ពិធីបញ្ជាក់ | ឈ្មោះរបស់កូន (ឈ្មោះបន្ថែម ប្រហែលអាចសរសេរទៅ ក្នុងពត៌មានប្រវត្តិ នៅផ្នែកខាងក្រោយ។) | |
|---|---|---|---|---|---|---|---|---|
| | | | | | | | អាយុ | អាយុ |
| | | | | | | | អាយុ | អាយុ |

អាស័យដ្ឋាន | លេខទូរស័ព្ទ | អ្នកផ្សព្វផ្សាយសាសនា ដែលចាប់ផ្ដើមការបង្រៀន

ឈ្មោះរបស់អ្នកដឹកនាំ និងឈ្មោះគ្រូបង្រៀនតាមផ្ទះ ឬ គ្រូសួរសុខទុក្ខតាមផ្ទះ | លេខទូរស័ព្ទ | អាស័យដ្ឋាន

* អក្សរកាត់៖ ស=សាសនាទាគន់ការី, អផគថ= អ្នកផ្លាស់ប្រែគំនិតថ្មី, សម= សមាជិកមិនសូវសកម្ម, សម=សមាជិក, ផសគ= ជាផ្នែកនៃសមាជិកនៅក្នុងគ្រួសារ

**កាលបរិច្ឆេទមេរៀន និងគោលការណ៍ដែលបានបង្រៀន** (គូសរង្វង់ បើបង្រៀនជាមួយសមាជិក។) | ***ស្ថានភាពនៃការតាំងចិត្ត ឬសកម្មភាពសំរាប់សាសនាទាគន់ការី ឬមេគ្រួសារ**

| សារលិខិតនៃការស្ដារឡើងវិញ | មុនពេលធ្វើពិធីបុណ្យជ្រមុជទឹក | ក្រោយពេលធ្វើពិធីបុណ្យជ្រមុជទឹក | បទបញ្ញត្ត | មុនពេលធ្វើពិធីបុណ្យជ្រមុជទឹក | ក្រោយពេលធ្វើពិធីបុណ្យជ្រមុជទឹក | ការអញ្ជើញ | ការរក្សា | |
|---|---|---|---|---|---|---|---|---|
| ព្រះជាព្រះវរបិតាដ៏ជាទីស្រឡាញ់របស់យើង | | | ការប្រតិបត | | | | | អានពីព្រះគម្ពីរមរមន |
| ដំណឹងល្អប្រទានពរដល់ក្រុមគ្រួសារ | | | អធិស្ឋានជាញឹកញាប | | | | | អធិស្ឋានអំពីព្យាការី យ៉ូសែប ស្ម៊ីធ និងព្រះគម្ពីរមរមន |
| ការកាន់កាប់ត្រួតត្រានៃដំណឹងល្អ | | | សិក្សាព្រះគម្ពីរ | | | | | ចូលរួមការប្រសិទ្ធិពរទំប៉ុង និងទឹក និងការប្រជុំផ្សេងៗ |
| សម័យបំរើរបស់ព្រះអង្គសង្គ្រោះនៅលើផែនដ | | | រក្សាថ្ងៃសិលឱ្យបរិសុទ | | | | | កុមារចូលរួមក្នុងថ្នាក់អង្គការបឋមសិក្សា យុវជន ឬយុវនារ |
| ការក្បត់សាសនាដ៏ធំ | | | ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ | | | | | ណែនាំក្រុមគ្រួសារ និងមិត្តឱ្យស្គាល់អ្នកផ្សព្វផ្សាយសាសនា |
| ការស្ដារឡើងវិញ៖ យ៉ូសែប ស្ម៊ីធ | | | ធ្វើតាមព្យាការី | | | | | ចូលរួមការបំរើពិធីបុណ្យជ្រមុជទឹក |
| ព្រះគម្ពីរមរមន | | | កាន់តាមក្រឹត្យវិន័យដប់ប្រការ | | | | | ជួបជាមួយប៊ីស្សប និងសមាជិកនៃក្រុមប្រឹក្សាវួដ |
| ការអធិស្ឋាន ព្រះវិញ្ញាណបរិសុទ | | | រស់នៅតាមច្បាប់ព្រហ្មចារីភាព | | | | | អភិវឌ្ឍមិត្តភាពជាមួយសមាជិកក្នុងវួដ |
| **ផែនការណ៍នៃសេចក្ដីសង្គ្រោះ** | | | ប្រតិបត្តិតាមពាក្យគតិបណ្ឌិត | | | | | កាន់តាមក្រឹត្យវិន័យដប់ប្រការ |
| ជីវិតមុនឆាកជីវិតនេះ | | | គោរពតាមច្បាប់ដង្វាយមួយភាគក្នុងដប់ | | | | | រស់នៅតាមច្បាប់ព្រហ្មចារីភាព |
| ការបង្ករបង្កើត | | | គោរពប្រតិបត្តិតាមច្បាប់ តមអាហារ | | | | | រស់នៅតាមពាក្យប្រាជ្ញាវាងវៃ |
| សេរីភាព និងការធ្លាក | | | របៀបធ្វើឱ្យបរិច្ចាកដង្វាយមួយភាគក្នុងដប់ និងតមអាហារ | | | | | រស់នៅតាមច្បាប់ដង្វាយមួយភាគក្នុងដប |
| ជីវិតរបស់យើងនៅលើផែនដ | | | ប្រតិបត្តិ និងគោរពតាមក្រឹត្យវិន័យ | | | | | រស់នៅតាមច្បាប់តមអាហារ |
| ដង្វាយធួន | | | **ច្បាប់ និងពិធីការផ្សេងៗ** | | | | | គោរពតាមច្បាប់រដ |
| ពិភពវិញ្ញាណ | | | បព្វជិតភាព និងអង្គការជំនួយទាំងឡាយ | | | | | ទទួលការសំភាសំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក |
| ការរស់ឡើងវិញ ការជំនុំជំរះ និងអមតភាព | | | កិច្ចការអ្នកផ្សព្វផ្សាយសាសនា | | | | | អញ្ជើញមិត្តភក្តិ និងក្រុមគ្រួសារចូលរួមពិធីបុណ្យជ្រមុជ និងពិធីបញ្ជាក់របស់ពួកគេ |
| នគរនៃភាពរុងរឿង | | | អាពាហ៍ពិពាហ៍ដ៏អស់កល្បជានិច្ច | | | | | ទទួលបុណ្យជ្រមុជទឹក និងទទួលពិធីបញ្ជាក់ |
| **ដំណឹងល្អនៃព្រះយេស៊ូវគ្រីស** | | | ព្រះវិហារបរិសុទ្ធ និងពង្សប្រវត | | | | | អាន និងសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនជារៀងរាល់ថ្ងៃ |
| ជំរះពីអំពើបាប | | | ការបំរើ | | | | | អាន និងសិក្សាព្រះគម្ពីរជាក្រុមគ្រួសាររៀងរាល់ថ្ងៃ |
| សេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស | | | ការបង្រៀន និងការសិក្សា | | | | | ធ្វើរាត្រីជួបជុំក្រុមគ្រួសាររាល់សប្ដាហ |
| ការកែប្រែចិត | | | ស៊ូទ្រាំដល់ទីបញ្ចប | | | | | ទទួលបព្វជិតភាព |
| ពិធីបុណ្យជ្រមុជទឹក ជាសេចក្ដីសញ្ញាទីមួយរបស់យើង | | | **រំលឹកសំណួរសំភាសន៍សំរាប់ពិធីបុណ្យជ្រមុជទឹក** | | | | | ទទួលមុខងារក្នុងសាសនាចក្រ |
| អំណោយទាននៃព្រះវិញ្ញាណបរិសុទ | | | | | | | | ចូលរួមក្នុងការ ធ្វើតំណាងពិធីបុណ្យជ្រមុជទឹក |
| ស៊ូទ្រាំរហូតដល់ទីបញ្ចប | | | | | | | | |

(សូមមើល ពត៌មានបន្ថែម ផ្នែកម្ខាងទៀតខាងក្រោយ)

© 2004 IRI. 7/04 7/04 បោះពុម្ពនៅសហរដ្ឋអាមេរិក។ 36987 258

*(ខាងមុខ)*

- កំណត់ហេតុនៃ ពេលដែលអ្នកបាន បង្រៀនគោលការណ៍ទាំងឡាយ ពីមេរៀនទាំង ប្រាំទីមួយៗ ហើយប្រសិនបើសមាជិក មានវត្តមាន នៅទីនោះ។ ផ្នែកនេះទុកអោយអ្នក សំរាប់ជាការ តាមដាន ដោយអាចប្រែប្រួលបាន ចំពោះអ្វីដែល អ្នកបង្រៀន ថ្វីបើអ្នកបានបង្រៀនគោល ការណ៍ ទាំងឡាយយ៉ាងណាក៏ដោយ។
- អ្នកអាចតាមដាន មេរៀនទាំងឡាយ ដែលបានបង្រៀនមុន ពេលពិធីបុណ្យជ្រមុជទឹក និងមេរៀនបាន បង្រៀនក្រោយ ពិធី បុណ្យជ្រមុជទឹក។
- កំណត់ហេតុស្ដីពីស្ថានភាពនៃការតាំង ចិត្ត ដែលសាសនាទាគន់ការីទាំងឡាយ ត្រូវតែរក្សាទុក។ នៅក្នុងផ្នែកនេះ អ្នកត្រូវកត់ត្រាពីកាលបរិច្ឆេទ ដែលអ្នក បានពង្រីកការអញ្ជើញ និងកត់សំគាល់ ថាតើពួកគេមានភាពមាំមួន ក្នុង ការរក្សាការ តាំងចិត្តដែរឬទេ។

កំណត់ចំណាំ

- ផ្ដោតទៅត្រង់កន្លែង ដែលអ្នករៀបរាប់ពីប្រវត្តិរបស់បុគ្គលម្នាក់ ឬគ្រួសារ។ សូមកុំរៀបរាប់អំពីចំណុច អវិជ្ជមាន ឬបទអត្ថាធិប្បាយផ្ទាល់ខ្លួន ក្នុងកំរិតមួយខ្ពស់ពេក។
- ផ្ដោតទៅត្រង់កន្លែង ដែលអ្នករៀបរាប់ពីព័ត៌មានសំខាន់ ដែលបានមកពី ការបង្រៀន។ អ្នកអាចបញ្ចូល ពីកង្វល់ ដែលពួក គេ បានលើកឡើង ការតាំងចិត្តទាំងឡាយ ដែលពួកគេបានពុះពារដើម្បីរក្សាទុកនោះ និងជោគជ័យនានា ដែលពួក គេបានទទួល តាមរយៈការអាន និងការអធិស្ឋាន។ អ្នកក៏អាចបញ្ជាក់ផងដែរ ប្រសិនបើពួកគេបានចូលរួមក្នុងព្រះវិហារ និងអ្វី ដែលពួកគេកំពុងអាននៅក្នុង ព្រះគម្ពីរមរមន។
- ផ្ដោតទៅត្រង់កន្លែង ដែលអ្នកអាចធ្វើការតាមដានលើការសួរសុខទុក្ខទាំងឡាយ ប្រសិនបើបុគ្គលម្នាក់ ឬគ្រួសារ ឈប់ចង់ដឹងពីសាសនាចក្រ។

ពេលកំណត់ហេតុបង្រៀន ត្រូវបានបង្កើតឡើង វាគួរតែបន្សល់ទុកនូវសៀវភៅតំបន់ រហូតដល់បុគ្គលម្នាក់ ឬគ្រួសារមានភាព សកម្មយ៉ាងពេញលេញនៅក្នុងសាសនាចក្រ ផ្លាស់ទីលំនៅ ឬទទួលមរណភាពនោះ។




(ខាងក្រោយ)




**កំណត់ហេតុស្ដីពីការរីកចំរើនៈ** កំណត់ហេតុនេះ អាចអោយអ្នកសង្ខេបពីការរីកចំរើនរបស់ សាសនាគន់ការី អ្នកផ្លាស់ប្រែគំនិតថ្មី និងសមាជិកទាំងឡាយ ដែលមិនសូវសកម្ម ដែលអ្នកកំពុងតែបង្រៀន។ ហើយវាក៏អនុញ្ញាតអោយអ្នកផងដែរ ដើម្បីរាយការណ៍ពីសញ្ញាណសំគាល់សំខាន់ៗ។ សូមប្រើប្រាស់វា ដើម្បីសំរបសំរួលកិច្ចប្រឹងប្រែងរបស់អ្នក ជាមួយអ្នកដឹកនាំវួដ និងសង្កាត់ ក្នុងការសំរបសំរួលជាមួយអ្នកផ្សព្វផ្សាយសាសនា និងកិច្ចប្រជុំក្រុមប្រឹក្សាវួដ។ អ្នកនឹងសំរួលកំណត់ហេតុនេះសារឡើងវិញ អំឡុងពេលសម័យប្រជុំផែនការប្រចាំសប្ដាហ៍របស់អ្នក ឬមុនពេលកិច្ចប្រជុំក្រុមប្រឹក្សាវួដ។ ប្រសិនបើអាចធ្វើទៅបាន សូមផ្ដល់កំណត់ហេតុនេះមួយច្បាប់ទៅអោយប៊ីស្សប អ្នកដឹកនាំបេសកកម្មក្នុងវួដ និងសមាជិកក្រុមប្រឹក្សាវួដដទៃទៀតនៅ រៀងរាល់សប្ដាហ៍ ឬកាន់តែញឹកញាប់កាន់តែប្រសើរ។ សូមធ្វើអោយប្រាកដថា អ្នកបានបញ្ចូលក្នុងបែបបទកំណត់ហេតុស្ដីពីការរីកចំរើន បានចប់សព្វគ្រប់ ត្រឹមត្រូវ និងបានសរសេរយ៉ាងស្អាត។ ការធ្វើបែបនេះ នឹងនាំឱ្យមានទំនុកចិត្តពីក្រុមប្រឹក្សាវួដ ចំពោះអ្នក។ សូមប្រើបញ្ជីរបាយការណ៍សង្ខេបដែលបានហៅចូល និងរបាយការណ៍ប្រចាំសប្ដាហ៍របស់អ្នកផ្សព្វផ្សាយសាសនា ដើម្បីរាយការណ៍អំពីពិធីបុណ្យ

កំណត់ចំណាំ

ជ្រមុជទឹកសំរាប់សប្ដាហ៍ ដែលពួកគេបានមាន និងពិធីបញ្ជាក់សំរាប់សប្ដាហ៍ ដែលពួកគេបានមាន។ ផងដែរ សូមធ្វើការបញ្ជូនវាទៅឱ្យបានត្រឹមត្រូវ បំពេញបញ្ជីពិធីបុណ្យជ្រមុជទឹក ពីព្រោះកំណត់ហេតុសមាជិកភាពជាផ្លូវការ មិនត្រូវបានបង្កើតឡើងទេ រហូតដល់បេសកកម្មរាយការណ៍អំពីពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ទៅកាន់ទីស្នាក់ការសាសនាចក្រ។

**សាសនាគន់ការីដ៏មានសក្ដានុពលៈ** នេះជាបែបបទដែលអាចអោយអ្នករក្សាកំណត់ហេតុមួយរបស់មនុស្ស ដែលមានសក្ដានុពល ក្លាយជាសាសនាគន់ការី។

- ស្ថានភាពនៃសាសនាគន់ការីដ៏មានសក្ដានុពល។ (តើពួកគេត្រូវបានដកចេញហើយរឺ តើពួកគេកំពុងទទួលការបង្រៀនសព្វថ្ងៃនេះរឺ ឬតើអ្នកត្រូវធ្វើការតាមដានបន្ថែមដែររឺទេ?)
- ប្រសិនបើបុគ្គលនោះជាមនុស្សថ្មីដែលត្រូវទៅជួបឬស្វែងរកបានដោយអ្នកផ្សព្វផ្សាយសាសនា។
- កាលបរិច្ឆេទ ដែលបាន ទំនាក់ទំនងជាមួយបុគ្គលនោះ។
- បទអត្ថាធិប្បាយសំខាន់ៗ។




ចំលងជូននូវព័ត៌មានសំខាន់ៗ ក្នុងបែបបទសាសនាគន់ការីដ៏មានសក្ដានុពល ចេញពីផ្នែក "សាសនាគន់ការីដ៏មានសក្ដានុពល" នៃកាលវិភាគប្រចាំថ្ងៃរបស់អ្នកផ្សព្វផ្សាយសាសនា។ ប្រើប្រាស់ព័ត៌មាននេះ ដើម្បីដាក់ផែនការតាមដាន ការសួរសុខទុក្ខ រំលឹកដល់សមាជិកឡើងវិញពី កិច្ចការអ្នកផ្សព្វផ្សាយសាសនា ជាមួយនឹងអ្នកដឹកនាំបេសកកម្មក្នុងវួដ និងដាក់ផែនការ ធ្វើសកម្មភាពផ្សេងទៀត ដើម្បីអាចជួយពួកគេ ចាប់ផ្ដើមចង់ដឹងពី ដំណឹងល្អដែលបានស្ដារឡើងវិញ។ បែបបទនេះក៏ បំរើជា កំណត់ហេតុប្រវត្តិ សំរាប់អ្នកផ្សព្វផ្សាយសាសនាទាំងឡាយ ដែលបានចាត់តាំងទៅកាន់តំបន់មួយ នាពេលខាងមុខ ផងដែរ។ ពេលអ្នកត្រូវបានផ្លាស់ប្ដូរទៅកាន់តំបន់ផ្សេងទៀត សូមចំលងរាល់ព័ត៌មានទាំងអស់ ចេញពីកាលវិភាគ ប្រចាំថ្ងៃរបស់អ្នកផ្សព្វផ្សាយសាសនា ឱ្យបានច្បាស់លាស់។

**សេចក្ដីរាយការណ៍សង្ខេបតាមទូរស័ព្ទៈ** សូមប្រើប្រាស់របាយការណ៍នេះ ជាប្រចាំសប្ដាហ៍ ដើម្បីប្រមូលព័ត៌មានស្ដីអំពី សញ្ញាណ សំគាល់សំខាន់នីមួយៗ។ ចំពោះភាពជាដៃគូនីមួយៗ សូមប្រើប្រាស់សេចក្ដីរាយការណ៍សង្ខេបតាមទូរស័ព្ទ ដែលមាននៅខាងខ្នងនៃកាលវិភាគប្រចាំថ្ងៃរបស់អ្នកផ្សព្វផ្សាយសាសនារបស់ពួកគេ ដើម្បីផ្ដល់ពត៌មាននេះទៅអោយ អ្នកដឹកនាំមណ្ឌល។ អ្នកដឹកនាំ មណ្ឌលសរសេរឈ្មោះរបស់ដៃគូនីមួយៗ នៅក្នុងមណ្ឌលរបស់ខ្លួន ក្នុងសេចក្ដីរាយការណ៍សង្ខេបតាមទូរស័ព្ទ ជាមួយនឹងចំនួនសរុប ប្រចាំសប្ដាហ៍របស់ខ្លួន សំរាប់សញ្ញាណសំគាល់សំខាន់នីមួយៗ។ បន្ទាប់មក គាត់សរុបលទ្ធផលទាំងឡាយ សំរាប់មណ្ឌលនៅក្នុង ផ្នែកខាងក្រោម។ ពត៌មានបង្ហាញពីធំដល់តូច។ អ្នកដឹកនាំមណ្ឌលផ្ដល់ចំនួនសរុបក្នុងមណ្ឌល ទៅឱ្យអ្នកដឹកនាំហ្សូនរបស់ខ្លួន។ អ្នក ដឹកនាំហ្សូន ផ្ដល់ចំនួនសរុបក្នុងហ្សូនទៅឱ្យអ្នកជំនួយការប្រធាន។ អ្នកជំនួយការប្រធាន ផ្ដល់ចំនួនសរុបក្នុងបេសកកម្ម ទៅឱ្យ ប្រធានបេសកកម្ម។



កំណត់ចំណាំ

**កាលវិភាគប្រចាំថ្ងៃរបស់អ្នកផ្សព្វផ្សាយសាសនា** ឧបករណ៍នេះរួមមានលក្ខណៈពិសេសដូចខាងក្រោមនេះ៖

- រយៈពេលប្រាំមួយសប្ដាហ៍នៃ ការណាត់ជួបប្រចាំថ្ងៃ ជាមួយនឹងសប្ដាហ៍ទីប្រាំពីរ ដែលមាននៅក្នុងទំព័រឯកសារយោង។
- ទំព័រនានា សំរាប់គោលដៅប្រចាំសប្ដាហ៍។
- សេចក្ដីសង្ខេបនៃគំរោងផែនការនានា ជាបញ្ជីនៃព្រឹត្តការណ៍ ដែលនាំទៅរកពិធីបុណ្យជ្រមុជទឹក ពិធីបញ្ជាក់ និងសកម្មភាពនៅក្នុងសាសនាចក្រ គំរោងមេរៀនរបស់អ្នកផ្សព្វផ្សាយសាសនាទាំងឡាយ គំនិតទាំងឡាយ ក្នុងការស្វែងរក មនុស្សដើម្បីបង្រៀន និងសំនួរសម្ភាសន៍បុណ្យជ្រមុជទឹក។
- ផ្នែកសំរាប់ព័ត៌មានស្ដីពី ការទំនាក់ទំនង អាស័យដ្ឋាន និងលេខទូរស័ព្ទ របស់សាសនាគន់ការី និងសមាជិកទាំងឡាយ។
- សេចក្ដីរាយការណ៍សង្ខេបតាមទូរស័ព្ទ សំរាប់រក្សាការតាមដាន លើលទ្ធផលប្រចាំសប្ដាហ៍របស់អ្នក។

អំឡុងពេលក្នុង សម័យប្រជុំផែនការប្រចាំសប្ដាហ៍របស់អ្នក អ្នកនឹងសរសេរគោលដៅប្រចាំសប្ដាហ៍របស់អ្នក នៅលើទំព័រការដាក់គោលដៅប្រចាំសប្ដាហ៍ក្នុង កាលវិភាគប្រចាំថ្ងៃរបស់អ្នកផ្សព្វផ្សាយសាសនា ដូចដែលបានបញ្ជាក់ខាងក្រោមនេះ។

- គោលដៅប្រចាំសប្ដាហ៍ សំរាប់សញ្ញាណសំគាល់សំខាន់នីមួយៗ។
- លទ្ធផលពិតប្រាកដ សំរាប់សប្ដាហ៍។ លទ្ធផលទាំងឡាយសំរាប់ថ្ងៃនីមួយៗ ត្រូវបានបង្កើតឡើង នៅក្នុងកាលវិភាគ ប្រចាំថ្ងៃ។ ចំនួនសរុបសំរាប់សប្ដាហ៍នីមួយៗ ត្រូវបានផ្លាស់ប្ដូរនៅត្រង់នេះ។




- ចំនួនមនុស្ស ដែលទំនងជាអាចជួយអ្នក សំរេចគោលដៅរបស់អ្នកបាន (សាសនាគន់ការីដែលកំពុងតែរីកចំរើន សាសនាគន់ការីថ្មី)។ សូមដាក់គោលដៅ សំរាប់អ្វីដែលអ្នកសង្ឃឹមថា នឹងកើតឡើងជាមួយនឹងមនុស្សទាំងនេះ។ (ចូលរួមក្នុងព្រះវិហារ អានព្រះគម្ពីរមរមន ចុះកាលបរិច្ឆេទបុណ្យជ្រមុជទឹក និងផ្សេងៗទៀត។)។
- នៅកន្លែងចន្លោះ សរសេរពីគោលដៅផ្ទាល់ខ្លួន និងគោលដៅដទៃទៀតរបស់ដៃគូ។

កំណត់ចំណាំ

ក្នុងថ្ងៃនីមួយៗ ពេលអ្នកដាក់ផែនការ និងផ្សព្វផ្សាយ អ្នកនឹងប្រើប្រាស់កាលវិភាគប្រចាំថ្ងៃ ដូចដែលបានបញ្ជាក់ នៅខាងក្រោមនេះ៖

- កាលវិភាគប្រចាំថ្ងៃ នៅត្រង់កន្លែងដែលអ្នកអាចកត់ត្រា ចំពោះការណាត់ជួបការបង្រៀន កិច្ចប្រជុំ និងការស្វែងរកសកម្មភាពនានា។ ចូរដាក់ផែនការ ដើម្បីអោយអ្នកមានសកម្មភាពដ៏មានខ្លឹមសារ នៅគ្រប់ម៉ោងទាំងអស់ ក្នុងរយៈពេលមួយ ថ្ងៃ។ នៅកន្លែងចន្លោះក៏ត្រូវបានផ្តល់ផងដែរ សំរាប់ការដាក់ផែនការផ្លាស់ប្តូរ។
- នៅកន្លែងចន្លោះ ចុះបញ្ជីនូវកិច្ចការនានា ដែលអ្នកត្រូវធ្វើ (ការហៅទូរស័ព្ទ មនុស្សដែលត្រូវទាក់ទង ការរៀបចំមេរៀន ការតាមដានការតាំងចិត្ត និងផ្សេងៗទៀត។)។




- នៅកន្លែងចន្លោះ កត់ត្រាពីអ្វី ដែលអ្នកនឹងសិក្សា ពេលអ្នករៀបចំ សំរាប់ការណាត់ជួបបង្រៀន។
- គោលដៅប្រចាំថ្ងៃ និងលទ្ធផលពិតប្រាកដ សំរាប់សញ្ញាណសំគាល់សំខាន់ៗ ដែលបានជ្រើសរើស។

**របាយការណ៍ប្រចាំសប្តាហ៍អ្នកផ្សព្វផ្សាយសាសនា៖** របាយការណ៍នេះផ្តល់ឳកាសមួយដល់អ្នក ដើម្បីរៀបរាប់ដោយផ្ទាល់ទៅកាន់ ប្រធានបេសកកម្មរបស់អ្នក ស្តីអំពីកិច្ចប្រឹងប្រែងផ្សព្វផ្សាយសាសនារបស់អ្នក និងស្តីអំពីបញ្ហាផ្ទាល់ខ្លួនទាំងឡាយទៀត ដែលអ្នកចង់ចែកចាយ។ ពេលសរសេរលិខិតនេះ សូមមានភាពជាក់លាក់ និងចំណុច ប៉ុន្តែសូមកុំមានអារម្មណ៍ថា អ្នកត្រូវបំពេញគ្រប់ចន្លោះទាំងអស់។ មានតែគាត់ម្នាក់ប៉ុណ្ណោះ ដែលនឹងអានលិខិតនេះដូច្នេះសូមមានអារម្មណ៍ទូលាយក្នុងការបើកចំហ ពីយោបល់របស់អ្នក។



កំណត់ចំណាំ

## របៀបដើម្បីដាក់គោលដៅ

គោលដៅទាំងឡាយ ឆ្លុះបញ្ចាំងពីបំណងប្រាថ្នានៅក្នុងដួងចិត្ត និងទស្សនៈរបស់យើង ចំពោះអ្វីដែលយើងអាចសំរេចបាន។ តាមរយៈគោលដៅ និងផែនការ សេចក្ដីសង្ឃឹមរបស់យើង ត្រូវបានផ្លាស់ទ្រង់ទ្រាយ ទៅជាសកម្មភាពវិញ។ ការដាក់គោលដៅ និងការដាក់ផែនការ គឺជាទង្វើមួយនៃសេចក្ដីជំនឿ។ ចូរដាក់គោលដៅដោយសេចក្ដីអធិស្ឋាន ដើម្បីអោយ ស្របគ្នាជាមួយនឹងសេចក្ដីបង្គាប់នៃព្រះអង្គសង្គ្រោះ ដើម្បី "ចូរទៅបញ្ចុះបញ្ចូលអោយមានសិស្ស នៅគ្រប់ទាំងសាសន៍ ព្រមទាំង ធ្វើបុណ្យជ្រមុជទឹកអោយ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ" (ម៉ាថាយ 28:19)។

> *"ខ្ញុំត្រូវបានធ្វើអោយជឿ យ៉ាងខ្លាំងថា ប្រសិនបើយើងមិនដាក់គោលដៅ នៅក្នុងជីវិតរបស់យើង និងរៀនពីរបៀបដើម្បីធ្វើជា ម្ចាស់ការ ក្នុងការរស់នៅដើម្បីសំរេចគោលដៅនានារបស់យើងនោះទេ យើងនឹងឆ្លងចូលវ័យចំណាស់ ហើយសំលឹងមើលពីជីវិតរបស់យើងមកខាងក្រោយ ត្រឹមតែបានឃើញថា យើងបានសំរេចមែន តែជាផ្នែកតូចៗនៃ សក្ដានុពលដ៏ពេញលេញ របស់យើង។ ពេលមនុស្សម្នាក់រៀនដើម្បី ស្ទាត់ជំនាញលើគោលការណ៍ទាំងឡាយនៃការដាក់គោលដៅ បន្ទាប់មកគាត់មានលទ្ធភាពអាចបង្កើតភាពខុសប្លែកពីគ្នា យ៉ាងអស្ចារ្យ ចំពោះផ្លែផ្កាដែលគាត់បានទទួល នៅក្នុងជីវិតរបស់គាត់។ "*
>
> — អែលឌើរ អេម. រ៉ាស់សល បាឡ្លាត
>
> សុន្ទរកថា ចែកផ្ដល់ទៅកាន់ យុវជនយុវនារី តំបន់សល ឡេក ថ្ងៃទី 18 ខែតុលា ឆ្នាំ 1981

ចូរដាក់គោលដៅសំរាប់សញ្ញាណសំគាល់សំខាន់នីមួយៗ។ អ្នកក៏អាចដាក់គោលដៅផងដែរ សំរាប់ការអភិវឌ្ឍន៍ផ្ទាល់ខ្លួនរបស់អ្នក។ ធ្វើអ្វីៗគ្រប់យ៉ាងក្នុងអំណាចរបស់អ្នក ដើម្បីសំរេចគោលដៅរបស់អ្នក ដោយគោរពចំពោះសេរីភាពក្នុងការជ្រើសរើស របស់អ្នក ដទៃ។ រង្វាស់នៃជោគជ័យនៅទីបំផុតនោះ មិនមែនគ្រាន់តែជាការសំរេចគោលដៅ តែប៉ុណ្ណោះនោះទេ តែស្ថិតក្នុងការបំរើ ដែល អ្នកបានចែកផ្ដល់អោយ និងការរីកចំរើនរបស់អ្នកដទៃ។ គោលដៅគឺជាខ្លឹមសារមួយ ក្នុងការជួយអ្នកនាំយកសេចក្ដីល្អយ៉ាងច្រើន ទៅក្នុងចំណោមកូនចៅនៃព្រះវរបិតាសួគ៌។ វាមិនមែនគ្រាន់តែយកមកប្រើ ដើម្បីទទួលយកនូវការទទួលស្គាល់នោះទេ។

ចូរពិចារណាយ៉ាងប្រុងប្រយ័ត្ន ចំពោះគោលដៅទាំងឡាយ ដែលនឹងផ្ដល់នូវការណែនាំយ៉ាងច្បាស់ដល់អ្នក ហើយនឹងជួយអ្នកបំពេញសកម្មភាពនានា ដែលនឹងជួយពង្រឹងដល់សេចក្ដីជំនឿរបស់ពួកគេ ចំពោះព្រះអង្គសង្គ្រោះ និងចំរើនឡើងឆ្ពោះទៅកាន់ ពិធីបុណ្យជ្រមុជទឹក ពិធីបញ្ជាក់ និងចូលរួមនៅគ្រប់សកម្មភាព នៅក្នុងសាសនាចក្រ។ គោលដៅដ៏លំបាកទាំងឡាយ នឹងជួយអ្នក ធ្វើកិច្ចការយ៉ាងមានប្រសិទ្ធិភាព ហើយនាំឱ្យអ្នកសំរេចបាន និងរីកចំរើន។ សូមធ្វើតាមការណែនាំ ខាងក្រោមនេះ ពេលអ្នក ដាក់គោលដៅទាំងឡាយៈ

- ធ្វើតាមព្រះវិញ្ញាណ។
- ផ្ដោតយកចិត្តទុកដាក់ ទៅលើសញ្ញាណសំគាល់សំខាន់ៗ។
- ផ្ដោតយកចិត្តទុកដាក់លើមនុស្ស។ ទោះបីជាអ្នកនឹងប្រើប្រាស់ស្ថិតិ ដែលអាចគាំទ្រដល់ចំនួនយ៉ាងច្រើនរបស់អ្នក ជាមួយនឹងឈ្មោះរបស់មនុស្សទាំងឡាយ នៅកន្លែងណាដែលអាចប្រព្រឹត្តទៅបានក៏ដោយ។
- សូមមានភាពជាក់លាក់ និងប្រាកដប្រជា តែសូមដាក់គោលដៅដែលអាចអោយអ្នកសំរេចបាន។
- ចូរដាក់គោលដៅប្រចាំថ្ងៃ និងប្រចាំសប្ដាហ៍។
- ចូរដាក់គោលដៅសិក្សាផ្ទាល់ខ្លួន និងការសិក្សាជាមួយដៃគូ រួមទាំងការសិក្សាភាសា ប្រសិនបើអ្នកនឹងសិក្សាភាសា ផ្សេងទៀតនោះ។
- ចូរវាស់ពីការរីកចំរើនរបស់អ្នក នៅរៀងរាល់ថ្ងៃ រៀងរាល់សប្ដាហ៍ និងបន្ទាប់ពីអំឡុងពេល ទាំងប្រាំមួយសប្ដាហ៍ នីមួយៗ។ ពេលគោលដៅអ្នកមិនទទួលបានលទ្ធផលវាយតំលៃ ពីកិច្ចប្រឹងប្រែងរបស់អ្នក ហើយស្វែងរកមធ្យោបាយទាំងឡាយ ដើម្បីសំរេចគោលដៅនោះ។ ប្រសិនបើចាំបាច់ សូមផ្លាស់ប្ដូរការរំពឹងទុករបស់អ្នក។

ប្រធានបេសកកម្មរបស់អ្នក អាចបង្កើតបទដ្ឋានដ៏ល្អឥតខ្ចោះ ឬគោលដៅបេសកកម្ម ដោយមានគោលបំណងលើកស្ទួយគោលដៅរបស់អ្នក ហើយបង្កើនដល់សេចក្ដីជំនឿរបស់អ្នក។ បទដ្ឋានមណ្ឌល ហ្សូន និងបេសកកម្ម នឹងជួយអោយអ្នករីកចំរើន ធ្វើការយ៉ាងមានប្រសិទ្ធិភាព ហើយសំរេចបាននូវការបំពេញកិច្ចការ ក្នុងកំរិតមួយយ៉ាងខ្ពស់។ វាមិនមែនត្រូវយកមកប្រើជារូបមន្តដែលតំរូវជាចាំបាច់ នូវគោលដៅជាក់លាក់ចំពោះអ្នក និងដៃគូរបស់អ្នកនោះទេ។

កំណត់ចំណាំ

### សកម្មភាពៈ ការសិក្សាជាមួយដៃគូ

សូមដាក់គោលដៅប្រចាំសប្តាហ៍សំរាប់សញ្ញាណសំគាល់នីមួយៗ។ ចំពោះគោលដៅនីមួយៗ សូមសួរខ្លួនរបស់អ្នកថាៈ

- តេមានឈ្មោះភ្ជាប់នឹងចំនួនលេខដែរឬទេ?
- តើគោលដៅនេះ ជាក់លាក់រឺទេ?
- តើគោលដៅនេះ ប្រាកដប្រជារឺទេ?
- តើគោលដៅនេះ នឹងអាចធ្វើអោយយើងសំរេចបានរឺទេ?
- តើយើងបានតាំងចិត្តចំពោះគោលដៅនេះទេ?

ចូរពិភាក្សានូវគោលដៅនីមួយៗ។ បើចាំបាច់ សូមកំណត់ពីរបៀបដែលអ្នកអាចសំរួលវាឡើងវិញ និងកំណត់ពីមូលហេតុ។

## សម័យប្រជុំផែនការប្រចាំសប្តាហ៍

បន្ទាប់ពីអ្នកបានដាក់គោលដៅទាំងឡាយ ចូរសំរេចចិត្តពីរបៀបដែលអ្នកនឹងសំរេចគោលដៅទាំងនោះ។ អ្នក និងដៃគូរបស់អ្នក គួរតែធ្វើសម័យប្រជុំផែនការប្រចាំសប្តាហ៍ នៅថ្ងៃមួយ និងនៅពេលមួយ ដែលមានប្រសិទ្ធិភាពតិចបំផុត ក្នុងការផ្សព្វផ្សាយ ដូចជាថ្ងៃព្រហស្បតិ៍ និងព្រឹកថ្ងៃសុក្រ។ ប្រធានបេសកកម្មរបស់អ្នក នឹងរៀបចំថ្ងៃមួយ និងពេលមួយ សំរាប់ការប្រជុំដាក់ ផែនការ ប្រចាំសប្តាហ៍។ ការដាក់ផែនការប្រចាំសប្តាហ៍នេះ អាចចំណាយពេលដល់ទៅ ពីរ ឬបីម៉ោង ដើម្បីបំពេញវា។

ការពិភាក្សារបស់អ្នក គួរតែផ្តោតទៅលើសេចក្តីត្រូវការរបស់មនុស្ស និងរបៀបដើម្បីជួយពួកគេរីកចំរើន។ នៅក្នុងអំឡុងពេល សម័យប្រជុំផែនការប្រចាំសប្តាហ៍ រំលឹកសារឡើងវិញ ពីគោលដៅមុន ហើយដាក់គោលដៅថ្មីសំរាប់សប្តាហ៍បន្ទាប់។ សូម ពិចារណាលើគ្រប់ទិដ្ឋភាព នៅក្នុងការផ្សព្វផ្សាយរបស់អ្នក។

នៅពេលល្ងាចថ្ងៃអាទិត្យ គឺជាពេលដែលបានផ្តល់អនុសាសន៍អោយ សំរាប់សេចក្តីរាយការណ៍តាមទូរស័ព្ទប្រចាំសប្តាហ៍។ សេចក្តីរាយការណ៍ពេលល្ងាចថ្ងៃអាទិត្យ ផ្តល់អោយនូវភាពត្រឹមត្រូវបំផុត និងស្ថានភាពដែលបានកំណត់ពេលឱ្យ របស់បេសកកម្ម ពីព្រោះពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ភាគច្រើន ប្រព្រឹត្តឡើងនៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ។

ដោយសារតែថ្ងៃ ដែលអ្នករៀបចំសម័យប្រជុំផែនការប្រចាំសប្តាហ៍របស់អ្នក ខុសគ្នាពីថ្ងៃរាយការណ៍ សូមគិតអំពី ការដាក់ផែនការប្រចាំថ្ងៃ ដោយមានរយៈពេល 10ថ្ងៃ។ ឧទាហរណ៍ ប្រសិនបើសម័យប្រជុំផែនការ ប្រចាំសប្តាហ៍របស់អ្នក ធ្វើនៅថ្ងៃព្រហស្បតិ៍ អ្នកនឹងរំលឹកសារឡើងវិញ នូវការរីកចំរើន ចំពោះគោលដៅរបស់អ្នក ដែលមានកន្លងមកក្នុងសប្តាហ៍នោះ ហើយអ្នកនឹងដាក់ផែនការចំពោះអ្វី ដែលអ្នកត្រូវធ្វើ ដើម្បីសំរេចគោលដៅទាំងនេះ តាមរយៈ ថ្ងៃអាទិត្យ។ បន្ទាប់មក ដាក់គោលដៅនានា និងធ្វើផែនការទាំងឡាយ សំរាប់សប្តាហ៍ក្រោយពីថ្ងៃច័ន្ទ ដល់ថ្ងៃអាទិត្យ។ នៅល្ងាចថ្ងៃអាទិត្យ អ្នកនឹងធ្វើការបូកសរុប និងរាយការណ៍ពីលទ្ធផលទាំងឡាយ សំរាប់សប្តាហ៍មុន ហើយអ្នកនឹងមានផែនការណ៍របស់អ្នករួចជា ស្រេច សំរាប់សប្តាហ៍បន្ទាប់។ ខាងក្រោមនេះគឺជាការរៀបរាប់ អំពីរបៀបណែនាំ ក្នុងការដាក់ផែនការ អនុវត្តចំពោះ សម័យប្រជុំ ផែនការប្រចាំសប្តាហ៍។

1. **អធិស្ឋានស្វែងរកការបំផុសគំនិត។** មុនពេលអ្នកចាប់ផ្តើម សូមអោយមានកាលវិភាគប្រចាំថ្ងៃរបស់អ្នកផ្សព្វផ្សាយសាសនា និងសៀវភៅតំបន់នៅក្បែរ។ ចាប់ផ្តើមសម័យប្រជុំផែនការរបស់អ្នក ជាមួយនឹងសេចក្តីអធិស្ឋាន។ ស្វែងរកការបំផុសគំនិត ពេលអ្នកពិភាក្សាពីសេចក្តីត្រូវការរបស់មនុស្ស ហើយដាក់ផែនការដើម្បីបំរើ និងជួយដល់ពួកគេ អោយរីកចំរើនក្នុងដំណឹងល្អ។ អធិស្ឋានអោយបានជាក់លាក់ សំរាប់សាសនាគន់ការីរបស់អ្នក។ ចូរមានសេចក្តីជំនឿ សូមសួរដល់ព្រះវរបិតាសួគ៌ ដើម្បីប្រទានពរ ជ័យដល់ពួកគេ ដើម្បីពួកគេទទួលបានចំលើយចំពោះការអធិស្ឋានរបស់ពួកគេ ដោយនូវបំណងមួយចូលរួមក្នុងព្រះវិហារ និងផ្សេងៗទៀត។

2. **ដាក់គោលដៅ និងផែនការ សំរាប់សាសនាគន់ការី ដើម្បីទទួលពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ នៅក្នុងសប្តាហ៍បន្ទាប់។** រំលឹកឡើងវិញ ចំពោះកំណត់ហេតុបង្រៀន សំរាប់មនុស្សម្នាក់ៗ ដែលត្រូវបានតាំងចិត្ត អោយទទួលបុណ្យ ជ្រមុជទឹក ឬទទួលពិធីបញ្ជាក់ នៅក្នុងសប្តាហ៍បន្ទាប់។ ពិភាក្សាពីការរៀបចំជួប ដែលអ្នកត្រូវធ្វើការសម្ភាសន៍ សំរាប់ពិធីបុណ្យ ជ្រមុជទឹក ការបំរើ និងការបញ្ជាក់ទាំងឡាយ។ ប្រើប្រាស់កំណត់ហេតុបង្រៀន ពិភាក្សាពីការតាំងចិត្តណាមួយ ដែលមនុស្សទាំង អស់នេះ កំពុងពុះពារជាមួយ និងរបៀបដែលអ្នកអាចជួយដល់ពួកគេបាន។ ដាក់ផែនការ ដើម្បីទាក់ទងជាប្រចាំថ្ងៃ ជាមួយពួកគេ។ ពិភាក្សាពីរបៀបដែលអ្នកអាចជួយដល់អ្នកដឹកនាំបេសកកម្មក្នុងវួដ សំរបសំរួលជាមួយប៊ីស្សប សំរាប់ការបញ្ជាក់ទាំងឡាយ របស់ពួកគេនៅក្នុងកិច្ចប្រជុំប្រសិទ្ធពរនំប៉័ង និងទឹក។

កំណត់ចំណាំ

3. **ដាក់គោលដៅ និងផែនការ សំរាប់សាសនាគន់ការី ដែលមានកាលបរិច្ឆេទបុណ្យជ្រមុជទឹក។** រំលឹកឡើងវិញនៅក្នុងកំណត់ហេតុបង្រៀន សំរាប់មនុស្សម្នាក់ៗ ដែលនឹងទទួលបុណ្យជ្រមុជទឹក នៅក្នុងសប្ដាហ៍បន្ទាប់។ ពិភាក្សាពី មេរៀនទាំងឡាយ ដែលអ្នកត្រូវបង្រៀនដល់ពួកគេ។ ចូរពិចារណាពីរបៀបដែលអ្នកអាចជួយពួកគេ រៀបចំសំរាប់ ពិធីបុណ្យ ជ្រមុជទឹក និងពិធីបញ្ជាក់។ ពិភាក្សាពី សាសនាគន់ការីទាំងឡាយ ដែលមិនទាន់បានទទួលបុណ្យជ្រមុជទឹក នៅថ្ងៃដែលបានណាត់ ជួបរបស់ពួកគេ។ ចូរពិចារណា និងពិភាក្សាយ៉ាងប្រុងប្រយ័ត្នអំពី សេចក្ដីត្រូវការរបស់ពួកគេ។ ដាក់គោលដៅថ្មី និងធ្វើផែនការ ទាំងឡាយ ដែលនឹងជួយអោយពួកគេរីកចំរើន ឆ្ពោះទៅកាន់ ថ្ងៃ និងពេលមួយយ៉ាងជាក់លាក់ ជាពេលដែលពួកគេអាចចូលទៅក្នុង សេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក និងទទួលពិធីការនៃពិធីបញ្ជាក់។ នៅក្នុងកំណត់ហេតុបង្រៀនរបស់អ្នក ធ្វើសញ្ញាសំគាល់ ដោយប្រើខ្មៅដៃ ពីគោលការណ៍ទាំងឡាយ ដែលអ្នកដាក់ផែនការបង្រៀន និងការតាំងចិត្តទាំងឡាយ ដែលអ្នកនឹងជួយអោយ ពួកគេរក្សាទុក។ ចូរកំណត់ពីអ្វីដែលអ្នកអាចធ្វើ ដើម្បីជួយពួកគេទទួលមេរៀនទាំងនេះ និងរក្សានូវការតាំងចិត្តទាំងនេះ។

4. **ដាក់គោលដៅ និងផែនការ ដើម្បីជួយដល់សាសនាគន់ការី ចូលរួមក្នុងកិច្ចប្រជុំប្រសិទ្ធពរនំប៉័ង និងទឹក។**
រំលឹកឡើងវិញនៅក្នុងកំណត់ហេតុបង្រៀន សំរាប់សាសនាគន់ការីម្នាក់ៗ ហើយពិភាក្សាពីការចូលរួមរបស់ពួកគេ នៅក្នុងកិច្ចប្រជុំប្រសិទ្ធពរនំប៉័ង និងទឹក។ ចំពោះសាសនាគន់ការីទាំងឡាយ ដែលចូលរួមក្នុងកិច្ចប្រជុំប្រសិទ្ធពរនំប៉័ង និងទឹកជាទៀងទាត់ ពិភាក្សាពីអ្វីដែលអ្នកត្រូវធ្វើដើម្បីជួយដល់ពួកគេ បន្តមានបទពិសោធន៍ខ្ពស់ឡើង ខាងវិញ្ញាណ។ ចំពោះអស់អ្នកដែលមិនធ្លាប់ចូលរួមក្នុងកិច្ចប្រជុំប្រសិទ្ធពរនំប៉័ង និងទឹក អ្នកដែលបានចូលរួមតែម្ដង ឬអ្នកដែលបានចូលរួមយូរៗម្ដង ចូរពិភាក្សាពីអ្វី ដែលអាចអោយពួកគេនៅតែបន្តមក។ ឧទាហរណ៍ ពួកគេអាចត្រូវការជំនួយ ក្នុងការធ្វើដំណើរ ពួកគេខ្លាច ឬមិនស្គាល់ការបំរើទាំងឡាយរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ ឬពួកគេធ្លាប់មានបទពិសោធន៍អវិជ្ជមាននៅក្នុងពេលអតីតកាល។ ពិភាក្សាពីអ្វី ដែលអ្នកអាចធ្វើដើម្បីជួយពួកគេយកឈ្នះលើឧបសគ្គទាំងនោះ។ ដាក់គោលដៅនានា សំរាប់សាសនាគន់ការីមួយចំនួន ដែលអ្នកដាក់ផែនការ ដើម្បីឱ្យចូលរួមក្នុងកិច្ចប្រជុំពិធីប្រសិទ្ធពរនំប៉័ង និងទឹកបន្ទាប់។ ដាក់ផែនការ អ្នកណាដែលនឹងត្រូវទៅយកមនុស្សទាំងនេះ ទៅកាន់ព្រះវិហារ អ្នកណានឹងទទួលរាក់ទាក់គាត់ ហើយអ្នកណានឹងអង្គុយជាមួយគាត់នៅក្នុងកិច្ចប្រជុំ។ ដាក់ផែនការដើម្បីទាក់ទងជាមួយ អ្នកដឹកនាំក្រុម និងអ្នកដឹកនាំអង្គការជំនួយ និងគ្រូបង្រៀនផ្សេងៗទៀត ដែលទទួលខុសត្រូវក្នុងថ្នាក់ ដែលសាសនាគន់ការី នឹងចូល រួមនោះ។ នៅក្នុងកំណត់ហេតុស្ដីពីការរីកចំរើន ចុះបញ្ជីនូវមធ្យោបាយទាំងឡាយ ដែលក្រុមប្រឹក្សាវួដ អាចជួយបាន។ ធ្វើផែនការទាំងឡាយ ចំពោះអ្វីដែលអ្នកត្រូវធ្វើនៅក្នុងថ្ងៃនីមួយៗ ក្នុងសប្ដាហ៍ ដើម្បីរៀបចំមនុស្សទាំងនេះឱ្យចូលរួម។



5. **ដាក់គោលដៅ និងផែនការ សំរាប់មេរៀន ដែលនឹងបង្រៀន ចំពោះសាសនាគន់ការី ដែលកំពុងរីកចំរើន។** រំលឹកឡើងវិញនៅក្នុងកំណត់ហេតុបង្រៀន សំរាប់សាសនាគន់ការីដែលកំពុងរីកចំរើន ដែលបានបង្រៀន ដែលមានវត្តមាន សមាជិក។ ពិភាក្សាពីរបៀបដែលអ្នកបានទទួលអារម្មណ៍ ថាពួកគេកំពុងតែទទួលសារលិខិត។ រំលឹកឡើងវិញនូវ ការតាំងចិត្ត និងព្រឹត្តការណ៍ទាំងឡាយ ក្នុងកំណត់ហេតុបង្រៀន ថាពួកគេកំពុងតែព្យាយាម ដើម្បីរក្សា និងបំពេញនោះ។ ពិភាក្សាពីរបៀបដើម្បីជួយដល់ សមាជិកក្នុងវួដ និងក្រុមប្រឹក្សាវួដអោយនៅតែពាក់ព័ន្ធ ជាមួយនឹង ការរីកចំរើនរបស់ពួកគេ។ ដាក់គោលដៅនានា សំរាប់មេរៀនទាំងឡាយ ដែលអ្នកនឹងបង្រៀន អ្នកនឹងជួយអោយពួកគេរក្សានូវ ការតាំងចិត្ត ជាពិសេសការចូលរួមក្នុងព្រះវិហារ និងបទពិសោធន៍សំខាន់ៗ ដែលអ្នកនឹងជួយពួកគេបានចូលរួមម្ដងហើយម្ដងទៀត នៅក្នុងសប្ដាហ៍បន្ទាប់ មួយចំនួនទៀត។

រំលឹកឡើងវិញនៅក្នុងកំណត់ហេតុបង្រៀន សំរាប់សាសនាគន់ការីម្នាក់ៗ ដែលកំពុងរីកចំរើន ដែលបានបង្រៀនដោយគ្មានវត្តមានសមាជិក។ សាសនាគន់ការីទាំងនេះ អាចជាមនុស្សដែលអ្នកបានស្វែងរក តាមរយៈកិច្ចប្រឹងប្រែងរបស់អ្នកផ្ទាល់។ ចូរពិភាក្សា ជាមួយអ្នកដឹកនាំបព្វជិតភាព ឬអ្នកដឹកនាំអង្គការជំនួយម្នាក់ណា ដែលអាចត្រូវបានអញ្ជើញ អោយធ្វើមិត្តភាពជាមួយពួកគេ។ រំលឹកមេរៀនទាំងឡាយសារឡើងវិញ ដែលអ្នកនឹងបង្រៀន និងការតាំងចិត្តទាំងឡាយ ដែលអ្នកនឹងជួយអោយពួកគេរក្សាទុក។ ដាក់គោលដៅ សំរាប់មេរៀនទាំងឡាយ ដែលអ្នកនឹងបង្រៀន របៀបដែលអ្នកនឹងពាក់ព័ន្ធជាមួយសមាជិក និងរបៀបដែលអ្នក នឹងជួយដល់សាសនាគន់ការីទាំងនេះចូលរួមក្នុង កិច្ចប្រជុំពិធីប្រសិទ្ធពរនំប៉័ង និងទឹក។ កត់ត្រាគោលដៅទាំងនេះ ក្នុងកំណត់ហេតុបង្រៀន ហើយធ្វើផែនការសំខាន់ៗ។

កំណត់ចំណាំ

6. **ដាក់គោលដៅ និងផែនការ សំរាប់មេរៀន ដែលនឹងត្រៀវរួចហើយ ចំពោះសាសនាគន់ការី ទាំងអស់ផ្សេងទៀត។** រំលឹកឡើងវិញនៅក្នុងកំណត់ហេតុបង្រៀន សំរាប់សាសនាគន់ការីម្នាក់ៗ ដែលមិនបានរីកចំរើន។ ពិភាក្សា ពីមូលហេតុ ដែល សាសនាគន់ការីម្នាក់ៗ មិនបានរក្សាការតាំងចិត្ត។ ពិភាក្សាពីរបៀបដែលអ្នកនឹងចូលរួមពាក់ព័ន្ធជាមួយ អ្នកដឹកនាំបព្វជិតភាព និងអ្នកដឹកនាំអង្គការជំនួយក្នុងការធ្វើមិត្តភាពជាមួយនឹង សាសនាគន់ការីទាំងនេះ។ ពិភាក្សាពីចំណុច ដូចៗគ្នា ដែលមាន ផ្តល់ជាយោបល់នៅក្នុង ជំហានទី 5។ ដាក់គោលដៅនានា និងដាក់ផែនការទាំងឡាយ ដើម្បីជួយដល់ មនុស្សទាំងនេះ បានរីកចំរើន។ ចូរសរសេរពីគោលដៅទាំងនេះ នៅក្នុងកំណត់ហេតុបង្រៀន។

7. **ដាក់គោលដៅ និងផែនការ ដើម្បីទាក់ទង និងបង្រៀនមនុស្សថ្មីដែលត្រូវទៅជួប ដែលបានទទួលពី សមាជិក សាសនាគន់ការី អ្នកមិនមែនជាសមាជិក និងទីស្នាក់ការសាសនាចក្រ។** រំលឹកឡើងវិញនូវបែបបទរបស់សាសនាគន់ការី ដ៏មានសក្តានុពល។ រំលឹកឡើងវិញចំពោះមនុស្សថ្មីដែលត្រូវទៅជួបទាំងអស់ ដែលអ្នកបានទទួល។ រំលឹកឡើងវិញនូវមនុស្សថ្មីដែលត្រូវទៅជួប ដែលអ្នកមិនទាន់បានទាក់ទងនៅឡើយ។ ដាក់គោលដៅ និងផែនការ ដើម្បីទំនាក់ទំនងមនុស្សថ្មីដែលត្រូវទៅជួបអោយបានច្រើនកាន់តែប្រសើរក្នុងអំឡុងពេលមួយសប្តាហ៍—ពោលគឺមនុស្សថ្មីដែលត្រូវទៅជួបទាំងអស់ ដែលមានការពេញចិត្ត។ មនុស្សថ្មីដែលត្រូវ ទៅជួបទាំងឡាយ ដែលបានមកពីទីស្នាក់ការសាសនាចក្រ គួរតែត្រូវបានទំនាក់ទំនងក្នុងរយៈពេល 24 ម៉ោង ប្រសិនបើអាច ធ្វើទៅបាន។ ពិភាក្សាពីរបៀបដែលអ្នកអាចស្គាល់មនុស្សម្នាក់ៗ និងក្រុមគ្រួសារនីមួយៗ និងសារលិខិតអ្វី ដែលអ្នកអាចយក ទៅបង្រៀន។ ប្រសិនបើមនុស្សថ្មីដែលត្រូវទៅជួបបានមកពី ទីស្នាក់ការ សាសនាចក្រ ចូរពិភាក្សាពីរបៀបដែលអ្នកនឹងបង្រៀន សារលិខិតដំណឹងល្អ ដោយប្រើប្រាស់ វីដេអូ សៀវភៅ ឬសំភារៈផ្សេងទៀត ដែលពួកគេបានស្នើសុំ។ សូមប្រាកដថា អ្នកមាន សំភារៈដែលពួកគេបានស្នើសុំ។ បើសមគួរ សូមទាក់ទងមនុស្សថ្មីដែលត្រូវទៅជួប តាមទូរស័ព្ទ និងធ្វើការណាត់ជួប។ ពិភាក្សា ពីអ្វីខ្លះ ដែលត្រូវតាមដានដែលអ្នកគួរធ្វើ។

8. **ដាក់គោលដៅ និងផែនការ ដើម្បីស្វែងរកមនុស្សថ្មីដែលត្រូវទៅជួប ឱ្យបានច្រើនបន្ថែមទៀត ដែលបានមកពីសមាជិក សាសនាគន់ការី និងអ្នកមិនមែនជាសមាជិក។** រកឱ្យឃើញ សមាជិកផ្សេងទៀត និងសាសនាគន់ការីទាំងឡាយ ដែលអ្នកអាចសួរសុខទុក្ខ ដោយការអធិស្ឋាន។ ដាក់ផែនការពីរបៀបមួយដែលអ្នកនឹងជួយឱ្យពួកគេ អញ្ជើញមិត្តភក្តិ និងសមាជិកគ្រួសារ របស់ពួកគេ សិក្សាពីដំណឹងល្អដែលបានស្តារឡើងវិញ។ ពិភាក្សាពីរបៀបមួយ ដែលអ្នកនឹងអញ្ជើញពួកគេ អោយចូលរួមក្នុង កិច្ចការអ្នកផ្សព្វផ្សាយសាសនា។ ធ្វើការណាត់ជួប និងធ្វើផែនការសំខាន់ៗ។

9. **ដាក់គោលដៅ និងធ្វើផែនការ សំរាប់មេរៀន ដែលអ្នកនឹងបង្រៀនដល់ អ្នកផ្លាស់ប្រែគំនិតថ្មី និងសមាជិកមិនសូវសកម្ម។** រំលឹកឡើងវិញនៅក្នុងកំណត់ហេតុបង្រៀនសំរាប់អ្នកផ្លាស់ប្រែគំនិតថ្មីម្នាក់ៗ និងសមាជិកមិនសូវសកម្ម ដែលអ្នកកំពុងបង្រៀន។ ដាក់គោលដៅ និងធ្វើផែនការសំរាប់មេរៀនទាំងឡាយ ដែលអ្នកនឹងបង្រៀន។ កំណត់ពីរបៀប ដែលអ្នកនឹងជួយមនុស្សទាំងនេះ អោយចូលរួមក្នុងកិច្ចប្រជុំប្រសិទ្ធពរនំបុ័ង និងទឹក និងរក្សាការតាំងចិត្តផ្សេងៗទៀត។

10. **ដាក់គោលដៅ និងធ្វើផែនការ ដើម្បីស្វែងរកសាសនាគន់ការីថ្មី។** រំលឹកឡើងវិញនូវកិច្ចប្រឹងប្រែងក្នុង សប្តាហ៍មុន ដើម្បីស្វែងរកសាសនាគន់ការីថ្មីតាមរយៈមនុស្សថ្មីដែលត្រូវទៅជួប ឱកាសបំរើនានា និងសកម្មភាពស្វែងរកផ្ទាល់ខ្លួន។ សំដៅចំពោះព័ត៌មាននៅក្នុងផ្នែក "សាសនគន់ការីដ៏មានសក្តានុពល" នៃសៀវភៅតំបន់របស់អ្នក។ ពិភាក្សាពីមូលហេតុ ដែលមនុស្សមួយចំនួនបានក្លាយជាសាសនាគន់ការីថ្មី ហើយខ្លះទៀតមិនទាន់បាន។ ដាក់គោលដៅសំរាប់ ចំនួនសាសនាគន់ការីថ្មី ប៉ុន្មាននាក់ ដែលអ្នកនឹងស្វែងរកនៅក្នុងសប្តាហ៍នេះ។ ធ្វើការបញ្ជាក់ចំពោះមនុស្ស ដែលទំនងជាចង់ក្លាយជាសាសនាគន់ការី។ ហើយក៏ធ្វើការបញ្ជាក់ផងដែរ ចំពោះសមាជិក និងជាផ្នែកនៃសមាជិកនៅក្នុងគ្រួសារ ដែលអ្នកចង់សួរសុខទុក្ខ មនុស្សថ្មីដែល ត្រូវទៅជួប ដែលត្រូវសួរសុខទុក្ខ និងឱកាសបំរើទាំងឡាយ ដែលអ្នកនឹងស្វែងរកបាន។ ចូរដាក់ផែនការ ឧបករណ៍ស្វែងរកណា មួយដែលអ្នកនឹងប្រើប្រាស់ ដូចជាៈ ខិតប័ណ្ណសំរាប់ចែកកាសែតវីដេអូ ឌីវីឌី ព្រះគម្ពីរ ឬកូនសៀវភៅស្តើងៗ។ ក៏ពិភាក្សា ផងដែរ កន្លែងណាដែលអ្នកនឹងទៅទាក់ទងជាមួយមនុស្ស តើចំនួនមនុស្សប៉ុន្មាននាក់ ដែលអ្នកនឹងទាក់ទងក្នុងថ្ងៃនីមួយៗ អ្នកនឹងសុំមនុស្ស ថ្មីដែលត្រូវទៅជួប ពីសាសនាគន់ការីទាំងឡាយ សាសនាគន់ការីមុន អ្នកនឹងធ្វើការសួរសុខទុក្ខ របៀបទាំងឡាយ ដែលក្រុមប្រឹក្សា វួដអាចជួយ និងមានផ្សេងៗទៀត។ សូមធ្វើផែនការច្បាស់លាស់ សំរាប់ថ្ងៃបន្ទាប់។ ប្រើប្រាស់ពេលដែលនៅសល់ទាំងអស់ ជាសកម្មភាពស្វែងរក ដែលនឹងជួយអ្នកសំរេចគោលដៅរបស់អ្នក។ ដាក់គោលដៅ និងដាក់ផែនការទាក់ទងទៅកាន់មនុស្សជាច្រើន ដូចដែលព្រះអម្ចាស់បានរៀបចំផ្លូវសំរាប់អ្នក។ ព្យាយាមជានិច្ចកាល ស្វែងរកមនុស្ស ដើម្បីបង្រៀន។

កំណត់ចំណាំ

11. **ដាក់ផែនការពីរបៀបដើម្បីធ្វើការជាមួយក្រុមប្រឹក្សាវួដ។** ប៊ីស្សុបគឺអ្នកដឹកនាំជាអធិបតី។ សូមគោរព និងផ្តល់កិត្តិយស ដល់សិទ្ធិអំណាចរបស់គាត់។ ស្ថិតក្រោមការដឹកនាំរបស់គាត់ រំលឹកឡើងវិញនូវ កំណត់ហេតុស្តីពីការរីកចំរើន ដែលបានប្រើនៅក្នុងកិច្ចប្រជុំសំរបសំរួលអ្នកផ្សព្វផ្សាយសាសនា ឬក្រុមប្រឹក្សាវួដ កាលពីមុន។ ពិភាក្សាពីការចាត់តាំងទាំងឡាយ ដែលអ្នកបានទទួលមកពីប៊ីស្សុប ឬអ្នកដឹកនាំបេសកកម្ម ហើយរាយការណ៍ ថាតើអ្នកបានបញ្ចប់វាហើយឬនៅ។ ពិភាក្សាពីរបៀប ដើម្បីចូលរួមពាក់ព័ន្ធជាមួយអ្នកដទៃ ដែលអាចជួយបាន ដូចជាៈ អ្នកដឹកនាំបេសកកម្មក្នុងវួដ អ្នកដឹកនាំបព្វជិតភាព និងអ្នកដឹកនាំអង្គការជំនួយ ហើយនឹងសមាជិកដទៃទៀត។ រៀបចំកំណត់ហេតុស្តីពីការរីកចំរើន យ៉ាងប្រុងប្រយ័ត្ន សំរាប់កិច្ចប្រជុំក្រុមប្រឹក្សា វួដលើកក្រោយ កិច្ចប្រជុំគណៈកម្មាធិកាប្រតិបត្តិបព្វជិតភាព ឬកិច្ចប្រជុំសំរបសំរួលអ្នកផ្សព្វផ្សាយសាសនា។ សូមធ្វើឱ្យ ប្រាកដថា វាត្រូវបានសរសេរយ៉ាងស្អាត ហើយអាចអានបាន។ ដាក់គោលដៅនានា និងធ្វើផែនការទាំងឡាយ ដើម្បីធ្វើការអោយស្របគ្នា ជាមួយនឹងអ្នកដឹកនាំវួដ។ ពេលណាអាចធ្វើទៅបាន សូមធ្វើកំណត់ហេតុស្តីពីការរីកចំរើនជាច្រើនច្បាប់ សំរាប់អ្នកដឹកនាំវួដ ដែលនឹងចូលរួម។

12. **ធ្វើកាលវិភាគសំរាប់កិច្ចប្រជុំដែល កើតឡើងឱ្យបានទៀងទាត់។** នៅក្នុងកាលវិភាគប្រចាំថ្ងៃរបស់អ្នកផ្សព្វផ្សាយសាសនា របស់អ្នក ធ្វើកាលវិភាគសំរាប់កិច្ចប្រជុំទាំងឡាយ ដែលកើតឡើងយ៉ាងទៀងទាត់ ដូចជាៈ ការប្រជុំមណ្ឌល សន្និសីទហ្សូន កិច្ចសម្ភាសន៍ និងកិច្ចប្រជុំនៅសាសនាចក្រ។ ពិភាក្សាពីការចាត់តាំងទាំងឡាយ ដែលអ្នកត្រូវបំពេញមុន ចំពោះកិច្ចប្រជុំណាមួយ ក្នុងចំណោមកិច្ចប្រជុំទាំងឡាយនេះ។ ហើយបន្ថែមវាចូលទៅក្នុងកំណត់សំគាល់របស់អ្នក ឬធ្វើបញ្ជី។

13. **ការវាយតំលៃក្នុងភាពជាដៃគូ។** នៅចុងបញ្ចប់នៃសម័យប្រជុំផែនការប្រចាំសប្តាហ៍របស់អ្នក សូមចែក ចាយគោលដៅសមរម្យទាំងឡាយជាមួយដៃគូរបស់អ្នក ហើយសុំអោយពួកគេជួយ បំពេញគោលដៅទាំងនេះ។ ពិភាក្សាពីកំឡាំង នៅក្នុង ភាពទំនាក់ទំនងរបស់អ្នកជាមួយដៃគូ។ ពិភាក្សាការលំបាកណាមួយ ដែលបង្អាក់ភាពជាដៃគូរបស់អ្នក ក្នុងការងារ សាមគ្គីភាព ឬបង្អាក់ក្នុងការគោរពច្បាប់។ ដោះស្រាយការលំបាកទាំងឡាយ។ ចែកចាយជាមួយដៃគូរបស់អ្នក ចំពោះអ្វីដែល អ្នកគិតថា ជាភាពខ្លាំងរបស់ពួកគេនោះ។ សុំអោយមានការផ្តល់ជាយោបល់ ស្តីពីរបៀបដែលអ្នក អាចកែលំអបាន។ បើចាំបាច់ ដាក់គោលដៅទាំងឡាយ ដែលនឹងកែលំអ ដល់ភាពទំនាក់ទំនងរបស់អ្នក។ បញ្ចប់ដោយការអធិស្ឋាន។

## សម័យប្រជុំផែនការរាល់ថ្ងៃ

ដឹកនាំសម័យប្រជុំផែនការ នៅចុងបញ្ចប់ ក្នុងថ្ងៃនីមួយៗ។ ប្រសិនបើអ្នកកំពុងបង្រៀនមេរៀនមួយ អ្នកអាចផ្សព្វផ្សាយ រហូតដល ម៉ោង 9:00 យប់។ មិនដូច្នោះអ្នកត្រូវត្រឡប់មកផ្ទះវិញនៅម៉ោង ៩ៈ៣០យប់ ហើយត្រូវរៀបចំសម័យប្រជុំ ផែនការប្រចាំថ្ងៃពីម៉ោង 9:00 ដល់ 9:30 យប់។ (ប្រធានបេសកកម្ម មានសិទ្ធិ អំណាចដើម្បីផ្លាស់ប្តូរកាលវិភាគ ស្របទៅនឹងស្ថានភាពនៅក្នុងតំបន់។) អនុវត្តគោលការណ៍ និងការណែនាំដូចគ្នានេះ នៅក្នុងសម័យប្រជុំផែនការប្រចាំថ្ងៃ ដែលអ្នកត្រូវធ្វើតាមសម័យប្រជុំប្រចាំសប្តាហ៍ ប៉ុន្តែក្នុងរបៀបមួយសាមញ្ញជាង។ សូមធ្វើការអធិស្ឋាន ពេលអ្នកពិភាក្សា ពីមេរៀនទាំងឡាយ ឬប្រធានបទទាំងឡាយ ដែលអ្នកអាចយកមកសិក្សា អំឡុងពេលការសិក្សាផ្ទាល់ខ្លួន និងការសិក្សាជាមួយដៃ គូ ដែលនឹងជួយដល់ផែនការរបស់អ្នក។ សរសេរប្រធានបទទាំងនេះ នៅកន្លែងចន្លោះ ដែលបានផ្តល់ជូននៅលើកាលវិភាគ ប្រចាំថ្ងៃ។ រំលឹកឡើងវិញកាលវិភាគ ប្រចាំថ្ងៃរបស់អ្នក។ ចូរមាននូវសកម្មភាពដ៏មានខ្លឹមសារត្រូវបានរៀបចំឡើង នៅគ្រប់ម៉ោង ទាំងអស់ ក្នុងរយៈពេលមួយថ្ងៃ។ អំឡុងពេលសម័យប្រជុំផែនការនៅយប់ថ្ងៃអាទិត្យ បូកសរុប និងបញ្ជូនសេចក្តីរាយការណ៍ សង្ខេបតាមទូរស័ព្ទ ប្រចាំសប្តាហ៍របស់អ្នក សូមសរសេរលិខិតប្រចាំសប្តាហ៍របស់អ្នក ទៅកាន់ប្រធានបេសកកម្ម ហើយធ្វើ គោលដៅរបស់អ្នក ជាចុងក្រោយ សំរាប់សប្តាហ៍បន្ទាប់។

មុនពេលចាកចេញពីផ្ទះរបស់អ្នក នៅថ្ងៃបន្ទាប់ សូមរំលឹកឡើងវិញពី គោលដៅ ផែនការ និងកាលវិភាគរបស់អ្នក។ ធ្វើការកែឡើងវិញ បើចាំបាច់។ អធិស្ឋានជានិច្ចកាលមុនពេលចាកចេញពីផ្ទះរបស់អ្នក។ អ្នកអាចប្រាប់ពីអ្វីដែលជាផែនការ យ៉ាងមានប្រសិទ្ធភាពរបស់អ្នក ដោយមិនចាំបាច់ត្រូវសួរអ្នកដទៃ “ឥឡូវនេះខ្ញុំគួរតែធ្វើអ្វីទៅ?”

កំណត់ចំណាំ

## ការទទួលខុសត្រូវ

> “នៅពេលការបំពេញកិច្ចការ ត្រូវបានវាស់វែង ការបំពេញកិច្ចការនោះ នឹងបានកែលំអឡើង។ ពេលការបំពេញកិច្ចការ ត្រូវបានវាស់វែង ហើយបានរាយការណ៍ នោះការកែលំអ កាន់តែមានសន្ទុះឡើងថែមទៀត។ ”
>
> — ប្រធាន ថូម៉ាស អេស. ម៉នសុន
> “THOU ART A TEACHER COME FROM GOD,” *IMPROVEMENT ERA*, ខែធ្នូ 1970, 101

គោលការណ៍នៃការទទួលខុសត្រូវគឺមានសារៈសំខាន់ខ្លាំងណាស់ នៅក្នុងផែនការដ៏នៅអស់កល្បជានិច្ចរបស់ព្រះ។ យើងទាំង អស់គ្នានឹងឈរនៅខាងមុខព្រះអម្ចាស់ នៅឯការជំនុំជំរះចុងក្រោយ ហើយផ្ដល់នូវការទទួលខុសត្រូវមួយ ចំពោះអ្វីដែលយើងបាន ធ្វើ ជាមួយនឹងឱកាសនានា ដែលទ្រង់បានប្រទានដល់យើងទាំងអស់គ្នា (សូមមើល អាលម៉ា 5:15–19 សូមមើល គ និង ស 137:9)។ មានច្រើនណាស់ ដែលអ្នកអាចរៀនស្ដីពីការទទួលខុសត្រូវ នៅក្នុងបេសកកម្មរបស់អ្នក ដែលផ្ដល់អត្ថប្រយោជន៍ ដល់អ្នកពេញមួយជីវិតរបស់អ្នក។ គោលការណ៍នៃការទទួលខុសត្រូវនឹងប្រសិទ្ធពរដល់អ្នក ប្រសិនបើអ្នកៈ

- យកចិត្តទុកដាក់ លើការដាក់គោលដៅ និងការដាក់ផែនការរបស់អ្នក ដោយមានគំនិតមួយ ដែលនឹងធ្វើអោយ អ្នកទទួលខុសត្រូវចំពោះកិច្ចប្រឹងប្រែងរបស់អ្នក ចំពោះអ្នកដឹកនាំបេសកកម្មរបស់អ្នក និងចំពោះព្រះអម្ចាស់ តាមរយៈការអធិស្ឋាន។
- ចូរទទួលអារម្មណ៍ក្នុងការទទួលខុសត្រូវផ្ទាល់ខ្លួន សំរាប់ការទុកចិត្តដ៏ពិសិដ្ឋ ដែលព្រះអម្ចាស់បានប្រទានដល់អ្នក។
- ចូរដាក់គោលដៅដែលមានសារៈប្រយោជន៍បំផុត។
- ចូរជ្រើសរើស ដើម្បីផ្ដួចផ្ដើមក្នុងការទទួលខុសត្រូវលើ កិច្ចការរបស់អ្នកចំពោះព្រះអម្ចាស់ និងចំពោះអ្នកដឹកនាំ បេសកកម្មរបស់អ្នក។ ចូរកុំរង់ចាំអោយគេសួរឡើយ។ កុំត្រូវអោយអ្នកដទៃ ធ្វើការតាមដានជាមួយអ្នកញឹកញាប់ពេក។ សូមមានបំណងប្រាថ្នាដើម្បីទទួលខុសត្រូវចំពោះការងាររបស់អ្នក។
- ទទួលយកនូវការទទួលខុសត្រូវ ចំពោះកិច្ចប្រឹងប្រែងរបស់អ្នក។ ចូរកុំបន្ទោសអ្នកដទៃ ចំពោះស្ថានភាពដ៏លំបាក ឬកង្វះខាតនៃការរីកចំរើន។
- ស្វះស្វែងដើម្បីរៀនសូត្រពីអ្នកដឹកនាំរបស់អ្នក និងអញ្ជើញពួកគេផ្ដល់ជាគំនិតយោបល់នូវរបៀប ដែលអ្នកអាច កែលំអបាន។
- ជំរុញចិត្តអោយធ្វើកិច្ចការ យ៉ាងអស់ពីសមត្ថភាព។

ការទទួលខុសត្រូវមិនមែន មានតែនៅពេល ចុងក្រោយបេសកកម្មរបស់អ្នកប៉ុណ្ណោះនោះទេ។ វាគឺជាគោលការណ៍ មួយដែលជះឥទ្ធិពលដល់របៀបមួយ ដែលអ្នកចាប់ផ្ដើម របៀបមួយដែលអ្នកគិត និងទទួលអារម្មណ៍អំពី ការទទួលខុសត្រូវចំពោះព្រះអម្ចាស់ ដែលបានប្រទានដល់អ្នក របៀបដែលអ្នកខិតជិតទៅរកការងាររបស់អ្នក ហើយអ្នកអាចស៊ូទ្រាំបានយ៉ាងល្អប៉ុណ្ណា។ ឥរិយាបទដែលអ្នកមានចំពោះបទពិសោធន៍ ក្នុងបេសកកម្មរបស់អ្នក គឺជាការឆ្លុះបញ្ចាំងពីសេចក្ដីស្រលាញ់របស់អ្នក ចំពោះព្រះវរបិតាសួគ៌របស់ អ្នក និងព្រះរាជបុត្រារបស់ទ្រង់ និងសេចក្ដីគោរពរបស់អ្នក ចំពោះបព្វជិតភាព។

ពេលអ្នកអធិស្ឋានផ្ទាល់ខ្លួន និងក្នុងភាពជាដៃគូរបស់អ្នក សូមស្វែងរកការបំផុសគំនិត ស្ដីពីអ្វី ដែលអ្នកគួរតែធ្វើក្នុងថ្ងៃនីមួយៗ។ ពេលអ្នកធ្វើតាមផែនការរបស់អ្នក សូមអធិស្ឋាន និងសូមដល់ព្រះអម្ចាស់ សំរាប់ជាការដឹកនាំ។ សូមអោយសេចក្ដីអធិស្ឋានមាននៅក្នុងដួងចិត្តរបស់អ្នក អស់ពេញមួយថ្ងៃ ដើម្បីព្រះវិញ្ញាណនឹងជួយអ្នកដឹង កន្លែងដែលត្រូវទៅ អ្វីដែលត្រូវធ្វើ និងអ្វីដែលត្រូវនិយាយ។ សូមសួរខ្លួនឯងថា “តើអ្វីខ្លះ ដែលខ្ញុំអាចធ្វើបានច្រើនជាងនេះ?” នៅក្នុងសេចក្ដីអធិស្ឋានរបស់អ្នក នៅចុងបញ្ចប់ ក្នុងរយៈពេលមួយថ្ងៃ សូមផ្ដល់នូវការទទួលខុសត្រូវចំពោះការងាររបស់អ្នក។

អ្នកនឹងផ្ដល់នូវការទទួលខុសត្រូវជារៀងរាល់សប្ដាហ៍ ដល់អ្នកដឹកនាំបេសកកម្មរបស់អ្នក ដោយប្រើសេចក្ដីរាយការណ៍សង្ខេបតាមទូរស័ព្ទ។ ប្រសិនបើអ្នកជាអ្នកដឹកនាំបេសកកម្ម អ្នកនឹងទទួលពត៌មាននេះ មកពីអ្នកផ្សព្វផ្សាយសាសនាដទៃទៀត។ បង្ហាញការចាប់អារម្មណ៍ នៅក្នុងជីវិតរបស់ពួកគេ និងនៅក្នុងជីវិតនៃអស់អ្នកដែលពួកគេបង្រៀន ជាជាងបង្ហាញការចាប់អារម្មណ៍ទៅលើចំនួនលេខ។ កុំប្រើប្រាស់បែបបទ ឬព័ត៌មានដែលអ្នកបានទទួល ជារបៀបគ្រប់គ្រង ឬដឹកនាំឡើយ។ ព័ត៌មាន ដែលអ្នកបានទទួលតាមរយៈបែបបទទាំងនេះ នឹងផ្ដល់ឱកាសដល់អ្នក ដើម្បីសរសើរដល់អ្នកផ្សព្វផ្សាយសាសនា ចំពោះការពលិកម្ម និងដើម្បីមើលឃើញពីឱកាសសំរាប់ការបណ្ដុះបណ្ដាលនាពេលអនាគត។

កំណត់ចំណាំ

## ការសិក្សាព្រះគម្ពីរ

**តើការទទួលខុសត្រូវ មានន័យយ៉ាងណាដែរ?**

សូមមើល គ និង ស 58:26–33 សូមមើល គ និង ស 101:78 អេសេគាល 33:1–6

**តើហេតុអ្វីបានជាសេរីភាពក្នុងការជ្រើសរើស មានសារៈសំខាន់ ចំពោះការទទួលខុសត្រូវ?**

នីហ្វៃទី 2 2:26–29 ហេលេមិន 14:30–31

**តើអ្នកផ្សព្វផ្សាយសាសនា និងអ្នកដឹកនាំបេសកកម្ម គួរតែធ្វើការរួមគ្នា ដោយរបៀបណា?**

សូមមើល គ និង ស 38:23–25 ហេព្រើរ 13:17–18

## ចូរចងចាំចំណុចនេះ

- ផ្ដោតយកចិត្តទុកដាក់ចំពោះកិច្ចប្រឹងប្រែង លើគោលបំណងរបស់អ្នក។
- ដាក់គោលដៅនានា ស្របទៅនឹងសញ្ញាណសំគាល់សំខាន់ៗ។
- អធិស្ឋានយ៉ាងមានអនុភាព ចំពោះគោលដៅនានា និងផែនការទាំងឡាយរបស់អ្នក។
- ប្រើប្រាស់សៀវភៅតំបន់ និងកាលវិភាគប្រចាំថ្ងៃរបស់អ្នកផ្សព្វផ្សាយសាសនា ដើម្បីជួយមនុស្សអភិវឌ្ឍន៍សេចក្ដីជំនឿ ប្រែចិត្ត ទទួលបុណ្យជ្រមុជទឹក ទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ និងការស៊ូទ្រាំរហូតដល់ទីបញ្ចប់។
- សំរាប់សញ្ញាណសំគាល់សំខាន់នីមួយៗ ដាក់គោលដៅនានា ដែលអាចជួយអ្នកសំរេចបាន អនុវត្តសេចក្ដីជំនឿ និងធ្វើកិច្ច ការយ៉ាងមានប្រសិទ្ធភាព។
- ដឹកនាំសម័យប្រជុំផែនការប្រចាំសប្ដាហ៍រាល់ថ្ងៃ និងផ្ដោតលើការជួយដល់អ្នកដទៃ អោយរីកចំរើនក្នុងដំណឹងល្អ។
- ទទួលខុសត្រូវចំពោះកិច្ចប្រឹងប្រែងរបស់អ្នក ចំពោះព្រះអម្ចាស់ និងចំពោះអ្នកដឹកនាំបេសកកម្ម។

កំណត់ចំណាំ

# គំនិតសំរាប់ការសិក្សា និងការអនុវត្ត

## ការសិក្សាផ្ទាល់ខ្លួន

- នៅក្នុងការសិក្សាអំពីទិន្នានុប្បវត្តិរបស់អ្នក សូមសរសេរចំលើយ មួយប្រយោគ ចំពោះសំនួរនីមួយៗ នៅក្នុង “ចូរពិចារណាចំណុចនេះ។”

- យកពេលមួយស្របក់ ហើយគិតពីថ្ងៃចុងក្រោយរបស់អ្នក នៅក្នុងបេសកកម្ម។ ពេលថ្ងៃនោះមកដល់៖
  - តើអ្នកចង់និយាយអំពីអ្វីខ្លះ ពេលអ្នកបានបញ្ចប់ធ្វើជា អ្នកផ្សព្វផ្សាយសាសនា?
  - តើអ្នកចង់ក្លាយជាអ្វី?
  - តើភាពខុសប្លែកអ្វីខ្លះ ដែលអ្នកចង់អោយអ្នកដទៃ កត់សំគាល់ពីអ្នក?

  នៅក្នុងការសិក្សាអំពីទិន្នានុប្បវត្តិរបស់អ្នក សូមសរសេរចំលើយ មួយប្រយោគចំពោះសំនួរនីមួយៗ។ កំណត់ពីអ្វីដែល អ្នកត្រូវធ្វើក្នុងពេលនេះ ដើម្បីចាំពីគោលដៅទាំងនេះ។ ចូរសរសេរផែនការដែលមកក្នុងគំនិត។

## ការសិក្សាជាមួយដៃគូ

- ប្រើប្រាស់សៀវភៅតំបន់ ឆ្លើយសំនួរដូចខាងក្រោម៖
  - តើរាល់កំណត់ហេតុថ្មីទាំងអស់ ត្រឹមត្រូវ និងស្រួលអានរឺទេ?
  - តើអ្នកផ្សព្វផ្សាយសាសនាថ្មី ទៅកាន់តំបន់អាចរំលឹកសារឡើងវិញ នូវសៀវភៅតំបន់ និងអាចដឹងពីកន្លែង ដែលមនុស្សរស់នៅ ការរីកចំរើនខាងវិញ្ញាណរបស់ពួកគេ ហើយនឹងអ្វីដែលជាសេចក្តីត្រូវការច្រើនទៀត ដែលត្រូវធ្វើអោយហើយ ក្នុងការជួយដល់ពួកគេរឺទេ?
  - តើអ្នកផ្សព្វផ្សាយសាសនាថ្មី ទៅកាន់តំបន់ទទួលផលប្រយោជន៍ ពីកិច្ចប្រឹងប្រែងរបស់អ្នក ក្នុងការរកសាសនា គន់ការីថ្មីរឺទេ?
  - ចូរទឹកស្រមៃថាអ្នក បង្ហាញក្នុងសៀវភៅតំបន់របស់អ្នក ចំពោះព្រះអម្ចាស់ ពេលអ្នកផ្តល់ការរ៉ាយរ៉ាប់មួយ អំពីរបៀបដែលអ្នក ទទួលខុសត្រូវនឹងខ្វល់ខ្វាយ ចំពោះមនុស្សនៅក្នុងតំបន់របស់អ្នក។ តើព្រះអម្ចាស់នឹងសព្វព្រះហឫទ័យចំពោះការ ខិតខំប្រឹងប្រែងរបស់អ្នក រឺទេ?

- ពិភាក្សាពីសាសនាគន់ការីថ្មីម្នាក់របស់អ្នក។ នៅក្នុងកាលវិភាគប្រចាំថ្ងៃរបស់អ្នកផ្សព្វផ្សាយសាសនារបស់អ្នក ដាក់នៅត្រង់ទំព័រដែលមានចំណងជើង “ព្រឹត្តិការណ៍ទាំងឡាយ ដែលនាំទៅរក ពិធីបុណ្យជ្រមុជទឹក ពិធីបញ្ជាក់ និងសកម្មភាពនៅក្នុងសាសនាចក្រ។” ជ្រើសរើសព្រឹត្តិការណ៍មួយ ហើយធ្វើបញ្ជីគ្រប់អ្វីៗទាំងអស់ ដែលអ្នកត្រូវធ្វើតាមរបៀបរៀបរយ ដើម្បីអោយព្រឹត្តិការណ៍នេះកើតឡើង។ ពិភាក្សាពីរបៀប ដែលអ្នកអាចដាក់ផែនការ ចំពោះកិច្ចការទាំងនេះ ដើម្បីអោយព្រឹត្តិការណ៍អាចកើតឡើង ក្នុងពេលដំបូងបង្អស់។

- ពិភាក្សាពីភាពស្រដៀងគ្នាដូចខាងក្រោម ជាមួយដៃគូរបស់អ្នក។ វាយតំលៃតើ “ខ្សែសន្ទូច” របស់អ្នក ស្ថិតនៅក្នុងទឹករាល់ថ្ងៃមានប្រវែងប៉ុន្មាន។

  “ក្នុងចំណោមយើងទាំងអស់គ្នា គ្មាននរណាម្នាក់ចង់ធ្វើជាអ្នកនេសាទ ដែលគិតថា គាត់បាននេសាទត្រីអស់ពេញ មួយថ្ងៃទេតាមការពិត គាត់បានចំណាយពេលភាគច្រើនបំផុតចុះទឹក និងឡើងពីទឹក ញាំអាហារថ្ងៃត្រង់ និងរអ៊ូរទាំចំពោះ ឧបករណ៍របស់គាត់នោះទេ។ ជោគជ័យក្នុងការនេសាទត្រី គឺសំដៅចំពោះ រយះពេលប៉ុន្មានដែលបាន ចំណាយពេលនៅក្នុងទឹក មិនមែនរយះពេលប៉ុន្មាន ដែលអ្នកនៅឆ្ងាយពីផ្ទះនោះទេ។ អ្នកនេសាទត្រីមួយចំនួន នៅឆ្ងាយពីផ្ទះអស់រយះពេលដប់ពីរម៉ោង ហើយចុះទឹកនេសាទត្រី បានតែដប់ម៉ោង។ អ្នកនេសាទត្រីខ្លះទៀត នៅឆ្ងាយពីផ្ទះអស់រយះពេលដប់ពីរម៉ោង ហើយចុះទឹក នេសាទត្រីបានត្រឹមតែពីរម៉ោងប៉ុណ្ណោះ។ ប្រភេទអ្នកនេសាទត្រីចុងក្រោយនេះ អាចឆ្ងល់ថា ហេតុអ្វីបានជាពួកគេ គ្មានជោគជ័យដូចអ្នកនេសាទត្រីដទៃទៀត។

  “គោលការណ៍ដូចគ្នានេះ អនុវត្តចំពោះអ្នកផ្សព្វផ្សាយសាសនាទាំងឡាយ ជាអ្នកដែលចៅហ្វាយបានហៅថា ‘អ្នកនេសាទមនុស្ស។’ អ្នកផ្សព្វផ្សាយសាសនាគួរចាប់ផ្តើមស្វែងរកមនុស្ស ដើម្បីបង្រៀន ក្នុងឱកាសដែលពួកគេចាក ចេញពីផ្ទះ” (ដាលីន អេច. អូកស៍ seminar for new mission presidents, ថ្ងៃទី 20 ខែមិថុនា 2000)។

កំណត់ចំណាំ

## ការប្រជុំមណ្ឌល និងសន្និសីទហ្សូន

- សូមអានទូវស្ថានភាពមួយខាងក្រោមទៅកាន់ អ្នកផ្សព្វផ្សាយសាសនា។ នៅក្នុងក្រុមតូចៗ អោយអ្នកផ្សព្វផ្សាយសាសនាពិភាក្សាពីគោលដៅ និងផែនការនានា ដើម្បីជួយដល់មនុស្ស នៅក្នុងគំរូទាំងនេះ ដើម្បីរីកចំរើនឆ្ពោះទៅដល់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។ អោយក្រុមនីមួយៗចែកចាយពីគំនិតរបស់ពួកគេ។

  *ស្ថានភាពទីមួយៈ* អ្នកបានជួប ឡារី និងបែត កាលពីពួកគេបានបំរើនៅទីកន្លែងផ្តល់ ចំណីអាហារដល់អ្នកក្រីក្រ។ អ្នកបានបង្រៀនមួយមេរៀនដល់ពួកគេ ហើយឥឡូវនេះ ពួកគេចង់ដឹងច្រើនថែមទៀត។ ពួកគេមិនស្គាល់សមាជិក ម្នាក់ឡើយនៅក្នុងសាសនាចក្រ។ បែត គឺជាគ្រីស្ទាន ហើយឡារីមិនកាន់យកសាសនាណាមួយពិតប្រាកដឡើយ។ ពួកគេពុំទាន់បានរៀបការ តែពួកគេបានរស់នៅជាមួយគ្នា។ ឡារីធ្វើការពីម៉ោង 4:00 រសៀល ដល់ម៉ោង 12:00 ពាក់កណ្តាលអាធ្រាត្រ។ បែត ធ្វើការជាច្រើន ម៉ោងនៅពេលថ្ងៃ។

  *ស្ថានភាពទីពីរៈ* ស្ទីវ បានរៀនគ្រប់មេរៀនទាំងអស់ ហើយបានចូលរួមក្នុងព្រះវិហារ យ៉ាងហោចណាស់ពីរដង ក្នុងមួយខែ ។ គាត់បានជឿថា យ៉ូសែប ស្ម៊ីធគឺជាព្យាការី ហើយថាព្រះគម្ពីរមរមនពិត។ សមាជិកគ្រួសាររបស់គាត់ជឿស៊ុបចំពោះសាសនាកាតូលិក ហើយមិនអនុញ្ញាតអោយគាត់ ជួបជាមួយអ្នកផ្សព្វផ្សាយសាសនាឡើយ។

  *ស្ថានភាពទីបីៈ* ជៀល គឺជាសិស្សអនុវិទ្យាល័យ។ គាត់មានមិត្តភក្តិម្នាក់ដែលជាសមាជិករបស់សាសនាចក្រ។ មិត្តភក្តិដែលជាសមាជិក របស់នាងបានអញ្ជើញនាងជួបជាមួយអ្នក។ អ្នកបានបង្រៀនពីរមេរៀនដល់នាង។ មិត្តភក្តិដែលជា សមាជិករបស់នាងបានចូលរួមទាំងពីរមេរៀន។ នាងមិនទាន់បានចូលរួមក្នុងសាសនាចក្រនៅឡើយ ហើយជាប់មមាញឹកយ៉ាង ខ្លាំងនឹងកិច្ចការសាលារបស់នាង ដែលវាមានការលំបាកចំពោះនាង ក្នុងការអានព្រះគម្ពីរមរមន។

- អញ្ជើញអ្នកផ្សព្វផ្សាយសាសនាចែកចាយបទពិសោធន៍នៅទីកន្លែងណាមួយ តាមរយៈការដាក់គោលដៅ និងការធ្វើ ផែនការ ពួកគេមានលទ្ធភាពអាចជួយដល់មនុស្សបានៈ

  – អភិវឌ្ឍន៍សេចក្តីជំនឿឱ្យធំជាង ចំពោះព្រះអង្គសង្គ្រោះ។

  – ប្រែចិត្ត ហើយធ្វើការផ្លាស់ប្តូរ ដើម្បីបាននាំពួកគេ អោយមកជិតព្រះ។

  – ទទួលសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។

  – ត្រឡប់មកកាន់សាសនាចក្រវិញ ហើយរំលឹកឡើងវិញ នូវសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹក។

- ចែកអ្នកផ្សព្វផ្សាយសាសនាជាបីក្រុម។ ចូរពន្យល់ថា ក្រុមនីមួយៗនឹងទទួលការចាត់តាំងដ៏សំខាន់។ បន្ទាប់មក ផ្តល់កិច្ចការមួយខាងក្រោមនេះ ដល់ក្រុមនីមួយៗៈ

  – បើកតំបន់ផ្សព្វផ្សាយថ្មី។

  – រៀបចំសម័យប្រជុំបណ្តុះបណ្តាល ក្នុងសន្និសីទហ្សូន ពីការណែនាំពីព្រះគម្ពីរមរមន ដល់សាសនាគន់ការី។

  – បញ្ចូលគ្រួសារដែលជាសាសនាគន់ការី ទៅក្នុងវួដ។ គ្រួសារមានកូនបីនាក់ៈ កូនស្រី អាយុ 8 ឆ្នាំ កូនស្រីអាយុ 12 ឆ្នាំ និងកូនប្រុសអាយុ 16ឆ្នាំ។

  ប្រាប់ដល់ អ្នកផ្សព្វផ្សាយសាសនាទាំងឡាយ ថាពួកគេមានរយៈពេលប្រាំបីនាទី ដើម្បីបណ្តុះផែនការមួយឡើង។ ក្នុងចំណោមអ្នកផ្សព្វផ្សាយសាសនាទាំងឡាយ អ្នកផ្សព្វផ្សាយសាសនាម្នាក់គួរតែកត់ទុក នូវផែនការ រួមទាំងសកម្មភាពប្រចាំថ្ងៃនានា។

  អោយក្រុមនីមួយៗឧទ្ទេសនាមពីផែនការរបស់ខ្លួន។ បន្ទាប់ពីការឧទ្ទេសនាមចប់ សូមសួរៈ

  – តើអ្នកផ្សព្វផ្សាយសាសនាត្រូវដឹងអ្វីខ្លះ នៅក្នុងស្ថានភាពនីមួយៗ?

  – តើអាចមានផ្លែផ្កាអ្វីខ្លះ ប្រសិនបើអ្នកមិនដាក់ផែនការ សំរាប់សកម្មភាពទាំងឡាយដ៏មានខ្លឹមសារ ឬមិនដាក់ផែនការសោះ?

  ក្រោយពេលការឧទ្ទេសនាមទាំងអស់ចប់ សូមសួរៈ

  – តើការដាក់ផែនការ និងការដាក់គោលដៅ ជាអំពើនៃសេចក្តីស្រលាញ់ដោយរបៀបណា? អំពើនៃសេចក្តីជំនឿដោយរបៀបណា?

កំណត់ចំណាំ

## ប្រធានបេសកកម្ម

- សុំអោយអ្នកផ្សព្វផ្សាយសាសនានាំយក សៀវភៅតំបន់របស់ពួកគេ ទៅកាន់សន្និសីទហ្សូន ឬការសម្ភាសន៍។ លើសពីនោះទៀត ដើម្បីរំលឹកសារឡើងវិញពីសៀវភៅតំបន់ដោយខ្លួនរបស់អ្នក ពិចារណាការដែលមាន អ្នកដឹកនាំ បេសកកម្ម ឬក៏ភរិយារបស់អ្នករំលឹកពីសៀវភៅតំបន់សារឡើងវិញ។
- ត្រួតពិនិត្យយូរៗម្តង ចំពោះសម័យប្រជុំផែនការប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍របស់អ្នកផ្សព្វផ្សាយសាសនា។
- ធ្វើការសម្ភាសន៍យូរៗម្តង នៅក្នុងផ្ទះរបស់អ្នកផ្សព្វផ្សាយសាសនា។ ពេលអ្នកធ្វើយ៉ាងដូច្នោះ អោយភរិយាអ្នក ឬជំនួយការអ្នករំលឹកសារឡើងវិញ ពីសៀវភៅតំបន់របស់ អ្នកផ្សព្វផ្សាយសាសនា និងកាលវិភាគប្រចាំថ្ងៃ។
- ចូររំលឹកសារឡើងវិញ ពីកាលវិភាគប្រចាំថ្ងៃរបស់អ្នកផ្សព្វផ្សាយសាសនា អោយបានញឹកញាប់។
- ចូលរួមយូរៗម្តង ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាវួដ។



# តើខ្ញុំអាចស្វែងរកមនុស្ស ដើម្បីបង្រៀនដោយរបៀបណា?

កំណត់ចំណាំ

**ចូរពិចារណាចំណុចនេះ**

- តើពាក្យ “ស្វែងរកពួកគេដែលនឹងទទួលអ្នក”មានន័យយ៉ាងណា (គ និង ស 42:8)?
- តើខ្ញុំអាចពង្រីកសេចក្ដីជំនឿរបស់ខ្ញុំ ដើម្បីស្វែងរកអ្នករៀនមកបង្រៀនដោយរបៀបណា?
- តើហេតុអ្វីខ្ញុំត្រូវទំនាក់ទំនងជាមួយសមាជិកនៅក្នុងការខិតខំស្វែងរកមនុស្សរបស់ខ្ញុំ?
- តើការផ្សព្វផ្សាយ និងការឱ្យអ្នករៀនថ្មីដែលត្រូវទៅជួបមកពីទីស្នាក់ការសាសនាចក្រមានតួនាទីគឺជាអ្វី?
- តើការស្វែងរក និងការបង្រៀនមានទំនាក់ទំនងអ្វីខ្លះ?
- តើតួនាទីនៃការបំរើនៅក្នុងការស្វែងរកអ្នករៀន ដើម្បីបង្រៀនជាអ្វី?
- តើមានគំនិតសំរាប់ស្វែងរកអ្នករៀន ដើម្បីបង្រៀនណាខ្លះ ដែលខ្ញុំមិនទាន់បានសាកល្បងនៅឡើយនោះ?

## ការអភិវឌ្ឍន៍សេចក្ដីជំនឿ ដើម្បីស្វែងរក

គោលលទ្ធិ និងគោលការណ៍ទាំងឡាយ នៅក្នុងជំពូកនេះ នឹងជួយពង្រឹងសេចក្ដីជំនឿរបស់អ្នកថា ព្រះអម្ចាស់កំពុងរៀបចំមនុស្សឱ្យទទួលអ្នក និងដំណឹងល្អ ដែលបានស្ដារឡើងវិញ។ ទ្រង់នឹងដឹកនាំអ្នក ទៅរកពួកគេ ឬទ្រង់នឹងនាំពួកគេមករកអ្នក។ ការស្វែងរកមានភាពខុសគ្នា នៅកន្លែងផ្សេងៗនៃពិភពលោក។ អ្នកផ្សព្វផ្សាយសាសនា និងប្រធានបេសកកម្មទាំងឡាយ ត្រូវការធ្វើការសម្រួបទៅតាមកាលៈទេសៈ។ ថ្វីត្បិតតែផ្សេងៗគ្នាក៏ដោយ ក៏គោលការណ៍សំរាប់ការស្វែងរក គឺមានជាសកល។

**គ្រួសារនៃព្រះ។** មនុស្សទាំងអស់នៅលើផែនដីនេះ គឺជាសមាជិកនៃគ្រួសារនៃព្រះនៅក្នុងជីវិតមុនឆាកជីវិតនេះ (សូមមើល កិច្ចការពួកសាវក 17:26–29, ហេព្រើរ 12:9)។ យើងគឺជាចំណែកនៃគ្រួសារនៃព្រះនៅក្នុងជីវិតនេះ ហើយអាចសប្បាយ នឹងពរជ័យដ៏មហិមាដូចជាសមាជិកនៃគ្រួសាររបស់ទ្រង់នៅជីវិត ក្រោយ។ យើងទាំងអស់គ្នាជាបងប្អូនប្រុសស្រីនៅក្នុងគ្រួសារ នៃព្រះ។ ចំណេះដឹងនេះផ្ដល់ឱ្យយើងដឹងអំពីអត្តសញ្ញាណ និងកម្មសិទ្ធិ។ នេះផ្ដល់ឱ្យយើងនូវមូលហេតុ ដើម្បីមានសេចក្ដី សង្ឃឹមសំរាប់ ជីវិតដ៏នៅអស់កល្បជានិច្ច នៅក្នុងវត្តមានរបស់ព្រះ។ យើងដឹងអំពីមូលដ្ឋាននៃសេចក្ដីពិតទាំងនេះ ដោយសារតែ ការស្ដារឡើងវិញ។ ការបង្រៀនអំពីសេចក្ដីពិត ដែលបានស្ដារឡើងវិញចំពោះបងប្អូនប្រុសស្រីរបស់អ្នក គឺជាការទទួលខុសត្រូវ និងពរជ័យរបស់អ្នក។ ដូចជាអាលម៉ាព្យាយាមដើម្បីជួយដល់ពួកសាសន៍សូរាំ ដែលក្បត់សាសនា អ្នកក៏អាចអធិស្ឋានថា ៖“ ឱព្រះអម្ចាស់អើយ សូមព្រះអង្គ ប្រទានដល់យើងខ្ញុំ ឱ្យយើងខ្ញុំមានជ័យជំនះ ក្នុងការដឹកនាំពួកគេឱ្យមករកព្រះអង្គនៅក្នុង ព្រះគ្រីស្ទវិញចុះ។ មើលចុះ ឱព្រះអង្គ អើយ ព្រលឹងរបស់គេមានតម្លៃ . . . ហើយពួកគេជាច្រើន គឺជាបងប្អូនយើងខ្ញុំ ហេតុដូច្នេះ ឱព្រះអម្ចាស់អើយ សូមប្រទានអានុភាព និងប្រាជ្ញាដើម្បីយើងខ្ញុំអាចនាំបងប្អូនយើងទាំងនេះ មករកព្រះអង្គវិញ” (អាលម៉ា 31:34–35)។

© 1990 1990 Del Parson. ហាមថតចម្លង។

កំណត់ចំណាំ

**"ស្វែងរកពួកគេ ដែលនឹងទទួលអ្នក។"** អ្នកមានកាតព្វកិច្ច ក្នុងការជួយឱ្យសាសនាចក្រមានការរីកចំរើនឡើង ដោយការស្វែងរក "ពួកគេដែលនឹងទទួលអ្នក" (សូមមើលគ និង ស 42:8)។ អ្នកទាំងនោះនឹងដឹងថា អ្នកគឺជាអ្នកបំរើរបស់ព្រះអម្ចាស់។ ពួកគេនឹងយល់ព្រមធ្វើតាមសារលិខិតរបស់អ្នក។ មនុស្សទាំងនោះភាគច្រើន ត្រូវបានរារាំងពីសេចក្ដីពិត [តែម្យ៉ាងគត់] ពីព្រោះពួកគេមិនដឹងកន្លែង ដើម្បីស្វែងរកសេចក្ដីពិតប៉ុណ្ណោះ (សូមមើល គ និង ស 123:12)។

ជាធម្មតា អ្នកនឹងមិនដឹងថា មនុស្សទាំងនោះជានរណានោះទេ។ ពួកគេប្រហែលជាមិនស្គាល់អ្នកភ្លាមៗនោះទេ ថា អ្នកគឺជាអ្នកបំរើ របស់ព្រះអម្ចាស់។ ពួកគេប្រហែលជាមិនយល់ថា សេចក្ដីសុខសាន្តដ៏មហិមា ការដឹកនាំ និងគោលបំណងនៅ ក្នុងជីវិតនេះ នឹងមានមកតាមរយៈដំណឹងល្អ ដែលបានស្ដារឡើងវិញ ជាងអ្វីៗទាំងអស់នោះទេ។ ជារឿយៗ ពួកគេមិនដឹងថា ពួកគេកំពុងស្វែងរកដំណឹងល្អ ដែលបានស្ដារឡើងវិញទេ រហូតដល់ពួកគេបានរកឃើញ។ ឧទាហរណ៍ អ្នកផ្លាស់ប្រែគំនិតម្នាក់ និយាយថា "នៅពេលខ្ញុំឮអំពីដំណឹង ល្អ វាបានបំពេញចំណង់នៅក្នុងចិត្តរបស់ខ្ញុំ ដែលខ្ញុំមិនដឹងថាខ្ញុំមានសោះ។" ហើយអ្នកផ្សេងទៀតនិយាយថា៖ "ខ្ញុំបានបញ្ចប់ការស្រាវជ្រាវ ដោយខ្ញុំមិនដឹងថា ខ្ញុំបានស្រាវជ្រាវនោះទេ។"

កន្លែងណាក៏ដោយ ដែលអ្នកត្រូវបានចាត់ឱ្យទៅបំរើ ចូរចងចាំថា ព្រះអម្ចាស់បានអនុញ្ញាតឱ្យអ្នកមកបេសកកម្មរបស់អ្នក ក្នុងគោលបំណង ដើម្បីសង្គ្រោះព្រលឹងវិញ្ញាណ។ ចូរធ្វើការដោយមានប្រសិទ្ធភាព ដើម្បីបន្លឺសំលេងរបស់អ្នកចំពោះមនុស្ស ទាំងឡាយ។ ចូរនិយាយអំពីគំនិត ដែលព្រះអម្ចាស់ នឹងដាក់មកក្នុងដួងចិត្តរបស់អ្នក។ បើអ្នកធ្វើយ៉ាងនេះ នោះអ្នកនឹងទទួលបានសេចក្ដីសន្យា ដែលអ្នកនឹងមិនត្រូវបានបំភាន់នៅចំពោះមនុស្សឡើយ ហើយនឹងត្រូវផ្ដល់ដល់អ្នក នៅគ្រប់ពេលនូវអ្វី ដែលអ្នកគួរនិយាយ (សូមមើល គ និង ស 100:4–6)។ ការស្វែងរកដោយព្រះវិញ្ញាណ គឺមានសារៈសំខាន់ ដូចជាការបង្រៀនដោយព្រះវិញ្ញាណដែរ។ ដូចជា នៅក្នុងការបង្រៀន ការខិតខំរបស់អ្នកក្នុងការស្វែងរក នឹងមានប្រសិទ្ធភាព បើអ្នកត្រូវបានដឹកនាំដោយព្រះវិញ្ញាណ។ ត្រូវមានជំនឿថា អ្នកនឹងដឹងនូវអ្វី ដើម្បីបង្រៀន និងអ្វីត្រូវធ្វើ ដើម្បីស្វែងរក ជនទាំងឡាយណា ដែលនឹងទទួលអ្នក។

### សកម្មភាព៖ ការសិក្សាជាមួយដៃគូ

សមាជិកភាគច្រើន ដែលអ្នកជួបនោះ អាចជាអ្នកផ្លាស់ប្រែគំនិតមកក្នុងសាសនាចក្រ។ ចូររៀបចំពេលមួយ ដើម្បីសួរពួកគេអំពី របៀប ដែលពួកគេទាក់ទងនឹងសាសនាចក្រ និងរបៀបដែលពួកគេអាចដឹងថា អ្នកផ្សព្វផ្សាយសាសនា កំពុងបង្រៀនពួកគេពី សេចក្ដីពិត។ ចូរសង្ខេបអំពីបទពិសោធន៍របស់ពួកគេ នៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក។

### ការសិក្សាព្រះគម្ពីរ

**តើកូនចៅរបស់ព្រះ ត្រូវបានរៀបចំ និងដឹកនាំឱ្យមកកាន់ដំណឹងល្អ ដែលបានស្ដារឡើងវិញដោយរបៀបណា?**

| | | |
|---|---|---|
| អាលម៉ា 13:24 | គ និង ស 29:7 | គ និង ស 84:45–47, 88 |
| អាលម៉ា 16:16–17 | គ និង ស 33:6 | គ និង ស 136:32–33 |

## និយាយជាមួយមនុស្សគ្រប់គ្នា



នៅពេលព្យាការីយ៉ូសែប ស្ម៊ីធ ធ្វើដំណើរជាមួយអ្នកផ្សព្វផ្សាយសាសនាមួយក្រុម នៅលើទន្លេមិស្ស៊ូរី ព្រះអម្ចាស់ បានបើកបង្ហាញថា វាមិនចាំបាច់ . . . សំរាប់អែលឌើរ ផ្លាស់ប្ដូរយ៉ាងឆាប់រហ័សទេ នៅពេលដែលអ្នកស្រុកទាំងឡាយ មិនថាជានៅខាងណា កំពុងតែវិនាស ដោយការឥតជំនឿនោះ (សូមមើល គ និង ស 61:3)។ នៅពេលអ្នកផ្លាស់ប្ដូរយ៉ាង រហ័ស ដើម្បីធ្វើសកម្មភាព ដែលបានរៀបចំ ចូរអធិស្ឋានសុំឱ្យមានលទ្ធភាព ដើម្បីមើលឃើញពីឱកាស ដែលមិនបានរៀបចំទុក ដើម្បីបំរើ និងបង្រៀនអ្នកទាំងឡាយណា ដែលនឹងត្រូវ "វិនាសដោយការឥតជំនឿ។" ចូរអធិស្ឋាន ឱ្យមានការយល់ដឹង ខាងវិញ្ញាណ ដើម្បីដឹងពីឱកាសទាំងឡាយ។ អ្នកនឹងរកឃើញថា ព្រះដាក់កូនចៅរបស់ទ្រង់ ដែលបានរៀបចំឱ្យនៅលើផ្លូវរបស់អ្នក ដើម្បីទទួល យកដំណឹងល្អ ដែលបានស្ដារឡើង។

គ្មានអ្វីកើតឡើងនៅក្នុងកិច្ចការផ្សព្វផ្សាយសាសនាទេ រហូតទាល់តែអ្នកស្វែងរកនរណាម្នាក់បង្រៀន។ និយាយជាមួយមនុស្សឱ្យបានច្រើន តាមដែលអ្នកធ្វើបានរៀងរាល់ថ្ងៃ។ វាគឺជាធម្មជាតិ ឱ្យងាយយល់នូវអ្វីមួយ អំពីការនិយាយទៅកាន់មនុស្ស ប៉ុន្តែអ្នកអាចអធិស្ឋានសំរាប់សេចក្ដីជំនឿ និងកម្លាំង ដើម្បីកាន់តែមានភាពក្លាហាន នៅក្នុងការបើកមាត់របស់អ្នក ប្រកាសដំណឹងល្អ ដែលបានស្ដារឡើងវិញ។ ចូរសាកល្បងអនុវត្តតាមគំនិតដូចខាងក្រោម នៅពេលអ្នកស្វែងរក ដើម្បីនិយាយទៅកាន់មនុស្សគ្រប់គ្នា ដែលអ្នកជួបៈ

- និយាយជាមួយមនុស្សអំពីក្រុមគ្រួសាររបស់ពួកគេ។ សូមជួយពួកគេឱ្យមើលឃើញពីរបៀប ដែលដំណឹងល្អ ដែលបានស្ដារឡើងវិញអាចជាពរជ័យមួយ ចំពោះក្រុមគ្រួសាររបស់ពួកគេ។
- សូមរកមើលសញ្ញាបង្ហាញផ្សេងៗ—ដូចជាវត្ថុនៅក្នុងផ្ទះ ឬនៅបរិវេណផ្ទះ អក្សរនៅលើខោអាវ ឬការបញ្ជាក់ អំពីកូនចៅ—ដើម្បីជួយអ្នកដឹងពីរបៀប ដើម្បីចាប់ផ្ដើមនិយាយជាមួយពួកគេ។
- ចូរស្ដាប់ដោយយកចិត្តទុកដាក់ទៅលើអ្វី ដែលពួកគេនិយាយមកកាន់អ្នក។
- សូមឱ្យមានភាពកក់ក្ដៅ មិត្តភាព និងសប្បាយរីករាយ។ ផ្ដល់ឱ្យមានការជួយជ្រោមជ្រែង។
- ចូរទុកចិត្តទៅលើព្រះវិញ្ញាណ ដើម្បីដាក់នៅក្នុងចិត្តរបស់អ្នក និងគំនិតរបស់អ្នកនូវអ្វី ដែលត្រូវបង្រៀន។
- អញ្ជើញមនុស្សគ្រប់រូបឱ្យរៀនអំពីដំណឹងល្អ ដែលបានស្ដារឡើងវិញ។
- ចែកចាយកាត ដែលមានពត៌មានរបស់សាសនាចក្រ។
- សូមសួរឈ្មោះ មនុស្សដែលអ្នកស្គាល់ ដែលអាចចាប់អារម្មណ៍នៅក្នុងសារលិខិតរបស់អ្នក។

នៅពេលអ្នកអានដំណើររឿងពិតមួយ នៅខាងក្រោមនេះ សូមរកមើលពីរបៀប ដែលបុរសម្នាក់នេះ ត្រូវបានរៀបចំ ដើម្បីទទួលអ្នកផ្សព្វផ្សាយសាសនា និងរបៀប ដែលអ្នកផ្សព្វផ្សាយសាសនា បានប្រើឱកាស ដែលមិនបានគ្រោងទុក ដើម្បីបង្រៀនដល់ គាត់អំពីដំណឹងល្អ។

*កាលនៅក្មេង ខ្ញុំមិនដែលបានបង្រៀនឱ្យអានព្រះគម្ពីរបរិសុទ្ធនោះទេ។ ខ្ញុំបានទៅព្រះវិហារនៅថ្ងៃអាទិត្យ ប៉ុន្តែខ្ញុំ មិនបានបរិច្ចាគអ្វីទេ ហើយគ្មានអារម្មណ៍ថា នឹងត្រឡប់មកវិញដែរ។ ខ្ញុំបានស្រងាកចិត្តយ៉ាងខ្លាំងដោយសារសាសនារបស់ខ្ញុំ . . .។ ខ្ញុំ បានស្រាវជ្រាវរក . . . ព្រះ—ចង់ដឹង បើសិនជាទ្រង់ពិតជាមានមែន។ ខ្ញុំស្រេកឃ្លានចង់ដឹងអំពីទ្រង់ និងបន្ទូល របស់ទ្រង់។ ប៉ុន្តែខ្ញុំ ហាក់ដូចជាមិនអាចរកឃើញនូវអ្វី ដែលខ្ញុំស្វែងរកនោះទេ។*

*មានឱកាសជាច្រើន ដែលខ្ញុំមានអារម្មណ៍ថា ជិតនឹងរំងាប់ការស្រេកឃ្លានរបស់ខ្ញុំ។ នៅពេលខ្ញុំបីកូនស្រីទីមួយរបស់ខ្ញុំ នៅក្នុងដៃរបស់ខ្ញុំជាលើកទីមួយ ខ្ញុំមានអារម្មណ៍ថា ពិតជាមានព្រះមែន។ ជាច្រើនឆ្នាំក្រោយមក នៅពេលប្អូនស្រីរបស់នាង បានកើតមក ខ្ញុំមានបទពិសោធន៍ក្នុងអារម្មណ៍ដូចគ្នានេះដែរ . . .។ ទោះជាយ៉ាងណាក៏ដោយ ស្ទើរគ្រប់ពេលទាំងអស់ ភាពអស់កម្លាំង មានមកលើព្រលឹងខ្ញុំ ដែលមិនអាចពិពណ៌នាបាន។ ខ្ញុំមានសេចក្ដីស្រេកឃ្លានខាងព្រលឹងវិញ្ញាណ និងមិនអាចរកកន្លែង ដើម្បីបំបែតការស្រេកឃ្លានខាងវិញ្ញាណរបស់ខ្ញុំបានសោះ។*

*នៅខែមេសា ឆ្នាំ 1994 ខ្ញុំរស់នៅក្នុងទីក្រុងម៉ិនទែរី ប្រទេសម៉ិកស៊ិក របរចិញ្ចឹមជីវិតជាអ្នកបើកឡានតាក់ស៊ី។ នៅថ្ងៃ មួយមានភ្លៀងធ្លាក់អស់រយៈពេលជាច្រើនម៉ោង ដោយនាំមកនូវទឹកធ្លាក់ចុះមកពីជើងភ្នំ។ បន្ទាប់ពីបើកបរនៅក្នុង ភ្លៀងអស់ រយៈពេលជាច្រើនម៉ោង ខ្ញុំដឹងថាខ្លួនខ្ញុំនៅក្នុងទីក្រុងតូចមួយ ប្រហែលជាចំងាយប្រាំបីគីឡូម៉ែត្រ (ប្រាំម៉ៃល) ពីម៉ិនទែរី។ វាប្រហែលជា . . . ជិតដល់ពេលត្រឡប់ទៅផ្ទះវិញ។ រំពេចនោះខ្ញុំបានឃើញយុវជនពីនាក់ដើរ។ ពួកគេស្លៀកពាក់ខោខ្មៅជើងវែង និងអាវ ស ហើយពួកគេមើលទៅទទឹកជោគ តាំងពីក្បាលរហូតដល់ចុងជើង។*

*នៅពេលខ្ញុំទៅជិតពួកគេ ខ្ញុំបានបើកទ្វារឡានតាក់ស៊ី ហើយហៅ “ចូលក្នុងឡានមក ខ្ញុំកំពុងធ្វើដំណើរទៅម៉ិនទែរី។”*

*ម្នាក់មាឌខ្ពស់ ដែលមានសម្បុរយ៉ាងសស្អាត តបថា “ពួកយើងឥតមានលុយទេ។”*

*ខ្ញុំក៏តបថា “មិនយកលុយទេ”។*

*ពួកគេក៏ប្រញាប់ឡើងឡានតាក់ស៊ី។*

*នៅពេលខ្ញុំ បើកបរ ពួកយើងបាននិយាយគ្នា។ ពួកគេបានសួរខ្ញុំ បើសិនជាពួកគេអាចចែកចាយសារលិខិតមួយ អំពីព្រះយេស៊ូវគ្រីស្ទជាមួយខ្ញុំ។ ខ្ញុំយល់ព្រម ហើយឱ្យអាស័យដ្ឋានរបស់ខ្ញុំទៅពួកគេ។*

*នៅពេលខ្ញុំទៅដល់ផ្ទះ ខ្ញុំបានដាស់ប្រពន្ធរបស់ខ្ញុំ ហើយប្រាប់គាត់អំពីយុវជនពីរនាក់នោះ។ ខ្ញុំនិយាយថា “អ៊ី ក៏គាប់ជួនម្ល៉េះ។ “ម្នាក់ជាជនជាតិម៉ិកស៊ិក្ហ ហើយម្នាក់ទៀតជាជនជាតិអាមេរិក ដែលពួកគេទាំងពីរនាក់ មានឈ្មោះថា អែលឌើរ។”*

*ប្រពន្ធរបស់ខ្ញុំបានឆ្លើយថា “អែលឌើរ មានន័យថា អ្នកផ្សព្វផ្សាយសាសនា ” គាត់គ្រាន់តែដឹងបន្តិចបន្តួចអំពី សាសនាចក្រ។*

*ខ្ញុំមានអារម្មណ៍ថា មានអ្វីមួយកំពុងរញ្ជួយនៅក្នុងជំរៅចិត្តខ្ញុំ។ យុវជនទាំងពីរនាក់នេះ បានបន្សល់ទុកនូវអារម្មណ៍ នៃរសជាតិដ៏ពិសេសមួយដែលមាននៅក្នុងចិត្តរបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំជិតបានរកឃើញអ្វី ដែលមកចំអែតខាងវិញ្ញាណ របស់ខ្ញុំហើយ ដែលវាមាននៅជិតបង្កើយ។*

*អ្នកផ្សព្វផ្សាយសាសនា មកផ្ទះរបស់យើងនៅថ្ងៃទី 5 ខែមិថុនា ហើយខ្ញុំសប្បាយចិត្តនឹងស្ដាប់ពួកគេ។ ពីរសប្ដាហ៍ក្រោយ មក នៅថ្ងៃទី19 ខែមិថុនា ខ្ញុំបានទទួលបុណ្យជ្រមុជទឹក។ បួនខែ ក្រោយមក ប្រពន្ធរបស់ខ្ញុំ បានទទួលបុណ្យជ្រមុជទឹក នៅក្នុងខែតុលា។ កូនស្រីច្បងរបស់យើងបានកំពុងទទួលការហ្វឹកហ្វឺនខាងសាសនានៅសាលាមួយ។ នាងបានយំ នៅពេល នាងទៅព្រះវិហារ ជាលើកទីមួយ “ប៉ា នេះ ល្អជាងអ្វីដែលខ្ញុំកំពុងរៀននៅសាលាឆ្ងាយណាស់!” នាងបានជ្រមុជទឹកនៅក្នុងខែតុលា ផងដែរ។*

កំណត់ចំណាំ

*នៅខែធ្នូ ឆ្នាំ1995 ពួកយើងបានផ្សាភ្ជាប់ជាគ្រួសារមួយ នៅក្នុងទីក្រុងម៉ិកស៊ិក្ធ ព្រះវិហារបរិសុទ្ធម៉ិកស៊ិក្ធ សំរាប់ជីវិតនេះ និងភាពដ៏នៅអស់កល្បជានិច្ច។ ឥឡូវយើងជាគ្រួសារមួយ ដែលសប្បាយនឹងភាពសុខដុម សេចក្តីសុខសាន្ត និងសុភមង្គល។ ពួកយើងស្គាល់ តួអង្គ ដែលពួកយើងថ្វាយបង្គំ។ យើងស្គាល់កន្លែង ដែលមក និងកន្លែងដែលយើងកំពុងទៅ។ យើងស្រឡាញ់បន្ទូលរបស់ព្រះ ពិសេស ព្រះគម្ពីរមរមន ហើយយើងស្រឡាញ់សាសនាចក្ររបស់ទ្រង់ គឺសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធ ថ្ងៃចុងក្រោយ។ តាមរយៈអំណោយទានទាំងនេះ យើងបានរកឃើញថា អណ្តូងមានទឹករស់ដែលព្រះអង្គសង្គ្រោះមានបន្ទូល ទៅកាន់ ស្ត្រីសាសន៍សាម៉ារីថាៈ “ តែអ្នក ដែលផឹកទឹកខ្ញុំឱ្យ នោះនឹងមិនស្រេកទៀតឡើយ ទឹកដែលខ្ញុំឱ្យនឹងត្រឡប់ជារន្ធ ទឹកនៅក្នុងអ្នកនោះ ដែលផុសឡើងដល់ទៅបានជីវិតអស់កល្បជានិច្ច” (យ៉ូហាន 4ៈ14)។ [Victor Manuel Cabrera, “Thirsting for the Living Water,”* Ensign, *ខែសីហា ឆ្នាំ 2001 ,60–61]*



© 2001 Simon Dewey. ហាមថតចម្លង។

## សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន និងជាមួយដៃគូ

- តើបុរសម្នាក់នេះ ត្រូវបានរៀបចំសំរាប់ដំណឹងល្អ ដែលបានស្តារឡើងវិញដូចម្តេចខ្លះ?
- តើអ្វីនឹងកើតឡើង បើអែលឌើរ មិនបានបើកមាត់របស់ពួកគេ ដើម្បីចែកចាយសារលិខិតដំណឹងល្អ?
- រំលឹកពីអ្វី ដែលអ្នកបានធ្វើកាលពីម្សិលមិញ។ តើអ្នកបាននិយាយជាមួយមនុស្សបានច្រើនតាមដែលអ្នកអាចធ្វើបាន ឬទេ? បើមិនបានធ្វើ ចូរធ្វើផែនការ និងដាក់គោលដៅ ដើម្បីធ្វើដូច្នេះនៅក្នុងថ្ងៃនេះ។

## ការសិក្សាព្រះគម្ពីរ

តើព្រះអម្ចាស់មានបន្ទូលអ្វីខ្លះ អំពីការបើកមាត់របស់អ្នក? តើអ្នកគួរតែបង្រៀនអ្វី? តើអ្នកត្រូវបានសន្យាអ្វីខ្លះ?

គ និង ស 24ៈ12
គ និង ស 28ៈ16
គ និង ស 33ៈ7–15
គ និង ស 60ៈ2–3, 7–8

## ចូរបង្រៀនដល់អ្នកដែលបានស្វែងរក ចូរអោយអ្នកនោះស្វែងរកអ្នកដទៃទៀតបង្រៀន

ការស្វែងរក និងការបង្រៀន គឺជាសកម្មភាពជាប់ទាក់ទងគ្នា។ នៅពេលអ្នកជួបមនុស្សទាំងឡាយ ចូររៀបចំបង្រៀនដោយសង្ខេប អំពីសេចក្តីពិតដែលបានស្តារឡើងវិញ ដើម្បីឱ្យព្រះវិញ្ញាណបរិសុទ្ធ អាចធ្វើជាសាក្សីថា អ្នកគឺជាអ្នកបំរើរបស់ ព្រះអម្ចាស់។ នៅក្នុងស្ថានភាពជាច្រើន អ្នកនឹងត្រូវមានលទ្ធភាព ដើម្បីបង្ហាញសារលិខិតមួយ នៅក្នុងពេលមួយនាទី ឬតិចជាងនេះ។ មនុស្សសាំនឹងការនិយាយដែលប្រកបដោយអំណាច ក្នុងពេលខ្លីៗ។ ឧទាហរណ៍ អ្នកអាចធ្វើទីបន្ទាល់ អំពីសារលិខិតនៃការស្តារឡើងវិញ តែពីរ ឬបីប្រយោគដូចជាៈ

> *បន្ទាប់ពីការបាត់បង់ជាច្រើនសតវត្សន៍នូវសេចក្តីពិតទាំងឡាយនៃព្រះកាលពីដើម (ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ) ត្រូវបានស្តារឡើងវិញ ដោយព្រះដ៏ជាទីស្រឡាញ់ តាមរយៈព្យាការីដែលនៅរស់។ យើងមានភស្តុតាងពីការណ៍នេះ ដែលអ្នកអាចកាន់នៅក្នុងដៃរបស់អ្នក អាន ពិចារណា នៅក្នុងចិត្តរបស់អ្នក ហើយអធិស្ឋានអំពីការរៀនសេចក្តីពិតនោះ ដោយខ្លួនអ្នកផ្ទាល់។ តើអ្នកព្រមអនុញ្ញាតឱ្យយើង ដើម្បី . . .*

បើមានពេលច្រើនជាងនេះទៀត អ្នកអាចនិយាយបន្ថែមដូចជាៈ

> *សារលិខិតរបស់យើងសាមញ្ញ។ ព្រះគឺជាព្រះវរបិតារបស់យើង។ យើងគឺជាកូនចៅរបស់ទ្រង់។ យើងគឺជាផ្នែកមួយ នៅក្នុងគ្រួសាររបស់ទ្រង់។ ទ្រង់ស្រឡាញ់យើង។ តាំងពីការចាប់ផ្តើមនៃលោកិយមក ទ្រង់បានធ្វើតាមគំរូនៃសេចក្តីស្រឡាញ់ និងការខ្វល់ខ្វាយ។ ច្រើនដងណាស់ ទ្រង់បានឈោងមករកយើងដោយសេចក្តីស្រឡាញ់ ដើម្បីបើកបង្ហាញដំណឹងល្អរបស់ព្រះ យេស៊ូវគ្រីស្ទ ដើម្បីឱ្យកូនចៅរបស់ទ្រង់ អាចស្គាល់ពីរបៀប ដើម្បីត្រឡប់ទៅរកទ្រង់វិញ។ ទ្រង់បានបើកបង្ហាញ ដំណឹងល្អ ទៅកាន់ព្យាការី ដូចជា លោកអ័ដាម ណូអេ អ័ប្រាហាំ និងម៉ូសេ។ ប៉ុន្តែមនុស្សខ្លះ ត្រូវបានជ្រើសរើស ដើម្បីបដិសេធ ដំណឹងល្អនោះ ម្តងហើយម្តងទៀត។ ពីរពាន់ឆ្នាំកន្លងទៅ ព្រះយេស៊ូវគ្រីស្ទ ព្រះអង្គផ្ទាល់ បានបង្រៀនដំណឹងល្អរបស់ទ្រង់។ មិនគួរឱ្យជឿ សោះថា មនុស្សបានបដិសេធព្រះយេស៊ូវ។ នៅពេលណា ដែលមនុស្សមិនគោរព ឬបង្ខូចគោលលទ្ធិ និងពិធីការពិតទាំងឡាយ ព្រះបានដកយកសិទ្ធិអំណាចរបស់ទ្រង់ ដើម្បីគ្រប់គ្រងសាសនាចក្រ។*

កំណត់ចំណាំ

*សេចក្ដីអញ្ជើញរបស់យើងចំពោះអ្នក ត្រូវបន្ថែមចំពោះសេចក្ដីពិតទាំងឡាយ ដែលអ្នកបានរក្សាទុករួចទៅហើយ។ ចូរពិចារណាអំពីភស្តុតាង ដែលថាព្រះវរបិតាសួគ៌របស់យើង បានឈោងមករកកូនចៅរបស់ទ្រង់ម្តងទៀត នៅក្នុងសេចក្ដីស្រឡាញ់ ហើយបានបើកបង្ហាញគោលលទ្ធិពិត និងពិធីការទាំងឡាយទៅឱ្យព្យាការីម្នាក់។ ឈ្មោះរបស់ព្យាការីម្នាក់នេះ គឺយ៉ូសែប ស្ម៊ីធ។ ភស្តុតាង នៃសេចក្ដីពិតដ៏រុងរឿងនេះ ត្រូវបានរកឃើញនៅក្នុងសៀវភៅមួយគឺ—ព្រះគម្ពីរមរមន។ អ្នកអាចកាន់នៅក្នុងដៃរបស់ អ្នក អាន និងពិចារណា សេចក្ដីពិតរបស់ព្រះគម្ពីរមរមន នៅក្នុងគំនិត និងចិត្តរបស់អ្នក។*

ចូរជៀសវាងក្នុងការនិយាយដូចជា “តើអ្នកមានពេលពីរបីនាទី ដែលយើងអាចបង្រៀនអ្នកនូវសារលិខិតមួយអំពី . . .” ដោយបែរមកបង្កើតជាទំលាប់ នៃការចាប់ផ្ដើមបង្រៀនហើយធ្វើទីបន្ទាល់នៅពេលអ្នកជួបនឹងពួកគេ ដោយភ្លាមៗ។ អ្នកនឹងរកបាន មនុស្សបង្រៀនច្រើនជាង នៅពេលអ្នកធ្វើទីបន្ទាល់ និងអនុញ្ញាតឱ្យពួកគេមានអារម្មណ៍ នៃអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។

អ្វីក៏ដោយ ដែលជាការនិយាយដំបូងរបស់អ្នក ចូរនិយាយអំពី លើការស្ដារឡើងវិញ នៃដំណឹងល្អឱ្យបានឆាប់រហ័ស ហើយសាមញ្ញ ពីព្រោះនេះគឺជាសារលិខិតដ៏ពិសេសតែមួយគត់ របស់យើងចំពោះពិភពលោក។ អ្នកទាំងឡាយណា ដែលអ្នកបង្រៀន ជារឿយៗមាន មិត្តភក្តិ ឬសាច់ញាតិ ដែលត្រូវបានរៀបចំ ដើម្បីទទួលដំណឹងល្អដែលបានស្ដារឡើងវិញ។ នៅគ្រប់ស្ថានភាព បង្រៀន—ដូចជាការស្វែងរក អ្នករៀន ការបង្រៀនសាសនាគន់ការី ធ្វើការជាមួយសមាជិក—សូមសួរ “តើមាននរណា ដែលអ្នកស្គាល់ ដែលនឹងមានចាប់អារម្មណ៍ ឬចង់ទទួលប្រយោជន៍ពីសារលិខិតនេះឬទេ? បន្ទាប់ពីទទួលបានអ្នករៀនថ្មីដែល ត្រូវទៅជួប ចូរសួរ “តើមាននរណាផ្សេងទៀត ដែលនឹងទទួលប្រយោជន៍ពីសារលិខិតរបស់យើងឬទេ?” ចូរកុំស្ទាក់ស្ទើរ ដើម្បីសួរម្ដងហើយម្ដងទៀត នៅពេលជួបលើកក្រោយ។ នៅពេលអ្នកទាំងឡាយ ដែលអ្នកបង្រៀនមានបទពិសោធន៍ ពរជ័យទាំងឡាយនៃដំណឹងល្អ នោះចំណង់របស់ពួកគេ ដើម្បីចែកចាយដំណឹងល្អ នឹងចំរើនឡើង (សូមមើល នីហ្វៃទី1 8:12)។ ជារឿយៗ ពួកគេនឹងបង្កើតមិត្តថ្មីៗ នៅពេលកំពុងរៀន ដំណឹងល្អ។ អ្នកផ្សព្វផ្សាយសាសនា ដែលអនុវត្តគោលការណ៍នេះ ជាធម្មតាមានមនុស្សបង្រៀនច្រើន។

### សកម្មភាពៈ ការសិក្សាជាមួយដៃគូ

- រៀបចំសារលិខិតរយៈពេលមួយនាទី យោងទៅលើមេរៀនមួយ ក្នុងចំណោមមេរៀនទាំងឡាយ។ គិតពីរបៀប ដើម្បីបង្រៀនមេរៀននេះ នៅក្នុងការរៀបចំស្វែងរកអ្នករៀន។
- កំណត់ថា តើអ្នកអាចភ្ជាប់សារលិខិតនេះបានរហ័សប៉ុណ្ណា ទៅនឹងការស្ដារឡើងវិញ។
- ចែកចាយសារលិខិតជាមួយនឹងដៃគូរបស់អ្នក។
- ដាក់គោលដៅ ដើម្បីបង្រៀនសារលិខិតនេះ នៅពេលសមរម្យក្នុងថ្ងៃនេះ ដើម្បីបន្ថែមសាសនាគន់ការីថ្មី ចូលក្នុងក្រុម មនុស្ស ដែលអ្នកបង្រៀន។

---

- រំលឹកសាឡើងវិញអំពីបញ្ជី នៃមនុស្ស ដែលអ្នកកំពុងបង្រៀនថ្មីៗនេះ។ ចូរធ្វើបញ្ជីមួយ នៃអ្នកទាំងឡាយណា ដែលអ្នក បានសុំឱ្យរកអ្នករៀនថ្មី ដែលត្រូវទៅជួប និងអ្នកទាំងឡាយណា ដែលអ្នកមិនទាន់សុំឱ្យរកអ្នករៀន។ ចូរហាត់ពីរបៀប ដែលអ្នកនឹង ធ្វើការអញ្ជើញដល់អ្នកទាំងនោះ នៅក្នុងក្រុមនីមួយៗ ឱ្យផ្ដល់ឱ្យអ្នក នូវអ្នករៀនថ្មីដែលត្រូវទៅជួប។ នៅក្នុងកាលវិភាគរបស់អ្នក ចូរធ្វើជាកំណត់ចំណាំមួយ ដើម្បីពង្រីក ការអញ្ជើញនេះ នៅពេលការណាត់ជួបពេលក្រោយរបស់អ្នក។

## ការនិយាយអំពីសារៈសំខាន់នៃក្រុមគ្រួសារ



ការស្ដារឡើងវិញ នៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ប្រទានពរដល់ក្រុមគ្រួសារ។ ដោយការរស់នៅតាមគោលការណ៍ទាំងឡាយ នៃដំណឹងល្អដែលបានស្ដារឡើងវិញ ក្រុមគ្រួសារត្រូវបានពង្រឹង និងអាចមានបទពិសោធន៍នៃសេចក្ដីសុខសាន្ត សេចក្ដីអំណរ និងអារម្មណ៍ល្អ ដែលបានក្លាយជាសមាជិក និងមានអត្តសញ្ញាណមួយ។

ការប្រាប់អំពីសារៈសំខាន់របស់គ្រួសារជាមួយអ្នកទាំងឡាយ ដែលអ្នកជួបរាល់ថ្ងៃ នឹងជួយអ្នករកបានមនុស្សបង្រៀន។ មនុស្សភាគច្រើន មានចំណាប់អារម្មណ៍តាំងពីកំណើតមួយនៅក្នុងក្រុមគ្រួសារ។ នៅក្នុងស្ថានភាពការស្វែងរកអ្នករៀនជាច្រើន អ្នកអាចភ្ជាប់ដោយរហ័សអំពីអ្វី

កំណត់ចំណាំ

ដែលមនុស្សភាគច្រើនដឹងអំពីគ្រួសារ ទៅនឹងសារលិខិតនៃការស្ដារឡើងវិញ។ នៅពេលធ្វើការ ស្វែងរកអ្នករៀន អ្នកអាចនិយាយរឿងខ្លះ ដូចនៅខាងក្រោមនេះ៖

*គ្មានអ្វី ដែលសំខាន់ជាងក្រុមគ្រួសារទេ។ គ្រួសាររបស់យើង ចងយើងឱ្យជាប់គ្នា ផ្ដល់ឈ្មោះឱ្យយើង ហើយជួយយើងមានអារម្មណ៍ថា ចាំបាច់ និងមានសេចក្ដីស្រឡាញ់។ មកពីក្រុមគ្រួសាររបស់យើង យើងទទួលមរតកជាជំនាញ អាកប្បកិរិយា និងលក្ខណៈចរិកខាងរាងកាយ ដោយផ្ទាល់ខ្លួន ដែលផ្ដល់ដល់យើងនូវអត្តសញ្ញាណពិសេសមួយចំនួន។*

*ការមានគ្រួសាររឹងមាំ និងសប្បាយ គឺជាឯកសិទ្ធិដ៏ខ្ពស់បំផុតសំរាប់មនុស្សជាច្រើនទូទាំងពិភពលោក។ ការសំរេច ជោគជ័យគោលដៅនេះ គឺជារឿយៗមានការលំបាក។ ការចិញ្ចឹមកូនៗ និងមានអាពាហ៍ពិពាហ៍រឹងមាំមួយ នៅក្នុងពិភពលោក សព្វថ្ងៃនេះ អាចមើលទៅហាក់ដូចជាមិនអាចកើតឡើងបានទេ នៅពេលមានសេចក្ដីអាក្រក់ មាននៅជុំវិញខ្លួនយើង។*

អ្នកអាចធ្វើការប្រាស្រ័យទាក់ទងទៅនឹងសារលិខិតនៃការស្ដារឡើងវិញ៖

*អារម្មណ៍នៃសេចក្ដីស្រឡាញ់ និងការខ្វល់ខ្វាយ ដែលយើងមានចំពោះក្រុមគ្រួសាររបស់យើង គឺអស់កល្បជានិច្ច ហើយបានចាក់ឫសយ៉ាងជ្រៅនៅក្នុងព្រលឹងរបស់យើង។ ពួកគេសំខាន់នៅក្នុងទំនាក់ទំនងរបស់យើងជាមួយព្រះ។ អ្នកមានចំណែកនៅក្នុងគ្រួសាររបស់ព្រះ តាំងពីមុនពេលអ្នកចាប់កំណើតមកម្ល៉េះ។ ទ្រង់គឺជាព្រះវរបិតារបស់យើង។ ពីព្រោះទ្រង់ជាព្រះវរបិតារបស់យើង យើងគឺជាបងប្អូនប្រុសស្រីនឹងគ្នា។ ព្រះវរបិតាសួគ៌ចង់ឱ្យយើងត្រឡប់ទៅរស់នៅជាមួយទ្រង់ ជាចំណែកនៃគ្រួសាររបស់ទ្រង់វិញ។ ក្រុមគ្រួសារនៅលើផែនដីនេះ ត្រូវបានចងភ្ជាប់នឹងគ្រួសាររបស់ព្រះ។ ក្រុមគ្រួសារអាចរស់នៅ ជាមួយគ្នាបន្ទាប់ពីជីវិតនេះ។ យើងដឹងការណ៍នេះ ពីព្រោះបន្ទាប់ពីច្រើនសតវត្សនៃការបាត់បង់គោលលទ្ធិពិត និងពិធីការ ទាំងឡាយ ដូចជាពិធីបុណ្យជ្រមុជទឹកដោយការជ្រមុជ ត្រូវបានស្ដារឡើងវិញនៅលើផែនដី ដោយសេចក្ដីស្រឡាញ់នៃ ព្រះវរបិតាសួគ៌របស់យើង តាមរយៈព្យាការីនៅរស់។ សេចក្ដីពិតដែលបានស្ដារឡើងវិញទាំងនេះ មិនត្រឹមតែជួយយើងឱ្យយល់ ពីកន្លែងរបស់យើងនៅក្នុងគ្រួសាររបស់ព្រះប៉ុណ្ណោះទេ ប៉ុន្តែវា គឺជាសេចក្ដីសង្ឃឹមដ៏ធំ ដែលយើងមានសំរាប់ គ្រួសារដ៏រឹងមាំ និងសប្បាយរីករាយមួយនៅក្នុងជីវិតនេះ។ តើពួកយើងអាចបង្រៀនអ្នកថែមទៀតបានទេ អំពី . . .*

ការណ៍ដូចគ្នានេះអាចត្រូវបានសំរេចជាមួយនឹងប្រធានបទផ្សេងទៀត ដូចជាសុភមង្គល ភាពមិនអនុគ្រោះ គោលបំណងនៃជីវិត ឬសេចក្ដីស្លាប់។ អ្វីក៏ដោយដែលជាការខិតទៅរកការស្វែងរកអ្នករៀនថ្មីរបស់អ្នក ចូរចងចាំថា ត្រូវភ្ជាប់វាឱ្យបានឆាប់រហ័ស ទៅនឹងសារលិខិតពិសេសរបស់យើងតែមួយទៅនឹងលោកិយ។

## សារៈសំខាន់របស់សមាជិក

ធ្វើការជាមួយសមាជិក នៃសាសនាចក្រ ដើម្បីស្វែងរកមនុស្សបង្រៀន។ ស្ថានភាពពិសេស គឺនៅពេលសមាជិកអញ្ជើញ អ្នកផ្សេងទៀតឱ្យរៀន និងមានវត្តមានសំរាប់ការបង្រៀន។ នៅពេលសមាជិកធ្វើដូចនេះ មនុស្សកាន់តែច្រើនត្រូវបានទទួល បុណ្យជ្រមុជទឹកនឹងនៅតែសកម្មនៅក្នុងសាសនាចក្រ។ ការទាក់ទងជាមួយសមាជិក គឺជាការសំខាន់ ពីព្រោះវា នឹងជួយ បន្ទន់ចិត្តមនុស្ស ហើយជារឿយៗដឹកនាំពួកគេឱ្យសង្កេតមើល ដំណឹងល្អ ដែលបានស្ដារឡើងវិញ។ នេះជាញឹកញាប់ មានន័យថា ពួកគេ ត្រូវបាននាំមកចូលក្នុងរង្វង់នៃមិត្តភក្តិ របស់សមាជិកក្នុងសាសនាចក្រ រួមមានទាំង សមាជិកសកម្ម និងសមាជិកមិនសូវសកម្ម អ្នកផ្លាស់ប្រែគំនិតថ្មី និងអ្នកដែលជាសមាជិកតែម្នាក់ឯងនៅព្រះវិហារ។

> *"បន្ទាប់ពីអ្វីៗទាំងអស់ ដែលបាននិយាយមកនេះ ករណីយកិច្ចដែលធំបំផុត និងសំខាន់បំផុត គឺដើម្បីប្រកាសដំណឹងល្អ។"*
>
> — ព្យាការីយ៉ូសែប ស្ម៊ីធ
> *TEACHINGS OF THE PROPHET JOSEPH SMITH*, 113

ប្រធានគរឌឹន ប៊ី ហ៊ីងឃ្លី បានបង្រៀនថា “យើងភាគច្រើនមើលទៅលើកិច្ចការផ្សព្វផ្សាយសាសនា ដូចជាការចែកចាយកូន សៀវភៅសាសនាតូចៗតាមផ្ទះអញ្ចឹង។ អ្នកណា ដែលស្គាល់កិច្ចការនេះ ដឹងថា មានមធ្យោបាយមួយប្រសើរជាង។ មធ្យោបាយនោះ គឺតាមរយៈសមាជិកទាំងឡាយ នៃសាសនាចក្រ។ នៅពេលណា មានសមាជិកម្នាក់ ណែនាំសាសនាគន់ការី នោះមានប្រពន្ធ័គាំទ្រភ្លាមៗ។ សមាជិកធ្វើទីបន្ទាល់នៃសេចក្ដីពិតអំពីកិច្ចការនេះ។ គាត់មានចិត្តអន្ទះសាសំរាប់សុភមង្គលនៃមិត្តសាសនាគន់ការីរបស់គាត់។ គាត់នឹងរំភើប នៅពេលមិត្តនោះមានការរីកចំរើននៅក្នុងការរៀនដំណឹងល្អ។

“អ្នកផ្សព្វផ្សាយសាសនាពេញម៉ោង អាចធ្វើការបង្រៀនដោយផ្ទាល់ ប៉ុន្តែសមាជិក នៅកន្លែងណាក៏ដោយ នឹងធ្វើការគាំទ្រចំពោះការបង្រៀននោះ ដើម្បីបន្តការបំរើរបស់អ្នកផ្សព្វផ្សាយសាសនាមាននៅផ្ទះរបស់គាត់។ គាត់នឹងចែកចាយទីបន្ទាល់ដោយស្មោះអំពីទេវភាពនៃកិច្ចការ។ គាត់នឹងនៅទីនោះដើម្បីឆ្លើយសំណួរទាំងឡាយ នៅពេលអ្នកផ្សព្វផ្សាយសាសនាមិននៅ។ គាត់នឹងធ្វើជាមិត្តម្នាក់ជាមួយនឹងអ្នកផ្លាស់ប្រែគំនិត ដែលកំពុងតែធ្វើការផ្លាស់ប្ដូរ ដ៏ធំមួយ ហើយជារឿយៗមានការលំបាក . . .។ ដំណើរការនៃការនាំ

កំណត់ចំណាំ

មនុស្សថ្មីចូលមកក្នុងសាសនាចក្រ គឺមិនមែនជាការទទួលខុស ត្រូវរបស់អ្នកផ្សព្វផ្សាយសាសនាតែមួយប៉ុណ្ណោះទេ។ ពួកគេមានជោគជ័យបំផុត នៅពេលសមាជិកធ្វើជាធនធាន សំរាប់ជួយ សាសនាគន់ការីថ្មី” (*Ensign*, ខែឧសភា ឆ្នាំ1999, 105–6)។

ចំណុចចាប់ផ្ដើមនៅក្នុងការកសាងទំនាក់ទំនងរឹងមាំជាមួយសមាជិកទាំងឡាយ គឺជាប៊ីស្សប។ ចូរជួយ និងបំរើ នៅក្នុងរបៀបសុចរិតណាមួយ ដែលគាត់សុំ។ ចូរសួរខ្លួនឯង ជាប្រចាំថា “តើខ្ញុំគឺជាពរជ័យមួយ ឬក៏ជាបន្ទុកចំពោះប៊ីស្សប? ចូរអភិវឌ្ឍន៍ ឥរិយាបទថា “តើខ្ញុំអាចជួយដោយរបៀបណា?”។ បើសិនជាអ្នករកមើលឱកាស ដើម្បីស្រឡាញ់ បំរើ និងបង្រៀន ប៊ីស្សប និងសមាជិកក្នុងវួដកាន់តែទុកចិត្តអ្នកជាមួយនឹង សមាជិកគ្រួសារ និងមិត្តភក្តិទាំងឡាយរបស់ពួកគេ។

ចូរពិចារណាអំពីការលើកលែងខាងក្រោមដកចេញមកពីសំបុត្រមួយច្បាប់ ដែលសរសេរដោយអ្នកផ្សព្វផ្សាយសាសនា ទៅកាន់ប្រធានបេសកកម្ម របស់គាត់ដូចខាងក្រោមនេះ៖

*ជូនចំពោះលោកប្រធានដាទីរាប់អាន,*

*អ្នកជំនួយការ បានទូរសព្ទមកប្រាប់ខ្ញុំនៅថ្ងៃនេះថា ខ្ញុំត្រូវប្ដូរតំបន់។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំគួរតែសរសេរ និងថ្លែង អំណរគុណចំពោះលោកប្រធាន សំរាប់ការបញ្ជូនខ្ញុំមកក្នុងតំបន់នេះ។ វាហាក់ដូចជាកាលពីថ្ងៃម្សិលមិញសោះ ដែលលោក បានប្រាប់ខ្ញុំអំពីឧបសគ្គទាំងឡាយដែលមាននៅចំពោះមុខ។*

*នៅអាទិត្យទីមួយរបស់យើង បានបញ្ជាក់នូវអ្វី ដែលលោកបានប្រាប់ដល់ខ្ញុំ។ យើងបានទទួលការស្វាគមន៍ខ្លះៗចូល ទៅក្នុងវួដ។ រឿងវិជ្ជមានតែមួយប៉ុណ្ណោះ នៅអាទិត្យទីមួយនោះ គឺស្កុត ដែលជាអ្នកដឹកនាំបេសកកម្ម នៅក្នុង វួដថ្មី។ គាត់បានផ្លាស់ទៅមូលដ្ឋានទព័អាកាសមួយខែមុន ហើយបានបំរើជាអ្នកដឹកនាំបេសកកម្មនៅក្នុងវួដបានពីរសប្ដាហ៍។ ស្កុត បានអញ្ជើញពួកយើងទៅផ្ទះរបស់គាត់ ដើម្បីបរិភោគអាហារពេលល្ងាច ជាថ្ងៃអាទិត្យទីមួយរបស់យើង ដើម្បីពិភាក្សាអំពីអ្វី ដែលត្រូវធ្វើ ដើម្បីឱ្យការងារបន្តទៅមុខ។ បន្ទាប់ពីញ៉ាំអាហារពេលល្ងាចរួច ពួកយើងបានលត់ជង្គង់អធិស្ឋាន ហើយសុំព្រះវរបិតាសួគ៌ សំរាប់ការដឹកនាំ របស់ទ្រង់។ នៅពេលពួកយើងអធិស្ឋាន ពួកយើងមានអារម្មណ៍សុខសាន្ត និងការប្ដេជ្ញាចិត្ត។ យើងប្ដេជ្ញាថា មធ្យោបាយ ដ៏ប្រសើរបំផុត ដើម្បីឱ្យការងារបន្តទៅមុខទៀត គឺត្រូវទទួលនូវការទុកចិត្តពីសមាជិកទាំងឡាយ។ យើងសំរេចចិត្ត ដើម្បីធ្វើតាមគំរូរបស់អាម៉ូន ហើយបំរើពួកគេ។*

*យើងបានចាប់ផ្ដើមជាមួយប៊ីស្សប។ ពីព្រោះថាមានការខ្វះខាត ពិធីបុណ្យជ្រមុជទឹកនៅក្នុងតំបន់ និងខ្វះខាត កិច្ចខំប្រឹងប្រែង មកពីអ្នកផ្សព្វផ្សាយសាសនាពីមុន គាត់មិនសូវរំភើបចំពោះសំណើររបស់យើង ដើម្បីជួបជាមួយគាត់។ ផាយថាហេតុ គាត់បានអញ្ជើញយើងឱ្យទៅផ្ទះគាត់ម្ដងទៀត ដើម្បីបរិភោគអាហារពេលល្ងាច។ យើងបានដឹងថា ប៊ីស្សប កំពុងរៀបចំផ្លាស់កំរាលព្រំ ពីបន្ទប់ទទួលភ្ញៀវរបស់គាត់ ហើយសង់ឡើងវិញនូវកំរាលឈើនៅពីក្រោម។ យើងបានស្ម័គ្រចិត្តជួយ ហើយគាត់បានយល់ព្រម។ នៅទីបញ្ចប់នៃគំរោងនេះ ប៊ីស្សបបានសុំយើងឱ្យនិយាយនៅក្នុងកិច្ចប្រជុំប្រសិទ្ធិពរទំប៉ុង និងទឹក។ យើងយកការណ៍នេះ ជាភស្ដុតាងថា គាត់ចាប់ផ្ដើមទុកចិត្តមកលើពួកយើង។*

*យើងបានធ្វើតាមគំរូនៃការបំរើដូចគ្នានេះ នៅពេលយើងជួបសមាជិកផ្សេងទៀត។ ពួកយើងរកបានឱកាសជាច្រើន ដើម្បីជួយពួកគេតាមរបៀបសាមញ្ញផ្សេងៗ។ នៅពេលយើងមិនទៅជួបនឹងសមាជិក យើងបានគោះទ្វារ ហើយ និយាយទៅកាន់មនុស្សជាច្រើនតាមដែលពួកយើងអាចធ្វើទៅបាន អំពីដំណឹងល្អ ដែលបានស្ដារឡើងវិញ។ ពួកយើងមានពរណាស់ ដែលមានមនុស្សរៀនហើយសមាជិកបានឃើញថា យើងបាននាំមនុស្សមកកាន់ព្រះវិហារ ដែលយើងបាន ស្វែងរកដោយខ្លួន របស់យើង។ ឥរិយាបទរបស់វួដទាំងមូលចាប់ផ្ដើមផ្លាស់ប្ដូរ។ មានការរំភើបចិត្តអំពីកិច្ចការផ្សព្វផ្សាយ សាសនាកើនឡើង។ នៅពេលសមាជិកទុកចិត្តលើយើង ការងារបានលឿនទៅមុខ។ ពិធីបុណ្យជ្រមុជទឹកជាច្រើន ចាប់ផ្ដើមមានមកបន្តបន្ទាប់។*



សមាជិកសាសនាចក្រជាច្រើន មានការភ័យខ្លាច អំពីការធ្វើកិច្ចការផ្សព្វផ្សាយសាសនា។ ភាគច្រើន មិនច្បាស់ថាគួរចាប់ផ្ដើម និយាយពីកន្លែងណា ឬពីអ្វី។ ភាគច្រើនភ័យខ្លាចថា ពួកគេនឹងបាត់បង់មិត្តភក្ដិជិតស្និទ្ធ បើពួកគេព្យាយាមចែកចាយដំណឹងល្អ ជាមួយមិត្តភក្ដិពួកគេ។ មានមធ្យោបាយជាច្រើន ដើម្បីជួយសមាជិក។ ឧទាហរណ៍ ជួយកសាងសេចក្ដីជំនឿរបស់ពួកគេ ដោយការបង្រៀនពួកគេអំពីសារលិខិតនៃការស្ដារឡើងវិញ និងគោលលទ្ធិផ្សេងទៀតនៅក្នុងមេរៀន។ ជួយពួកគេ ឱ្យមានអារម្មណ៍ ព្រះវិញ្ញាណ និងអំណាចនៃសារលិខិតរបស់យើង។ ពង្រឹងការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិរបស់ព្រះគ្រីស្ទ នឹងធ្វើឱ្យកើន ការទុកចិត្តរបស់ពួកគេចំពោះអ្នកកាន់តែច្រើន ហើយនឹងសាងភាពរំភើបរីករាយរបស់ពួកគេ ឱ្យធ្វើកិច្ចការអ្នកផ្សព្វផ្សាយសាសនា ជាជាងអ្វីៗទាំងអស់ដែលអ្នកអាចធ្វើ។ ជួយពួកគេឱ្យយល់ថា ការចែកចាយដំណឹងល្អ ដែលបានស្ដារឡើងវិញ នឹងហូរចាក់ចូលមកកាន់តែច្រើនក្នុងទំនាក់ទំនង ដែលពួកគេកំពុងស្វែងរក ដើម្បីស្រឡាញ់ និងបំរើដល់សមាជិកគ្រួសារ និងមិត្តភក្ដិទាំងឡាយរបស់ពួកគេ។ បង្រៀនពួកគេនូវគោលការណ៍មកពីវគ្គ “ទៅធ្វើកិច្ចការល្អ” នៃជំពូកនេះ។ ចូរលើកទឹកចិត្តសមាជិកឱ្យ “រួមគ្នាតមអាហារ ហើយអធិស្ឋានឱ្យអស់ពី

កំណត់ចំណាំ

ចិត្ត ដើម្បីសុខុមាលភាព ដល់ព្រលឹងរបស់ជនទាំងឡាយ ដែលពុំ [ស្គាល់] ព្រះ” (អាលម៉ា 6៖6)។ នៅគ្រប់អ្វីៗ ដែលអ្នកធ្វើជាមួយសមាជិក ចូរស្វែងរកដើម្បីលើកតំកើង និងសាងសេចក្តីជំនឿ របស់ពួកគេ ដើម្បីពួកគេជួយ ធ្វើកិច្ចការអ្នកផ្សព្វផ្សាយសាសនា។

លើសពីនេះទៅទៀត ដើម្បីធ្វើការជាមួយនឹងសមាជិកសកម្ម ចូរយកចិត្តទុកដាក់ស្វែងរកមនុស្សបង្រៀន តាមរយៈអ្នកត្រៀមខ្លួនធ្វើជាអែលឌើរ សមាជិកមិនសូវសកម្ម និងសមាជិកថ្មី។ សមាជិកទាំងនេះ មានមិត្តភក្តិច្រើន ខាងជំនឿផ្សេង ហើយនឹងបានពរជ័យនៅពេល ពួកគេចែកចាយដំណឹងល្អ ដែលបានស្តារឡើងវិញ ជាមួយនឹងសមាជិក គ្រួសារ និងមិត្តភក្តិរបស់ពួកគេ។

នៅរាល់ការជួបសួរសុខទុក្ខជាមួយនឹងសមាជិក ចូរប្រឹងឱ្យអស់ពីសមត្ថភាព ដើម្បីលើកទឹកចិត្តពួកគេឱ្យ៖

- អធិស្ឋាន ហើយធ្វើតាមព្រះវិញ្ញាណ។
- ផ្តល់ការបំរើ។
- បង្កើនមិត្តភាព។
- បើកមាត់របស់ពួកគេ ដើម្បីចែកចាយដំណឹងល្អ ដែលបានស្តារឡើងវិញ។
- អញ្ជើញអ្នកផ្សេងទៀតឱ្យធ្វើការណ៍ទាំងឡាយ ដើម្បីចំរើនសេចក្តីជំនឿរបស់ពួកគេនៅក្នុងព្រះគ្រីស្ទ។

គ្រប់អ្នករៀនថ្មីដែលត្រូវជួប ដែលអ្នកបានទទួលមកពីសមាជិកម្នាក់ គួរតែយកចិត្តទុកដាក់ដូចជារបស់មានតម្លៃ។ នៅពេលសមាជិកម្នាក់ឱ្យឈ្មោះមិត្តភក្តិម្នាក់ដល់អ្នក ឱ្យទូរសព្ទ ឬទៅជួប ចូរឆ្លើយតបមកវិញឱ្យឆាប់រហ័ស និងរាយការណ៍អំពីលទ្ធផល មកដល់សមាជិកវិញ។

## គំនិតសំរាប់ជួយសមាជិក

មានមធ្យោបាយជាច្រើន ដើម្បីលើកទឹកចិត្តឱ្យសមាជិកកាន់តែមានទំនាក់ទំនងនិងកិច្ចការអ្នកផ្សព្វផ្សាយសាសនា។ ចូរពិចារណាគំនិតទាំងឡាយនៅខាងក្រោមនេះ៖

- ស្វែងរកការណែនាំពីប៊ីស្សប និងអ្នកដឹកនាំនៅក្នុងវួដផ្សេងទៀត។ សូមមើលជំពូកទី 13 សំរាប់ជាជំនួយបន្ថែមនៅក្នុង ផ្នែកនេះ។
- បង្រៀនអ្នកដឹកនាំសាសនាចក្រទាំងឡាយ និងសមាជិកអំពីសារលិខិតនៃការស្តារឡើងវិញ និងមេរៀនដទៃទៀត។
- បង្រៀនពួកគេឱ្យស្រឡាញ់ និងបំរើអ្នកជិតខាង និងមិត្តភក្តិរបស់ពួកគេ។
- លើកទឹកចិត្តពួកគេឱ្យតមអាហារ និងអធិស្ឋានសំរាប់ឱកាសធ្វើជាអ្នកផ្សព្វផ្សាយសាសនា។
- លើកទឹកចិត្តពួកគេឱ្យជួបនឹងអ្នកដែលគេស្គាល់ អ្នកដែលមានបទពិសោធន៍ថ្មីៗ អំពីព្រឹត្តិការណ៍ជីវិតផ្លាស់ប្តូរ (ការចាប់កំណើត មរណៈភាពនៅក្នុងគ្រួសារ អាពាហ៍ពិពាហ៍ ឬអ្នកផ្លាស់ទីលំនៅថ្មី)។
- អញ្ជើញពួកគេឱ្យជួយអ្នកបង្រៀន។ ក្នុងស្ថានភាពពិសេស គឺត្រូវមានសមាជិកសាសនាចក្រចូលរួមជាមួយអ្នក ដែលកាលពីមុនជាសមាជិកក្នុងព្រះវិហារដូចគ្នានៅក្នុងនាមជាសាសនាគន់ការី។
- ជួយពួកគេឱ្យដាក់កាលបរិច្ឆេទ នៅពេលពួកគេនឹងអញ្ជើញមិត្តភក្តិរបស់ពួកគេ ឱ្យរៀនអំពីសារលិខិតនៃការស្តារឡើងវិញ។
- បង្ហាញពួកគេអំពីវត្ថុ ដែលពួកគេអាចផ្តល់ទៅឱ្យអ្នកដទៃ ដូចជា ព្រះគម្ពីរមរមនមួយក្បាល វីដេអូ និងកាតផ្សព្វផ្សាយ។
- លើកទឹកចិត្តពួកគេឱ្យអញ្ជើញមិត្តភក្តិរបស់ពួកគេ ចូលរួមនៅព្រះវិហារ ឬការប្រជុំរាត្រីក្រុមគ្រួសារ ដើម្បីបង្ហាញវីដេអូ ដែលផលិតដោយសាសនាចក្រ ឬដើម្បីចូលរួម នៅក្នុងការសន្ទនាអំពីដំណឹងល្អ។
- ជួយពួកគេឱ្យអនុវត្តនូវអ្វី ដែលពួកគេត្រូវនិយាយទៅកាន់មិត្តភក្តិរបស់ពួកគេ។
- បង្រៀនពួកគេពីមូលហេតុ ដែលវាមានតំលៃក្នុងការចែកចាយដំណឹងល្អ ដែលវាជាផ្លែផ្កា។

មានមធ្យោបាយជាច្រើនទៀត ដើម្បីជួយដល់សមាជិកឱ្យមកចូលរួមកាន់តែច្រើន។ សូមដាក់ចំណុចនេះចូលទៅក្នុងបញ្ជី ក្នុងបេសកកម្មទាំងមូលរបស់អ្នក។ ចែកចាយគំនិតរបស់អ្នកជាមួយអ្នកផ្សព្វផ្សាយសាសនាផ្សេងទៀត។

## សកម្មភាពៈ ការសិក្សាជាមួយដៃគូ

ជាមួយដៃគូរបស់អ្នក ចូររំលឹកឡើងវិញនូវអ្វី ដែលអ្នកបានធ្វើ ដើម្បីបំរើ និងជួយប៊ីស្សប និងអ្នកដឹកនាំដទៃទៀត និងសមាជិកទាំងឡាយ អំឡុងខែកន្លងទៅនេះ។ ចូរពិភាក្សា និងធ្វើផែនការអំពីអ្វី ដែលអ្នកអាចធ្វើ អំឡុងខែ ដែលនឹងមកដល់ ដើម្បីបង្កើនទំនាក់ទំនងកាន់តែរឹងមាំជាមួយពួកគេ។

---

រំលឹករាល់គំនិតទាំងឡាយ ដែលបានចុះបញ្ជី នៅក្នុងប្រអប់ “គំនិតសំរាប់ជួយសមាជិក”។ ចូរបញ្ជាក់ពីគំនិតខ្លះៗ ដែលអ្នកមិនទាន់បានសាកល្បងនៅឡើយ។ ប្រើប្រាស់កាលវិភាគប្រចាំថ្ងៃរបស់អ្នក ធ្វើផែនការ និងសាកល្បងគំនិតខ្លះៗ អំឡុងសប្តាហ៍ក្រោយ។

កំណត់ចំណាំ

## អ្នករៀនថ្មីដែលត្រូវទៅជួប បានមកពីតាមការផ្សព្វផ្សាយ និងទីស្នាក់ការសាសនាចក្រ

អ្នករៀនថ្មី ដែលត្រូវទៅជួបទាំងឡាយ គឺជាធនធានមួយទៀតនៅក្នុងការស្វែងរកមនុស្ស ដែលត្រូវបានរៀបចំសំរាប់ ដំណឹងល្អដែលបានស្ដារឡើងវិញ។ លើសពីនោះទៅទៀតចំពោះអ្នករៀនថ្មីដែលត្រូវទៅជួបមកពីសមាជិក សាសនាចក្រ អាចទំនាក់ទំនងយ៉ាងសកម្ម តាមវិធីជាច្រើន ដល់កូនចៅរបស់ព្រះ។ សាសនាចក្របង្កើតចំណាប់អារម្មណ៍ តាមរយៈកិច្ចខំប្រឹងប្រែង ដូចជាការផ្សាយពាណិជ្ជកម្មតាមប្រពន្ធ័ផ្សព្វផ្សាយ មជ្ឈមណ្ឌលសំរាប់អ្នកទស្សនា តាមកន្លែងប្រវត្តិសាស្ត្រ ជំនួយសុខុមាលភាព និងជំនួយមនុស្សធម៌ និងអ៊ិនធើណែត (www.mormon.org, www.lds.org, www.familysearch.org)។ អ្នករៀនថ្មីដែលត្រូវទៅជួបទទួលបានមកពីប្រពន្ធ័ផ្សព្វផ្សាយ និងទីស្នាក់ការសាសនាចក្រ តំណាងឱ្យមនុស្សដែលបានយល់ព្រមឱ្យ មានអ្នកតំណាងសាសនាចក្រទៅជួប ដើម្បីចែកផ្ដល់វត្ថុមួយចំនួន (ដូចជាព្រះគម្ពីរបរិសុទ្ធ ឬព្រះគម្ពីរមរមន) ហើយនឹងត្រូវ បង្រៀនច្រើន អំពីសាសនាចក្រ។ អ្នកផ្សព្វផ្សាយសាសនា គួរតែចាត់ទុកថា ឱកាសនៃការបង្រៀនទាំងនេះ ជាការទទួលខុសត្រូវដ៏ពិសិដ្ឋមួយ។

មុនពេលអ្នកទៅជួបនឹងអ្នករៀនថ្មីដែលត្រូវទៅជួប ចូរឱ្យប្រាកដថា អ្នកស្គាល់អំពីវត្ថុ ដែលត្រូវបានស្នើសុំ។ ធ្វើផែនការមេរៀនខ្លីមួយ ដើម្បីធ្វើជាការផ្លាស់ប្ដូរពីការឱ្យវត្ថុទៅជា ការបង្រៀនសារលិខិត នៃការស្ដារឡើងវិញ។ នៅក្នុងករណីមួយចំនួន អ្នករៀនថ្មីដែលត្រូវទៅជួប នាំអ្នកឱ្យទៅជួបអ្នកដទៃទៀត ដែលព្រះកំពុងរៀបចំ។ បើមនុស្សដែលអ្នកទាក់ទង មិនចាប់អារម្មណ៍ទេ សូមសួរពួកគេបើពួកគេ ស្គាល់នរណាម្នាក់ ដែលអាចចាប់អារម្មណ៍។ សូមនិយាយជាមួយនិងសមាជិកដទៃទៀត នៃគ្រួសារនោះ និងអ្នកជិតខាងពួកគេផងដែរ។ សូមសួរម្នាក់ៗថា មាននរណាទៀត ដែលចាប់អារម្មណ៍ សារលិខិតរបស់អ្នក។ ប្រហែលជាអ្នក ត្រូវបាននាំឱ្យទៅជួបនឹងមនុស្សម្នាក់ទៀត ដោយសារមនុស្សម្នាក់ផ្សេងទៀត នៅក្នុងផ្ទះ ឬអ្នកជិតខាង ដែលរៀបចំជាស្រេច ដើម្បីទទួលដំណឹងល្អ។

នៅពេលធ្វើការជាមួយនិងអ្នករៀនថ្មី ដែលត្រូវទៅជួប ចូរចងចាំថាៈ

- ទាក់ទងជាមួយពួកគេក្នុងរយៈពេល 24 ម៉ោង។
- បើអាចធ្វើទៅបាន ចូរទូរសព្ទ័ទៅឱ្យបានឆាប់ ដើម្បីរៀបចំការណាត់ជួប សួរសុខទុក្ខ។ បើសិនជាពួកគេមិន នៅផ្ទះ ចូរព្យាយាមនៅពេលផ្សេងទៀត។
- នាំយកវត្ថុ ដែលពួកគេបានស្នើសុំ ហើយរំលឹកពួកគេថា ពួកគេស្នើរសុំឱ្យអ្នកមកជួប។ ការប្រមូលអ្នកដែលនៅក្នុងផ្ទះ ទាំងអស់គ្នាឱ្យស្ដាប់។
- បង្រៀនសារលិខិតនៃការស្ដារឡើងវិញ។
- ពង្រីកការអញ្ជើញ ដែលនឹងជួយសាងសេចក្ដីជំនឿរបស់ពួកគេនៅក្នុងព្រះគ្រីស្ទ។
- សួររកអ្នករៀនថ្មី ដែលត្រូវទៅជួបបន្ថែម។
- រៀបចំដើម្បីត្រឡប់មកជួបវិញ។
- ធ្វើផែនការដើម្បីជួបជាមួយនឹងអ្នកជិតខាងនោះ បន្ទាប់ពីការណាត់ជួបរបស់អ្នកបានបញ្ចប់។
- បើសិនជាមនុស្សមិននៅផ្ទះ ចូរនិយាយជាមួយនិងអ្នកជិតខាងរបស់ពួកគេ។

### សកម្មភាពៈ ការសិក្សាជាមួយដៃគូ

ចូរដាក់អ្នករៀនថ្មី ដែលត្រូវទៅជួបទាំងអស់ ដែលបានទទួលនៅក្នុងតំបន់របស់អ្នក កាលពីខែមុន។ ចូរបញ្ជាក់បើមាន មនុស្សទាំងឡាយដែលមិនបានទំនាក់ទំនង ឬមិនបានជួប។ ចូរសំរេចចិត្តថា អ្នកទាំងនោះណាមួយ ដែលបានជួបកាលពីមុនហើយ ហើយគួរតែទៅជួបម្ដងទៀត។

## ពង្សប្រវត្តិ

ពង្សប្រវត្តិ ឬពង្សាវលី ជាមធ្យោបាយមួយផ្សេងទៀត ដែលអ្នកអាចស្វែងរកមនុស្សដើម្បីបង្រៀន។ ពង្សប្រវត្តិ ក្នុងពេលបច្ចុប្បន្ននេះ គឺជាការកំសាន្តមួយ ដែលរីកសុះសាយច្រើនបំផុតនៅលើពិភពលោក។ វិញ្ញាណរបស់អេលីយ៉ា គឺមានឥទ្ធិពល ចំពោះមនុស្សរាប់លាននាក់ ទូទាំងពិភពលោក ដើម្បីស្រាវជ្រាវរកជីដូនជីតារបស់ពួកគេ។ មានសេចក្ដីប្រាថ្នាជាច្រើន ដែលចង់ ពង្រីកគ្រួសាររបស់ពួកគេ។ នេះ អាចដឹកនាំទៅរកសេចក្ដីប្រាថ្នាមួយ ដើម្បីរកទំនាក់ទំនង និងអត្តសញ្ញាណមួយ ជាមួយនិង គ្រួសាររបស់ព្រះ។

កំណត់ចំណាំ

> *"ខ្ញុំសង្ឃឹមថា នឹងឃើញយើងទាំងអស់គ្នាអាចរំលាយខ្សែខណ្ឌសីមាសប្បនិម្មិត ដែលជាញឹកញាប់ យើងដាក់នៅចន្លោះកិច្ចការអ្នកផ្សព្វផ្សាយសាសនា និងព្រះវិហារបរិសុទ្ធ និងកិច្ចការពង្សាវលី ពីព្រោះតែវាគឺដូចជាកិច្ចការដ៏ប្រោសលោះដែរ!"*
>
> — ប្រធានស្ពែនស៊ើរ ដបិលយូ ឃិមបល
> "THE THINGS OF ETERNITY—STAND WE IN JEOPARDY?"
> *ENSIGN*, ខែមករា ឆ្នាំ 1977, 3

ចូរកំណត់អំពីប្រភេទធនធាននៃពង្សប្រវត្តិជាអ្វីខ្លះ ដែលអាចមាននៅក្នុងតំបន់របស់អ្នក។ ឧទាហរណ៍ អ្នកអាចអញ្ជើញ មនុស្សទាំងឡាយឱ្យទៅមជ្ឈមណ្ឌលពង្សប្រវត្តិប្រចាំតំបន់ ឬណែនាំពួកគេឱ្យជួបសមាជិកដែលអាចជួយពួកគេធ្វើ ការស្រាវជ្រាវដំបូងអំពី ពង្សាវតា របស់ពួកគេ។ អ្នកមិនចាំបាច់ដឹងអំពីពង្សប្រវត្តិឱ្យបានច្រើនបំផុត ដើម្បីធ្វើកិច្ចការនេះទេ បើអ្នកមានជំនួយពីសមាជិក សាសនាចក្រ។ នៅតំបន់ភាគច្រើននៅលើពិភពលោក មានសមាជិកជាច្រើន ដែលអាចជួយអ្នកដទៃទៀតឱ្យស្រាវជ្រាវ អំពីឬសគល់គ្រួសាររបស់ពួកគេ។ ពេលដែលមានសមាជិកចូលរួមនឹងសាសនាគន់ការីដ៏មានសក្តានុពល នោះពួកគេនឹងជួបជាមួយនិងមនុស្ស ដែលអាចមានមិត្តភាព។ ចូរពន្យល់ថា ការប្រើប្រាស់មជ្ឈមណ្ឌលពង្សប្រវត្តិ គឺជាសេវាកម្ម មួយដែលឥតគិតលុយ។

នៅពេលអ្នកដើរគោះទ្វារតាមផ្ទះ អ្នកអាចចែកមនុស្សគ្រប់គ្នានូវកាតពង្សប្រវត្តិជាមួយនិងលេខទូរសព្ទ មជ្ឈមណ្ឌលពង្សប្រវត្តិប្រចាំតំបន់នៅក្នុងកាតនោះ ផ្តល់ឱ្យមានការស្រាវជ្រាវដំបូងអំពីឬសគល់គ្រួសារដោយឥតគិតថ្លៃ។ ធ្វើការទំនាក់ទំនងមួយទៀត នៅថ្ងៃបន្ទាប់ ឬពីរថ្ងៃក្រោយនៅផ្ទះ ដែលអ្នកទុកកាតឱ្យនោះ។ ចែកចាយកាតទាំងនេះជាមួយនិងសាសនាគន់ការី ដែលអាចឱ្យកាតទាំងនោះទៅមិត្តភក្តិ ឬសាច់ញាតិរបស់ពួកគេ។ នេះគឺជាគំនិតល្អមួយផងដែរ ដើម្បីមានតារាងបួន ជំនាន់ផ្ទាល់ខ្លួនរបស់អ្នក ធ្វើជាគំរូមួយ ហើយដើម្បីចែកចាយវាជាមួយអ្នកទាំងឡាយណា ដែលមានត្រកូលដូចគ្នានិងត្រកូលរបស់អ្នក។

ដើម្បីធ្វើការចាប់ផ្តើម ចូរពិចារណារបៀបធ្វើដូចខាងក្រោមៈ

- ទៅទស្សនាមជ្ឈមណ្ឌលពង្សប្រវត្តិ បើមានកន្លែងមួយនៅក្នុងតំបន់របស់អ្នក។
- ពិភាក្សាជាមួយនិងប៊ីស្សប និងក្រុមប្រឹក្សាវួដ ដែលអ្នកមានបំណងចង់ចែកចាយ ជាមួយនឹងពង្សប្រវត្តិរបស់អ្នកទាំងឡាយដែលអ្នកជួបរាល់ថ្ងៃ។
- ពិភាក្សាជាមួយនិងអ្នកដឹកនាំនៅក្នុងវួដ ពីរបៀបដើម្បីសម្របសម្រួលឱ្យបានល្អបំផុតចំពោះកិច្ចប្រឹងប្រែងនេះៈ
  - តើប៊ីស្សបមានអារម្មណ៍ល្អជាមួយនិងការស្នើរបស់អ្នក ដើម្បីជួយដល់សមាជិកនៅក្នុងវួដដែរឬទេ?
  - តើសមាជិកក្នុងវួដណាមួយ ដែលបំរើនៅក្នុងមជ្ឈមណ្ឌលពង្សប្រវត្តិ ឬមានបទពិសោធន៍ នៅក្នុងកិច្ចការពង្សប្រវត្តិ?
  - តើអ្នកអាចសុំជំនួយពីសមាជិកទាំងនេះបានយ៉ាងល្អបំផុតដោយរបៀបណា?
  - តើនរណាអាចអមអ្នកបាន នៅពេលអ្នកប្រគល់តារាងពង្សាវលី និងកំណត់ហេតុក្រុមគ្រួសារ?

សូមអានដំណើររឿង ដែលមានទាក់ទងនៅខាងក្រោម ដោយអ្នកផ្សព្វផ្សាយសាសនាប្អូន។ ចូរកត់ចំណាំអំពីតួនាទីរបស់ពង្សប្រវត្តិដើរតួនាទីនៅក្នុងការផ្លាស់ប្រែគនិតរបស់គូស្វាមីភរិយា។

*មិលទ្រេឌ ស្កាល្ប គឺជាសមាជិកដ៏រឹងមាំនៅក្នុងព្រះវិហាររបស់នាង។ វាគ្មានការភ្ញាក់ផ្អើលអ្វីទេ នៅពេលអ្នកផ្សព្វផ្សាយ សាសនាគោះទ្វាររបស់គាត់ គាត់មិនចង់ខ្ជះខ្ជាយពេល ដើម្បីអញ្ជើញអ្នកផ្សព្វផ្សាយសាសនាចូលទៅក្នុងផ្ទះ ដើម្បីគាត់អាច បង្រៀនអំពី "សេចក្តីពិត។" នៅពេលអ្នកផ្សព្វផ្សាយសាសនាបង្រៀន គាត់ត្រូវបានធ្វើអោយ ដក់ជាប់ក្នុងចិត្តដោយសេចក្តីពិត នៃដំណឹងល្អ ដែលបានស្តារឡើងវិញ ហើយបានទទួលបុណ្យជ្រមុជទឹក។ ក្នុងដំណើរការនៃការបង្រៀនទាំងមូល ប្តីរបស់គាត់ ហ្វ្រេង ជ្រើសរើសមិនស្តាប់ដំណឹងល្អទេ។*

*នេះគឺជាកន្លែង ដែលខ្ញុំមានការជាប់ទាក់ទង។ អែលឌើរ បានណែនាំយើងទៅបងស្រី ស្កាល្ប។ យើង បានជួយគាត់ឱ្យ ចាប់ផ្តើមពង្សាវលីរបស់គាត់ ហើយបន្ទាប់មកបានអញ្ជើញគាត់ឱ្យជួបពួកយើងនៅមជ្ឈមណ្ឌលពង្សប្រវត្តិ។ ថ្ងៃនៃការជួបរបស់យើងក៏បានមកដល់ ហើយលោកហ្វ្រេង បានសួរ បើសិនជាគាត់អាចមកដែរ ដើម្បីគាត់អាចស្រាវជ្រាវអំពីជីដូនជីតារបស់គាត់ផង។ ប្រាកដណាស់ បងស្រីគាត់មានចិត្តសប្បាយចំពោះគំនិតរបស់ប្តីគាត់ ហើយពួកគេបានធ្វើដំណើរទៅកាន់មជ្ឈមណ្ឌល។*

*អែលឌើរ បានរៀបចំដើម្បីជួបពួកយើងនៅទីនោះ អំឡុងពេលថ្ងៃ។ មុនពេលពួកគេមកដល់ យើងបានបង្ហាញ បណ្ណាល័យ ដល់ហ្វ្រេង និងមិលទ្រេឌ និងបានណែនាំពួកគេទៅស៊ីស្ទើរ ៉ាយ។ ស៊ីស្ទើរ ៉ាយ គឺជាអ្នកឯកទេស នៅក្នុងពង្សប្រវត្តិ ហើយគាត់ស្នើសុំជួយស្វែងរកពត៌មានអំពីគ្រួសាររបស់លោក ហ្វ្រេង។ គាត់រកឃើញឈ្មោះរបស់គាត់ នៅក្នុងសៀវភៅមួយ ហើយអាចផ្តល់ទៅឱ្យលោកហ្វ្រេងជាមួយនិងផែនទីនៃប្រទេសអាឡឺម៉ង់ផងដែរ ដែលបង្ហាញអំពីទីតាំង នៃកន្លែងកំណើតរបស់ ឪពុករបស់លោកហ្វ្រេង។ គាត់រំភើបយ៉ាងខ្លាំងអំពីការរកឃើញទាំងនេះ ហើយនៅពេលអែលឌើរមកដល់ គាត់បានអញ្ជើញពួកគេ ឱ្យញ៉ាំអាហារពេលល្ងាច ដើម្បីបង្ហាញរូបភាពទាំងឡាយ ហើយចែកចាយអំពីពង្សប្រវត្តិរបស់គាត់។ វិញ្ញាណរបស់អេលីយ៉ា បានដក់ជាប់ ហើយបន្ទន់ចិត្តគាត់ ហើយបានបើកទ្វារសំរាប់ដំណឹងល្អ ដើម្បីបំពេញនៅក្នុងជីវិតរបស់គាត់។*

កំណត់ចំណាំ

*នៅល្ងាចនោះ មិលទ្រេឌ ពិចារណាអំពីអ្វី ដែលគាត់អាចនិយាយ ដើម្បីជួយប្រ៉ែហ្វង ឱ្យមានចំណាប់អារម្មណ៍កាន់តែច្រើន នៅក្នុងដំណឹងល្អ។ សំណួរមួយកើតនៅក្នុងគំនិតរបស់គាត់។ គាត់ចាប់ផ្ដើម "ប្រ៉ែហ្វង" "តើបងចង់រស់នៅជាមួយអូនជារៀងរហូត សូម្បីតែបន្ទាប់ពីជីវិតនេះទៅឬទេ? តើបងចង់មានគ្រួសារដ៏អស់កល្បជានិច្ចមួយឬទេ?" គាត់ឆ្លើយតបមកវិញយ៉ាងឆាប់រហ័សថា "មែនហើយ មិលទ្រេឌ ប្រាកដណាស់បង ពិតជាចង់មានគ្រួសារដ៏អស់កល្បជានិច្ច។ តើបងអាចធ្វើដោយរបៀបណា? សំណួរនេះ គឺជាអ្វី ដែលគាត់បានអធិស្ឋាន។ គាត់បានឆ្លើយតប។"ចូរស្ដាប់អ្វី ដែលអ្នកផ្សព្វផ្សាយសាសនានិយាយចុះ។" ប្រ៉ែហ្វង យល់ព្រម នៅពេលអែលឌើរបានបង្រៀន ភាពកក់ក្ដៅនៃដំណឹងល្អនៃការស្ដារឡើងវិញ បានរំលាយសេចក្ដីសង្ស័យ និងភាពភ័យខ្លាច របស់គាត់។ គាត់បានទទួលរួចស្រេចហើយ ដើម្បីទទួលសេចក្ដីពិត ដែលអ្នកផ្សព្វផ្សាយសាសនាបានចែកចាយ។ គាត់ បានទទួលការអញ្ជើញឱ្យធ្វើបុណ្យជ្រមុជទឹក។ ប្រ៉ែហ្វង និងមិលទ្រេឌ រឹងមាំ និងសកម្មនៅក្នុងសាសនាតាំងពីពេលនោះមក។*

*ប្រ៉ែហ្វង និងមិលទ្រេឌ ប្រឹងប្រែង ដើម្បីបំពេញកិច្ចការ ដើម្បីអាចធ្វើពិធីការនៃការសង្គ្រោះសំរាប់គ្រួសាររបស់ពួកគេ។ វាគឺជាថ្ងៃដ៏រីករាយ នៅពេលពួកគេបានទទួលបុណ្យជ្រមុជទឹក ជំនួសឱ្យសមាជិកគ្រួសាររបស់ពួកគេ។ នៅក្នុងដំណើរការ ដើម្បីធ្វើកិច្ចការព្រះវិហារបរិសុទ្ធឱ្យស្រេចបាច់ បងប្រុសស្កាល្ស បានយល់សុបិន អំពីឪពុករបស់គាត់។ គាត់បានឃើញ ឪពុករបស់គាត់នៅវាលចិញ្ចឹមសត្វ ដែលជាផ្ទះមួយ កាលពីឪពុកគាត់នៅតាំងពីតូច។ ឪពុករបស់គាត់ឈរនៅជិតកោអីឃោល នៅវានហាល ស្លៀកពាក់ស ហើយកាន់ដៃកូនប្រុសរបស់គាត់។ ប្រ៉ែហ្វង ភ្ញាក់ពីសុបិននោះ យំ។ គាត់ដឹងថា ឪពុករបស់គាត់ បានទទួលកិច្ចការ ដែលពួកគេបានធ្វើនោះហើយ។*

## សកម្មភាពៈ ការសិក្សាជាមួយដៃគូ

- តើអ្វី ដែលមានឥទ្ធិពល ធ្វើឱ្យប្រ៉ែហ្វងសំរេចចិត្តឱ្យអ្នកផ្សព្វផ្សាយសាសនាបង្រៀនគាត់?
- តើអ្នកអាចភ្ជាប់កិច្ចការពង្សប្រវត្តិឱ្យបានប្រសើរជាងនេះ ចំពោះផែនការរបស់ព្រះសំរាប់ក្រុមគ្រួសារ ដោយរបៀបណា?
- តើអ្នកប្រើប្រាស់ពង្សប្រវត្តិ ជាឧបករណ៍មួយសំរាប់ស្វែងរកអ្នករៀនដោយរបៀបណា? តើមានមធ្យោបាយអ្វីខ្លះ ដែលអាចធ្វើឱ្យអ្នកអាចផ្ដល់ព័ត៌មានពង្សប្រវត្តិ ចំពោះមនុស្ស ដែលអ្នកជួបរៀងរាល់ថ្ងៃនោះ? ចូរធ្វើផែនការ ដើម្បីជាការចាប់ ផ្ដើមពង្សប្រវត្តិ ដែលជាឧបករណ៍មួយកាន់តែមានប្រសិទ្ធភាព នៅក្នុងការប្រឹងប្រែងរកអ្នករៀនរបស់អ្នក។

ពង្សប្រវត្តិ គឺជាធនធានដ៏មានអំណាចមួយ ដើម្បីប្រើប្រាស់នៅក្នុងការស្វែងរកអ្នកទាំងឡាយណា ដែលព្រះអម្ចាស់កំពុងរៀបចំ ដើម្បីទទួលដំណឹងល្អ ដែលបានស្ដារឡើងវិញ។ ចូរអធិស្ឋាន ដើម្បីឱ្យដឹងអំពីឱកាស ដើម្បីប្រើប្រាស់ពង្សប្រវត្តិនៅក្នុងការ ប្រឹងប្រែងរកអ្នករៀនរបស់អ្នក។ ជាតួយ៉ាង មនុស្សមានអារម្មណ៍ខាងវិញ្ញាណ នៅពេលពួកគេនិយាយអំពីក្រុមគ្រួសារ។ មនុស្សក៏មានអារម្មណ៍ខាងវិញ្ញាណ នៅពេលពួកគេត្រូវបានបង្រៀនអំពីគោលលទ្ធិ ដែលទាក់ទងអំពីមូលហេតុ ដែលពួកគេ ធ្វើកិច្ចការពង្សប្រវត្តិ ។ លើសពីនេះទៅទៀត ការថែរក្សាអ្នកផ្លាស់សាសនាថ្មី គឺជាការធ្វើឱ្យប្រសើរឡើង ក្នុងនាមជាសមាជិកថ្មី គឺមានលទ្ធភាព ដើម្បីធ្វើការស្រាវជ្រាវឬសគល់គ្រួសាររបស់ពួកគេ ហើយធ្វើពិធីការដ៏ពិសិដ្ឋទាំងឡាយ ជំនួសឱ្យជីដូនជីតារបស់ពួកគេ។

## ការសិក្សាព្រះគម្ពីរ

**តើព្រះអម្ចាស់បានស្ដារអ្វីខ្លះ ឡើងវិញលើផែនដី តាមរយៈលោកអេលីយ៉ា?**

| | | |
|---|---|---|
| គ និង ស 110:14–16 | គ និង ស 138:32–34 | ម៉ាឡាគី 4:5–6 |
| គ និង ស 128:16–18 | | |

## សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន និងជាមួយដៃគូ

រៀបចំដើម្បីទៅទស្សនាទៅមជ្ឈមណ្ឌលពង្សប្រវត្តិប្រចាំតំបន់ ជាមួយនឹងសមាជិកម្នាក់ ដែលមានបទពិសោធន៍ ជាមួយនឹងពង្ស ប្រវត្តិ។ នៅពេលអ្នកធ្វើដំណើរទៅទស្សនាទៅមជ្ឈមណ្ឌលពង្សប្រវត្តិ ចូរស្វែងយល់ពីប្រភេទនៃការបំរើ ដែលមាន។ ចូរស្វែងយល់ ពីព័ត៌មានផ្សេងៗទៀត ដូចជានៅពេលមជ្ឈមណ្ឌលបើក អ្នកណា ដែលបំរើនៅក្នុងមជ្ឈមណ្ឌល និងអ្វី ដែលជួយអ្នកទាំងឡាយ ដែលអ្នកជួបទាក់ទងរៀងរាល់ថ្ងៃ។

ហាត់ពីរបៀប ដែលអ្នកនឹងផ្ដល់ជំនួយខាងឱ្យពង្សប្រវត្តិ ដើម្បីជួយដល់អ្នកទាំងឡាយ ដែលអ្នកជួប។ ចូរធ្វើផែនការ ដើម្បីផ្ដល់ជំនួយពង្សប្រវត្តិនៅក្នុងការខិតខំប្រឹងប្រែងស្វែងរករបស់អ្នក។

---

អាន ហើយពិភាក្សា "Family History Work and Genealogy" នៅក្នុង *ពិតចំពោះសេចក្ដីជំនឿ* ដើម្បីទទួល បានការយល់ដឹងកាន់តែប្រសើរឡើងអំពីកិច្ចការពង្សប្រវត្តិ។ ចូរសរសេរអំពីអ្វី ដែលអ្នករៀននៅក្នុងសៀវភៅកត់ត្រាក្នុង ការសិក្សារបស់អ្នក។

កំណត់ចំណាំ

## សាសនាគន់ការីចាស់



© 2001 Del Parson. ហាមថតចម្លង។

សាសនាគន់ការីចាស់ គឺជាប្រភពដ៏មានតម្លៃ សំរាប់ស្វែងរកមនុស្សបង្រៀន។ មានមូលហេតុជាច្រើន ដែលមនុស្ស ឈប់រៀន នៅក្នុងសាសនាចក្រ។ មូលហេតុទាំងនោះ រួមមានអ្នកផ្សព្វផ្សាយសាសនា ផ្លាស់ប្ដូរតំបន់ សាសនាគន់ការីទៅ វិស្សមកាល អ្នកផ្សព្វផ្សាយសាសនាឈប់មកសួរសុខទុក្ខ ទោះបីជាសាសនាគន់ការី នៅតែមានបំណងក្នុងការសួរសុខទុក្ខ ហើយសាសនាគន់ការីជឿថាអ្នកផ្សព្វផ្សាយសាសនាគ្មានអ្វីថ្មី ដើម្បីបង្រៀនពួកគេ។ សាសនាគន់ការីចាស់ជាច្រើន និយាយថា ពួកគេនឹងជួបជាមួយអ្នកផ្សព្វផ្សាយសាសនាម្ដងទៀត។

បើកមើល សៀវភៅតំបន់របស់អ្នក ឱ្យបានញឹកញាប់ ដើម្បីស្គាល់សាសនាគន់ការីចាស់។ ចូរឆ្លុះបញ្ចាំងដោយការអធិស្ឋាន ស្ដីអំពីពត៌មាននៅក្នុងសៀវភៅតំបន់ អំពីរបៀប ដែលសាសនាគន់ការីមកទាក់ទងជាមួយនឹងសាសនាចក្រលើកដំបូង តើពួកគេបានបង្រៀនអ្វីខ្លះ តើពួកគេបានឆ្លើយតបដោយរបៀបណា ហើយហេតុអ្វីពួកគេឈប់រៀនដំណឹងល្អ។ បើសិនជាសមាជិក មានការជាប់ទាក់ទងនៅក្នុងការបង្រៀន ហើយរាក់ទាក់ជាមួយនឹងសាសនាគន់ការីចាស់ សូមសួរសមាជិកអំពីអ្វី ដែលពួកគេចងចាំបទពិសោធន៍។ ផ្ដោតទៅលើពត៌មាននេះ ចូរធ្វើផែនការ ដើម្បីទាក់ទងជាមួយនឹងសាសនាគន់ការីម្ដង ទៀត។

បើសិនជានរណាម្នាក់ ដែលអ្នកកំពុងបង្រៀន ឈប់បន្តការរៀនដំណឹងល្អរបស់ពួកគេ ចូរកត់ត្រាពត៌មាននៅក្នុងសៀវភៅតំបន់ ដែលនឹងជាជំនួយសំរាប់អ្នកផ្សព្វផ្សាយសាសនា ដែលនឹងទាក់ទងពួកគេនៅពេលអនាគត។

នៅពេលអ្នកអានបទពិសោធន៍នៅខាងក្រោមនេះ ចូរពិចារណាអំពីអំណាច នៃការទាក់ទងសាសនាគន់ការីចាស់។

*ភាពភ្ញាក់ផ្អើលយ៉ាងខ្លាំងរបស់ខ្ញុំ ខ្ញុំត្រូវបានហៅឱ្យបំរើនៅក្នុងបេសកកម្មដូចគ្នា នឹងបងស្រីរបស់ខ្ញុំ បានបំរើ កាលពីមួយឆ្នាំមុន។ បន្ទាប់ពីពីរបីខែនៅក្នុងបេសកកម្ម ខ្ញុំត្រូវបានផ្លាស់ទៅតំបន់មួយ ក្នុងចំណោមតំបន់នានា ដែលបងស្រីខ្ញុំ បានបំរើ។ ស្ថិតលើការរៀនសូត្ររបស់ខ្ញុំអំពីការផ្លាស់តំបន់ បងស្រីរបស់ខ្ញុំបានសរសេរសំបុត្រ ហើយសុំឱ្យខ្ញុំទៅ សួរសុខទុក្ខគ្រួសារមួយ ដែលគាត់ និងដៃគូរបស់គាត់បានបង្រៀន។ គាត់បង្ហាញអារម្មណ៍នៃសេចក្ដីស្រឡាញ់ និងភាពស្និទ្ធស្នាល ដែលគាត់មានជាមួយនឹងគ្រួសារ នរមែន និងតើគាត់ខកចិត្តប៉ុណ្ណា នៅពេលពួកគេមិនបន្តរៀនអំពីសាសនាចក្រ។*

*ដៃគូរបស់ខ្ញុំ និងខ្ញុំ បានរកឃើញគ្រួសារនរមែន ហើយត្រូវបានទទួលដោយកក់ក្ដៅពីពួកគេ។ ពួកគេទទួលការអញ្ជើញ របស់ពួកយើងឱ្យស្ដាប់ដំណឹងល្អ ដែលបានស្ដារឡើងវិញម្ដងទៀត។ ខ្ញុំមិនប្រាកដថា តើអ្វីដែលធ្វើឱ្យមានភាពខុសគ្នានៅពេលនេះទេ ប៉ុន្តែពួកគេបានរៀបចំជាស្រេច ដើម្បីទទួលសារលិខិតរបស់យើង។ គ្រួសារទាំងមូល ត្រូវបានទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។*

*បន្ទាប់ពីបទពិសោធន៍នេះ ខ្ញុំខ្វាយខ្វល់អំពីសាសនាគន់ការីចាស់ៗផ្សេងទៀត ដែលបងស្រីរបស់ខ្ញុំបានធ្វើការជាមួយ ពួកគេ។ ខ្ញុំបានគិតថា "បើសិនជាមានប្រសិទ្ធភាពជាមួយនឹងគ្រួសារនរមែន ប្រហែលជាវានឹងមានប្រសិទ្ធភាព ជាមួយនឹងអ្នក ផ្សេងទៀត ដែលបងស្រីរបស់ខ្ញុំបានបង្រៀនផងដែរ។" ខ្ញុំបានសំរេចចិត្តសរសេរសំបុត្រមកបងស្រីរបស់ខ្ញុំអំពីគំនិត នៃការទាក់ទង ជាមួយនឹងអ្នកផ្សេងទៀត ដែលគាត់បង្រៀន។ គាត់បានមើលទៅក្នុងទិន្នានុប្បវត្តិរបស់គាត់ ហើយផ្ញើរឈ្មោះជាច្រើន ដែលជា សាសនាគន់ការីចាស់ៗផ្សេងទៀតនៅក្នុងតំបន់មកឱ្យខ្ញុំ។*

*ដៃគូរបស់ខ្ញុំ និងខ្ញុំ បានចំណាយពេលនៅសប្ដាហ៍បន្ទាប់មក ដើម្បីទាក់ទងជាមួយនឹងមនុស្សទាំងនោះ។ ចំពោះ សេចក្ដីរីករាយយ៉ាងខ្លាំងរបស់យើង ស្ទើរតែពាក់កណ្ដាលនៃសាសនាគន់ការីទាំងអស់នោះ បានទទួលការអញ្ជើញឱ្យស្ដាប់ដំណឹងល្អ ដែលបានស្ដារឡើងវិញម្ដងទៀត។ មានមួយចំនួននៅក្នុងក្រុមនេះ បានទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។ នៅពេលជួប ជាមួយនឹងសាសនាគន់ការីចាស់ៗទាំងនេះ យើងបានសួរពួកគេអំពីអ្នករៀនថ្មីដែលត្រូវទៅជួប ដែលជាមិត្តភក្ដិ និងអ្នកដែលពួកគេស្គាល់ ដែលចាប់អារម្មណ៍នៅក្នុង សារលិខិតរបស់យើងផងដែរ។ ជាលទ្ធផល យើងរកបានមនុស្សបង្រៀនបន្ថែម។ នេះគឺជាពេលដ៏រវល់បំផុតនៃបេសកកម្មរបស់ខ្ញុំ។*

### សកម្មភាពៈ ការសិក្សាជាមួយដៃគូ

- កត់សំគាល់អំពីសាសនាគន់ការីចាស់ៗទាំងអស់ នៅក្នុងសៀវភៅតំបន់របស់អ្នក។
- ធ្វើផែនការ ដើម្បីទាក់ទងឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន អំឡុង 24 ម៉ោងបន្ទាប់។

កំណត់ចំណាំ

## ការស្វែងរកអ្នករៀន តាមរយៈកិច្ចប្រឹងប្រែងរបស់អ្នកផ្ទាល់

ចូរស្វែងរក ដើម្បីពង្រឹងសេចក្តីជំនឿរបស់អ្នកថា ព្រះកំពុងរៀបចំកូនចៅរបស់ទ្រង់ ឱ្យទទួលសារលិខិតនៃការស្តារឡើងវិញ។ នៅពេលអ្នកធ្វើអស់សមត្ថភាព នៅក្រោមការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីរកមនុស្សបង្រៀន ព្រះអម្ចាស់នឹងដាក់មនុស្សទាំងអស់ នៅលើផ្លូវរបស់អ្នក។

មានមធ្យោបាយជាច្រើន ដ៏ប្រកបដោយកិត្តិយស ដើម្បីស្វែងរកអ្នកទាំងឡាយ ដែលបានរៀបចំសំរាប់ដំណឹងល្អ ដែលបានស្តារឡើងវិញ។ អ្នកត្រូវធ្វើអោយអស់ពីសមត្ថភាព ដែលអ្នកអាចត្រូវបានដាក់នៅលើផ្លូវសំរាប់អ្នកទាំងនោះ ដែលត្រូវបានរៀបចំហើយ។ អ្នកផ្សព្វផ្សាយសាសនា បានរកឃើញថា គំនិតនៅខាងក្រោមនេះ បានជួយដល់ពួកគេឱ្យរកមនុស្ស បង្រៀនដោយការកិច្ចប្រឹងប្រែងរបស់ពួកគេផ្ទាល់។ នៅពេលអ្នករំលឹកបញ្ជីសារឡើងវិញ ចូរធ្វើផែនការ ដើម្បីសាកល្បងគំនិត ទាំងនេះខ្លះៗ ដែលជាគំនិតថ្មីសំរាប់អ្នក។ បញ្ជីនេះក៏បានបំរើជាចំណុចចាប់ផ្តើមមួយផងដែរ សំរាប់អ្នកនៅក្នុងការគិត អំពីមធ្យោបាយផ្សេង ទៀត ដ៏ប្រកបដោយកិត្តិយស ដើម្បីរកមនុស្សបង្រៀន។



- ធ្វើការជាមួយនឹងប៊ីស្សប និងក្រុមប្រឹក្សានៅក្នុងវួដ ដើម្បីធ្វើការបញ្ជាក់ និងទាក់ទងជាមួយមនុស្ស ដែលទើប តែមានកូនង៉ែតថ្មីៗ ផ្លាស់ចូលមកតំបន់ ឬមានបទពិសោធន៍មួយដោយមាននរណាម្នាក់ទទួលមរណៈភាពនៅក្នុងគ្រួសារ។
- ស្វែងរកឱកាស ដើម្បីផ្តល់នូវការបំរើដ៏សាមញ្ញ។
- បង្រៀនសមាជិក—ទាំងសមាជិកសកម្ម និងមិនសូវសកម្ម អ្នកផ្លាស់ប្រែគំនិតថ្មី និងអ្នកដែលជាសមាជិកតែម្នាក់ក្នុង ក្រុមគ្រួសារ—អំពីសារលិខិតនៃការស្តារឡើងវិញ។ សួរពួកគេឱ្យណែនាំអ្នក ទៅកាន់មនុស្សដែលអ្នកអាចបង្រៀន។
- រៀបចំឱ្យមានការប្រជុំពិសេសជាមួយនឹងសមាជិក ដើម្បីពួកគេអាចនាំមិត្តភក្តិរបស់ពួកគេ ឬ ដែលអ្នកអាចបង្រៀន ដំណឹងល្អ និងសួររកអ្នករៀនថ្មីដែលត្រូវទៅជួប។
- ជួយបង្រៀនដល់មនុស្ស អំពីរបៀបធ្វើការប្រជុំរាត្រីក្រុមគ្រួសារ។
- ជួយយកអ្នកទាំងឡាយ ដែលអ្នកជួប ទៅទស្សនាសាលាប្រជុំនៅក្នុងតំបន់។
- ជួយរៀបចំការប្រជុំជាមួយនឹងប៊ីស្សប។
- អញ្ជើញមនុស្សឱ្យមើលនៅ www.mormon.org.
- រៀបចំថ្នាក់សិក្សាបទគម្ពីរមួយ។
- បង្រៀនភាសាអង់គ្លេស ដែលជាភាសាទីពីរ។
- អញ្ជើញមនុស្ស ដែលមានអាយុសមរម្យឱ្យចូលរួមនៅក្នុងថ្នាក់សិក្ខាសាលា ឬថ្នាក់វិទ្យាស្ថាន។
- ចេញពីផ្ទះមួយទៅផ្ទះមួយទៀត ឬនិយាយជាមួយមនុស្សនៅតាមផ្លូវ។
- ប្រើប្រាស់កាតផ្សព្វផ្សាយ ឌីវីឌី វីដេអូ និងកូនសៀវភៅតូចៗ។
- រកអ្នករៀនថ្មីដែលត្រូវទៅជួបមកពីសាសនាគន់ការីថ្មី សាសនាគន់ការីចាស់ សមាជិកមិនសូវសកម្ម អ្នកត្រៀមចេញជាអែលឌើរ និងមនុស្សគ្រប់គ្នា ដែលអ្នកជួប។
- សម្របសម្រួលជាមួយនឹងអ្នកតំណាងកិច្ចការសាធារណៈ របស់សាសនាចក្រប្រចាំតំបន់ឱ្យបានជិតស្និទ្ធ សំរាប់ឱកាស ទទួលបានការបោះពុម្ពអត្ថបទនៅក្នុងការសែតប្រចាំតំបន់ អំពីការបំរើរបស់អ្នកផ្សព្វផ្សាយសាសនារបស់អ្នក។
- អញ្ជើញមនុស្សឱ្យទៅកាន់ការប្រជុំរបស់សាសនាចក្រ សកម្មភាព និងការសម្ពោធទាំងឡាយ។
- អញ្ជើញមនុស្សឱ្យចូលរួមនៅក្នុងការបំរើពិធីបុណ្យជ្រមុជទឹក។ ទាំងនេះផ្តល់ជាការណែនាំដ៏ល្អបំផុតអំពីសាសនាចក្រ ហើយជាឱកាសល្អគ្រប់គ្រាន់ សំរាប់សាសនាគន់ការីទទួលអារម្មណ៍ឥទ្ធិពលពីព្រះវិញ្ញាណបរិសុទ្ធ។

កំណត់ចំណាំ

## ទៅចុះឡើងធ្វើការល្អ

សេចក្ដីជំនឿរបស់អ្នក ដើម្បីរកមនុស្សបង្រៀន ត្រូវបានបង្ហាញតាមរយៈសកម្មភាពរបស់អ្នក។ អំឡុងនៃការបង្រៀន របស់ទ្រង់នៅក្នុងជីវិតរមែងស្លាប់ ព្រះអង្គសង្គ្រោះ "មកយករូបភាពជាបាវបំរើវិញ" (ភីលីព 2៖7)។ ទ្រង់បានយាងចុះឡើង "ធ្វើការល្អ" (កិច្ចការពួកសាវក 10៖38) ហើយ "ប្រកាសដំណឹងល្អ" (ម៉ាថាយ 4៖23)។ នៅពេលអ្នកធ្វើតាមគំរូនេះ អ្នកនឹងរកឃើញអ្នកទាំងឡាយណា ដែលនឹងទទួលអ្នក។

តាមរយៈការបំរើ អ្នក និងអ្នកទាំងឡាយ ដែលត្រូវបានរៀបចំសំរាប់ដំណឹងល្អ ដែលបានស្ដារឡើងវិញនឹងមកជាមួយគ្នាលើមាគ៌ាប្រកបដោយអំណាច និងការបំផុសគំនិត។ កិច្ចការល្អរបស់អ្នកនឹងជួយមនុស្ស ឱ្យស្គាល់អ្នកថា ជាអ្នកបំរើរបស់ព្រះ ហើយនឹងនាំអ្នកទៅកាន់ឱកាស ដើម្បីបង្រៀនដំណឹងល្អដែលបានស្ដារឡើងវិញ។



បទពិសោធន៍របស់អ្នកផ្សព្វផ្សាយសាសនាជាច្រើនជាមួយនឹងការបំរើមុនពេលបេសកកម្មរបស់ពួកគេបានជាប់ទាក់ទងការរៀបចំ " គម្រោងការបំរើ។" ដូចជាការជួយនរណាម្នាក់ផ្លាស់ទីលំនៅ ការបំរើនៅក្នុងកសិដ្ឋានសាសនាចក្រ ឬសំអាតបរិវេណផ្ទះ។ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ អ្នកនឹងជួយផ្ដល់នូវការបំរើដូច្នេះរាល់សប្ដាហ៍ (សូមមើល *សៀវភៅណែនាំ អ្នកផ្សព្វផ្សាយសាសនា* សំរាប់ជាពត៌មានបន្ថែម)។

ប្រភេទនៃការបំរើត្រូវបានពិពណ៌នានៅក្នុងវគ្គនេះ ផ្ដោតទៅលើឱកាសដែលមិនបានគ្រោងទុក។ ការបំរើប្រភេទនេះមានទំនាក់ទំនងនិងការស្ដាប់តាមព្រះវិញ្ញាណ ដើម្បីដឹងអំពីឱកាសទាំងឡាយ សំរាប់ទង្វើចិត្តល្អតិចតួច សាមញ្ញ ដែលអ្នកអាចផ្ដល់អោយកូនចៅនៃព្រះ។ ចូរអធិដ្ឋាន និងដឹងជាមុនអំពីឱកាសរាល់ថ្ងៃគ្រប់ពេលដើម្បីធ្វើល្អ។ នៅពេលអ្នកស្វែងរកធ្វើល្អ អ្នកនឹងត្រូវបានដឹកនាំទៅកាន់មនុស្ស ដែលត្រូវបានរៀបចំដើម្បីទទួលដំណឹងល្អដែលបានស្ដារឡើងវិញ។

នៅពេលអ្នកអានដំណើររឿងនៅខាងក្រោមនេះ ចូរកត់ចំណាំរបៀប ដែលអ្នកផ្សព្វផ្សាយសាសនា "ធ្វើល្អ" ហើយបានប្រកាសដំណឹងល្អ។

> "តើអ្នកចង់បានសេចក្ដីសប្បាយឬទេ? បំភ្លេចខ្លួនរបស់អ្នក ហើយលះបង់ខ្លួនរបស់អ្នកទាំងស្រុងទៅលើការព្យាយាមក្នុងផ្លូវដ៏ធំនេះ ឱ្យការខំប្រឹងប្រែងរបស់អ្នកទៅជួយអ្នកដទៃ ...។ ការកាន់តែឥតខ្ចោះ ដោយលើក ដៃដែលស្រពន់ឡើង និងជង្គង់ដែលស្ពុតដែរ។ ការរស់នៅតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។"
>
> — ប្រធាន គរដិន ប៊ី ហ៊ីងឃ្លី
> *TEACHINGS OF GORDON B. HINCKLEY*, 597

*ប៉ាប្លូ មកថ្នាក់ភាសាអង់គ្លេសរបស់យើងជារៀងរាល់សប្ដាហ៍។ គាត់ជាសុភាពបុរស ចូលនិវត្តន៍ម្នាក់ ដែលមករៀនភាសា អង់គ្លេស ដើម្បីជួយធ្វើឱ្យគាត់ឈប់ខ្វល់ខ្វាយ គាត់គិតពីប្រពន្ធគាត់ដែលមានជំងឺ ជានិច្ច។ នៅសប្ដាហ៍មួយនោះ គាត់ឈប់មករៀន។ ហើយគ្មាននរណាដឹងពីមូលហេតុអ្វីនោះទេ។ ប្រហែលជាមួយខែក្រោយមក គាត់មកថ្នាក់រៀនម្ដងទៀត។ គាត់មើលទៅប្លែកពីមុន។ គាត់ស្គម ហើយមើលទៅក្រៀមក្រំទៀតផង។ គាត់មិនបានចូលរួម នៅក្នុងថ្នាក់ដូចកាលពីមុនទេ គាត់ចាកចេញពីថ្នាក់មុនពេលពួកយើងអាចនិយាយជាមួយគាត់។*

*នៅសប្ដាហ៍បន្ទាប់ ដៃគូរបស់ខ្ញុំ និងខ្ញុំ បានអធិស្ឋានសុំឱ្យ ប៉ាប្លូ ត្រឡប់មកថ្នាក់រៀនវិញ ដើម្បីយើងអាចនិយាយជាមួយ គាត់។ ការអធិស្ឋានរបស់យើងបានទទួលចំលើយ ពេលដែលគាត់បានមកថ្នាក់រៀនពេលក្រោយទៀត។ នៅពេលយើងនិយាយ ជាមួយគាត់បន្ទាប់ពីរៀនចប់ គាត់បានប្រាប់យើងថាប្រពន្ធរបស់គាត់ស្លាប់ហើយ។ គាត់បានប្រាប់យើងបន្តិចបន្តួច អំពីបទពិសោធន៍ ហើយយើងបង្ហាញនូវការសោកស្ដាយ។ យើងបានប្រាប់គាត់ថា យើងចង់ជួយគាត់ឱ្យយល់ ពីរបៀប ដែលគាត់អាចនៅជាមួយនឹងប្រពន្ធរបស់គាត់ម្ដងទៀត។ គាត់បានងើបមុខឡើង ហើយមើលមកក្នុងកែវភ្នែករបស់ខ្ញុំជាមួយនឹងទឹកភ្នែកដោយកំហឹង និងភាពសោកស្ដាយ "បើអ្នកពិតជាចង់ជួយខ្ញុំ អ្នកអាចមកផ្ទះរបស់ខ្ញុំ ហើយជួយខ្ញុំឱ្យរៀបចំជីវិត របស់ខ្ញុំជាថ្មីឡើងវិញ។ តើនោះមិនមែនជាអ្វីដែលអ្នកផ្សព្វផ្សាយសាសនាធ្វើទេឬអី? ខ្ញុំត្រូវការជំនួយឱ្យរៀបចំផ្ទះរបស់ខ្ញុំ និងកិច្ចការទាំងឡាយឱ្យមានរបៀបរៀបរយ។"*

*យើងភ្ញាក់ផ្អើល ហើយបន្ទាបខ្លួនចំពោះការអធិប្បាយរបស់ប៉ាប្លូ។ យើងជួយផ្ដល់ការជួយជ្រោមជ្រែងអ្វីៗទាំងអស់ ដែលគាត់ត្រូវការ។ ខ្ញុំគិតថានោះជាចំណុចដែលគាត់ចាប់ផ្ដើមទុកចិត្ត ទៅលើការយកចិត្តទុកដាក់របស់យើង។ គាត់បានប្រាប់យើង ឱ្យទៅផ្ទះរបស់គាត់នៅថ្ងៃ បន្ទាប់ដើម្បីជួយគាត់កាត់មែកឈើ។ យើងបានទៅផ្ទះរបស់គាត់តាមពេលណាត់ជួប ហើយចាប់ផ្ដើម ធ្វើការជាមួយគាត់។ អស់រយៈពេលជាច្រើនខែដែលគាត់ថែរក្សាប្រពន្ធរបស់គាត់ គាត់មិនបានធ្វើការងារនៅជុំវិញបរិវេណ និងផ្ទះ របស់គាត់។ មានការងារជាច្រើនសំរាប់ពួកយើងទាំងបីនាក់ធ្វើ។ នេះបានក្លាយទៅជាបទពិសោធន៍ ការបំរើនៅផ្ទះរបស់គាត់ ជាប្រចាំសប្ដាហ៍។ យើងកាត់មែកឈើ ដកស្មៅ ហើយបេះផ្លែឈើ។ យើងមិនបានចាប់ផ្ដើមការបង្រៀនទេ—នៅពេលណា ដែល យើងព្យាយាមចាប់ផ្ដើមការបង្រៀន គាត់ក៏បញ្ឈប់ការសន្ទនារបស់យើងភ្លាម។ គាត់ ពេញចិត្តយ៉ាងខ្លាំង នៅពេលយើងនិយាយ អំពីជីវិត និងគ្រួសាររបស់គាត់។ ភាគច្រើនយើងបានត្រឹមតែស្ដាប់ប៉ុណ្ណោះ។*

*ប្រហែលជាមួយខែកន្លះក្រោយមក ប៉ាប្លូធ្វើឱ្យយើងភ្ញាក់ផ្អើល ដោយសួរយើងថា "តើខ្ញុំពិតជានឹងបានជួបប្រពន្ធ របស់ខ្ញុំវិញឬ? យើងបានឆ្លើយតបដោយរីករាយថា គាត់ពិតជាជួបប្រពន្ធរបស់គាត់ម្ដងទៀត។ យើងបានធ្វើទីបន្ទាល់អំពី ក្រុមគ្រួសារដ៏អស់កល្បជានិច្ច ហើយព្យាយាមឆ្លើយដោយអស់ពីសមត្ថភាពចំពោះសំនួររបស់គាត់។*

*យើងបានបង្រៀនប៉ាប្លូ អំពីផែនការនៃសេចក្ដីសង្គ្រោះ។ គាត់ត្រូវបានផ្លាស់ប្ដូរដោយគោលលទ្ធិ។ ពីមុនពួកយើង ចាកចេញ គាត់បានអោយបញ្ជីសំណួរមួយ ដែលគាត់ចង់បានចម្លើយ ដូចជា "តើប្រពន្ធរបស់ខ្ញុំនឹងមានរូបកាយឬទេ នៅពេលខ្ញុំជួបគាត់ម្ដងទៀត?" និង "តើយើងនឹងគ្មានជំងឺ និងឈឺចាប់ទៀតរឺទេ?" យើងបានឆ្លើយសំណួររបស់គាត់ ហើយធ្វើការណាត់ជួបម្ដងទៀត ដើម្បីពិភាក្សាអំពីគោលការណ៍ទាំងឡាយ នៃដំណឹងល្អដែលបានស្ដារឡើងវិញនៃ ព្រះយេស៊ូវគ្រីស្ទ។*

*តាំងពីពេលនោះមកក្នុងរយៈពេលដ៏ខ្លី ទឹកមុខរបស់ប៉ាប្លូក៏បានផ្លាស់ប្ដូរ។ គាត់ញញឹមច្រើនជាងមុន និងមើលទៅ មានសន្តិភាពច្រើនផងដែរ។ គាត់ពិតជាមាន "សង្ឃឹមជាប្រាកដថា នឹងបានពិភពលោកមួយដ៏ប្រសើរ" (អេធើរ 12៖4)។ ការបំរើរបស់យើងបានជួយ ឱ្យគាត់មានទំនុកចិត្តទៅលើអ្វីៗ ដែលយើងបង្រៀន។*

## សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន និងជាមួយដៃគូ

- តើអ្នកផ្សព្វផ្សាយសាសនានៅក្នុងដំណើររឿងនេះ "ធ្វើល្អ"ដោយវិធីណា?
- តើការបំរើបានដើរតួអ្វីខ្លះ នៅក្នុងការសំរេចចិត្តរបស់ប៉ាប្លូ ដើម្បីទទួលការបង្រៀនដំណឹងល្អ?
- តើអ្នកស្វែងរកឱកាស ដើម្បីធ្វើល្អរាល់ថ្ងៃគ្រប់ពេលឬទេ? តើអ្នកអាចកែលំអនៅក្នុងផ្នែកនេះឬទេ?

សរសេរនៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក ឬពិភាក្សាជាមួយនឹងដៃគូរបស់អ្នកពីរបៀប ដែលអ្នកអាចធ្វើល្អកាន់តែ ច្រើនរាល់ថ្ងៃ ដើម្បីស្វែងរកមនុស្សកាន់តែច្រើន ដើម្បីបង្រៀន។

សូមជឿថា មនុស្សដែលបានរៀបចំ ដើម្បីទទួលសារលិខិតនៃការស្ដារឡើងវិញ នឹងដាក់មកលើផ្លូវរបស់អ្នក។ ព្រះនឹងដាក់អ្នកនៅចំទង្វើ និងពាក្យល្អរបស់អ្នក នឹងរៀបចំមនុស្សឱ្យទទួលអ្នកផ្សព្វផ្សាយសាសនានិងសមាជិកសាសនាចក្រ ផងដែរ។ រាល់ការខិតខំស្វែងរករបស់អ្នក ចូរអធិស្ឋាន និងស្វែងរកឱកាសដើម្បីបំរើ ជួយ និងលើកស្ទួយអ្នកដទៃ។ នៅពេលអ្នកកំពុងបំរើ ចូរនិយាយជាមួយមនុស្សរាល់គ្នា ដែលអ្នកជួប។ ចូរមានជំនឿថា អ្នកអាចចែកចាយដំណឹងល្អ ដែលបានស្ដារឡើងវិញ។



នៅគ្រប់វិធីដែលអ្នកបំរើ អ្នកគួរតែធ្វើដូច្នោះ ពីព្រោះអ្នកស្រឡាញ់បងប្អូនប្រុសស្រីរបស់អ្នក ហេតុដូច្នោះហើយសេចក្ដីសង្ឃឹម ការអធិស្ឋាន និងបំណងប្រាថ្នាដ៏ស្មោះស្ម័គ្រ ដើម្បីបង្រៀនពួកគេអំពីដំណឹងល្អ ដែលបានស្ដារឡើងវិញ។

## ការណែនាំ

**ចូរចងចាំការណែនាំខាងក្រោមនេះ នៅពេលអ្នកស្វែងរកធ្វើល្អៈ**

- នៅជាមួយដៃគូរបស់អ្នក។
- រក្សានិស្ស័យដ៏ពិសិដ្ឋ នៃមុខងាររបស់អ្នក។
- រក្សាច្បាប់អ្នកផ្សព្វផ្សាយសាសនា ហើយកុំបរិច្ចាគ ឬប្រើប្រាស់លុយរបស់អ្នក។
- សូមមើល *សៀវភៅណែនាំអ្នកផ្សព្វផ្សាយសាសនា* សំរាប់ជាការណែនាំទាក់ទងនឹងការបំរើក្នុងសហគមន៍ប្រចាំសប្ដាហ៍។

កំណត់ចំណាំ

កំណត់ចំណាំ

## ការសិក្សាព្រះគម្ពីរ

**តើតួនាទីនៃការបំរើ នៅក្នុងជីវិតនៃព្រះអង្គសង្គ្រោះគឺជាអ្វី?**

នីហ្វៃទី3 17:7, 21 — ម៉ាថាយ 9:1–8 — យ៉ូហាន 4:46–54
ម៉ាថាយ 8:1–4 — ម៉ាកុស 1:21–28

**តើតួនាទីនៃការបំរើនៅក្នុងបេសកកម្មរបស់អាំម៉ូន និងអើរ៉ុន គឺជាអ្វី?**

អាលម៉ា 17:19–25 — អាលម៉ា 18:8–10 — អាលម៉ា 22:3

**តើព្រះអម្ចាស់សុំឱ្យអ្នកធ្វើអ្វីខ្លះ?**

នីហ្វៃទី3 27:21

## គ្មានការប្រឹងប្រែងណា ដែលឥតប្រយោជន៍នោះទេ

នៅពេលមនុស្សជ្រើសរើសមិនរៀនដំណឹងល្អ ដែលបានស្តារឡើងវិញ កិច្ចការរបស់អ្នកមិនមែនឥតប្រយោជន៍នោះទេ។ ការខិតខំប្រឹងប្រែងជាប្រចាំរបស់អ្នកនៅក្នុងការបំរើ និងការបង្រៀនមនុស្សឱ្យបានច្រើនដែលអ្នកអាចធ្វើទៅបាន គឺជាវិធីមួយ ដែលព្រះរៀបចំកូនចៅរបស់ទ្រង់ ឱ្យទទួលអ្នកបំរើទាំងឡាយរបស់ទ្រង់។ ជាញឹកញាប់ ទ្រង់សម្តែងចំពោះកូនចៅរបស់ទ្រង់ តាមរយៈអ្នក។ សូម្បីតែនៅពេលមនុស្សមិនទទួលយកឱកាស ដើម្បីរៀនដំណឹងល្អក៏ដោយ ក៏ការបំរើ និងពាក្យសំដីរបស់អ្នក គឺជាភស្តុតាងនៃសេចក្តីស្រឡាញ់របស់ព្រះចំពោះពួកគេ ហើយបន្សល់ទុកនូវឥទ្ធិពលសំរាប់អ្នកផ្សព្វផ្សាយសាសនានាពេលអនាគត និងសមាជិក នៃសាសនាចក្រស្ថាបនាពីលើនោះ។

នៅពេលមនុស្សមិនទទួលយកដំណឹងល្អ ចូរកុំអោយមានការបាក់ទឹកចិត្ត។ អ្នកបានដំឡើងសម្លេងនៃការព្រមានមួយហើយ។ អ្នកបានផ្តល់ឱ្យពួកគេនូវការជ្រើសរើសដ៏ច្បាស់លាស់មួយ។ សិស្សរបស់ព្រះគ្រីស្ទ មានអារម្មណ៍សោកស្តាយ នៅពេលមនុស្ស ជ្រើសរើសមិនប្រែចិត្ត ប៉ុន្តែពួកគេបន្តយល់ដឹង អំពីខ្លួនពួកគេ ថាជានរណា និងកិច្ចការអ្វី ដែលពួកគេកំពុងធ្វើ។ ពួកគេបន្ត ដោយព្យាយាម ដើម្បីបន្តទៅមុខទៀត។

## ចូរចងចាំចំណុចនេះ

- ស្ថាបនាសាសនាចក្រឡើង ដោយការស្វែងរកអ្នកទាំងឡាយណា ដែលនឹងទទួលអ្នក (សូមមើល គ និង ស 42:8)។
- ស្វែងរក និងធ្វើតាមព្រះវិញ្ញាណ នៅពេលស្វែងរកអ្នករៀន។
- មនុស្សនៅក្នុងតំបន់របស់អ្នក ត្រូវបានរៀបចំដើម្បីទទួលយកដំណឹងល្អ ដែលបានស្តារឡើងវិញ។
- សមាជិកនៃសាសនាចក្រ—រួមមានអ្នកទាំងឡាយណា ដែលសកម្ម មិនសូវសកម្ម និងអ្នកត្រៀមធ្វើជា អែលឌើរ និងអ្នកផ្លាស់ប្រែចិត្តថ្មី—គឺជាធនធានដ៏ល្អ បំផុតរបស់អ្នក សំរាប់ការស្វែងរកអ្នករៀន ទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។
- អភិវឌ្ឍន៍ទំនាក់ទំនងរឹងមាំមួយ ជាមួយនឹងប៊ីស្សប និងសមាជិកទាំងឡាយ។
- បង្រៀននៅពេលអ្នកស្វែងរក ហើយស្វែងរកនៅពេលអ្នកបង្រៀន។
- ត្រូវស្គាល់អំពីឱកាស ស្វែងរកអ្នករៀន ដែលមិនបានគ្រោងទុក។
- អធិស្ឋានសំរាប់ឱកាស ដើម្បីធ្វើល្អ និងផ្សព្វផ្សាយសារលិខិត នៃការស្តារឡើងវិញ នៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។
- មានវិធីជាច្រើន ដើម្បីស្វែងរកមនុស្សបង្រៀន។ ចូរចៀសវាងពីការផ្តោតទៅលើការចូលទៅជួបតែមនុស្សម្នាក់ឬ ពីរនាក់។

## គំនិតសំរាប់ការសិក្សា និងការអនុវត្ត

កំណត់ចំណាំ

### ការសិក្សាផ្ទាល់ខ្លួន

- ចូរអានសំបុត្រខាងក្រោមនេះ មកពីអ្នកផ្សព្វផ្សាយសាសនាម្នាក់ ទៅកាន់ឳពុកម្ដាយរបស់នាងមានដូចជាៈ “ខ្ញុំបានបង្រៀនស្រ្តីដ៏អស្ចារ្យម្នាក់ នៅលើឡានក្រុង។ ពេលយើងកំពុងតែត្រឡប់មកពីការប្រជុំនៅក្នុងមណ្ឌលវិញ ហើយឡានក្រុង មានកៅអីទំនេរតែមួយ ដូច្នេះខ្ញុំបានអង្គុយចុះ ហើយចាប់ផ្ដើមមើលសំបុត្ររបស់ខ្ញុំ។ ប្រាកដណាស់ សំបុត្រទីមួយគឺត្រូវអានសំបុត្រ របស់អ្នកជាមួយនឹងរូបថតកូនឆ្មែតអេវ៉ាន។ ខ្ញុំកត់សំគាល់ថា ភ្នែករបស់អ្នកដែលនៅជិតនឹងខ្ញុំ កំពុងមើលរូបថតទាំងនោះ ផងដែរ ហើយខ្ញុំបានមើលទៅប្រទះនឹងភ្នែករបស់ស្រ្តីចំណាស់ម្នាក់។ គាត់ញញឹមដាក់ខ្ញុំបន្តិច ហើយក៏ក្រឡេកមើលទៅតាមបង្អួច។ ក្រោយមកគាត់បិទភ្នែក ហាក់ដូចជាដេកលក់។ ខ្ញុំ បានអធិស្ឋានដល់ព្រះវរបិតាសួគ៌ ខ្ញុំចង់និយាយជាមួយគាត់។ សូមជួយខ្ញុំ។ មួយនាទីក្រោយមក គាត់បើកភ្នែក ហើយអង្គុយត្រង់ខ្លួន ហើយរំពេចនោះខ្ញុំ បាននិយាយថា ‘ តើអ្នកមិនគិតថា គាត់គួរឱ្យស្រឡាញ់ទេឬអី?’ ខ្ញុំបានបង្ហាញរូបថតរបស់អីវ៉ាន ដល់គាត់ ហើយចាប់ផ្ដើមនិយាយអំពីក្រុមគ្រួសារជាមួយគាត់។ ខ្ញុំបានសួរគាត់ អំពីកូនៗរបស់គាត់ ហើយគាត់មានទឹកភ្នែករលីងរលោង ហើយប្រាប់ខ្ញុំរឿងមួយ អំពីរឿងដែលកូនស្រីរបស់គាត់ស្អប់គាត់ ហើយមិនចង់ធ្វើអ្វីទាំងអស់សំរាប់គាត់ឡើយ។ គាត់បានយំ ហើយខ្ញុំក៏យំជាមួយគាត់។ ខ្ញុំបានប្រាប់គាត់អំពីផែនការ នៃសេចក្ដីសង្គ្រោះ និងថាព្រះវរបិតាសួគ៌ស្គាល់គាត់ និងដឹងអំពីអ្វីៗ ដែលគាត់បានឆ្លងកាត់។ ខ្ញុំបានយំ ហើយប្រាប់គាត់ថា ខ្ញុំដឹងថាកូនស្រីរបស់គាត់ស្រឡាញ់គាត់ ពីព្រោះខ្ញុំក៏ជាកូនរបស់ម្ដាយម្នាក់ ដែលស្រឡាញ់ខ្ញុំ ហើយខ្ញុំស្រឡាញ់គាត់។ ខ្ញុំបានពន្យល់ថា ពេលខ្លះ មនុស្សធ្វើការសំរេចចិត្តខុស ហើយថា កូនស្រីរបស់គាត់មានសេរីភាពក្នុងការជ្រើសរើស។ គាត់ប្រាប់ខ្ញុំ ដោយស្នាមញញឹម ‘ ខ្ញុំជឿថាម្ដាយរបស់អ្នកច្បាស់ជានឹកអ្នកណាស់ហើយ ហើយគាត់នឹងមិនអោយអ្នកទៅណាទៀតទេ នៅពេលគាត់ជួបអ្នកម្ដងទៀត។’ គាត់អរគុណខ្ញុំ ដែលនិយាយជាមួយគាត់ ហើយបានឱ្យអាស័យដ្ឋានរបស់គាត់មកខ្ញុំ ដើម្បីយើងអាចចែកចាយដំណឹងល្អជាមួយគាត់។ នៅពេលគាត់ចុះពីឡានក្រុង គាត់និយាយថា ‘ ខ្ញុំឡើងខុសឡានក្រុង ប៉ុន្តែខ្ញុំមិនបានចុះទេ។ គ្មាននរណាអង្គុយជិតខ្ញុំសោះរហូតទាល់ តែអ្នកមកដល់...ហើយមើលចុះអ្វីបានកើតឡើង។’ ផែនការរបស់ព្រះគឺល្អឥតខ្ចោះ!”

  តើគោលការណ៍អ្វីខ្លះ ដែលដកចេញពីជំពូកនេះ ដែលអ្នកឃើញថាមាននៅក្នុងដំណើររឿងនេះឬទេ? ចូររំលឹកពីជំពូកនេះឡើងវិញ ហើយធ្វើបញ្ជីមួយនៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក។ តើគោលការណ៍ទាំងនោះណាមួយដែលអ្នកអាចសាកល្បង មកអនុវត្តនៅពេលសព្វថ្ងៃនេះ?

- សូមអានយ៉ូហាន 15ៈ12–13, 21ៈ15–17, ថែស្សាឡូនីចទី1 2 និងម៉ូសាយ 18ៈ8–10។ តើអ្នកបានបំពេញ តាមការទទួលខុសត្រូវរបស់អ្នកឱ្យស្រឡាញ់ និងបំរើអ្នកដទៃបានល្អយ៉ាងណា? តើអ្នកអាចកែលំអដោយរបៀបណា? ចូរសរសេរចំលើយនៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក។

- តើមនុស្សអាចដឹងថា អ្នកគឺជាអ្នកបំរើម្នាក់របស់ព្រះអម្ចាស់ដោយរបៀបណា? នៅពេលអ្នកពិចារណាអំពីសំនួរនេះ ចូរសិក្សាមរ៉ូណៃ 7ៈ3–5 ម៉ាថាយ 7ៈ20, យ៉ូហាន 13ៈ34–35។ ចូរកត់ត្រាគំនិតរបស់អ្នក នៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក។

- សូមអាននីហ្វៃទី3 18ៈ31–32, អាលម៉ា 8ៈ16, អាលម៉ា 24ៈ7–8 និងអាលម៉ា 32ៈ41។ ចូរពិចារណាអំពីអ្វី ដែល ខគម្ពីរទាំងនេះបង្រៀន ការធ្វើការជាមួយនឹងសាសនាគន់ការីចាស់។ ចូរកត់ត្រាអំពីអ្វី ដែលអ្នករៀន នៅក្នុង សៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក ហើយបង្រៀនដៃគូរបស់អ្នក។

### ការសិក្សាជាមួយដៃគូ

- ការប្រើប្រាស់កាលវិភាគប្រចាំថ្ងៃរបស់អ្នក ចូរធ្វើផែនការ ដើម្បីជួបជាមួយនឹងអ្នកផ្លាស់សាសនាថ្មី។ សុំឱ្យពួកគេចែកចាយអំពីរបៀប ដែលពួកគេត្រូវបានរៀបចំសំរាប់ដំណឹងល្អ។ សួរសំនួរដូចជាៈ តើអ្នកមកជួបទាក់ទង នឹងសាសនាចក្រជាលើកទីមួយនៅពេលណា? នៅទីបំផុត តើអ្វី ដែលធ្វើនាំអោយអ្នកជួបនឹងអ្នកផ្សព្វផ្សាយ សាសនា? ចូរសរសេរអំពីអ្វី ដែលអ្នកបានសិក្សានៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក។

- រំលឹកសារឡើងវិញនូវប្រធានបទនីមួយៗនៅខាងក្រោមនេះ។ ប្រើប្រាស់មេរៀន រៀបចំរបៀបចូលជួបនិយាយនៅ ក្នុងការស្វែងរកអ្នករៀនដោយ សាមញ្ញមួយ។ ហាត់បង្រៀននៅក្នុងការស្វែងរកអ្នករៀនថ្មី ហើយភ្ជាប់នឹងប្រធានបទនីមួយៗអោយបានលឿន ទៅនឹងការស្ដារឡើងវិញ។

  – អារម្មណ៍ដែលជាសេចក្ដីត្រូវការសំរាប់ការដឹកនាំ និងគោលបំណងច្រើនទៀតនៅក្នុងជីវិត។

កំណត់ចំណាំ

- ការចង់ខិតទៅកាន់តែជិតព្រះ។
- សេចក្ដីត្រូវការជួយដល់ការសំរេចចិត្តសំខាន់ៗ។

- សូមអានទំព័រ 66–68 *of Our Search for Happiness* និងទំព័រ 59–64 *of True to the Faith* ដើម្បីឱ្យមានការយល់ដឹងអំពីគោលលទ្ធិគ្រឹះនៃកិច្ចការពង្សប្រវត្តិ។ ចូររៀបចំការនិយាយមួយអំពីកិច្ចការពង្សប្រវត្តិ ហើយ ចែកចាយជាមួយនឹងដៃគូរបស់អ្នក។

- ចូរនឹកគិតថា អ្នក និងដៃគូរបស់អ្នក ត្រូវបានផ្លាស់តំបន់ទៅតំបន់ថ្មីមួយ។ អ្នករកឃើញសៀវភៅតំបន់ នៅក្នុងលក្ខខ័ណ្ឌ ល្អ ប៉ុន្តែអ្នកគ្មានសាសនាគន់ការីទេ។ តើអ្នកនឹងធ្វើអ្វី ដើម្បីបន្ថែមមនុស្សចូលក្នុងបញ្ជីការបង្រៀនរបស់អ្នកឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន? ចូរធ្វើផែនការ ដើម្បីអនុវត្តគំនិតមួយចំនួនទាំងនេះ នៅក្នុងថ្ងៃនេះ។

- គំនិតខាងក្រោមនេះ មានជោគជ័យចំពោះអ្នកផ្សព្វផ្សាយសាសនា និងសមាជិកជាច្រើន។ សូមអាន និងសិក្សាអំពីគំនិតនេះជាមួយនឹងដៃគូរបស់អ្នក។
  - សូមជួយសមាជិកឱ្យធ្វើបញ្ជីមិត្តភក្តិ សាច់ញាតិ និងមនុស្សដែលពួកគេស្គាល់មួយ ជាមួយនឹងអ្នកដែលពួកគេ អាចចែកចាយដំណឹងល្អ។ សូមរំលឹកបញ្ជីនេះសារឡើងវិញជាមួយនឹងសមាជិក ហើយជួយពួកគេឱ្យអធិស្ឋានជ្រើសរើស នរណាម្នាក់ ដែលពួកគេចង់រៀបចំឱ្យស្ដាប់ដំណឹងល្អ។
  - ជួយពួកគេឱ្យកំណត់ថ្ងៃ ដែលពួកគេនឹង *(ក)* ដើម្បីធ្វើឱ្យមានមនុស្ស ឬគ្រួសារ បានរៀបចំដើម្បីបង្រៀន នៅក្នុងផ្ទះរបស់ពួកគេ ឬ *(ខ)* ធ្វើសកម្មភាពរាក់ទាក់មួយចំនួនផ្សេងទៀត ដើម្បីរៀបចំពួកគេ។ កំណត់កាលបរិច្ឆេទ ផ្ដល់ នូវគោលដៅមួយដល់សមាជិក ហើយជួយពួកគេអនុវត្តសេចក្ដីជំនឿរបស់ពួកគេ។
  - ជួយពួកគេធ្វើផែនការអំពីអ្វី ដែលពួកគេនឹងធ្វើរវាងពេលឥឡូវនេះ និងកាលបរិច្ឆេទ ដែលពួកគេបានដាក់។
  - តាមដានជាមួយពួកគេជាប្រចាំ ដើម្បីគាំទ្រ និងលើកទឹកចិត្តពួកគេ។ អញ្ជើញពួកគេឱ្យចែកចាយអំពី ជោគជ័យ និងកង្វល់របស់ពួកគេ។

  ពិភាក្សាអំពីរបៀប ដែលអ្នកអាចអនុវត្តគំនិតនេះ នៅក្នុងតំបន់ដែលអ្នកកំពុងបំរើ។

## ការប្រជុំមណ្ឌល និងសន្និសីទហ្សូន

- សូមអាន និងពិភាក្សាអំពី វគ្គ “ការស្វែងរកអ្នករៀនតាមរយៈការខិតខំប្រឹងប្រែងផ្ទាល់ខ្លួន”។
  - ពិភាក្សាអំពីរបៀប ដែលគំនិតទាំងនេះបានជួយអ្នកផ្សព្វផ្សាយសាសនា ស្វែងរកមនុស្សបង្រៀន។
  - នៅលើក្ដារខៀនមួយ ចូរធ្វើបញ្ជីគំនិតផ្សេងទៀត ដើម្បីស្វែងរកមនុស្សបង្រៀន។ អញ្ជើញអ្នកផ្សព្វផ្សាយសាសនា បង្ហាញអំពីគំនិតរបស់ពួកគេ។
  - អញ្ជើញឱ្យអ្នកផ្សព្វផ្សាយសាសនាដាក់គោលដៅផ្ទាល់ខ្លួន ដើម្បីកែលំអកិច្ចខំប្រឹងប្រែងក្នុងការ ស្វែងរកអ្នករៀនថ្មី របស់ពួកគេ។

- បង្កើតបញ្ជីនៃស្ថានភាពការស្វែងរកអ្នករៀន។
  - ចាត់ ទៅឱ្យអ្នកផ្សព្វផ្សាយសាសនាម្នាក់ៗនូវស្ថានភាពមួយក្នុងចំណោមស្ថានភាពនានា។ អនុញ្ញាតឱ្យ អ្នកផ្សព្វផ្សាយសាសនា ម្នាក់ៗរយៈពេលប្រាំនាទី ដើម្បីរៀបចំរបៀប ដែលពួកគេនឹងបង្រៀនសារលិខិតនៃការស្ដារឡើងវិញ។ ឱ្យពួកគេសំដៅទៅលើ មេរៀន “សារលិខិតនៃការស្ដារឡើងវិញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ” បើចាំបាច់។
  - សង្កត់ធ្ងន់ទៅលើសារៈសំខាន់ នៃការរក្សារយៈពេលក្នុងការបង្រៀនសារលិខិតឱ្យបានសមរម្យទៅនឹង ពេលកំណត់។ ឧទាហរណ៍ អ្នកផ្សព្វផ្សាយសាសនាអាចចំណាយពេលច្រើន ដើម្បីបង្រៀននៅក្នុងផ្ទះរបស់សមាជិកម្នាក់ ជាងពួកគេបង្រៀននរណាម្នាក់ នៅក្នុងហាងលក់ឥវ៉ាន់។
  - អនុញ្ញាតឱ្យអ្នកផ្សព្វផ្សាយសាសនាច្រើននាក់បង្រៀន តាមដែលអាចធ្វើបាន ដើម្បីបង្រៀនសារលិខិត នៃការស្ដារឡើងវិញនៅក្នុងស្ថានភាព ដែលបានចាត់តាំងឱ្យ។

កំណត់ចំណាំ

- បង្រៀនគោលការណ៍ទាំងឡាយ ដែលបានរកឃើញនៅក្នុងវគ្គ “បង្រៀនទៅពេលអ្នកស្វែងរក ហើយស្វែងរកនៅពេលអ្នកបង្រៀន“។
  - ចាត់តាំងឱ្យអ្នកផ្សព្វផ្សាយសាសនាម្នាក់ៗ រៀបចំសារលិខិតមួយរយៈពេលមួយនាទី ដែលពួកគេអាចចែកចាយនៅក្នុងការកំណត់ ការស្វែងរកអ្នករៀន។ សារលិខិតទាំងនេះ គួរតែអាស្រ័យទៅលើគោលលទ្ធិ ដែលរកបាននៅក្នុងមេរៀនអ្នកផ្សព្វផ្សាយសាសនា។
  - អញ្ជើញអ្នកផ្សព្វផ្សាយសាសនាឱ្យហាត់ចែកចាយសារលិខិត រយៈពេលមួយនាទីរបស់ពួកគេជាមួយគ្នាទៅវិញទៅមក។ អ្នកប្រហែលជាចង់រៀបចំការកំណត់ការស្វែងរកអ្នករៀនផ្សេងៗទៀត ដូចជាការបង្រៀននៅក្នុងផ្ទះរបស់សមាជិក ការបង្រៀនទៅមាត់ទ្វារ ការបង្រៀនទៅតាមចិញ្ចើមផ្លូវ ឬការទាក់ទងរកអ្នករៀនថ្មីដែលត្រូវទៅជួបម្នាក់។ ចូរឱ្យអ្នកផ្សព្វផ្សាយសាសនា ហាត់បង្រៀន នៅក្នុងការកំណត់នីមួយៗទាំងនេះ។

## ប្រធានបេសកកម្ម

- ធ្វើជាគំរូអំពីកិច្ចការអ្នកផ្សព្វផ្សាយសាសនានៅក្នុងគ្រួសាររបស់អ្នក។ ចែកចាយបទពិសោធន៍របស់អ្នកជាមួយអ្នកផ្សព្វផ្សាយសាសនា និងសមាជិកទាំងឡាយ។
- ប្រឹក្សាជាមួយនឹងអ្នកដឹកនាំបព្វជិតភាព ដែលជាមធ្យោបាយប្រសើរបំផុតសំរាប់អ្នកផ្សព្វផ្សាយសាសនា ដើម្បីស្វែងរកមនុស្សបង្រៀន នៅក្នុងបេសកកម្មរបស់អ្នក។
- រៀបចំការប្រជុំអ្នកផ្សព្វផ្សាយសាសនាពិសេស ដែលអ្នកអាចនិយាយទៅកាន់សាសនាគន់ការីនៅក្នុងបេសកកម្មរបស់អ្នក។ សម្របសម្រួលជាមួយនឹងអ្នកដឹកនាំបព្វជិតភាពក្នុងតំបន់ ដើម្បីធ្វើការប្រជុំពិសេស ដែលអាចឱ្យសមាជិកនាំមិត្តភក្តិ របស់ពួកគេមក។ នៅផ្នែកនៃការប្រជុំពិសេសទាំងនេះ ចូរឱ្យអ្នកផ្លាស់ប្រែគំនិតថ្មី ថ្លែងទីបន្ទាល់ និងប្រាប់អំពីរឿងផ្លាស់ប្រែគំនិតរបស់ពួកគេ មុនពេលអ្នកនិយាយ។ ផ្ដល់ការកត់សំគាល់របស់អ្នកទៅលើសារលិខិតនៃការស្ដារឡើងវិញ។
- ចែកចាយតារាងបួនជំនាន់របស់អ្នកជាមួយនឹងអ្នកផ្សព្វផ្សាយសាសនា ហើយពន្យល់អំពីរបៀប ដែលអ្នកប្រើប្រាស់តារាងនេះនៅក្នុងកិច្ចខំប្រឹងប្រែងនៃការស្វែងរកអ្នករៀនរបស់អ្នក។
- យូរៗម្ដង ចូរទៅជាមួយនឹងអ្នកផ្សព្វផ្សាយសាសនា ដើម្បីជួយពួកគេស្វែងរកមនុស្សបង្រៀន។

កំណត់ចំណាំ



# តើខ្ញុំអាចពង្រីកជំនាញនៃការបង្រៀនរបស់ខ្ញុំបានដោយរបៀបណា?

កំណត់ចំណាំ

## ចូរពិចារណាអំពីការណ៍នេះ

- តើខ្ញុំគួរតែបង្រៀនមកពីគម្ពីរទាំងឡាយយ៉ាងដូចម្ដេច?
- ហេតុអ្វីខ្ញុំគួរតែសួរសំនួរ នៅពេលខ្ញុំបង្រៀន?
- តើសំនួរប្រភេទណា ដែលខ្ញុំគួរតែសួរ?
- តើខ្ញុំអាចស្ដាប់អ្នកទាំងឡាយ ដែលខ្ញុំបង្រៀន និងព្រះវិញ្ញាណបានឱ្យកាន់តែប្រសើរដោយរបៀបណា?
- តើខ្ញុំអាចជួយដល់មនុស្ស ដើម្បីដោះស្រាយកង្វល់របស់ពួកគេបានយ៉ាងដូចម្ដេច?
- តើខ្ញុំអាចជួយអ្នកដទៃឱ្យយកឈ្នះលើទំលាប់អាក្រក់ និងការញៀនបានយ៉ាងដូចម្ដេច?

អ្នកត្រូវបានហៅឱ្យបង្រៀនដំណឹងល្អដែលបានសាងឡើងវិញ ទៅដល់មនុស្សឱ្យបានច្រើនដូចដែលពួកគេនឹងទទួលអ្នក។ ការបង្រៀនគឺជាចំណុចកណ្ដាលនៃអ្វីៗដែលអ្នកធ្វើ។ អ្នកពង្រីកអាកប្បកិរិយាឱ្យដូចជាព្រះគ្រីស្ទ សិក្សាមេរៀន អ្នកផ្សព្វផ្សាយសាសនា បង្កើនសមត្ថភាពដើម្បីនិយាយភាសានៅក្នុងបេសកកម្មរបស់អ្នក និងពឹងផ្អែកទៅលើព្រះវិញ្ញាណ ដើម្បីបង្រៀនជាមួយនឹងអំណាចនៃការធ្វើឱ្យជឿតាម។ ព្រះអម្ចាស់មានបន្ទូលជាបញ្ញត្តិមួយយ៉ាងសមញ្ញដូច្នេះ ជាមួយនឹងការសន្យាថា៖

មុនពេលយើងប្រកាសព្រះបន្ទូលរបស់ទ្រង់ យើងគួរខំព្យាយាម ដើម្បីឱ្យបានព្រះបន្ទូលរបស់ទ្រង់ជាមុនសិន ហើយខណៈនោះអណ្ដាត របស់យើងនឹងបានស្រាយ ពេលនោះបើសិនជាយើងមានប្រាថ្នា នោះយើងនឹងបានព្រះវិញ្ញាណរបស់ទ្រង់ និងព្រះបន្ទូលរបស់ទ្រង់ ព្រះចេស្ដានៃព្រះ ដើម្បីបញ្ចុះបញ្ចូលមនុស្សលោក (សូមមើលគ និងស 11៖21)។

យើងគួរតែបន្តរក្សាទុកក្នុងគំនិតយើងរាល់គ្នា នូវព្រះបន្ទូល ទាំងឡាយនៃជីវិត ហើយចំម៉ោងនោះ នៅចំណែកនោះ នឹងត្រូវបានប្រទានមកឱ្យយើង ដែលនឹងបានវាស់ដល់មនុស្សគ្រប់រូប (សូមមើល គ និងស 84៖85)។

គណៈប្រធានទីមួយ និងក្រុមសាវកទាំងដប់ពីរនាក់មានប្រសាសន៍ថា៖ “គោលបំណងរបស់យើង គឺដើម្បីបង្រៀនសារលិខិតនៃ ដំណឹងល្អសាងឡើងវិញ នៅក្នុងរបៀប ដែលអនុញ្ញាតឱ្យព្រះវិញ្ញាណដឹកនាំទាំងអ្នកផ្សព្វផ្សាយសាសនា និងអ្នកទាំងឡាយណាដែលត្រូវបានបង្រៀន។ វាជាការសំខាន់ ដើម្បីរៀន [មេរៀនអ្នកផ្សព្វផ្សាយសាសនា] ប៉ុន្តែទាំងនេះ មិនគួរត្រូវបានបង្រៀនដោយការទន្ទិញចាំមាត់នោះទេ។ អ្នកផ្សាយសាសនាគួរតែ និយាយមកពីដួងចិត្តនៅក្នុងភាសារបស់គាត់ផ្ទាល់ ពេលដែលមានការបំផុសពីព្រះវិញ្ញាណ។ គាត់មិនគួរផ្ដល់មេរៀន បែបទន្ទេញចាំមាត់ទេ។ តែគួរនិយាយ ជាពាក្យផ្ទាល់ខ្លួនវិញ។ គាត់អាចចេញពី លំដាប់លំដោយ នៃមេរៀន តាមដែលគាត់ត្រូវបានបំផុសគំនិតឱ្យធ្វើ យោងទៅតាមចំណាប់អារម្មណ៍ និងសេចក្ដីត្រូវការនៃអ្នករៀន។ ការនិយាយចេញមកដោយការផ្លាស់គំនិតរបស់គាត់ផ្ទាល់ និងដោយសំដីរបស់គាត់ផ្ទាល់ គាត់គួរតែចែកចាយទីបន្ទាល់នៃសេចក្ដីពិត

កំណត់ចំណាំ

នៃការបង្រៀនរបស់គាត់” (“Statement on Missionary Work,” លិខិតមកពីគណៈប្រធានទីមួយនៅថ្ងៃទី 11 ខែធ្នូ ឆ្នាំ 2003)។

រៀនដើម្បីពឹងផ្អែកទៅលើព្រះវិញ្ញាណ ដើម្បីផ្តល់ឱ្យអ្នកនូវអ្វី ដែលអ្នកគួរតែនិយាយ និងធ្វើ។ ដោយការសិក្សា ការពង្រីក និងការ ប្រើប្រាស់ជំនាញនៃការបង្រៀនទៅក្នុងជំពូកនេះ អ្នកនឹងក្លាយទៅជាឧបករណ៍ដ៏មានសមត្ថភាពកាន់តែច្រើនឡើង នៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់។ ព្រះវិញ្ញាណ នឹងកើតមានយោបលទៅតាម ប្រភពចំណេះដឹង និងជំនាញ ដែលអ្នកបានពង្រីក ដើម្បីជួយអ្នកបង្រៀនកាន់តែមានប្រសិទ្ធភាព។ គុណភាព និងអំណាចនៃការបង្រៀនរបស់អ្នក នឹងជួយអ្នកដទៃឱ្យយល់ និងទទួលអារម្មណ៍អំពីសារៈសំខាន់នៃដំណឹងល្អដែលបានសាងឡើងវិញមានចំពោះពួកគេ។ ការយល់ដឹងរបស់ពួកគេ នឹងមានឥទ្ធិពលដោយសារមកពីភាពសក្ដិសមរបស់អ្នកផ្ទាល់។ ការយល់ដឹងរបស់ពួកគេនឹងមានឥទ្ធិពលផងដែរ តាមការយកចិត្តទុកដាក់របស់អ្នកចំពោះពួកគេបានល្អប៉ុណ្ណានោះ តាមរបៀបពន្យល់របស់អ្នកអំពីដំណឹងល្អ ការប្រើប្រាស់ព្រះគម្ពីរ ចែកចាយទីបន្ទាល់របស់អ្នក ការសួរសំនួរ និងការអញ្ជើញពួកគេឱ្យធ្វើ និងរក្សាការតាំងចិត្ត។

### ធ្វើតាមព្រះវិញ្ញាណ

“ព្រះវិញ្ញាណ គឺជាធាតុដ៏សំខាន់តែមួយគត់នៅក្នុងកិច្ចការនេះ។ ជាមួយនឹងព្រះវិញ្ញាណតំកើងមុខងាររបស់អ្នក អ្នកអាចធ្វើ អព្ភូតហេតុទាំងឡាយសំរាប់ព្រះអម្ចាស់ នៅក្នុងតំបន់បេសកកម្ម។ ដោយគ្មានព្រះវិញ្ញាណ អ្នកនឹងមិនទទួលបានជោគជ័យ *សូម្បីតែ* ទេពកោសល្យ និងសមត្ថភាពរបស់អ្នក” (Ezra Taft Benson, seminar for new mission presidents, ថ្ងៃទី 25 ខែមិថុនា ឆ្នាំ1986)។

### អញ្ជើញព្រះវិញ្ញាណ

យោបល់ខាងក្រោមនេះ នឹងជួយអ្នកឱ្យអញ្ជើញព្រះវិញ្ញាណ នៅពេលអ្នកបង្រៀន៖

– អធិស្ឋាន។
– ប្រើប្រាស់គម្ពីរ។
– ចែកចាយទីបន្ទាល់។
– ចែកចាយបទពិសោធន៍។
– បង្ហាញសេចក្តីស្រឡាញ់ចំពោះព្រះអម្ចាស់ និងអ្នកដទៃ។

## របៀបចាប់ផ្តើមការបង្រៀន

ខណៈតំបូងជាមួយនឹងសាសនាគតការី គឺសំខាន់ណាស់។ សាសនាគន់ការីត្រូវតែរៀនទុកចិត្តលើអ្នក។ ចូរចាប់ផ្តើមការមកជួបរបស់អ្នកជាលើកទីមួយដោយភាពកក់ក្តៅ ការគោរព ដោយអាកប្បកិរិយាស្មោះត្រង់។ សូមសួរសំនួរ សាមញ្ញមួយចំនួន ដើម្បីជួយអ្នកឱ្យយល់ដឹងអំពីប្រវត្តិសាសនារបស់ពួកគេ និងការសង្ឃឹមទុករបស់ពួកគេចំពោះការមកជួបរបស់ អ្នក។ ឧទាហរណ៍ សួរថា “តើសាសនាមានតួនាទីអ្វី នៅក្នុងជីវិតរបស់អ្នក?” ទោះជាយ៉ាងណាក៏ដោយ កុំសួរសំនួរផ្ទាល់ខ្លួនឱ្យ សោះ នោះនឹងធ្វើឱ្យពួកគេមានអារម្មណ៍មិនល្អ។

ពីមុនអ្នកចាប់ផ្តើម សូមសួរដល់អ្នកទាំងឡាយ ដែលនៅទីនោះឱ្យចូលរួមជាមួយអ្នកនៅក្នុងមេរៀន។ សូមលើកទឹកចិត្តពួកគេឱ្យបិទទូរទស្សន៍ និងផ្លាស់អ្វីៗដែលធ្វើឱ្យបែកអារម្មណ៍ចេញ ដើម្បីកុំឱ្យរារាំងព្រះវិញ្ញាណនៃព្រះអម្ចាស់។

សូមពន្យល់ថា អ្នកចង់ចាប់ផ្តើម និងបញ្ចប់មេរៀននីមួយៗដោយការអធិស្ឋាន។ សូមឱ្យយោបល់ថា អ្នកនឹងធ្វើការអធិស្ឋានបើក។ សូមអធិស្ឋានដោយសាមញ្ញ ប៉ុន្តែដោយរាបសារថា ព្រះអម្ចាស់នឹងប្រទានពរដល់មនុស្ស ដែលអ្នកកំពុងបង្រៀននៅក្នុង គ្រប់ទិដ្ឋភាពទាំងឡាយ នៃជីវិតរបស់ពួកគេ ហើយជាពិសេសថា ពួកគេអាចមានអារម្មណ៍ នៃសេចក្តីពិត ពីអ្វីដែលអ្នកនឹង បង្រៀន។

ស្រាយបំភ្លឺអំពីចំណាប់អារម្មណ៍ដោយអស់ពីចិត្ត និងដោយសេចក្តីស្រឡាញ់ចំពោះសាសនាគន់ការី និងមានជំនឿនៅក្នុងអំណាចនៃការផ្លាស់គំនិតនៃដំណឹងល្អ (សូមមើលម៉ូរ៉ូណៃ 7:43–48)។ នៅពេលត្រូវបានដឹកនាំដោយព្រះវិញ្ញាណ អ្នកអាចបង្ហាញពីគំនិតដូចទៅខាងក្រោមនេះ ចំពោះសាសនាគន់ការីរបស់អ្នក៖

- ពីព្រោះព្រះគឺជាព្រះវរបិតាសួគ៌ យើងទាំងអស់គ្នាគឺជាបងប្អូនប្រុសស្រីនឹងគ្នា។ យើងចង់សំដៅទៅលើអ្នកថា ជាបងប្អូនប្រុសស្រីយើង។
- មនុស្សម្នាក់ៗ ដែលយើងបង្រៀនមានឧបសគ្គ និងកង្វល់ផ្ទាល់ខ្លួន។ ដោយមិនគិតថាសេចក្តីត្រូវការ ឬកង្វល់របស់អ្នកជា អ្វីទេ ព្រះអង្គសង្គ្រោះ និងការបង្រៀនរបស់ទ្រង់—ដំណឹងល្អ—នឹងជួយអ្នក។
- សារលិខិតរបស់យើងនឹងអាចជួយអ្នក ដើម្បីលើកកំពស់អំពីគុណភាពនៃជីវិតរបស់អ្នក។ សារលិខិត នឹងជួយអ្នកឱ្យ ប្រឈមមុខជាមួយនឹងបញ្ហា និងឧបសគ្គទាំងឡាយ ដែលយើងទាំងអស់គ្នាជួបប្រទះនៅក្នុងជីវិត។

កំណត់ចំណាំ

- សារលិខិតរបស់យើង ដែលនៅចំកណ្ដាលផ្ដោតទៅលើព្រះយេស៊ូវគ្រីស្ទ គឺមានតម្លៃដ៏អស្ចារ្យ និងសារៈសំខាន់។
- យើងទាំងអស់គ្នាមានកំហុសនៅក្នុងជីវិត ហើយកំហុសទាំងនេះ ធ្វើឱ្យមានអារម្មណ៍ថាបានធ្វើខុស ហើយខ្មាស់អៀន។ អារម្មណ៍ទាំងនេះមិនអាចរលត់បាត់ទៅបានទេ បើគ្មានការប្រែចិត្ត និងការអភ័យទោស។ អារម្មណ៍ទាំងនេះអាចបានជាសះស្បើយ ពេញលេញតាមរយៈដង្វាយធួននៃព្រះគ្រីស្ទ។
- សារលិខិតរបស់យើង មិនអាចរៀនទាំងអស់នៅក្នុងពេលតែមួយបានទេ។ ការយល់ដឹងនឹងកើតមានតាមក្រោយ តាមរយៈការអធិស្ឋាន ការសិក្សា បទពិសោធន៍ និងការរក្សាបទបញ្ញត្តិទាំងឡាយរបស់ព្រះ។
- យើងមានភាពទន់ខ្សោយ ដូចអ្នករាល់គ្នាដែរ។ យើងប្រហែលជាមិនចេះនិយាយភាសាបានស្ទាត់ ឬអាចឆ្លើយរាល់សំនួរទាំងឡាយដែលអ្នកមាន។ ប៉ុន្តែយើងត្រូវបានហៅដោយព្យាការីម្នាក់ នៃព្រះ ដើម្បីចែកចាយពីអ្វី ដែលយើងដឹង។ យើងដឹងថា សារលិខិតរបស់យើង គឺជាការពិត។
- យើងនឹងត្រូវបានដឹកនាំ ដើម្បីអ្នកអាចរៀនពីសេចក្ដីពិត នៃសារលិខិតរបស់យើងសំរាប់ខ្លួនអ្នកផ្ទាល់។ វាគឺជាការជ្រើស រើសរបស់អ្នក ដើម្បីទទួល និងធ្វើតាមសារលិខិត។ ហេតុដូច្នោះហើយ អ្នកគួរតែមានអារម្មណ៍ដោយសេរី ដើម្បីសួរសំនួរទាំងឡាយ។
- នៅពេលអ្នកធ្វើការស្រាវជ្រាវដោយអស់ពីចិត្ត ដើម្បីយល់អំពីសារលិខិតរបស់យើង អ្នកអាចនឹងប្រឈមមុខជាមួយ ឧបសគ្គច្រើន ប៉ុន្តែព្រះនឹងជួយអ្នក។
- នៅពេលអ្នកទទួលសារលិខិតរបស់យើង អ្នកនឹងរៀនពីរបៀប ដើម្បីធ្វើសេចក្ដីសញ្ញា ឬកិច្ចសន្យាជាមួយនឹងព្រះ។ អ្នក នឹងរៀនពីរបៀប ដើម្បីធ្វើឱ្យមានការផ្លាស់ប្ដូរនៅក្នុងជីវិតរបស់អ្នក ដើម្បីឱ្យចុះសម្រុងជាមួយនឹង ការបង្រៀនរបស់ទ្រង់។ អ្នក នឹងចង់ធ្វើតាមការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ ហើយទទួលបុណ្យជ្រមុជទឹក ដោយសិទ្ធិអំណាចត្រឹមត្រូវ (សូមមើលយ៉ូហាន 3:5)។

មុនពេលបង្រៀនគោលលទ្ធិទាំងឡាយ នៅក្នុងមេរៀនមួយ ចូរធ្វើការពិចារណា ដើម្បីផ្ដល់ជាទស្សនៈសាមញ្ញមួយ ពីអ្វី ដែលអ្នកនឹងបង្រៀន។ សូមជួយមនុស្សទាំងនោះឱ្យមើលឃើញថា វានឹងមានភាពទាក់ទងដោយផ្ទាល់ជាមួយនឹងពួកគេ។ មានសាសនាគន់ការីជាច្រើន ដែលអ្នកបង្រៀនត្រូវបានរៀបចំដោយព្រះអម្ចាស់ (សូមមើល អាលម៉ា 16:16–17) ។ នៅពេលអ្នកចែកចាយបទពិសោធន៍ខាងវិញ្ញាណជាមួយគ្នា ក្នុងការប្រជុំលើកទីមួយ ពួកគេនឹងសំគាល់អ្នកថា ជាអ្នកបំរើរបស់ព្រះអម្ចាស់។

**សកម្មភាពៈ ការសិក្សាជាមួយដៃគូ**

ជាមួយនឹងដៃគូរបស់អ្នក ចូរអនុវត្តរបៀបផ្សេងៗគ្នា ដើម្បីធ្វើការចាប់ផ្ដើមមេរៀនមួយ ដោយប្រើនូវយោបល់មួយចំនួនទាំង នេះ។

## សម្របសម្រួលការបង្រៀនរបស់អ្នក ដើម្បីបំពេញតាមសេចក្ដីត្រូវការ



មនុស្សម្នាក់ៗ ឬគ្រួសារនីមួយៗ ដែលអ្នកបង្រៀន គឺប្លែកពីគ្នា។ ទោះជាអ្នកមិនយល់អំពីចំណាប់អារម្មណ៍ ភាពជោគជ័យ តំរូវការ និងកង្វល់ ទាំងឡាយរបស់ពួកគេក៏ដោយ អ្នកគួរតែស្វែងរក ដើម្បីដឹងអំពីកាលៈទេសៈរបស់ពួកគេ។ ទោះជាមានសេចក្ដីតំរូវការ ឬបញ្ហាអ្វីក៏ដោយ មនុស្សទាំងអស់ មានជំនួយដ៏ធំបំផុត នៅពេលពួកគេទទួលយក និងរស់នៅតាមដំណឹងល្អ។ អ្នកនឹងមានលទ្ធភាព ដើម្បីសម្របសម្រួលការបង្រៀនរបស់អ្នក នៅពេលអ្នកស្ដាប់តាមការណែនាំ នៃព្រះវិញ្ញាណ។

អ្នកអាចផ្លាស់ប្ដូរលំដាប់នៃមេរៀនទាំងឡាយ នៅពេលអ្នកបានបំផុសគំនិតឱ្យស្របទៅតាមចំណាប់អារម្មណ៍ និងសេចក្ដី ត្រូវការទាំងឡាយរបស់សាសនាគន់ការី។ អ្នកអាចប្រើពេលជួបច្រើនជាងមួយដង ដើម្បីបង្រៀនគោលការណ៍ទាំងឡាយ នៅក្នុង មេរៀនមួយ ហើយជួនកាល អ្នកអាចបង្រៀនមាតិកានៃមេរៀនពីរ នៅពេលជួបគ្នាម្ដង។ ព្រះវរបិតាសួគ៌ ស្គាល់កូនចៅរបស់ទ្រង់ ដូច្នេះចូរពឹងផ្អែកទៅលើការបំផុសគំនិត ដើម្បី

កំណត់ចំណាំ

ធ្វើការសំរេចចិត្តទាំងនេះ នៅពេលអ្នកបង្រៀន។ ចូរអធិស្ឋានសំរាប់អំណោយទាន នៃការញែកដឹង រួចយកចិត្តទុកដាក់ ចំពោះគំនិតដែលមកចូលក្នុងគំនិត ឬអារម្មណ៍របស់អ្នក ដែលអ្នកមាន អំពីអ្វីដែលអ្នកបង្រៀន។

អ្នកនឹងត្រូវការ សំរបការបង្រៀនរបស់អ្នក ដើម្បីយកចិត្តទុកដាក់កាន់តែច្រើនទៅលើការតាំងចិត្ត ដែលមានការលំបាកឮជាច្រើន ចំពោះសាសនាគន់ការីម្នាក់ ដើម្បីធ្វើតាម។ ឧទាហរណ៍ មនុស្សម្នាក់ អាចទទួលយកព្រះគម្ពីរមរមន ជាព្រះបន្ទូលនៃព្រះ ដោយងាយស្រួល នៅពេលដែលមានអ្នកដទៃទៀត អាចមានការលំបាកនឹង ទទួលយកទាល់តែសោះក្រៅពីព្រះគម្ពីរបរិសុទ្ធ។ មនុស្សម្នាក់អាចមានបញ្ហាក្នុងការឈប់ជក់ថ្នាំជក់ ប៉ុន្តែបាន រៀបចំនឹងទទួលយកច្បាប់ដង្វាយមួយភាគក្នុងដប់រួចទៅហើយ។

បើអ្នកមានផែនការ នៅពេលបង្រៀនគោលលទ្ធិណាមួយនោះ ត្រូវដឹងថាតើពត៌មានថ្មីច្រើនប៉ុណ្ណា ដែលអ្នកចែកចាយ។ ចូរបង្រៀនតាមល្បឿនមួយ ដែលសមរម្យសំរាប់សាសនាគន់ការី។ មានអ្នកខ្លះនឹងរីកចំរើនលឿន ឬយឺតជាងអ្នកដទៃ។ ចូរឱ្យប្រាកដថា អ្នកសួរសំនួរគ្រប់គ្រាន់ ហើយស្តាប់ដោយយកចិត្តទុកដាក់ចំពោះចំលើយរបស់ពួកគេ ដូច្នេះអ្នកនឹងមានការយល់ដឹងបានល្អ អំពីការរៀន និងការអនុវត្តគោលលទ្ធិរបស់សាសនាគន់ការី ដែលអ្នកបង្រៀន បានលឿន និងល្អប៉ុណ្ណានោះ។

សូមឱ្យដឹងពីពេលវេលា។ ការណាត់ជួបការបង្រៀនភាគច្រើន គួរតែមិនយូរជាង45 នាទីទេ។ ការជួបបង្រៀនមួយ អាចត្រូវបានបញ្ចប់ នៅក្នុងពេល 15 ឬ 20 នាទី បើចាំបាច់។ បើមនុស្សម្នាក់នោះមានតែ 15 នាទី ដើម្បីជួបជាមួយអ្នក ចូរសំរួលការបង្រៀនរបស់អ្នក ដើម្បីគោរពតាមការកំណត់នោះ។

សូមទុកចិត្តនឹងការសន្យា ដែលព្រះវិញ្ញាណនឹងប្រទានមកដល់អ្នក អំពីអ្វីដែលអ្នកត្រូវនិយាយ នៅគ្រប់ម៉ោងដែលអ្នកត្រូវការវា (សូមមើល គ និង ស 100:6)។

### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

ចូរនឹកគិតថា អ្នកកំពុងដើរតាមផ្លូវ ហើយកត់សំគាល់ថាមានមនុស្សចាស់ម្នាក់ កំពុងតែព្យាយាមដាក់ស្បៀងធុនធ្ងន់ឮមួយចំនួន នៅក្នុងធុងសំរាមមួយ។ អ្នក និងដៃគូរបស់អ្នក ជួយដល់គាត់ ហើយជាលទ្ធផល គាត់សួរថា អ្នកជានរណា។ បន្ទាប់ពីការ ពិភាក្សាខ្លះឮមក គាត់បានអញ្ជើញអ្នកចូលទៅក្នុងផ្ទះរបស់គាត់ ហើយយល់ព្រម ដើម្បីស្តាប់សារលិខិតរបស់អ្នក។ អំឡុងពេល នៃការពិភាក្សាដំបូង គាត់ប្រាប់អ្នកថាៈ

- ប្រពន្ធរបស់គាត់បានស្លាប់មួយឆ្នាំកន្លងទៅហើយ ហើយគាត់នឹកប្រពន្ធគាត់ខ្លាំងណាស់។
- គាត់ឆាប់ហត់ ពីព្រោះតែជម្ងឺបេះដូង។
- គាត់កាន់តែឆ្ងល់ខ្លាំងឡើងតាំងពីមុន និងពេលឥឡូវនេះថា ព្រះមានពិតឬ។

តើអ្នកអាចបង្រៀនគាត់អំពីអ្វី? តើអ្នកអាចសម្រួល ការបង្រៀនរបស់អ្នកយ៉ាងណា ដើម្បីឱ្យត្រូវនឹងតំរូវការ និងកង្វល់របស់គាត់?

### ការសិក្សាព្រះគម្ពីរ

**តើការផ្តល់ "ចំណែកដែលបានវាស់ដល់មនុស្សគ្រប់រូប" មានន័យយ៉ាងណាខ្លះ?**

អាលម៉ា 29:8 — គ និង ស 84:85

**តើព្រះអម្ចាស់បានសន្យាអ្វីខ្លះ ដល់អ្នកផ្សព្វផ្សាយសាសនា ដែលស្មោះត្រង់?**

គ និង ស 68:2–4 — គ និង ស 100:5–8 — ម៉ាថាយ 10:19–20

## បង្រៀនជាមួយដៃគូរបស់អ្នកដោយមានការឯកភាព

ព្រះអម្ចាស់បានបញ្ជាថា យើងរាល់គ្នាត្រូវចេញទៅ ដោយនូវព្រះចេស្តា នៃព្រះវិញ្ញាណរបស់ទ្រង់ ដោយផ្សាយដំណឹងល្អរបស់ទ្រង់ ពីរឮនាក់ (សូមមើល គ និង ស 42:6)។ ការបង្រៀនរបស់អ្នកនឹងមានឥទ្ធិពល និងចំណាប់អារម្មណ៍កាន់តែខ្លាំង បើអ្នក និងដៃគូរបស់អ្នក ធ្វើការជាមួយគ្នា ដោយមានការឯកភាព។ នៅពេលអ្នកធ្វើផែនការ និងសិក្សារៀងរាល់ថ្ងៃ ចូរពិភាក្សា អំពីរបៀប ដែលអ្នកនឹងបង្រៀន ដើម្បីអ្នកអាចសាមគ្គីគ្នា ហើយបង្រៀនដោយសំលេងតែមួយ។



កំណត់ចំណាំ

ការបង្រៀនរបស់អ្នកនឹងកាន់តែមានឥទ្ធិពល បើអ្នក និងដៃគូរបស់អ្នកផ្លាស់គ្នា ផ្ដល់ផ្នែកទាំងឡាយនៃមេរៀនដោយសង្ខេប។ ចូរចៀសវាងការធ្លាក់ចូលទៅក្នុងទំលាប់ នៅពេលបង្ហាញសារលិខិត។ ចូរគាំទ្រដៃគូរបស់អ្នកដោយការធ្វើជាសាក្សីទីពីរ ចំពោះសេចក្ដីពិត ដែលពួកគេបានធ្វើទីបន្ទាល់។ ចូរធ្វើតាមចំណាប់អារម្មណ៍របស់អ្នក នៅពេលព្រះវិញ្ញាណ ប្រាប់អ្នកឱ្យនិយាយអ្វីមួយ។ ក្នុងនាមជាដៃគូ សូមឱ្យរៀបចំរួចជាស្រេច ដើម្បីបន្ទន់ចំពោះគ្នាទៅវិញទៅមក ដើម្បីអ្នកមិនរារាំង ការដឹកនាំ នៃព្រះវិញ្ញាណ។ នៅពេលអ្នកនិយាយ ចូររក្សាកែវភ្នែករបស់អ្នកមើលឱ្យចំសាសនាគន់ការី។ នៅពេលអ្នកមិននិយាយ ចូរអធិស្ឋានសំរាប់ដៃគូរបស់អ្នក ហើយសង្កេតដោយយកចិត្តទុកដាក់ទៅលើការឆ្លើយតបទាំងឡាយ របស់សាសនាគន់ការី។

## ការសិក្សាព្រះគម្ពីរ

**តើដៃគូអាចគាំទ្រចំពោះគ្នាទៅវិញទៅមកដោយរបៀបណា?**

អាលម៉ា 12:1 — គ និង ស 42:6 — គ និង ស 52:9–10

## អញ្ជើញសមាជិក ឱ្យជួយបង្រៀន

នៅពេលណាក៏ដោយ ដែលអាចធ្វើទៅបាន សូមអញ្ជើញសមាជិក អ្នកផ្លាស់គំនិតថ្មីតាមការចូលចិត្ត ដើម្បីជួយអ្នកបង្រៀន។ ស្ថានភាពពិសេស គឺត្រូវបញ្ចូលនូវសមាជិកសាសនាចក្រណា ដែលកាលពីមុនទៅក្នុងព្រះវិហារដូចគ្នានឹងសាសនាគនការី ។ ចូរបង្ហាញសមាជិកនូវសៀវភៅមេរៀនមួយក្បាល ហើយពិភាក្សាអំពីអ្វី ដែលអ្នកចង់ឱ្យពួកគេបង្រៀន។ ចូរពិភាក្សាពីរបៀប ដើម្បី ធ្វើការជាមួយគ្នា។ ឧទាហរណ៍ ឱ្យសមាជិក តាមគួរសម ចែកចាយពីរបៀប ដែលពួកគេអាចរៀន ទទួលយក និងរស់នៅ តាមគោលការណ៍ជាក់លាក់មួយនៅក្នុងមេរៀន។ ចូរឱ្យពួកគេពន្យល់ពីរបៀប ដែលពួកគេធ្វើការសំរេចចិត្ត ដើម្បីចូលរួមនៅក្នុង សាសនាចក្រ ។ នៅពេលសមាជិកទាំងឡាយ ចូលរួមនៅក្នុងការបង្រៀន ពួកគេនឹងមានឱកាស ដើម្បីទទួលអារម្មណ៍នៃសេចក្ដី អំណរ នៃកិច្ចការអ្នកផ្សព្វផ្សាយសាសនា។ វាក៏ផ្ដល់ជាមិត្តភាពសំរាប់សាសនាគន់ការីផងដែរ។ ប្រធានថូម៉ាស អែស មនសុន បានបង្រៀនថា៖

*ស្វាមីភរិយាជាសមាជិកមួយគូ ដែលប៉ុន្មានឆ្នាំថ្មីៗនេះ ទើបតែបានបោះជំហានដើម្បីទទួលពិធីបុណ្យជ្រមុជទឹក ហើយក្លាយជាសមាជិក។ នៅក្នុងបេសកកម្ម ប្រទេសកាណាដា ទីក្រុង អនទែរីយ៉ូ និង កេប៊ិច ជាទីកន្លែងដែលគ្រួសារយើងរស់នៅ កាលដែលខ្ញុំធ្វើជាអធិបតីលើបេសកកម្ម យើងសង្កេតឃើញថា ប្រជាជនភាគច្រើន ជាសមាជិករបស់និកាយចំនួនបីគឺ ៖ រ៉ូម៉ាំង កាតូលិក អង់គ្លិឃែន និង ក្រុមជំនុំរួបរួមនៃប្រទេស កាណាដា ។ នៅគ្រប់ទីក្រុងទាំងអស់ក្នុងបេសកកម្ម យើងបានរៀបចំសមាជិកគ្រួសារដែលទើបទទួលបុណ្យជ្រមុជទឹកថ្មីៗ ដែលចេញមកពីជំនឿនិមួយៗខាងលើនេះ ឲ្យមានពេលជួយពួកអ្នកផ្សព្វផ្សាយសាសនា នៅក្នុងដំណើរការនៃការបង្រៀនសាសនាគន់ការីថ្មី ដូច្នេះសមាជិកគូស្វាមីភរិយា អាចចុះទៅបង្រៀនជាមួយក្រុមអ្នកផ្សព្វផ្សាយសាសនាអាចនៅក្នុងការជួបលើកទីពីរ ឬទីបី ។*

*តើអ្នកមានអំណរគុណទេ ឧទាហរណ៍ថា នៅពេលពួកអ្នកផ្សព្វផ្សាយសាសនា [ ធ្វើការ ] ជាមួយអស់អ្នកដែលមកពីក្រុមជំនុំរួបរួមនៃប្រទេសកាណាដា ឮទីបន្ទាល់រឹងមាំរបស់ [ បងប្អូនប្រុសស្រី ] ចេញមកពីក្រុមជំនុំរួបរួមនៃប្រទេសកាណាដានោះ ។ [ ស្វាមីមួយរូប ] បានពោលថា ៖ « ពេលដែលខ្ញុំចូលសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ . .. នោះខ្ញុំបានរកឃើញសេចក្ដីពិតពេញលេញ ។ អ្នកក៏អាចធ្វើការវិន្ន័យដោយខ្លួនអ្នកដែរ ។ អ្នកក៏អាចធ្វើការសម្រេចចិត្តដូចគ្នានេះផងដែរ ។ តាមពិតទៅ យើងសូមទោយកអ្នកនៅថ្ងៃអាទិត្យពេលព្រឹកនេះ ដើម្បីយើងអាចអង្គុយជាមួយគ្នានៅក្នុងព្រះវិហារ។ ដូច្នេះ អ្នកអាចបានឮ និងទទួលអារម្មណ៍ដោយខ្លួនអ្នកផ្ទាល់ ។ យើងនឹងនៅក្បែរអ្នក » ។*

*អាតូនី និង អ៊ីឌីត ប៊ែលហ្វីលីអូ ក៏ក្លាយជាគូស្វាមីភរិយាដែលចាំទទួលស្វាគមន៍ដល់សមាជិកដែលមកពីសាសនា រ៉ូម៉ាំង កាតូលិក ។ លទ្ធផលគឺដូចគ្នា ។ វាអាចធ្វើបាន ហើយអ្នកដែលបានផ្លាស់ប្រែចិត្តទាំងនោះ នឹងនៅបន្តផ្លាស់ប្រែចិត្តជានិច្ច ។ បន្ថែមពីលើនេះ គូស្វាមីភរិយាទាំងនោះ ត្រូវបានជ្រើសតាំងឲ្យបំពេញតាមការចាត់តាំងនេះ ដោយបានចាក់ឫសរបស់ពួកគេផ្ទាល់ទៅក្នុងដីដ៏មានជីវជាតិនៃដំណឹងល្អ ។ បងប្រុស ប៊ែលហ្វីលីអូ ត្រូវបានតែងតាំងជា [ លោកអយ្យកោ ] ។ កិច្ចខិតខំរួមគ្នារវាងសមាជិក និងពួកអ្នកផ្សព្វផ្សាយសាសនា នៅក្នុងកិច្ចសហការណ៍ដ៏ពិសេសនេះ នាំមកនូវលទ្ធផលដ៏ច្រើនឥតគណនា ក្នុងការប្រមូលផ្ដុំព្រលឹងដ៏មានតម្លៃទាំងនោះ ( ការចាក់ផ្សាយតាមផ្កាយរណបស្ដីពីការបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនាថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៣ ) ។*

កំណត់ចំណាំ

**សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន**

ចូរនឹកគិតថាអ្នកមានការណាត់ជួបមួយ ដើម្បីបង្រៀនមេរៀនទៅដល់គ្រួសារមួយនៅក្នុងផ្ទះរបស់សមាជិកម្នាក់។ ចូរសំរេចចិត្ត ពីរបៀបដែលអ្នកនឹងរៀបចំឱ្យសមាជិកម្នាក់ៗក្រោយមកទៀត ជួយអ្នកបង្រៀនៈ

- អ្នកផ្សព្វផ្សាយសាសនាទៅវ័យម្នាក់ ដែលទើបតែត្រឡប់មកពីបេសកកម្មពេញម៉ោងក្នុងពេលថ្មីៗ
- សង្ឃម្នាក់
- អ្នកផ្លាស់គំនិតថ្មីៗ
- ប៊ីស្សប

## ប្រើព្រះគម្ពីរ

ព្រះគម្ពីរនៃសាសនាចក្រ គឺជាប្រភពជាមូលដ្ឋានសំរាប់ការបង្រៀនអំពីដំណឹងល្អសាងឡើងវិញ របស់ព្រះយេស៊ូវគ្រីស្ទ ។ អ្នកអាចប្រើប្រសាសន៍របស់ព្យាការីនៅរស់ផងដែរ។ មានហេតុផលជាច្រើនថា ហេតុអ្វីចាំបាច់ដោយខានមិនបាន ដើម្បីប្រើព្រះគម្ពីរ ធ្វើជាមូលដ្ឋានសំរាប់ការបង្រៀនរបស់អ្នក។ ជាឧទាហរណ៍ៈ

- ព្រះអម្ចាស់ និងព្យាការីទាំងឡាយរបស់ទ្រង់ បានណែនាំយើងឱ្យធ្វើដូច្នោះ (សូមមើលគ និងស 42ៈ12, 56–58, 71ៈ1)។ ព្យាការីថ្ងៃចុងក្រោយម្នាក់បានទូន្មានថា “ពាក្យ និងរបៀប ដែលពួកគេបានប្រើនៅក្នុងព្រះគម្ពីរមរមនដោយព្រះអម្ចាស់ . . . គួរតែត្រូវបានប្រើដោយយើងនៅក្នុងការបង្រៀនគោលការណ៍នៃដំណឹងល្អ” (Ezra Taft Benson, “The Book of Mormon and the Doctrine and Covenants,” *Ensign*, ខែឧសភា ឆ្នាំ1987, 84)។
- បទគម្ពីរអញ្ជើញព្រះវិញ្ញាណបរិសុទ្ធ ក្នុងការបង្រៀនរបស់អ្នក។ បទគម្ពីរបង្រៀនព្រះបន្ទូលរបស់ព្រះ ជាមួយនឹង អំណាច (សូមមើល អាលម៉ា 31ៈ5)។
- បទគម្ពីរឆ្លើយសំនួរអស្ចារ្យទាំងឡាយខាងព្រលឹងវិញ្ញាណ (សូមមើល នីហ្វៃទី2 32ៈ3 យ៉ាកុប2ៈ8)។
- បទគម្ពីរ ផ្តល់សិទ្ធិអំណាច និងសុពលភាពចំពោះការបង្រៀនរបស់អ្នក សូម្បីតែនៅក្នុងតំបន់ទាំងឡាយ ដែលគ្មានប្រវត្តិ ជាពួកគ្រីស្ទានក៏ដោយ។


© Greg K. Olsen។ ហាមថតចម្លង។

សមត្ថភាពរបស់អ្នក ដើម្បីបង្រៀនជាមួយនឹងអំណាចមកពីព្រះគម្ពីរ កើតមាននៅក្នុងរង្វាស់ដ៏ធំមកពីពេលវេលាដែលអ្នកចំណាយ ពេលដោយផ្ទាល់ ដើម្បីសិក្សាបទគម្ពីរ។ នៅពេលអ្នកទទួលទាននូវព្រះបន្ទូលជាប្រចាំ សមត្ថភាពរបស់អ្នកដើម្បីបង្រៀនបទគម្ពីរ នឹងរីកចំរើនឡើង។ បន្ថែមពីនោះទៀត ការអញ្ជើញរបស់អ្នក ដើម្បីសិក្សា និងពិចារណាបទគម្ពីរ នឹងកាន់តែមានឥទ្ធិពល ពីព្រោះ អ្នក កំពុងធ្វើដូចគ្នានេះនៅក្នុងជីវិតរបស់អ្នក។ សូមជួយមនុស្សឱ្យទទួលបានជំនឿ នៅក្នុងព្រះគម្ពីរ—ជាពិសេសព្រះគម្ពីរ មរមន —ជាប្រភពនៃសេចក្តីពិតដែលបានបើកសំដែង។ នៅពេលមនុស្សជឿលើព្រះគម្ពីរ អ្នកនឹងអាចជួយពួកគេឱ្យយល់ដឹងពី គោលលទ្ធិកាន់តែបានត្រឹមត្រូវ។ យោបល់ខាងក្រោមនេះអាចជាជំនួយ។

**ការណែនាំព្រះគម្ពីរ។** ចូរពិពណ៌នាដោយសង្ខេបអំពីប្រវត្តិ និងបរិបទនៃវគ្គ ដែលអ្នកនឹងប្រើ។ សូមអញ្ជើញសាសនាគន់ការី ឱ្យរក មើលចំណុចពិសេសនៅក្នុងវគ្គ។ នៅពេលធ្វើការបង្រៀនដល់មនុស្ស ដែលមានចំណេះដឹងមានកំណត់អំពីគម្ពីរ អ្នកប្រហែល ជា ត្រូវការចាប់ផ្តើមដោយការពិពណ៌នាអំពីមាតិកានៃវគ្គមួយ ដោយប្រើ ភាសាណា ដែលពួកគេនឹងយល់។ ខាងក្រោមនេះ គឺជា ឧទាហរណ៍ នៃការណែនាំគម្ពីរមួយៈ

កំណត់ចំណាំ

- "នៅទីនេះមាននៅក្នុងប្រវត្តិរបស់យ៉ូសែប ស៊្មីធ យើងមានពាក្យសំដីរបស់យ៉ូសែបដោយផ្ទាល់ ដែលកំពុងប្រាប់ពីអ្វី ដែល បានកើតឡើងចំពោះលោក នៅពេលលោកទៅក្នុងព្រៃដើម្បីអធិស្ឋាន។ លោកមានប្រសាសន៍ថា 'ខ្ញុំបានឃើញសសរពន្លឺមួយ . . .។'
- "នៅក្នុងវគ្គនេះ ព្យាការីអាលម៉ា កំពុងបង្រៀនដល់ប្រជាជន ដែលក្រីក្រ ឱ្យអនុវត្តសេចក្ដីជំនឿរបស់ពួកគេ នៅក្នុង ព្រះបន្ទូលនៃព្រះ។ លោកប្រៀបធៀប បន្ទូលនៃព្រះទៅនឹងគ្រាប់ពូជមួយគ្រាប់ ដែលអាចដាំនៅក្នុងដួងចិត្តរបស់យើង។ តើអ្នក នឹងចាប់ផ្ដើមអានខទី . . ."

**អានវគ្គ។** សូមអានខគម្ពីរទាំងឡាយឱ្យខ្លាំងៗ ឬសុំឱ្យសាសនាគន់ការីអានខ្លាំងៗ។ ត្រូវដឹងអំពីថានរណា ដែលមិនសូវចេះអាន។ បើវគ្គមួយមានការលំបាកសំរាប់ពួកគេយល់ សូមអានជាមួយពួកគេដោយយកចិត្តទុកដាក់ ហើយជួយពួក គេឱ្យយល់ចំណុច ដែលពិបាកៗ។ ឬឱ្យពួកគេអានវគ្គសាមញ្ញៗ។ អ្នកអាចឱ្យនិយមន័យពាក្យពិបាកៗ ឬកថាខណ្ឌ ផងដែរ៖

- "តែសូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង [' ឥតបន្ទោសផង ' មានន័យថា ព្រះ មិនស្ដីបន្ទោស ឬចាប់កំហុសឡើយ] នោះទ្រង់នឹងប្រទានឱ្យ"(យ៉ាកុប 1៖5)។

វគ្គគម្ពីរមួយចំនួន ច្បាស់លាស់ ហើយមិនត្រូវការការពន្យល់ទេ។ ចំពោះវគ្គគម្ពីរផ្សេងៗទៀត អ្នកប្រហែលជាត្រូវចំណាយពេលដើម្បីពន្យល់ពីអ្វីដែលបានអាន។

**អនុវត្តព្រះគម្ពីរ។** "ប្រដូច"បទគម្ពីរទៅនឹងខ្លួនអ្នក និងទៅនឹងសាសនាគន់ការី ដោយការបង្ហាញពីរបៀប ដែលគោលការណ៍ទាំងនេះ មានទាក់ទងនឹងសព្វថ្ងៃនេះ (សូមមើល នីហ្វៃទី1 19៖23)។ ចូរបង្ហាញដល់សាសនាគន់ការី ពីរបៀប ដែលពួកគេអាចអនុវត្តគោលការណ៍ទាំងឡាយ នៅក្នុងជីវិតរបស់ពួកគេ។ នៅពេលពួកគេធ្វើដូច្នោះ ពួកគេនឹងកាន់តែដឹងថា គោលលទ្ធិគឺពិត។ ចូរធ្វើទីបន្ទាល់ របស់អ្នកអំពីគោលការណ៍ ហើយសន្យានឹងពួកគេជាមួយពរជ័យជាច្រើន។ ឧទាហរណ៍៖

- "ប្រជាជនរបស់អាលម៉ា ដូចជាអ្នករាល់គ្នា មានបន្ទុកយ៉ាងធ្ងន់នៅលើពួកគេ ស្ទើរតែមិនអាចរែកបាន។ ប៉ុន្តែ នៅពេលពួកគេអនុវត្តសេចក្ដីជំនឿ 'ហើយបានអំពាវនាវដល់ព្រះអង្គ' ទ្រង់បានផ្ដល់កម្លាំងដល់ពួកគេ ដើម្បីគេអាចស៊ូទ្រាំនឹងឧបសគ្គទាំងឡាយ ហើយបន្ទាប់មកបានរំដោះពួកគេចេញពីការសាកល្បង។ គឺដូចគ្នានឹងអ្វីដែលទ្រង់ធ្វើជាមួយប្រជាជនទាំងនេះ ខ្ញុំដឹងថា ព្រះនឹងជួយអ្នកនៅក្នុងការសាកល្បងរបស់អ្នក នៅពេលអ្នក . . .។"
- "ការបង្រៀនរបស់អាលម៉ាចំពោះប្រជាជននៅទន្លេមរមន អនុវត្តចំពោះយើងនៅសព្វថ្ងៃនេះ។ ចន តើយល់ ព្រមដើម្បី . . ."

មនុស្សដែលអ្នកបង្រៀន នឹងមានភាពផ្សេងគ្នាយ៉ាងខ្លាំង តាមរបៀបដែលពួកគេយល់ពីអត្ថបទពិសិដ្ឋ តើពួកគេថ្មីកជាមួយនឹងគម្ពីរបរិសុទ្ធយ៉ាងដូចម្ដេច តើពួកគេយល់អំពីភាសាព្រះគម្ពីរបានល្អយ៉ាងណា ហើយតើពួកគេជឿស៊ីជំរៅប៉ុណ្ណាថា គម្ពីរបរិសុទ្ធមានព្រះបន្ទូលនៃព្រះ។ សូមជួយសាសនាគន់ការីទាំងអស់ទទួលបានសេចក្ដីថ្លែងអំណរគុណចំពោះព្រះគម្ពីរ។ ពីព្រោះការប្រើព្រះគម្ពីរដោយ មានប្រសិទ្ធភាពនៅក្នុងការបង្រៀនរបស់អ្នក នោះអ្នកអាចជួយសាសនាគន់ការី ឱ្យចាប់ផ្ដើមសិក្សាគម្ពីរដោយខ្លួនឯង។ បន្ទាប់ពី ការជួបនីមួយៗ សូមឱ្យយោបល់ជាជំពូក ឬខគម្ពីរជាក់លាក់សំរាប់ពួកគេអាន។ អ្នកអាចផ្ដល់សំនួរឱ្យពួកគេ ពិចារណានៅពេល ពួកគេអាន ដែលអ្នកអាចពិភាក្សានៅពេលប្រជុំថ្ងៃក្រោយទៀត។ នេះនឹងលើកទឹកចិត្តពួកគេឱ្យសិក្សាគម្ពីរជាប្រចាំនៅក្នុងផ្ទះ និងចូលរួមនៅក្នុងការប្រជុំរបស់សាសនាចក្រ និងថ្នាក់ទាំងឡាយ ដែលប្រើគម្ពីរ។

### ទស្សនៈវប្បធម៌នៃព្រះគម្ពីរ

សាសនាភាគច្រើន មានអត្ថបទពិសិដ្ឋ ឬបទគម្ពីរនៃព្រះគម្ពីរ ប៉ុន្តែការប្រើប្រាស់ និងការយល់ដឹងអំពីបទគម្ពីររបស់ពួកគេ ប្រហែល ជាមានភាពផ្សេងគ្នាពីរបៀបដែលសមាជិក ទាំងឡាយនៃសាសនាចក្រយល់ដឹងអំពីបទគម្ពីរ។ ឧទាហរណ៍ អ្នកប្រហែលជាត្រូវការពន្យល់ថា ការគូសចំណាំបទគម្ពីររបស់អ្នក គឺជាភស្តុតាងនៃបំណងរបស់អ្នក ដើម្បីយល់ដឹង និងអនុវត្តការបង្រៀន នៃ ព្រះគម្ពីរ ហើយមិនមែនជាសញ្ញានៃការមិនគោរពនោះទេ។ សូមជួយអ្នកទាំងនោះ ដែលអ្នកបង្រៀនឱ្យយល់ឃើញថា ព្រះគម្ពីរ មានសារៈសំខាន់ ពីព្រោះមានព្រះបន្ទូលនៃព្រះអម្ចាស់ ដែលបានសរសេរដោយព្យាការីរបស់ព្រះ ដែលយើងទទួលស្គាល់ថា ជាសេចក្ដីពិត។

កំណត់ចំណាំ

## សកម្មភាព៖ ការសិក្សាដាដៃគូ

សូមរំលឹកវគ្គមួយ នៃវគ្គគម្ពីរជាច្រើនខាងក្រោមនេះ។ ចូរកំណត់ពីរបៀបដែលអ្នកនឹង៖

- ណែនាំវគ្គគម្ពីរ។
- ផ្ដល់ប្រវត្តិ និងបរិបទ។
- អានវគ្គគម្ពីរ ហើយពន្យល់អត្ថន័យរបស់វា។
- ពន្យល់ពាក្យពិបាកៗ។
- ជួយសាសនាគន់ការីឱ្យអនុវត្តនៅក្នុងជីវិតរបស់ពួកគេ។

ចំណងជើងនៃព្រះគម្ពីរមរមន នីហ្វៃទី3 11 ម៉ូរ៉ូណៃ 10:3–10 យ៉ូហាន 17:3 រ៉ូម 8:16–17 កូរិនថូសទី 1 15:29 យ៉ាកុប 1:5 ពេត្រុសទី 1 3:19–20 អេម៉ុស 3:7។

## ការសិក្សាព្រះគម្ពីរ

**ហេតុអ្វីបានជាវាសំខាន់ ដើម្បីបង្រៀនចេញពីបទគម្ពីរ?**

នីហ្វៃទី1 19:23
គ និងស 20: 7–12
ធីម៉ូថេទី2 3:15–17
នីហ្វៃទី 2 4:15–16

## បង្រៀនដើម្បីឱ្យមានការយល់ដឹង

មនុស្សនឹងអាចជឿទៅលើសារលិខិតនៃការសាងឡើងវិញ នៃដំណឹងល្អកាន់តែខ្លាំងឡើង នៅពេលពួកគេយល់អំពីសារលិខិត ។ ប្រធាន ជេម អ៊ី ហ្វៅស មានប្រសាសន៍ថា៖ “ចូរសិក្សា ពិចារណា និងបង្រៀនចេញពីបទគម្ពីរ ជាពិសេសព្រះគម្ពីរមរមន និងព្រះ គម្ពីរសញ្ញាថ្មី។ ចូរស្គាល់សេចក្ដីពិតឱ្យបានល្អ ដែលអ្នកអាចនិយាយបានដោយច្បាស់លាស់។ ប៊ី អេច រ៉ូប៊ើត បានសរសេរថា “ដើម្បីស្គាល់ សេចក្ដីពិត មនុស្សត្រូវតែនិយាយ និងកាន់តែច្បាស់លាស់ ហើយសេចក្ដីថ្លែងកាន់តែពេញលេញអំពីសេចក្ដីពិតនោះ នឹងជាឱកាសកាន់តែប្រសើរ ដើម្បីឱ្យមានព្រះវិញ្ញាណបរិសុទ្ធ សំរាប់ការធ្វើទីបន្ទាល់ចំពោះព្រលឹងវិញ្ញាណរបស់មនុស្សទាំងឡាយ ថាកិច្ចការទាំងនេះគឺពិត។’ [*New Witnesses for God,* វ៉ុល 3 (1909), 2: vii]។ អ្នកមិនអាចផ្លាស់គំនិតមនុស្សទេ បើអ្នក មិនមានការផ្លាស់គំនិតដោយខ្លួនអ្នកផ្ទាល់នោះ។ (“What I Want My Son to Know before He Leaves on His Mission,” *Ensign*, ខែឧសភា ឆ្នាំ1996, 41)។

> *“វាជាប្រាជ្ញាដ៏ពិត សំរាប់មនុស្សម្នាក់ ដើម្បីយកប្រធានបទមួយ ដែលអាចកំបាំង និងអស្ចារ្យតាមប្រធានបទផ្ទាល់ ដើម្បីធ្វើឱ្យរីកចំរើនបន្តិចម្ដងៗ និងមានភាពងាយស្រួល ដើម្បីឱ្យកូនក្មេងម្នាក់អាចយល់បាន។”*
>
> — ប្រធានយ៉ូហាន ថេល័រ
> *THE GOSPEL KINGDOM,* ជ្រើសរើសដោយ
> G. HOMER DURHAM (1943), 270

អ្នកត្រូវបានបញ្ជាឱ្យដោះស្រាយ និងពន្យល់ប្រាប់បទគម្ពីរ នៅពេលអ្នកបង្រៀន (សូមមើល គ និងស 68:1)។ *ពន្យល់ប្រាប់* មានន័យថា ដើម្បីពង្រីក និងពន្យល់ឱ្យបានច្បាស់លាស់។ ការពន្យល់ប្រាប់អំពីដំណឹងល្អ មានន័យថាអ្នកពន្យល់ពីអត្ថន័យនៃ គោលលទ្ធិ និងវគ្គគម្ពីរទាំងឡាយដោយសមញ្ញ ហើយច្បាស់លាស់ ដោយពឹងផ្អែកទៅលើព្រះវិញ្ញាណ ដើម្បីដឹកនាំអ្វី ដែលអ្នកត្រូវនិយាយ។ អ្នកប្រើភាសាសាមញ្ញ ហើយថ្លៃថ្នូរ ដើម្បីជួយមនុស្សឱ្យយល់ពីគោលការណ៍ខាងគោលលទ្ធិ។ អ្នកសួរសំនួរ ដើម្បីជួយ ពួកគេគិតអំពីគោលការណ៍ទាំងឡាយ និងដើម្បីឱ្យឃើញថា បើពួកគេយល់ និងទទួលយក អ្វីដែលអ្នកបានបង្រៀន។

នៅចុងបញ្ចប់នៃមេរៀនបីគំបូងនីមួយៗនៅក្នុងជំពូកទី3 គឺជាបញ្ជី នៃពាក្យទាំងឡាយ ដែលប្រហែលជាអ្នកទាំងឡាយ ដែលអ្នកបង្រៀន មិនធ្លាប់ស្គាល់ច្បាស់ទេ។ ផ្នែកនៃការបង្រៀន សំរាប់ការយល់ដឹង គឺដើម្បីធ្វើឱ្យប្រាកដថា អ្នកពន្យល់ពាក្យ ឃ្លា និងគំនិតទាំងនោះ ដើម្បីអ្នកដទៃទៀតយល់ពីអ្នកឱ្យកាន់តែប្រសើរឡើង។ អ្នកអាចពង្រីកសមត្ថភាពរបស់អ្នក ដើម្បីពន្យល់អំពីដំណឹងល្អ ដោយ៖

- ការយល់ដឹងអំពីពាក្យទាំងឡាយ ដែលអ្នកប្រើ។

- ការពន្យល់ន័យនៃពាក្យ ដែលអ្នកផ្សេងៗទៀត ប្រហែលជាមិនយល់។ ពាក្យជាច្រើន ដែលមានអត្ថន័យពិសេសអំពី អ្វីមួយចំពោះសមាជិកនៃសាសនាចក្រ គឺមានន័យដោយសាមញ្ញនៅក្នុង Guide to the Scriptures និង *True to the Faith*។
- សូមសួរសំនួរដូចជា "តើអ្នកដឹងថាយើងចង់មានន័យដូចម្ដេចទេ នៅពេលយើងនិយាយ . . . ? ឬ "តើអ្នកអាចនិយាយឡើងវិញបានទេ នូវអ្វី ដែលយើងទើបតែនិយាយ ជាសំដីរបស់អ្នកផ្ទាល់?

នៅពេលអ្នកសិក្សាគោលលទ្ធិ នៅក្នុងជំពូកទី 3 ចូរគូសបង្ហាញអំពីពាក្យ ដែលអ្នកគិតថា ប្រហែលជាពិបាក សំរាប់សាសទាគន់ការីដើម្បីយល់។ នៅពេលអ្នកបង្រៀនគោលលទ្ធិនៅក្នុងជំពូក 3 ចូរធ្វើកំណត់ចំណាំទៅលើពាក្យ ឃ្លា និងគំនិតដែលសាសទាគន់ការីមានការលំបាកដើម្បីយល់។ ចូរឱ្យនិយមន័យពាក្យទាំងនោះ ដោយប្រើធនធានទាំងឡាយ ដែលបានប្រាប់នៅខាងលើ។ ចូរធ្វើការសាកល្បងនិយមន័យរបស់អ្នកជាមួយសាសទាគន់ការី និងអ្នកផ្លាស់គំនិតថ្មីៗ។

### ការសិក្សាព្រះគម្ពីរ

**តើហេតុអ្វីបានជាយើងគួរតែបកស្រាយ ឬពន្យល់អំពីគោលលទ្ធិដោយប្រុងប្រយ័ត្នដូច្នេះ?**

| | | |
|---|---|---|
| ម៉ូសាយ 8:3 | អាលម៉ា 12:1 | គ និង ស 68:1–5 |
| ម៉ូសាយ 27:35 | នីហ្វៃទី3 26:1 | គ និង ស 71:1 |

**តើយើងរៀនយ៉ាងដូចម្ដេច? ហេតុអ្វីបានជាវាសំខាន់ ដើម្បីលាតត្រដាង ឬបើកបង្ហាញពតិមានដោយបន្តិចម្ដងៗដូច្នេះ?**

| | | |
|---|---|---|
| នីហ្វៃទី2 28:30 | ម៉ូសាយ 2:9 | គ និង ស 98:11–12 |
| យ៉ាកុប 4:13 | | |

**តើហេតុអ្វីក៏ភាពច្បាស់លាស់មានសារះសំខាន់យ៉ាងនេះ?**

| | | |
|---|---|---|
| នីហ្វៃទី2 25:4, 7, 28 | អាលម៉ា 13:23 | នេហេមា 8:8 |
| នីហ្វៃទី2 32:7 | | |

**តើព្រះអម្ចាស់មានទំនាក់ទំនងជាមួយកូនចៅរបស់ទ្រង់ដោយរបៀបណា?**

| | | |
|---|---|---|
| នីហ្វៃទី2 31:3 | គ និងស 1:24 | |

## សួរសំនួរ



ព្រះយេស៊ូវគ្រីស្ទ ជារឿយៗសួរសំនួរទាំងឡាយដើម្បីជួយប្រជាជនឱ្យធ្វើការពិចារណា និងអនុវត្តគោលការណ៍ទាំងឡាយ។ ទ្រង់សួរសំនួរបំផុសគំនិតការស្រាវជ្រាវខាងព្រលឹងវិញ្ញាណ និងការតាំងចិត្ត។

សំនួរល្អនឹងជួយអ្នកឱ្យយល់ពីចំណង់ចំនូលចិត្ត កង្វល់ ឬសំនួរ ដែលអ្នកដទៃមាន។ សំនួរល្អទាំងនោះអាចពង្រីកការបង្រៀន របស់អ្នក ដោយអញ្ជើញព្រះវិញ្ញាណ និងជួយសាសទាគន់ការីឱ្យរៀន។

សំនួរមិនល្អ អាចបំភិតបំភ័យ ធ្វើឱ្យខឹង និងធ្វើឱ្យអាក់អន់ចិត្តដល់សាសទាគន់ការី។ ពួកគេអាចធ្វើឱ្យអ្នកបាត់បង់ការគ្រប់ គ្រងទៅលើស្ថានភាពនៃការបង្រៀនផងដែរ។ ចូរព្យាយាមសួរសំនួរដែលៈ

- សាមញ្ញ ហើយងាយស្រួលយល់។
- ជួយមនុស្សឱ្យគិតអំពីអ្វី ដែលអ្នកកំពុងបង្រៀន។
- ជួយអ្នកឱ្យកំណត់ថា តើសាសទាគន់ការីយល់បានល្អប៉ុណ្ណា អំពីអ្វីដែលអ្នកកំពុងបង្រៀន។
- ជួយពួកគេឱ្យអនុវត្តអ្វី ដែលពួកគេរៀន។

កំណត់ចំណាំ

កំណត់ចំណាំ

នៅពេលអ្នកទាំងឡាយ ដែលអ្នកបង្រៀនឆ្លើយតបចំពោះសំនួរប្រភេទនេះ ពួកគេនឹងមានអារម្មណ៍ថា ពួកគេអាចនិយាយ ដោយបើកចំហរ។ សំនួរល្អអាចនាំឱ្យសាសនាគន់ការី សួរសំនួរដល់អ្នក នៅពេលពួកគេមិនយល់ នៅពេលពួកគេ មានកង្វល់ ឬនៅពេលពួកគេចង់ដឹងអ្វីមួយ ដើម្បីធ្វើ។ សំនួរល្អ អាចជួយអ្នកទាំងឡាយ ដែលអ្នកបង្រៀន ចែកចាយនូវអារម្មណ៍របស់ពួកគេ ហើយដោយការធ្វើដូច្នោះ នឹងធ្វើឱ្យយើងអាចរកឃើញថា ទីបន្ទាល់មានការរីកចំរើន។ ឧទាហរណ៍ នៃសំនួរដែលមានប្រសិទ្ធភាព រួមមានដូចតទោះ

- តើអ្នកមានសំនួរអំពីអ្វី ដែលយើងបានបង្រៀនដែរឬទេ?
- តើអ្នកជឿដែរឬទេ ថាព្រះវរបិតាស្រឡាញ់អ្នក? ហេតុអ្វី?
- តើយើង ពេលខ្លះធ្វើកំហុសដូចគ្នា ដូចជាប្រជាជននៅក្នុងរឿងនេះដោយរបៀបណា?

ដើម្បីជួយអ្នកទាំងឡាយ ដែលអ្នកបង្រៀនឱ្យរៀបចំឆ្លើយសំនួរ អ្នកប្រហែលជាចង់និយាយថា “ដូចខ្ញុំពន្យល់អំពីសារៈសំខាន់នៃការគោរពថ្ងៃសីលទុកជាបរិសុទ្ធ សូមសួរដល់ខ្លួនរបស់អ្នកថា ‘តើបទបញ្ញត្តិនេះមានន័យអ្វីខ្លះចំពោះខ្ញុំ?’ ចូរចៀសវាងសួរសំនួរ ដែលះ

- បញ្ចូលគំនិតច្រើនជាងមួយ។
- ទាក់ទងជាមួយគោលលទ្ធិ ដែលអ្នកមិនទាន់បង្រៀន។
- មិនមានគោលបំណងច្បាស់លាស់។
- សួរចំលើយ ហើយជ្រៀតជ្រែកចូលទៅអ្វីដែលមិនចាំបាច់។

ការសួរសំនួរច្រើនពេក ជាពិសេសនៅពេលជួបជាលើកទីមួយ នឹងធ្វើឱ្យគេចាប់អារម្មណ៍ថា អ្នកកំពុង “សួរចំលើយ។” ចូរកុំសួរសាសនាគន់ការីឱ្យឆ្លើយសំនួរជាក់លាក់អំពីការលំអិតដែលមិនសំខាន់ ឬជាក់ស្តែងអ្វីមួយឡើយ។ នេះនឹងផ្លាស់ បរិយាកាសនៃការបង្រៀនល្អទៅជាល្បែងទស្សទាយ។ នៅពេលអ្នកត្រូវការចំលើយច្បាស់លាស់ វាជាការប្រសើរបំផុត ដើម្បីសួរសំនួរពិត ឬបង្ហាញព័ត៌មាន តាមរបៀបណាមួយ។ ចូរចៀសវាងសួរសំនួរ ដែលអាចធ្វើឱ្យនរណាម្នាក់ខ្មាស់អៀន បើពួកគេមិនដឹងចំលើយ។ សំនួរទាំងឡាយ នឹងមានប្រយោជន៍បំផុត នៅពេលត្រូវបានសួរ បន្ទាប់ពីអ្នកបានបង្រៀន និងធ្វើទីបន្ទាល់អំពីគោលការណ៍សំខាន់មួយ។ នៅខាងក្រោមនេះគឺជាឧទាហរណ៍ នៃសំនួរដែលគ្មានប្រសិទ្ធភាពះ

- តើនរណាគឺជាព្យាការីដំបូងគេ? (សូមសួរពីមុនបង្រៀនអំពីការកាន់កាប់ត្រួតត្រាទាំងឡាយ។)
- តើការថែរក្សារាងកាយរបស់យើងឱ្យបរិសុទ្ធ នឹងជួយយើងមានព្រះវិញ្ញាណ និងបង្ហាញថា យើងមានចិត្តចង់ ធ្វើតាមព្យាការីម្នាក់របស់ព្រះ ដោយរបៀបណា? (មានគំនិតច្រើនជាងមួយ។)
- តើវាជាការសំខាន់ទេ ដើម្បីដឹងអំពីបទបញ្ញត្តិរបស់ព្រះ? (ចំលើយបាទ, ចា៎ស ដែរឬទេ និងជាក់ស្តែងជ្រុល។)
- តើអ្នកមានអារម្មណ៍យ៉ាងណា អំពីព្រះគម្ពីរមរមន? (មុនពេលពួកគេអានព្រះគម្ពីរមរមន។)
- តើមានអ្វីខ្លះ ដែលយើងអាចធ្វើជារៀងរាល់ថ្ងៃ ដែលនឹងជួយយើងឱ្យមានអារម្មណ៍កាន់តែ ខិតជិតព្រះ? (សំនួរស្រពិចស្រពិល រកមើលចំលើយច្បាស់លាស់គឺះ អធិស្ឋាន។)
- តើនរណា គឺជាព្យាការីបន្ទាប់ពីព្យាការីណូអេ?(សុំឱ្យពួកគេស្មាន។)

ចូររៀនសួរសំនួរ នៅពេលបំផុសគំនិតដោយព្រះវិញ្ញាណ។ ប្រភេទសំនួរដ៏ត្រឹមត្រូវ នៅពេលសមរម្យ អាចជាជំនួយដ៏អស្ចារ្យដល់អ្នកទាំងឡាយ ដែលអ្នកបង្រៀនឱ្យរៀនដំណឹងល្អ និងមានអារម្មណ៍ពីព្រះវិញ្ញាណ។ ដូចគ្នានេះដែរ ប្រភេទសំនួរខុស ឬសំនួរនៅ ពេលមិនសមរម្យ នោះអាចធ្វើឱ្យបង្អាក់ការស្តាប់របស់ពួកគេ។ ការសួរសំនួរឱ្យបានសមរម្យត្រូវពេល តំរូវឱ្យអ្នកត្រូវនៅគៀក ជាមួយនឹងព្រះវិញ្ញាណ ដើម្បីឱ្យអ្នកស្តាប់អ្នកទាំងឡាយ ដែលអ្នកកំពុងបង្រៀន ហើយអ្នកអាចផ្តោតអារម្មណ៍ទៅលើ បទពិសោធន៍នៃការបង្រៀនទាំងមូល។ ការបង្រៀន ដែលមានប្រសិទ្ធភាព អាចជាកិច្ចការពិបាក ហើយតំរូវឱ្យមានការស្ម័ងស្មាធ និងការខំប្រឹងប្រែងរបស់អ្នក និងដៃគូរបស់អ្នក។



© 1985 Robert T. Barrett

កំណត់ចំណាំ

### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន ឬជាដៃគូ

តើអ្វីដែលអាចនឹងកើតឡើងចំពោះការរីកចំរើនរបស់សាសនាគន់ការី បើគាត់ ឬនាងជួបប្រទះនឹងស្ថានភាព ដូចខាង ក្រោមនេះ ហើយអ្នកមិនដែលបានដឹងអំពីស្ថានភាពទាំងនោះសោះ?

- អ្នកធ្វើការជាមួយ ដែលតែងតែសើចចំអកអំពីកិច្ចការខាងវិញ្ញាណ។
- សមាជិកគ្រួសារ ដែលរឹងមាំនៅក្នុងព្រះវិហារដទៃទៀត។
- មិត្តភក្តិដែលជឿថា ពួកមរមនមិនមែនជាពួកលទ្ធិសាសនាគ្រីស្ទានទេ។
- បទពិសោធន៍ខាងវិញ្ញាណមួយនៅក្នុងការអានមកពីព្រះគម្ពីរមរមន។

ចូរគិតអំពីសំនួរ ដែលអ្នកនឹងសុំឱ្យរៀនថែមទៀត អំពីស្ថានភាពនីមួយៗខាងលើ។ ចូរសរសេរសំនួររបស់អ្នក នៅក្នុងសៀវភៅ កំណត់ហេតុក្នុងការសិក្សា។ ចូរពិភាក្សាជាមួយដៃគូរបស់អ្នកអំពីរបៀប ដែលអ្នកអាចធ្វើឱ្យមានការរីកចំរើនចំពោះសំនួរនីមួយៗ ដែលអ្នកបានសរសេរសំរាប់សកម្មភាពនេះ។

## ស្តាប់

នៅពេលអ្នកស្តាប់អ្នកដទៃដោយយកចិត្តទុកដាក់ អ្នកនឹងយល់ពួកគេកាន់តែច្រើន។ នៅពេលពួកគេដឹងថា គំនិត និងអារម្មណ៍របស់ពួកគេសំខាន់ចំពោះអ្នក ពួកគេនឹងកាន់តែស្តាប់ការបង្រៀនរបស់អ្នក ចែកចាយបទពិសោធន៍ផ្ទាល់ខ្លួន និងធ្វើការតាំងចិត្តទាំងឡាយ។ នៅពេលអ្នកស្តាប់ អ្នកនឹងអាចធ្វើការសម្របសម្រួលការបង្រៀនរបស់អ្នក កាន់តែមាន ប្រសិទ្ធភាពឡើង ចំពោះតំរូវការ និងចំណាប់អារម្មណ៍របស់ពួកគេ។

ជាពិសេសស្តាប់តាមការខ្សឹបប្រាប់ពីព្រះវិញ្ញាណ។ នៅពេលអ្នកដទៃ ចែកចាយអារម្មណ៍របស់ពួកគេជាមួយអ្នក គំនិត និងយោបល់ទាំងឡាយ អាចចូលមកក្នុងគំនិតរបស់អ្នក ដែលត្រូវបានដឹកនាំដោយព្រះវិញ្ញាណ។ អ្នកនឹងអាចយល់អំពីអ្វី ដែលអ្នកដទៃ កំពុងព្យាយាមបង្ហាញចេញមកផងដែរ។

នៅពេលអ្នកដទៃនិយាយមកកាន់អ្នក ចូរចៀសវាងនូវនិន្នាការ ដែលគិតអំពីអ្វី ដែលអ្នកនឹងនិយាយ។ ចូរឱ្យច្បាស់ថា អ្នកពិតជាសញ្ជឹងគិតដោយពិត ទៅលើមនុស្ស ដែលកំពុងនិយាយ ជាជាងការរៀបចំឆ្លើយតបរបស់អ្នក។ អែលឌើរ ជែហ្វ្រី អរ ហូលលែន បានបង្រៀនះ “ដែលសំខាន់ជាងការនិយាយ គឺការស្តាប់។ មនុស្សទាំងនេះ គឺមិនមែនវត្ថុគ្មានជីវិត ដែលត្រូវគេ ប្រើសំរាប់ ធ្វើស្ថិតិនៃពិធីបុណ្យជ្រមុជទឹកទេ។ ពួកគេគឺជាកូនចៅនៃព្រះ ដែលជាបង ប្អូនប្រុសស្រីរបស់យើង ហើយពួកគេ ត្រូវការអ្វី ដែលយើងមាន។ សូមពិតទៀងត្រង់។ សូមឈោងទៅរកអ្នកដទៃ ដោយអស់ពីចិត្ត។ សូមសួរដល់មិត្តទាំងនេះ ថាអ្វីដែលជារឿងធំបំផុតចំពោះ*ពួកគេ*។ តើអ្វីដែល*ពួកគេ* ស្រឡាញ់ជាទីបំផុតនោះ ហើយតើអ្វីដែល*ពួកគេ* ចាត់ទុកថាមានតម្លៃ? ហើយបន្ទាប់ពីនោះ ចូរស្តាប់។ បើស្ថានភាពអំណោយផល អ្នកអាចសួរពួកគេ ពីអ្វីដែលជាភាពភ័យខ្លាចរបស់ពួកគេ តើពួកគេចង់បានអ្វី តើពួកគេមានអារម្មណ៍ថា បាត់អ្វីនៅក្នុងជីវិតរបស់ពួកគេ។ ខ្ញុំសន្យានឹងអ្នកថា *អ្វីមួយក៏ដោយ* នៅក្នុងអ្វី ដែលពួកគេនិយាយនឹង *តែងតែ* បញ្ជាក់ចំណុចសំខាន់នូវសេចក្តីពិតមួយនៃដំណឹងល្អអំពី អ្វីដែលអ្នកអាចចែកចាយទីបន្ទាល់ និងអំពីអ្វី ដែលអ្នកអាចធ្វើ បន្ទាប់មកស្នើរសុំបន្ថែម . . .។ បើយើងស្តាប់ដោយសេចក្តីស្រឡាញ់ យើងនឹងមិនត្រូវការខ្វល់ពីអ្វី ដែលនឹងនិយាយទេ។ វានឹងផ្តល់ឱ្យយើង—តាមព្រះវិញ្ញាណ និងតាមមិត្តភក្តិរបស់យើង” (“Witnesses Unto Me,” *Ensign* ខែឧសភា ឆ្នាំ2001, 15 អក្សរផ្តេកនៅក្នុងច្បាប់ដើម)។

មនុស្សក៏មានទំនាក់ទំនងជាមួយគ្នាផងដែរតាមរបៀបដែលពួកគេអង្គុយ ការបង្ហាញទឹកមុខ អ្វីដែលពួកគេធ្វើជាមួយនឹងដៃ សំលេង និងការផ្លាស់ប្តូរនៃកែវភ្នែករបស់ពួកគេ។ សូមធ្វើការអង្កេតអំពីសារដែលមិនចេញជាសំដីទាំងនេះ ទង្វើរទាំងនេះអាច ជួយអ្នកឱ្យយល់អំពីអារម្មណ៍ នៃអ្នកទាំងឡាយ ដែលអ្នកបង្រៀន។ សូមឱ្យដឹងផងដែរភាសាខាងរាងកាយ របស់អ្នកផ្ទាល់។ សូមឱ្យគេដឹងអំពីការចាប់អារម្មណ៍ និងសប្បាយចិត្ត ដោយការស្តាប់ដោយយកចិត្តទុកដាក់។

ចូរកុំខ្លាចពីភាពស្ងាត់ស្ងៀម។ មនុស្សជារឿយៗត្រូវការពេលវេលា ដើម្បីគិត និងឆ្លើយតបចំពោះសំនួរ ឬដើម្បីបង្ហាញអំពីអ្វីដែលពួកគេមានអារម្មណ៍។ អ្នកអាចឈប់ បន្ទាប់ពីអ្នកបានសួរសំនួរមួយ បន្ទាប់ពីចែកចាយបទពិសោធន៍ខាងវិញ្ញាណ ឬនៅពេលមនុស្សមានការលំបាក បង្ហាញពីខ្លួនពួកគេ។ សូមចាំថា ត្រូវផ្តល់ពេលឱ្យគេបញ្ចប់គំនិតរបស់ពួកគេ មុនពេល អ្នកឆ្លើយតប ហើយកុំកាត់សំដីនៅពេលពួកគេនិយាយ។

នៅពេលអ្នកមានអារម្មណ៍ថា យល់ពីអ្វី ដែលបាននិយាយ ចូរផ្តល់យោបល់ បង្ហាញថា អ្នកយល់ ដូចជា “ដូច្នេះអ្វី ដែលអ្នកកំពុងនិយាយគឺ ________________។ តើត្រឹមត្រូវទេ?” ឬ“បើខ្ញុំយល់ អ្នកមានអារម្មណ៍ថា ________________។” នៅពេលអ្នកមិនប្រាដក ថា អ្នកយល់ ចូរសួរសំនួរ ដើម្បីមានការស្រាយបំភ្លឺឱ្យបានច្បាស់។

កំណត់ចំណាំ

មនុស្សមួយចំនួនអាចទោរទន់ទៅតាមការគ្រប់គ្រង លើការសន្ទនា និងរារាំងអ្នកពីការបង្រៀនដំណឹងល្អ ដែលបានសាងឡើងវិញ។ អ្នកនឹងត្រូវការរៀន គ្រប់គ្រងឱ្យបានល្អទៅលើស្ថានភាពដូច្នេះ។ ឧទាហរណ៍ "យើងថ្លែងអំណរគុណចំពោះអ្វី ដែលអ្នកបានចែកចាយជាមួយយើង ប៉ុន្តែនោះគឺជាអ្វី ដែលយើងនឹងពិភាក្សា នៅថ្ងៃក្រោយ។ ខ្ញុំនឹងសុំដៃគូរបស់ខ្ញុំឱ្យសរសេរវាទុក ដូច្នេះយើងនឹងប្រាកដថា យើងមិនភ្លេច ដើម្បីពិភាក្សាអំពីវានៅពេលជួបគ្នាថ្ងៃក្រោយ។" ចូរចងចាំថា អ្នកនឹងជួយមនុស្សខ្លាំងបំផុត តាមរយៈការបង្រៀនពួកគេ អំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។

នៅពេលអ្នកស្ដាប់ដោយយកចិត្តទុកដាក់ ព្រះវិញ្ញាណនឹងជួយអ្នកឱ្យដឹងអ្វី ដែលត្រូវនិយាយ។ ការស្ដាប់ត្រូវការការប្រឹងប្រែង និងការសញ្ជឹងគិត។ អ្នកផ្សព្វផ្សាយសាសនាម្នាក់ បានចែកចាយបទពិសោធន៍ពិតមួយដូចខាងក្រោម (ឈ្មោះត្រូវបានផ្លាស់ប្ដូរ)៖

*ដៃគូរបស់ខ្ញុំ និងខ្ញុំ កំពុងបង្រៀនគ្រួសារ សានចេស្ស។ ពេលនោះក្ដៅ ហើយកូនក្មេងឡូឡាយ៉ាងខ្លាំង។ ខ្ញុំសួរបងស្រី សានចេស្ស អំពីការអាននៅក្នុងព្រះគម្ពីរមរមនរបស់គាត់។ នៅពេលគាត់ចាប់ផ្ដើមពន្យល់ ខ្ញុំបានកត់ចំណាំថា កូនប្រុស របស់គាត់ វាយកសៀវភៅរបស់ដៃគូខ្ញុំ ហើយបានរត់ជុំវិញបន្ទប់ លើកសៀវភៅនោះគ្រវីឡើង។ ថ្វីត្បិត ខ្ញុំមើលទៅ បងស្រីសានចេស្សក៏ ដោយ គំនិតរបស់ខ្ញុំគឺនៅកន្លែងផ្សេង។ ខ្ញុំគិតអំពីខ្លួនឯង ថា"ក្ដៅណាស់ ហើយចង់ឱ្យក្មេងតូចៗ នឹងនៅស្ងៀម។ តែនេះមិនអាចកើតឡើងបានទេ។ "នៅពេលគំនិតរបស់ខ្ញុំខ្វល់ខ្វាយ ខ្ញុំសំគាល់ឃើញថា បងស្រីសានចេស្ស មានបញ្ហា ក្នុងការ និយាយ។ អារម្មណ៍មួយមានមកក្នុងគំនិតខ្ញុំឱ្យស្ដាប់។ ខ្ញុំបានប្រឆាំងជាមួយកំដៅ និងសំលេង។ ខ្ញុំមើលទឹកមុខរបស់គាត់ ដោយ យកចិត្តទុកដាក់នៅពេលគាត់និយាយ។ គាត់មើលចុះក្រោម បន្ទាប់មកមើលមកខ្ញុំនឹងដៃគូរបស់ខ្ញុំ។ ស្វាមីរបស់គាត់អស់សង្ឃឹម នឹងធ្វើឱ្យកូនពៅស្ងៀមស្ងាត់។ មានការផ្អាកមួយភ្លែត ហើយបន្ទាប់មកសំលេងរបស់គាត់ញ័រ គាត់និយាយថា "ខ្ញុំបានធ្វើតាមអ្វី ដែលអ្នកសុំឱ្យខ្ញុំធ្វើ។ ខ្ញុំបានអានជំពូកទាំងឡាយ ដែលអ្នកចង់ឱ្យខ្ញុំអាន ហើយខ្ញុំបានអធិស្ឋាន។ "ជាថ្មីម្ដងទៀត គាត់បានឈប់ ហើយមើលចុះក្រោម។ គាត់ក្រឡេកមើលកូនពៅរបស់គាត់ បន្ទាប់មកមើលមកចំកែវភ្នែកខ្ញុំ។ "ខ្ញុំបានទទួលចំលើយមួយ" គាត់ និយាយដោយស្នាមញញឹម និងពេញទៅដោយទឹកភ្នែក។ "វាជាការពិត ខ្ញុំដឹងថាវា ជាការពិត។" ព្រះវិញ្ញាណមានពេញមួយបន្ទប់។ ជាមួយនឹងដួងចិត្តដែលពោរពេញទៅដោយការដឹងគុណថា ខ្ញុំបានស្ដាប់ ខ្ញុំញញឹម ហើយនិយាយថា "បាទ វាជាការពិត មែនហើយ។"*

## សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន ឬជាដៃគូ

បន្ទាប់ពីការរំលឹកឡើងវិញនូវរឿងខាងលើ ចូរសរសេរជាចំលើយនៅក្នុងសៀវភៅសិក្សាក្នុងកំណត់ហេតុរបស់អ្នកចំពោះសំនួរ ទាំងឡាយនៅខាងក្រោម ឬពិភាក្សាចំលើយជាមួយនឹងដៃគូរបស់អ្នកក៏បាន។

- តើអ្វី ដែលអាចកើតឡើង បើសិនជាអ្នកផ្សព្វផ្សាយសាសនានោះ មានកង្វល់កាន់តែច្រើន អំពីការកំសាន្តចិត្តផ្ទាល់ខ្លួន ឬសៀវភៅសរសេររបស់ដៃគូរបស់គាត់នោះ?
- តើសាសនាគន់ការីនេះបានទទួលពរជ័យ ពីព្រោះអ្នកផ្សព្វផ្សាយសាសនានោះ បានស្ដាប់ដល់ពួកគេយ៉ាងដូចម្ដេចខ្លះ?

---

ឆ្លើយសំនួរដូចខាងក្រោមនេះ

ក = មិនដែលពិតសំរាប់ខ្ញុំ　　គ = ជារឿយៗពិតសំរាប់ខ្ញុំ

ខ = ពេលខ្លះពិតសំរាប់ខ្ញុំ　　ឃ =តែងតែពិតសំរាប់ខ្ញុំ

- នៅពេលខ្ញុំនិយាយជាមួយអ្នកដទៃ ខ្ញុំគិតអំពីបទពិសោធន៍ស្រដៀងគ្នា ដែលខ្ញុំអាចចែកចាយជំនួសការស្ដាប់ ដោយយកចិត្តទុកដាក់។
- នៅពេលអ្នកដទៃប្រាប់ខ្ញុំអំពីអារម្មណ៍របស់ពួកគេ ខ្ញុំព្យាយាមយល់អំពីការរំពឹងទុករបស់ពួកគេ ដើម្បីយល់ពីអារម្មណ៍ថា បើខ្ញុំនឹងមានអារម្មណ៍ជាយ៉ាងណា។
- នៅពេលខ្ញុំបង្រៀនសាសនាគន់ការី ខ្ញុំព្រួយបារម្ភអំពីអ្វី ដែលខ្ញុំនឹងនិយាយ ឬក៏បង្រៀនបន្ទាប់មកទៀត។
- ខ្ញុំមួរម៉ៅ នៅពេលសាសនាគន់ការីចង់និយាយច្រើន។
- ខ្ញុំពិបាកធ្វើតាម និងយល់អំពីអ្វី ដែលអ្នកដទៃព្យាយាម ដើម្បីប្រាប់មកខ្ញុំ។
- ខ្ញុំមានអារម្មណ៍មិនមូល នៅពេលដៃគូរបស់ខ្ញុំកំពុងបង្រៀន។
- ខ្ញុំអន់ចិត្ត បើនរណាម្នាក់កំពុងនិយាយមកកាន់ខ្ញុំ ហើយអ្នកដទៃទៀតមកកាត់សំដី ឬរំខានការយកចិត្តទុកដាក់របស់ខ្ញុំ។
- ខ្ញុំទទួលបានការបណ្ដាលចិត្តខាងវិញ្ញាណដើម្បីនិយាយ ឬធ្វើអ្វីមួយ ប៉ុន្តែខ្ញុំមិនខ្វល់នឹងការបំផុសគំនិតនោះទេ។

ចូរកំណត់ឱ្យច្បាស់នូវអ្វី ដែលអ្នកអាចធ្វើ ដើម្បីពង្រឹកសមត្ថភាពរបស់អ្នកក្នុងការស្ដាប់។

## កសាងទំនាក់ទំនងល្អជាមួយសាសនាគន់ការី

ដើម្បីជៀសវាងសេចក្ដីខ្មាស់អៀន មនុស្សខ្លះ នឹងឆ្លើយសំនួរ តាមរបៀបដែលពួកគេគិតថា អ្នកចង់ឱ្យពួកគេឆ្លើយជាជាងចែកចាយពីអារម្មណ៍ពិត។ សូមស្វែងរកដើម្បីពង្រឹកទំនាក់ទំនងមួយ ដែលអនុញ្ញាតឱ្យពួកគេអាចមានអារម្មណ៍ល្អ នៅក្នុងការ ចែកចាយពីអារម្មណ៍ពិតរបស់ពួកគេជាមួយអ្នក។

## ជួយមនុស្សដោះស្រាយកង្វល់របស់ពួកគេ



មនុស្សមួយចំនួន ដែលអ្នកបង្រៀននឹងមានការខ្វះសេចក្ដីជំនឿ ដើម្បីរក្សារាល់ការតាំងចិត្តទាំងឡាយ អ្នកផ្សេង នឹងប្រឈម មុខនឹងការជំទាស់ ហើយអ្នកដទៃទៀត នឹងមិនមែនតែងតែទទួលយកអ្វីៗ ដែលអ្នកចែកចាយទេ។ ពួកគេត្រូវតែ ធ្វើការជ្រើស រើសដោយខ្លួនឯង ប៉ុន្តែអ្នកនឹងចង់ធ្វើអ្វីៗទាំងអស់ ដែលអ្នកអាចធ្វើបាន ដើម្បីឆ្លើយសំនួររបស់ពួកគេ ជួយដោះស្រាយកង្វល់ពួកគេ និងយកឈ្នះលើការជំទាស់នោះ។

ពេលខ្លះកង្វល់របស់មនុស្ស គឺដូចជាផ្ទាំងទឹកកកអណ្ដែតលើសមុទ្រ។ មានតែផ្នែកតូចមួយប៉ុណ្ណោះ ដែលស្ដែងឱ្យឃើញនៅផ្ទៃខាងលើ។ កង្វល់ទាំងនេះអាចស្មុគស្មាញ ហើយពិបាក ដើម្បីដោះស្រាយ។ ចំពោះមូលហេតុនេះ អ្នកត្រូវការធ្វើតាមព្រះវិញ្ញាណ ហើយឆ្លើយតបក្នុងរបៀបមួយ ដែលសមបំផុតទៅនឹងស្ថានភាព។ ចូរអធិស្ឋានសំរាប់អំណោយទាននៃការញែកដឹង ហើយ ធ្វើតាមអារម្មណ៍របស់អ្នក។ ព្រះវរបិតាសួគ៌ ស្គាល់ដួងចិត្ត និងបទពិសោធន៍របស់មនុស្សទាំងអស់ (ផ្ទាំងទឹកកក អណ្ដែត នៅលើ សមុទ្រទាំងមូល) ហើយនឹងជួយអ្នកឱ្យដឹងនូវអ្វី ដែលល្អបំផុតសំរាប់មនុស្សម្នាក់ៗ។

នៅពេលអ្នកជួយអ្នកដទៃ ដោះស្រាយកង្វល់របស់ពួកគេ ទីមួយត្រូវស្វែងយល់អំពីកង្វល់របស់ពួកគេ ដោយការសួរសំនួរ ហើយស្ដាប់។ ចូរពឹងផ្អែកទៅលើព្រះវិញ្ញាណ ដើម្បីជួយឱ្យអ្នកដឹងពីរបៀប ជួយពួកគេ ដោះស្រាយកង្វល់របស់ពួកគេ។ ឧទាហរណ៍ អ្នកអាចប្រើបទគម្ពីរមួយ ដើម្បីប្រាប់អំពីសេចក្ដីត្រូវការសំរាប់ពិធីបុណ្យជ្រមុជទឹក ឬអ្នកអាចចែកចាយទីបន្ទាល់របស់អ្នក អំពីព្យាការីយ៉ូសែប ស្ម៊ីធ។

ជារឿយៗកង្វល់ទាំងឡាយ មានលក្ខណៈជាសង្គម ច្រើនជាងគោលលទ្ធិ។ ឧទាហរណ៍ សាសនាគន់ការីអាចមានការភ័យខ្លាចចំពោះការប្រឆាំងរបស់សមាជិកគ្រួសារ បើពួកគេចូលសាសនាចក្រ។ ឬពួកគេអាចភ័យខ្លាចក្នុងការបដិសេធ ពីសំណាក់មិត្តភក្តិរបស់ពួកគេ នៅកន្លែងធ្វើការ។ មិនថាជាកង្វល់អ្វីក៏ដោយ សាសនាគន់ការីរបស់អ្នក អាចនឹងមានបទពិសោធន៍ ឬឥទ្ធិពល ដទៃទៀតកាលពីមុន ដែលជាផ្នែក នៃកង្វល់ ដែលអ្នកមិនយល់។ នៅក្នុងករណីជាច្រើន សមាជិកអាចមានលទ្ធភាព ជួយអ្នកឱ្យយល់ និងជួយដោះស្រាយកង្វល់របស់ពួកគេ។

របៀប ដែលអ្នកចូលទៅដល់កង្វល់របស់សាសនាគន់ការី នឹងអាស្រ័យតាមកាលៈទេសៈ នៃកង្វល់នោះ។ ចូរធ្វើការកំណត់សំគាល់កង្វល់នោះ មានមកពីព្រោះតែមនុស្សម្នាក់មិនមានការបញ្ជាក់ពីខាងវិញ្ញាណ នៃការសាងឡើងវិញ នៃសេចក្ដីពិត ឬមកពីមនុស្សម្នាក់នោះមិនចង់តាំងចិត្តដើម្បីរស់នៅតាមគោលការណ៍ពិត។ ការយល់ដឹងអំពីប្រភព នៃបញ្ហានៅក្នុងរបៀបមួយនេះ នឹងជួយអ្នកឱ្យដឹងថាតើគួរសង្កត់ធ្ងន់ទៅលើទីបន្ទាល់ ឬក៏ការតាំងចិត្ត។

**សកម្មភាពៈ ការសិក្សាជាដៃគូ**

ចូរជ្រើសរើសការតាំងចិត្តមួយ ដែលអ្នកផ្ដល់ឱ្យ នៅពេលបង្រៀនមេរៀន។ បន្ទាប់មកធ្វើការចង្អុលបង្ហាញ អំពីកង្វល់ផ្សេងៗគ្នាទាំងឡាយ ដែលអាចរារាំងនរណាម្នាក់ មិនឱ្យទទួលយក ឬរក្សាការតាំងចិត្ត នោះ។ ចូរធ្វើការពិភាក្សា និងអនុវត្តនូវរបៀប ដែលអ្នកអាចជួយដល់ពួកគេបានប្រសើរបំផុត នៅពេលពួកគេធ្វើការដោះស្រាយកង្វល់របស់ពួកគេ។

## ការប្រែចិត្ត និង ការជាសះស្បើយពីការញៀន

ការប្រែចិត្ត គឺជាដំណើរការខាងវិញ្ញាណ ដែលទាក់ទងនឹងភាពសុភាពរាបសារ ការសារភាព ការប្រែចិត្ត និងការចាកចេញពីអំពើបាប។ វាគឺជាការផ្លាស់ប្ដូរជារៀងរហូត នៃគំនិត និងសកម្មភាព។ ជាពិសេស ការប្រែចិត្តចំពោះអំពើបាបមួយជាក់លាក់ គួរមានតែមួយដងគត់។ ទោះជាយ៉ាងណាក៏ដោយ បើអំពើបាប ត្រូវបានធ្វើឡើងដដែលៗ នោះការប្រែចិត្តនឹងអាចប្រើជា ប្រយោជន៍ ដូចជាមធ្យោបាយ នៃការព្យាបាល (សូមមើលម៉ូសាយ 26:30, ម៉ូរ៉ូណៃ 6:8, គ និងស 1:31–32)។

ការកែប្រែចិត្ត អាចទាក់ទងនឹង អារម្មណ៍ និងខាងរាងកាយ។ មនុស្សត្រូវតែបញ្ឈប់អ្វី ដែលកំពុងតែកើតឡើងផ្លូវ ដែលសាងឡើងយ៉ាងរឹងមាំ នៃទង្វើដែលមិនសមរម្យ។ សកម្មភាពដែលមិនបានប៉ងទុក ត្រូវតែជំនួសដោយការប្រព្រឹត្តល្អ និងសមរម្យទាំងឡាយ។

កំណត់ចំណាំ

កំណត់ចំណាំ

ហេតុដូច្នេះហើយ ទាំងការប្រែចិត្ត និងការព្យាបាល អាចត្រូវការចំណាយពេលវេលា។ នៅពេលខ្លះ អ្នកផ្លាស់គំនិត សូម្បីតែមានចេតនាខ្លាំងបំផុត ត្រូវចុះញ៉មនឹងការល្បួង នៅពេលពួកគេរីកចំរើនទៅរកការដាក់វិន័យលើខ្លួនឯងកាន់តែខ្លាំងជាងនោះ។ នៅក្នុងករណីនេះ អ្នកផ្លាស់គំនិតថ្មី ត្រូវធ្វើការជាមួយនឹងអ្នកដឹកនាំបព្វជិតភាពរបស់ពួកគេ មិនមែនជាមួយនឹងអ្នកផ្សព្វផ្សាយសាសនាទេ នៅពេលពួកគេស្វែងរក ដើម្បីយកឈ្នះលើសេចក្ដីល្បួង និងដើម្បីប្រែចិត្តឱ្យបានពេញលេញ។

តាមរយៈពិធីបុណ្យជ្រមុជទឹក និងពិធីការបញ្ជាក់ មនុស្សទទួលបានអំណោយទាន នៃព្រះវិញ្ញាណបរិសុទ្ធ ដែលនឹងពង្រឹងដល់សមត្ថភាពរបស់ពួកគេ ដើម្បីយកឈ្នះលើឧបសគ្គទាំងនេះ។ ប៉ុន្តែពិធីបុណ្យជ្រមុជទឹក និងពិធីការបញ្ជាក់ ប្រហែលជាមិនអាចធ្វើអ្វីបានជាមួយនឹងការជម្រុញខាងអារម្មណ៍ និងខាងរាងកាយ ដែលទៅព្រមជាមួយនឹងការប្រព្រឹត្តទាំងនេះទេ។ សូម្បីតែមនុស្សម្នាក់ៗ អាចមានជោគជ័យខ្លះនៅពេលដំបូង លុះក្រោយមកទើបការដាសះស្បើយខាងអារម្មណ៍ ប្រហែលជាមានការចាំបាច់ដើម្បីប្រែចិត្តដោយពេញលេញ និងបានស្រួលឡើងវិញ។

### សកម្មភាព៖ ការសិក្សាផ្ទាល់ខ្លួន ឬជាដៃគូ

- គិតអំពីសាសនាគន់ការីម្នាក់ អ្នកផ្លាស់សាសនាម្នាក់ ឬសមាជិកមិនសូវសកម្មម្នាក់ ដែលព្យាយាមយកឈ្នះលើការញៀន។
- រំលឹក“ ជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ” និង “ការប្រែចិត្ត” សារឡើងវិញ មកពី “ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ” មេរៀននៅក្នុងជំពូកទី 3។
- តើអ្នកអាចបង្រៀនអ្វីខ្លះ ដល់មនុស្សម្នាក់នេះ ពីមេរៀន និងពីជំពូកនេះ ដែលនឹងជួយពួកគេយកឈ្នះ លើការញៀន?
- បង្កើតផែនការមេរៀនមួយ ដើម្បីជួយមនុស្សម្នាក់នេះ។

## ការជួយដល់សាសនាគន់ការី និងអ្នកផ្លាស់គំនិតថ្មី ឱ្យយល់អំពីការប្រែចិត្ត និងការជាសះស្បើយពីការញៀន

អ្នកអាចត្រូវបានសួរឱ្យឆ្លើយសំនួរ និងកង្វល់ទាំងឡាយអំពីការញៀន។ អ្នកនឹងចង់ជួយមនុស្ស ស្វែងរកចំលើយ ដើម្បីឆ្លើយនឹងសំនួរពិបាកៗ ដែលទាក់ទង ទៅនឹងបញ្ហាទាំងនេះ។ យោបល់ខាងក្រោមនេះ ប្រហែលជាអាចជួយបាន៖



© 2000 Simon Dewey។ ហាមថតចម្លង។

- ចែកចាយទីបន្ទាល់របស់អ្នកអំពី ការជាសះស្បើយនៃដំណឹងល្អ ជាពិសេសដង្វាយធួន (សូមមើល អាលម៉ា 7៖11–13)។
- ធ្វើទីបន្ទាល់ថា មានតែព្រះមួយអង្គប៉ុណ្ណោះ ដែលអាចសំរេចអព្ភូតហេតុ នៃការព្យាបាលខាងវិញ្ញាណ (សូមមើល ទំនុកដំកើង 147៖3)។
- ពន្យល់ថាអំណោយទាន នៃការព្យាបាល បានពង្រីកទៅដល់ទាំងខាងផ្នែករាងកាយ និងខាងវិញ្ញាណ។

ជំហានជាមូលដ្ឋាន ដែលជួយមនុស្សនៅក្នុងការព្យាបាលខាងអារម្មណ៍មានដំណើររួមដូចខាងក្រោម៖

- កំណត់ និងទទួលស្គាល់បញ្ហា។ នេះតំរូវឱ្យមានការប្រុងប្រយ័ត្ន និងការពិនិត្យដោយខ្លួនឯង ដោយស្មោះត្រង់។
- ទទួលស្គាល់ថា ការប្រព្រឹត្ត គឺនាំឱ្យមានទុក្ខទោស។ វាអាចមានឥទ្ធិពលដល់អ្នកដទៃ និងតំរូវឱ្យមានការផ្លាស់ប្ដូរ។
- ការបន្ទាបខ្លួន និងអារម្មណ៍សោកស្ដាយ។
- ស្វែងរកការអភ័យទោសមកពីអ្នកដទៃ ដែលត្រូវបានរងទុក្ខទោស ហើយរៀនអភ័យទោសឱ្យខ្លួនឯង។
- បញ្ឈប់សកម្មភាពញៀន ហើយចាប់ផ្ដើមធ្វើអ្វីៗ ដែលនាំឱ្យមានសុខភាពល្អ។
- នៅតែមានការស្មោះត្រង់—រក្សាសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក ផ្ដល់កិច្ចការបំរើ អធិស្ឋានសំរាប់ជំនួយ មកពីព្រះវិញ្ញាណបរិសុទ្ធ ហើយបង្ហាញពីចំណង់ ដើម្បីរក្សាបទបញ្ញត្តិរបស់ព្រះ។
- យល់ថា ព្រះអម្ចាស់នឹងស្រឡាញ់កូនចៅរបស់ទ្រង់ជានិច្ច—សូម្បីនៅពេលពួកគេធ្វើកំហុស និងធ្លាក់ទៅក្នុងចំណង់ចាស់ក៏ដោយ។ ការប្រែចិត្ត និងផ្លូវទៅកាន់ការជាសះស្បើយ គឺតែងតែមានជានិច្ច។

កំណត់ចំណាំ

## ផែនការមួយ សំរាប់យកឈ្នះទៅលើឥរិយាបទដែលនាំឱ្យញៀន

សាសនាគន់ការីទាំងឡាយ និងសមាជិកមិនសូវសកម្ម និងសមាជិកថ្មី អាចសួរអំពីអ្វី ដែលពួកគេអាចធ្វើ ដើម្បីឈ្នះទៅលើការញៀន។ ពួកគេទុកចិត្តលើសមត្ថភាពរបស់អ្នក ដើម្បីផ្ដល់ការណែនាំ និងគាំទ្រ។ នៅខាងក្រោមនេះ ជាយោបល់ ដែលអាចជាជំនួយៈ

- សូមឱ្យពួកគេធ្វើជាបញ្ជីពេលវេលា ទីកន្លែង និងមនុស្ស ដែលអាចនាំឱ្យមានការប្រព្រឹត្តដូច្នោះ។ បន្ទាប់មកធ្វើការ ពិភាក្សាអំពីបញ្ជីជាមួយនឹងស្វាមីភរិយា ប៊ីស្សប អ្នកផ្សព្វផ្សាយសាសនាក្នុងវួដ ឬអ្នកដទៃទៀត ដែលជាមិត្តទុកចិត្ត។ ចូរនិយាយ អំពីអ្វី ដែលពួកគេត្រូវការធ្វើ ដើម្បីផ្លាស់ប្ដូរ ឬជៀសវាងពីវត្ថុទាំងឡាយ ដែលនៅក្នុងបញ្ជី។
- ឱ្យពួកគេសរសេរអំពីអ្វី ជាឥរិយាបទ ដែលអាចបណ្ដាលឱ្យពួកគេបាត់ក្នុងពេលឥឡូវនេះ បើសិនជាមិនត្រឹមត្រូវ តើអ្វីដែលបណ្ដាលឱ្យពួកគេបាត់ នៅពេលអនាគតនោះ។
- សូមឱ្យពួកគេសរសេរអំពីកិច្ចផ្សេងៗគ្នា ដែលពួកគេអាចធ្វើ ដើម្បីជៀសវាង ឬមិនលើកទឹកចិត្តចំពោះការប្រព្រឹត្ត ដែលមិនសមរម្យ។ នេះប្រហែលជារួមបញ្ចូលទាំងការនិយាយចំពោះស្វាមីភរិយាណាមួយ ការហៅប៊ីស្សប ឬមិត្តម្នាក់ ដើម្បីគាំទ្រ ការហាត់ប្រាណ និងសកម្មភាពផ្សេងទៀតណាក៏ដោយ ដែលជួយពួកគេជៀសវាងពីការល្បួង។
- លើកទឹកចិត្តពួកគេឱ្យអធិស្ឋានជាទៀតទាត់ សិក្សាបទគម្ពីរ ស្ដាប់តន្ត្រីដែលលើកតំកើង និងអានសៀវភៅល្អៗ។
- លើកទឹកចិត្តពួកគេឱ្យស្វែងរកការប្រសិទ្ធពរពីបព្វជិតភាព។
- លើកទឹកចិត្តពួកគេឱ្យបន្តសកម្មនៅក្នុងសាសនាចក្រ ដែលនៅទីនោះគឺជាកន្លែងដែលអាចជួយ ពួកគេឱ្យយកឈ្នះទៅលើបញ្ហារបស់ពួកគេ និងកាន់តែខិតទៅជិតព្រះអម្ចាស់។
- លើកទឹកចិត្តពួកគេឱ្យចូលរួមនឹងក្រុមគាំទ្រមួយ ឬទទួលជំនួយពីអ្នកជំនាញការណ៍ ដែលសមរម្យ ។ នៅក្នុងកន្លែងមួយចំនួន LDS Family Services (សេវាកម្មគ្រួសារ អិល ឌី អែស) អាចជួយបាន។
- លើកទឹកចិត្តពួកគេកុំឱ្យចុះចាញ់ឱ្យសោះ! ព្រះអម្ចាស់នឹងជួយពួកគេ ទោះបីវាត្រូវការពេលវេលាខ្លះៗក៏ដោយ។



ពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលសកម្ម អាចជាជំនួយល្អបំផុតដល់សមាជិកថ្មីឱ្យនៅសកម្ម ដោយការធ្វើជាមិត្តរបស់ពួកគេ។ សមាជិកទាំងឡាយ គួរតែទៅរាក់ទាក់សាសនាគន់ការី និងសមាជិកថ្មីដោយភាពកក់ក្ដៅ ឥរិយាបទរីករាយ។ សាសនាគន់ការី និងអ្នកផ្លាស់គំនិតថ្មី នឹងឆ្លើយតបដោយពេញចិត្ត នៅពេលត្រូវបានជំរាបសួរជាមួយនឹងស្នាមញញឹម នៅពេលត្រូវបានសួរ ដោយអស់ពីចិត្តអំពីរបៀប ដែលពួកគេកំពុងធ្វើ នៅពេលអ្នកដទៃទៀតអង្គុយជិតពួកគេអំឡុងពេលប្រជុំ និងនៅពេលពួកគេត្រូវបានអញ្ជើញឱ្យញាំអាហារគ្រួសារ ឬរាត្រីជួបជុំក្រុមគ្រួសារ។

ដោយហេតុថាប្រហែលជា មានអ្នកខ្លះអាចត្រឡប់ទៅជាញៀនវិញ អ្នកដឹកនាំបព្វជិតភាព និងសមាជិកទាំងឡាយ មិនគួររន្ធត់ ឬបាក់ទឹកចិត្តទេ បើពួកគេដឹងថា សាសនាគន់ការី ឬសមាជិកថ្មីម្នាក់ ប្រហែលជាមានភាពស្មុគស្មាញជាមួយ នឹងបញ្ហាដូច្នេះនោះ។ ពួកគេគួរតែបង្ហាញនូវទំនុកចិត្តលើ បុគ្គលម្នាក់ៗ ហើយមិនត្រូវវិនិច្ឆ័យ បើមនុស្សម្នាក់នោះត្រឡប់ទៅរកចំណង់កាលពីមុន។ ពួកគេគួរតែប្រព្រឹត្តនឹង ជាបណ្ដោះអាសន្ន ហើយយល់អំពីការត្រឡប់ថយ មកក្រោយវិញ។ ការថ្កោលទោសដល់សាសនាគន់ការី ឬអ្នកផ្លាស់គំនិតថ្មី មិនអាចជួយអ្វីបានទេ ហើយហាក់ដូចជា នាំទៅរកការបាក់ទឹកចិត្ត ការចុះចាញ់ និងអសកម្មទៅវិញ។ អ្នកផ្លាស់ គំនិតថ្មី ដែលឈប់ចូលរួមក្នុងសាសនាចក្រ ភ្លាមៗអាចធ្លាក់ទៅរក ការញៀនកាលពីមុន ហើយមានអារម្មណ៍ថា មិនសក្ដិសម និងបាក់ទឹកចិត្ត។ ការសួរសុខទុក្ខភ្លាមៗ ផ្ដល់នូវការលើកទឹកចិត្ត និងគាំទ្រ ដែលអាចជួយមនុស្ស ម្នាក់នោះបានទទួល ជោគជ័យ។ សមាជិកគួរតែបង្ហាញជាសំដី និងសកម្មភាព ដែលពួកគេទទួល យកអ្នកផ្លាស់គំនិត (សូមមើលនីហ្វៃទី3 18៖32)។

ការនៅតែសកម្មនៅក្នុងសាសនាចក្រ និងការព្យាយាមរស់នៅក្នុងភាពស្មោះត្រង់ គឺជារឿងសំខាន់បំផុត ដែលបុគ្គលម្នាក់ៗ អាចធ្វើដើម្បីយកឈ្នះទៅលើបញ្ហាការញៀន។

កំណត់ចំណាំ

### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

ចូរគិតអំពីទំលាប់មួយចំនួន ដែលអ្នកមាន—ជាអ្វីៗ ដែលអ្នកធ្លាប់ធ្វើជារឿយៗ ដោយមិនបានគិត ដូចជាកាច់ម្រាមដៃរបស់អ្នក ការរំកិលកែវទឹករបស់អ្នក ការញ៉ាំច្រើនពេក គេងក្រោយម៉ោងជាដើម។ ឥឡូវចូរព្យាយាមកុំធ្វើទង្វើនេះម្ដងទៀត។ នៅពេល អ្នកធ្វើបានជោគជ័យ ចូរព្យាយាមពេញមួយសប្ដាហ៍ដោយមិនធ្វើទំលាប់នោះ ។ ចូរពិភាក្សាបទពិសោធន៍ របស់អ្នកជា មួយដៃគូ។ បន្ទាប់ព្យាយាម ដើម្បីទឹកគិតថាតើសាសនាគន់ការីមានការពិបាកជាងនេះយ៉ាងណាទៀត ដើម្បីយកឈ្នះលើការញៀន ដូចជាថ្នាំ ជក់ ឬគ្រឿងស្រវឹង ដែលធ្វើទុក្ខទោសមកលើនោះ។

## ចាកចោលកិច្ចការមួយចំនួន

នៅទីបញ្ចប់នៃការជួបបង្រៀនទីមួយៗ ចូរផ្ដល់ឱ្យសាសនាគន់ការីជាមួយនឹងអ្វីមួយ ដើម្បីអាន និងពិចារណា នៅក្នុងការរៀបចំសំរាប់ការជួបនៅពេលក្រោយ។ អ្នកអាចចែកឱ្យពួកគេនូវជំពូកទាំងឡាយ មកពីព្រះគម្ពីរមរមន។ អ្នកអាចឱ្យពួកគេកូនសៀវភៅតូចដែលនិយាយអំពីអ្វី ដែលអ្នកបានបង្រៀន ឬអ្វី ដែលអ្នកនឹងបង្រៀននៅក្នុងការជួបនៅថ្ងៃ ក្រោយ ឬវាអាចជាអក្សរសាស្ត្រ ឬការបង្ហាញតាមសោតទស្សន៍។ បើពួកគេអាចចូលតាមអ៊ីនធើណែត លើកទឹកចិត្តពួកគេឱ្យ ចូលទៅ www.mormon .org។ ពួកគេគួរតែត្រូវបានផ្ដល់អ្វីមួយជានិច្ច ដើម្បីគិត ពិចារណា និងអធិស្ឋាន។ នេះអាចក្លាយ ទៅជាការបើកប្រធានបទនៃការពិភាក្សាមួយដែលអ្នកជួបនៅពេលក្រោយទៀត។

### សកម្មភាពៈ ការសិក្សាជាមួយដៃគូ

សូមរំលឹកអំពីឯកសារ ដែលអ្នកមាន ដើម្បីទុកជាមួយនឹងសាសនាគន់ការី រួមទាំងសៀវភៅតូច និងសម្ភារសោតទស្សន៍។ តើមានវត្ថុអ្វីផ្សេងទៀត ដែលអ្នកត្រូវមាន ដើម្បីអ្នកអាចចែកចាយជាមួយនឹងសាសនាគន់ការីរបស់អ្នក? ចូរធ្វើបញ្ជីមួយ នៅក្នុងកាលវិភាគ របស់អ្នកអំពីឯកសារទាំងឡាយ ដែលអ្នកត្រូវការបញ្ជាទិញ។

ចូរពិចារណាអំពីសាសនាគន់ការីទាំងឡាយ ដែលអ្នកបានណាត់ជួប ដើម្បីបង្រៀននៅសប្ដាហ៍នេះ។ តើជំពូកទាំងឡាយ នៅក្នុង ព្រះគម្ពីរមរមននឹងជាជំនួយសំខាន់បំផុតចំពោះពួកគេទេ? តើឯកសារផ្សេងទៀត នឹងជាប្រយោជន៍ដល់ពួកគេដែរឬទេ? ចូរកត់ត្រានៅក្នុង កំណត់ចំណាំ/បញ្ជីការងារដែលត្រូវធ្វើ នៅក្នុងកាលវិភាគរបស់អ្នក អំពីអ្វី ដែលអ្នកចង់ផ្ដល់ទៅឱ្យសាសនាគន់ការីម្នាក់ៗ ហើយតើអ្នកព្រមធ្វើការតាមដានអ្វីខ្លះនៅការជួបលើកក្រោយរបស់អ្នក។

## បង្រៀនដំណឹងល្អដែលបានសាងឡើងវិញ ដល់អ្នកទាំងឡាយ ដែលមិនមានប្រវត្តិជាពួកគ្រីស្ទាន

មនុស្សមួយចំនួន ដែលអ្នកនឹងបង្រៀន ប្រហែលជាមិនជឿដល់ព្រះវរបិតា និងព្រះយេស៊ូវ ឬមានទំនៀមទំលាប់ជាពួកគ្រីស្ទានទេ។ ទោះជាយ៉ាងណាក៏ដោយ ភាគច្រើននៃមនុស្សទាំងនេះ នឹងមានការអនុវត្តជំនឿ និងគោរពទីកន្លែង ដែលពួកគេចាត់ទុកជាពិសិដ្ឋ។ ក្នុងនាមជាអ្នកបំរើម្នាក់របស់ព្រះ វាគឺជាការសំខាន់ ដែលអ្នកបង្ហាញនូវការគោរពដោយសមរម្យ ចំពោះសាសនា និងទំនៀមទំលាប់របស់ពួកគេ។ ចូរកុំធ្វើអ្វីៗ ដែលនឹងបង្ហាញការមិនគោរពចំពោះអ្វី ដែលសំខាន់ចំពោះពួកគេ។

អ្នកប្រហែលជាឆ្ងល់ថា តើអ្នកគួរតែសម្របការបង្រៀនរបស់អ្នកទៅចំពោះមនុស្សទាំងឡាយនេះដោយរបៀបណា។ វានឹងជាប្រយោជន៍ ដែលចងចាំថា ដើម្បីទទួលបានការផ្លាស់គំនិត កូនចៅនៃព្រះ ទាំងអស់ ដោយមិនគិតដល់ជីវប្រវត្តិ ត្រូវតែអភិវឌ្ឍន៍ជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ប្រែចិត្ត ទទួលពិធីការទាំងឡាយ នៃពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ហើយស៊ូទ្រាំ ដល់ពីបញ្ចប់ ដោយការរក្សា បទបញ្ញត្តិទាំងឡាយ និងការផ្ដល់ការបំរើ។ គោលការណ៍ទាំងឡាយ ដែលជួយដល់អ្នកដទៃ ឱ្យស្ថាបនាជំនឿ នៅក្នុងព្រះយេស៊ូវគ្រីស្ទ គឺដូចគ្នានៅក្នុងគ្រប់វប្បធម៌ទាំងអស់។

អ្នកអាចជួយមនុស្សឱ្យទទួលបានការយល់ដឹងត្រឹមត្រូវមួយ អំពីព្រះ ដែលជាព្រះវរបិតារបស់យើង ហើយពង្រីកជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ដោយការជួយពួកគេមានបទពិសោធន៍ខាងវិញ្ញាណ ជាជាងការប្រាប់ដោយសាមញ្ញទៅដល់ពួកគេ អំពីនិស្ស័យនៃព្រះ។ ឧទាហរណ៍ អ្នកនឹងជួយមនុស្សឱ្យទទួលបានការយល់ដឹងនេះ នៅពេលពួកគេៈ

- ទទួលការផ្លាស់គំនិតខាងវិញ្ញាណថា ព្រះ ជាព្រះវរបិតា និងបុត្រារបស់ទ្រង់ គឺជាព្រះយេស៊ូវគ្រីស្ទ ដែលបានបង្ហាញព្រះអង្គទ្រង់ដល់ព្យាការីយ៉ូសែប ស្ម៊ីធ។

កំណត់ចំណាំ

- ចូរស្ដាប់ការបង្រៀនដោយអស់ពីចិត្ត និងទីបន្ទាល់ នៃដំណឹងល្អរបស់អ្នក ដែលរួមមានទាំង មូលហេតុអ្វីបានជាអ្នកជ្រើសរើសដើម្បីធ្វើតាមព្រះយេស៊ូវគ្រីស្ទ។
- ជារឿយៗស្ដាប់អ្នក និងសមាជិកដទៃទៀត និយាយទៅកាន់ព្រះវរបិតាសួគ៌ដោយសាមញ្ញ អធិស្ឋានដោយអារម្មណ៍ពីដួងចិត្ត។
- ចូរស្ដាប់អ្នកចែកចាយទីបន្ទាល់ ដែលប្រកបដោយអំណាច។
- អធិស្ឋានជាមួយអ្នក និងដោយខ្លួនពួកគេផ្ទាល់។
- រៀនពីរបៀប ដែលអ្នកមានអារម្មណ៍អំពីបទគម្ពីរទាំងឡាយ នៅពេលអ្នកអាន និងពិភាក្សាបទគម្ពីរ។
- អានព្រះបន្ទូលរបស់ព្រះពីបទគម្ពីរទាំងឡាយជាប្រចាំ (ជាពិសេស ព្រះគម្ពីរមរមន)។
- ចូលរួមនៅក្នុងព្រះវិហារ ដើម្បីពួកគេអាចឃើញពីរបៀប ដែលយើងថ្វាយបង្គំព្រះអម្ចាស់។
- ជួបនឹងសមាជិក នៃសាសនាចក្រ ដែលអាចពន្យល់ពួកគេអំពីរបៀប ដែលពួកគេមកជឿលើព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ។
- រក្សាបទបញ្ញត្តិទាំងឡាយ។

សកម្មភាពទាំងឡាយនេះ គឺជាគុណប្រយោជន៍ចំពោះមនុស្សគ្រប់រូប ដែលអ្នកបង្រៀន ប៉ុន្តែពួកគេ មានសារៈសំខាន់ នៅពេលបង្រៀនដល់អ្នកទាំងឡាយ ដែលគ្មានប្រវត្តិជាពួកគ្រីស្ទាន ពីព្រោះមនុស្សទាំងនោះ គឺទំនងជាគ្មានគំរូវឱ្យមានបទពិសោធន៍ទាំងនេះជាមុនទេ។

អ្នកផ្លាស់គំនិតជាច្រើន មកពីប្រវត្តិអ្នកដែលមិនមែនជាគ្រីស្ទានបានរាយការណ៍ថា ពួកគេមិនសូវយល់ដឹងច្រើនអំពីអ្វី ដែលអ្នកផ្សព្វផ្សាយសាសនា កំពុងនិយាយទេ ប៉ុន្តែពួកគេមានអារម្មណ៍ពីព្រះវិញ្ញាណ ហើយចង់ធ្វើអ្វី ដែលអ្នកផ្សព្វផ្សាយសាសនាចង់ឱ្យពួកគេធ្វើ។ អ្នកត្រូវតែធ្វើអ្វីៗទាំងអស់ ដែលអ្នកអាចធ្វើ ដើម្បីជួយដល់សាសនាគន់ការី ឱ្យយល់អំពី គោលលទ្ធិនៃដំណឹងល្អ។ ចូរអត់ធ្មត់ ហើយគាំទ្រ ដែលវាប្រហែលជាត្រូវការពេលវេលាខ្លះៗ សំរាប់មនុស្ស ដើម្បីរៀនសំគាល់ ហើយបង្ហាញពីអារម្មណ៍ ទាំងឡាយដែលពួកគេមាននៅខាងក្នុងខ្លួន។ អ្នកប្រហែលជាត្រូវការសម្របសម្រួលល្បឿន និងជម្រៅនៃការបង្រៀនរបស់អ្នក ដើម្បីពួកគេអាចយល់។ នៅពេលអ្នករៀបចំ ដើម្បីបង្រៀនដល់អ្នកទាំងឡាយណា ដែលគ្មានប្រវត្តិជាពួកគ្រីស្ទាន ការធ្វើតាមយោបល់ខាងក្រោមនេះប្រហែលជាអាចជួយៈ

- ផ្ដល់ទិដ្ឋភាពសាមញ្ញៗ ហើយរំលឹកសំរាប់មេរៀនទីមួយៗ។
- សួរពួកគេឱ្យប្រាប់អ្នកពីអ្វី ដែលពួកគេយល់ និងពីអ្វី ដែលពួកគេបានពិសោធ។
- ចំណាយពេល ដើម្បីឱ្យនិយមន័យពាក្យ និងគោលការណ៍សំខាន់ៗទាំងឡាយ។ អ្នកទាំងឡាយ ដែលអ្នកបង្រៀន ប្រហែលជាមិនធ្លាប់ស្គាល់ពាក្យជាច្រើន ដែលអ្នកនឹងប្រើនៅពេលអ្នកបង្រៀនទេ។
- ត្រឡប់ទៅមេរៀន ដែលបានបង្រៀនពីមុន ដើម្បីបង្រៀនអំពីគោលលទ្ធិឱ្យកាន់តែច្បាស់ជាងមុន។ ការណ៍នេះ អាចចាំបាច់នៅគ្រប់ពេលនៅក្នុងដំណើរការនៃការបង្រៀន។

### គំរូខាងព្រះគម្ពីរ

បទគម្ពីរមាននូវគំរូរបស់អ្នកផ្សព្វផ្សាយសាសនា ដែលបានបង្រៀនទៅដល់អ្នកទាំងឡាយ ដែលមិនជឿដល់ព្រះ ឬភាន់ច្រឡំអំពីទិស្សយ៍ពិតរបស់ទ្រង់។ ចូរសិក្សាបទគម្ពីរដូចខាងក្រោមនេះ ហើយបន្ទាប់មកពន្យល់ទៅដៃគូរបស់អ្នក ឬកត់ទុកនៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក អំពីរបៀប ដែលអ្នកផ្សព្វផ្សាយសាសនាទាំងនេះ បានជួយដល់មនុស្សឱ្យទទួលបាន ទីបន្ទាល់មួយថា ព្រះមានព្រះជន្មរស់។

- អាលម៉ា និងអាមូលេក (អាលម៉ា 9–12, 15)
- អាំម៉ូន និងអើរ៉ុន (អាលម៉ា 17–22)
- អាលម៉ា (អាលម៉ា 30)
- អាលម៉ា និងអ្នកផ្សេងទៀត (អាលម៉ា 31–35)
- ប៉ុល (កិច្ចការ 17:16–34)

កំណត់ចំណាំ

## សកម្មភាពៈ ការសិក្សាជាដៃគូ

នៅពេលដែលអាចធ្វើទៅបាន ចូរចង្អុលបង្ហាញអំពីអ្នកផ្លាស់គំនិតម្នាក់ ដែលមិនមែនជាផ្នែកមួយ នៃទំនៀមទំលាប់ពួកគ្រីស្ទាន មុនពេលពួកគេជួបជាមួយនឹងអ្នកផ្សព្វផ្សាយសាសនា។ ចូររៀបចំ ដើម្បីជួបជាមួយនឹងពួកគេ ហើយសួរអំពីបទពិសោធន៍ នៃការផ្លាស់គំនិតរបស់ពួកគេ។ ឧទាហរណ៍ អ្នកអាចសួរថា អ្វី ដែលនាំឱ្យមនុស្សនោះជឿដល់ព្រះ លើកទីមួយ ដែលពួកគេ អធិស្ឋាន លើកទីមួយ ដែលពួកគេមានអារម្មណ៍ទទួលចំលើយចំពោះការអធិស្ឋាន តួនាទីរបស់បទគម្ពីរ នៅក្នុងការផ្លាស់គំនិត របស់ពួកគេ ហើយតើនៅពេលពួកគេចូលរួមក្នុងការកិច្ចការនៅថ្ងៃអាទិត្យយ៉ាងដូចម្ដេច។ ចូរសរសេរអំពីអ្វី ដែលអ្នករៀននៅក្នុង សៀវភៅកំណត់ហេតុក្នុងការសិក្សារបស់អ្នក។

## ចូរចងចាំការណ៍នេះ

- នៅពេលមនុស្ស ត្រូវបានបង្រៀនដំណឹងល្អដែលបានសាងឡើងវិញ ហើយរស់នៅក្នុងដំណឹងល្អ សេចក្ដីត្រូវការរបស់ពួកគេនឹងបានបំពេញ។
- ធ្វើផែនការ និងសិក្សារាល់ថ្ងៃ ជាមួយដៃគូរបស់អ្នក ដើម្បីឱ្យមានសាមគ្គីភាព និងដើម្បីបង្រៀន ដោយសំលេង តែមួយ។
- ចែកចាយទីបន្ទាល់របស់អ្នកជារឿយៗ។
- បទគម្ពីរ ជាពិសេសព្រះគម្ពីរមរមន គឺជាប្រភពសំខាន់របស់អ្នក សំរាប់ការបង្រៀន។
- អធិស្ឋានសំរាប់អំណោយទាននៃការញែកដឹង ដើម្បីដឹងថា នៅពេលណាត្រូវប្រើជំនាញទាំងឡាយ ដែលបានពិពណ៌នានៅ ក្នុងជំពូកនេះ

# យោបល់សំរាប់ការសិក្សា និងអនុវត្ត

កំណត់ចំណាំ

## ការសិក្សាផ្ទាល់ខ្លួន

- សន្មត់ថាអ្នក ត្រូវបានដាក់នៅក្នុងស្ថានភាពដូចខាងក្រោមនេះ។ តើអ្នកអាចប្រើគោលការណ៍ និងជំនាញនៅក្នុងជំពូកនេះ ដើម្បីជួយមនុស្សទាំងនេះឱ្យរីកចំរើនបានយ៉ាងដូចម្ដេច? ចូរធ្វើផែនការអំពីរបៀប ដែលអ្នកអាចអនុវត្តគោលការណ៍ទាំងនេះ នៅក្នុងស្ថានភាពនីមួយៗ។
  - នៅពេលកំពុងដើរនៅក្នុងសួនមួយ អ្នកឃើញស្ត្រី និងក្មេងប្រុសម្នាក់កំពុងអង្គុយម្នាក់នៅលើកៅអីវែងមួយ។ ស្ត្រីនោះកំពុងយំ។
  - អ្នកមកដល់ផ្ទះរបស់សាសនាគន់ការី ដែលកំពុងតែរៀបចំសំរាប់ពិធីបុណ្យជ្រមុជទឹក ហើយពួកគេបានប្រាប់ថា ពួកគេមិនចង់ជួបជាមួយអ្នកតទៅទៀតទេ។
  - អ្នកកំពុងតែជួបជាលើកទីប្រាំពីរ ជាមួយសាសនាគន់ការីម្នាក់ ដែលបានបង្រៀនដោយអ្នកផ្សព្វផ្សាយ សាសនាជាច្រើននាក់ ជាងពីរឆ្នាំមកហើយ។ មានសញ្ញានៃការរីកចំរើនបន្តិចបន្តួច។
  - អ្នកកំពុងតែចាប់ផ្ដើម បង្រៀនសមាជិកគ្រួសារមួយអំពីសារលិខិតដំណឹងល្អ ហើយពួកគេនិយាយថា“ យើងបានសួររួចហើយ ដល់មនុស្សគ្រប់រូប ដែលយើងស្គាល់ ដើម្បីជួបជាមួយនឹងអ្នកផ្សព្វផ្សាយសាសនា ហើយពួកគេទាំង អស់និយាយថា ទេ។”
- ចូរជ្រើសរើសមេរៀនមួយ ពីមេរៀនរបស់អ្នកផ្សព្វផ្សាយសាសនា។ ចូរចង្អុលបង្ហាញវគ្គគម្ពីរមួយ ឬពីរមកពីគោលការណ៍សំខាន់ នីមួយៗ។ ចូរអនុវត្តការបង្រៀន ពីវគ្គគម្ពីរទាំងនោះ ដូចបានផ្ដល់ជាលំនាំនៅក្នុងវគ្គ “ប្រើប្រាស់ព្រះគម្ពីរ“ សំរាប់ជំពូកនេះ។
- រំលងជាច្រើនសប្ដាហ៍មក ចូររំលឹកអំពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងដំណឹងល្អ (ម៉ាថាយ ម៉ាកុស យ៉ូហាន) និងនីហ្វៃទី 3។ នៅក្នុងសៀវភៅកំណត់ហេតុក្នុងការសិក្សា ចូរធ្វើបញ្ជីនៃសំនួរមួយ ដែលទ្រង់បានសួរ។ ចូរប្រៀបធៀប សំនួរទាំងនេះ ជាមួយនឹងសំនួរ ដែលជាប្រភេទអ្នកសួរ។
- សូមអានដំណើររឿងរបស់អាំម៉ូន និងស្ដេចឡាម៉ូណៃ នៅក្នុងអាលម៉ា 18 និងដំណើររឿងរបស់អើរ៉ុននៅក្នុងអាលម៉ា 22:4–18។ នៅពេលអ្នកអាន ចូរគត់សំគាល់ និងពិពណ៌នាអំពីអាំម៉ូន និងអើរ៉ុនជាយ៉ាងណានោះៈ
  - ធ្វើតាមព្រះវិញ្ញាណ និងបង្រៀនដោយសេចក្ដីស្រឡាញ់។
  - ចាប់ផ្ដើមបង្រៀន។
  - សម្របសម្រួលការបង្រៀនរបស់ពួកគេឱ្យត្រូវនឹងសេចក្ដីត្រូវការទាំងឡាយ។
  - ថ្លែងទីបន្ទាល់។
  - ប្រើប្រាស់បទគម្ពីរ។
  - សួរសំនួរ ស្ដាប់ ហើយដោះស្រាយកង្វល់។
  - លើកទឹកចិត្តអ្នកទាំងនោះ ដែលពួកគេបង្រៀនឱ្យធ្វើការតាំងចិត្ត។
- ពិចារណាសេចក្ដីថ្លែងនៅខាងក្រោមនេះ ដោយប្រធាន ហារ៉ូល ប៊ី លី អំពីការបង្រៀនសំរាប់ឱ្យមានការយល់ដឹង។ ធ្វើការវាយតំលៃថា តើអ្នកបង្រៀនគោលលទ្ធិនៃដំណឹងល្អបានច្បាស់លាស់ប៉ុណ្ណា។ កត់ត្រាអំពីអ្វី ដែលអ្នករៀននៅក្នុងសៀវភៅ កំណត់ហេតុក្នុងការសិក្សារបស់អ្នក។

  “សូមឱ្យអ្នកនៅជាមួយនឹងបរិបទ នៃព្រះគម្ពីរ និងធ្វើឱ្យងាយយល់ព្រះគម្ពីរ ដើម្បីអាចយល់ពាក្យទាំងឡាយនោះ”(*The Teachings of Harold B. Lee*, ជ្រើសរើស Clyde J. Williams [ឆ្នាំ 1996], 444)។

  “ឥឡូវនេះ អ្នកជាគ្រូបង្រៀន ដែលមិនត្រូវបានបញ្ជូនចេញទៅឱ្យបង្រៀនគោលលទ្ធិថ្មីទេ។ អ្នកគឺត្រូវបង្រៀនគោលលទ្ធិ ចាស់ ដែលមិនច្បាស់លាស់ពេក ដែលពួកគេ អាចត្រឹមតែយល់ដោយងាយឡើយ ប៉ុន្តែអ្នកត្រូវតែបង្រៀនគោលលទ្ធិ នៃ សាសនាចក្រ ឱ្យបានច្បាស់បំផុត ដែលនឹងមិនធ្វើឱ្យនរណាម្នាក់មានការភាន់ច្រឡំ”(*The Teachings of Harold B. Lee*, 458)។

## ការសិក្សាជាដៃគូ

- ចូររំលឹកផែនការមេរៀនរបស់អ្នក មកពីមេរៀនថ្មីៗនេះ ដែលអ្នកបានបង្រៀន។ ចូរសរសេរសំនួរមួយសំរាប់ គោលការណ៍ ចំបងៗនីមួយៗ ដែលបានបង្ហាញជាលំនាំនៅក្នុងផែនការរបស់អ្នក។ បន្ទាប់មករំលឹក សំនួរទាំងឡាយរបស់អ្នក ដើម្បីឃើញថា

កំណត់ចំណាំ

តើមានត្រូវគ្នានឹងអ្វី ដែលត្រូវបង្រៀនទៅក្នុងជំពូកនេះដែរឬទេ។ បន្ទាប់មកឆ្លើយសំនួរនីមួយៗ ដែលអ្នកដូចជាសាសនាគន់ការីម្នាក់។ កែសំនួររបស់អ្នក បើចាំបាច់។ ចែកចាយសំនួររបស់អ្នកជាមួយនឹងដៃគូរបស់អ្នក។ ធ្វើការវាយតំលៃអំពីសំនួរទាំងឡាយរបស់អ្នកទាំងអស់គ្នា។

ចូរពិចារណាអំពីតំរូវការរបស់សាសនាគន់ការីម្នាក់ ដែលអ្នកកំពុងបង្រៀន។ ចូរពិភាក្សាអំពីរបៀប ដែលគាត់ ឬនាង អាចឆ្លើយសំនួររបស់អ្នក។ ព្រមទាំងពិភាក្សាអំពីរបៀប ដែលសំនួរទាំងនេះ អាចអញ្ជើញព្រះវិញ្ញាណបរិសុទ្ធ និងជួយសាសនាគន់ការីឱ្យរៀនដំណឹងល្អផងដែរ។

- ចូរគិតអំពីសាសនាគន់ការីថ្មីៗម្នាក់ៗ។ ចូរពិភាក្សាអំពីអ្វី ដែលអ្នកអាចធ្វើ ដើម្បីជួយពួកគេឱ្យក្លាយទៅជា សាសនាគន់ការី ដែលមានការរីកចំរើន។ ចូរសរសេរអំពីគំនិតរបស់អ្នក នៅក្នុងសៀវភៅកំណត់ហេតុក្នុងការសិក្សារបស់អ្នក ហើយធ្វើផែនការនៅក្នុងកាលវិភាគជាប្រចាំរបស់អ្នក។

## ការប្រជុំក្នុងមណ្ឌល និងសន្និសីទក្នុងហ្សូន

- អញ្ជើញសមាជិក ឬសាសនាគន់ការីថ្មីៗ ដើម្បីចូលរួមនៅក្នុងការប្រជុំរបស់អ្នក។ ចូរពន្យល់ទៅក្រុមថា អ្នកចង់ឱ្យអ្នកផ្សព្វផ្សាយសាសនា ពង្រីកសមត្ថភាពរបស់ពួកគេ ក្នុងការចែកចាយសារលិខិតដ៏សំខាន់របស់ពួកគេ។ ចូរជ្រើសរើសមេរៀន និងជំនាញមួយ។ ហើយឱ្យអ្នកផ្សព្វផ្សាយសាសនា បង្រៀនដល់សមាជិក ឬសាសនាគន់ការីនូវមេរៀន ដែលអ្នកបានជ្រើសរើស សំរាប់រយៈពេល 20 នាទី ដោយផ្តោតទៅលើជំនាញ ដែលអ្នកបានប្រាប់។ សូមឱ្យពួកគេផ្លាស់ប្តូរ បន្ទាប់ពីរយៈពេល 20នាទី។ បន្ទាប់ពីអ្នកផ្សព្វផ្សាយសាសនា មានឱកាសដើម្បីបង្រៀនម្តងម្នាក់ហើយ ចូរនាំក្រុមមកជួបជុំគ្នាវិញ ហើយឱ្យសមាជិក និង សាសនាគន់ការី ប្រាប់ដល់អ្នកផ្សព្វផ្សាយសាសនា អំពីអ្វី ដែលមានប្រសិទ្ធភាពបំផុត និងវិធីមួយ ដែលពួកគេអាចរីកចំរើន។

- បង្ហាញវីដេអូអំពីគំរូ នៃអ្នកផ្សព្វផ្សាយសាសនា ដែលកំពុងបង្រៀន និងទាក់ទងជាមួយមនុស្ស។ ចូរជ្រើសរើសជំនាញ មួយមក ហើយធ្វើការពិភាក្សាជាក្រុមមួយ ថាតើអ្នកផ្សព្វផ្សាយសាសនា នៅក្នុងវីដេអូបានអនុវត្តគោលការណ៍ទាំងឡាយសំរាប់ជំនាញមួយនោះបានល្អយ៉ាងណា។

- ចូរជ្រើសរើសជំនាញមួយ ឬទិដ្ឋភាពសំខាន់មួយ នៃជំនាញ ហើយសំគាល់អំពីគោលលទ្ធិ ឬវគ្គគម្ពីរ ដែលគាំទ្រ ដល់ជំនាញនោះ។ ចូរបង្រៀនអំពីគ្រឹះនៃគោលលទ្ធិ នៃជំនាញទៅកាន់អ្នកផ្សព្វផ្សាយសាសនាទាំងឡាយ។

## ប្រធានបេសកកម្ម

- ជូនកាលទៅតាមអ្នកផ្សព្វផ្សាយសាសនា នៅពេលពួកគេបង្រៀន។ ធ្វើផែនការជាមួយពួកគេ អំពីរបៀប ដែលអ្នកអាចចូលរួមនៅក្នុងការបង្រៀន។

- លើកទឹកចិត្តដល់អ្នកដឹកនាំបព្វជិតភាព ដើម្បីទៅតាមអ្នកផ្សព្វផ្សាយសាសនានៅក្នុងការជួបបង្រៀនរបស់ពួកគេ ហើយផ្តល់គំនិតមកវិញ។

- ស្រាយបំភ្លឺអំពីប្រសិទ្ធភាព នៃការប្រើបទគម្ពីរ សំនួរ ហើយការស្តាប់ នៅពេលបង្រៀនអ្នកផ្សព្វផ្សាយសាសនា នៅក្នុងសន្និសីទក្នុងតំបន់ និងធ្វើការសម្ភាសន៍។



# តើខ្ញុំជួយឱ្យមនុស្សធ្វើ និងរក្សាការតាំងចិត្ត យ៉ាងដូចម្ដេច?

កំណត់ចំណាំ

**ចូរពិចារណាចំណុចនេះ**

- តើហេតុអ្វីបានជាខ្ញុំ យកចិត្តទុកដាក់ទៅលើ ការអញ្ជើញមនុស្សឱ្យធ្វើការតាំងចិត្ត?
- តើការតាំងចិត្តមានទំនាក់ទំនងអ្វីជាមួយនឹងការផ្លាស់គំនិត?
- តើខ្ញុំអាចថ្លែងសក្ខីភាពដ៏បន្ទាបខ្លួន យ៉ាងដូចម្ដេច?
- តើអ្វីពរជ័យខ្លះ ដែលខ្ញុំអាចសន្យា?
- ហេតុអ្វីវាសំខាន់សំរាប់ខ្ញុំ ដើម្បីធ្វើការតាមដានពេលដែលមនុស្សធ្វើការតាំងចិត្ត?

## ពង្រីកការអញ្ជើញឱ្យតាំងចិត្ត

ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា អ្នកមានបំណងប្រាថ្នាដើម្បី សេចក្ដីសង្គ្រោះនៃព្រលឹង (សូមមើល ម៉ូសាយ 28:3)។ អ្នកដឹងថា មនុស្សអាចមកឯព្រះគ្រីស្ទ និងត្រូវបានសង្គ្រោះ មានតែតាមល័ក្ខខ័ណ្ឌនៃការប្រែចិត្តតែប៉ុណ្ណោះ (សូមមើល គ និង ស 18:10–16)។ វិធីមួយដើម្បីបំពេញបំណងប្រាថ្នារបស់អ្នក គឺស្រែករកការប្រែចិត្ត (សូមមើល អាលម៉ា 5:49, គ និង ស 15:6, 16:6) និងអញ្ជើញមនុស្សដោយក្លាហាន ឱ្យអនុវត្តសេចក្ដីជំនឿទៅរក ការប្រែចិត្ត ពិធីបុណ្យជ្រមុជទឹកដោយទឹក និងដោយ ព្រះវិញ្ញាណ ហើយស៊ូទ្រាំដល់ទីបំផុតដោយស្មោះត្រង់ (សូមមើល នីហ្វៃទី3 27:16–20, មរមន 7:10)។

ការតាំងចិត្តគឺជា ផ្នែកសំខាន់ដ៏នៃការប្រែចិត្ត។ វាជាកាតព្វកិច្ចនៃមនុស្សម្នាក់ ក្នុងការប្រព្រឹត្តអ្វីមួយ ហើយបន្ទាបមកធ្វើតាមដោយឧស្សាហ៍ព្យាយាម តាមការសំរេចចិត្តនោះ។ ពេលដែលមនុស្សតាំងចិត្តដោយពិតប្រាកដ នោះពួកគេនឹងមានគោល បំណងពិតមានន័យថា ពួកគេមានគោលបំណងយ៉ាងពិតប្រាកដ ដើម្បីធ្វើអ្វី ដែលពួកគេបានតាំងចិត្ត ថានឹងធ្វើ។ ពួកគេរឹងមាំ ហើយសំរេចចិត្តយ៉ាងពិតប្រាកដ ដើម្បីផ្លាស់ប្ដូរ។ ពួកគេក្លាយជាមនុស្ស មានភក្ដីភាពចំពោះព្រះគ្រីស្ទ និងលះបង់ចំពោះ ដំណឹងល្អរបស់ទ្រង់។ ការរក្សាការតាំងចិត្តរបស់គេ គឺជារបៀបដែលពួកគេ ប្រាកដជាសំដែងដោយកិច្ចការ ទាំងឡាយរបស់ពួកគេ ថាពួកគេបានទទួលពីព្រះវិញ្ញាណនៃព្រះគ្រីស្ទ ចំពោះការផ្ដាច់បាបទាំងឡាយរបស់ពួកគេ (សូមមើល គ និង ស 20:37)។ ពេលដែលអ្នក ប្រើការតាំងចិត្ត គឺអ្នកកំពុងអញ្ជើញសាសនាគន់ការី ឱ្យប្រែចិត្តហើយ។

វិធីមួយដ៏ប្រសើរបំផុតដើម្បីជួយមនុស្សធ្វើ និងរក្សាការតាំងចិត្ត គឺជាការីពង្រីកការអញ្ជើញឱ្យតាំងចិត្ត។ ការពង្រីក និងការតាមដានលើការអញ្ជើញការតាំងចិត្ត គឺសំខាន់ព្រោះ:

© 2002 Del Parson. Do not copy.

កំណត់ចំណាំ

- មនុស្សក្លាយជាអ្នកផ្លាស់សាសនា ពេលដែលពួកគេរស់នៅតាមគោលការណ៍ ដែលពួកគេរៀន (សូមមើល យ៉ូហាន 7:17) និងទទួលអារម្មណ៍បញ្ជាក់ពីព្រះវិញ្ញាណថា អ្វីដែលពួកគេកំពុងធ្វើគឺផ្គាប់ព្រះហឫទ័យព្រះវរបិតានៅស្ថានសួគ៌។
- ការប្រែចិត្ត និងការផ្លាស់ប្តូរ នឹងជួយអ្នកឈ្នះលើឧបសគ្គ បំបាត់ភាពអាម៉ាស ពីខ្លួនពួកគេ និងកំហុស និងទទួលបទពិសោធន៍នៃសេចក្តីសុខសាន្ត និងសេចក្តីអំណរនៃការអភ័យទោសរបស់ព្រះ។
- ការរក្សាការតាំងចិត្ត រៀបចំមនុស្ស ដើម្បីធ្វើ និងរក្សាសេចក្តីសញ្ញាពិសិដ្ឋរបស់ពួកគេ។



© 2001 Simon Dewey។ ហាមថតចំលង។

អ្នកអាចបង្ហាញសេចក្តីស្រលាញ់របស់អ្នក សំរាប់មនុស្ស និងសេចក្តីជំនឿរបស់អ្នកទៅក្នុងការសន្យារបស់ព្រះ ដោយធ្វើការតាមដានដើម្បីជួយពួកគេប្រែចិត្ត និងរក្សាការតាំងចិត្តរបស់ពួកគេ។

ការតាំងចិត្តជាតំរូវការសំរាប់បុណ្យជ្រមុជទឹកគឺ ត្រូវបានសរសេរនៅក្នុងមេរៀនទាំងបួនដំបូង។ ការតាំងចិត្តមានទំនាក់ទំនងនឹងការរីកចំរើនខាងវិញ្ញាណ បន្ទាប់ពីពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ដែលត្រូវបានសរសេរនៅក្នុងមេរៀនទី 5។ ត្រូវតែជាក់លាក់អំពីសេចក្តីត្រូវការ ដើម្បីអញ្ជើញមនុស្សឱ្យធ្វើអ្វីៗ ដែលនឹងពង្រឹង សេចក្តីជំនឿរបស់គេនៅក្នុងព្រះគ្រីស្ទ។ ចូរចាំនូវគោលការណ៍ដូចខាងក្រោម៖

- រាល់ឱកាសដែលមាន—ជាមួយសមាជិក មនុស្សថ្មីដែលត្រូវទៅជួប ឬការទំនាក់ទំនងផ្ទាល់ខ្លួន—គួរតែនាំទៅរក ការអញ្ជើញមួយដើម្បីរៀនពីសារដំណឹង នៃការស្តារឡើងវិញ។
- ដោយកម្រ តែបើមាន តើអ្នកគួរតែនិយាយទៅកាន់មនុស្ស ឬបង្រៀនពួកគេ ដោយគ្មានការពង្រីកការអញ្ជើញឱ្យតាំង ចិត្តដើម្បីធ្វើអ្វីដែលនឹងពង្រឹងសេចក្តីជំនឿ របស់ពួកគេនៅក្នុងព្រះគ្រីស្ទ។
- យកចិត្តទុកដាក់ទៅលើការតាំងចិត្តមួយ ឬច្រើនជាង នៅពេលដែលអ្នកបង្រៀន។ បើអ្នកមិនអញ្ជើញមនុស្សដើម្បី ធ្វើការតាំងចិត្តទាំងនេះទេ អ្នកមិនបានសួរពួកគេឱ្យប្រែចិត្ត និងមកឯព្រះគ្រីស្ទទេ។
- នៅពេលដែលអ្នករៀបចំក្នុងពេលសិក្សាជាមួយដៃគូ ដើម្បីបង្រៀនមេរៀនមួយ ចូរពិចារណាលើសេចក្តីត្រូវការ និងស្ថានភាពរបស់សាសនាគន់ការីម្នាក់ៗ និងបញ្ចូលការតាំងចិត្តមួយ ឬច្រើនជាងនៅក្នុងផែនការមេរៀន។
- អំឡុងពេលបង្រៀន អ្នកប្រហែលជាអាចទទួលការបំផុសគំនិត ដើម្បីពង្រីកការអញ្ជើញ ឱ្យតាំងចិត្តផ្សេងទៀត ច្រើនជាងការតាំងចិត្តដែលអ្នកបានរៀបផែនការ។ ចូរអញ្ជើញមនុស្សឱ្យប្រែចិត្តជានិច្ច។
- ចូរក្លាហាន និងជឿជាក់ ពេលអ្នកអញ្ជើញមនុស្សឱ្យធ្វើការតាំងចិត្ត (សូមមើល អាលម៉ា 38:12)។ ភាពក្លាហានបង្ហាញសេចក្តីជំនឿរបស់អ្នកថា ការគោរពប្រតិបត្តិចំពោះព្រះបញ្ញត្តិរបស់ព្រះអម្ចាស់នាំមកនូវពរជ័យ។
- មនុស្សនឹងមិនចូលចិត្តធ្វើការផ្លាស់ប្តូរទេ លើកលែងតែពួកគេត្រូវបានអញ្ជើញឱ្យធ្វើដូច្នោះ។

## ការសិក្សាព្រះគម្ពីរ

### ហេតុអ្វីការពង្រីកការតាំងចិត្តសំខាន់?

| | |
|---|---|
| អាលម៉ា 5:62 | មរ៉ូណៃ 7:13 |

### ហេតុអ្វីការតាំងចិត្តសំខាន់ខ្លាំងម្លេះ?

| | | |
|---|---|---|
| នីហ្វៃទី 2 31 | អាលម៉ា 32:27 | យ៉ូហាន 7:17 |
| ម៉ូសាយ 2:41 | គ និង ស 14:7 | |
| អាលម៉ា 7:14–16 | គ និង ស 20:37 | |

កំណត់ចំណាំ

## សួរសំនួរចំៗ

ការអញ្ជើញឱ្យតាំងចិត្ត តែងតែប្រើទម្រង់សំនួរ “តើអ្នកព្រម” ដែលតម្រូវឱ្យមានចំលើយ *ព្រម* ឬ *មិនឆ្លើយតប*។ ការញ្ជើញគួរតែជាក់លាក់ ចំៗ និងច្បាស់។ ពាក្យទាំងនេះអញ្ជើញ ឬនាំមនុស្សឱ្យសំរេចចិត្តដើម្បីធ្វើសកម្មភាព។ ពាក្យទាំងនេះតម្រូវឱ្យពួកគេធ្វើការតាំងចិត្ត និងអនុវត្តសេចក្តីជំនឿដែលមានសកម្មភាព នៅក្នុងគោលការណ៍ដែលអ្នកបង្រៀនពួកគេ។

ខាងក្រោម គឺជាគំរូនៃការអញ្ជើញ ដែលភ្ជាប់ជាមួយដោយ ការចាប់ផ្តើមនៃការសន្យា និងសក្ខីភាពៈ

- តើអ្នកព្រមអាន [នីហ្វៃទី 3 11, ម៉ូរ៉ូណៃ 10ៈ3–5, សៀវភៅតូចនេះ ] ពីមុនការមកជួបម្តងទៀតរបស់យើង នៅថ្ងៃស្អែកម៉ោង 7ៈ00 ល្ងាច ដែរឬទេ? ខ្ញុំដឹងថា ការធ្វើដូច្នេះនឹង . . . ខ្ញុំសូមថ្លែងថា ព្រះគម្ពីរមរមនគឺ . . .
- តើអ្នកព្រមអធិស្ឋានសួរព្រះថា តើយ៉ូសែប ស៊្មីធ គឺជាព្យាការី ដែរឬទេ? ខ្ញុំដឹងថា ពេលដែលអ្នកអធិស្ឋានព្រះនឹង . . . ខ្ញុំដឹង ថា យ៉ូសែប ស៊្មីធ គឺជាព្យាការី . . .
- តើអ្នកព្រមទៅព្រះវិហារជាមួយយើង នៅថ្ងៃអាទិត្យនេះ នៅម៉ោង 9ៈ00 ព្រឹក ដែរឬទេ? បើអ្នកព្រម អ្នកនឹង . . . ខ្ញុំដឹងថា ព្រះវិហាររបស់ព្រះគ្រីស្ទ គឺត្រូវបានស្តារឡើងវិញ . . .
- តើអ្នកព្រមចាប់ផ្តើមពីឥឡូវ ដើម្បីរស់នៅតាមច្បាប់នៃបរិសុទ្ធភាព ដូចដែលយើងបានពន្យល់ដែរឬទេ? ការរស់នៅតាម ច្បាប់នេះនឹង . . .។ ក្នុងនាមជាអ្នកបំរើរបស់ព្រះអម្ចាស់ ខ្ញុំសូមថ្លែងថា ការរស់នៅក្នុងជីវិតដែលបរិសុទ្ធ . . .
- តើអ្នកព្រមអញ្ជើញ [ឈ្មោះ] ពីមុនថ្ងៃសុក្រ ដើម្បីជួបជាមួយពួកយើង និងចាប់ផ្តើមរៀនអំពីដំណឹងល្អដែរឬទេ? ព្រះវិញ្ញាណនឹងជួយអ្នក . . .។ ការចែកចាយដំណឹងល្អនឹងប្រទានពរដល់ជីវិតរបស់យើង . . .
- តើពួកយើងអាចមកផ្ទះរបស់អ្នក និងប្រាប់អ្នកបន្ថែមទៀត អំពីរបៀបដែលព្រះ បានហៅព្យាការីនៅក្នុងសម័យរបស់យើង ដូចដែលទ្រង់បានធ្វើនៅសម័យបុរាណ ដែរឬទេ? ចូរបង្កើនគោលបំណង ទិសដៅ ដើម្បីសេចក្តីសុខសាន្តនឹងមកនៅក្នុងជីវិតរបស់អ្នក ពេលដែលអ្នកងាកមកយល់ . . . ខ្ញុំសូមថ្លែងម្តងទៀតថា ព្រះបានហៅ . . .

### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន ឬការសិក្សាជាមួយដៃគូ

នៅក្នុងសៀវភៅសិក្សារបស់អ្នក ចូរសរសេរការអញ្ជើញដែលសាមញ្ញ ចំៗ ច្បាស់លាស់ និងរាល់ការតាំងចិត្ត នៅក្នុងមេរៀន។ បើអ្នកបានធ្វើសកម្មភាពនេះរួចទៅហើយ ចូររំលឹកវាឡើងវិញ ហើយប្រៀបធៀប ការអញ្ជើញថ្មីរបស់អ្នកជាមួយនឹង កំណែពីមុន។ ចូរសួរខ្លួនឯងថា តើសមត្ថភាពរបស់អ្នក ដើម្បីពង្រីកការអញ្ជើញ បានអភិវឌ្ឍន៍ឬទៅ។

រំលឹកការអញ្ជើញដែលអ្នកបានសរសេរជាមួយដៃគូរបស់អ្នក។ សំរាប់ការអញ្ជើញនីមួយៗ ពិភាក្សាសំនួរដូចខាងក្រោមៈ

- តើខ្ញុំបានពន្យល់អំពីពរជ័យដែលព្រះអម្ចាស់ បានសន្យា ដែរឬទេ ពេលដែលខ្ញុំពង្រីកការអញ្ជើញ? បើមិនធ្វើដូច្នោះ តើមកពីហេតុអ្វី?
- តើខ្ញុំបានជៀសវាងពីការពង្រីក ការអញ្ជើញនេះ ដែរឬទេ? បើដូច្នោះ តើមកពីហេតុអ្វី?
- តើខ្ញុំមានអារម្មណ៍ខ្មាស់អៀន ដែរឬទេ ពេលដែលខ្ញុំពង្រីកការអញ្ជើញនេះ? តើខ្ញុំអាចអភិវឌ្ឍន៍ យ៉ាងដូចម្តេច?
- តើការអញ្ជើញនេះ សំខាន់យ៉ាងដូចម្តេច ចំពោះខ្លួនខ្ញុំផ្ទាល់?
- តើខ្ញុំចងចាំ ដើម្បីធ្វើការតាមដាន លើការអញ្ជើញដែលខ្ញុំបានពង្រីក ញឹកញាប់ដែរឬទេ? តើខ្ញុំអាចអភិវឌ្ឍន៍ យ៉ាងដូចម្តេច?

ចូរគិតអំពីសាសនាគន់ការី ឬសមាជិកមិនសូវសកម្មដែលអ្នកស្គាល់ ហើយអនុវត្តពង្រីកការអញ្ជើញទាំងនេះ ដូចជាគំនិតដែលអ្នកនិយាយទៅកាន់បុគ្គលទាំងនោះ។

បើចាំបាច់ ចូរបន្ថែមការអញ្ជើញនៅក្នុងផែនការមេរៀនរបស់អ្នក។ ចូរដាក់គោលដៅជាក់លាក់ ដែលនឹងជួយអ្នកពង្រីកការអញ្ជើញជារៀងរាល់ថ្ងៃ និងរាល់សប្តាហ៍។

## សន្យាថានឹងប្រទានពរជ័យដល់មនុស្ស

មនុស្សត្រូវការមូលហេតុដើម្បីផ្លាស់ប្តូរគំនិត និងសកម្មភាពរបស់គេ។ ពរជ័យដែលបានសន្យា ជាញឹកញាប់ផ្តល់ហេតុផលដ៏មានអំណាចដើម្បីគោរពប្រតិបត្តិតាមព្រះ។ ពេលដែលព្រះអម្ចាស់ផ្តល់ព្រះបញ្ញត្តិមក ជាញឹកញាប់ទ្រង់សន្យាប្រទានពរជ័យ សំរាប់ការរក្សាព្រះបញ្ញត្តិនោះ (សូមមើល គ និង ស 130ៈ20–21)។ ពេលដែលអ្នករៀបចំមនុស្សឱ្យគោរពប្រតិបត្តិព្រះបញ្ញត្តិជាក់លាក់ណាមួយ ចូរបង្រៀនពួកគេថាៈ

កំណត់ចំណាំ

- ការរស់នៅតាមព្រះបញ្ញត្តិ បង្ហាញសេចក្តីស្រលាញ់សំរាប់ព្រះ និងព្រះរាជបុត្រារបស់ទ្រង់។
- ពួកគេបង្ហាញការទុកចិត្តរបស់គេលើព្រះ ពេលដែលពួកគេគោរពប្រតិបត្តិព្រះបញ្ញត្តិរបស់ទ្រង់។
- ពរជ័យដែលត្រឡប់មកវិញ គឺពួកគេនឹងទទួលពរជ័យដែលទ្រង់បានសន្យា។

នៅពេលដែលអ្នកថ្លែងពីព្រះបញ្ញត្តិ ចូរនិយាយអំពីពរជ័យដែលអ្នកបានទទួល បានមកពីការរស់នៅតាមព្រះបញ្ញត្តិនោះ។ ចូរសន្យាអ្នកទាំងឡាយណាដែល អ្នកបង្រៀនថា ពួកគេអាចរីករាយនឹងពរជ័យស្រដៀងគ្នានោះ។

ពេលដែលមនុស្សព្យាយាមដើម្បីរក្សាការតាំងចិត្ត ចូរសួរពួកគេឱ្យនិយាយអំពីពរជ័យ ដែលព្រះវរបិតាសួគ៌បានប្រទានដល់ពួកគេ។ អះអាងជាមួយពួកគេថា ទោះបីជាការលំបាកនឹងចូលនៅក្នុងជីវិតរបស់គេ ពរជ័យរបស់ទ្រង់នឹងបន្ត ពេលដែលពួកគេគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ទ្រង់។

### ការសិក្សាព្រះគម្ពីរ

**តើព្រះអម្ចាស់មានបន្ទូលអ្វី អំពីបំណងប្រាថ្នារបស់ទ្រង់ដើម្បីប្រទានពរជ័យដល់យើង?**

| | | |
|---|---|---|
| អាលម៉ា 37៖17 | គ និង ស 1៖37 | គ និង ស 76៖5–10 |

### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

អានគោលលិទ្ធិ និងសេចក្តីសញ្ញា 82៖10 និង 130៖20–21។ បន្ទាប់មក សិក្សាព្រះគម្ពីរដូចខាងក្រោម។ ធ្វើគូឡៅនពីរនៅក្នុង សៀវភៅសិក្សារបស់អ្នក។ នៅផ្នែកម្ខាងសរសេរព្រះបញ្ញត្តិដែលអ្នករកឃើញនៅផ្នែកខាងក្រោយនីមួយៗ នៅផ្នែកម្ខាងទៀត សរសេរ សេចក្តីសន្យាសំរាប់ការរក្សាព្រះបញ្ញត្តិ។

| | | |
|---|---|---|
| គ និង ស 11៖21 | គ និង ស 89៖18–21 | គ និង ស 100៖5–8 |
| គ និង ស 84៖85 | គ និង ស 95៖8–9 | ម៉ាឡាគី 3៖10–12 |

រំលឹកការតាំងចិត្តដែលបានសរសេរនៅក្នុងមេរៀនមួយ នៃមេរៀនរបស់អ្នកផ្សព្វផ្សាយសាសនា។ សំរាប់ការតាំងចិត្តនីមួយៗ ចូរឆ្លើយសំនួរទាំងនេះ

- តើពរជ័យអ្វីដែលព្រះអម្ចាស់បានសន្យា ចំពោះអ្នកទាំងឡាយណាដែលរក្សាការតាំងចិត្តនេះ?
- តើការគោរពប្រតិបត្តិគោលការណ៍នេះ នឹងជួយមនុស្សកើនសេចក្តីជំនឿ និងសក្ខីភាព យ៉ាងដូចម្តេច?
- តើការតាំងចិត្តនេះនឹងជួយមនុស្សប្រែចិត្ត និងកាន់តែដឹងពីព្រះវិញ្ញាណដូចម្តេច?

## ថ្លែងសក្ខីភាពជាញឹកញាប់

សក្ខីភាព គឺជាសាក្សីខាងវិញ្ញាណ និងការអះអាងដែលត្រូវបានផ្តល់ឱ្យដោយព្រះវិញ្ញាណបរិសុទ្ធ។ ការថ្លែងសក្ខីភាពគឺជាការផ្តល់ឱ្យគំរូ ការប្រកាសចំៗ នៃការជឿជាក់ —អារម្មណ៍ ការធានាអះអាង ការជឿជាក់នៃដំណឹងល្អ។ ការចែកចាយសក្ខីភាព របស់អ្នកជាញឹកញាប់ គឺជាផ្លូវមួយនៃផ្លូវដ៏ប្រសើរបំផុត នៃការអញ្ជើញព្រះវិញ្ញាណ និងជួយអ្នកដទៃមានអារម្មណ៍ពីព្រះវិញ្ញាណ។ បន្ថែមសក្ខីភាពថ្មីៗ សាក្សីផ្ទាល់ខ្លួនចំពោះសេចក្តីពិតដែលអ្នកបានបង្រៀនចេញពីព្រះគម្ពីរ។ អ្នកផ្សព្វផ្សាយសាសនាដែលមានប្រសិទ្ធិភាព បង្រៀន ថ្លែងសក្ខីភាព និងអញ្ជើញអ្នកដទៃឱ្យធ្វើអ្វី ដែលសាងសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ។

> *“ចំពោះសក្ខីភាពរបស់មនុស្សម្នាក់ ចូរចងចាំមនុស្សណាម្នាក់ដែលមានឆន្ទៈ ចែកចាយអ្វីដែលគាត់មាន ពេលដែលគាត់មាន នោះភាពអាត្មានិយមធ្វើឱ្យគាត់បាត់បង់ . . .។ បង្រៀន និងធ្វើទីបន្ទាល់។ វាគ្មានរឿងសម្ងាត់ដែលប្រសើរនោះទេ។”*
>
> — អែលឌើរ ថូម៉ាស អេស មនសុន
> *PATHWAYS TO PERFECTION* [1973], 100–101

ការណ៍នេះបូករួមទាំងការធ្វើការសន្យា ដែលមកពីគោលការណ៍ពិត។ ឧទាហរណ៍ អ្នកផ្សព្វផ្សាយសាសនាម្នាក់ អាចនិយាយថាៈ “ខ្ញុំដឹងថា ពេលដែលអ្នករក្សាថ្ងៃសីលឱ្យបរិសុទ្ធ អ្នកនឹងរកឃើញសេចក្តីសុខសាន្តកាន់តែច្រើននៅក្នុងដួងចិត្តរបស់អ្នក។ ”

ដើម្បីឱ្យសក្ខីភាពរបស់អ្នកមានអំណាចជឿជាក់ អ្នកត្រូវមានចិត្តស្មោះសរ។ សក្ខីភាពដែលមានអំណាច គឺមិនពឹងទៅលើទេពកោសល្យខាងវោហារ ឬសូរនៃសំលេងរបស់អ្នកទេ តែលើការជឿជាក់នៃដួងចិត្តរបស់អ្នក។ ការព្យាយាមប្រចាំថ្ងៃដើម្បី ពង្រឹង

កំណត់ចំណាំ

ការយល់ដឹងរបស់អ្នក និងលើការជឿជាក់នៃគោលលទ្ធិ និងគោលការណ៍ដែលអ្នកបង្រៀន។ ចូរថ្លែងសក្ខីភាពរបស់អ្នក ញឹកញាប់ដើម្បីផ្សាភ្ជាប់ការពិត នៃគោលការណ៍ឬគោលលទ្ធិដែលអ្នកកំពុងបង្រៀន។ តាមដែលអាចធ្វើទៅបានយ៉ាងឆាប់ចូរបង្រៀន បន្ទាប់មកថ្លែងសក្ខីភាព និងថ្លែងសក្ខីភាពពេលដែលអ្នកបង្រៀន។



សក្ខីភាពរបស់អ្នកអាចមានលក្ខណៈសាមញ្ញដូចជា "ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ" ឬ "ខ្ញុំបានរៀនដោយខ្លួនឯងថា ព្រះគម្ពីរមរមន គឺពិត"។ អ្នកក៏អាចចែកចាយបទពិសោធន៍ខ្លីៗផងដែរ អំពីរបៀបដែលអ្នកបង្កើនចំណេះវិជ្ជា។ ចូរថ្លែងសក្ខីភាព ឱ្យបានច្រើនដងនៅក្នុងមេរៀនទីមួយៗ មិនមែនគ្រាន់តែនៅពេលបញ្ចប់មេរៀនទេ។ ថ្លែងសក្ខីភាពពីអ្វី ដែលដៃគូរបស់អ្នកបានបង្រៀន ថានោះគឺមកពីព្រះ។ ថ្លែងសក្ខីភាពថា គោលការណ៍ដែលអ្នកនឹងបង្រៀន នឹងប្រទានពរដល់ជីវិតរបស់សាសនាគន់ការ៍ បើពួកគេ នឹងធ្វើតាមគោលការណ៍នេះ។ ចូរនិយាយអំពីការរស់នៅតាមគោលការណ៍មួយ ដែលបានប្រទានពរដល់ជីវិតរបស់អ្នក។

មនុស្សពេលខ្លះអាចប្រើបញ្ហា ដើម្បីសួរសំនួរអំពីអ្វី ដែលអ្នកបង្រៀន ពីព្រោះវាពិបាកក្នុងការសួរសំនួរ ស្មោះត្រង់ចេញពីបេះដូង។ ពេលដែលអ្នកថ្លែងសក្ខីភាព ចូរអធិស្ឋានថា អ្នកទាំងឡាយណាដែលអ្នកកំពុងបង្រៀន នឹងទទួលអារម្មណ៍សាក្សីពិតប្រាកដនៃព្រះវិញ្ញាណបរិសុទ្ធ។ ពេលដែលអ្នកថ្លែងសក្ខីភាព គឺអ្នកជួយបង្កើតបរិយាកាសសំរាប់សាសនាគន់ការ៍ ដើម្បីទទួលអារម្មណ៍ព្រះវិញ្ញាណបរិសុទ្ធបញ្ជាក់សាក្សីរបស់អ្នកនៃសេចក្ដីពិត។ ការណ៍នេះរៀបចំពួកគេទទួលស្គាល់ការតាំងចិត្តដែលអ្នកនឹងពង្រីក។

ព្រិហ្គាំ យ៉ង់ មិនបានទទួលបុណ្យជ្រមុជទឹកនៅក្នុងសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធ ថ្ងៃចុងក្រោយទេ នៅក្នុង ឆ្នាំដំបូងនៃការរៀនរបស់លោកអំពីដំណឹងល្អ ដែលបានស្តារឡើងវិញ។ តែលោកមានប្រសាសន៍ ពីការផ្លាស់គំនិតរបស់លោកថា៖ "បើអ្នកមានទេពកោសល្យ អ្នកមានជំនាញ អ្នកមានប្រាជ្ញា និងអ្នកស្វែងយល់ពីពិភពលោកផ្ញើរ ព្រះគម្ពីរមរមន មកឱ្យខ្ញុំ ហើយប្រកាសក្នុងវោហារនៃលោកកិយដ៏ត្រអើតក្រទម ពីសេចក្ដីពិតនៃព្រះគម្ពីរមរមន ដើម្បីបំភ្លឺព្រះគម្ពីរមរមនដោយការរៀន និងប្រាជ្ញាលោកកិយ ប្រាប់ដល់ខ្ញុំ នោះពួកគេហាក់ដូចជាផ្សែងដែលគ្រាន់តែហុយ ហើយក៏បាត់ទៅតែប៉ុណ្ណោះ។ តែពេលដែលខ្ញុំ បានឃើញបុរសដែលគ្មានវោហារ ឬទេពកោសល្យនិយាយក្នុងសាធារណៈ ដែលជាអ្នកដែលគ្រាន់តែអាចនិយាយថា 'ខ្ញុំដឹងដោយព្រះចេស្ដា នៃព្រះវិញ្ញាណបរិសុទ្ធថា ព្រះគម្ពីរមរមន គឺពិត ហើយថា យ៉ូសែប ស៊្មីធ គឺជាព្យាការីនៃព្រះអម្ចាស់' ព្រះវិញ្ញាណបរិសុទ្ធ បានបំភ្លឺពីបុគ្គលម្នាក់នេះដល់ខ្ញុំ បំភ្លឺការយល់ដឹងរបស់ខ្ញុំ និងជាពន្លឺ និងអមតភាពនៅពីមុខខ្ញុំ។ ខ្ញុំត្រូវ បានព័ទ្ធដោយពន្លឺទាំងនោះ និងត្រូវបានបំពេញដោយពន្លឺទាំងនោះ ហើយខ្ញុំដឹងដោយខ្លួនខ្ញុំថា សក្ខីភាពរបស់បុរសម្នាក់នោះ គឺពិត" (ក្នុង *Journal of Discourses,* 1៖90)។

## សកម្មភាព៖ ការសិក្សាផ្ទាល់ខ្លួន

សារលិខិតខាងក្រោមគឺជា គំរូនៃការថ្លែងសក្ខីភាព។ ចូរអានសំនួរ និងព្រះគម្ពីរទីមួយៗ។ សរសេរចំលើយរបស់អ្នកទៅក្នុងសៀវភៅកំណត់ចំណាំសិក្សារបស់អ្នក។

- នៅក្នុងខទាំងនេះ តើសាវក និងព្យាការីថ្លែងអំពីអ្វី?
- តើពួកគេជឿខ្លាំងប៉ុណ្ណា ពីអ្វីដែលពួកគេកំពុងនិយាយ? តើអ្នកអាចប្រាប់ថា ពួកគេជឿជាក់សេចក្ដីពិត យ៉ាងដូចម្ដេច?
- ពេលដែលអ្នកនិយាយថា៖ "ខ្ញុំដឹងថា ________________ គឺពិត" តើអ្នកចង់មានន័យយ៉ាងដូចម្ដេច? តើពាក្យអ្វីផ្សេងទៀតដែលអ្នកអាចប្រើ ដើម្បីផ្ទេរការជឿជាក់របស់អ្នក?

| | | |
|---|---|---|
| យ៉ាកុប 7៖7–12 | គ និង ស 76៖22–24 | កិច្ចការពួកសាវក 2៖14–38 |
| អាលម៉ា 5៖45–48 | យ៉ូហាន 3៖3–11 | កិច្ចការពួកសាវក 10៖34–44 |
| អាលម៉ា 34៖1, 8 | | |

កំណត់ចំណាំ

## ការសិក្សាព្រះគម្ពីរ

**តើការថ្លែងសក្ខីភាព មានគោលការណ៍ និងការសន្យាអ្វីខ្លះ?**

នីហ្វៃទី 2 33:1 | គ និង ស 84:61 | យ៉ូហាន 15:26
គ និង ស 62:3 | គ និង ស 100:5–8

## ការតាមដាន

ការពង្រីកការតាំងចិត្តដោយគ្មានការតាមដាន គឺដូចជាការចាប់ផ្ដើមធ្វើដំណើរដោយគ្មានទីបញ្ចប់ ឬការទិញ សំបុត្រទៅមើលការប្រគុំតន្ត្រី ដោយមិនចូលទៅក្នុងរោងតន្ត្រី។ បើគ្មានការបំពេញ សកម្មភាពទេ ការតាំងចិត្តគឺដូចជាគ្មានអ្វីសោះ។

ការផ្លាស់ប្ដូរអាចជាការពិបាក។ តួនាទីរបស់អ្នក គឺដើម្បីជួយពង្រឹងពួកគេ ក្នុងការសំរេចចិត្ត ដើម្បីផ្លាស់ប្ដូរ។ អ្នកគួរធ្វើឱ្យអស់ពីសមត្ថភាពរបស់អ្នក ដើម្បីជួយមនុស្សរក្សាការតាំងចិត្តរបស់ពួកគេ។

ការបង្ហាញនៃការប្រែចិត្តពិតប្រាកដ ដ៏ប្រសើរបំផុត គឺបានបំភ្លឺតាមរយៈការធ្វើសកម្មភាពសុចរិត ជារៀងរហូត ជាពិសេសសំរាប់ព្រះបញ្ញត្តិ ដូចជា បរិសុទ្ធភាព ពាក្យគតិបណ្ឌិត និងដង្វាយមួយភាគដប់។ ពេលដែលអ្នក និងអ្នកដឹកនាំវួដ របស់អ្នក ធ្វើការជាមួយនឹងមនុស្ស ដើម្បីជួយពួកគេរក្សាការតាំងចិត្តរបស់ពួកគេ ចូរបង្ហាញការយល់ចិត្ត។ ចូរមានចិត្តអត់ធ្មត់ តែមិនមានះ។ អ្នកមិនបានបញ្ចប់ការបំរើរបស់អ្នកទេ លុះត្រាតែមនុស្សទាំងនោះរស់នៅតាមការតាំងចិត្តទាំងនេះ ឬម្យ៉ាងវិញទៀតថា លុះត្រាតែពួកគេបានប្រែចិត្ត (សូមមើល នីហ្វៃទី 3 18:32)។ ពេលខ្លះ ការទៅសួរសុខទុក្ខច្រើនដង ប្រហែលជាចាំបាច់សំរាប់អ្នក ដើម្បីជួយមនុស្សអភិវឌ្ឍន៍សេចក្ដីជំនឿខ្លាំងល្មមគ្រប់គ្រាន់ នៅក្នុងគោលការណ៍ ដើម្បីដឹកនាំទៅរកការប្រែចិត្ត។

ការតាមដានចាប់ផ្ដើម ពេលដែលអ្នកទៅសួរសុខទុក្ខ និងបង្រៀនមនុស្ស៖

- ចូរឱ្យពួកគេសរសេរការតាំងចិត្តរបស់ពួកគេ នៅលើអ្វីមួយដែលអ្នកទុកឱ្យគេ ដូចជា សៀវភៅតូច ឬកាតដែល មានឈ្មោះ និងលេខទូរសព្ទ័របស់អ្នក។
- ត្រូវប្រាកដថា មនុស្សដឹងថា អ្នកនឹងមកសួរសុខទុក្ខឆាប់ៗ ជាប្រចាំ រវាងការណាត់ជួបសំរាប់ការបង្រៀន។ ចូរពន្យល់ ថា គោលបំណងរបស់អ្នក គឺដើម្បីជួយពួកគេ។ ចូរផ្ដល់ឱ្យពួកគេនូវគំនិត នៃអ្វីដែលអ្នកនឹងធ្វើនៅអំឡុងពេលមកជួបនោះ។
- ធ្វើការកត់ចំណាំពិសេសមួយ នៅក្នុងកំណត់ចំណាំ/ធ្វើបញ្ជីដំពូក នៃផែនការរបស់អ្នក ដើម្បីតាមដាននៅថ្ងៃស្អែក ពីការអញ្ជើញឱ្យតាំងចិត្តនីមួយៗ ដែលអ្នកបានពង្រីកនៅថ្ងៃនេះ។

ធ្វើទំនាក់ទំនងឱ្យបានញឹកញាប់ ជារៀងរាល់ថ្ងៃ បើអាចធ្វើទៅបាន គឺដើម្បីស្វែងយល់បើពួកគេកំពុងតែរីកចំរើន នឹងការតាំងចិត្តរបស់ពួកគេ ចូរឆ្លើយសំនួរ ជួយពួកគេឱ្យយកឈ្នះលើបញ្ហា បង្រៀនមេរៀនបន្ថែម អានជាមួយគ្នាពីព្រះគម្ពីរមរមន ចែកចាយសារលិខិតនៃព្រះ គម្ពីរ ឬប្រើសម្ភារៈសោតទស្សន៍។ ពេលដែលអ្នកទៅសួរសុខទុក្ខមនុស្សញឹកញាប់ អ្នកនឹងពង្រឹងអារម្មណ៍ខាងវិញ្ញាណដែលពួក គេបានទទួលពេល ដែលអ្នកបង្រៀនពួកគេពីសារដំណឹងនៃការស្ដារឡើងវិញ នៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។ ការគាំទ្រឥទ្ធិពលនៃវិញ្ញាណនេះ គឺសំខាន់ណាស់។ វាប្រហែលជាមាន ពេលដែលអ្នកទូរស័ព្ទទៅសាសនាគន់ការី ដើម្បីរំលឹក និងលើកទឹកចិត្តពួកគេឱ្យរក្សាការតាំងចិត្ត។

ជួយសាសនាគន់ការីបញ្ជាក់ពីពរជ័យ ដែលពួកគេបានទទួល ពេលដែលពួកគេបានរក្សាការតាំងចិត្ត។ ជាពិសេស ជួយ ពួកគេពិពណ៌នាពីអារម្មណ៍ផ្ទាល់ខ្លួន ពេលដែលព្រះវិញ្ញាណបានធ្វើទីបន្ទាល់ ពីភាពពេញលេញនៃសារដំណឹង។

ចូរសរសើរ និងលើកទឹកចិត្តដល់មនុស្ស ដែលកំពុងទទួលជោគជ័យក្នុងការរក្សាការតាំងចិត្ត។ សាសនាគន់ការី គឺកំពុងផ្លាស់ប្ដូរជីវិតរបស់ពួកគេ។ ពួកគេមានអ្វីៗជាច្រើនដើម្បីរៀន និងធ្វើ។ ចូរសរសើរពួកគេដោយស្មោះត្រង់ឱ្យបានញឹកញាប់។ បង្ហាញអំណរគុណរបស់អ្នក សំរាប់ការរីកចំរើនរបស់ពួកគេ និងការជឿជាក់របស់អ្នកថា ពួកគេអាចទទួលជោគជ័យ។ លើកទឹកចិត្តពួកគេ ពេលណាដែលអ្នកនៅជាមួយពួកគេ។

បង្ហាញកង្វល់ និងការខកចិត្ត ពេលដែលមនុស្សបរាជ័យក្នុងការរក្សាការតាំងចិត្តរបស់ពួកគេ និងហេតុដូច្នេះ ពួកគេបរាជ័យក្នុងការទទួលបទពិសោធន៍ពរជ័យ។

## សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន និងការសិក្សាជាមួយដៃគូ

សរសេរនៅក្នុងផែនការប្រចាំថ្ងៃរបស់អ្នក នូវផែនការប្រចាំថ្ងៃដែលអ្នកទំនាក់ទំនងនឹង សាសនាគន់ការីម្នាក់ៗ។ រៀបចំ ផែនការត្រៀមទុកឱ្យបានច្រើនថ្ងៃ អំពីអ្វីដែលអ្នកនឹងធ្វើ ដើម្បីធ្វើការតាមដាន ជាមួយនឹងសាសនាគន់ការី។

---

ចូរជ្រើសរើសការអញ្ជើញឱ្យតាំងចិត្តមួយ ដែលអ្នកនឹងពង្រីកពេលដែលអ្នកបង្រៀនមេរៀន។ បន្ទាប់មក បញ្ជាក់ពីកង្វល់ខុសៗគ្នា ដែលអាចធ្វើឱ្យនរណាម្នាក់ជៀសវាងពីការទទួល ឬការរក្សាការតាំងចិត្តនោះ។ ពិភាក្សា និងអនុវត្ត របៀបដែលអ្នកអាចជួយមនុស្សយ៉ាងប្រសើរបំផុត ពេលដែលអ្នកធ្វើការដើម្បីដោះស្រាយកង្វល់របស់ពួកគេ។

## សូមចងចាំចំណុចនេះ

- យកចិត្តទុកដាក់លើការអញ្ជើញមនុស្សឱ្យធ្វើការតាំងចិត្ត នៅក្នុងរាល់ស្ថានភាពស្វែងរក ឬការបង្រៀន គឺទាំងជាមួយអ្នកទាំងឡាយណាដែលមិនមែនជាសមាជិក និងសមាជិកនៃសាសនាចក្រ។
- ពង្រីកការអញ្ជើញឱ្យតាំងចិត្ត ដើម្បីជួយដល់មនុស្សទទួលបទពិសោធន៍ផ្លាស់គំនិត។
- ពរជ័យសន្យា។
- ថ្លែងសក្ខីភាព។
- ធ្វើការតាមដាន ដើម្បីជួយដល់មនុស្សរក្សាការតាំងចិត្ត។

កំណត់ចំណាំ

កំណត់ចំណាំ

## គំនិតសំរាប់សិក្សា និងការអនុវត្ត

### ការសិក្សាផ្ទាល់ខ្លួន

- បញ្ជាក់ព្រះបញ្ញត្តិដែលបានសរសេរនៅក្នុងមេរៀនទី 4 ឬ ទី5 ក៏បាន។ ចូរគិតពីពរជ័យអ្នកបានទទួលមកពីការគោរពប្រតិបត្តិព្រះបញ្ញត្តិនេះ ហើយសរសេរពីពរជ័យនោះនៅក្នុងសៀវភៅទិន្នានុប្បវត្តិរបស់អ្នក។

- នៅក្នុងសំបុត្រ ចូរសួរសមាជិកគ្រួសារអ្នក ឱ្យប្រាប់ពីរបៀប ដែលពួកគេទទួលបានពរជ័យ ដោយការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិណាមួយ (ឧទាហរណ៍ ដង្វាយមួយភាគដប់)។

- ចូរសរសេរពីអារម្មណ៍របស់អ្នក អំពីការពង្រីកការតាំងចិត្ត។ តើអ្នកក្លាហាន ឬខ្មាស់អៀនទេ? តើអ្នកជឿជាក់ថា មនុស្សនឹងទទួលពរជ័យ ឬអ្នកមានការសង្ស័យទេ? តើអ្នក រឹងមាំ អត់ធ្មត់ និងរហ័សរហួនដែរឬទេ ពេលដែលអ្នកធ្វើទំនាក់ទំនងប្រចាំថ្ងៃ? តើពួកគេដឹងថា អ្នកស្រលាញ់ពួកគេ ដែរឬទេ? តើអ្នកអាចកែលំអភាពទន់ខ្សោយរបស់អ្នកបានដែរទេ ពេលអ្នកបញ្ជាក់នៅក្នុងការអញ្ជើញរបស់អ្នក?

- រំលឹកផែនការមេរៀនរបស់អ្នកសំរាប់មេរៀនទីមួយៗ។ តើអ្នកបានបញ្ចូលការតាំងចិត្តជាក់លាក់ណាមួយឬទេ? តើអ្នករៀបចំផែនការមេរៀនច្បាស់លាស់ដែរឬទេ អំពីការធ្វើការតាំងចិត្ត?

### ការសិក្សាជាមួយដៃគូ

- ចេញពីផែនការប្រចាំថ្ងៃរបស់អ្នក ចូរធ្វើបញ្ជីនៃមនុស្សដែលអ្នកបានទាក់ទង នាពេលពីរថ្ងៃខាងមុខ ដោយបូករួមទាំងសាសនាគន់ការី និងសមាជិក។ សំរាប់មនុស្សម្នាក់ៗ ចូរសរសេរការតាំងចិត្ត (ច្រើន) ដែលពួកគេបានធ្វើ ព្រមទាំងការអញ្ជើញផ្សេងៗទៀត ដែលអ្នកអាច ឬគួរតែបានពង្រីកផងដែរ។ ពិភាក្សាពីមូលហេតុ ដែលអ្នកទទួលបានការតាំងចិត្តពីមនុស្សខ្លះៗនៃមនុស្សទាំងនេះ ហើយតើអ្វីដែលរារាំងអ្នក មិនអាចទទួលការតាំងចិត្ត។ តើអ្នកនឹងធ្វើអ្វី ដើម្បីតាមដាន លើការតាំងចិត្តទាំងនេះ?

- ចូរមើលនៅក្នុងផែនការប្រចាំថ្ងៃ និងសរសេរឈ្មោះសាសនាគន់ការីណា ដែលអ្នកនឹងបង្រៀននៅថ្ងៃក្រោយ ឬពីរថ្ងៃទៀត។ ចូរពិចារណា ព្រះបញ្ញត្តិណាមួយ ដែលបានសរសេរនៅក្នុងមេរៀនទី 4 ឬទី 5 ដែលអ្នកនឹងអញ្ជើញពួក គេឱ្យរស់នៅតាម។ ចូរពិភាក្សារបៀបដែលអ្នកនឹងពង្រីកការតាំងចិត្ត និងពរជ័យជាក់លាក់ណាមួយដែលអ្នកនឹងសន្យា សំរាប់ការគោរពប្រតិបត្តិ។

- ចូរពិចារណាការបង្ហាញបញ្ជីបង្រៀន ទៅសាសនាគន់ការី ដើម្បីឱ្យពួកគេដឹងថា អ្វីដែលនឹងត្រូវបានសង្ឃឹមទុកជាមុន។ បើសមរម្យ ចែកបញ្ជីបង្រៀនជាមួយពួកគេមួយច្បាប់។

- រំលឹកកំណត់ចំណាំ/ការធ្វើបញ្ជីនៅក្នុងផែនការ សំរាប់រយៈពេលបីថ្ងៃកន្លងទៅ ដើម្បីដឹងថា បើអ្នកបាន សរសេរកិច្ចការរបស់អ្នក សំរាប់ធ្វើការតាមដាន រាល់ការអញ្ជើញដែលអ្នកបានពង្រីកឬទេ។

### ការប្រជុំមណ្ឌល និងសន្និសីទហ្សូន

- ពិភាក្សាពីប្រសិទ្ធិភាព និងការបង្កើតគំនិត សំរាប់ការទាក់ទង ប្រចាំថ្ងៃជាមួយសាសនាគន់ការី។ តើអ្នកផ្សព្វផ្សាយ សាសនាធ្វើការជាមួយសមាជិក ដោយមានប្រសិទ្ធិភាពយ៉ាងដូចម្ដេច? តើឯកសារ ឬសោតទស្សន៍អ្វីដែលមានប្រយោជន៍? តើអ្នកអាចធ្វើអ្វីពេលដែលមនុស្សមិននៅផ្ទះ ឬរវល់ពេកក្នុងការជួបអ្នក?

- ពិភាក្សាពីវិធីដែលអ្នកផ្សព្វផ្សាយសាសនាបង្រៀនដោយមានប្រសិទ្ធិភាពពីព្រះបញ្ញត្តិនៅក្នុងមេរៀនទី 4 និងទី 5។

- ពិភាក្សាកង្វល់ជាក់លាក់ណាមួយ នៃសាសនាគន់ការីថ្មីៗ។ តើកង្វល់ទាំងនេះមានលក្ខណៈដូចម្ដេច? តើអ្នកផ្សព្វផ្សាយសាសនាអាចធ្វើអ្វី ដើម្បីដោះស្រាយកង្វល់នោះ?

### ប្រធានបេសកកម្ម

- តាមពេលដែលអាចធ្វើទៅបាន ចូលរួមជាមួយអ្នកផ្សព្វផ្សាយសាសនា ពេលដែលពួកគេបង្រៀន។ ជួយពួកគេយកចិត្តទុកដាក់ទៅលើការជួយមនុស្សធ្វើ និងរក្សាការតាំងចិត្ត។

- លើកទឹកចិត្តអ្នកកាន់បព្វជិតភាព និងសមាជិកឱ្យចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើការទាក់ទង ប្រចាំថ្ងៃជាមួយ សាសនាគន់ការី។

- ចូរធ្វើជាគំរូនៃការពង្រីកការអញ្ជើញ នៅក្នុងការខិតខំប្រឹងប្រែងរបស់ផ្សព្វផ្សាយសាសនា និងអ្នកផ្សព្វផ្សាយសាសនា ដែលអ្នកបំរើ។



# តើខ្ញុំត្រូវរៀបចំមនុស្ស សំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ដោយរបៀបណា?

កំណត់ចំណាំ

**ចូរពិចារណាចំណុចនេះ**

- តើខ្ញុំត្រូវការធ្វើអ្វីដើម្បី ជួយរៀបចំមនុស្សសំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់?
- តើខ្ញុំត្រូវដឹកនាំការសម្ភាសន៍ធ្វើពិធីបុណ្យជ្រមុជទឹកដោយមានប្រសិទ្ធិភាព បានយ៉ាងដូចម្ដេច?
- តើពិធីបុណ្យជ្រមុជទឹកដែលប្រកបដោយព្រះវិញ្ញាណ ត្រូវបានរៀបផែនការក្នុងការនាំបានយ៉ាងដូចម្ដេច?
- តើខ្ញុំត្រូវធ្វើការយ៉ាងជិតស្និទជាមួយនឹងប៊ីស្សបដោយរបៀបណា ដើម្បីបញ្ជាក់ថា អ្នកផ្លាស់សាសនាពិតជាត្រូវបានធ្វើពិធីបញ្ជាក់?
- ហេតុអ្វី ជាការងារសំខាន់ដើម្បីបំពេញបញ្ជីពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់?

## រៀបចំមនុស្សសំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់

គោលបំណងនៃការបង្រៀនរបស់អ្នក គឺដើម្បីជួយអ្នកដទៃឱ្យអភិវឌ្ឍន៍សេចក្ដីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ និងប្រែចិត្តពីអំពើបាបទាំងឡាយរបស់ពួកគេ។ ដូចដែលមរមនបានបង្រៀនថាៈ "ផលដំបូងនៃការប្រែចិត្ត គឺបុណ្យជ្រមុជទឹក" (ម៉ូរ៉ូណៃ 8ៈ25)។ ពិធីសម្ភាសន៍ សំរាប់ពិធីបុណ្យជ្រមុជទឹក គឺជាវិធីដែលត្រូវបានសាងឡើងដោយសាសនាចក្រ ដើម្បីបញ្ជាក់ថា បុគ្គលម្នាក់ៗ ស្ថិតលើបទដ្ឋានរបស់ ព្រះអម្ចាស់ សំរាប់បុណ្យជ្រមុជទឹក និងគឺត្រូវបានរៀបចំ ដើម្បីទទួលអំណោយទាន នៃព្រះវិញ្ញាណបរិសុទ្ធ។ តាមរយៈការសម្ភាសន៍ បុគ្គលដែលទទួលបុណ្យជ្រមុជទឹក បំពេញតំរូវការខាងបទគម្ពីរ ដែលពួកគេធ្វើជាសាក្សីពីមុខ អ្នកមានសិទ្ធិអំណាចតំណាងសាសនាចក្រ ថា ពួកគេ "ប្រាកដជាបានប្រែចិត្ត ចំពោះអំពើបាបរបស់ពួកគេទាំងអស់" (គ និង ស 20ៈ37)។ ការតាំងចិត្តទាំងឡាយដែលសាសនាគន់ការីធ្វើ គឺរៀបចំពួកគេ ដើម្បីធ្វើ និងរក្សាសេចក្ដីសញ្ញានៃបុណ្យជ្រមុជទឹក។ មនុស្សដែលបានរក្សាការតាំងចិត្តដែលអ្នកបានអញ្ជើញ ពួកគេឱ្យធ្វើ ជាមនុស្សដែលបានរៀបចំបានយ៉ាងល្អ សំរាប់ការសម្ភាសន៍ និងសំរាប់សមាជិកភាព និងសកម្មភាព នៅក្នុងសាសនាចក្រ។

ពេលដែលអ្នកបង្រៀនសាសនាគន់ការី និងរៀបចំពួកគ សំរាប់បុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ សូមប្រាកដថា ពួកគេមានភាពសក្ដិសមសំរាប់ពិធីបុណ្យជ្រមុជទឹក។

© 1988 Greg K. Olsen. រៀបចំ Mill Pond Press and Dr. Gerry Hooper។ ហាមថតចំលង។

កំណត់ចំណាំ

## គុណសម្បត្តិសំរាប់ពិធីបុណ្យជ្រមុជទឹក

**គោលលទ្ធិនិងសេចក្ដីសញ្ញា 20:37**

- បន្ទាបខ្លួននៅចំពោះមុខព្រះ។
- មានបំណងចង់ទទួលបុណ្យជ្រមុជទឹក។
- មកដោយមានចិត្តសង្រេង និងវិញ្ញាណទន់ទាប។
- ប្រែចិត្តចំពោះអំពើបាបរបស់ពួកគេទាំងអស់។
- យល់ព្រមលើកដាក់មកលើខ្លួន នូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ។
- ប្ដេជ្ញាចិត្តថា នឹងបំរើព្រះគ្រីស្ទដល់ទីបំផុត។
- សំដែងដោយកិច្ចការទាំងឡាយរបស់ពួកគេថា ពួកគេបានទទួលព្រះវិញ្ញាណនៃព្រះគ្រីស្ទ ចំពោះការផ្ដាច់បាបទាំងឡាយរបស់ពួកគេ។

**គណៈប្រធានទីមួយ និងក្រុមនៃសាវកដប់ពីរនាក់៖**

- ធ្វើការផ្លាស់ប្ដូរពិតប្រាកដនៅក្នុងជីវិតរបស់ពួកគេ ដើម្បីមានភាពសក្ដិសមដូចត្រូវបានបញ្ជាក់នៅក្នុង គោលលទ្ធិនិងសេចក្ដីសញ្ញា 20:37។
- អភិវឌ្ឍន៍សេចក្ដីជំនឿនៅក្នុងព្រះគ្រីស្ទ។
- ប្រែចិត្តពីការរំលងរបស់ពួកគេ។
- រស់នៅតាមគោលការណ៍ នៃសីលធម៌នៃភាពសក្ដិសម។
- រស់នៅតាមពាក្យតិបណ្ឌិត។
- ការតាំងចិត្តដើម្បីបង់ដង្វាយមួយភាគដប់។
- ទទួលមេរៀនទាំងអស់របស់អ្នកផ្សព្វផ្សាយសាសនា [មេរៀនទី 1–4 នៅលើបញ្ជីបង្រៀន និងការតាំងចិត្តដែលមានទំនាក់ទំនង]។
- ជួបជាមួយប៊ីស្សប ឬប្រធានសាខា។
- ចូលរួមការបំរើពិធីប្រសិទ្ធពរនំប៉័ងនិងទឹកជាច្រើនដង។

(“Statement on Missionary Work,” សំបុត្ររបស់គណៈប្រធានទីមួយ ថ្ងៃទី 11 ខែធ្នូ ឆ្នាំ 2002)។

ពេលដែលសាសនាគន់ការីរើសកាលបរិច្ឆេទត្រឹមត្រូវ សំរាប់ពិធីបុណ្យជ្រមុជទឹកហើយ ចូរណាត់ ពេលដែលអ្នកនឹងបំពេញកិច្ចការសព្វគ្រប់អស់ដែលដឹកនាំទៅកាន់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ដូចដែលបានសរសេរនៅក្នុងផែនការប្រចាំថ្ងៃរបស់អ្នក។ ចូររំលឹកឡើងវិញនូវបញ្ជីបង្រៀនដោយយកចិត្តទុកដាក់ ដើម្បីបញ្ជាក់ថា អ្នកបានបង្រៀនគោលលទ្ធិគ្រឹះ ហើយថា បុគ្គលនោះ ត្រូវបានរៀបចំដើម្បីឆ្លើយតបចំពោះសំនួរនីមួយៗ នៅក្នុងការសម្ភាសន៍ធ្វើបុណ្យជ្រមុជទឹក។ ចូររំលឹកឡើងវិញកាលវិភាគនេះ ជាមួយនឹងសាសនាគន់ការីក្នុងការជួបពេលក្រោយ។ បើអាចធ្វើបាន សាសនាគន់ការីគួរតែចូលរួមក្នុងពិធីបុណ្យជ្រមុជទឹក ពីមុន ពិធីបុណ្យជ្រមុជទឹករបស់ពួកគេផ្ទាល់។

បើអ្នកទទួលអារម្មណ៍ថា មនុស្សដែលអ្នកកំពុងបង្រៀនត្រូវការការរៀបចំខ្លួនបន្ថែមទៀត ចូរកុំធ្វើការណាត់ជួបសម្ភាសន៍ រហូតដល់សាសនាគន់ការីស្ថិតលើបទដ្ឋានសិន។ បើបុគ្គល មានអាយុតិច ចូរប្រាកដថា ឪពុកម្ដាយ ឬអ្នកថែរក្សាបានផ្ដល់ឱ្យនូវការអនុញ្ញាតដោយមានជាលាយលក្ខណ៍អក្សរ សំរាប់ពួកគេ ដើម្បីទទួលបុណ្យជ្រមុជទឹក។

ពេលដែលអ្នកជួយមនុស្សរៀបចំ សំរាប់ការសម្ភាសន៍ ធ្វើពិធីបុណ្យជ្រមុជទឹក ចូរនិយាយជាមួយពួកគេអំពីគោលបំណងនៃការ សម្ភាសន៍ ។ ចូរបង្រៀនពួកគេ និងថ្លែងសក្ខីភាពពីភាពពិសិដ្ឋនៃពិធីបុណ្យជ្រមុជទឹក និងការទទួលអំណោយទាននៃ ព្រះវិញ្ញាណបរិសុទ្ធ។ ចូរពន្យល់ថា អ្នកចង់បញ្ជាក់បើ ពួកគេយល់ពីគោលការណ៍ទាំងឡាយ ដែលអ្នកបានបង្រៀន និងសេចក្ដីសញ្ញាដែល ពួកគេនឹងធ្វើ។ ចូរពន្យល់ផងដែរថា ការសម្ភាសន៍គឺជា ឱកាសសំរាប់ពួកគេដើម្បីធ្វើជាសាក្សីចំពោះអ្នកដំណាងរបស់ព្រះអម្ចាស់ថា ពួកគេបានត្រៀម សំរាប់ទទួលពិធីការពិសិដ្ឋទាំងនេះ។ ពេលដែលពួកគេរក្សាសេចក្ដីសញ្ញា ដែលបានធ្វើនៅពេលធ្វើពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ នោះពួកគេនឹងទទួលការផ្ដាច់បាប។ ចូរចែកចាយសំនួរដែលអ្នក សម្ភាសន៍នឹងសួរអំពីជំនឿរបស់គេ នៅក្នុងគោលលទ្ធិសំខាន់ៗ ការប្រែចិត្តពីអំពើបាបរបស់គេពីអតីតកាល និងឆន្ទះរបស់ពួកគេចំពោះសេចក្ដីសញ្ញា ដើម្បីគោរពប្រតិបត្តិតាមព្រះយេស៊ូវគ្រីស្ទ នៅពេញមួយជីវិតរបស់ពួកគេ។ ចូរបញ្ជាក់ថា ពិធីបុណ្យជ្រមុជទឹកដោយទឹក គឺមិនពេញលេញ ទេបើគ្មានពិធីបញ្ជាក់ និងអំណោយទាននៃ ព្រះវិញ្ញាណបរិសុទ្ធ។

កំណត់ចំណាំ

## សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន និងការសិក្សាជាមួយដៃគូ

- ចូរអានខ្ទរវាល់សារលិខិតនីមួយៗ ដូចខាងក្រោម និងចូរធ្វើបញ្ជីសង្ខេបអំពីតំរូវការព្រះគម្ពីរសំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។

| | | |
|---|---|---|
| នីហ្វៃទី 2 9:23, 31:4–13 | នីហ្វៃទី 3 27:13–21 | គ និង ស 20:37 |
| ម៉ូសាយ 18:8–10 | មរ៉ូណៃ 6:1–4 | គ និង ស 22 |
| អាលម៉ា 7:14–15 | មរ៉ូណៃ 8:25–26 | កិច្ចការពួកសាវក 2:37-39 |

- នៅក្នុងការសម្ភាសន៍ធ្វើពិធីបុណ្យជ្រមុជទឹក បុគ្គលត្រូវបានសួរថាតើ ពួកគេនឹងព្រមលើកដាក់លើខ្លួនគេ នូវព្រះនាម នៃព្រះគ្រីស្ទ។ តើអ្នកអាចធ្វើអ្វីដើម្បីជួយពួកគេយល់សំនួរនេះ? ពេលដែលអ្នកពិចារណាពីសំនួរនេះ ចូរសិក្សាព្រះគម្ពីរដូចខាងក្រោមៈ

| | | |
|---|---|---|
| ម៉ូសាយ 4–5 | ម៉ូសាយ 26:18, 21–27 | នីហ្វៃទី 3 27:1–10 |
| ម៉ូសាយ 18:1–11 | | |

អ្នកអាចរកមើលសារលិខិតផ្សេងៗទៀត ដែលជួយអ្នកឱ្យយល់ពីគោលការណ៍នេះផងដែរ។

## របៀបដើម្បីដឹកនាំការសម្ភាសន៍

អ្នកដែលត្រូវដឹកនាំការសម្ភាសន៍គួរតែប្រើ សំនួរសម្ភាសន៍សំរាប់ពិធីបុណ្យជ្រមុជទឹក ជាមួយនឹងការដឹកនាំនៃព្រះវិញ្ញាណ ដើម្បីកំណត់ថាតើបុគ្គលដែលនឹងទទួលបុណ្យជ្រមុជទឹក មានខ្ទរគុណសម្បត្តិដែលបានពិពណ៌នានៅក្នុងគោលលទ្ធិ និងសេចក្តីសញ្ញា 20:37 ឬទេ។ គាត់ក៏គួរតែធ្វើឱ្យសំនួរមានលក្ខណៈប្រែប្រួលស្របតាមអាយុ និងភាពចាស់ទុំនៃបុគ្គលដែរ។

បើបុគ្គលមិនមានលក្ខណៈគ្រប់គ្រាន់ស្របតាមសំនួរសម្ភាសន៍សំរាប់ពិធីបុណ្យជ្រមុជទឹកទេ នោះពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់គួរតែផ្អាក។ សាសនាគន់ការីគួរតែទទួលការបង្រៀនបន្ថែម ដោយអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង និងមានការរាក់ទាក់ពីសមាជិកនៅក្នុងវួដ។

អ្នកដឹកនាំមណ្ឌល ឬអ្នកដឹកនាំហ្សូន ដែលជាអ្នកដែលដឹកនាំការសម្ភាសន៍គួរតែៈ

- ធ្វើការសម្ភាសន៍នៅកន្លែងដែលផាសុខភាព កន្លែងឯកជន ដែលនាំឱ្យទទួលអារម្មណ៍នៃព្រះអម្ចាស់។ ដៃគូរបស់អ្នកសម្ភាសន៍គួរតែនៅជិតនោះ។
- បើកការសម្ភាសន៍ជាមួយនឹងការអធិស្ឋាន។
- ជួយបុគ្គលឱ្យទទួលអារម្មណ៍ផាសុកភាព។
- ធ្វើឱ្យការសម្ភាសន៍មានខ្ទរបទពិសោធន៍ខាងវិញ្ញាណ និងភាពលើកដំកើង។
- ចូរបញ្ជាក់ថា បុគ្គលយល់ពីគោលបំណងនៃការសម្ភាសន៍។
- សួរសំនួរសម្ភាសន៍សំរាប់ពិធីបុណ្យជ្រមុជទឹក។ ចូរប្រើសំនួរតាមដាន ដើម្បីទទួលបាននូវអារម្មណ៍ ដើម្បីជាកំលាំងសំរាប់ សក្តិភាព និងការប្រែចិត្តដោយស្មោះសររបស់បុគ្គល។
- ចូរឆ្លើយចំពោះសំនួររបស់បុគ្គល។
- ចូរអញ្ជើញបុគ្គលឱ្យថ្លែង និងបង្ហាញអារម្មណ៍របស់ពួកគេ។
- បើបុគ្គលមានបញ្ហាជាមួយនឹងសក្តិភាព ឬភាពសក្តិសម ចូរពន្យល់ថា វាប្រសើរណាស់ដើម្បីផ្អាកពិធីបុណ្យជ្រមុជទឹក រហូតដល់ពួកគេបានរៀបចំប្រសើរជាង។

## សំនួរសម្ភាសន៍សំរាប់ពិធីបុណ្យជ្រមុជទឹក_

1. តើអ្នកជឿថា ព្រះគឺជាព្រះវរបិតាដ៏អស់កល្បរបស់យើង ដែរឬទេ? តើអ្នកជឿថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រា នៃព្រះ ជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះនៃពិភពលោក ដែរឬទេ?_
2. តើអ្នកជឿថា សាសនាចក្រ និងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ត្រូវបានស្តារឡើងវិញ តាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ដែរឬទេ? តើអ្នកជឿថា [ប្រធានសាសនាចក្របច្ចុប្បន្ន] គឺជាព្យាការីនៃព្រះ ដែរឬទេ? តើការណ៍នេះមានអត្ថន័យយ៉ាងណា ចំពោះអ្នក?
3. តើការប្រែចិត្តមានអត្ថន័យយ៉ាងណាចំពោះអ្នក? តើអ្នកមានអារម្មណ៍ថា អ្នកបានប្រែចិត្តពីការរំលងពីអតីតកាល ហើយឬទេ?

កំណត់ចំណាំ

4. តើអ្នកធ្លាប់ប្រព្រឹត្តបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែរឬទេ? បើមាន តើឥឡូវនេះអ្នកស្ថិតនៅក្នុងការព្យួរទោសដោយមានលក្ខខ័ណ្ឌ ឬការដោះលែងឱ្យរួចពីទោស ដែរឬទេ? តើអ្នកធ្លាប់ពន្លូតកូនដែរឬទេ? ការរួមភេទដូចគ្នា ដែរឬទេ?
5. អ្នកបានត្រូវបង្រៀនថា សមាជិកភាពនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ប្តូររួមទាំង ការរស់នៅតាមបទដ្ឋានដំណឹងល្អ។ តើអ្នកយល់អ្វីខ្លះនូវបទដ្ឋានដូចខាងក្រោម? តើអ្នកព្រមគោរពប្រតិបត្តិតាមបទដ្ឋានទាំង នេះដែរឬទេ?
   ក. ច្បាប់នៃបរិសុទ្ធភាព ដែលច្បាប់នេះហាមឃាត់មិនឱ្យមានទំនាក់ទំនងផ្លូវភេទក្រៅអាពាហ៍ពិពាហ៍ស្របច្បាប់ រវាងបុរស និងស្ត្រី។
   ខ. ច្បាប់នៃដង្វាយមួយភាគដប់។
   គ. ពាក្យគតិបណ្ឌិត។
   ឃ. ថ្ងៃសីល ដោយប្តូររួមទាំងការទទួលទាននៃពិធីប្រសិទ្ធពរនំប៉័ងនិងទឹក ជារៀងរាល់សប្តាហ៍ និងផ្តល់នូវការបំរើ ចំពោះសមាជិកទាំងប្រុសទាំងស្រី។
6. ពេលដែលអ្នកបានទទួលបុណ្យជ្រមុជទឹក អ្នកបានចុះសេចក្តីសញ្ញាជាមួយព្រះថា អ្នកព្រមលើកដាក់នៅលើខ្លួនរបស់អ្នក នូវព្រះនាមនៃព្រះគ្រីស្ទ និងរក្សាព្រះបញ្ញត្តិរបស់ទ្រង់នៅក្នុងមួយឆាកជីវិតរបស់អ្នក។ តើអ្នករៀបចំហើយឬនៅ ដើម្បីរក្សាសេចក្តីសញ្ញានេះ និងព្យាយាមដើម្បីស្មោះស្ម័គ្រចំពោះសេចក្តីសញ្ញានេះ ឬទេ?

នៅទីបញ្ចប់នៃការសម្ភាសន៍ដែលទទួលបានជោគជ័យ ចូរអបអរសាទរដល់បុគ្គលនោះ។ ឆ្លើយតបចំពោះអ្នកផ្សព្វផ្សាយសាសនាដទៃទៀត និងពន្យល់ពីអ្វីដែលនឹងកើតឡើង នៅពិធីបុណ្យជ្រមុជទឹក។

ចូរពន្យល់ថា ការធ្វើពិធីបញ្ជាក់នឹងធ្វើឡើងនៅក្រោមការដឹកនាំរបស់ប៊ីស្សប នៅក្នុងការប្រជុំសាក្រាម៉ង់នៃវួដ ដែលពួកគេនៅ។

ពេលដែលចាំបាច់ដើម្បីផ្អាកពិធីបុណ្យជ្រមុជទឹក អ្នកដឹកនាំមណ្ឌល ឬអ្នកដឹកនាំហ្សូន និងអ្នកផ្សព្វផ្សាយសាសនាដទៃទៀត គួរតែគ្រប់គ្រងស្ថានការដោយយកចិត្តទុកដាក់ និងផ្ទាល់ខ្លួន។ បញ្ជាក់ចំពោះបុគ្គលថា ពួកគេអាចទទួលបានជោគជ័យ និងពន្យល់ ពីការរំលងខ្លះៗដែលតំរូវឱ្យចំណាយពេលទៀតតាមរយៈការប្រែចិត្ត។ ចូរពន្យល់ថា ធម្មជាតិពិសិដ្ឋនៃពិធីការ តំរូវឱ្យមានបទដ្ឋានខ្ពស់ នៃភាពសក្តិសម។ បញ្ជាក់ចំពោះបុគ្គលថា អ្នក និងអ្នកដទៃទៀតនឹងធ្វើឱ្យអស់ពីសមត្ថភាពដើម្បីជួយគាំទ្រដល់ពួកគេ។ បន្ទាប់មកត្រូវធ្វើតាមដោយស្មោះត្រង់ដើម្បីរក្សាការសន្យារបស់អ្នក។

## ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់៖ សំនួរ និងចំលើយ

### តើនរណាដឹកនាំការសម្ភាសន៍សំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់?

ជាធម្មតា អ្នកដឹកនាំមណ្ឌលជាអ្នកសម្ភាសន៍បុគ្គលដែលទទួលបុណ្យជ្រមុជទឹក ដែលត្រូវបានបង្រៀនដោយអ្នកផ្សព្វផ្សាយសាសនា នៅក្នុងមណ្ឌលរបស់គាត់ ដោយប្តូររួមទាំងបុគ្គលដែលត្រូវបានបង្រៀនដោយអ្នកដឹកនាំហ្សូនរបស់គាត់ផងដែរ។ អ្នកដឹកនាំហ្សូនធ្វើការសម្ភាសន៍បុគ្គលដែលត្រូវបានបង្រៀនដោយអ្នកដឹកនាំមណ្ឌល។ ប្រធានបេសកកម្ម ឬនរណាម្នាក់ដែលគាត់ ចាត់តាំង ត្រូវតែសម្ភាស មនុស្សដែលមានទំនាក់ទំនងនឹងអំពើបាបធ្ងន់ធ្ងរ។ អ្នកដឹកនាំមណ្ឌល ឬអ្នកដឹកនាំហ្សូន មិនសម្ភាសន៍ បុគ្គលដែលទទួលបុណ្យ ជ្រមុជទឹកនៅក្រោមមណ្ឌល ឬហ្សូនរបស់ពួកគេទេ លើកលែងតែប្រធានបេសកកម្មចាត់តាំងឱ្យពួកគេ ធ្វើដូច្នោះ។

### តើអត្ថន័យនៃពាក្យពិធីបុណ្យជ្រមុជទឹកអ្នកផ្លាស់សាសនា គឺជាអ្វី?

ពិធីបុណ្យជ្រមុជទឹកអ្នកផ្លាស់សាសនា គឺជាពិធីបុណ្យជ្រមុជទឹករបស់៖

- មនុស្សដែលមានអាយុប្រាំបួនឆ្នាំ ឬចាស់ជាង ដែលពុំដែលបានទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ជាសមាជិកនៃ សាសនាចក្រពីមុនមក។
- កុមារដែលមានអាយុប្រាំបីឆ្នាំ ដែលឪពុកម្តាយទាំងពីរមិនមែនជាសមាជិក ឬមានឪពុកម្តាយដែលទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ នៅពេលដូចគ្នាជាមួយនឹងកូន។

### តើខ្ញុំត្រូវការការអនុញ្ញាតដើម្បីធ្វើបុណ្យជ្រមុជទឹកដល់ក្មេងដែលមានអាយុតិច ឬទេ?

ពីមុនពេល ដែលអ្នកអាចបង្រៀន និងធ្វើបុណ្យជ្រមុជទឹកដល់សាសនាគន់ការី ដែលមានអាយុក្រោមអាយុពេញសិទ្ធិ អ្នកត្រូវតែទទួលការអនុញ្ញាតពីឪពុកម្តាយ ឬអាណាព្យាបាល ដែលមានជាលាយលក្ខណ៍អក្សរ។ ជាជំនួយបន្ថែម អ្នកគួរមានមូលហេតុត្រឹម ត្រូវដើម្បីជឿថា ក្មេងយល់ពីសេចក្តីសញ្ញាពិធីបុណ្យជ្រមុជទឹក និងធ្វើការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា ដើម្បីរក្សាសេចក្តីសញ្ញានោះ តាមរយៈការគោរពប្រតិបត្តិចំពោះដំណឹងល្អ ដោយប្តូររួមទាំងការចូលរួមប្រជុំនៅក្នុងសាសនាចក្រដោយស្មោះត្រង់។

### តើខ្ញុំត្រូវការការអនុញ្ញាតពីប្តីប្រពន្ធ ដើម្បីធ្វើបុណ្យជ្រមុជទឹកឱ្យប្តី ឬប្រពន្ធដែរឬទេ?

អ្នកត្រូវការការអនុញ្ញាត។ ចូរកុំធ្វើពិធីបុណ្យជ្រមុជទឹកឱ្យមនុស្សដែលរៀបការ ដោយគ្មានការយល់ព្រមពីប្តីប្រពន្ធរបស់ពួកគេឡើយ។

កំណត់ចំណាំ

**បើឪពុកនៅក្នុងគ្រួសារ មិនទាន់ត្រៀមខ្លួនរួចស្រេចបាច់សំរាប់ពិធីបុណ្យជ្រមុជទឹក តើខ្ញុំគួរតែធ្វើបុណ្យជ្រមុជទឹកឱ្យក្រុមគ្រួសារ ឬខ្ញុំគួរតែ រង់ចាំរហូតដល់ឪពុក?**

បើឪពុកនៃក្រុមគ្រួសារ មិនទាន់បានត្រៀមខ្លួនរួចរាល់សំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ តែសមាជិកគ្រួសារដទៃទៀតបានត្រៀមខ្លួនរួចរាល់ ហើយ អ្នកអាចប្រាប់ ឪពុកថា អ្នកមិនចង់ធ្វើបុណ្យជ្រមុជទឹកគ្រួសារដោយគ្មានគាត់ទេ ព្រោះសាសនាចក្រ គោរពដល់មេគ្រួសារ នឹងពីព្រោះ សមាជិក គ្រួសារនឹងរីកចំរើនដ៏ប្រសើរនៅក្នុងដំណឹងល្អជាក្រុមគ្រួសារ។ បើឪពុកបន្ទូបដិសេធ នោះអ្នកអាចធ្វើបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់ឱ្យសមាជិកគ្រួសារដទៃទៀតជាមួយនឹងការអនុញ្ញាតរបស់គាត់។

**តើវាជាគំនិតល្អទេ ក្នុងការតែងតាំងឪពុកឱ្យមានបព្វជិតភាពអើរ៉ុនភ្លាមៗ បន្ទាប់ពីពិធីបុណ្យជ្រមុជទឹក ដើម្បីឱ្យគាត់អាចធ្វើបុណ្យ ជ្រមុជទឹកឱ្យសមាជិកដទៃទៀតនៅក្នុងគ្រួសារ?**

មិនបានទេ។ ឪពុកត្រូវតែបានទទួលការបញ្ជាក់នៅក្នុងការប្រជុំការប្រសិទ្ធពរនំប៉័ង និងទឹក និងបន្ទាប់ពីការសម្ភាសន៍ជាមួយប៊ីស្សប ត្រូវទទួលការ គាំទ្រដើម្បីទទួលបព្វជិតភាពអើរ៉ុន។ ពិធីបុណ្យជ្រមុជទឹកនៃសមាជិកក្រុមគ្រួសារ មិនគួរពន្យាពេលដើម្បីឱ្យ ឪពុកអាចធ្វើពិធីបុណ្យជ្រមុជទឹក ដោយខ្លួនគាត់នោះទេ។

តើខ្ញុំអាចបង្រៀន និងជ្រមុជទឹកមនុស្សដែលត្រូវបានផ្ដាច់ចេញពីសាសនាដែរឬទេ?

ពិធីបុណ្យជ្រមុជទឹកនៃអ្នកត្រូវបានផ្ដាច់ចេញពីសាសនា គឺមិនមែនជាពិធីបុណ្យជ្រមុជទឹកអ្នកផ្លាស់សាសនាទេ ហើយអ្នក ផ្សព្វផ្សាយសាសនាមិនធ្វើ ការសម្ភាសន៍មនុស្សនោះសំរាប់ពិធីបុណ្យជ្រមុជទឹកទេ។ អ្នកអាចធ្វើការជាមួយមនុស្សនោះ មានតែ នៅក្រោមការគ្រប់គ្រងដ៏ជិតដិតរបស់ប្រធាន បេសកកម្ម និងប៊ីស្សបតែប៉ុណ្ណោះ។

**ចុះបើមនុស្សនោះបានត្រូវដាក់កាលបរិច្ឆេទសំរាប់ពិធីបុណ្យជ្រមុជទឹក តែគេមិនរក្សាការតាំងចិត្តទាំងអស់នោះទេ?**

បើអ្នកមានអារម្មណ៍ថា នរណាម្នាក់ដែលអ្នកកំពុងបង្រៀន ត្រូវការការរៀបចំបន្ថែម ចូរកុំណាត់ពេលសំរាប់ការសម្ភាសន៍ ធ្វើបុណ្យជ្រមុជទឹកឡើយ លុះត្រាតែសាសនាគន់ការី រក្សាការតាំងចិត្ត និងស្ថិតលើបទដ្ឋាន។

**តើខ្ញុំធ្វើអ្វីទៅ ពេលដែលមនុស្សចង់ធ្វើបុណ្យជ្រមុជទឹក តែពួកគេរស់នៅជាមួយគ្នា ដោយគ្មានការរៀបអាពាហ៍ពិពាហ៍?**

បុគ្គលដែលត្រូវទទួលបុណ្យជ្រមុជទឹក ដែលរស់នៅជាមួយនឹងមនុស្សដែលមានភេទផ្ទុយគ្នាដោយគ្មានចំណងអាពាហ៍ពិពាហ៍ទេ នោះត្រូវតែ រៀបការ ឬឈប់រស់នៅជាមួយគ្នា ពីមុនពួកគេអាចទទួលបុណ្យជ្រមុជទឹក។

**សំនួរទី4 នៅក្នុងការសម្ភាសធ្វើបុណ្យជ្រមុជទឹកសួរថា បើមនុស្សបានមានទំនាក់ទំនងនឹងអំពើបាបធ្ងន់ធ្ងរ ដូចជា ការពន្លូតកូន ការរួមភេទ ដូចគ្នា ឬឧក្រិដ្ឋកម្មធ្ងន់ធ្ងរ។ តើខ្ញុំគួរធ្វើដូចម្ដេចទៅ បើនរណាម្នាក់សារភាពអំពើបាបបែបនោះ?**

1. *ការណែនាំសំរាប់អ្នកផ្សព្វផ្សាយសាសនា។* ពេលខ្លះសាសនាគន់ការី ស្ម័គ្រចិត្តប្រាប់នូវអំពើបាបដូច្នោះពេលដែលអ្នក បង្រៀនអំពីព្រះបញ្ញត្តិ និងអញ្ជើញពួកគេឱ្យធ្វើការតាំងចិត្ត។ ទោះជាយ៉ាងណាក៏ដោយ បើពួកគេមិននិយាយអ្វីទេ តែអ្នកគិតថា ពួកគេប្រហែលជាមានបញ្ហា ចូររៀបចំពួកគេសំរាប់ការសម្ភាសន៍ ធ្វើបុណ្យជ្រមុជទឹក ដោយការសួរពួកគេ បើពួកគេមានទំនាក់ ទំនងនៅក្នុងអំពើបាបទាំងនេះទេ។ បើអ្នក ដឹងអំពីអំពើបាបធ្ងន់ធ្ងរ ចូរកុំសួរពត៌មានល្អិតល្អន់អំពីអំពើបាប។ ចូរកុំកំណត់កាល បរិច្ឆេទសំរាប់ពិធីបុណ្យជ្រមុជទឹក ឬធ្វើការសន្យាអ្វីឡើយ មិនថាឡើយបើពួកគេនឹងត្រូវបានអនុមតិសំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ឬអត់។ បង្ហាញសេចក្ដីស្រលាញ់របស់អ្នក និងរំលឹកឡើងវិញ គោលការណ៍នៃការប្រែចិត្ត។ ពន្យល់ដោយទន់ភ្លន់ថា អំពើបាបទាំងនេះ គឺធ្ងន់ធ្ងរ ហើយថា មនុស្សដែលមានភាពចាស់ទុំ និងមាន បទពិសោធន៍ច្រើនជាង (ប្រធានបេសកកម្មរបស់អ្នក ឬនរណាដែល គាត់ចាត់តាំង) នឹងនិយាយជាមួយពួកគេអំពីរឿងទាំងនេះ។ បន្ទាប់មក បញ្ជូនសេចក្ដីស្នើសុំការសម្ភាសន៍ធ្វើបុណ្យ ជ្រមុជទឹក ឆ្ពោះទៅកាន់ប្រធាន បេសកម្ម។
2. *ការណែនាំសំរាប់អ្នកដែលដឹកនាំ ការសម្ភាសន៍ធ្វើបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។* បើអ្នកផ្សព្វផ្សាយសាសនាបានបង្រៀន បុគ្គលដោយត្រឹមត្រូវ ពីមុនការសម្ភាសធ្វើបុណ្យជ្រមុជទឹក ចំពោះរឿងនេះ បើមាន គួរតែត្រូវបានបញ្ជូនទៅកាន់ប្រធានបេសកកម្ម។ បើរឿងនោះកើតឡើង ចូរបង្ហាញសេចក្ដីស្រលាញ់របស់អ្នក និងរំលឹកឡើងវិញនូវព្រះបញ្ញត្តិ នឹងគោលការណ៍នៃការប្រែចិត្ត។ ពន្យល់ដោយទន់ភ្លន់ថា អំពើបាបទាំងនេះ គឺធ្ងន់ធ្ងរ ហើយថា មនុស្សដែលមានភាពចាស់ទុំ និងមានបទពិសោធន៍ច្រើនជាង (ប្រធានបេសកកម្មរបស់អ្នក ឬនរណាដែលគាត់ចាត់តាំង) នឹងនិយាយជាមួយពួកគេអំពីរឿងទាំងនេះ។ បន្ទាប់មកបញ្ជូន សេចក្ដីស្នើសុំការសម្ភាសន៍ធ្វើបុណ្យជ្រមុជទឹក ឆ្ពោះទៅកាន់ប្រធានបេសកកម្ម។

## សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន

គិតអំពីអារម្មណ៍ដែលអ្នកអាចទទួល បើអ្នកត្រូវបានទទួលការសម្ភាសន៍។ ចូរពិចារណាអំពីសំនួរដូចខាងក្រោមៈ

- តើការសម្ភាសន៍អំពីអ្វីដែលជាទិដ្ឋភាពចំលែកចំពោះអ្នក? តើអ្នកសម្ភាសន៍គួរធ្វើ ឬនិយាយអ្វីដើម្បីធ្វើឱ្យ អ្នកមានអារម្មណ៍ងាយស្រួល?
- តើអ្នកចង់ឱ្យអ្នកសម្ភាសន៍ ប្រព្រឹត្តជាមួយអ្នក យ៉ាងដូចម្ដេច?

កំណត់ចំណាំ

- តើអ្នកចង់ឱ្យអ្នកសម្ភាសន៍ឆ្លើយតបយ៉ាងដូចម្ដេច ក្នុងករណីដែលអ្នកបង្ហាញការសង្ស័យ ឬការមិនយល់ ឬបើអ្នកបានសារភាពពីអំពើបាបធ្ងន់ធ្ងរ? សរសេរចំលើយចំពោះសំនួរទាំងនេះទៅក្នុងសៀវភៅសិក្សារបស់អ្នក។

## ចូរបំពេញបញ្ជីនៃពិធីបុណ្យជ្រមុជទឹក និងបញ្ជីប្រវត្តិពិធីបញ្ជាក់

អ្នកផ្សព្វផ្សាយសាសនាដែលដឹកនាំការសម្ភាសន៍ គួរតែបំពេញកំណត់ហេតុពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់បច្ចុប្បន្ន។ គាត់គួរតែធ្វើតាមការណែនាំនៅលើទំរង់បែបបទ និងត្រូវប្រាកដថា ទំរង់បែបបទទាំងនោះបានបំពេញ និងត្រឹមត្រូវ។ គាត់គួរតែពន្យល់ថា បញ្ជីប្រវត្តិសមាជិកភាព គឺត្រូវបានបង្កើតចេញពីបញ្ជីប្រវត្តិពិធីបុណ្យជ្រមុជទឹក ហើយនឹងផ្ទុកនូវព័ត៌មាន សំខាន់ៗអំពីសមាជិកថ្មី និងពិធីការទាំងឡាយដែលពួកគេបានទទួល។ នៅពេលដែលសមាជិកផ្លាស់ទីលំនៅ បញ្ជីប្រវត្តិ សមាជិកភាព គឺត្រូវបានបញ្ជូនទៅកាន់អង្គភាពថ្មី ដើម្បីឱ្យប៊ីស្សុបថ្មីរបស់ពួកគេ អាចផ្ដល់នូវការរាក់ទាក់ និងការជួយទំនុកបំរុង។ អ្នកផ្សព្វផ្សាយសាសនាគួរតែសួរបុគ្គលដើម្បីត្រួតពិនិត្យមើលពត៌មាននៅលើទំរង់បែបបទនៅអំឡុងធ្វើការសម្ភាសន៍នោះ។ អ្នកផ្សព្វផ្សាយសាសនាដែលដឹកនាំការសម្ភាសន៍គួរតែយកកំណត់ហេតុបុណ្យជ្រមុជទឹក ទៅកាន់ពិធីបុណ្យជ្រមុជទឹក ហើយប្រគល់វាទៅឱ្យអ្នកដែលជាអធិបតី។

ប៊ីស្សុបត្រូវឱ្យច្បាស់ថា ទំរង់បែបបទនៃពិធីបញ្ជាក់/ពិធីបុណ្យជ្រមុជទឹក និងលិខិតពិធីបញ្ជាក់ ត្រូវបានបំពេញសំរាប់បុគ្គលម្នាក់ៗទៅតាមការណែនាំនៅលើទំរង់បែបបទនោះ។

**សកម្មភាព៖ ការសិក្សាផ្ទាល់ខ្លួន ឬការសិក្សាជាមួយដៃគូ**

សិក្សាម៉ូសាយ 6៖1–3 និងម៉ូរ៉ូណៃ 6៖1–4។ តើសារលិខិតនេះមានទំនាក់ទំនងអ្វី ចំពោះការទទួលខុសត្រូវរបស់អ្នក សំរាប់ ការរក្សាបញ្ជីប្រវត្តិនៃពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ដោយត្រឹមត្រូវ?

## ពិធីបុណ្យជ្រមុជទឹក

ព្រះវិញ្ញាណនឹងត្រូវបង្ហាញយ៉ាងខ្លាំងក្លានៅពេលដែលពិធីការពិសិដ្ឋនៃពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ គឺត្រូវបានធ្វើឡើង។ ពិធីបុណ្យជ្រមុជទឹក និងបន្ទាប់មកពិធីបញ្ជាក់គួរតែធ្វើឡើងយ៉ាងពិសេសខាងវិញ្ញាណសំរាប់អ្នកផ្លាស់គំនិតថ្មី។ អ្នក ហើយនឹងអ្នកដឹកនាំបេសកកម្មនៅនៅក្នុងវួដ គួរតែធ្វើអ្វីៗដែលអ្នកអាចធ្វើបាន ដើម្បីបញ្ជាក់ថា ការបំរើពិធីបុណ្យជ្រមុជទឹកឱ្យ មានសណ្ដាប់ធ្នាប់ឱ្យនៅតែមានសកម្មភាពត្រូវបានរៀបចំ និងបំផុសគំនិត និងគួរឱ្យចងចាំ។ ពិធីទាំងនេះគួរតែពង្រឹងដល់អ្នក ផ្លាស់គំនិតថ្មីក្នុងការតាំងចិត្តរបស់ពួកគេដើម្បី បន្តសកម្ម។



ចូរអញ្ជើញគណៈប៊ីស្សុប ក្រុម និងអ្នកដឹកនាំជំនួយ និងគ្រូបង្រៀនតាមផ្ទះ និងអ្នកសួរសុខទុក្ខ (បើត្រូវបានចាត់តាំង) ដើម្បីចូល រួមពិធីបុណ្យជ្រមុជទឹក។ មិត្តភក្ដិ និងញាតិសន្ដាននៃអ្នកផ្លាស់គំនិត និងសាសនាគន់ការីបច្ចុប្បន្ន របស់អ្នកទាំងអស់ គួរតែត្រូវបាន អញ្ជើញឱ្យចូលរួមក្នុងពិធីបុណ្យជ្រមុជទឹក និងការប្រជុំការប្រសិទ្ធពរនំប៉័ងនិងទឹក ជាកន្លែងដែលពិធី បញ្ជាក់នឹងត្រូវបាន ធ្វើឡើង។ បទពិសោធន៍ទាំងនេះនឹងជួយពួកគេ ទទួលអារម្មណ៍ពីព្រះវិញ្ញាណ និងរៀបចំពួកគេដើម្បីទទួលការ អញ្ជើញ រៀនបន្ថែមទៀត អំពីដំណឹងល្អ។ ចូរធ្វើការជាមួយនឹងបុគ្គលដែលទទួលបុណ្យជ្រមុជទឹក និងអ្នកដឹកនាំបេសកកម្មក្នុងវួដ ដើម្បី អញ្ជើញមិត្តភក្ដិ និងញាតិសន្ដានរបស់បុគ្គលចូលរួមជាមួយ។ បន្ទាប់មក ធ្វើការតាមដានបន្ទាប់ពីកម្មវិធី ដើម្បីពិភាក្សា ពីបទពិសោធន៍របស់ពួកគេ និងអញ្ជើញពួកគេដើម្បីរៀនពី មូលហេតុដែលមិត្តរបស់ពួកគេជ្រើសរើស ទទួលបុណ្យជ្រមុជទឹក។

អ្នកផ្សព្វផ្សាយសាសនាដែលបានបង្រៀនបុគ្គលទទួលបុណ្យជ្រមុជទឹក សំរបសំរួលជាមួយនឹងអ្នកដឹកនាំបេសកកម្មក្នុងវួដ ដើម្បីរៀបចំកម្មវិធី។ ចូរពន្យល់ទៅបុគ្គលទទួលបុណ្យជ្រមុជទឹក ពីអ្វីដែលបានរៀបគំរោង និងមូលហេតុ។ ចូរពិភាក្សាពីសំលៀកបំពាក់សមរម្យ ដោយប្អូករួមទាំងរបៀបដែលបុគ្គលនឹងត្រូវផ្ដល់ឱ្យនូវសំលៀកបំពាក់ពណ៌ស

កំណត់ចំណាំ

សំរាប់ពាក់ក្នុងពិធីបុណ្យជ្រមុជទឹក ។ ចូរព្រមព្រៀងគ្នាសំរាប់ទីកន្លែង និងពេលវេលាសំរាប់ពិធីបុណ្យជ្រមុជទឹក។ ជាធម្មតា សមាជិកនៃគណៈប៊ីស្សប ឬអ្នកដឹកនាំ បេសកកម្ម ក្នុងវួដ និងដឹកនាំកម្មវិធី។ ខាងក្រោមគឺជា កិច្ចការសំខាន់ដើម្បីរៀបគំរោង និងរៀបចំ។

កម្មវិធីពិធីបុណ្យជ្រមុជទឹកគួរតែរួមបញ្ចូលៈ

1. ភ្លេងផ្តើម
2. ការស្វាគមន៍យ៉ាងខ្លី ដោយអ្នកកាន់បព្វជិតភាពដែលដឹកនាំការបំរើ (សមាជិកនៃគណៈប្រធានប៊ីស្សប គួរតែជាគណៈអធិបតី)។
3. ចំរៀងបើក និងអធិស្ឋានបើក។
4. ការនិយាយខ្លីៗមួយ ឬពីរអំពីដំណឹងល្អ ដូចជាពិធីបុណ្យជ្រមុជទឹក និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។
5. តន្ត្រីមួយដែលបានជ្រើសរើស
6. ធ្វើពិធីបុណ្យជ្រមុជទឹក។
7. ជាពេលនៃគារវភាព ក្នុងខណៈដែលអ្នកទទួលបុណ្យជ្រមុជទឹក ប្តូរសំលៀកបំពាក់។ ការណ៍នេះគួរតែបូករួម ទាំងការស្តាប់តន្ត្រីកំសាន្ត ការច្រៀងទំនុកដំកើងដែលចេះច្រៀង និងចំរៀងកុមារាកុមារី ការបង្ហាញផលិតផលសោតទស្សន៍របស់ សាសនាចក្រ ឬការថ្លែងសក្ខីភាព។
8. ឱកាសរបស់អ្នកផ្លាស់គំនិតថ្មី ដើម្បីថ្លែងសក្ខីភាព បើពួកគេមានចង់ធ្វើ។
9. ចំរៀងបិទ និងការអធិស្ឋានបិទ។
10. តន្ត្រីបញ្ចប់។

## ពិធីបញ្ជាក់

មនុស្សទទួលពិធីការនៃពិធីបញ្ជាក់បន្ទាប់ពី ពួកគេបានទទួលបុណ្យជ្រមុជទឹក (សូមមើល គ និង ស 20ៈ41)។ អ្នកផ្លាស់គំនិតថ្មីម្នាក់ គឺត្រូវបានចាត់ទុកថាជាសមាជិកនៃសាសនាចក្រ បន្ទាប់ពីពិធីការនៃពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ត្រូវបានធ្វើឡើង (សូមមើល យ៉ូហាន 3ៈ5, គ និង ស 33ៈ11)។ អ្នកផ្លាស់គំនិតថ្មីគឺត្រូវបានបញ្ជាក់នៅក្នុងការប្រជុំពិធីប្រសិទ្ធពរ នំប៉័ងនិងទឹក នៃវួដដែលពួកគេរស់នៅ មិនមែននៅក្នុងការបំរើពិធីបុណ្យជ្រមុជទឹកទេ។ ប៊ីស្សប គឺទទួលខុសត្រូវដើម្បីមើលថា ពិធីបញ្ជាក់ កើតឡើងយ៉ាងឆាប់បំផុតតាមហេតុផលបន្ទាប់ពីពិធីបុណ្យជ្រមុជទឹក។ ប៊ីស្សប ឬទីប្រឹក្សាម្នាក់របស់គាត់ត្រូវចូលរួមនៅក្នុងពិធីបញ្ជាក់។ ប៊ីស្សបអាចអញ្ជើញអ្នកផ្សព្វផ្សាយសាសនាជាអែលឌើរ ដែលជួយបង្រៀនអ្នកផ្លាស់គំនិត ឱ្យចូលរួមនៅក្នុងពិធី បញ្ជាក់។ ចូរធ្វើការយ៉ាងជិតស្និទជាមួយនឹងប៊ីស្សប និងអ្នកដឹកនាំបេសកកម្មក្នុងវួដ ដើម្បីបញ្ជាក់ថា ពិធីការសំខាន់នេះ គឺត្រូវបានធ្វើឡើង។



## បន្ទាប់ពីពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់

ក្រោមការដឹកនាំរបស់ប៊ីស្សប អ្នកផ្សព្វផ្សាយសាសនាអាចបន្តរាក់ទាក់ជាមួយនឹងសមាជិកថ្មី។ ចូរបន្តបង្រៀនពួកគេ និងរំលឹកឡើងវិញពីអ្វីដែលពួកគេបានរៀន។ ចូរលើកទឹកចិត្ត និងគាំទ្រដល់ពួកគេ ចូរអានព្រះគម្ពីរមរមនជាមួយពួកគេ និងជួយពួក គេចែកចាយដំណឹងល្អជាមួយសមាជិកក្រុមគ្រួសារ និងមិត្តភក្តិរបស់ពួកគេ។ តាមដែលសមរម្យ ចូរបន្តជាមួយអ្នកទាំងឡាយណា ដែលអ្នកបានបង្រៀន ពេញមួយជីវិតរបស់អ្នក ទាក់ទង និងលើកទឹកចិត្ត និងគាំទ្រដល់ពួកគេ។

បន្ទាប់ពីពិធីបញ្ជាក់ ចូរបន្តប្រើបញ្ជីបង្រៀន ដើម្បីកត់ត្រាការរីកចំរើនរបស់អ្នក នៅក្នុងការបង្រៀនមេរៀនទី 1–4 ម្តងទៀត និងក្នុងការបង្រៀនមេរៀនទី 5។ ចូរធ្វើការជាមួយនឹងអ្នកដឹកនាំបេសកកម្មក្នុងវួដ និងអ្នកដឹកនាំនៅក្នុងវួដ ដើម្បីជួយអ្នកផ្លាស់គំនិតថ្មីឱ្យនៅសកម្ម និងទទួលពរជ័យទាំងអស់ នៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ។

កំណត់ចំណាំ

## ចូរចងចាំចំណុចនេះ

- ចូររៀបចំបុគ្គលទទួលបុណ្យជ្រមុជទឹកឱ្យបានសមរម្យ សំរាប់ការសម្ភាសន៍សំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។
- ចូរបញ្ជាក់ថា បុគ្គលមានទទួរតំរូវការសំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។
- ជួយបញ្ជាក់ថា កម្មវិធីពិធីបុណ្យជ្រមុជទឹក មានទទួរការលើកដំកើងខាងវិញ្ញាណ។
- ប្រើកម្មវិធីពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ជាឱកាសដើម្បីស្វែងរក។
- ចូរបំពេញទំរង់បែបបទពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ឱ្យបានត្រឹមត្រូវ។

# គំនិតសំរាប់ការសិក្សា និងការអនុវត្ត

## ការសិក្សាផ្ទាល់ខ្លួន

- ចូរធ្វើបញ្ជីនៃឧបសគ្គដែលបុគ្គលទទួលបុណ្យជ្រមុជទឹកអាចជួបប្រទះ។ ហេតុអ្វីវាសំខាន់ដែលបុគ្គលទទួលអារម្មណ៍ សេចក្តីស្រលាញ់ និងមិត្តភាពនៃសាសនាចក្រ?

- ចូរសិក្សាម៉ូរ៉ូណៃ 6 និងគោលលទ្ធិ និងសេចក្តីសញ្ញា 20:68–69។ តើអ្នករៀនអ្វីពីខទាំងនេះអំពីការរៀបចំមនុស្ស សំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់? សរសេរពីអ្វីដែលអ្នករៀន ហើយចែកចាយគំនិតរបស់អ្នកជាមួយនឹងដៃគូ អំឡុង ពេលសិក្សាជាមួយដៃគូ។

## ការសិក្សាជាមួយដៃគូ

- អែលឌើរ ហ៊ែនរី ប៊ី អាយរ៉ុង បានពន្យល់ពីសារៈសំខាន់នៃការមានបទដ្ឋានខ្ពស់។ ចូរពិភាក្សាពាក្យទូន្មាននេះ ជាមួយដៃគូរបស់អ្នក និងវាយតំលៃអំពីអារម្មណ៍ដែលអ្នកមាន ចំពោះការជួយមនុស្សដោយមោះមុតដើម្បី ឱ្យស្ថិតលើមាត្រដ្ឋានទាំងនេះ។ “ព្រះអម្ចាស់ដាក់បទដ្ឋានរបស់ទ្រង់ ដើម្បីទ្រង់អាចប្រទានពរដល់យើង។ ចូរគិតអំពីពរជ័យទាំងនោះ ទ្រង់សន្យាចំពោះ អ្នកទាំងឡាយណាដែលស្ថិតលើបទដ្ឋានជំនួយនៃព្រះវិញ្ញាណបរិសុទ្ធ។ ទ្រង់សន្យាសេចក្តីសុខសាន្តផ្ទាល់ខ្លួន។ ទ្រង់សន្យា ឱកាសដើម្បីទទួលពិធីការពិសិដ្ឋនៅក្នុងដំណាក់របស់ទ្រង់។ ហើយទ្រង់សន្យាចំពោះអ្នកទាំងឡាយណាដែល ស៊ូទ្រាំក្នុងការរស់នៅតាមបទដ្ឋាន របស់ទ្រង់ ដែលពួកគេនឹងមានជីវិតអស់កល្បជានិច្ច…។ ព្រោះយើងស្រលាញ់មនុស្សដែលយើងបំរើ នោះយើងទាំងអស់គ្នាចង់ធ្វើអ្វី ដែលប្រសើរជាងក្នុងការលើកដំកើងកូនចៅរបស់ព្រះវរបិតាសួគ៌របស់យើង ចំពោះសេចក្តីស្មោះត្រង់ និងបរិសុទ្ធភាព ដែលពួកគេ ត្រូវការដើម្បីទទួលពរជ័យទាំងអស់របស់ព្រះអម្ចាស់…។ អ្នកចាប់ផ្តើមដោយលើកឡើងនូវបទដ្ឋានរបស់ព្រះអម្ចាស់យ៉ាងច្បាស់ ហើយដោយគ្មានការសោកស្តាយ។ ហើយពេលដែលលោកីយកាន់តែឃ្លាតឆ្ងាយពីពួកគេ និងចំអកដល់ពួកគេ នោះយើងក៏កាន់តែ ក្លាហានក្នុងការធ្វើ ប៉ុណ្ណោះដែរ” (“Standards of Worthiness,” *First Worldwide Leadership Training Meeting*, ខែមករា ឆ្នាំ 2003, 10–11)។

- ចែកចាយជាមួយដៃគូរបស់អ្នកពីអ្វីដែលអ្នកបានរៀនពីជំពូកនេះ អំពីការរៀបចំមនុស្សសំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។

- ចូររំលឹកឡើងវិញពីកម្មវិធីពិធីបុណ្យជ្រមុជទឹកចុងក្រោយគេ ដែលអ្នកបានចូលរួម។ ចូរប្រៀបធៀបកម្មវិធីនោះ ជាមួយនឹងទំរង់គំនិតនៅក្នុងវគ្គដែលមានចំណងជើង “កម្មវិធីពិធីបុណ្យជ្រមុជទឹក។” តើអ្វីដែលធ្វើបានល្អ? តើអ្វីដែលគួរតែអភិវឌ្ឍន៍? ចូរពិភាក្សាពី របៀបដែលអ្នកនឹងប្រាកដថា កម្មវិធីដែលអ្នករៀបគំរោង នឹងពោរពេញដោយព្រះវិញ្ញាណ និងការលើកដំកើង។

- អនុវត្តរបៀបជាក់លាក់ណាមួយ ដែលអ្នកអាចរៀបចំសាសនាគន់ការី សំរាប់ការសម្ភាសន៍ធ្វើបុណ្យជ្រមុជទឹ។

- ចូររំលឹកឡើងវិញនូវសំនួរសម្ភាសន៍ធ្វើបុណ្យជ្រមុជទឹក។ ចូរពិចារណារបៀបដែលអ្នកអាចគ្រប់គ្រងលើស្ថានភាពពិបាកៗ ដែលមានដូចខាងក្រោមៈ
  - បុគ្គលមិនបានប្រាប់អ្នកថា គាត់កំពុងស្ថិតលើស្ថានភាពព្យួរទោសដោយច្បាប់សំរាប់ឧក្រិដ្ឋកម្ម បានប្រព្រឹត្តពីមុនទេ។
  - បុគ្គលនោះមិនទាន់បានទទួលចំលើយយ៉ាងជាក់លាក់ទៅនឹងការអធិស្ឋានដែលថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការី។
  - បុគ្គលនោះបានជក់បារីពីរថ្ងៃមុន។
  - បុគ្គលនោះមិនប្រាកដថា តើនាងបានទទួលចំលើយចំពោះការអធិស្ឋានរបស់នាងហើយឬទេ។
  - ក្រុមគ្រួសារទទួលអារម្មណ៍តាបសង្កត់ពីមិត្តភក្តិ ហើយមិនប្រាកដថា ពួកគេរួចស្រេចសំរាប់ពិធីបុណ្យជ្រមុជទឹកឬអត់។

- ចូររំលឹកឡើងវិញនូវទំរង់បែបបទបញ្ជីបុណ្យជ្រមុជទឹក និងបញ្ជីពិធីបញ្ជាក់ និងលិខិតបញ្ជាក់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។ តើអ្នកអាចអះអាងថា ពត៌មានដែលអ្នកបានផ្តល់ គឺត្រឹមត្រូវនិងពេញលេញ បានយ៉ាងដូចម្តេច?

## ការប្រជុំមណ្ឌល និងសន្និសីទហ្សូន

- ចូររំលឹកឡើងវិញពីសារៈសំខាន់នៃការសម្ភាសន៍ធ្វើបុណ្យជ្រមុជទឹក។ ចូរពិភាក្សាពីរបៀបដែលអ្នកផ្សព្វផ្សាយសាសនាគួរតែរៀបចំសាសនាគន់ការី សំរាប់ការសម្ភាសន៍។

- ចូរពិភាក្សាពីវិធីដែលត្រូវប្រើកម្មវិធីពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់សំរាប់ជាឱកាសស្វែងរក។

កំណត់ចំណាំ

កំណត់ចំណាំ

## ប្រធានបេសកកម្ម

- ចូរធ្វើការជាមួយនឹងអ្នកដឹកនាំបព្វជិតភាពប្រចាំតំបន់ ដើម្បីបញ្ជាក់ការប្រើដោយមានប្រសិទ្ធិភាពនៃបញ្ជីរកចំរើន។
- យូរៗម្តង ដឹកនាំការសម្ភាសន៍លើកទីមួយសំរាប់ពិធីបុណ្យជ្រមុជទឹក។
- បង្រៀនអ្នកដឹកនាំមណ្ឌល និងអ្នកដឹកនាំហ្សូន ពីរបៀបដើម្បីដឹកនាំការសម្ភាសន៍ធ្វើបុណ្យជ្រមុជទឹក។
- បង្រៀនដល់សមាជិកនៃគណៈប្រធានបេសកកម្ម និងអ្នកដឹកនាំបព្វជិតភាព ពីរបៀបដើម្បី ដឹកនាំការសម្ភាសន៍ធ្វើបុណ្យជ្រមុជទឹក សំរាប់បុគ្គលទទួលបុណ្យជ្រមុជទឹក ដែលប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ។



# តើខ្ញុំអាចធ្វើការជាមួយនឹងអ្នកដឹកនាំក្នុងស្តេក និងវួដបានដោយរបៀបណា?

កំណត់ចំណាំ

**ចូរពិចារណាចំណុចនេះ**

- តើអ្នកផ្លាស់សាសនាថ្មី និងសមាជិកមិនសូវសកម្មត្រូវការអ្វីខ្លះ ដើម្បីក្លាយទៅជាសមាជិកសកម្មនៅក្នុងសាសនាចក្រ?
- តើអ្នកដឹកនាំក្នុងស្តេក និងវួដ មានការទទួលខុសត្រូវអ្វីខ្លះ ក្នុងកិច្ចការផ្សព្វផ្សាយសាសនា ការថែរក្សា និងការធ្វើឱ្យសកម្មឡើងវិញ?
- តើខ្ញុំអាចជួយអ្នកដឹកនាំក្នុងវួដ បង្កើតសាសនាចក្រឡើងដោយរបៀបណា?
- តើអ្វីនឹងកើតឡើងនៅក្នុងការប្រជុំសហសម្ព័ន្ធរាល់សប្តាហ៍ ជាមួយនឹងអ្នកដឹកនាំបេសកកម្មក្នុងវួដ?

អ្នកមានឱកាសដ៏អស្ចារ្យ ដើម្បីធ្វើការជាមួយនឹងអ្នកដឹកនាំ និងសមាជិកក្នុងអំឡុងពេលបេសកកម្មរបស់អ្នក។ ទាំងអស់គ្នា អ្នកនឹងពង្រឹង និងបង្កើតសាសនាចក្រព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយឡើង។ ទំនាក់ទំនង ដែលអ្នកបង្កើតជាមួយនឹងអ្នកដឹកនាំសាសនាចក្រ នឹងផ្តល់ពរឱ្យអ្នក អស់មួយជីវិត។ ទាំងនេះ គឺជាទំនាក់ទំនងដ៏សំខាន់ នៅពេលអ្នក និងសមាជិកសាសនាចក្រ ព្យាយាមដើម្បីនាំដំណឹងល្អដែលបានស្តារឡើងវិញ ទៅកាន់កូនចៅទាំងឡាយរបស់ព្រះវរបិតាសួគ៌។ ការយល់ដឹងអំពីមូលដ្ឋានដើម្បីធ្វើការនៅក្នុងអង្គការវួដ នឹងជួយអ្នកឆ្ពោះទៅមុខជាមួយ នឹងការយកចិត្តទុកដាក់ដ៏អស្ចារ្យ និងអំណាច។

## ការពង្រឹងសមាជិកថ្មី និងសមាជិកមិនសូវសកម្ម

នៅពេលអ្នកផ្លាស់សាសនា ទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ពួកគេធ្វើការសន្យាដ៏ពិសិដ្ឋ ដើម្បីគោរព និងបំរើព្រះ និងអ្នកដទៃ អស់មួយជីវិត។ ពួកគេក្លាយទៅជាបេក្ខជនសំរាប់សេចក្តីសង្គ្រោះ នៅក្នុងនគរសេឡេស្ទាល។ ដើម្បីទទួលបានពរជ័យដែលបានសន្យា ពួកគេត្រូវតែប្រកាន់ខ្ជាប់ដរាបដល់ចុងបំផុត ដោយសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ។ សមាជិកសាសនាចក្រ មានសារៈសំខាន់នៅក្នុងការជួយដល់អ្នកផ្លាស់សាសនាថ្មីឱ្យនៅសកម្ម និងស្មោះត្រង់។

ប្រធានគរឌីន ប៊ី ហ៊ីងឃ្លីមានប្រសាសន៍ថាៈ “គ្មានចំណុចពេញលេញទេ នៅក្នុងការធ្វើកិច្ចការផ្សព្វផ្សាយសាសនា លុះត្រាតែយើង កាន់ឱ្យជាប់នូវផលផ្លែនៃការខិតខំនោះ។ ទាំងពីរនាក់មិនត្រូវបែកចេញពីគ្នាឡើយ . . .។ គ្រប់អ្នកផ្លាស់សាសនា គឺជាការទទួលខុស ត្រូវដ៏ធំ និងធ្ងន់ធ្ងរមួយ” (“Find the Lambs, Feed the Sheep,” *Ensign*, ខែឧសភា ឆ្នាំ1999, 108)។

នៅក្រោមការដឹកនាំរបស់ប៊ីស្សប ក្រុមប្រឹក្សាក្នុងវួដមានការទទួលខុសត្រូវជាចំបង សំរាប់ពង្រឹងសមាជិកថ្មី និងសមាជិកមិនសូវសកម្ម។ ពួកគេត្រូវប្រាកដថា អ្នកផ្លាស់សាសនាថ្មី និងសមាជិកមិនសូវសកម្ម មានមិត្តភក្តិ ដែលត្រូវបានចិញ្ចឹមបីបាច់ដោយព្រះបន្ទូលដ៏ល្អនៃព្រះ ហើយទទួលមុខងារ និងការទទួលខុសត្រូវទាំងឡាយ។ ពួកគេប្រហែលជាទាមទារឱ្យអ្នកផ្សព្វផ្សាយសាសនា ពេញម៉ោងជួយនៅ

© 2003 Simon Dewey(។ ហាមថតចម្លង។

កំណត់ចំណាំ

ក្នុងការបង្រៀនតាមផ្ទះ (ឬអ្នកផ្សព្វផ្សាយសាសនាដែលជាស៊ីស្ទើរជួយសួរសុខទុក្ខតាមផ្ទះ) និងនៅក្នុងការសួរសុខទុក្ខសមាជិកថ្មី សមាជិកមិនសូវសកម្ម និងអ្នកត្រៀមធ្វើជាអែលឌើរ។ វាជាការប្រសើរ បើអ្នកអាចរៀបចំ សមាជិកឱ្យទៅជាមួយ ដើម្បីធ្វើការសួរសុខទុក្ខ។

អ្នកក៏មានការទទួលខុសត្រូវសំរាប់មនុស្សទាំងនេះផងដែរ។ ប្រធាន ហ៊ីងឃ្លី មានប្រសាសន៍ថាៈ "អ្នកផ្សព្វផ្សាយសាសនាទាំងឡាយ . . . មានចំណែកទទួលខុសត្រូវក្នុងការចងភ្ជាប់ អ្នកផ្លាស់សាសនាថ្មីរបស់អ្នកទៅនឹងសាសនាចក្រនេះ។ អ្នកប្រហែលជាមិនអាចបន្តសួរសុខទុក្ខពួកគេទេ។ ប៉ុន្តែអ្នកអាចសរសេរសំបុត្រទៅលេងពួកគេយូរៗម្តង ហើយផ្តល់ការលើកទឹកចិត្តដល់ពួកគេ . . .។ នៅពេលអ្នកទៅផ្ទះវិញ ចូរកុំភ្លេចពួកគេ។ ត្រូវរស់នៅដោយសក្តិសមគ្រប់ពេលតាមការទុកចិត្តរបស់ពួកគេ។ ចូរសរសេរសំបុត្រទៅលេង ពួកគេយូរៗម្តង ដើម្បីធានាដល់ពួកគេអំពីសេចក្តីស្រឡាញ់របស់អ្នក" (*Ensign*, ខែឧសភា ឆ្នាំ1999, 109)។



នៅពេលចូលរួមនៅក្នុងការប្រជុំព្រះវិហារ អ្នកនិងដៃគូរបស់អ្នកគួរតែអង្គុយជាមួយនឹងសាសនាគន់ការីរបស់អ្នក ឬសមាជិក ទាំងឡាយដែលអ្នកបានរាក់ទាក់ ដើម្បីគាំទ្រ និងពង្រឹងដល់ពួកគេ។ អ្នកមិនគួរអង្គុយជាមួយនឹងក្រុមអ្នកផ្សព្វផ្សាយសាសនា ដទៃទៀតទេ។

ផ្នែកដ៏មានតម្លៃមួយនៃបេសកកម្មរបស់អ្នក គឺបង្កើតសាសនាចក្រ និងពង្រឹងដល់ក្រុមដែលអ្នកបំរើ។ អ្នកធ្វើដូចនេះ ជាផ្នែកមួយ ដើម្បីជួយដល់អ្នកផ្លាស់សាសនាថ្មីឱ្យនៅសកម្ម និងជួយសមាជិកមិនសូវសកម្មត្រឡប់មកសកម្មវិញ។ កាតព្វកិច្ចមួយក្នុងចំណោម កាតព្វកិច្ចទាំងឡាយរបស់អ្នក គឺត្រូវចូលរួមជាមួយនឹងអ្នកផ្សព្វផ្សាយសាសនាក្នុងវួដ ដើម្បីបង្រៀនមេរៀនទាំងបួន ម្តងទៀត ហើយបង្រៀនមេរៀនទី 5។ អ្នកផ្សព្វផ្សាយសាសនាក្នុងវួដ គ្រូបង្រៀនតាមផ្ទះ និងគ្រូបង្រៀនសួរសុខទុក្ខ អាចជួយ បង្រៀនគោលការណ៍ទាំងនេះផងដែរ។

ប្រធាន គរឌឹន ប៊ី ហ៊ីងឃ្លី បានភ្ជាប់ជាមួយនូវកង្វល់អំពីឧបសគ្គជាច្រើន ដែលអ្នកផ្លាស់សាសនាថ្មីនឹងប្រឈមមុខ មានដូចខាងក្រោមនេះៈ

> *កាលពីថ្ងៃមុនខ្ញុំ បានទទួលសំបុត្រមួយច្បាប់ ដែលគួរឱ្យចាប់អារម្មណ៍។ សំបុត្រនោះសរសេរដោយស្ត្រីម្នាក់ ដែលបានចូលរួមក្នុងសាសនាចក្រអស់ពេលមួយឆ្នាំកន្លងទៅហើយ។ គាត់សរសេរថាៈ*
>
> *"ការធ្វើដំណើរនៅក្នុងសាសនាចក្ររបស់ខ្ញុំ ពិសេស ហើយក៏មានឧបសគ្គខ្លះ។ កាលពីឆ្នាំមុខនេះ ជាឆ្នាំ ដែលពិបាកជាងគេ ដែលខ្ញុំមាននៅក្នុងជីវិតរបស់ខ្ញុំ។ ហើយវាក៏ជារង្វាន់ដ៏ធំបំផុតផងដែរ។ ក្នុងនាមជាសមាជិកថ្មី ខ្ញុំនៅតែបន្តមានឧបសគ្គជារៀងរាល់ថ្ងៃ។"*
>
> *គាត់និយាយបន្តទៀតថា នៅពេលគាត់ចូលក្នុងសាសនាចក្រ គាត់អត់មានអារម្មណ៍ជួយគាំទ្រមកពីអ្នកដឹកនាំ នៅក្នុង វួដសោះ។ ប៊ីស្សបរបស់គាត់ហាក់ដូចជាព្រងើយកន្តើយនឹងគាត់ ដែលជាសមាជិកថ្មីម្នាក់។ ពីព្រោះតែគាត់មានអារម្មណ៍ថា ត្រូវគេបដិសេធ គាត់បានត្រឡប់ទៅរកប្រធានបេសកកម្មរបស់គាត់វិញ ដែលជាអ្នក ដែលបានបើកឱកាសឱ្យគាត់។*
>
> *គាត់និយាយថា "សមាជិកសាសនាចក្រមិនដឹងថាវាយ៉ាងណានោះទេ ដើម្បីក្លាយទៅជាសមាជិកថ្មីម្នាក់នោះ . . .។ ហេតុនេះហើយ ដើម្បីដឹងអំពីរបៀប ដើម្បីគាំទ្រដល់យើង វាស្ទើរតែមិនអាចធ្វើទៅបានចំពោះពួកគេ។"*
>
> *ខ្ញុំជំរុញដល់អ្នកទាំងអស់គ្នា បងប្អូនប្រុសស្រីថា បើសិនជាអ្នកមិនដឹងថាវាជាយ៉ាងណានោះ ចូរអ្នកព្យាយាមដើម្បីនឹក ស្រមៃគិតថាវាយ៉ាងដូចម្តេច។ វាអាចជាភាពឯកកោរដែលគួរឱ្យភ័យខ្លាច។ វាអាចជាការខកចិត្ត។ វាអាចជាការភិតភ័យ។ យើង ដែលនៅក្នុងសាសនាចក្រនេះ មានភាពផ្សេងគ្នាយ៉ាងដាច់ឆ្ងាយពីលោកីយលើសពីអ្វី ដែលយើងគិតអំពីខ្លួនយើងទៅទៀត។ ស្ត្រីម្នាក់នេះបន្តទៅទៀតថា "នៅពេលយើងជាសាសនាគន់ការី ក្លាយទៅជាសមាជិកនៃសាសនាចក្រ យើងភ្ញាក់ផ្អើលណាស់ នៅពេលរកឃើញថា យើងបានចូលទៅក្នុងពិភពលោកបរទេសទាំងស្រុង ជាពិភពលោកមួយដែលមានទំនៀមទំលាប់ វប្បធម៌ និងភាសាផ្ទាល់ខ្លួន។ យើងបានរកឃើញថាគ្មានមនុស្សណាម្នាក់ ឬកន្លែងសំអាងណាមួយថា យើងអាចត្រឡប់ទៅរកការណែនាំ នៅក្នុងការធ្វើដំណើររបស់យើងនៅក្នុងពិភពលោកថ្មីនេះទេ។ ការធ្វើដំណើរមានភាពគួរឱ្យរំភើបរីករាយ កំហុសរបស់ យើងគួរឱ្យចង់សើច បន្ទាប់មកប្រែក្លាយទៅជាការមួរម៉ៅ ហើយបន្តិចម្តងៗ ការមួរម៉ៅត្រឡប់ទៅជាកំហឹង។ ហើយនៅដំណាក់ កាលនៃភាពមួរម៉ៅ និងកំហឹងទាំងនេះហើយ ដែលយើងបានចាកចេញ។ យើងបានត្រឡប់ទៅកាន់លោកីយ ដែលយើងបានចេញ មកជាកន្លែងដែលយើងដឹងថា យើងធ្លាប់ជានរណា កន្លែងដែលយើងបានធ្វើវិភាគទាន ហើយ ដែលយើងអាចនិយាយភាសា [*Ensign*, ខែឧសភា ឆ្នាំ1999, 108]។*

កំណត់ចំណាំ

### សកម្មភាពៈ ការសិក្សាផ្ទាល់ខ្លួន និងជាមួយដៃគូ

សូមអានដំណើររឿងពីមុននេះ។ ចូរសរសេរចំលើយសំនួរខាងក្រោមនៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សា របស់អ្នក ឬពិភាក្សាចំលើយទាំងនោះជាមួយនឹងដៃគូរបស់អ្នក។ ចូរបង្កើតគោលដៅ និងផែនការឱ្យបានសមរម្យ។

- យោងទៅតាមដំណើររឿងនេះ តើកត្តាមួយចំនួនណាខ្លះ ដែលធ្វើឱ្យមានការលំបាកសំរាប់សមាជិកថ្មី ដើម្បីបន្តទៅសកម្ម?
- តើការដែលមានសមាជិកមកចូលរួម តាំងពីនៃដំណើរការក្នុងការបង្រៀន អាចជួយដល់បញ្ហាទាំងនេះបានយ៉ាងដូចម្តេច?
- ចូរគិតអំពីអ្នកទាំងឡាយណា ដែលអ្នកកំពុងបង្រៀន។ តើអ្នកអាចធ្វើឱ្យសមាជិកមកចូលរួមកាន់តែប្រសើរឡើង ដើម្បីជួយដល់សាសនាគន់ការី ឱ្យចាប់ផ្តើមមិត្តភាពជាទូទៅ នៅក្នុងសាសនាចក្របានដោយរបៀបណា?

## ការបង្រៀនតាមផ្ទះ និងការបង្រៀនសួរសុខទុក្ខ

ប្រធានស្តេក និងប៊ីស្សប ធ្វើការសម្របសម្រួលជាមួយនឹងប្រធានបេសកកម្ម ប្រហែលជាអាចប្រើប្រាស់អ្នកផ្សព្វផ្សាយសាសនាឱ្យទៅសួរសុខទុក្ខអ្នកមិនសូវសកម្ម និងអ្នកដែលជាសមាជិកតែម្នាក់ឯងនៅក្នុងគ្រួសារ។ នៅក្នុងស្ថានភាពសមរម្យ ពួកគេ ប្រហែលជាត្រូវស្នើរសុំឱ្យអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ចូលរួមនៅក្នុងការបង្រៀនតាមផ្ទះ និងនៅក្នុងការបង្រៀនពេលសួរសុខទុក្ខ។ ឱកាសនៃការបង្រៀនទាំងនេះ គួរតែពង្រឹងដល់សមាជិក ហើយកើនលទ្ធភាព ឱ្យអ្នកផ្សព្វផ្សាយសាសនា បង្រៀន និងជួយអ្នកផ្សព្វផ្សាយសាសនាទទួលបានអ្នករៀនថ្មី (សូមមើល “Statement on Missionary Work,” លិខិតមកពីគណៈប្រធានទីមួយ នៅថ្ងៃទី 11 ខែ ធ្នូ ឆ្នាំ2002)។

## ធ្វើការជាមួយនឹងក្រុមប្រឹក្សាវួដ ដើម្បីពង្រឹងសមាជិកថ្មី និងសមាជិកមិនសូវសកម្ម


© 1999 Greg K. Olen. Courtesy Mill Pond Press។ ហាមថតចម្លង។

ការបង្រៀន និងការធ្វើបុណ្យជ្រមុជទឹកឱ្យសាសនាគន់ការី គឺស្ថិតនៅក្រោមការដឹកនាំ របស់ប្រធានបេសកកម្មរបស់អ្នក។ ទោះជាយ៉ាងណាក៏ដោយ កិច្ចការនៃការប្រកាសដំណឹងល្អ នឹងបន្តឆ្ពោះទៅមុខប្រកបដោយអំណាច នៅពេលអ្នកផ្សព្វផ្សាយ សាសនា ពេញម៉ោង និងសមាជិកសម្របសម្រួល ការខិតខំប្រឹងប្រែងរបស់ពួកគេ ហើយធ្វើការជាធ្លុងមួយ។ ជារឿយៗអ្នក ប្រហែលជា ត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងការប្រជុំក្រុមប្រឹក្សាវួដ និងគណៈកម្មាធិការប្រតិបត្តិនៃបព្វជិតភាព។ អាទិភាព តំបូងរបស់អ្នកគឺត្រូវប្រាកដថា សាសនាគន់ការីរបស់អ្នកនៅក្នុងសាសនាចក្រ។ ជាញឹកញាប់នេះ នឹងមានន័យថា អ្នកនឹងទៅ ជាមួយពួកគេ។ បើមានទំនាស់ណាមួយរវាងការចូលរួមក្នុងការប្រជុំក្រុមប្រឹក្សាវួដ និងការនាំនរណាម្នាក់មកព្រះវិហារ ចូរផ្តល់កំណត់ហេតុស្តីពីការរីកចំរើនមួយច្បាប់ ទៅឱ្យអ្នកដឹកនាំបេសកកម្មវួដ ហើយត្រូវអះអាងថា គាត់បានទទួលព័ត៌មានទាំងអស់ ដែលត្រូវការសំរាប់ក្រុមប្រឹក្សាវួដ ឬគណៈកម្មាធិការនៃបព្វជិតភាព។

ប្រធានគរឌិន ប៊ី ហ៊ីងឃ្លី មានប្រសាសន៍ថាៈ

“អ្នកផ្លាស់សាសនាថ្មីគ្រប់ៗរូប ត្រូវការរបស់បីយ៉ាងគឺៈ

“1. មិត្តម្នាក់នៅក្នុងសាសនាចក្រ ដែលគាត់អាចងាកទៅរកជានិច្ច ដែលនឹងជួយគាត់ ដែលនឹងឆ្លើយសំនួររបស់គាត់ ដែលនឹងយល់អំពីបញ្ហារបស់គាត់។

“2. កិច្ចការមួយ។ សកម្មភាព គឺជាការកំណត់អំពីចារិកលក្ខណៈរបស់សាសនាចក្រនេះ។ វាគឺជាដំណើរការ ដែលធ្វើឱ្យយើងរីកចំរើន។ សេចក្តីជំនឿ និងសេចក្តីស្រឡាញ់ចំពោះព្រះអម្ចាស់ គឺដូចជាសាច់ដុំដៃរបស់ខ្ញុំ។ បើសិនជាខ្ញុំប្រើប្រាស់ដៃរបស់ខ្ញុំ នោះនឹងបានរីក ចំរើនខ្លាំងឡើងៗ។ បើសិនជាខ្ញុំ ដាក់ដៃរបស់ខ្ញុំព្យួរចោល នោះដៃរបស់ខ្ញុំនឹងប្រែជាខ្សោយទៅៗ។ គ្រប់អ្នកផ្លាស់សាសនាទាំងអស់សមនឹងបានការទទួលខុសត្រូវមួយ ...។

“3. អ្នកផ្លាស់សាសនាគ្រប់រូប ត្រូវតែបាន ‘បីបាច់ដោយព្រះបន្ទូលដ៏ល្អនៃព្រះ’ (មរ៉ូណៃ 6ៈ4)។ ពួកគេនឹងទៅចូលរួមជាមួយនឹងក្រុមបព្វជិតភាព ឬសមាគមសង្គ្រោះ យុវនារីយុវជន សាលាថ្ងៃអាទិត្យ ឬអង្គការបឋមសិក្សា។ ពួកគេត្រូវតែលើកទឹកចិត្តឱ្យមកចូលរួមការប្រជុំពិធីប្រសិទ្ធិពរនំប៉័ង និងទឹក ដើម្បីទទួលទាននំប៉័ង និងទឹក ដើម្បីរំលឹកសេចក្តីសញ្ញា ដែលបានធ្វើនៅពេលធ្វើពិធីបុណ្យជ្រមុជទឹក” (*Ensign*, ខែឧសភា ឆ្នាំ1999, 106)។

កំណត់ចំណាំ

ក្រុមប្រឹក្សាវួដ នឹងធ្វើការដឹកនាំនៅក្នុងការផ្តល់មិត្ត ការទទួលខុសត្រូវ និងការចិញ្ចឹមបីបាច់ខាងវិញ្ញាណសំរាប់អ្នកផ្លាស់សាសនាថ្មី។ អ្នកនឹងជួយពួកគេដូចបានស្នើរសុំ។ អ្នកដឹកនាំបព្វជិតភាព និងសមាជិក នឹងផ្តល់ការរាក់ទាក់ ព្រមជាមួយនឹងជំនួយរបស់អ្នក។

**មិត្តភាព**



- មុនពេលពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ចូរប្រាកដថា សមាជិកត្រូវមានវត្តមាននៅគ្រប់មេរៀន បើអាចធ្វើបាន។ សមាជិកទាំងនេះ គួរតែនៅជាមួយនឹងសាសនាគន់ការីជារឿយៗ ដើម្បីឆ្លើយសំនួររបស់ពួកគេ យល់អំពីឧបសគ្គរបស់ពួកគេ និងលើកទឹកចិត្តពួកគេ។
- អញ្ជើញសមាជិកឱ្យចូលរួមនៅក្នុងការធ្វើពិធីបុណ្យជ្រមុជទឹក ហើយដើម្បីស្វាគមន៍អ្នកផ្លាស់សាសនាថ្មីចូលមកក្នុងវួដ។ សមាជិកជួយអ្នកផ្លាស់សាសនាថ្មីឱ្យមានអារម្មណ៍សុខសាន្តនៅក្នុងការប្រជុំសាសនាចក្រផ្សេងៗ។ ពួកគេគួរតែត្រូវបានណែនាំ ទៅកាន់សមាជិកផ្សេងទៀតផងដែរ។
- ណែនាំសាសនាគន់ការីទៅកាន់ប៊ីស្សប ទីប្រឹក្សារបស់គាត់ ប្រធានក្រុមអែលឌើរ និងប្រធានសមាគមន៍សង្គ្រោះ និងអ្នកដឹកនាំក្នុងវួដដទៃទៀតឱ្យបានឆាប់បំផុត។ ចូរពន្យល់អំពីតួនាទីរបស់ប៊ីស្សប និងអ្នកដឹកនាំដទៃទៀត។

**ឱកាសដើម្បីបំរើ**

- ជួយអ្នកផ្លាស់សាសនាភេទប្រុសឱ្យយល់ និងរៀបចំដើម្បីទទួលបព្វជិតភាពអើរ៉ុន និងបព្វជិតភាពម៉ិលគីស្សាដែក។ ចូរពន្យល់ថា ក្រុមបព្វជិតភាពផ្តល់ឱកាសដើម្បីរៀន ថ្វាយបង្គំ និងបំរើជាមួយគ្នា។
- ផ្តល់ឱ្យអ្នកផ្លាស់សាសនាថ្មី និងសមាជិកមិនសូវសកម្ម នូវឱកាសដើម្បីបំរើ ដូចជាការជួយដល់ស្ត្រីមេម៉ាយ ឬនរណាម្នាក់ដែលឈឺ ឬចូលរួមនៅក្នុងកម្មវិធីសុខុមាលភាព។
- បញ្ជូនអ្នកផ្លាស់សាសនាថ្មីទៅទីប្រឹក្សាពង្សប្រវត្តិ ដើម្បីឱ្យពួកគេអាចបំពេញនៅក្នុងកំណត់ហេតុក្រុមគ្រួសារ_និងតារាងពង្សាវលី។ បើមានឱកាស សូមជួយពួកគេឱ្យរៀបចំ ដើម្បីធ្វើបុណ្យជ្រមុជទឹកនៅក្នុង ព្រះវិហារបរិសុទ្ធ សំរាប់ជីដូន ជីតារបស់ពួកគេដែលស្លាប់ទៅហើយនោះ។
- អញ្ជើញអ្នកផ្លាស់សាសនាថ្មីឱ្យរៀបចំសមាជិកគ្រួសារ និងមិត្តភក្តិ ដើម្បីឱ្យអ្នកផ្សព្វផ្សាយសាសនាបង្រៀន។ អ្នកផ្សព្វផ្សាយសាសនាគួរតែសុំឱ្យអ្នកផ្លាស់សាសនាថ្មី និងសមាជិកមិនសូវសកម្មផ្តល់អ្នករៀនថ្មីដែលត្រូវទៅជួប។

**ការចិញ្ចឹមបីបាច់ដោយព្រះបន្ទូលនៃព្រះ**

- បញ្ចប់ការបង្រៀនគោលការណ៍នៅក្នុងមេរៀនទី 5 “ច្បាប់ និងពិធីការទាំងឡាយ។”
- រំលឹកដល់អ្នកផ្លាស់សាសនាថ្មី និងសមាជិកមិនសូវសកម្មអំពីការតាំងចិត្តទាំងឡាយ ដែលពួកគេបានធ្វើមុនពេលធ្វើ ពិធីបុណ្យជ្រមុជទឹក និងសេចក្តីសញ្ញាទាំងឡាយ ដែលពួកគេធ្វើ នៅពេលពួកគេទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់។
- លើកទឹកចិត្តពួកគេឱ្យអធិស្ឋានជាប្រចាំជាបុគ្គល និងជាមួយក្រុមគ្រួសាររបស់ពួកគេ។
- លើកទឹកចិត្តពួកគេឱ្យសិក្សាព្រះគម្ពីរជាប្រចាំ ជាពិសេសព្រះគម្ពីរមរមន។
- ពង្រឹងទីបន្ទាល់របស់អ្នកផ្លាស់សាសនា អំពីការស្តារឡើងវិញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ តាមរយៈ ព្យាការីយ៉ូសែប ស្ម៊ីធ។ រំលឹកមេរៀន ដែលអ្នកបង្រៀនសារឡើងវិញ មុនពេលធ្វើពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ សម្រួលការអញ្ជើញឱ្យធ្វើការតាំងចិត្តទៅតាម សេចក្តីត្រូវការបច្ចុប្បន្នរបស់ពួកគេ។
- បន្តបង្រៀនអំពីសារៈសំខាន់ នៃការចូលរួមក្នុងព្រះវិហាររៀងរាល់ថ្ងៃអាទិត្យ និងមានភាពសក្តិសមក្នុងការទទួលទាន ពិធីប្រសិទ្ធិពរនំប៉័ង និងទឹក។ សូមចូលរួម និងអង្គុយជាមួយនឹងអ្នកផ្លាស់សាសនាថ្មី ឬសមាជិកមិនសូវសកម្ម។
- អញ្ជើញពួកគេឱ្យចូលរួមក្នុងថ្នាក់គោលការណ៍ដំណឹងល្អ អំឡុងពេលថ្នាក់សាលាថ្ងៃអាទិត្យ។
- បង្រៀនពួកគេអំពីរបៀប ដើម្បីធ្វើរាត្រីជួបជុំក្រុមគ្រួសារនៅយប់ថ្ងៃច័ន្ទ ដោយប្រើ *Family Home Evening Resource Book*។

កំណត់ចំណាំ

- លើកទឹកចិត្តពួកគេឱ្យចែកចាយដំណឹងល្អ ដែលបានស្តារឡើងវិញជាមួយនឹងអ្នកដទៃ។
- ជួយពួកគេចុះឈ្មោះនៅក្នុងថ្នាក់សិក្ខាសាលា ឬថ្នាក់វិទ្យាស្ថាន។
- ឱ្យពួកគេដឹងអំពីធនធានរបស់សាសនាចក្រដូចជា www.mormon.org, www.lds.org, និង www.familysearch.org។

## ការសិក្សាព្រះគម្ពីរ

**ចិញ្ចឹមបីបាច់ដោយព្រះបន្ទូលនៃព្រះ**

| | | |
|---|---|---|
| ម៉ូសាយ 18:18–20 | អាលម៉ា 31:5 | មូរ៉ូណៃ 6:4 |

**ការបំរើ**

| | | |
|---|---|---|
| ម៉ូសាយ 2:17 | ម៉ាថាយ 25:40 | Guide to the Scriptures, “Service” |

## តើប្រធានបេសកកម្ម មានតួនាទីអ្វីខ្លះ?

ប្រធានបេសកកម្ម កាន់កូនសោសំរាប់ពិធីបុណ្យជ្រមុជទឹករបស់អ្នកផ្លាស់សាសនាថ្មី។ ក្រោមការដឹកនាំរបស់គាត់ អ្នកផ្សព្វផ្សាយសាសនាពេញម៉ោង មានការទទួលខុសត្រូវសំខាន់ក្នុងការបង្រៀនសាសនាគន់ការី។ ទោះជាយ៉ាងណាក៏ដោយ ប៊ីស្សបត្រួតពិនិត្យមើល ការរីកចំរើន និងការរាក់ទាក់របស់សាសនាគន់ការី ដូចដែលពួកគេត្រូវបានបង្រៀន។ ផែនការ បេសកកម្មវួដ ត្រូវបានអនុវត្តក្រោមអ្នកដឹកនាំជាអធិបតី នៃប៊ីស្សប។ ប្រធានបេសកកម្មជួបជាមួយនឹងប្រធានស្តេកជាទៀងទាត់ ដើម្បីប្រាកដថាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង សហការជាមួយនឹងអ្នកដឹកនាំបព្វជិតភាពក្នុងតំបន់។ គាត់សម្របសម្រួលក្នុង កិច្ចខំប្រឹងប្រែងផ្សព្វផ្សាយ ហើយស្នើរសុំជួយដល់ប្រធានស្តេកដោយផ្តល់ការណែនាំនៅក្នុងគោលការណ៍ទាំងឡាយ និងការអនុវត្ត កិច្ចការផ្សព្វផ្សាយសាសនា។

## តើអ្នកដឹកនាំស្តេក និងវួដ មានការទទួលខុសត្រូវអ្វីខ្លះ?

អ្នកដឹកនាំ និងសមាជិកសាសនាចក្រប្រចាំតំបន់ គឺជាសម្ព័ន្ធមិត្តដ៏ល្អបំផុតរបស់អ្នក។ ចូរគោរពពួកគេ ហើយព្យាយាមបង្កើតទំនាក់ទំនងល្អជាមួយគ្នា។ នៅពេលអ្នកធ្វើកិច្ចការជាមួយអ្នកដឹកនាំទាំងនេះ ចូរចងចាំថា ពួកគេមានការទទួលខុសត្រូវ ផ្សេងទៀតដែលទាក់ទងជាមួយនឹងមុខងាររបស់ពួកគេ។ ចូរព្យាយាមធ្វើជាពរជ័យមួយ ដែលមិនមែនជាបន្ទុក ចំពោះអ្នកដឹកនាំ នៅក្នុងស្តេក និងវួដរបស់អ្នក។ អាកប្បកិរិយារបស់អ្នក គួរតែជាផ្នែកមួយនៃការប្រឹក្សាជាមួយនឹងប៊ីស្សប និងអ្នកដឹកនាំក្នុងវួដ “តើពួកយើងអាចជួយដោយរបៀបណា?” អំពីផែនការ និងសកម្មភាពរបស់អ្នក។ ចូរឱ្យប្រាកដថា អ្វីដែលអ្នកធ្វើគាំទ្រដល់វួដ និងផែនការរបស់បេសកកម្ម។

តួនាទីនៃការដឹកនាំបព្វជិតភាពប្រចាំតំបន់ ស្តីអំពីកិច្ចការអ្នកផ្សព្វផ្សាយសាសនា ត្រូវបានពិពណ៌នានៅខាងក្រោម។ ការយល់ដឹងអំពីតួនាទីទាំងឡាយរបស់ពួកគេ នឹងជួយអ្នកធ្វើការជាមួយពួកគេកាន់តែប្រសើរឡើង។

### ប្រធានស្តេក

ប្រធានស្តេកមើលខុសត្រូវលើប៊ីស្សប នៅក្នុងភារកិច្ចការផ្សព្វផ្សាយសាសនា ការថែរក្សា និងការធ្វើឱ្យសកម្មឡើងវិញ របស់ពួកគេ។ នៅក្នុងការសម្ភាសន៍ប្រចាំខែ ជាមួយប៊ីស្សប គាត់ពិភាក្សាអំពីផែនការ និងការរីកចំរើនរបស់សាសនាគន់ការី និងសមាជិកជាក់លាក់។ គាត់ត្រូវឱ្យប្រាកដថា គោលលទ្ធិមានទាក់ទងនឹងកិច្ចការផ្សព្វផ្សាយសាសនា ត្រូវបានបង្រៀន ជាទៀងទាត់នៅក្នុងការប្រជុំស្តេក និងវួដ ហើយថាអ្នកដឹកនាំបព្វជិតភាព និងអ្នកផ្សេងទៀត ត្រូវបានហ្វឹកហ្វឺននៅក្នុងភារកិច្ច អ្នកផ្សព្វផ្សាយសាសនា របស់ពួកគេ។

ប្រធានស្តេកក៏ជួបជាទៀងទាត់ជាមួយនឹងប្រធានបេសកកម្មផងដែរ ដើម្បីសម្របសម្រួលការខិតខំរបស់អ្នកផ្សព្វផ្សាយសាសនា រួមមាននូវការហ្វឹកហ្វឺននៃអ្នកដឹកនាំ និងសមាជិក ដើម្បីប្រើប្រាស់ និងជំនួសអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង និងជំនួយនៅក្នុងកម្លាំងធ្វើឱ្យសកម្មឡើងវិញ។

### ទីប្រឹក្សាជាន់ខ្ពស់

ទីប្រឹក្សាជាន់ខ្ពស់ម្នាក់ត្រូវបានចាត់ដោយគណៈប្រធានស្តេក ដើម្បីផ្សាយកិច្ចការអ្នកផ្សព្វផ្សាយសាសនា ការថែរក្សា និងការធ្វើឱ្យសកម្មឡើងវិញនៅក្នុងស្តេក។ គាត់រាយការណ៍ជាប្រចាំអំពីការរីកចំរើននៃកិច្ចការនេះទៅឱ្យគណៈប្រធានស្តេក។ គាត់ត្រូវឱ្យប្រាកដថាអ្នកដឹកនាំបេសកកម្មក្នុងវួដ ត្រូវបានហ្វឹកហ្វឺនត្រឹមត្រូវនៅក្នុងកាតព្វកិច្ចរបស់ពួកគេ រួមមានទាំងការរៀបចំ ផែនការបេសកកម្មនៅក្នុងវួដ។

កំណត់ចំណាំ

## ប៊ីស្សប



ប៊ីស្សបមានការទទួលខុសត្រូវចំពោះកម្លាំងផ្សព្វផ្សាយសាសនា និងការថែទាំ និងការធ្វើឱ្យសកម្មឡើងវិញនៅក្នុងវួដ។ ការចូលរួមរបស់គាត់ដោយផ្ទាល់ និងជាអ្នកដឹកនាំ មានសារៈសំខាន់ណាស់។ ដើម្បីជួយសំរេចកិច្ចការនេះ ប៊ីស្សប ហៅអ្នកកាន់បព្វជិតភាពមិលគីស្សាដែក ដែលមានភាពសក្តិសមម្នាក់ឱ្យបំរើជាអ្នកដឹកនាំបេសកកម្មក្នុងវួដ។ គាត់ក៏ហៅ អ្នកផ្សព្វផ្សាយសាសនាក្នុងវួដ ឱ្យមានចំនួនមួយគ្រប់គ្រាន់ ដើម្បីបំពេញតាមសេចក្តីត្រូវការនៅក្នុងវួដផងដែរ។

ប៊ីស្សបប្រើប្រាស់គណៈកម្មាធិការប្រតិបត្តិនៃបព្វជិតភាព និងក្រុមប្រឹក្សាវួដ ដើម្បីសម្របសម្រួលកិច្ចខំប្រឹងប្រែងក្នុងកិច្ចការផ្សព្វផ្សាយសាសនា ការថែទាំ និងការធ្វើឱ្យសកម្មឡើងវិញ។ គាត់ផ្តល់ការណែនាំដើម្បីអភិវឌ្ឍន៍ និងដាក់ចេញ ផែនការ បេសកកម្ម ក្នុងវួដ។

### សកម្មភាពៈ ការសិក្សាជាមួយដៃគូ

រៀបចំពេលវេលាមួយ ដើម្បីជួបជាមួយប៊ីស្សប។ ស្វែងរកការណែនាំរបស់គាត់ តើអ្នកអាចបំរើឱ្យល្អបំផុតនៅក្នុងវួដបាន ដោយរបៀបណា។

## អ្នកដឹកនាំបព្វជិតភាព និងអង្គការជំនួយ

អ្នកដឹកនាំបព្វជិតភាព និងអង្គការជំនួយ គួរតែរំលឹកជាទៀងទាត់អំពីឋានៈរបស់សមាជិកថ្មី សមាជិកមិនសូវសកម្ម ហើយធ្វើផែនការដើម្បីមានការរាក់ទាក់ និងពង្រឹងពួកគេឱ្យបានល្អបំផុត។ ពួកគេគួរតែធ្វើការជិតស្និទជាមួយនឹងអ្នកដឹកនាំ បេសកកម្មវួដផងដែរ ដើម្បីសម្របសម្រួលជាមួយនឹងការខិតខំផ្សព្វផ្សាយសាសនា ការថែទាំ និងការធ្វើឱ្យសកម្មឡើង វិញជាមួយនឹងអ្នកផ្សព្វផ្សាយសាសនាក្នុងវួដ និងអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង។

## អ្នកដឹកនាំបេសកកម្មវួដ

នៅក្រោមការដឹកនាំរបស់ប៊ីស្សប អ្នកដឹកនាំបេសកកម្មវួដៈ

- ធ្វើជាគំរូនៅក្នុងការចែកចាយដំណឹងល្អជាមួយអ្នកដទៃ និងរាក់ទាក់សាសនាគន់ការី អ្នកផ្លាស់សាសនាថ្មី និងសមាជិកមិនសូវសកម្ម។
- សម្របសម្រួលកិច្ចការអ្នកផ្សព្វផ្សាយសាសនាក្នុងវួដ និងអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងជាមួយ អ្នកដឹកនាំបព្វជិតភាព អ្នកដឹកនាំអង្គការជំនួយ និងសមាជិកទាំងឡាយ។
- ប្រើប្រាស់កំណត់ហេតុស្តីពីការរីកចំរើន និងបញ្ជីសកម្មភាពរបស់អ្នកផ្លាស់សាសនាថ្មី និងបញ្ជីសកម្មភាព និងការសម្ភាសន៍របស់គណៈប៊ីស្សប ដើម្បីរំលឹកអំពីការរីកចំរើនរបស់សាសនាគន់ការី អ្នកផ្លាស់សាសនាថ្មី និងសមាជិកមិន សូវសកម្មនៅក្នុងការប្រជុំគណៈកម្មាធិការប្រតិបត្តិបព្វជិតភាព និងក្រុមប្រឹក្សាវួដ។ បញ្ជីសកម្មភាពរបស់អ្នកផ្លាស់សាសនាថ្មី និងបញ្ជីសកម្មភាព និងការសម្ភាសន៍របស់គណៈប៊ីស្សប ត្រូវបានបង្កើតជារបាយការណ៍ឡើងដើម្បីប្រើប្រាស់កំព្យូទ័រសាលាប្រជុំក្នុងវួដ។ វាត្រូវប្រើដើម្បីកត់ត្រាការរីកចំរើនរបស់អ្នកផ្លាស់សាសនាថ្មី និងសមាជិកដទៃទៀត។
- ដឹកនាំការប្រជុំសម្របសម្រួលអ្នកផ្សព្វផ្សាយសាសនារាល់សប្តាហ៍។
- រៀបចំការធ្វើពិធីបុណ្យជ្រមុជទឹកអ្នកផ្លាស់សាសនានៅក្នុងវួដ នៅក្នុងការសហប្រតិបត្តិការជាមួយអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង។ សមាជិកម្នាក់ពីគណៈប៊ីស្សប ឬអ្នកដឹកនាំបេសកកម្មវួដ ជាធម្មតាដឹកនាំពិធីទាំងនេះ។

អ្នកដឹកនាំបេសកកម្មវួដ ក៏បំរើនៅក្នុងគណៈកម្មាធិការប្រតិបត្តិនៃបព្វជិតភាព ក្រុមប្រឹក្សាវួដ និងផងដែរគណៈកម្មាធិការ សុខុមាលភាព និងចូលរួមក្នុងការប្រជុំការដឹកនាំបព្វជិតភាពស្តេក។

## អ្នកផ្សព្វផ្សាយសាសនាក្នុងវួដ

បងប្អូនប្រុសស្រីណា ដែលមានគុណសម្បត្តិគ្រប់គ្រាន់ ត្រូវបានហៅឱ្យបំរើជាអ្នកផ្សព្វផ្សាយសាសនាក្នុងវួដ។ ពួកគេត្រូវគ្រប់គ្រងដោយអ្នកដឹកនាំបេសកកម្មវួដ។

អ្នកផ្សព្វផ្សាយសាសនាក្នុងវួដ ស្វែងរក រាក់ទាក់ និងបង្រៀនសាសនាគន់ការី។ ពួកគេក៏បង្រៀន និងរាប់អានអ្នកផ្លាស់សាសនាថ្មី និងសមាជិកមិនសូវសកម្មផងដែរ។

អ្នកផ្សព្វផ្សាយសាសនាវួដម្នាក់ ដែលកាន់បព្វជិតភាពម៉ិលគីស្សាដែក អាចត្រូវបានហៅឱ្យបំរើជាអ្នកជំនួយការរបស់អ្នកដឹកនាំបេសកកម្មវួដ។

## ការសម្របសម្រួលអ្នកផ្សព្វផ្សាយសាសនា

កិច្ចការអ្នកផ្សព្វផ្សាយសាសនាក្នុងវួដ ជាធម្មតាត្រូវបានសម្របសម្រួលនៅក្នុងការប្រជុំគណៈកម្មាធិការប្រតិបត្តិនៃបព្វជិតភាព និងក្រុមប្រឹក្សាវួដ តាមរយៈការប្រើកំណត់ហេតុស្តីពីការរីកចំរើន ដែលបានផ្តល់ឱ្យដោយអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង។ គោលបំណង របស់អ្នកផ្សព្វផ្សាយសាសនាក្នុងការប្រជុំទាំងនេះ គឺដើម្បីរាយការណ៍ ធ្វើផែនការ និងសម្របសម្រួល ការចាត់តាំងដើម្បីស្វែងរក បង្រៀន រាក់ទាក់ និងធ្វើឱ្យសកម្មឡើងវិញដូចមានគ្រោងនៅក្នុងកថាខ័ណ្ឌខាងក្រោមនេះ។

*ការស្វែងរកមនុស្សបង្រៀន។* គណៈកម្មាធិការប្រតិបត្តិនៃបព្វជិតភាព និងក្រុមប្រឹក្សាវួដ ពិភាក្សាអំពីផែនការសំរាប់ ការរៀបចំមនុស្សជាក់លាក់ឱ្យបង្រៀនដោយអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង។ ពួកគេពិភាក្សាអំពីការរីកចំរើនរបស់សមាជិក វួដជាក់លាក់នៅក្នុងការរៀបចំបុគ្គលម្នាក់ៗ និងក្រុមគ្រួសារសំរាប់មេរៀនអ្នកផ្សព្វផ្សាយសាសនា។

*ការបង្រៀន និងការជ្រមុជទឹក។* គណៈកម្មាធិការប្រតិបត្តិនៃបព្វជិតភាព និងក្រុមប្រឹក្សាវួដរំលឹក អំពីកំណត់ហេតុ ស្តីពីការរីកចំរើនរាល់សប្តាហ៍ ដែលពិពណ៌នាអំពីការរីកចំរើនរបស់មនុស្សម្នាក់ៗ ដែលបានបង្រៀនដោយអ្នកផ្សព្វផ្សាយ សាសនាពេញម៉ោង។ ពួកគេធ្វើផែនការសម្របសម្រួលផងដែរ សំរាប់ការបង្រៀននៅក្នុងផ្ទះសមាជិក ការរាក់ទាក់សាសនាគន់ការី នឹងជំរុញឱ្យសមាជិកចូលរួមនៅក្នុងការធ្វើពិធីបុណ្យជ្រមុជទឹក។

*ការរាក់ទាក់ និងការបង្រៀនសមាជិកថ្មី។* គណៈកម្មាធិការប្រតិបត្តិនៃបព្វជិតភាព និងក្រុមប្រឹក្សាវួដរំលឹកបញ្ជីសកម្មភាព អ្នកផ្លាស់សាសនា ដើម្បីត្រួតពិនិត្យលើការរីកចំរើនរបស់សមាជិកថ្មីម្នាក់ៗ។ ពួកគេពិភាក្សាអំពីរបៀបដើម្បីរាក់ទាក់សមាជិកថ្មីផងដែរ។ ដូចបានស្នើរសុំដោយប៊ីស្សប ពួកគេធ្វើអនុសាសន៍លើមុខងារសក្តានុពល សំរាប់អ្នកផ្លាស់សាសនាថ្មី។

*ការរាក់ទាក់ និងការបង្រៀនសមាជិកមិនសូវសកម្ម។* គណៈកម្មាធិការប្រតិបត្តិនៃបព្វជិតភាព និងក្រុមប្រឹក្សាវួដ សម្របសម្រួលកម្លាំងនៃការធ្វើឱ្យសកម្មឡើងវិញរបស់ក្រុមបព្វជិតភាព និងអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង។ ពួកគេធ្វើផែនការអំពីរបៀប ដើម្បីរាក់ទាក់សមាជិកមិនសូវសកម្មផងដែរ ជាពិសេសដោយការអញ្ជើញពួកគេមក ការប្រជុំ និងសកម្មភាពរបស់សាសនាចក្រ។

## ការសម្របសម្រួលបន្ថែមជាមួយអ្នកដឹកនាំបេសកកម្មវួដ

កិច្ចការផ្សព្វផ្សាយសាសនានៅក្នុងវួដ ជាធម្មតាត្រូវបានសម្របសម្រួល នៅក្នុងការប្រជុំគណៈកម្មាធិការប្រតិបត្តិនៃបព្វជិតភាព និងក្រុមប្រឹក្សាវួដ។ បើសិនជាមានការសម្របសម្រួលចាំបាច់បន្ថែម អ្នកដឹកនាំបេសកកម្មវួដ អាចមានការប្រជុំសម្របសម្រួលអ្នកផ្សព្វផ្សាយសាសនាវួដជាមួយនឹង អ្នកផ្សព្វផ្សាយសាសនាពេញម៉ោង។ អ្នកផ្សេងទៀតអាចត្រូវបានអញ្ជើញឱ្យចូលរួម នៅក្នុងការប្រជុំនេះ រួមមានអ្នកផ្សព្វផ្សាយសាសនាក្នុងវួដ អ្នកជំនួយការម្នាក់មកពីក្រុមការដឹកនាំសង្ឃជាន់ខ្ពស់ ទីប្រឹក្សាម្នាក់មកពីគណៈប្រធានក្រុមអែលឌើរ និងទីប្រឹក្សាម្នាក់មកពីគណៈប្រធានសមាគមសង្គ្រោះ។

អ្នកទាំងឡាយណា ដែលចូលរួមនៅក្នុងការប្រជុំអាចត្រូវរំលឹក និងរាយការណ៍អំពីកិច្ចការ និងគោលដៅមកពីការប្រជុំកាលពីមុន ហើយពិភាក្សាអំពីផែនការសំរាប់សប្តាហ៍ក្រោយ។ នៅពេលចាំបាច់ ពួកគេអាចសម្របសម្រួលកិច្ចការរបស់អ្នកផ្សព្វផ្សាយសាសនាក្នុងវួដទៅនឹងកិច្ចការជាមួយអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងផងដែរ និងពិភាក្សាអំពីរបៀបដើម្បី ប្រមូលកម្លាំងរបស់អ្នកផ្សព្វផ្សាយសាសនាក្នុងវួដជាមួយនឹងអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងឱ្យកាន់តែមានប្រសិទ្ធិភាព។

## ផែនការបេសកកម្មវួដ

វួដជាច្រើនបានរកឃើញថា ការអភិវឌ្ឍន៍ផែនការបេសកកម្មវួដមួយជួយលើកកំពស់ កិច្ចការអ្នកផ្សព្វផ្សាយសាសនាក្នុងវួដ។ ផែនការដូច្នេះ អាចរាប់បញ្ចូលទាំងគោលដៅ ផ្តើមគំនិត និងសកម្មភាពទាំងឡាយ ដើម្បីជួយសមាជិកវួដអញ្ជើញមនុស្ស

កំណត់ចំណាំ

ឱ្យស្តាប់ដំណឹងល្អ។ បុគ្គលម្នាក់ៗ និងក្រុមគ្រួសារក៏ជាអត្ថប្រយោជន៍មកពីការអភិវឌ្ឍន៍ ផែនការដូច្នេះផងដែរ ដើម្បីណែនាំដល់កម្លាំងអ្នកផ្សព្វផ្សាយសាសនារបស់ពួកគេ។

សមាជិកគួរតែប្រើប្រាស់វាល់មធ្យោបាយដោយថ្លៃថ្នូរ ដើម្បីស្វែងរកមនុស្ស ដែលមានបំណងស្តាប់សារលិខិត នៃការស្តារឡើងវិញ។ ពួកគេគួរតែសង្កត់ធ្ងន់លើការស្វែងរកឪពុក ម្តាយ និងកូនៗ ដែលនឹងមកសាសនាចក្រជាក្រុមគ្រួសារ។ នៅខាងក្រោមនេះគឺជាយោបល់ខ្លះៗ ដើម្បីពិចារណានៅក្នុងការអភិវឌ្ឍន៍ផែនការ បេសកកម្មមួយ។

- អធិស្ឋានសូម ព្រះអម្ចាស់ជួយរៀបចំដួងចិត្តមនុស្សជាក់លាក់ ដើម្បីស្តាប់ដំណឹងល្អ។ អធិស្ឋានដើម្បីអោយបានដឹង អំពីជនទាំងឡាយណា ដែលទ្រង់កំពុងតែរៀបចំផងដែរ (សូមមើលអាលម៉ា 6:6)។ “វានឹងក្លាយទៅជាថ្ងៃដ៏អស្ចារ្យ” បង្រៀនដោយប្រធានគរឌឹន ប៊ី ហ៊ីងឃ្លី “នៅពេលប្រជាជនរបស់យើង មិនត្រឹមតែអធិស្ឋាន សំរាប់អ្នកផ្សព្វផ្សាយសាសនា ទូទាំងពិភពលោកប៉ុណ្ណោះ ប៉ុន្តែបានសុំដល់ព្រះអម្ចាស់ឱ្យជួយដល់ពួកគេ ដើម្បីជួយ អ្នកផ្សព្វផ្សាយសាសនា ដែលកំពុងតែធ្វើការនៅក្នុងវួដរបស់ពួកគេផ្ទាល់ទៀតផង” (“Missionary Service,” *First Worldwide Leadership Training Meeting,* ខែមករា ឆ្នាំ2003, 19)។
- ត្រូវដឹងឱកាស ដើម្បីប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ។ ត្រូវធ្វើជាអ្នកជិតខាង ហើយប្រាស្រ័យទាក់ទងគ្នា ដោយសេចក្តីស្រឡាញ់ចំពោះមនុស្សគ្រប់រូប។
- សុំឱ្យមិត្តភក្តិ និងអ្នកជិតខាងបំរើដោយជិតស្និទ ជាមួយសមាជិក ដូចជា ការផ្តល់សេវាកម្មក្នុងសហគមន៍ ការផ្តល់អាហារដល់អ្នកក្រីក្រ ការបង្រៀនថ្នាក់តូចៗនៅក្នុងការប្រជុំកែលំអ ក្នុងសមាគមន៍សង្គ្រោះ ការជួយសកម្មភាពក្នុងវួដ ការជួយដល់មនុស្សផ្លាស់លំនៅ ការធ្វើការនៅក្នុងក្រុមកាយរិទ្ធ និងការជួយក្នុងពង្សប្រវត្តិ ឬគម្រោង សុខុមាលភាពនានា។
- អញ្ជើញសាច់ញាតិដែលមិនមែនជាសមាជិក មិត្តភក្តិ និងអ្នកជិតខាងឱ្យចូលរួមនៅក្នុងពិធីបុណ្យជ្រមុជទឹក ពិធីបញ្ជាក់ និងពិធីការបព្វជិតភាពផ្សេងៗ។
- អញ្ជើញអ្នកដែលមិនមែនជាសមាជិកឱ្យជួយនៅក្នុងព្រឹត្តិការណ៍ពិសេសៗ ដូចជាការញាំុអាហារពេលព្រឹក នៅថ្ងៃបុណ្យជាតិមួយជាដើម។
- បង្កើតការប្រជុំក្នុងវួដ សកម្មភាព ការប្រជុំពិសេស និងពិធីសម្ពោធន៍ ដែលប្រកបដោយគុណភាព និងគួរឱ្យចាប់អារម្មណ៍ ដែលសមាជិកចង់អញ្ជើញមនុស្ស ដែលពួកគេស្គាល់អោយមកចូលរួម។
- អញ្ជើញមនុស្សឱ្យចូលរួមនៅក្នុងការប្រជុំរាត្រីជួបជុំក្រុមគ្រួសារ។
- សួរសុខទុក្ខមនុស្ស ដែលកំពុងតែមានបទពិសោធន៏នៃការផ្លាស់ប្តូរនៅក្នុងជីវិតរបស់ពួកគេ ដូចជាអាពាហ៍ពិពាហ៍ ការចាប់កំណើត ឬក៏ការស្លាប់ជាដើម។
- សួរសុខទុក្ខ ហើយជួយមនុស្ស ដែលផ្លាស់ប្តូរលំនៅមកជាអ្នកជិតខាងខ្លួន។ ចែកចាយពត៌មានអំពីសមាគមន៍ អ្នកជិតខាង និងសាសនាចក្រ។
- ឆ្លៀតគ្រប់ឱកាស ដើម្បីនិយាយអំពីដំណឹងល្អ។ ពិភាក្សាអំពីប្រធានបទដូចជា ព្រះអង្គសង្គ្រោះ ព្រះគម្ពីរមរមន ព្រះគម្ពីរបរិសុទ្ធគោលបំណងនៃជីវិតនេះ គ្រួសារ និងពង្សប្រវត្តិ។
- លើកទឹកចិត្តដល់យុវវ័យឱ្យមានការរាក់ទាក់ជាមួយនឹងយុវវ័យផ្សេងទៀត ហើយអញ្ជើញពួកចូលរួម ការប្រជុំសាសនាចក្រ និងសកម្មភាពទាំងឡាយ។
- ធ្វើការជាមួយនឹងអ្នកដែលជាសមាជិកក្នុងគ្រួសារតែម្នាក់ឯង។
- ធ្វើផែនការការប្រជុំពិធីប្រសិទ្ធិពរទំប៉ុង និងទឹកដែលលើកតំកើងខាងវិញ្ញាណ។

### សកម្មភាពៈ ការសិក្សាជាមួយដៃគូ

- ជាមួយនឹងដៃគូរបស់អ្នក ចូរអាន និងពិភាក្សានៅទំព័រ 34–37 នៃ *True to the Faith,* “Church Administration.”
- ចែកចាយជាមួយដៃគូរបស់អ្នក ហើយសរសេរនៅក្នុងសៀវភៅកត់ត្រាការសិក្សារបស់អ្នក អំពីអ្វី ដែលអ្នកបានរៀន។
- ពិភាក្សាអំពីអារម្មណ៍ក្នុងចិត្តរបស់អ្នក ដែលនឹងមានឥទ្ធិពលលើរបៀប ដែលអ្នកបង្ហាញការងាររបស់អ្នក ជាមួយនឹងអ្នកដឹកនាំសាសនាចក្រ។

កំណត់ចំណាំ

## ការតាំងចិត្ត ដើម្បីទៅតែសកម្មនៅក្នុងសាសនាចក្រ

កិច្ចការអ្នកផ្សព្វផ្សាយសាសនា មានឥទ្ធិពលយ៉ាងខ្លាំងបំផុត នៅពេលមនុស្សធ្វើ និងរក្សាការតាំងចិត្ត ដើម្បីនៅសកម្មនៅក្នុងសាសនាចក្រ អស់មួយជីវិត។ វាមិនគ្រប់គ្រាន់ទេ ដែលគ្រាន់តែមកសាសនាចក្រប៉ុណ្ណោះដោយធម្មតា។ ពួកគេត្រូវតែ មកហើយនៅសកម្មក្នុងសាសនាចក្រ។ រាល់ការបង្រៀន និងការអញ្ជើញទាំងអស់របស់អ្នក ត្រូវតែបែរឆ្ពោះត្រង់ទៅរកទីបញ្ចប់នេះ។ ដើម្បីទទួលរាល់ពរជ័យទាំងអស់ ដែលព្រះវរបិតាសួគ៌របស់យើងមាននៅក្នុងឃ្លាំងសំរាប់ពួកគេ សមាជិកត្រូវតែបន្តរស់នៅតាមដំណឹងល្អ ហើយសកម្មនៅក្នុងសាសនាចក្រ។

នីហ្វៃបានបង្រៀនថា៖ "ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ បន្ទាប់ពីអ្នកបានចូលតាមផ្លូវតូច ហើយចង្អៀតនេះ ហើយខ្ញុំសូមសួរថា តើអ្នកបានធ្វើសព្វគ្រប់អស់ហើយឬអី? មើលចុះ ខ្ញុំសូមនិយាយទៅកាន់អ្នកថា៖ ទេ…អ្នករាល់គ្នាត្រូវតែឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ…ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត មើលចុះនោះព្រះវរបិតា ទ្រង់មានព្រះបន្ទូលថា៖ អ្នករាល់គ្នានឹងមានជីវិតដ៏នៅអស់កល្បជានិច្ច" (នីហ្វៃទី2 31:19–20)។

សូមផ្តល់ការប្រឹងប្រែងដ៏ខ្ពស់បំផុតដើម្បីជួយមនុស្សស័ក្តិសមសំរាប់ជីវិតដ៏អស់កល្បជានិច្ច ដែលជាអំណោយទានដ៏ធំបំផុតមួយក្នុងចំណោមអំណោយទានទាំងអស់នៃព្រះ (សូមមើលគ និង ស 14:7)។

### ចូរចងចាំចំណុចនេះ

- សាងទំនាក់ទំនងឱ្យរឹងមាំជាមួយនឹងប៊ីស្សប និងសមាជិកនៃក្រុមប្រឹក្សាក្នុងវួដ។
- ចូលរួមដោយរបៀបសមរម្យ អំឡុងពេលមានការប្រជុំគណៈកម្មាធិការប្រតិបត្តិនៃបព្វជិតភាព និងក្រុមប្រឹក្សាវួដ។
- ត្រូវបំរើដល់ក្រុមប្រឹក្សាក្នុងវួដ។ នៅពេលសមាជិកនៃក្រុមប្រឹក្សាសុំជំនួយពីអ្នក៖
  - ត្រូវមានឆន្ទះ ដើម្បីរាក់ទាក់អ្នកផ្លាស់សាសនា និងសមាជិកមិនសូវសកម្ម ជួយពួកគេនៅក្នុងមុខងាររបស់ពួកគេ និងឱកាសបំរើទាំងឡាយ និងបង្រៀនមេរៀនអ្នកផ្សព្វផ្សាយសាសនាសារឡើងវិញ។
  - ជាមួយនឹងសមាជិក ចូរបង្រៀនអ្នកផ្លាស់សាសនាថ្មីនូវមេរៀន "ច្បាប់ និងពិធីការទាំងឡាយ។"

កំណត់ចំណាំ

## គំនិតសំរាប់ការសិក្សា និងការអនុវត្ត

### ការសិក្សាផ្ទាល់ខ្លួន

- ប្រើប្រាស់កាលវិភាគប្រចាំថ្ងៃរបស់អ្នក ចូរបង្កើតផែនការ ដើម្បីនិយាយជាមួយនឹងអ្នកផ្លាស់ប្រែគំនិតថ្មី និងសមាជិកដែលសកម្មឡើងវិញថ្មីៗអំពីការផ្លាស់ប្តូរជីវិតរបស់ពួកគេ និងការចូលរួមនៅក្នុងសាសនាចក្រ។ តើអ្វីខ្លះ ដែលបានជួយពួកគេប្រសើរបំផុត? នៅក្នុងសៀវភៅកត់ត្រាក្នុងការសិក្សារបស់អ្នក ចូរសរសេរគំនិតរបស់អ្នកអំពី បទពិសោធន៍របស់ពួកគេ។ តើអ្នកបានរៀនអ្វីខ្លះ ដែលនឹងជួយអ្នកឱ្យធ្វើការជាមួយនឹងសាសនាគន់ការីថ្មីរបស់អ្នក?

- សិក្សានីហ្វៃទី2 31:18–20, អាលម៉ា 26:1–7 និង32:32–42, និងម៉ូរ៉ូណៃ 6។ ចូរសរសេរអ្វី ដែលអ្នកបានរៀនមកពីខគម្ពីរទាំងនេះ អំពីការពង្រឹងដល់អ្នកផ្លាស់សាសនាថ្មី។

### ការសិក្សាជាមួយដៃគូ

- អំឡុងពេលការប្រជុំក្រុមប្រឹក្សាវួដ ចូរសួរដល់ប៊ីស្សប បើសិនជាមានសមាជិកមិនសូវសកម្មនៅក្នុងតំបន់របស់អ្នក ដែលគាត់ចង់អោយអ្នកទៅសួរសុខទុក្ខនៅក្នុងសប្តាហ៍នេះ។ នៅពេលអ្នកសួរសុខទុក្ខសមាជិកមិនសូវសកម្មទាំងនេះ ចូរស្វែងរកសាងជំនឿរបស់ពួកគេនៅក្នុងព្រះយេស៊ូវគ្រីស្ទ។ សូមសួររកអ្នករៀនថ្មីដែលត្រូវទៅជួបពីពួកគេ។

- ចូរសិក្សាកូរិនថូសទី1 3:2, ហេព្រើរ 5: 12 និងគោលលទ្ធិ និងសេចក្តីសញ្ញា 19:22។ តើទឹកដោះដែលបានសំដៅទៅលើនោះជាអ្វី? តើអ្វីទៅជាអាហារ? ចូរប្រៀបធៀបចំលើយរបស់អ្នកជាមួយនឹងគោលលទ្ធិនៅក្នុង ជំពូក "តើខ្ញុំត្រូវសិក្សានិងបង្រៀនអំពីអ្វី?" តើហេតុអ្វីអ្នកត្រូវតែផ្តល់ទឹកដោះ និងអាហារនៅពេលត្រឹមត្រូវ ហើយមានចំនួនត្រឹមត្រូវ? តើអ្នកអាចធ្វើយ៉ាងនោះបានដោយរបៀបណា?

- សូមអានពាក្យស្រង់នៅខាងក្រោមនេះ ដែលប្រធានយ៉ូសែប អែហ្វ ស្ម៊ីធ ពិពណ៌នាអំពីអារម្មណ៍របស់គាត់នៅគ្រាដែលគាត់ធ្វើពិធីបុណ្យជ្រមុជទឹកៈ

  "អារម្មណ៍ដែលមានមកលើខ្ញុំនោះ គឺជាអារម្មណ៍នៃសេចក្តីសុខសាន្តដ៏បរិសុទ្ធ នៃសេចក្តីស្រឡាញ់ និងពន្លឺ។ ខ្ញុំដឹងនៅក្នុងព្រលឹងរបស់ខ្ញុំថា បើខ្ញុំមានអំពើបាប—ហើយប្រាកដណាស់ខ្ញុំមិនមែនឥតមានអំពើបាបនោះទេ—ពិធី បុណ្យជ្រមុជទឹកបានអភ័យបាបដល់ខ្ញុំ ដែលខ្ញុំបានជ្រះស្អាតដោយពិតពីបាប ដួងចិត្តរបស់ខ្ញុំត្រូវបានជ្រាបចូល ហើយខ្ញុំទទួល អារម្មណ៍ថា ខ្ញុំនឹងមិនធ្វើឱ្យសត្វល្អិតដ៏តូចបំផុតនៅក្រោមជើង ធ្វើឱ្យខ្ញុំអន្តរាយនោះទេ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំចង់ធ្វើល្អនៅគ្រប់ទីកន្លែង ជាមួយនឹងមនុស្សគ្រប់រូប និងចំពោះអ្វីៗទាំងអស់។ ខ្ញុំទទួលអារម្មណ៍ថា ខ្ញុំមានជីវិតថ្មីមួយ បំណងថ្មីមួយ ដើម្បីធ្វើអ្វីដែលត្រឹមត្រូវ។ ហើយគ្មានបំណងធ្វើអាក្រក់ សូម្បីតែមួយចំណែកតូចណាមួយ នៅសល់ក្នុងព្រលឹងរបស់ខ្ញុំទេ . . .។ នេះគឺជាឥទ្ធិពលដែលមាន មកលើខ្ញុំ ហើយខ្ញុំដឹងថា ឥទ្ធិពលនេះមកពីព្រះ និងជាសាក្សីដែលនៅរស់ជារៀងរហូត ចំពោះខ្ញុំអំពីការទទួលយករបស់ខ្ញុំនៃ ព្រះអម្ចាស់" (*Gospel Doctrine*, បោះពុម្ពលើកទី 5 [1939], 96)។

  ឥឡូវចូរអានអំពីអ្វី ដែលប្រធានស្ម៊ីធបាននិយាយ អំពីអារម្មណ៍របស់គាត់ក្រោយពីពិធីបុណ្យជ្រមុជទឹកៈ

  "ហើយដែលខ្ញុំអាចរក្សាព្រះវិញ្ញាណ និងបំណងដដែលនោះនៅក្នុងដួងចិត្ត គ្រប់ពេលក្នុងជីវិតរបស់ខ្ញុំចាប់តាំងពី [ថ្ងៃនៃពិធីបុណ្យជ្រមុជទឹករបស់ខ្ញុំ] សំរាប់ការណ៍នេះ។ ពេលដែលយើងភាគច្រើនបានទទួលសាក្សី ការចាប់កំណើតថ្មី ការផ្លាស់ប្តូរដួងចិត្តនោះ យើងអាចមានកំហុសនៅក្នុងការវិនិច្ឆ័យ ឬបានធ្វើកំហុសជាច្រើន ហើយជារឿយៗប្រហែលជា មកពីភាពខ្សត់ខ្សោយនៃបទដ្ឋាន សេចក្តីពិតនៅក្នុងជីវិតរស់នៅរបស់យើង យើងបានប្រែចិត្តពីអំពើអាក្រក់ ហើយបានស្វែងរក ការអភ័យទោសពីព្រះហស្ត នៃព្រះអម្ចាស់ជាលំដាប់ ដើម្បីឱ្យមកដល់សព្វថ្ងៃនេះ យើងនៅតែមានបំណង និងគោលបំណង ដដែលនេះ ជ្រួតជ្រាបនៅក្នុងព្រលឹងរបស់យើង នៅពេលយើងទទួលបុណ្យជ្រមុជទឹក ហើយទទួលបានការរំដោះបាបរបស់យើង ដែលនឹងនៅតែមានក្នុងដួងចិត្តរបស់យើង ហើយនៅតែគ្រប់គ្រងលើមនោសញ្ចេតនា និងតណ្ហានៃព្រលឹងរបស់យើង" (*Gospel Doctrine*, 96)។

  - តើអ្នករៀនអ្វីខ្លះ មកពីប្រធានស្ម៊ីធ អំពីទីបន្ទាល់របស់អ្នក និងការតាំងចិត្ត ដើម្បីរស់នៅតាមដំណឹងល្អ?
  - តើអ្នករៀនអ្វីខ្លះ អំពីផលពិបាក របស់អ្នកផ្លាស់សាសនាថ្មី សូម្បីតែព្យាការីនាពេលអនាគត ត្រូវប្រឈមមុខ នឹងពិធីបុណ្យជ្រមុជទឹកខាងក្រោមនេះ?
  - ចូរគិតអំពីអ្នកផ្លាស់សាសនាថ្មី និងសមាជិកមិនសូវសកម្ម តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីជួយពួកគេទទួលបាន "ចំណង់ និងគោលបំណង"សារឡើងវិញ ដែលពួកគេធ្លាប់មាន?

កំណត់ចំណាំ

## ការប្រជុំមណ្ឌល និងសន្និសីទហ្សូន

- អញ្ជើញប៊ីស្សុបឱ្យនិយាយអំពីឧបសគ្គ នៃការធ្វើការជាមួយ សមាជិកមិនសូវសកម្ម និងអ្នកផ្លាស់ប្រែគំនិតថ្មី។ សុំឱ្យគាត់សង្កត់បញ្ជាក់អំពីរបៀប ដែលអ្នកផ្សព្វផ្សាយសាសនា អាចជួយជាមួយនឹងឧបសគ្គទាំងនេះ។
- ពិភាក្សាអំពីរឿងប្រៀបធៀបនៃចៀមវង្វេង និងកូនប្រុសតិរិច្ឆាន (សូមមើលលូកា 15)។

## ប្រធានបេសកកម្ម

- ធ្វើការជាមួយនឹងអ្នកដឹកនាំបព្វជិតភាព ដើម្បីលើកទឹកចិត្តពួកគេឱ្យជួយដល់អ្នកផ្លាស់សាសនាថ្មីៈ
  - ត្រូវបានតែងតាំងជាបព្វជិតភាព។
  - ទទួលគ្រូបង្រៀនតាមផ្ទះ។
  - រៀបចំឈ្មោះរបស់ជីដូនជីតា ដើម្បីយកទៅព្រះវិហារបរិសុទ្ធ និងធ្វើពិធីបុណ្យជ្រមុជទឹកសំរាប់អ្នកស្លាប់។
  - ទទួលយកមេរៀន “ក្រិត្យវិន័យ និងពិធីការទាំងឡាយ” ដែលគ្រូបង្រៀនតាមផ្ទះបង្ហាញ។
- បង្រៀនអ្នកដឹកនាំប្រចាំតំបន់អំពីរបៀប ដើម្បីប្រើប្រាស់អ្នកផ្សព្វផ្សាយសាសនា នៅក្នុងក្រុមប្រឹក្សាក្នុងវួដ។
- បង្រៀនអ្នកដឹកនាំប្រចាំតំបន់ អំពីគោលបំណង ហើយប្រើប្រាស់កំណត់ហេតុស្តីពីការរីកចំរើន។
- យូរៗម្តង សូមសួរដល់អ្នកផ្សព្វផ្សាយសាសនា ឱ្យបង្ហាញដល់អ្នកនូវកំណត់ហេតុ ស្តីអំពីការរីកចំរើនរបស់ពួកគេ មួយច្បាប់។
- យូរៗម្តងតាមដានជាមួយនឹងអ្នកផ្លាស់ប្រែគំនិតថ្មីៗ ដើម្បីស្វែងរករបៀបដែលពួកគេកំពុងធ្វើ និងរបៀប ដែលអ្នកផ្សព្វផ្សាយសាសនា និងសមាជិកអាចជាជំនួយ។
- សូមអញ្ជើញអ្នកដឹកនាំស្តេក និងវួដឱ្យនិយាយទៅកាន់អ្នកផ្សព្វផ្សាយសាសនារបស់អ្នក ដើម្បីពន្យល់អំពីរបៀប ដែលអ្នកផ្សព្វផ្សាយសាសនាអាចក្លាយទៅជាជំនួយដ៏សំខាន់បំផុត។
- សូមអញ្ជើញសមាជិកថ្មីឱ្យនិយាយទៅកាន់អ្នកផ្សព្វផ្សាយសាសនា និងភ្ជាប់នូវបទពិសោធន៍របស់ពួកគេ ក្នុងខណៈដែលពួកគេជាសមាជិកថ្មីនៃសាសនាចក្រ។
- យូរៗម្តងសួរដល់សមាជិក ដែលផ្លាស់ប្រែគំនិត ចែកចាយបទពិសោធន៍នៃការផ្លាស់សាសនារបស់ពួកគេ នៅក្នុងសន្និសីទហ្សូនមួយ។

កំណត់ចំណាំ

## ក


ការរៀន, ដំណើរការនៃការទទួលវិវរណៈ 18
ជាសមាជិកសាសនាចក្រ 89
ដោយព្រះវិញ្ញាណបរិសុទ្ធ 18
ការពន្លូតកូន, និងភាពសក្តិសមសំរាប់ពិធីបុណ្យជ្រមុជទឹក 210–211
ការទទួលខុសត្រូវ 154
ការចាកផុតពីការញៀន 191–194
ការក្បត់សាសនា, និយមន័យ 35–36
ដ៏ធំធេង 35–36
ការសម្ភាសន៍សំរាប់ពិធីបុណ្យជ្រមុជទឹក, រៀបដឹកនាំ 209–211
រៀបចំសាសនាគន់ការីដើម្បី 208
សំណួរ 209–210
អ្នកដែលដឹកនាំ 209–210
ការបំរើនៃពិធីបុណ្យជ្រមុជទឹក, របៀបដឹកនាំ 212–213
ការអញ្ជើញឱ្យធ្វើការតាំងចិត្ត 199–200
ការតាំងចិត្ត, និងពរជ័យ 201–202
និងសំណួរចំៗ 202
និងតាមដាន 204
បង្កើនជំនឿ 200
ផ្នែកដ៏ចាំបាច់នៃការប្រែចិត្ត 199
ការតាំងចិត្ត, គោលបំណងនៃ 8
ការសិក្សាជាមួយដៃគូ, គោលបំណង ix
គម្រោងពេល viii
ការកែលំអគ្នាទៅវិញទៅមករវាងដៃគូ 153
ការប្រតិបត្តិតាម 124
បទបញ្ញត្តិ 72
ការជំទាស់, របៀបឆ្លើយសំណួរ, ជាមួយព្រះគម្ពីរមរមន 111
ការអត់ធ្មត់ 122
ការបើកសំដែងផ្ទាល់ខ្លួន 91–92
ការសិក្សាផ្ទាល់ខ្លួន, គោលបំណង viii–ix
គម្រោងពេលវេលា viii
ការស្លាប់ខាងរាងកាយ, និយមន័យ 59
ការអធិស្ឋាន, បទបញ្ញត្តិមួយ 74
និងសេចក្តីជំនឿ, ក្នុងការផ្លាស់គំនិត 95–97
ជញ្ជឹងវាយតំលៃ 96
របៀបផ្តល់ 39
មធ្យោបាយដើម្បីរៀនសេចក្តីពិត 39
តួនាទីនៃ 39
យោបល់សំរាប់ 96–97
ការចេះដឹង 121
ការរៀនភាសា, និងវេយ្យាករណ៍ 132
និងការទន្ទេញ 131–132
គោលដៅ 131
គោលការណ៍នៃ 130–131
ផែនការសិក្សា 131–133
ឧបករណ៍សំរាប់ 131
ជាមួយដៃគូ 133–134
ក្រិត្យវិន័យ, ប្រតិបត្តិតាម និងគោរព 82
ក្រិត្យវិន័យ និងពិធីការ, ក្រោយពីពិធីបុណ្យជ្រមុជទឹក 83–89
របៀបសិក្សា 84
របៀបបង្រៀនអំពី 83
កង្វល់, ត្រូវការដោះស្រាយឱ្យសាសនាគន់ការី 191
ការគូសចំណាំបទគម្ពីរ 24
កុមារតូចៗ, និងពិធីបុណ្យជ្រមុជទឹក 211
កិច្ចការអ្នកផ្សព្វផ្សាយសាសនា, សមាជិកត្រូវធ្វើ 85
កំណត់ហេតុ, សំរាប់ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ 212
ការប្រោសលោះ, និយមន័យ 59
កំណែទំរង់ 35
ការចាប់ជាតិ, និងការរស់ឡើងវិញ 53
ការប្រែចិត្ត 191–194
និងការតាំងចិត្ត 199
ការកសាងឡើងវិញ, និយមន័យ 70
ការស្តារឡើងវិញ, សារលិខិតនៃ, ពន្យល់ 6–8
នៃដំណឹងល្អ 36–37
ការរស់ឡើងវិញ 53
និយមន័យ 51, 59
ការបើកសំដែង, ផ្ទាល់ខ្លួន 91–92
ការប្រជុំប្រសិទ្ធិពរទំព័ង និងទឹក 64
ការសង្គ្រោះ, មានសំរាប់មនុស្សទាំងអស់ 87
ការសិក្សាព្រះគម្ពីរ, បទបញ្ញត្តិមួយ 74–75
ការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ 37
ការបំរើ, ជាសមាជិកនៃសាសនាចក្រ 88
ជាប្រភពសំរាប់ការស្វែងរកសាសនាគន់ការី 172–173
ការសិក្សា, ធនធានដែលបានអនុម័តដើម្បី 23
ជាការរៀបចំដើម្បីបង្រៀន 19–22
ចាប់ផ្តើមដោយការអធិស្ឋាន 17, 22
ប្រសិទ្ធភាព 17
ការណែនាំសំរាប់ 20–21
យោបល់សំរាប់ប្រសិទ្ធភាព 22–24
ការនិយាយ, យោបល់សំរាប់, ជាមួយអ្នកដទៃ 159
ឧបករណ៍សំរាប់ការស្វែងរក 160–162
កំណត់ហេតុនៃការបង្រៀន, ទំរង់ដែលបានពិពណ៌នា 144–145
ការបង្រៀន, កែសំរួលដើម្បីបំពេញសេចក្តីត្រូវការ 181–182
ការប្រឹក្សានៃគណៈប្រធានទីមួយស្តីអំពី 179–180
និងការស្តាប់ 189–190
និងការស្វែងរក 162–163
និងការទន្ទេញ vii
ដោយព្រះវិញ្ញាណ 3–4
របៀបចាប់ផ្តើម 180–181
នៅក្នុងមុខងារនៃសាសនាចក្រ 89
រយៈពេលនៃការតែងតាំង 182
រយៈពេលនៃមេរៀន vii
ប្រជាជនដែលគ្មានសារតាជាគ្រីស្ទាន 194–195
ដំណឹងល្អជាអ្នកផ្សព្វផ្សាយសាសនា 179
ជាមួយដៃគូ 182–183
ជាមួយសមាជិក 183
ជាមួយនឹងសំណួរ 187–188
ជាមួយព្រះគម្ពីរ 184–186
ការប្រើប្រាស់ពេលវេលា, ប្រសិទ្ធភាព 139
ការបង្រៀនពេលសួរសុខទុក្ខ 219
ក្រុមប្រឹក្សាវួដ 219–221
និងមិត្តភាពនៃអ្នកផ្លាស់គំនិតថ្មី 220

និងការជួយអ្នកផ្លាស់គំនិតថ្មី ឱ្យបំរើតាមមុខងារ 221
និងការបីបាច់អ្នកផ្លាស់គំនិតថ្មី 221–22
ទទួលខុសត្រូវក្នុងការរាក់ទាក់ 218
ការប្រជុំផែនការប្រចាំសប្ដាហ៍, របៀបធ្វើ 150–54
ការទន្ទេញ, និងការបង្រៀន vii
ការស្ដាប់, ដើម្បីកែលំអជំនាញខាងភាសា 132
ការប្រើប្រាស់នៃ, ក្នុងការបង្រៀន 188–190
ការវិនិច្ឆ័យ, និយមន័យ 59
ចុងក្រោយ 53
ការបន្ទាបខ្លួន 122–23
ការដាក់គោលដៅ 139
ការធ្វើតាមព្យាការី 76–77
ការថ្វាយបង្គំ, នៃសមាជិកថ្មី 213
ការស្វែងរកសាសនាគន់ការី, យោបល់សំរាប់ 171
ការស្វែងរកមនុស្សដើម្បីបង្រៀន 159
ការស្វែងរក, និងការបង្រៀន 162–63
ដោយព្រះវិញ្ញាណ 160
ជាមួយសមាជិក 164–66
កិច្ចការពង្សប្រវត្តិ 86–87
ការធ្លាក់នៃលោកអ័ដាម និងអេវ៉ា 49–50
និយមន័យ 58
ការស្ដាបនាសាសនាចក្រ 10
កុងហ្វាជារ 46
ការផ្លាស់គំនិត, តួនាទីរបស់អ្នកផ្សព្វផ្សាយសាសនា 112
តួនាទីរបស់ព្រះវិញ្ញាណ 112
ការបង្កបង្កើត, នៃសេចក្ដីស្លាប់ 49
ការប្រជុំផែនការប្រចាំថ្ងៃ 153–54
ការខកចិត្ត 9–10
ការប្រជុំមណ្ឌល, និងការសិក្សា viii
ការលើកតំកើង 53
និយមន័យ 58
កាប្រេ៉ា, វ៉ុចទ័រ ម៉ាញ៉អ៊ែល, រឿងនៃការផ្លាស់គំនិត 161–62
ការបង្រៀនតាមផ្ទះ 219
ការប្រុងប្រយ័ត្ន, នៅក្នុងការទទួលវិវរណៈ 100–101


## ខ


ខាលវីន, យ៉ូហាន 45–46


## គ


គុណធម៌ 120–121
គោលបំណង, ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា 1
គម្រោងពេលវេលាប្រចាំថ្ងៃរបស់អ្នកផ្សព្វផ្សាយសាសនា viii
គោលបំណងរបស់អ្នកផ្សព្វផ្សាយសាសនា, តំណាងព្រះយេស៊ូវគ្រីស្ទ 2
គំនិតសំរាប់ការសិក្សា និងការអនុវត្ត, របៀបប្រើប្រាស់ xi
គោលដៅ, ការប្រជុំផែនការប្រចាំសប្ដាហ៍ 150–54
របៀបដាក់ 149
គណៈប្រធានទីមួយ, ស្ដីអំពីកិច្ចការអ្នកផ្សព្វផ្សាយសាសនា 29–30
គ្រួសារ, គោលបំណងនៃ 86
គ្រួសារនៃព្រះ 31–32 159
គ្រួសារ, មានពរដោយដំណឹងល្អ 32
ដំណឹងល្អដែលស្ដារឡើងវិញ ប្រសិទ្ធិពរ 3
ការបង្រៀនស្ដីអំពីសារសំខាន់នៃ 163–64
“គ្រួសារៈ ការប្រកាសដល់ពិភពលោក” 3, 86, 118
គណៈកម្មាការ, បង្រៀនដំណឹងល្អដែលបានស្ដារឡើងវិញ 1


## ច


ចរិតលក្ខណៈ, របៀបសិក្សា 118
នៃព្រះគ្រីស្ទ 117
ច្បាប់ស៊ីវិល, គោរព និងធ្វើតាម 82


## ជ


ជំរះពីអំពើបាប 2, 5–6, 61–62
ជីវិតអស់កល្បជានិច្ច, និយមន័យ 71
ជីវិតនៅលើផែនដី 50
ជោគជ័យរបស់អ្នកផ្សព្វផ្សាយសាសនា 10–11
ជីវិតមុនកើតលើផែនដី 48
និយមន័យ 59
ជីវិតមុនឆាកជីវិតនេះ, និយមន័យ 59
ជោគជ័យ, និយមន័យ 10–11


## ន


នគរសេឡេស្ទាល 53
នគរទេរេស្ទ្រាល 53
នគរនៃសីរីល្អ 53
និយមន័យ, ពាក្យមិនស្គាល់ 21


## ប


បព្វជិតភាពអើរ៉ុន, ដែលបានស្ដារឡើងវិញ 37
បាលឡាត អែម រ៉ាស់សល, អំពីគោលដៅ 149
អំពីអំណាចនៃព្រះវិញ្ញាណ 96
ប៊ែនសុន អែសរ៉ា ថាហ្វ ស្ដីអំពីការឆ្លើយសំណួរ ជាមួយនឹងព្រះគម្ពីរមរមន 110–111
ស្ដីអំពីព្រះគម្ពីរមរមន ជាសិលាគន្លឹះ 106
ស្ដីអំពីសំណួរសំខាន់ៗនៃព្រលឹង 109
ស្ដីអំពីសារសំខាន់នៃព្រះវិញ្ញាណ 180
ស្ដីអំពីការយកដំណឹងល្អទៅឯលោកីយ 2
ស្ដីអំពីការងារ 123
ប៊ីស្សប 152–54
និងកិច្ចការអ្នកផ្សព្វផ្សាយសាសនា 165
ដឹកនាំកិច្ចប្រឹងប្រែងនៃអ្នកផ្សាយសាសនាប្រចាំវួដ 218
ភារកិច្ចអ្នកផ្សាយសាសនានៃ 222
បទបញ្ញត្តិទាំងឡាយ 72–82
របៀបសិក្សា 73–74
របៀបបង្រៀនអំពី 72–73
ប្រធានបេសកកម្ម, តួនាទីនៃ 221
បព្វជិតភាពម៉ិលគីស្សាដែក, ដែលបានស្ដារឡើងវិញ 37
ប៉ាំផ្លូ, រឿងនៃការផ្លាស់គំនិតតាមរយៈការបំរើ 172–73
បណ្ណាល័យអ្នកផ្សព្វផ្សាយសាសនា ix
ប្រធានសាសនាចក្រ, ស្ដីអំពីកិច្ចការអ្នកផ្សព្វផ្សាយសាសនា 12–13
បព្វជិតភាព និងថ្នាក់ជំនួយ 84–85
បព្វជិតភាព, អើរ៉ុន 45–46
និយមន័យ 32
ម៉ិលគីស្សាដែក 84
ការស្ដារឡើងវិញនៃ 37, 84
បឋមសិក្សា, អង្គការ 84–85

## ព


- ពិធីបញ្ជាក់ព្រះវិញ្ញាណបរិសុទ្ធ 66
  - និយមន័យ 71
  - របៀបធ្វើ 214
  - ការរៀបចំ 207–208
  - *សូមមើលផងដែរ* ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ព្រះវិញ្ញាណបរិសុទ្ធ
- ពង្សាវល្លី, ប្រភពស្វែងរកសាសនាគន់ការី 167–169
- ពិភពវិញ្ញាណ 53
- ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ 8–9, 76
  - សំណួរ និងចំលើយអំពី 210–12
  - កំណត់ហេតុ 212
- ពិធីបុណ្យជ្រមុជទឹក, ការអញ្ជើញ 40, 67
  - ភាពចំបាច់សំរាប់សមាជិកភាព នៃសាសនាចក្រ 65
  - មិនចាំបាច់សំរាប់កុមារតូចៗ 65
  - ដោយភ្លើង 66
  - នៃបេក្ខជនដែលគ្មានគុណសម្បត្តិគ្រប់គ្រាន់ 211
  - សេចក្ដីសញ្ញាតំបូងរបស់យើង 64–65
  - ការរៀបចំសំរាប់ 207–208
  - គុណសម្បត្តិដើម្បី 208
- ពិធីបុណ្យជ្រមុជទឹកសំរាប់អ្នកស្លាប់ 86
- ព្រះគម្ពីរបរិសុទ្ធ, គាំទ្រព្រះគម្ពីរមរមន 107–108
- ពរជ័យ, និងការតាំងចិត្ត 200–201
- ព្រះគម្ពីរមរមន, ឆ្លើយសំណួរនៃព្រលឹង 109–110
  - ជាសិលាគន្លឹះ 105–106
  - ទាញមនុស្សឱ្យទៅក្បែរព្រះ 110
  - ភស្តុតាងនៃទេវភាពរបស់ព្រះយេស៊ូវគ្រីស្ទ 105
  - ភស្តុតាងនៃការស្ដារឡើងវិញ 7, 38–39, 105
  - របៀបអាន, ជាមួយសាសនាគន់ការី 112–113
  - របៀបប្រើប្រាស់ 112–113
  - គោលបំណងនៃ 38
  - អាន, ដើម្បីរៀនភាសានៃបេសកកម្ម 132
  - គាំទ្រព្រះគម្ពីរបរិសុទ្ធ 107–108
  - ធ្វើទីបន្ទាល់ដល់ព្រះយេស៊ូវគ្រីស្ទ 106
- ព្រះពុទ្ធ (ព្រះគោទមៈ) 46
- ព្រះគ្រីស្ទ, ពន្លឺនៃ *សូមមើល* ពន្លឺនៃព្រះគ្រីស្ទ
- ព្រះគ្រីស្ទ *សូមមើល* ព្រះយេស៊ូវគ្រីស្ទ
- ពិធីបុណ្យជ្រមុជទឹកឱ្យអ្នកផ្លាស់គំនិត 210–211
- ពិធីការពិសិដ្ឋ 87
- ពង្សប្រវត្តិៈ ប្រភពដើម្បីស្វែងរកសាសនាគន់ការី 167–169
- ព្រះជាព្រះវរបិតា, លេចចេញចំពោះយ៉ូសែបស្ម៊ីធ 37
- ព្រះ, ព្រះវរបិតារបស់យើង 31–32, 48
- ព្រះ, បង្រៀនអ្នកដែលមិនមែនជាគ្រីស្ទានអំពី 32
- ព្រះគុណ, និយមន័យ 71
- ព្រះវរបិតាសួគ៌ 31–32
- ព្រះវិញ្ញាណបរិសុទ្ធ, អំណោយទាន 92
  - ការរៀនដោយ 18
  - តួអង្គនៃ 92
  - អំណោយនៃ 93
- ព្រះវិញ្ញាណបរិសុទ្ធនៃការសន្យា 93
- ព្រះយេស៊ូវគ្រីស្ទ, លេចមកចំពោះយ៉ូសែប ស្ម៊ីធ 37
  - ជាព្រះអង្គសង្គ្រោះ 51–52, 61–62
  - ដង្វាយធួននៃ *សូមមើល* ដង្វាយធួន
  - ការបំរើនៅលើផែនដី របស់ 34
  - ការជួយប្រជាជនឱ្យរៀនអំពី 47–48
- ពិធីការ, និយមន័យ 64
- ព្យាការី, ពន្យល់ 34
  - តួនាទីនៃ 32–33
- ព្រះគម្ពីរ, ការគូសចំណាំ 24
  - ការប្រើប្រាស់នៃ, ក្នុងការបង្រៀន 184–86
- ព្រះវិញ្ញាណ, អំណោយនៃ, ក្នុងការផ្លាស់គំនិត 93–94
  - ការបំផុសនៃ 98–100
  - គួរតែដឹកនាំការបង្រៀន 180
  - ការបង្រៀនដោយ 3–4
- ព្រះវិហារបរិសុទ្ធ, ការថ្វាយបង្គំនៅក្នុង 87
- ព្រហ្មចារីយ៍, ក្រិត្យវិន័យ 78


## ម


- ការបំរើ, នៅក្នុងសាសនាចក្រ 87–88
  - *សូមមើលផងដែរ* មុខងារជាអ្នកផ្សព្វផ្សាយសាសនា
- មនុស្សដែលត្រូវទៅជួប ដោយទីស្នាក់ការសាសនាចក្រ 167
- ម៉ូហាម៉េដ 46
- ថូម៉ាស អេស ម៉នសុន, ស្ដីអំពីការថ្លែងសក្ខីភាព 202
  - ស្ដីអំពីភាសានៃវិញ្ញាណ 135
  - ស្ដីអំពីការទទួលខុសត្រូវ 154
  - ស្ដីអំពីការអត់ធ្មត់ 122
  - ស្ដីអំពីការបង្រៀនជាមួយសមាជិក 183
- មតភាព 50
  - និយមន័យ 59
  - គោលបំណងនៃ 31–32
- ម្ដាយ, ភារកិច្ចនៃ 86
- មនុស្សថ្មីដែលត្រូវទៅជួប, គោលការណ៍សំរាប់ការធ្វើការជាមួយ 167
- មុខងារអ្នកផ្សព្វផ្សាយសាសនា, និងការទទួលខុសត្រូវ 4
  - អំណាច និងសិទ្ធិអំណាចនៃ 4–5
  - ដើម្បីបង្រៀនដំណឹងល្អដែលបានស្ដារឡើងវិញ 179


## ដ


- ដង្វាយមួយភាគក្នុងដប់, ដង្វាយតមអាហារ, ការបរិច្ចាគ 81
- ដង្វាយមួយភាគក្នុងដប់, ក្រិត្យវិន័យនៃ 81
- ដើមឈើជីវិត, សកម្មភាព 2
- ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ *សូមមើល* ដំណឹងល្អ
- ដំណឹងល្អ 61–67
  - ប្រសិទ្ធិពរដល់ក្រុមគ្រួសារ 3, 32
  - និយមន័យ 5, 71
  - បំពេញសេចក្ដីត្រូវការមនុស្ស 1–2
  - គោលបំណងនៃ 6
  - ការស្ដារឡើងវិញ 36–37
- ដង្វាយធួន 31–33, 34, 48, 51–52, 61–62
  - និយមន័យ 59


## យ


- យុវជន, អង្គការ 85
- យុវនារី, អង្គការ 85
- យាំង, ព្រីហ៊្គម, ស្ដីអំពីការទទួលទីបន្ទាល់ 203

**រ**

របាយការណ៍សង្ខេបតាមទូរស័ព្ទ, ទំរង់ដែលបានពិពណ៌នា 146
រាត្រីជួបជុំក្រុមគ្រួសារ 86
រូបចម្លាក់ព្រះ 78
របាយការណ៍ប្រចាំសប្តាហ៍, ទំរង់ដែលបានពិពណ៌នា 148

**ល**

លក្ខណៈដូចជាព្រះគ្រីស្ទ, អំណោយទានពីព្រះ 117
  របៀបអភិវឌ្ឍន៍ 124–25
  ចាំបាច់ដើម្បីអភិវឌ្ឍន៍ 117
លី, ហារ៉ូល ប៊ី, ស្តីអំពីសារសំខាន់នៃគ្រួសារ 4
  ស្តីអំពីការបង្រៀនសំរាប់ការយល់ដឹង 197

**វ**

វប្បធម៌, ត្រូវរៀន 134

**ទ**

ទេវតា, ការថ្វាយបង្គំដែលសមរម្យ 78

**ភ**

ភាពឧស្សាហ៍ 123

**ធ**

ធ្វើល្អ 172–73

**ត**

តស៊ូដល់ទីបំផុត 66, 88
  និយមន័យ 71
តមអាហារ, ច្បាប់ 82
មជ្ឈមណ្ឌលពង្សប្រវត្តិ, ប្រភពដើម្បីស្វែងរកសាសនាគន់ការី 168
ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ 48
ឪពុក, ភារកិច្ចនៃ 86
ហ្វោស្ត, ជេមស៍ អ៊ី, ស្តីអំពីសេចក្តីសង្ឃឹម 119
  ស្តីអំពីការការបង្រៀនច្បាស់លាស់ 186
ភាពដែលអាចបត់បែនបាន vii
  នៅក្នុងការបង្រៀន vii
តាមដាន, និងការតាំងចិត្ត 204
ហ៊ីងឃ្លី, គរដិន, អ្នកផ្សព្វផ្សាយសាសនាត្រូវធ្វើឱ្យអ្នកផ្លាស់គំនិត
  គង់វង្សនៅសាសនាចក្រ 218
  ស្តីអំពីការរក្សាអ្នកផ្លាស់គំនិតឱ្យគង់វង្ស 217
  ស្តីអំពីសេចក្តីជំនឿ និងការអធិស្ឋាន 95–96
  ស្តីអំពីសមាជិកជួយអ្នកផ្សព្វផ្សាយសាសនា 164
  ស្តីអំពីការអធិស្ឋានរបស់អ្នកផព្វផ្សាយសាសនា 96
  ស្តីអំពីសេចក្តីត្រូវការនៃអ្នកផ្លាស់គំនិតថ្មី 219–20
  ស្តីអំពីការអានព្រះគម្ពីរមរមនដោយមានការអធិស្ឋាន 110
  ស្តីអំពីការទទួលស្គាល់ព្រះវិញ្ញាណ 98–99
  ស្តីអំពីការបំរើ 172
ហូលែន, ជែហ្វ្រី អា, ស្តីអំពីការរៀនភាសា 130
  ស្តីអំពីការស្តាប់ 188
  ស្តីអំពីការបង្រៀនជាមួយនឹងអំណាច 8
ទំនាក់ទំនងនៃការរួមភេទដូចគ្នា, និងភាពសក្តិសមសំរាប់ពិធីបុណ្យជ្រមុជទឹក
  210–12
ហិនថើរ, ហូវើដ ដបិលយូ, ស្តីអំពីការទទួលស្គាល់ព្រះវិញ្ញាណ 101
ភ្នំទឹកកក, ការប្រៀបបារម្ភតីដូចគ្នា 191

ប្រអប់ព័ត៌មាន, នៅក្នុង "ប្រកាសដំណឹងល្អរបស់យើង" x–xi
យ៉ែមបល, ស្ពែនសឺរ ដបិលយូ, ស្តីអំពីកិច្ចការអ្នកផ្សព្វផ្សាយសាសនា
  និងព្រះវិហារបរិសុទ្ធ 168
  ស្តីអំពីការញែកចេញ 4
មេរៀន, សំរាប់សមាជិកថ្មី 29
  ដើម្បីបង្រៀនសាសនាគន់ការី 29
  ប្រើប្រាស់សំរាប់ការសិក្សា និងការហ្វឹកហ្វឺន 29
ពន្លឺនៃព្រះគ្រីស្ទ 92
លូថើ, ម៉ាទិន 45
ម៉ាក់ស្វែល, នៀល អេ, ស្តីអំពីសេចក្តីសង្ឃឹម 119
មនុស្សដែលត្រូវទៅជួបតាមរយៈប្រព័ន្ធឃោសនា 167
ភាសាបេសកកម្ម, និងភាសាកំណើត 129
  រៀបចំដើម្បីរៀន 129
  តម្រូវឱ្យមានការលះបង់ 130
គណៈកម្មាធិការសម្របសម្រួលនៃអ្នកផ្សព្វផ្សាយសាសនា, ភារកិច្ចនៃ 223
ផែនការប្រចាំថ្ងៃនៃអ្នកផ្សព្វផ្សាយសាសនា, ពិពណ៌នា 147–48
តួនាទីរបស់អ្នកផ្សព្វផ្សាយសាសនា ក្នុងការផ្លាស់គំនិត 95
ផាកកឺ, បយឃេ, ស្តីអំពីការជ្រមុជទឹកដោយទឹក និងភ្លើង 243
  ស្តីអំពីការបង្ហំហេតុការណ៍ខាងវិញ្ញាណ 104
  ស្តីអំពីការទទួលស្គាល់ព្រះវិញ្ញាណ 98, 101
  ស្តីអំពីព្រះវិញ្ញាណ នៅក្នុងការផ្លាស់គំនិត 95
  ស្តីអំពីបទពិសោធន៍ខាងវិញ្ញាណ 101
  ស្តីអំពីរបៀបដែលសិក្សា ផ្លាស់ប្តូរឥរិយាបទ 19
  ស្តីអំពីអំណាចបីបាច់នៃព្រះគម្ពីរមរមន 110
  ស្តីអំពីពន្លឺនៃព្រះគ្រីស្ទ 92
ភែរី អ៊ែល ធំ, ស្តីអំពីការប្រតិបត្តិតាម 124
ផែនការសង្គ្រោះ 47–54
  តារាង 54
*"ប្រកាសដំណឹងល្អរបស់យើង"* ប្រើប្រាស់ដោយអ្នកផ្សព្វផ្សាយសាសនា
  និងអ្នកដឹកនាំប្រចាំវួដ xi
  របៀបប្រើប្រាស់ vii
របាយការណ៍កែចំរើន, ទំរង់ដែលបានពិពណ៌នា 145
ថ្ងៃស៊ីល, ការញែក, បរិសុទ្ធ 75
  និយមន័យ 59–60
  ផែនការណ៍នៃ 47–54
គម្រោងពេល *សូមមើល* គម្រោងពេល ប្រចាំថ្ងៃ អ្នកផ្សព្វផ្សាយសាសនា
ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ, និងភាពសក្តិសមសំរាប់ពិធីបុណ្យជ្រមុជទឹក 210–12
វិញ្ញាណនៃលោកអេលីយ៉ា 166–167
ថាញ់ខេល, វិល្លាម 45–46
ផែនការបេសកកម្មប្រចាំវួដ 223
ក្រុមប្រឹក្សាជាន់ខ្ពស់នៃសង្កាត់, ភារកិច្ចនៃ 222
ប្រធានសង្កាត់, ភារកិច្ចនៃ 221
ថេល័រ, យ៉ូហាន, ស្តីអំពីការបង្រៀនសាមញ្ញ 183
បទបញ្ញត្តិទាំងដប់ប្រការ, ការប្រតិបត្តិតាម 77–79

**ទ**

ទិន្នានុប្បវត្តិនៃការសិក្សា, ពន្យល់ x
ទីបន្ទាល់, ថ្លែងជាញឹកញាប់ 202–03

**ភ**

ភាសា, អំណោយទាននៃ 135

## ព

ពិតចំពោះសេចក្ដីជំនឿ 21
ពាក្យសំដីនៃប្រាជ្ញាវាងវៃ 79

## វ

វ៉ាយគ្លីហ្វ, ចន 45
វើស្ទិន, យ៉ូសែប, ប៊ី ស្ដីអំពីការប្រើព្រះគម្ពីរមរមន 112

## ស

សេចក្ដីសង្ឃឹម គ្រីស្ទ
សាជីព័តិមាន 124
សិទ្ធិជ្រើសរើស 48, 49
ស្បៀវភៅតំបន់, ពិពណ៌នា 142–144
 ប្រើដើម្បីរកអតីតសាសនាគន់ការី 66
សកម្មភាពកែលំអចរិតលក្ខណៈ, ការវាយតំលៃខ្លួនឯង 128
សិទ្ធិអំណាច, របស់អ្នកផ្សាយសាសនា 4
 បព្វជិតភាព, បាត់បង់ 35
 ដែលបានស្ដារឡើងវិញ 36
សាងសាសនាចក្រឡើង 160
សេចក្ដីសប្បុរស 120
សេចក្ដីសញ្ញា, និយមន័យ 71
 ពន្យល់ 63
សម័យកាន់កាប់ត្រួតត្រា 33
សម័យកាន់កាប់ត្រួតត្រា 32–34
 គោលបំណង ix
សមាជិកដែលត្រូវបានកាត់ផ្ដាច់ចេញពីសាសនាចក្រ, តើត្រូវជ្រមុជទឹកឱ្យទេ 211
សេចក្ដីជំនឿ, និងការរកមនុស្សដើម្បីបង្រៀន 159
 និងការអធិស្ឋាន 94–96
 នៅក្នុងព្រះយេស៊ូវគ្រីស្ទ 61–62, 118–19
សារលិខិតពីគណៈប្រធានទីមួយ v
សាសនាគន់ការី, អ្នកផ្សព្វផ្សាយសាសនានឹងរៀបចំ,
 សំរាប់ការសម្ភាសន៍សំរាប់ពិធីបុណ្យជ្រមុជទឹក 208
 ការដាក់គោលដៅដើម្បី 149–154
 អានព្រះគម្ពីរមរមន 112–13
សញ្ញាណសំខាន់, និយមន័យ 140–42
 សំរាប់ការប្រែគំនិត 140–42
 ការដាក់គោលដៅដើម្បី 149
សមាជិកមិនសូវសកម្ម, ប្រភពសំរាប់ស្វែងរកសាសនាគន់ការី 116
 ការពង្រឹង 217–18
សេចក្ដីស្រឡាញ់ 130
សមាជិក, ភ័យខ្លាចការងារអ្នកផ្សព្វផ្សាយសាសនា 165
 ជួយរកសាសនាគន់ការី 164–66
 របៀបជួយ, ជាមួយនឹងកិច្ចការអ្នកផ្សព្វផ្សាយ 166
សេចក្ដីមេត្តាករុណា, និយមន័យ 71
សារលិខិតនៃការស្ដារឡើងវិញ 31
 និងក្រុមគ្រួសារ 163
 ពន្យល់ 6–8
សមាជិកថ្មី, ប្រភពសំរាប់ស្វែងរកសាសនាគន់ការី 166
 អ្នកផ្សព្វផ្សាយសាសនាដើម្បីរាក់ទាក់ 213
 ទទួលមេរៀន 29
 ការពង្រឹង 217–18
 ទទួលមេរៀនម្ដងទៀត 213
សាវតាមិនមែនជាគ្រីស្ទាន, កំពុងបង្រៀនដំណឹងល្អជាមួយ 194–95
សាសនាគន់ការីដែលមានសក្ដានុពល, ទំរង់ដែលបានពិពណ៌នា 146
សេចក្ដីថ្លែងការណ៍ដែលមានការព្យាករណ៍ស្ដីអំពីកិច្ចការផ្សព្វផ្សាយសាសនា 12–13
សំណួរនៃព្រលឹង, និងព្រះគម្ពីរ 109–10
សំណួរ, និងការតាំងចិត្ត 201
 របៀបឆ្លើយ, ជាមួយព្រះគម្ពីរមរមន 111
 ការប្រើប្រាស់, នៅក្នុងការបង្រៀន 187–88
សមាគមស្ត្រីសង្គ្រោះ 85
ស្គុល, ហ្វ្រេង និងម៉ិលដ្រេត, រឿងនៃការផ្លាស់គំនិត 168–69
ស៊្មីធ, ហៃរ៉ាំ, ស្ដីអំពីការបង្រៀនគោលការណ៍ទីមួយ 6
ស៊្មីធ, យ៉ូសែប, និងការនិមិត្តដំបូង 37
 និងការស្ដារឡើងវិញ 36–37
 ស្ដីអំពីពិធីបុណ្យជ្រមុជទឹកដោយទឹក និងព្រះវិញ្ញាណបរិសុទ្ធ 8–9
 ស្ដីអំពីព្រះគម្ពីរមរមនជាសិលាគន្លឹះ 105
 ស្ដីអំពីការប្រកាសដំណឹងល្អ 164
 ស្ដីអំពីការពឹងផ្អែកលើព្រះវិញ្ញាណ 98–99
 ស្ដីអំពីការបង្រៀនដែលមានទាំងអស់ 160
 ស្ដីអំពីអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ 177
 ស្ដីអំពីភាពចាំបាច់នៃការបើកសំដែង 91
ស៊្មីធ, យ៉ូសែប អែហ្វ, ស្ដីអំពីអារម្មណ៍នៅពេលលោកទទួលបុណ្យជ្រមុជទឹក 266
ស្នាយឌើរ, រឿងនៃ 115
សេចក្ដីស្លាប់ខាងវិញ្ញាណ, និយមន័យ 59
សន្និសីទហ្សូន និងការសិក្សា viii
សួនអេដែន 49

## អ

អ្នកដឹកនាំជំនួយ, ភារកិច្ចនៃ 222
អ្នកដឹកនាំបេសកកម្មប្រចាំវួដ, ភារកិច្ចនៃ 222–23
អ្នកដឹកនាំវួដ, និងកិច្ចការអ្នកផ្សព្វផ្សាយសាសនា 217
 ភារកិច្ចនៃ 221
អ្នកផ្សព្វផ្សាយសាសនាប្រចាំវួដ, តួនាទីនៃ 223
 របៀបប្រើ “*ប្រកាសដំណឹងល្អរបស់យើង*” xi
អ្នកដឹកនាំសង្កាត់, និងកិច្ចការអ្នកផ្សព្វផ្សាយសាសនា 217
 ភារកិច្ចនៃ 221
អំពើបាប, ដែលបានចាត់ទុកដោយវប្បធម៌ជាច្រើន 62
អ្នកកែទំរង់ 45
អមតភាព, និយមន័យ 59
 ពន្យល់ 53
អនាគតអែលឌើរ, ប្រភពដើម្បីស្វែងរកសាសនាគន់ការី 166
អូក, ដាល្លិន អេច, ស្ដីអំពីការអញ្ជើញអ្នកដទៃមកព្រះគ្រីស្ទ 9
អ្នកដឹកនាំបព្វជិតភាព, ភារកិច្ចនៃ 222
អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ 66, 99
អំណោយទាននៃភាសា 135
អំណោយទាននៃព្រះវិញ្ញាណ 93
អតីតសាសនាគន់ការី, ប្រភពសំរាប់ស្វែងរកមនុស្សដើម្បីបង្រៀន 170
អាពាហ៍ពិពាហ៍អស់កល្បជានិច្ច 128
អង់គ្លេស, ចាំបាច់ត្រូវរៀន 130

## ចូរចងចាំចំណុចនេះ ... .

- គោលបំណងរបស់អ្នកគឺ នាំព្រលឹងទាំងឡាយមកព្រះគ្រីស្ទ។
- រៀបចំមនុស្សទាំងឡាយឱ្យ បំពេញតាមគុណសម្បត្តិសំរាប់ពិធីបុណ្យជ្រមុជទឹក នៅក្នុងគោលលទ្ធិ និងសេចក្តីសញ្ញា 20:37 និងសំនួរសម្ភាសន៍សំរាប់ពិធីបុណ្យជ្រមុជទឹក។

---

- អធិស្ឋានឱ្យបានញឹកញាប់ សំរាប់ខ្លួនឯង និងអ្នកដទៃ។
- ពឹងផ្អែកទៅលើព្រះវិញ្ញាណ ដើម្បីបង្ហាញអ្នកថាត្រូវទៅទីណា ត្រូវធ្វើអ្វី និងអ្វីដែលត្រូវនិយាយ។
- គោរពប្រតិបត្តិតាមដោយត្រឹមត្រូវ
- សិក្សាភាសាបេសកកម្មរបស់អ្នក រាល់ថ្ងៃ។

---

- ធ្វើផែនការណ៍រាល់ថ្ងៃ និងផ្តោតយកចិត្តទុកដាក់ លើសញ្ញាសំគាល់សំខាន់។
- ធ្វើការឱ្យមានប្រសិទ្ធិភាពពេញមួយថ្ងៃ រាល់ថ្ងៃ។

---

- សួររកមនុស្សថ្មីដែលត្រូវទៅជួប ពី***មនុស្សគ្រប់គ្នា*** !
- បង្រៀនពេលអ្នករកស្វែងរកឃើញ, ស្វែងរកឱ្យឃើញ ពេលអ្នកបង្រៀន។

---

- អានព្រះគម្ពីរមរមន ជាមួយមនុស្សទាំងឡាយដែលអ្នកបង្រៀន។
- បង្រៀនមនុស្សទាំងឡាយថា វិធីដ៏សំខាន់មួយដើម្បីដឹងថា យ៉ូសែហ្វ ស៊្មីធជាព្យាការី គឺត្រូវអាច និងអធិស្ឋានអំពី ព្រះគម្ពីរមរមន។
- ទាក់ទងសាសនាគន់ការីថ្មីជាប្រចាំថ្ងៃ។
- ថ្លែងទីបន្ទាល់ឱ្យបានញឹកញាប់។
- ឱ្យមានសមាជិកម្នាក់ចូលរួមដែរ រាល់ពេលបង្រៀនមេរៀន បើអាចធ្វើបាន។
- ចូរកំណត់កាលបរិច្ឆេទ និងពេលវេលា ជាក់លាក់ជានិច្ច សំរាប់មេរៀនបន្ទាប់។
- អញ្ជើញសាសនាគន់ការីទាំងអស់ ឱ្យចូលរួមក្នុងពិធីបុណ្យជ្រមុជទឹក។
- ក្រោយពីបង្រៀនមេរៀនទីមួយៗ ចូរផ្តល់ឱ្យសាសនាគន់ការីនូវ អ្វីមួយដើម្បីទុកអាន និងពិចារណា ក្នុងការរៀបចំ សំរាប់ការប្រជុំបន្ទាប់។

---

- សាងទំនាក់ទំនង ជាមួយសមាជិកដោយការបំរើពួកគេ និងការធ្វើការជាមួយថ្នាក់ដឹកនាំ នៅក្នុងវួដ។
- ជួយអ្នកដឹកនាំវួដ ជាមួយនឹងសកម្មនៃការរក្សាឱ្យគង្វង់ និងការធ្វើឱ្យសកម្ម។

---

- ជួយមនុស្សគ្រប់គ្នា ដែលអ្នកបង្រៀន ឱ្យធ្វើការតាំងចិត្ត ដែលនាំមកនូវការប្រែចិត្ត ហើយនឹងពង្រឹងសេចក្តីជំនឿ របស់ពួកគេ នៅក្នុងព្រះអង្គសង្គ្រោះ។
- ស្រលាញ់ព្រះអម្ចាស់ ហើយបំរើទ្រង់ ឱ្យអស់ពីសមត្ថភាពដែលអ្នកអាច ធ្វើបាន។

សាសនាចក្រនៃ

# ព្រះយេស៊ូវគ្រីស្ទ

នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ


CAMBODIAN

4 02366 17258 0

36617 258